# ព្រះ ត្រៃបិដក

## ប្រែរួមនឹង ព្រះអដ្ឋកថា

## ភាគ៦៥

បាលីប្រែ ៧៨ - ៧៩

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# អភិធម្មបិដក

## និង

# អដ្ឋសាលិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ធម្មសង្គណិ

# បឋម-ទុតិយភាគ

# ៦៥

# បាលីប្រែ ៧៨-៧៩



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៦៥

# ធម្មសង្គណិ បឋម-ទុតិយភាគ

*សូមនមស្ការព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## អកុសលបទ ធម្មុទ្ទេសវារ

## អកុសលចិត្តដួងទី ១

[ ២៧៥ ] *ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្តប្រកបដោយសោមនស្ស ប្រកបដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធនូវអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា មិច្ឆាទិដ្ឋិ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងដោយអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។*

[ ២៧៦ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សម្ផស្ស ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះ ផស្សៈកើតមានក្នុងសម័យនោះ ។

[ ២៧៧ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីស្រួលប្រព្រឹត្តទៅក្នុងចិត្តដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមាន ក្នុងសម័យនោះ ។

# អដ្ឋសាលិនី

# អដ្ឋកថា ធម្មសង្គណិ

# ចិត្តុប្បាទកណ្ឌ

## អកុសលបទ ធម្មុទ្ទេសវារ

## អកុសលចិត្តដួង ទី ១

[ ២៧៥-២៧៧ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីចែកអកុសលបទ ទើបទ្រង់ផ្ដើមព្រះតម្រាស់ថា **កតមេ ធម្មា អកុសលា** ដូច្នេះជាដើម ។

ក្នុងពាក្យថា អកុសលជាដើមទាំងនោះ គប្បីជ្រាបប្រភេទវារៈ មានការកំណត់ធម៌ជាដើម និងការវិនិច្ឆ័យសេចក្ដីនៃបទដែលមកហើយ ក្នុងខាងដើមដោយន័យដែលពោលហើយនុ៎ះឯង ។ ខ្ញុំនឹងពណ៌នាត្រឹមតែបទដែលផ្សេងគ្នាក្នុងទីនោះៗប៉ុណ្ណោះ ។ ក្នុងអធិការនៃអកុសលនោះ ក្នុងការកំណត់សម័យទ្រង់មិនបានត្រាស់អកុសលនេះ ដែលជាកាមាវចរៈពិតប្រាកដថាជាកាមាវចរៈ ព្រោះអកុសលមិនមានការផ្សេងគ្នានៃភូមិដូចកុសលមាន ។

ក្នុងបទនេះថា **ទិដ្ឋិគតសម្បយុត្តំ** ទិដ្ឋិគត គឺទិដ្ឋិ ដូចក្នុងប្រយោគជាដើមថា **គូថគតំ** ជាក់លាមក **មុត្តគតំ** ជាក់មូត្រ ដូច្នេះ ។ មួ៉ាងទៀតធម៌ដែលឈ្មោះថា **ទិដ្ឋិគត** ព្រោះអត្ថថា ទិដ្ឋិគតនេះត្រឹមតែជាការប្រព្រឹត្តទៅរបស់ទិដ្ឋិប៉ុណ្ណោះ ព្រោះមិនមានវត្ថុដែលគួរដឹង ឬព្រោះមិនមានវត្ថុដែល

គួរប្រព្រឹត្តទៅ ។ ដែលឈ្មោះថា **ទិដ្ឋិគតសម្បយុត្ត** ព្រោះអត្ថថា ប្រកប ដោយទិដ្ឋិនោះ ។

ក្នុងទិដ្ឋិគតសម្បយុត្តចិត្តនោះ បណ្ឌិតគប្បីជ្រាបការកើតឡើងនៃសេចក្តី យល់ខុស ពោលគឺទិដ្ឋិគតនេះ ដោយហេតុទាំងឡាយជាដើមយ៉ាងនេះ គឺ **អសទ្ធម្មសវនំ** ការស្តាប់អសទ្ធម្ម **អកល្យាណមិត្តតា** ភាពជាអ្នកមានមិត្ត អាក្រក់ **អរិយានំ អទស្សនកាមតាទីនិ** ភាពជាអ្នកមិនប្រាថ្នាឃើញព្រះ អរិយៈជាដើម **អយោនិសោ មនសិការោ** ការធ្វើទុកក្នុងចិត្តដោយឧបាយ មិនត្រូវទំនង ។

ពិតណាស់ ការយល់ខុសនោះ គប្បីជ្រាបថា រមែងកើតឡើងដោយ ការស្តាប់អសទ្ធម្ម ដែលប្រកបដោយវាទៈដែលខុស ដែលជាការស្តាប់ដែល មានមានៈច្រើននាំមុខ ដែលឈានកន្លងភាពជាកណ្តាល ដែលវៀរចាកការ ពិចារណាដោយភាពជាអ្នកមានកល្យាណមិត្ត ពោលគឺសេពគប់មិត្តអាក្រក់ ដែលមានទិដ្ឋិវិបត្តិដោយមិនប្រាថ្នាឃើញព្រះអរិយៈទាំងឡាយ មានព្រះពុទ្ធ ជាដើម និងសប្បុរសទាំងឡាយដោយភាពជាអ្នកមិនឈ្លាស ក្នុងអរិយធម៌ មានសតិប្បដ្ឋាន ៤ ជាដើម និងក្នុងសប្បុរិសធម៌ដោយការមិនមានវិន័យ ពោលគឺការបែកនៃសំវរៈក្នុងអរិយធម៌ មានបាតិមោក្ខសំវរៈ ឥន្ទ្រិយសំវរៈ សតិសំវរៈ ញាណសំវរៈ បហានសំវរៈ និងក្នុងសប្បុរិសធម៌ ដោយការធ្វើ ទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង ដែលខ្ជួនអប់រំហើយ ដោយហេតុទាំង នោះឯង និងព្រោះភាពជាអ្នកខ្វល់ខ្វាយក្នុងមង្គលភ្ញាក់ផ្អើលជាដើម ។ គប្បី

*ជ្រាបថា ចិត្តនេះជាអសង្ខារ ( មិនមានការបបួលដឹកនាំ ) ដោយន័យដែលពោលហើយក្នុងខាងដើមនុ៎ះឯង ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងវារៈនៃធម្មុទ្ទេស ( មាតិកាធម៌ ) ដូចតទៅនេះថា*

*បទថា* **ផស្សោ** *បានដល់ ផស្សៈដែលកើតព្រមជាមួយអកុសលចិត្ត ។ ក្នុងធម៌មានវេទនាជាដើម ក៏ន័យនេះឯង ។ ធម៌មានផស្សៈជាដើមទាំងនេះ ផ្សេងអំពីធម៌ដែលសម្តែងទុកក្នុងកាលមុនត្រឹមតែជាអកុសលប៉ុណ្ណោះ ដោយប្រការដូច្នេះ ។*

*បទថា* **ចិត្តស្សេកគ្គតា ហោតិ** *សេចក្តីថា ឯកគ្គតានៃចិត្ត ( សមាធិចិត្ត ) រមែងមាន ព្រោះចិត្តមិនរាយមាយ ក្នុងខណៈធ្វើបាណាតិបាតជាដើម ។ ពិតមែន មនុស្សទាំងឡាយតាំងចិត្តទុកមាំមិនរាយមាយទើបញុំាងសស្ត្រាឲ្យធ្លាក់ទៅក្នុងសរីរៈរបស់សត្វទាំងឡាយ មិនឲ្យខុស ជាអ្នកមានចិត្តតាំងមាំហើយ រមែងនាំវត្ថុដែលជារបស់មាននៃជនដទៃទៅ មានចិត្តត្រេកអរក្នុងរឿងមួយរមែងប្រព្រឹត្តមិច្ឆាចារ ។ ឯកគ្គតានៃចិត្តរមែងមាន ព្រោះប្រព្រឹត្តអកុសល ដោយប្រការដូច្នេះ ។*

*បទថា* **មិច្ឆាទិដ្ឋិ** *បានដល់ ការយល់ឃើញដែលមិនពិត ម្យ៉ាងទៀត ឈ្មោះថា មិច្ឆាទិដ្ឋិ ព្រោះអត្ថថា យល់ខុសឃ្លៀងឃ្លាតដោយកាន់យកខុស ។ ឈ្មោះថា* **មិច្ឆាទិដ្ឋិ** *ព្រោះអត្ថថា ជាទិដ្ឋិដែលបណ្ឌិតគួរស្អប់ខ្ពើម ព្រោះនាំមកតែសេចក្តីវិនាស ។ សូម្បីក្នុងមិច្ឆាសង្កប្បជាដើម ក៏ន័យនេះឯង ។ ម្យ៉ាងទៀត ឈ្មោះថា* **មិច្ឆាទិដ្ឋិ** *ព្រោះអត្ថថា ជាហេតុឲ្យមនុស្សយល់ឃើញ*

ខុស ឬយល់ឃើញខុសឯង ឬទិដ្ឋិនេះត្រឹមតែយល់ឃើញខុសប៉ុណ្ណោះ ។

មិច្ឆាទិដ្ឋិនោះ **អយោនិសោ អភិនិវេសលក្ខណា** មានការប្រកាន់មាំដោយឧបាយមិនត្រូវទំនងជាលក្ខណៈ **បរាមាសរសា** មានសេចក្តីប្រកាន់មាំខុសបាកសភាវៈជាកិច្ច **មិច្ឆាភិនិវេសនបច្ចុប្បដ្ឋានា** មានការប្រកាន់មាំខុសជាអាការប្រាកដ **អរិយានំ អទស្សនកាមតាទិបទដ្ឋានា** មានការមិនប្រាថ្នាឃើញព្រះអរិយៈទាំងឡាយជាដើម ជាហេតុជិត គប្បីឃើញថា ជាទោសយ៉ាងក្រៃលែង ។ សូម្បីក្នុងមិច្ឆាសង្កប្បជាដើម មានសេចក្តីផ្សេងគ្នាត្រឹមតែបទថា **មិច្ឆា** ប៉ុណ្ណោះ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលក្នុងអធិការនៃកុសលទុំ៖ឯង ។

សេចក្តីនៃ ពល សព្ទ ក្នុងបទនេះថា **អហិរិកពលំ អនោត្តប្បពលំ** នេះ នឹងជាក់ច្បាស់ក្នុងនិទ្ទេសវារៈ ចំណែកក្នុងសព្ទក្រៅអំពីនេះមានវិគ្គហៈដូចតទៅនេះថា បុគ្គលឈ្មោះថា អហិរិកៈ ព្រោះអត្ថថា មិនខ្មាស ។ ភាវៈនៃបុគ្គលអ្នកមិនខ្មាស ឈ្មោះថា អហិរិកៈ ។ សភាវធម៌ ដែលមិនក្រែងខ្លាចបាប ឈ្មោះថា អនោត្តប្បៈ ។ ក្នុងធម៌ទាំងពីរនោះ អហិរិកៈ **កាយ-ទុច្ចរិតាទីហិ អជិគុច្ឆនលក្ខណំ** មានការមិនខ្ពើមកាយទុច្ចរិតជាដើម ជាលក្ខណៈ **អលជ្ជនលក្ខណំ វា** ឬមានការមិនខ្មាសកាយទុច្ចរិតជាដើមជាលក្ខណៈ ។ អនោត្តប្បៈ **តេហេវ អសារជ្ជលក្ខណំ** មានការមិនខ្លាច-កាយទុច្ចរិតជាដើមទាំងនោះឯងជាលក្ខណៈ **អនុត្តាសនលក្ខណំ វា** ឬមានការមិនតក់ស្លុតចំពោះកាយទុច្ចរិតជាដើមទាំងនោះឯងជាលក្ខណៈ ។ កម្លាំង

គឺការមិនខ្មាសបាប ឈ្មោះថា **អហិរិកពល** ។ កម្លាំង គឺការមិនខ្លាចបាប ឈ្មោះថា **អនោត្តប្បពល** ។ សេចក្តីសង្ខេបក្នុងអធិការនៃអកុសលនេះមានប្រមាណប៉ុណ្ណេះ ។ ចំណែកសេចក្តីពិស្តារ គប្បីជ្រាបដោយអំណាចភាពជាបដិបក្ខគ្នាតាមដែលពោលក្នុងខាងដើមនុ៎ះឯង ។

សភាវធម៌ ដែលឈ្មោះថា **លោភោ** ព្រោះអត្ថថា ជាហេតុឲ្យមនុស្សចង់បាន ឬចង់បានឯង ឬត្រឹមតែជាការចង់បានប៉ុណ្ណោះ ។ ដែលឈ្មោះថា **មោហោ** ព្រោះអត្ថថា ជាហេតុឲ្យមនុស្សវង្វេង ឬវង្វេងឯង ឬត្រឹមតែជាការវង្វេងប៉ុណ្ណោះ ។ បណ្តាសភាវៈទាំងពីរនោះ លោភៈ **អារម្មណគ្គហណលក្ខណោ** មានការប្រកាន់អារម្មណ៍ ជាលក្ខណៈ ដូចស្វាជាប់ជ័រ **អភិសង្គរសោ** មានការជាប់ក្នុងអារម្មណ៍ ជាកិច្ច ដូចដុំសាច់ដែលដាក់លើអំបែងក្តៅ **អបរិចាគបច្ចុបដ្ឋានោ** មានការមិនលះបង់ជាអាការប្រាកដ ដូចប្រឡាក់ដោយប្រេងនិងថ្នាំបន្តក់ភ្នែក **សញ្ញោជនិយធម្មេសុ អស្សាទទស្សនបទដ្ឋានោ** មានការឃើញថា គួរត្រេកអរក្នុងធម៌ ដែលជាអារម្មណ៍របស់សំយោជនៈ ជាហេតុជិត ។ លោភៈនោះ កាលចម្រើនឡើងដោយភាពជាស្ទឹង គឺតណ្ហា គប្បីជ្រាបថា រមែងនាំទៅកាន់អបាយប៉ុណ្ណោះ ដូចស្ទឹងមានក្រសែទឹកហូរត្របាញ់ រមែងហូរនាំទៅកាន់មហាសមុទ្ទ ដូច្នោះ ។

មោហៈ **ចិត្តស្ស អន្ធភាវលក្ខណោ** មានសេចក្តីងងឹតនៃចិត្តជាលក្ខណៈ **អញ្ញាណលក្ខណោ វា** ឬមានការមិនដឹងជាលក្ខណៈ **អសម្បដិវេធរសោ** មានការមិនចាក់ធ្លុះ ជាកិច្ច **អារម្មណសភាវច្ឆាទនរសោ វា**

ឬមានការបិទបាំងសភាវៈនៃអារម្មណ៍ ជាកិច្ច **អសម្មាបដិបត្តិបច្ចុបដ្ឋានោ** មានការមិនបដិបត្តិដោយប្រពៃ ជាអាការប្រាកដ **អន្ធការបច្ចុបដ្ឋានោ វា** ឬមានសេចក្ដីងងឹតជាអាការប្រាកដ **អយោនិសោមនសិការបទដ្ឋានោ** មានការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនង ជាហេតុជិត ។ គប្បីជ្រាបថាជាឫសគល់នៃអកុសលធម៌ទាំងពួង ។

សភាវធម៌ដែលឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា ជាហេតុឲ្យមនុស្សសម្លឹង ឬសម្លឹងឯង ឬធម៌នេះត្រឹមតែជាការសម្លឹងប៉ុណ្ណោះ ។ អភិជ្ឈានោះ **បរសម្បត្តីនំ សកករណឥច្ឆាលក្ខណា** មានសេចក្ដីប្រាថ្នាធ្វើសម្បត្តិរបស់អ្នកដទៃឲ្យជារបស់ខ្លួនជាលក្ខណៈ **តេនាការេន បសង្គភាវរសា** មានការជាប់ចំពាក់ដោយអាការៈយ៉ាងនោះ ជាកិច្ច **បរសម្បត្តិអភិមុខភាវបច្ចុ-បដ្ឋានា** មានការបែរមុខទៅរកសម្បត្តិរបស់អ្នកដទៃជាអាការប្រាកដ **បរ-សម្បត្តីសុ អភិរតិបទដ្ឋានា** មានសេចក្ដីត្រេកអរក្រៃលែងក្នុងសម្បត្តិរបស់អ្នកដទៃជាហេតុជិត ។ មែនពិត អភិជ្ឈានោះរមែងប្រាកដឆ្ពោះមុខតែសម្បត្តិរបស់អ្នកដទៃប៉ុណ្ណោះ កាលសេចក្ដីត្រេកអរក្រៃលែងមាននៅ អភិជ្ឈានោះក៏រមែងប្រព្រឹត្តទៅក្នុងសម្បត្តិរបស់អ្នកដទៃទាំងនោះ គប្បីជ្រាបថា ដូចចិត្តលាដៃទៅក្នុងសម្បត្តិរបស់អ្នកដទៃ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សមថោ ហោតិ** ជាដើមដូចតទៅនេះថា

សភាវធម៌ដែលឈ្មោះថា **សមថ** ព្រោះស្ងប់ការរាយមាយក្នុងកិច្ចដទៃៗ ឈ្មោះថា **បគ្គាហោ** ព្រោះផ្គងចិត្តឲ្យប្រព្រឹត្តទៅក្នុងអកុសល ។ ឈ្មោះថា

**អវិក្ខេបោ** ព្រោះមិនរាយមាយទៅ ។ ក្នុងអកុសលចិត្តនេះ មិនកាន់យកធម៌ទាំងនេះ គឺសទ្ធា សតិ បញ្ញានិងធម៌ ៦ គូ ។ ព្រោះហេតុអ្វី ព្រោះឈ្មោះថា ការជ្រះថ្លា រមែងមិនមានក្នុងចិត្តដែលមិនជាទីតាំងនៃសទ្ធា ព្រោះហេតុនោះ ទើបខាងដើម ទ្រង់មិនកាន់យកសទ្ធា ។ សួរថា ជនមានទិដ្ឋិទាំងឡាយ មិនជឿសាស្តារបស់ខ្លួនឬ ឆ្លើយថា ជឿ ។ តែការជឿនោះ មិនឈ្មោះថា សទ្ធា ពាក្យថា ជឿនេះត្រឹមតែជាការទទួលពាក្យប៉ុណ្ណោះ ពោលដោយអត្ថ ជំនឿនោះរមែងជាជំនឿដែលប្រាសចាកការពិចារណាខ្លះ ជាមិច្ឆាទិដ្ឋិខ្លះ ។

មួយទៀត សតិរមែងមិនមានក្នុងចិត្ត ដែលមិនជាទីតាំងនៃសតិ ព្រោះហេតុនោះ ទើបព្រះអង្គមិនកាន់យក ។ សួរថា ជនទាំងឡាយដែលមានមិច្ឆាទិដ្ឋិ មិនរឭកដល់ការងារដែលខ្លួនធ្វើខ្លះទេឬ ។ ឆ្លើយថា រឭកបាន តែការរឭកនោះមិនឈ្មោះថាជាសតិ ។ អកុសលចិត្ត រមែងប្រព្រឹត្តទៅដោយអាការរឭកនោះតែម្យ៉ាង ព្រោះហេតុនោះទើបទ្រង់មិនកាន់យកសតិ ។ សួរថា កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ក្នុងព្រះសូត្រទើបត្រាស់ថា មិច្ឆាសតិ ឆ្លើយថា ដើម្បីទ្រង់ញ៉ាំងមិច្ឆត្តនៃមិច្ឆាមគ្គឲ្យបរិបូណ៌ ព្រោះអកុសលក្ខន្ធទាំងឡាយ ជាសភាវៈវៀរចាកសតិនិងជាបដិបក្ខចំពោះសតិ ទើបទ្រង់ធ្វើទេសនាមិច្ឆាសតិ ទុកក្នុងព្រះសូត្រនោះដោយអម តែមិច្ឆាសតិនោះពោលដោយត្រង់មិនមាន ព្រោះហេតុនោះទើបទ្រង់មិនកាន់យក ។

ម្យ៉ាងទៀត បញ្ញារមែងមិនមានក្នុងចិត្តរបស់អន្ធពាល ព្រោះហេតុនោះ

ទើបទ្រង់មិនកាន់យក ។ សួរថា បញ្ញា ជាគ្រឿងបោកបញ្ឆោតរបស់បុគ្គល ដែលជាមិច្ឆាទិដ្ឋិ មិនមានឬ ឆ្លើយថា មាន តែចំណេះដឹងជាគ្រឿងបោកបញ្ឆោតនោះ មិនឈ្មោះថាបញ្ញា ចំណេះដឹងនោះឈ្មោះថាជាមាយា ពោលដោយអត្ថ មាយានោះ ក៏គឺតណ្ហានុ៎ះឯង ។

ព្រោះចិត្តនេះ ជាចិត្តក្រវល់ក្រវាយ ធ្ងន់ គ្រោតគ្រាត រឹង រឹងត្អឹង មិនគួរដល់ការងារ ឈឺ វៀច កោង ព្រោះហេតុនោះទើបធម៌ ៦ គូ មានបស្សទ្ធិជាដើម ព្រះអង្គមិនកាន់យក ។

ព្រះមានព្រះភាគ កាលទ្រង់សម្តែងបទ ៣២ ដែលឡើងកាន់ព្រះបាលីដោយអំណាចអង្គនៃចិត្ត ដោយលំដាប់បទត្រឹមតែប៉ុណ្ណោះហើយ ឥឡូវនេះដើម្បីទ្រង់សម្តែងយេវាបនកធម៌ ទើបត្រាស់ព្រះពុទ្ធវចនៈជាដើមថា **យេ វា បន តស្មឹ សមយេ** ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យជាដើមថា យេវាបនកធម៌នោះ ដូចតទៅនេះថា

ក្នុងអកុសលចិត្តទាំងអស់ មានយេវាបនកធម៌ ១០ នេះប៉ុណ្ណោះ គឺឆន្ទៈ អធិមោក្ខ មនសិការ មានៈ ឥស្សា មច្ឆរិយៈ ថីនៈ មិទ្ធៈ ឧទ្ធច្ចៈ កុក្កុច្ចៈ ធម៌ទាំងឡាយលោកពោលថា មានមកក្នុងព្រះសូត្រ រមែងប្រាកដក្នុងបទនៃព្រះសូត្រ ។ ចំណែកក្នុងអកុសលចិត្តនេះ មានយេវាបនកធម៌ ៤ ប្រការពោលគឺជាអង្គដែលពិតប្រាកដទាំងនេះ គឺឆន្ទៈ អធិមោក្ខ មនសិការ ឧទ្ធច្ចៈ ។

បណ្តាយេវាបនកធម៌ទាំងនោះ ធម៌មានឆន្ទៈជាដើម គប្បីជ្រាបដោយ

ន័យដែលពោលហើយក្នុងខាងដើមនុ៎ះឯង ។ ធម៌មានឆន្ទៈជាដើម ( ឆន្ទៈ អធិមោក្ខ មនសិការ តត្រមជ្ឈត្តតា ) ជាកុសលតែម្យ៉ាង ធម៌មានឆន្ទៈជាដើម ( ឆន្ទៈ អធិមោក្ខ មនសិការ ឧទ្ធច្ចៈ ) ទាំងនេះ ជាអកុសល ។ ចំណែកឧទ្ធច្ចៈក្រៅអំពីនេះ ភាពដែលចិត្តរាយមាយ ឈ្មោះថា ឧទ្ធច្ចៈ ។

ឧទ្ធច្ចៈនោះ **អវូបសមលក្ខណំ** មានការមិនចូលទៅស្ងប់ ជាលក្ខណៈ ដូចទឹករញ្ជួយព្រោះខ្យល់បក់ **អនវដ្ឋានរសំ** មានការមិនតម្កល់មាំ ជាកិច្ច ដូចទង់ជ័យនិងទង់ជ្វាលាបក់ទៅមកព្រោះខ្យល់ **ភន្តត្តបច្ចុបដ្ឋានំ** មានការវេទៅមកជាអាការប្រាកដ ដូចផេះហុយឡើង ព្រោះដុំថ្មដែលគប់ **ចេតសោ អវូបសមេ អយោនិសោមនសិការបទដ្ឋានំ** មានការធ្វើទុកក្នុងចិត្តខុសទំនង ព្រោះចិត្តមិនស្ងប់ជាហេតុជិត ឧទ្ធច្ចៈនោះ គប្បីជ្រាបថា ជាការរាយមាយនៃចិត្ត ។

ដោយប្រការដូច្នេះ បទធម៌ ៣២ មានផស្សៈជាដើម ( មានអវិក្ខេបៈជាទីបំផុត ) និងបទធម៌ ៤ មានឆន្ទៈជាដើម ដែលត្រាស់ដោយអំណាចយេវាបនកធម៌ រួមទាំងអស់ ជាបទធម៌ ៣៦ ក្នុងវារៈនៃធម្មុទ្ទេសនេះ ។ បទធម៌ដែលមកក្នុងបាលីទាំងនោះ បន្ថយបទធម៌ ដែលជាយេវាបនកធម៌ដែលពិតប្រាកដ ៤ យ៉ាងចេញហើយក៏សល់តែ ៣២ ប៉ុណ្ណោះ ។ តែក្នុងឧទ្ទេសនៃអកុសលនេះ ព្រោះកាន់យកធម៌ដែលមិនត្រួតគ្នា ទើបជាធម៌ ១៦ បទ គឺពួកធម៌ ៥ មានផស្សៈជាដើម វិតក្ក ១ វិចារ ១ បីតិ ១ ឯកគ្គតានៃចិត្ត ១ វីរិយិន្ទ្រិយ ១ ជីវិតិន្ទ្រិយ ១ មិច្ឆាទិដ្ឋិ ១ លោភៈ ១ មោហៈ ១

អហិរិកៈ ១ អនោត្តប្បៈ ១ ។

បណ្ដាធម៌ទាំង ១៦ នោះ ធម៌ ៧ ចែកមិនបាន ធម៌ ៩ ចែកបាន ធម៌ ៧ ដែលចែកមិនបាន តើដូចម្ដេច ធម៌ដែលចែកមិនបានទាំងនេះ គឺផស្សៈ សញ្ញា ចេតនា វិចារ បីតិ ជីវិតិន្ទ្រិយ មោហៈ ។ ចំណែកធម៌ដែលចែកបានទាំង ៩ នេះគឺ វេទនា ចិត្ត វិតក្ក ឯកគ្គតានៃចិត្ត វីរិយិន្ទ្រិយ មិច្ឆាទិដ្ឋិ អហិរិក អនោត្តប្ប លោភៈ ។

បណ្ដាធម៌ទាំង ១៦ យ៉ាងនោះ ធម៌ ៦ យ៉ាង ចែកបាន ២ ឋាន ធម៌មួយចែកបាន ៣ ឋាន ធម៌មួយចែកបាន ៤ ឋាន និងធម៌មួយចែកបាន ៦ ឋាន ។ សួរថា តើចែកដូចម្ដេច ធម៌ទាំង ៦ យ៉ាងនេះ គឺចិត្ត វិតក្ក មិច្ឆាទិដ្ឋិ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ ចែកបាន ២ ឋាន ។ មែនពិត បណ្ដាធម៌ទាំង ៦ នោះ ពោលដល់ចិត្តមុន សម្ដៅដល់ផស្សបញ្ចកៈ ហៅថាចិត្ត សម្ដៅដល់ឥន្ទ្រិយ ហៅថាមនិន្ទ្រិយ ។ វិតក្ក សម្ដៅដល់អង្គឈានទាំងឡាយ ហៅថាវិតក្ក សម្ដៅដល់អង្គមគ្គទាំងឡាយ ហៅថាមិច្ឆាសង្កប្ប ។ មិច្ឆាទិដ្ឋិ ក៏ជាមិច្ឆាទិដ្ឋិដូចគ្នា ទាំងក្នុងអង្គមគ្គ ទាំងក្នុងកម្មបថ ។ អហិរិកៈ សម្ដៅដល់ពលៈទាំងឡាយ ហៅថា អហិរិកពលៈ សម្ដៅដល់ពួកពីរ នៃធម៌ជាគ្រឿងញុំាងលោកឲ្យវិនាស ហៅថា អហិរិកៈ សូម្បីក្នុងអនោត្តប្បៈក៏ន័យនេះឯង ។ លោភៈសម្ដៅដល់មូល ហៅថាលោភៈ សម្ដៅដល់កម្មបថ ហៅថា អភិជ្ឈា ។ ធម៌ទាំង ៦ យ៉ាងនេះ ចែកបាន ២ ឋាន ។

ចំណែកវេទនាសម្ងឹងដល់ផស្សបញ្ចកៈ ហៅថាវេទនា សម្ងឹងដល់អង្គឈានទាំងឡាយ ហៅថាសុខ សម្ងឹងដល់ឥន្ទ្រិយទាំងឡាយ ហៅថាសោមនស្សិន្ទ្រិយ ធម៌មួយចែកបាន ៣ ឋាន ដោយប្រការដូច្នេះ ។

វីរិយៈសម្ងឹងដល់ឥន្ទ្រិយទាំងឡាយ ហៅថាវីរិយិន្ទ្រិយ សម្ងឹងដល់អង្គមគ្គទាំងឡាយ ហៅថាមិច្ឆាវាយាមៈ សម្ងឹងដល់ពលៈ ហៅថាវីរិយពលៈ សម្ងឹងដល់បិដ្ឋិទុកៈ ហៅថាបគ្គាហ ធម៌មួយចែកបាន ៤ ឋានដោយប្រការដូច្នេះ ។

សមាធិ សម្ងឹងដល់អង្គឈានទាំងឡាយ ហៅថាឯកគ្គតានៃចិត្ត សម្ងឹងដល់ឥន្ទ្រិយ ហៅថាសមាធិន្ទ្រិយ សម្ងឹងដល់អង្គមគ្គទាំងឡាយ ហៅថាមិច្ឆាសមាធិ សម្ងឹងដល់ពលៈទាំងឡាយ ហៅថាសមាធិពលៈ សម្ងឹងដល់បិដ្ឋិទុកៈ ហៅថាសមថដោយអំណាចនៃធម៌ចំណែកមួយក្នុងទុតិយទុកៈ ហៅថាអវិក្ខេបក្នុងតតិយទុកៈ ។ ធម៌មួយចែកបាន ៦ ឋាន ដោយប្រការដូច្នេះ ។

ធម៌សូម្បីទាំងអស់នេះ ចាត់ជា ៩ កង គឺផស្សបញ្ចកៈ ១ អង្គឈាន ១ ឥន្ទ្រិយ ១ អង្គមគ្គ ១ ពលៈ ១ មូល ១ កម្មបថ ១ លោកនាសកធម៌ ១ បិដ្ឋិទុកៈ ១ ។

បណ្តាធម៌ទាំង ៩ កងនោះ ពាក្យណាដែលខ្ញុំគប្បីពោល ពាក្យនោះខ្ញុំពោលទុកក្នុងនិទ្ទេសនៃកុសលចិត្តដួងទីមួយហើយទុំះឯង ។

**ធម្មុទ្ទេសវារៈ ចប់**

# អភិធម្មបិដក

## ធម្មសង្គណី

[ ២៧៨ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សញ្ញា សេចក្ដីសម្គាល់ សេចក្ដីចាំបាន ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះសញ្ញាកើតមានក្នុងសម័យនោះ ។

[ ២៧៩ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ចេតនា សេចក្ដីរិះគិត ការតាក់តែងដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះចេតនាកើតមានក្នុងសម័យនោះ ។

[ ២៨០ ] ចិត្តកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះចិត្តកើតមានក្នុងសម័យនោះ ។

[ ២៨១ ] វិតក្កៈកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើង គឺមិច្ឆាសង្កប្បៈណា ក្នុងសម័យនោះ នេះវិតក្កៈកើតមានក្នុងសម័យនោះ ។

[ ២៨២ ] វិចារៈកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការសម្រឹងនៃចិត្ត ការសម្លឹងមើលណា ក្នុងសម័យនោះ នេះវិចារៈកើតមានក្នុងសម័យនោះ ។

[ ២៨៣ ] បីតិកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្អែតចិត្ត សេចក្តីរីករាយ សេចក្តីសប្បាយ សេចក្តីស្រួល សេចក្តីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ ការអណ្តែតអណ្តូង សេចក្តីត្រេកអរ របស់ចិត្តណា ក្នុងសម័យនោះ នេះបីតិកើតមានក្នុងសម័យនោះ ។

[ ២៨៤ ] សុខកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសុខកើតមានក្នុងសម័យនោះ ។

[ ២៨៥ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតម្កល់នៅនឹង ការតាំងមាំ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង ការស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ មិច្ឆាសមាធិណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ២៨៦ ] វីរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សង្ហាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាត សេចក្តីសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងនូវធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ មិច្ឆាវាយាមៈណា ក្នុងសម័យនោះ នេះវីរិយិន្ទ្រិយ

កើតមានក្នុងសម័យនោះ ។

[ ២៨៧ ] សមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ មិច្ឆាសមាធិណារបស់ចិត្ត ក្នុងសម័យនោះ នេះសមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២៨៨ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតផូរផង់ គឺកវគ្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញា-ណធាតុដ៏សមគួរដល់ផស្សៈជាដើមនោះ ណាក្នុងសម័យនោះ នេះមនិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ២៨៩ ] សោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសោមនស្សិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ២៩០ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា ក្នុងសម័យនោះ នេះ

ជីវិតិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ២៩១ ] មិច្ឆាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីយល់ សេចក្តីឃើញ សេចក្តីសាំញ៉ាំគឺទិដ្ឋិ កន្តារៈគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីសុះស្មាគឺទិដ្ឋិ ធម្មជាតិជាគ្រឿងប្រកបព្រម គឺទិដ្ឋិ ការចាប់ប្រកាន់ ការប្រកាន់មាំ ការតាំងមាំ ការស្ទាបអង្អែល ផ្លូវអាក្រក់ គន្លងខុស សេចក្តីខុស ធម្មជាតិជាកំណើតនៃសេចក្តីវិនាស គឺលទ្ធិដូចកំពង់សម្រាប់ចូង ការប្រកាន់ព្រោះស្វែងរកខុសណា ក្នុងសម័យនោះ នេះមិច្ឆាទិដ្ឋិកើតមាន ក្នុងសម័យនោះ ។

[ ២៩២ ] មិច្ឆាសង្កប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើង គឺមិច្ឆាសង្កប្បៈណា ក្នុងសម័យនោះ នេះមិច្ឆាសង្កប្បៈកើតមានក្នុងសម័យនោះ ។

[ ២៩៣ ] មិច្ឆាវាយាមៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឧហាត សង្វាត ខិតខំព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាត ការសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ មិច្ឆាវាយាមៈណា ក្នុងសម័យនោះ នេះមិច្ឆាវាយាមៈកើតមានក្នុងសម័យនោះ ។

[ ២៩៤ ] មិច្ឆាសមាធិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការ

ឋិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ មិច្ឆាសមាធិណា ក្នុងសម័យនោះ នេះមិច្ឆាសមាធិកើតមានក្នុងសម័យនោះ ។

[ ២៩៥ ] វីរិយពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីខិហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាត សេចក្តីសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងនូវធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈ មិច្ឆាវាយាមៈណា ក្នុងសម័យនោះ នេះវីរិយពលៈកើតមានក្នុងសម័យនោះ ។

[ ២៩៦ ] សមាធិពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ មិច្ឆាសមាធិណា ក្នុងសម័យនោះ នេះសមាធិពលៈកើតមានក្នុងសម័យនោះ ។

[ ២៩៧ ] អហិរិកពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនខ្មាសដោយអំពើទុច្ចរិតដែលគួរខ្មាស មិនខ្មាសដោយការចូលប្រទះនូវពួកអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះអហិរិកពលៈកើតមានក្នុងសម័យនោះ ។

[ ២៩៨ ] អនោត្តប្បពលៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនតក់ស្លុតដោយអំពើទុច្ចរិតដែលគួរតក់ស្លុត មិនតក់ស្លុតដោយការជួបប្រទះនូវពួកអកុសលធម៌ដ៏លាមកក្នុងសម័យនោះ នេះអនោត្តប្បពលៈកើតមានក្នុងសម័យនោះ ។

[ ២៩៩ ] លោភៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការចង់បាន ការជាប់ចំពាក់ សេចក្តីជាប់ចំពាក់ តម្រេកខ្លាំង ត្រេកត្រអាល សេចក្តីត្រេកត្រអាល ការសម្លឹងរំពៃ គឺលោភៈជាអកុសលមូលណា ក្នុងសម័យនោះ នេះលោភៈកើតមានក្នុងសម័យនោះ ។

[ ៣០០ ] មោហៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនដឹង មិនឃើញ ការមិនដល់ព្រមចំពោះការមិនត្រាស់ដឹងនូវធម៌តាមសមគួរ ការមិនដឹងធម៌ដ៏ស្ងប់ ការមិនចាក់ធ្លុះចំពោះការមិនកាន់យក ការមិនចុះចិត្ត ការមិនឃើញស្មើ ការមិនពិចារណា ការមិនធ្វើឲ្យជាក់ច្បាស់ ការយល់ខុស សេចក្តីល្ងង់ សេចក្តីមិនដឹងខ្លួន សេចក្តីវង្វេង សេចក្តីវង្វេងខ្លាំង សេចក្តីវង្វេងសព្វ សេចក្តីមិនដឹងច្បាស់ អន្ទង់គឺអវិជ្ជា គ្រឿងប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា សេចក្តីគ្របសង្កត់គឺអវិជ្ជា គន្លឹះគឺអវិជ្ជា គឺមោហៈជាអកុសលមូលណាក្នុងសម័យនោះ នេះមោហៈកើតមានក្នុងសម័យនោះ ។

[ ៣០១ ] អភិជ្ឈា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីចង់បាន ការជាប់ចំពាក់ ភាពជាប់ចំពាក់ តម្រេកខ្លាំង ការត្រេកត្រអាល

ភាពត្រេកត្រអាល គឺអភិជ្ឈា លោភៈជាអកុសលមូលណា ក្នុងសម័យនោះ នេះអភិជ្ឈា កើតមានក្នុងសម័យនោះ ។

[ ៣០២ ] មិច្ឆាទិដ្ឋិ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីយល់ សេចក្តីឃើញសាំញ៉ាំ គឺទិដ្ឋិ កន្តារៈគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ សេចក្តីស្ទុះស្ទាគឺទិដ្ឋិ ធម្មជាតិជាគ្រឿងប្រកបគឺទិដ្ឋិ ការចាប់ប្រកាន់ ការប្រកាន់មាំ ការតាំងមាំ ការស្ទាបអង្អែល ផ្លូវអាក្រក់ គន្លងខុស សេចក្តីខុស ធម្មជាតិជាកំណើតនៃសេចក្តីវិនាស លទ្ធិដូចជាកំពង់សម្រាប់ឆ្លង ការប្រកាន់ព្រោះស្វែងរកខុសណា ក្នុងសម័យនោះ នេះមិច្ឆាទិដ្ឋិកើតមានក្នុងសម័យនោះ ។

[ ៣០៣ ] អហិរិកៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនខ្មាសដោយអំពើទុច្ចរិតដែលគួរខ្មាស មិនខ្មាសដោយការជួបប្រទះនូវពួកអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះអហិរិកៈកើតមាន ក្នុងសម័យនោះ ។

[ ៣០៤ ] អនោត្តប្បៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនតក់ស្លុតដោយអំពើទុច្ចរិតដែលគួរតក់ស្លុត មិនតក់ស្លុតដោយការជួបប្រទះនូវពួកអកុសលធម៌ដ៏លាមក ក្នុងសម័យនោះ នេះអនោត្តប្បៈកើតមានក្នុងសម័យនោះ ។

[ ៣០៥ ] សមថៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅការតម្កល់នៅនឹង ការតាំងនៅស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយភាពនៃចិត្តមិនឃ្លេងឃ្លោង គឺសមថៈ សមាធិន្ទ្រិយ សមាធិពលៈ មិច្ឆា-

សមាធិណារបស់ចិត្តក្នុងសម័យនោះ នេះសមថៈកើតមានក្នុងសម័យនោះ ។

[ ៣០៦ ] ការផ្គងឡើងកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាមប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីឱហាត សង្វាត ខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាត សេចក្តីសង្វាតមិនធូរថយ ការមិនដាក់ចុះនូវសេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ ការផ្គងនូវធុរៈគឺវិរិយ វិរិយិន្ទ្រិយ វិរិយពលៈ មិច្ឆាវាយាមៈណា ក្នុងសម័យនោះ នេះការផ្គងឡើងកើតមានក្នុងសម័យនោះ ។

[ ៣០៧ ] ការមិនរាយមាយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតម្កល់នៅនឹង ការតម្កល់ស៊ប់ ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈ មិច្ឆាសមាធិណារបស់ចិត្ត ក្នុងសម័យនោះ នេះការមិនរាយ-មាយកើតមានក្នុងសម័យនោះ ។

[ ៣០៨ ] ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣០៩ ] ខន្ធ ៤ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ឈានប្រកបដោយអង្គ ៥ មគ្គប្រកបដោយអង្គ ៤ ពលៈ ៤ ហេតុ ២ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣១០ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ បីតិ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា មិច្ឆាទិដ្ឋិ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈឬក៏ពួកអរូបធម៌ ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើក ទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុង សម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។

# អដ្ឋកថា

# និទ្ទេសវារៈ

[ ២៧៨-៣១០ ] គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសឯកគ្គតានៃចិត្តក្នុងនិទ្ទេសវារៈ មុន

ពីរបទនេះ ដែលត្រាស់ថា **សណ្ឋិតិ** ( ការតម្កល់នៅនឹង ) **អវដ្ឋិតិ** ( ការតាំងមាំ ) ជាពាក្យវេវចនៈរបស់បទថា **ឋិតិ** ( ការឋិតនៅ ) ទុំះឯង ចំណែកពាក្យណាដែលពោលទុកក្នុងនិទ្ទេសនៃកុសលថា ឈ្មោះថា **អវដ្ឋិតិ** ព្រោះអត្ថថា ឈមចុះកាន់អារម្មណ៍ គឺចូលទៅហើយតាំងនៅ ពាក្យនោះមិនមានក្នុងនិទ្ទេសនៃអកុសលនេះ ព្រោះថា ក្នុងអកុសល ឯកគ្គតានៃចិត្តមានកម្លាំងខ្សោយ ពាក្យនេះខ្ញុំសម្ដែងទុកហើយខាងដើមនោះឯង ។ ពីរបទនេះដូច្នេះ ។

ធម៌ដែលឈ្មោះថា **អវិសាហារោ** ( ការមិនឃ្លេងឃ្លោង ) ព្រោះជាសភាពបដិបក្ខនឹងសេចក្ដីរាយមាយ ដែលប្រព្រឹត្តទៅដោយអំណាចឧទ្ធច្ចៈនិងវិចិកិច្ឆា ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃអកុសលនេះ ទើបមិនបានអត្ថ សូម្បីដូច្នេះ តែក្នុងសហជាតធម៌ ចិត្តឈ្មោះថា **អវិសាហារ** ព្រោះអត្ថថា មិនរាយមាយ ។ ដែលឈ្មោះថា **អវិក្ខេប** ព្រោះអត្ថថា មិនរាយមាយ ។ សភាវនៃចិត្តដែលមិនឃ្លេងឃ្លោងដោយអំណាចឯកគ្គតានៃចិត្ត ដែលជាអកុ-សល ឈ្មោះថា **អវិសាហដមានសតា** ។ ដែលឈ្មោះថា **សមាធិពល** ព្រោះអត្ថថា មិនញាប់ញ័រ ក្នុងសហជាតធម៌ទាំងឡាយ ។ ដែលឈ្មោះថា

**មិច្ឆាសមាធិ** ព្រោះតាំងមាំតាមសេចក្តីមិនពិត ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីក្នុងអធិការឯកគ្គតានៃចិត្តនេះយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវីរិយិន្ទ្រិយ ដូចតទៅនេះថា

ន័យជាដើមថា សភាវៈនោះ ឈ្មោះថា ការខ្នះខ្នែង ព្រោះបន្ទោបង់នូវកាមទាំងឡាយឯណា ដែលខ្ញុំពោលហើយខាងដើម ន័យនោះ មិនមានក្នុងនិទ្ទេសនៃអកុសលនេះ ។ គប្បីជ្រាបថា ឈ្មោះថា **វីរិយពល** ដោយអត្ថថា មិនញាប់ញ័រក្នុងសហជាតធម៌ទាំងឡាយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមិច្ឆាទិដ្ឋិ ដូចតទៅនេះថា

សភាវៈដែលឈ្មោះថា **មិច្ឆាទិដ្ឋិ** ដោយអត្ថថា ឃើញតាមសេចក្តីមិនពិត ។ ដែលឈ្មោះថា **ទិដ្ឋិគត** ព្រោះអត្ថថា ការឃើញនេះ ប្រព្រឹត្តទៅក្នុងទិដ្ឋិទាំងឡាយ ព្រោះជាសភាវៈឈមចុះខាងក្នុងទិដ្ឋិ ៦២ ។ សេចក្តីនៃទិដ្ឋិនេះ ខ្ញុំពោលហើយក្នុងខាងដើមនុ៎ះឯង ។ ទិដ្ឋិនុ៎ះឯង ឈ្មោះថា **ទិដ្ឋិ-គហណ** ព្រោះអត្ថថា ឈានកន្លងទៅដោយលំបាក ដូចព្រៃស្មៅ ព្រៃស្មុកញកភ្នំ ។ ទិដ្ឋិនុ៎ះឯង ឈ្មោះថា **ទិដ្ឋិកន្តារ** ដោយអត្ថថា គួររង្កៀស និងមានភ័យចំពោះមុខ ដូចកន្តារព្រោះចោរ កន្តារព្រោះសត្វសាហាវ កន្តារព្រោះខ្សាច់ កន្តារព្រោះទឹក កន្តារព្រោះទុព្ភិក្ខភ័យ ។ ដែលឈ្មោះថា **ទិដ្ឋិ-វិសូកាយិក** ដោយអត្ថថា ជំទាស់ និងផ្ទុយគ្នាជាមួយសម្មាទិដ្ឋិ ។ ពិតណាស់ សេចក្តីយល់ខុស កាលកើតឡើងរមែងជំទាស់ និងផ្ទុយគ្នាជាមួយសម្មាទិដ្ឋិ ។ ដែលឈ្មោះថា **ទិដ្ឋិវិប្ផន្ទិត** ព្រោះអត្ថថា ប្រែប្រួលខុសប្រ-

ក្រតីនៃទិដ្ឋិ ព្រោះគ្រាខ្លះ ក៏កាន់យកសេចក្តីទៀង គ្រាខ្លះ ក៏កាន់យកសេចក្តីដាច់សូន្យ ព្រោះថា ជនដែលមានការយល់ខុសរមែងមិនអាចតាំងនៅក្នុងការយល់ឃើញតែមួយ គឺជួនកាលក៏យល់ស្របតាមសេចក្តីទៀង ជួនកាលក៏យល់ស្របតាមសេចក្តីដាច់សូន្យ ។ ទិដ្ឋិនុ៎ះឯងជាសញ្ញោជន ដោយអត្ថថាជាគ្រឿងចង ព្រោះហេតុនោះ ទើបឈ្មោះថា ទិដ្ឋិសញ្ញោជន ។

ដែលឈ្មោះថា **គាហ** ព្រោះអត្ថថា ចាប់យកអារម្មណ៍ទុកយ៉ាងមាំ ដូចសត្វសាហាវមានក្រពើជាដើម យកមាត់ខាំមនុស្សទុកយ៉ាងមាំ ដូច្នោះ ។ ដែលឈ្មោះថា **បតិដ្ឋាហ** ព្រោះតាំងទុកដោយចំពោះ ពិតណាស់ ការតាំងមាំនេះ តាំងមាំហើយប្រកាន់ទុកដោយការប្រព្រឹត្តទៅដ៏មានកម្លាំង ។ ដែលឈ្មោះថា **អភិនិវេស** ព្រោះអត្ថថា ប្រកាន់មាំដោយភាពជារបស់ទៀងជាដើម ។ ដែលឈ្មោះថា **បរាមាស** ព្រោះអត្ថថា ឈានកន្លងសភាវធម៌ ហើយកាន់យកដោយប្រការដទៃ ដោយអំណាចនៃសេចក្តីទៀងជាដើម ។ ដែលឈ្មោះថា **កុម្មគ្គ** ព្រោះអត្ថថា ជាផ្លូវដែលបណ្ឌិតគួរខ្ពើម ព្រោះជាផ្លូវនាំមកនូវសេចក្តីវិនាស ឬជាផ្លូវនៃអបាយទាំងឡាយ ដែលបណ្ឌិតខ្ពើម ។ ដែលឈ្មោះថា **មិច្ឆាបថ** ព្រោះជាផ្លូវតាមសេចក្តីមិនពិត ។ ដែលឈ្មោះថា **មិច្ឆត្ត** ព្រោះជាសភាវៈខុសក៏ដូចគ្នា ។ ដូចផ្លូវដែលជនវង្វេងទិស ប្រកាន់មាំថា ផ្លូវនេះឈ្មោះផ្លូវរបស់ស្រុកឯណោះ ដូច្នេះ ក៏មិនញុំាងបុគ្គលនោះឲ្យដល់ស្រុកបានយ៉ាងណា ទិដ្ឋិដែលបុគ្គលមិច្ឆាទិដ្ឋិប្រកាន់ថា ជាផ្លូវទៅកាន់សុគតិ ក៏មិនអាចធ្វើឲ្យដល់សុគតិបាន ក៏យ៉ាងនោះ ។ ឈ្មោះថា ផ្លូវខុស

ព្រោះជាផ្លូវតាមសេចក្ដីមិនពិត ។ សភាវៈនេះ ឈ្មោះថា ភាវៈដែលខុស ព្រោះមានសភាពខុស ។ ដែលឈ្មោះថា **តិត្ថ** ព្រោះជាទីដែលពួកជនពាល ធ្លងទៅដោយការវិលទៅមកក្នុងទីនោះនុ៎ះឯង ។ **តិត្ថ** នោះផង ជាអាយតនៈ នៃវត្ថុមិនជាប្រយោជន៍ផង ព្រោះហេតុនោះ ទើបឈ្មោះថា **តិត្ថាយតន** ។ ម្យ៉ាងទៀត ឈ្មោះថា **តិត្ថាយតន** ព្រោះអត្ថថា ជាប្រភពកើត ដោយអត្ថថា ជាទីកើត និងដោយអត្ថថា ជាលំនៅរបស់ពួកតិរ្ថិយ ។ ដែលឈ្មោះថា **វិបរិយេសគ្គាហ** ព្រោះអត្ថថា ជាការកាន់យកសភាវៈដែលពិចារណាខុស ឬជាការប្រកាន់ផ្ទុយគ្នា អធិប្បាយថា កាន់យកឃ្វៀងឃ្វាត ។

ក្នុងនិទ្ទេសនៃអហិរិកៈនិងអនោត្តប្បៈ បណ្ឌិតគប្បីជ្រាបអត្ថដោយបរិយាយផ្ទុយគ្នា ក្នុងនិទ្ទេសនៃហិរិនិងឱត្តប្បៈ ។ បណ្ឌិតគប្បីជ្រាបអហិរិកពលៈនិងអនោត្តប្បពលៈ ព្រោះអត្ថថា មិនញាប់ញ័រក្នុងសហជាតធម៌ទាំងឡាយនោះឯង ។

គប្បីជ្រាបវិគ្គហៈ ក្នុងនិទ្ទេសនៃលោភៈនិងមោហៈ ដូចតទៅនេះថា

សភាវៈដែលឈ្មោះថា **លោភៈ** ព្រោះអត្ថថា ចង់បាន ។ អាការដែលលោភ ឈ្មោះថា **លុព្ភនា** ។ ចិត្តដែលសម្បយុត្តដោយលោភៈ ឬបុគ្គលដែលប្រកបដោយសេចក្ដីលោភ ឈ្មោះថា **លុព្ភិត** ភាវៈនៃចិត្តដែលសម្បយុត្តដោយលោភៈ ឬនៃបុគ្គលដែលប្រកបដោយសេចក្ដីលោភ ឈ្មោះថា **លុព្ភិតត្ត** ។ ដែលឈ្មោះថា **សារាគ** ព្រោះអត្ថថា ត្រេកអរ ។ អាការៈនៃសេចក្ដីតម្រេក ឈ្មោះថា **សារជ្ជនា** ។ ភាវៈនៃចិត្តដែលត្រេកត្រអាល

ឈ្មោះថា **សារដ្ឋិតត្ត** ។ ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា សម្លឹង ។ ហេតុព្រះមានព្រះភាគ ត្រាស់ដោយសព្ទថា លោភៈ ទៀត ។ អកុសលនោះផង ជាមូលផង ទើបឈ្មោះថា អកុសលមូល ។ ម្យ៉ាងទៀត ឈ្មោះថា អកុ-សលមូល ព្រោះអត្ថថា ជាមូលនៃអកុសលទាំងឡាយ ។

សភាវៈដែលឈ្មោះថា **អញ្ញាណ** ព្រោះបដិបក្ខចំពោះញាណ ។ ដែលឈ្មោះថា **អទស្សន** ព្រោះជាបដិបក្ខចំពោះការឃើញ ។ ដែលឈ្មោះថា **អនភិសមយ** ព្រោះអត្ថថា ជាសភាវៈចំពោះមុខក៏មិនត្រាស់ដឹងតាមធម៌បាន គឺមិនដល់ដោយប្រពៃ ។ ដែលឈ្មោះថា **អនុពោធ** ព្រោះអត្ថថា ដឹងធម៌ដោយសមគួរ ។ ដែលឈ្មោះថា **អននុពោធ** ព្រោះអននុពោធនោះ ជាបដិបក្ខចំពោះអនុពោធនោះ ។ ដែលឈ្មោះថា **អសម្ពោធ** ព្រោះអត្ថថា មិនត្រាស់ដឹងប្រកបជាមួយសភាវៈទាំងឡាយមានការមិនទៀងជាដើម ។ ដែលឈ្មោះថា **អសម្ពោធ** ព្រោះអត្ថថា ដឹងវត្ថុដែលមិនមាននិងវត្ថុដែលមិនត្រឹមត្រូវ ដូច្នេះក៏មាន ។ ដែលឈ្មោះថា **អប្បដិវេធ** ព្រោះអត្ថថា មិនចាក់ធ្លុះធម៌ គឺសច្ចៈ ៤ ។ ដែលឈ្មោះថា **អសង្គាហនា** ព្រោះអត្ថថា មិនកាន់យកដោយល្អ សូម្បីធម៌មួយក្នុងធម៌ មានរូបជាដើម ដោយសាមញ្ញលក្ខណៈមានការមិនទៀងជាដើម ។ ដែលឈ្មោះថា **អបរិយោគាហនា** ព្រោះអត្ថថា មិនឈមចុះកាន់ធម៌នោះនុ៎ះឯង ។ ដែលឈ្មោះថា **អសមបេក្ខណា** ព្រោះអត្ថថា មិនសម្លឹងដោយស្មើ ។ ដែលឈ្មោះថា **អបច្ចវេក្ខណា** ព្រោះអត្ថថា មិនសម្លឹងចំពោះសភាវៈនៃធម៌ទាំងឡាយ ។

ដែលឈ្មោះថា **អបច្ចក្ខកម្ម** ព្រោះអត្ថថា កម្មសូម្បីតែមួយក៏មិនប្រចក្សដល់សភាវៈនេះ បណ្ដាកុសលកម្មនិងអកុសលកម្មទាំងឡាយ ដោយការប្រព្រឹត្តទៅដោយវិបរិតខ្លះ ដោយមិនមានការកំណត់ដោយសភាវៈខ្លះ ម្យ៉ាងទៀត ឈ្មោះថា ការធ្វើធម៌ណាមួយឲ្យប្រចក្សឯងមិនមាន កាលមោហៈនេះមិនទាន់កើតឡើងចិត្តសន្ដានណាគប្បីជាចិត្តបរិសុទ្ធ ស្អាតផូរផង់ ចិត្តសន្ដានដ៏បរិសុទ្ធនោះដែលមោហៈនេះប្រទូស្ដហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **ទុម្មេជ្ឈ** ។ ដែលឈ្មោះថា **ពាល្យ** ព្រោះអត្ថថា ជាភាវៈរបស់ពួកជនពាល ។ ដែលឈ្មោះថា **មោហ** ព្រោះអត្ថថា វង្វេង ។ មោហៈមានកម្លាំងដ៏ខ្លាំងក្លា ឈ្មោះថា **បមោហ** ។ ដែលឈ្មោះថា **សម្មោហ** ព្រោះអត្ថថា វង្វេងដោយជុំវិញ ។ ដែលឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា មិនមែនវិជ្ជា ព្រោះជាបដិបក្ខចំពោះវិជ្ជា ។ អត្ថនៃឱឃៈ យោគៈ និងគន្ថៈ ខ្ញុំពោលទុកហើយនោះឯង ។ ដែលឈ្មោះថា **អនុសយ** ព្រោះអត្ថថា ដេកត្រាំ ដោយអត្ថថាមានកម្លាំង ។ ដែលឈ្មោះថា **បរិយុដ្ឋាន** ព្រោះអត្ថថា រួបរឹត គឺគ្របសង្កត់ចិត្ត ។ ដែលឈ្មោះថា **លង្គី** ( គន្លឹះ ) ព្រោះអត្ថថា រមែងមិនអាចដើម្បីផ្ទោះមុខចំពោះប្រយោជន៍ គឺជាប់នៅដោយពិត ព្រោះមិនមានការកាន់យកប្រយោជន៍បាន គឺទៅដោយលំបាក ។ ម្យ៉ាងទៀត ឈ្មោះថា **លង្គី** ព្រោះអត្ថថា ដកឡើងបានដោយក្រ ។ ដូចគន្លឹះ ពោលគឺដុំដែកធំ ជារបស់ដកឡើងដោយលំបាកយ៉ាងណា អវិជ្ជានេះក៏យ៉ាងនោះ ដូចជាគន្លឹះ ព្រោះហេតុនោះ ទើបអវិជ្ជានោះ ឈ្មោះថា **លង្គី** ។

ពាក្យដ៏សេសមានសេចក្តីងាយយល់ហើយ ព្រោះហេតុនោះ គប្បីជ្រាប សុម្បីសង្គហវារៈនិងសុញ្ញតវារៈ ដោយអត្ថ ដោយន័យដែលពោលទុកខាងដើមនុ៎ះឯង ។

## អកុសលចិត្តដួងទី ១ ចប់

# អភិធម្មបិដក

## អកុសលចិត្តដួងទី ២

[ ៣១១ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ ចិត្តជាអកុសល ប្រកបដោយសោមនស្ស ប្រកបដោយទិដ្ឋិ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ សេចក្តីមិនរាយមាយក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។បេ។

## អកុសលចិត្តដួងទី ៣

[ ៣១២ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ ចិត្តជាអកុសល ប្រកបដោយសោមនស្ស ប្រាសចាកទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗ កើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យ

ហេតុក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣១៣ ] ខន្ធ ៤ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ឈានប្រកបដោយអង្គ ៥ មគ្គប្រកបដោយអង្គ ៣ ពលៈ ៤ ហេតុ ២ ផស្សៈ ១ កើតមានក្នុងសម័យនោះ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣១៤ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ បីតិ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។បេ។

## អកុសលចិត្តដួងទី ៤

[ ៣១៥ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្ត ជាចិត្តប្រទ្បាំដោយសោមនស្ស តែប្រាសចាកទិដ្ឋិ ប្រកបដោយសង្ខារ មានរូបជា

អារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណា ៗ កើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេប ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។បេ។

# អកុសលចិត្តដួងទី ៤

[ ៣១៦ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្តប្រទ្បំដោយឧបេក្ខា ប្រកបដោយទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វិរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា មិច្ឆាទិដ្ឋិ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣១៧ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិចទង្គិចណាក្នុងសម័យនោះ នេះផស្សៈ

កើតមានក្នុងសម័យនោះ ។ វេទនាកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនធ្ងាញ់ពិសា មិនមែនជាមិនធ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍មិនទុក្ខមិនសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។បេ។ ឧបេក្ខាកើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនធ្ងាញ់ពិសា មិនមែនជាមិនធ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខាកើតមានក្នុងសម័យនោះ ។បេ។ ឧបេក្ខិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនធ្ងាញ់ពិសា មិនមែនជាមិនធ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខិន្ទ្រិយកើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣១៨ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ឈានមានអង្គ ៤ មគ្គមានអង្គ ៤ ពលៈ ៤ ហេតុ ២ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមាន

ក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣១៩ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាទិដ្ឋិ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា មិច្ឆាទិដ្ឋិ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។

## អកុសលចិត្តដួងទី ៦

[ ៣២០ ] ពួកធម៌ជាអកុសល តើដូចម្ដេច ។ អកុសលចិត្ត ជាចិត្តប្រទ្បំដោយឧបេក្ខាប្រកបដោយទិដ្ឋិ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។បេ។

# អកុសលចិត្តដួងទី ៧

[ ៣២១ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្ត ជាចិត្តប្រទូំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗ កើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣២២ ] ខន្ធ ៤ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ៣ ពលៈ ៤ ហេតុ ២ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣២៣ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ

មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ លោភៈ មោហៈ អភិជ្ឈា អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុក៏កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។

# អកុសលចិត្តដួងទី ៨

[ ៣២៤ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្ត ជាចិត្តប្រទ្បាំដោយឧបេក្ខា ប្រាសចាកទិដ្ឋិ តែប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។បេ។

# អកុសលចិត្តដួងទី ៩

[ ៣២៥ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្ត ជាចិត្តប្រទ្បាំដោយទោមនស្ស ប្រកបដោយសេចក្តីចង្អៀតចង្អល់ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអា-

រម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ទុក្ខ ឯកគ្គតារបស់ចិត្ត វិរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ ទោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វិរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ ទោសៈ មោហៈ ព្យាបាទៈ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ឬក៏អរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣២៦ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈ កើតមានក្នុងសម័យនោះ ។ វេទនាកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខ ប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។បេ។ ទុក្ខកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនា

មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះទុក្ខកើតមានក្នុងសម័យនោះ ។បេ។ ទោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះទោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ ។បេ។ ទោសៈកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីខឹង ការប្រទូស្ត ភាពប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពព្យាបាទ សេចក្តីខុស សេចក្តីក្តាត់ សេចក្តីកាច សម្តីអសុរោះ សេចក្តីមិនត្រេកអរនៃចិត្តណា ក្នុងសម័យនោះ នេះទោសៈកើតមាន ក្នុងសម័យនោះ ។បេ។ ព្យាបាទ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីខឹង ការប្រទូស្ត ភាពប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពព្យាបាទ សេចក្តីខុស សេចក្តីក្តាត់ សេចក្តីកាច សម្តីអសុរោះ សេចក្តីមិនត្រេកអរនៃចិត្តណា ក្នុងសម័យនោះ នេះព្យាបាទក៏កើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣២៧ ] ខន្ធ ៤ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ឈានមានអង្គ ៤ មគ្គប្រកបដោយអង្គ ៣ ពលៈ ៤ ហេតុ ២ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យ

នោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣២៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ ទោសៈ មោហៈ ព្យាបាទ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។

## អកុសលចិត្តដួងទី ១០

[ ៣២៩ ] ពួកធម៌ជាអកុសល តើដូចម្ដេច ។ អកុសលចិត្ត ជាចិត្តប្រកបដោយទោមនស្ស ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ទាំងប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។បេ។

# អកុសលចិត្តដួងទី ១១

[ ៣៣០ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្ត ជាចិត្តប្រឡំដោយឧបេក្ខា ប្រកបដោយវិចិកិច្ឆា មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តីឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ វីរិយពលៈ អហិរិកពលៈ អនោត្តប្បពលៈ វិចិកិច្ឆា មោហៈ អហិរិកៈ អនោត្តប្បៈ បគ្គាហៈ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣៣១ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណាក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។បេ។ ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅណារបស់ចិត្តក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។បេ។ វិចិកិច្ឆា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឆ្ងល់ អាការឆ្ងល់ ភាពឆ្ងល់ សេចក្តីយល់ស្ទាក់ស្ទើរ សេចក្តីងឿងឆ្ងល់ ចិត្តបែកជាពីរ ចិត្តញែកជា ២ ផ្លូវ សេចក្តីសង្ស័យ ការប្រកាន់ដោយចំណែកច្រើន ការដកថយមិនរួច ការទម្ងុះទម្ងាយទៅមិនបាន ការប្រកាន់មិនមាំ សេចក្តីរឹងត្អឹងរបស់ចិត្ត ការរសេមរសាមចិត្តណា ក្នុងសម័យ

នោះ នេះវិចិកិច្ឆាកើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣៣២ ] ខន្ធ ៤ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៤ ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ២ ពលៈ ៣ ហេតុ ១ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣៣៣ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ វីរិយពលៈ អហិរិកពលៈ អនោត្តប្បពលៈ វិចិកិច្ឆា មោហៈ អហិរិកៈ អនោត្តប្បៈ បគ្គាហៈ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។

# អកុសលចិត្តដួងទី ១២

[ ៣៣៤ ] ពួកធម៌ជាអកុសល តើដូចម្តេច ។ អកុសលចិត្ត ជាចិត្តប្រទូំដោយឧបេក្ខា ប្រកបដោយឧទ្ធច្ចៈ មានរូបជាអារម្មណ៍ក្តី មានសំឡេងជាអារម្មណ៍ក្តី មានក្លិនជាអារម្មណ៍ក្តី មានរសជាអារម្មណ៍ក្តី មានផោដ្ឋព្វៈជាអារម្មណ៍ក្តី មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ ឧទ្ធច្ចៈ មោហៈ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។

[ ៣៣៥ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។បេ។ ឧទ្ធច្ចៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការអណ្តែតអណ្តូងចិត្ត ការមិនស្ងប់រម្ងាប់ ការរាយមាយចិត្ត ការភ្ញាក់ផ្អើលចិត្តណា ក្នុងសម័យនោះ នេះឧទ្ធច្ចៈកើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣៣៦ ] ខន្ធ ៤ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ឈានប្រកបដោយអង្គ ៤ មគ្គប្រកបដោយអង្គ ៣ ពលៈ ៤ ហេតុ ១ ផស្សៈ ១ ។បេ។ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអកុសល ។បេ។

[ ៣៣៧ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ មិច្ឆាសង្កប្បៈ មិច្ឆាវាយាមៈ មិច្ឆាសមាធិ វីរិយពលៈ សមាធិពលៈ អហិរិកពលៈ អនោត្តប្បពលៈ ឧទ្ធច្ចៈ មោហៈ អហិរិកៈ អនោត្តប្បៈ សមថៈ បគ្គាហៈ អវិក្ខេបៈ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអកុសល ។

**ចប់ អកុសលចិត្ត ១២ ។**

# អដ្ឋកថា

# អកុសលចិត្តដួងទី ២ ជាដើម

[ ៣១១-៣៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអកុសលចិត្តដួងទី ២ ( ជាដើម ) ដូចតទៅនេះថា

បទថា **សសង្ខារេន** ជាពាក្យបន្ថែមមក ពាក្យនោះខ្ញុំពោលទុកក្នុងខាងដើមនោះឯង ។ អកុសលចិត្តនេះ រមែងកើតឡើងដល់បុគ្គលដែលមានចិត្តត្រេកអរក្នុងអារម្មណ៍ទាំង ៦ ដែលញ៉ាំងលោភៈឲ្យកើតឡើងហើយកាន់យកខុសដោយន័យជាដើមថា សត្វ សត្វ ដូច្នេះក៏ពិត តែក្នុងកាលណាកុលបុត្តប្រាថ្នាកុមារិការបស់ត្រកូលមិច្ឆាទិដ្ឋិ តែពួកមិច្ឆាទិដ្ឋិទាំងនោះ មិនឲ្យកុមារិកាដោយអាងថា ពួកអ្នកកាន់ទិដ្ឋិដទៃ តែខាងក្រោយមក ពួកញាតិមួយពួកទៀត ប្រាប់ឲ្យលើកឲ្យដោយពោលថា កុលបុត្តនេះនឹងធ្វើតាមពួកអ្នកធ្វើនោះឯង ។ កុលបុត្តនោះ ចូលទៅរកពួកតិរ្ថិយមួយអន្លើដោយពួកញាតិនោះឯងដំបូងនៅជាអ្នកស្ទាក់ស្ទើរ តែពេលវេលាកន្លងទៅក៏គិតថា កិរិយារបស់ពួកតិរ្ថិយទាំងនេះគួរពេញចិត្ត ដូច្នេះហើយក៏គាប់ចិត្តក្នុងលទ្ធិ ព្រមទទួលទិដ្ឋិ ។ ក្នុងកាលបែបនេះ គប្បីជ្រាបថា អកុសលចិត្តនេះរមែងបាន ( កើតឡើង ) ព្រោះការកើតឡើងដោយសម្បយោគ ( ការប្រកបព្រមគ្នា ) ព្រមដោយឧបាយ ព្រោះអកុសលចិត្តនោះ ជាសសង្ខារិក ( មានការបបួលដឹកនាំ ) ។

ចំណែកក្នុងយេវាបនកធម៌ទាំងឡាយ ថីនៈនិងមិទ្ធៈ ជាធម៌បន្ថែមចូលមកក្នុងអកុសលចិត្តដួងទី ២ នេះ ។ ក្នុងថីនៈនិងមិទ្ធៈនោះ ការរួញរាឈ្មោះ

ថា **ថីនៈ** ការងងុយងោកងក់ ឈ្មោះថា **មិទ្ធៈ** អធិប្បាយថា ការមិនឧស្សាហៈ ការមិនអង់អាច ព្រោះសម្លាប់នូវការអាច ។ រួញរាផង ងោកងុយផង ឈ្មោះថា ថីនមិទ្ធ ក្នុងអកុសលទាំងពីរនោះ ថីនៈ **អនុស្សាហលក្ខណំ** មានការមិនឧស្សាហ៍ ជាលក្ខណៈ **វីរិយវិនោទនរសំ** មានការកម្ចាត់វីរិយៈ ជាកិច្ច **សំសីទនបច្ចុបដ្ឋានំ** មានការរាថយ ជាអាការប្រាកដ ។

មិទ្ធៈ **អកម្មញ្ញតាលក្ខណំ** មានការមិនគួរដល់ការងារ ជាលក្ខណៈ **ឱនហនរសំ** មានការដាក់ចុះ ជាកិច្ច **លីនតាបច្ចុបដ្ឋានំ** មានការរួញរា ជាអាការប្រាកដ **បចលាយិកានិទ្ទាបច្ចុបដ្ឋានំ វា** ឬមានការងងុយងោកងក់ និងដេកលក់ ជាអាការប្រាកដ ។ ថីនមិទ្ធៈសូម្បីទាំងពីរ **អរតិតន្ទីវិជម្ភិតា-ទីសុ អយោនិសោមនសិការបទដ្ឋានំ** មានមនសិការដោយឧបាយមិនត្រូវទំនង ក្នុងសភាវៈមានសេចក្ដីមិនត្រេកអរ សេចក្ដីខ្ជិលប្រអូស និងសេចក្ដីងងុយងោកងក់ជាដើម ជាហេតុជិត ។

អកុសលចិត្តដួងទី ២ ចប់

# អកុសលចិត្តដួងទី ៣

អកុសលចិត្តដួងទី ៣ រមែងកើតដល់បុគ្គល ដែលមានចិត្តត្រេកអរក្នុងអារម្មណ៍ទាំង ៦ ដែលញុំាងលោភៈឲ្យកើតឡើងហើយ មិនប្រកាន់ដោយន័យជាដើមថា សត្វ សត្វ ដូច្នេះ ដែលសម្លឹងមើលព្រះរាជា ការប្រកួតរបស់

អ្នកចំបាប់និងអ្នករបាំជាដើម ឬដែលខ្វល់ខ្វាយក្នុងការស្តាប់សំឡេងដែលជាទីគាប់ចិត្តជាដើម ។ ក្នុងអកុសលចិត្តដួងទី ៣ នេះ យេវាបនកធម៌ ៤ ដែលពិតប្រាកដ រួមជាមួយមានះជាអង្គ ៥ ដែលពិតប្រាកដ ។ ក្នុងអង្គទាំងនោះ សភាវៈដែលឈ្មោះថា មានះ ព្រោះអត្ថថា រមែងប្រកាន់ខ្លួន ។ មានះនោះ **ឧន្នតិលក្ខណោ** មានការលើកខ្លួន ជាលក្ខណៈ **សម្បគ្គហាណរសោ** មានការផ្គងឡើងនូវខ្លួន ជាកិច្ច **កេតុកម្យតាបច្ចុបដ្ឋានោ** មានសេចក្តីប្រាថ្នាដូចទង់ ជាអាការប្រាកដ **ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ** មានលោភៈមិនប្រកបដោយទិដ្ឋិជាហេតុជិត គប្បីជ្រាបថា ដូចមនុស្សឆ្កួត ។

**អកុសលចិត្តដួងទី ៣ ចប់**

# អកុសលចិត្តដួងទី ៤

អកុសលចិត្តដួងទី ៤ រមែងកើតឡើងក្នុងឋានៈ មានប្រការដូចពោលហើយនុ៎ះឯង គឺក្នុងឋានៈទាំងឡាយ មានជាដើមយ៉ាងនេះថា ក្នុងកាលណាពួកជនរមែងស្តោះទឹកមាត់លើក្បាល ឬរោយធូលីដែលជាប់នឹងជើងទៅ ក្នុងកាលនោះអកុសលចិត្តដួងទី ៤ រមែងកើតដល់បុគ្គលទាំងឡាយដែលសម្លឹងមើលក្នុងចន្លោះៗដោយប្រព្រឹត្តទៅជាមួយនឹងឧស្សាហៈ ដើម្បីចៀសវាងទឹកមាត់និងធូលីនៃបាតជើងនោះ និងរមែងកើតដល់បុគ្គលទាំងឡាយដែលសម្លឹងមើលតាមប្រហោងនោះៗ កាលសេចក្តីជ្រួលច្របល់ ប្រព្រឹត្តទៅក្នុងកាលតួ

ល្ងោនកំពុងចេញមក ។ ក្នុងអកុសលចិត្តដួងទី ៤ នេះ យេវាបនកធម៌ ៤ ដែលពិតប្រាកដ រួមទាំងមានះ ថីនៈ និងមិទ្ធៈ ជាយេវាបនកធម៌ ៧ ។ សូម្បីក្នុងអកុសលចិត្តទាំងពីរ គឺអកុសលចិត្តដួងទី ៣ និងទី ៤ រមែងដកមិច្ឆាទិដ្ឋិចេញ គប្បីជ្រាបចំនួនធម៌ដោយអំណាចធម៌ដ៏សេស វៀរមិច្ឆាទិដ្ឋិនុ៎ះឯង ។

**អកុសលចិត្តដួងទី ៤ ចប់**

# អកុសលចិត្តដួងទី ៥

អកុសលចិត្តដួងទី ៥ រមែងកើតដល់មជ្ឈត្តបុគ្គល ( អ្នកព្រងើយ ) ដោយអំណាចនៃវេទនាក្នុងអារម្មណ៍ទាំង ៦ ដែលញុំាងលោភៈឲ្យកើតហើយ ប្រកាន់ដោយន័យជាដើមថា សត្វ សត្វ ។ ក្នុងអកុសលចិត្តដួងទី ៥ នេះ ឧបេក្ខាវេទនារមែងមានក្នុងទីសោមនស្ស ( ជំនួសសោមនស្សវេទនា ) ។ ដកបីតិចេញ ។ ពាក្យដ៏សេសទាំងអស់ដូចអកុសលចិត្តដួងទី ១ នុ៎ះឯង ។

**អកុសលចិត្តដួងទី ៥ ចប់**

# អកុសលចិត្តដួងទី ៦ ទី ៧ ទី ៨

សូម្បីអកុសលចិត្តដួងទី ៦ ទី ៧ និងទី ៨ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងអកុសលចិត្តដួងទី ២ ទី ៣ ទី ៤ នុ៎ះឯង ដោយផ្លាស់ប្តូរវេទនា និងដកបីតិចេញ ។ អធិបតីទាំង ២ គឺ សហជាតាធិបតិនិងអារម្មណាធិបតិ

រមែងបានក្នុងចិត្តដែលសហគតៈដោយលោភៈ ៨ ដួងទាំងនេះ ។

**អកុសលចិត្តដួងទី ៦ ទី ៧ ទី ៨ ចប់**

## អកុសលចិត្តដួងទី ៩

អកុសលចិត្តដួងទី ៩ រមែងកើតឡើងដល់បុគ្គលដែលមានទោមនស្ស ក្នុងអារម្មណ៍ទាំង ៦ ដែលញ៉ាំងបដិឃៈឲ្យកើតឡើងនុ៎ះឯង ។ នឹងវិនិច្ឆ័យក្នុងវារៈពោលដោយការកំណត់សម័យ ៣ នៃអកុសលចិត្តដួងទី ៩ នោះជាមុនសិន ។

មនៈដែលទោសប្រទូស្តហើយ ឬមនៈដែលបណ្ឌិតស្អប់ខ្ពើម ព្រោះមានវេទនាដ៏អាក្រក់ ព្រោះហេតុនោះទើបឈ្មោះថា ទុម្មនៈ ។ ភាវៈនៃចិត្តអាក្រក់ឈ្មោះថា **ទោមនស្ស** ។ អកុសលចិត្តដែលឈ្មោះថា **ទោមនស្សសហគតំ** ព្រោះអត្ថថា អកុសលចិត្តសហគដោយទោមនស្សនោះ ។

សភាវៈដែលឈ្មោះថា **បដិឃៈ** ព្រោះអត្ថថា រមែងប៉ះខ្ទប់ក្នុងអារម្មណ៍ដោយភាវៈដែលមិនពេញចិត្ត ។ អកុសលចិត្តដែលឈ្មោះថា បដិឃសម្បយុត្ត ព្រោះអត្ថថា ប្រកបដោយសេចក្តីថ្នាំងថ្នាក់នោះ ។ ក្នុងធម្មទេស ទោមនស្សវេទនាមកហើយក្នុងឋានៈ ៣ ។ ក្នុងឋានៈទាំង ៣ មានវេទនាជាដើមនោះ ពាក្យថា **វេទនា** មានអត្ថតាមដែលពោលទុកហើយនោះឯង ។ ពាក្យថា ទុក្ខនិងទោមនស្ស ក៏ពោលទុកហើយដូចគ្នា ។ តែកាលពោលដោយ

លក្ខណៈជាដើម ទោមនស្ស **អនិដ្ឋារម្មណានុភវនលក្ខណំ** មានការសោយអារម្មណ៍មិនជាទីពេញចិត្ត ជាលក្ខណៈ **យថាតថា វា អនិដ្ឋាការសម្ភោគរសំ** មានការសោយអាការមិនល្អយ៉ាងណានីមួយ ជាកិច្ច **ចេតសិកាពាធបច្ចុបដ្ឋានំ** មានអាពាធតាមផ្លូវចិត្ត ជាអាការប្រាកដ **ឯកន្តេន វា ហទយវត្ថុបទដ្ឋានំ** មានហទយវត្ថុប៉ុណ្ណោះ ជាហេតុជិត ។

ក្នុងមូលកម្មបថទាំងឡាយ ព្រះអង្គត្រាស់ថា ទោសៈរមែងមាន ព្យាបាទរមែងមាន ដូចព្រះតម្រាស់ដែលត្រាស់ដល់អកុសលចិត្តដួងមុនៗថា លោភៈរមែងមាន អភិជ្ឈារមែងមាន ដូច្នោះ បណ្តាធម៌ទាំងពីរ គឺទោសៈនិងព្យាបាទនោះ មានវិគ្គហៈ ដូចតទៅនេះថា សភាវៈដែលឈ្មោះថា ទោសៈ ព្រោះអត្ថថា ជាហេតុប្រទូស្តជន ឬប្រទូស្តឯង ឬថា ធម្មជាតនោះត្រឹមតែជាគ្រឿងប្រទូស្តប៉ុណ្ណោះ ។

ទោសៈនោះ **ចណ្ឌិក្កលក្ខណោ** មានការកាចជាលក្ខណៈ គប្បីឃើញដូចអសិរពិសត្រូវវាយ **វិសប្បនរសោ** មានការអន្ទះអន្ទែង ជាកិច្ច គប្បីឃើញដូចត្រូវថ្នាំពិស **អត្តនោ និស្សយទហនរសោ វា** ឬមានការដុតនូវទីអាស្រ័យរបស់ខ្លួនជាកិច្ច គប្បីឃើញដូចភ្លើងឆេះព្រៃ **ទុស្សនបច្ចុបដ្ឋានោ** មានការប្រទូស្តជាអាការប្រាកដ គប្បីឃើញដូចសត្រូវបានឱកាស **អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុជាហេតុជិត គប្បីឃើញដូចទឹកមូត្រស្អុយលាយដោយថ្នាំពិស ដូច្នោះ ។

សភាវៈដែលឈ្មោះថា ព្យាបាទ ព្រោះអត្ថថា ជាហេតុបៀតបៀន គឺ

ចិត្តចូលដល់សភាវៈខូច ឬថារមែងញុំាងវិន័យ អាចារៈ រូបសម្បត្តិនិងហិតសុខជាដើម ឲ្យដល់នូវសេចក្ដីវិបត្តិ ។ កាលពោលដោយអត្ថ ព្យាបាទនេះ ក៏គឺទោសៈនុ៎ះឯង តែក្នុងអកុសលចិត្តដួងទី ៩ នេះ ជាបទអកុសល ២៩ តាមលំដាប់ ។ ព្រោះកាន់យកធម៌ដែលមិនត្រួតគ្នាទើបជាធម៌ ១៤ បទ ។ គប្បីជ្រាបប្រភេទកងធម៌ ដែលចែកបាននិងចែកមិនបាន ដោយអំណាចនៃបទធម៌ទាំងនោះ ។

ក្នុងយេវាបនកធម៌ទាំងឡាយសភាវៈធម៌ គឺឆន្ទៈ អធិមោក្ខ មនសិការ និងឧទ្ធច្ចៈ ជានិយតៈ ( គឺចេតសិកប្រកបជាមួយនឹងអកុសលចិត្តដួងទី ៩ ពិតប្រាកដ ) ។ សភាវៈធម៌ទាំងនេះកាលរួមជាមួយធម៌ គឺឥស្សា មច្ឆរិយៈ ឬកុក្កុច្ចៈឯណានីមួយ រមែងកើតឡើងម្ដង ៥ ។ ធម៌ទាំង ៣ មានឥស្សាជាដើមទាំងនេះ ឈ្មោះថា **អនិយតយេវាបនក** ដោយប្រការដូច្នេះ ។ បណ្ដាធម៌ទាំង ៣ នោះ សភាវធម៌ដែលឈ្មោះថា ឥស្សា ព្រោះអត្ថថា ច្រណែន ។

ឥស្សានោះ **បរសម្បត្តីនំ ឧស្សូយនលក្ខណា** មានការច្រណែននឹងសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ **តត្ថេវ អនភិរតិរសា** មានការមិនត្រេកអរក្នុងសម្បត្តិរបស់អ្នកដទៃនោះឯងជាកិច្ច **តតោ វិមុខភាវបច្ចុបដ្ឋានា** មានការបែរមុខចេញអំពីសម្បត្តិរបស់អ្នកដទៃនោះជាអាការប្រាកដ **បរសម្បត្តិបទដ្ឋានា** មានសម្បត្តិរបស់អ្នកដទៃជាហេតុជិត គប្បីជ្រាបថា ជាសញ្ញោជនៈ ។

ភាវៈនៃសេចក្ដីកំណាញ់ ឈ្មោះថា **មច្ឆរិយ** មច្ឆរិយៈនោះ **លទ្ធានំ វា**

**លភិតព្វានំ វា អត្ថានោ សម្បត្តីនំ និគូហនលក្ខណំ** មានការបិទបាំងសម្បត្តិរបស់ខ្លួនដែលបានមកហើយក្តី ដែលគួរបានក្តីជាលក្ខណៈ **តាសំយេវ បរេហិ សាធារណភាវអក្ខមនរសំ** មានការអត់ធន់មិនបានក្នុងភាពដែលសម្បត្តិរបស់ខ្លួននោះឯង ជាសាធារណៈដល់ជនដទៃជាកិច្ច **សង្កោចនបច្ចុបដ្ឋានំ** មានមុខក្រញូវជាអាការប្រាកដ **កដុកញ្ចុកតាបច្ចុបដ្ឋានំ វា** ឬមានការចង្អៀតចង្អល់ជាអាការប្រាកដ **អត្តសម្បត្តិបទដ្ឋានំ** មានសម្បត្តិរបស់ខ្លួនជាហេតុជិត មច្ឆរិយៈនេះ គប្បីឃើញថា ជាភាពពិការរបស់ចិត្ត ។

កម្មដែលបណ្ឌិតខ្ពើម ដែលបុគ្គលធ្វើហើយ ឈ្មោះថា **កុកត** ភាវៈនៃកុកតៈនោះ ឈ្មោះថា **កុក្កុច្ច** កុក្កុច្ចៈនោះ **បច្ឆានុតាបលក្ខណំ** មានសេចក្តីក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយ ជាលក្ខណៈ **កតាកតានុសោចនរសំ** មានសេចក្តីសោករឿយៗ ដល់បាបដែលធ្វើហើយ និងបុណ្យដែលមិនទាន់បានធ្វើជាកិច្ច **វិប្បដិសារបច្ចុបដ្ឋានំ** មានវិប្បដិសារៈ គឺសេចក្តីក្តៅក្រហាយស្តាយក្រោយជាអាការប្រាកដ **កតាកតបទដ្ឋានំ** មានការធ្វើបាបហើយ និងមិនបានធ្វើបុណ្យទុកជាហេតុជិត គប្បីឃើញថា ដូចភាពជាទាសៈ ដូច្នោះ ។

នេះជាសេចក្តីផ្សេងគ្នាក្នុងឧទ្ទេសវារៈ ។ ក្នុងនិទ្ទេសវារៈ គប្បីជ្រាបការមិនពេញចិត្ត ក្នុងវេទនានិទ្ទេស ដោយអំណាចធម៌ជាបដិបក្ខចំពោះសេចក្តីពេញចិត្ត ។

គប្បីជ្រាបវិគ្គហៈក្នុងទោសនិទ្ទេស ដូចតទៅនេះថា

សភាវៈដែលឈ្មោះថា ទោសៈ ព្រោះអត្ថថា គិតប្រទូស្ត ។ អាការដែលគិតប្រទូស្ត ឈ្មោះថា **ទុស្សនា** ។ ភាវៈនៃសេចក្ដីប្រទូស្ត ឈ្មោះថា **ទុស្សិតត្ត** ។

គំនិតបៀតបៀន ឈ្មោះថា **ព្យាបត្តិ** ដោយអត្ថថា លះនូវប្រក្រតី ។ អាការៈនៃបំណងអាក្រក់ ឈ្មោះថា **ព្យាបជ្ជនា** ។ ដែលឈ្មោះថា **វិរោធ** ព្រោះអត្ថថា ខឹងក្រោធ ។ ដែលឈ្មោះថា **បដិវិរោធ** ព្រោះអត្ថថា ខឹងក្រោធរឿយៗ ។ ម្យ៉ាងទៀត ពាក្យទាំងពីរនេះត្រាស់ទុកដោយអំណាចនៃអាការដែលខឹងក្រោធ និងអាការដែលចង្អៀតចង្អល់ ។

បុគ្គលមានចិត្តកាច ហៅថា ចណ្ឌិកៈ ភាវៈនៃចណ្ឌិកៈនោះ ហៅថា ចណ្ឌិក្កៈ ។ សម្ដីដែលមនុស្សកាចនេះលើកឡើងនិយាយដោយល្អ មិនមានទេ សម្ដីរបស់ជនដូច្នេះជាពាក្យនិយាយអាក្រក់ គឺនិយាយឲ្យបរិបូណ៌មិនបានឡើយ ព្រោះហេតុនោះទើបឈ្មោះថា អសុរោបៈ ។ ពិតណាស់ ក្នុងវេលាដែលបុគ្គលកាចក្រោធហើយ ដែលឈ្មោះថាពាក្យនិយាយដ៏បរិបូណ៌ រមែងមិនមាន ។ ទោះបីមានដល់ជនពួកខ្លះ សេចក្ដីនោះក៏មិនជាប្រមាណ ។ អាចារ្យមួយពួកពោលថា ឈ្មោះថា អសុរោបៈ ព្រោះអត្ថថា ឲ្យកើតទឹកភ្នែកដោយការហូរចេញនៃទឹកភ្នែក ។ ពាក្យដែលពោលមកនោះ មិនមែនជាហេតុ ព្រោះសូម្បីសោមនស្ស ក៏ធ្វើឲ្យទឹកភ្នែកកើតបាន ។ សភាវៈដែលឈ្មោះថា **អនត្តមនតា** ព្រោះអត្ថថា ភាពជាអ្នកមិនមានចិត្តជារបស់ខ្លួន ព្រោះជាបដិបក្ខចំពោះភាពជាអ្នកមានចិត្តជារបស់ខ្លួន តាមដែលពោលហើយ

ខាងដើម ។ តែព្រោះការមិនមានចិត្តរីករាយនោះជារបស់ចិត្តប៉ុណ្ណោះ មិនជារបស់សត្វ ហេតុនោះ ទើបត្រាស់ថា **ចិត្តស្ស** ដូច្នេះ ។ ពាក្យដ៏សេសក្នុងអកុសលចិត្តដួងទី ៩ នេះ ទាំងក្នុងសង្គហវារៈនិងសុញ្ញតវារៈ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងខាងដើមនុ៎ះឯង ។

## អកុសលចិត្តដួងទី ៩ ចប់

# អកុសលចិត្តដួងទី ១០

អកុសលចិត្តដួងទី ១០ រមែងកើតដល់បុគ្គលដែលត្រូវជនដទៃៗឲ្យកើតឧស្សាហៈខ្លះ ត្រូវពួកជនដទៃៗជាស់តឿនឲ្យនឹកឃើញកំហុសខ្លះ ខ្លួនឯងនុ៎ះឯងនឹកឃើញកំហុសរបស់ជនដទៃ ៗ ហើយខឹងក្រោធខ្លះ ព្រោះអកុសលចិត្តនេះ ប្រព្រឹត្តទៅជាមួយនឹងការដឹកនាំ ។ សូម្បីក្នុងអកុសលចិត្តនេះ ក៏មានអកុសលធម៌ ២៩ បទតាមលំដាប់បទ ។ ព្រោះកាន់យកធម៌ដែលមិនត្រួតគ្នា ទើបជាធម៌ ១៤ បទប៉ុណ្ណោះ ។ តែថីនៈនិងមិទ្ធៈ រមែងបានក្នុងយេវា-បនកធម៌ទាំងឡាយ ព្រោះហេតុនោះ ក្នុងអកុសលចិត្តដួងនេះទើបវៀរឥស្សាមច្ឆរិយៈ និងកុក្កុច្ចៈ ឬវៀរនូវធម៌ទាំង ៦ នេះ គឺអង្គយេវាបនកធម៌ដែលពិតប្រាកដ ៤ និងថីនមិទ្ធៈ កាលរួមជាមួយធម៌ណាមួយក្នុងឥស្សាជាដើម ក្នុងវេលាដែលឥស្សាជាដើមនោះ កើតឡើងជា ៧ ប្រការ រមែងកើតឡើងក្នុង

ខណៈជាមួយគ្នា ។ ពាក្យដ៏សេសទាំងអស់គ្រប់វារៈដូចអកុសលចិត្តដួងទី ៩ នោះឯង ។ ក្នុងទោមនស្សចិត្តទាំង ២ នេះ រមែងបានសហជាតាធិបតិតែម្យ៉ាង មិនបានអារម្មណាធិបតិ ។ ព្រោះបុគ្គលខឹងក្រោធហើយរមែងមិនធ្វើអារម្មណ៍ណាមួយឲ្យធ្ងន់ ( ជាអធិបតិ ) បាន ដូច្នេះឯង ។

**អកុសលចិត្តដួងទី ១០ ចប់**

## អកុសលចិត្តដួងទី ១១

អកុសលចិត្តដួងទី ១១ រមែងកើតឡើងក្នុងវេលាដែលសេចក្តីសង្ស័យប្រព្រឹត្តទៅដល់បុគ្គលអ្នកព្រងើយកន្តើយដោយអំណាចវេទនា ក្នុងអារម្មណ៍ទាំង ៦ ។ ក្នុងការកំណត់សម័យរបស់អកុសលចិត្តដួងទី ១១ នោះ បទថា **វិចិកិច្ឆាសម្បយុត្តំ** ជាពាក្យដែលមិនធ្លាប់អធិប្បាយ ។ សេចក្តីនៃពាក្យនោះមានដូចតទៅនេះថា សភាវៈដែលឈ្មោះថា **វិចិកិច្ឆាសម្បយុត្ត** ព្រោះអត្ថថា ប្រកបព្រមដោយវិចិកិច្ឆា ។ ក្នុងធម្មុទ្ទេស បទថា **វិចិកិច្ឆា ហោតិ** ដូច្នេះ ប៉ុណ្ណោះ ជាពាក្យបន្ថែមចូលមក ។

គប្បីជ្រាបវិគ្គហៈក្នុងវិចិកិច្ឆានោះដូចតទៅនេះថា

សភាវធម៌ដែលឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ប្រាសចាកការកែខ្វែង ម្យ៉ាងទៀត ឈ្មោះថា **វិចិកិច្ឆា** ព្រោះអត្ថថា ជាហេតុឲ្យមនុស្សកាលគិតសភាវធម៌ រមែងស្មុគស្មាញ គឺរមែងលំបាក ។

វិចិកិច្ឆានោះ **សំសយលក្ខណា** មានការសង្ស័យ ជាលក្ខណៈ **កម្ប-ឆរសា** មានការញាប់ញ័រ ជាកិច្ច **អនិច្ឆយបច្ចុបដ្ឋានា** មានការសម្រេចចិត្តមិនបាន ជាអាការប្រាកដ **អនេកំសគាហបច្ចុបដ្ឋានា វា** ឬមានការកាន់យកតែម្យ៉ាងមិនបាន ជាអាការប្រាកដ **អយោនិសោមនសិការបទដ្ឋានា** មានការធ្វើទុកក្នុងចិត្តដោយឧបាយមិនត្រូវទំនងជាហេតុជិត គប្បីជ្រាបថា ជាការធ្វើអន្តរាយចំពោះការបដិបត្តិ ។

ក្នុងអកុសលចិត្តដួងទី ១១ នេះ បានអកុសលធម៌ ២៣ បទ តាមលំដាប់បទ ព្រោះកាន់យកធម៌ដែលមិនត្រួតគ្នាទើបជាធម៌ ១៤ បទ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងកងធម៌ដែលចែកបាន និងចែកមិនបានដោយអំណាចនៃធម៌ទាំង ១៤ បទនោះ ។ ធម៌ ២ ប្រការ គឺមនសិការនិងឧទ្ធច្ចៈនោះឯង ជាយេវាបនកធម៌ ។

ព្រោះក្នុងនិទ្ទេសឯកគ្គតានៃចិត្ត នៃនិទ្ទេសវារៈ អកុសលចិត្តនេះទុព្វលមានត្រឹមតែឋិតិ ( គឺការតាំងនៅ ) ប្រព្រឹត្តទៅ ហេតុនោះទើបមិនត្រាស់ថា **សណ្ឋិតិ** ជាដើម តែត្រាស់បទមួយប៉ុណ្ណោះថា **ចិត្តស្ស ឋិតិ** និងដោយហេតុនោះនុ៎ះឯង សូម្បីក្នុងឧទ្ទេសវារៈ ព្រះអង្គក៏មិនត្រាស់ពាក្យជាដើមថា **សមាធិន្ទ្រិយំ** ។

គប្បីជ្រាបវិគ្គហៈក្នុងវិចិកិច្ឆានិទ្ទេស ដូចតទៅនេះថា

សភាវៈដែលឈ្មោះថា **កង្ខា** ដោយអំណាចនៃការងឿងឆ្ងល់ ។ អាការប្រព្រឹត្តទៅនៃការងឿងឆ្ងល់ ឈ្មោះថា **កង្ខាយនា** ។ ពិតណាស់ ការងឿង

ឆ្ងល់ដំបូង ឈ្មោះថា នាំមកនូវការងឿងឆ្ងល់តទៅ ។ ម្យ៉ាងទៀត កិរិយាដែលងឿងឆ្ងល់នេះ ត្រាស់ទុកដោយអំណាចនៃអាការ ។ ចិត្តដែលដល់ព្រមដោយការងឿងឆ្ងល់ ឈ្មោះថា **កង្ខាយិត** ព្រោះនាំមកនូវសេចក្ដីងឿងឆ្ងល់ ។ ភាវៈនៃកង្ខាយិតៈនោះ ឈ្មោះថា **កង្ខាយិតត្ត** ។ សភាវៈដែលឈ្មោះថា **វិមតិ** ព្រោះការគិតឃើញផ្សេង ៗ ។ វិចិកិច្ឆា មានសេចក្ដីដូចដែលពោលហើយនុ៎ះឯង ។ ដែលឈ្មោះថា **ទ្វេឡ្ហកំ** ព្រោះអត្ថថា ឃើញពីរយ៉ាងដោយអត្ថថា ញាប់ញ័រទៅ ។ ដែលឈ្មោះថា **ទ្វេធាបថោ** ព្រោះអត្ថថា ដូចផ្លូវបែកជាពីរ ដោយការហាមការបដិបត្តិ ។ ដែលឈ្មោះថា **សំសយោ** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅដោយជុំវិញ ព្រោះមិនអាចតាំងនៅក្នុងអាការៈមួយដែលប្រព្រឹត្តទៅថា នេះទៀងឬហ្ន៎ ឬថាមិនទៀងជាដើម ។ ដែលឈ្មោះថា **អនេកំសគ្គាហោ** ព្រោះអត្ថថា មិនមែនកាន់យកដោយចំណែកមួយ ព្រោះមិនអាចកាន់យកដោយចំណែកមួយ ។ ដែលឈ្មោះថា **អាសប្បនា** ព្រោះអត្ថថា វិចិកិច្ឆានោះ កាលមិនអាចដើម្បីគួសបញ្ជាក់ ទើបថយត្រឡប់ចាកអារម្មណ៍ ។ ដែលឈ្មោះថា **បរិសប្បនា** ព្រោះអត្ថថា វិចិកិច្ឆានោះ កាលមិនអាចឈមចុះ ទើបគិតបែកចេញទៅដោយជុំវិញ ។ ដែលឈ្មោះថា **អបរិយោគាហណា** ព្រោះជាសភាវៈមិនអាចឈមចុះកាន់យកបាន ។ ដែលឈ្មោះថា **ថម្ភិតត្តំ** ព្រោះជាសភាវៈដែលមិនអាចប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយអំណាចការសម្រេចចិត្តបាន អធិប្បាយថា ភាវៈនៃចិត្តជាធម្មជាតិរឹងត្អឹង ។ ពិតណាស់ វិចិកិច្ឆាកើតឡើងហើយ រមែងធ្វើចិត្តឲ្យរឹង ក៏ព្រោះ

វិចិកិច្ឆានោះ កាលកើតឡើងដូចជាការចាប់អារម្មណ៍មកជំទាស់នូវចិត្ត ហេតុនោះ ទើបទ្រង់ត្រាស់ថា **មនោវិលេខោ** ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើមានសេចក្ដីងាយទាំងអស់នោះឯង ។

**អកុសលចិត្តដួងទី ១១ ចប់**

# អកុសលចិត្តដួងទី ១២

គប្បីជ្រាបវិនិច្ឆ័យក្នុងអកុសលចិត្តដួងទី ១២ ដូចតទៅនេះថា

ក្នុងការកំណត់សម័យនៃអកុសលចិត្តដួងទី ១២ អកុសលចិត្ត ដែលឈ្មោះថា **ឧទ្ធច្ចសម្បយុត្ត** ព្រោះអត្ថថា ប្រកបដោយឧទ្ធច្ចៈ ។ ពិតណាស់អកុសលចិត្ត ដួងទី ១២ នេះ ជាកណ្ដាល ( ឧបេក្ខា ) ដោយអំណាចវេទនាក្នុងអារម្មណ៍ ៦ ជាធម្មជាតិរាយមាយ ។ ក្នុងអកុសលចិត្តដួងនេះ បទថា **ឧទ្ធច្ចំ ហោតិ** មកជំនួសវិចិកិច្ឆាក្នុងធម្មទ្ទេស ។ រមែងមានធម៌ ២៨ បទ តាមលំដាប់បទ ។ ព្រោះកាន់យកធម៌ដែលមិនត្រួតគ្នា ទើបបានធម៌ ១៤ បទ ។ គប្បីជ្រាបវិធីចែកកងធម៌ដែលចែកបាន និងចែកមិនបានដោយអំណាចនៃធម៌ទាំង ១៤ បទនោះ ។ ធម៌ទាំង ២ គឺអធិមោក្ខនិងមនសិការប៉ុណ្ណោះ ជាយេវាបនកធម៌ ។

គប្បីជ្រាបវិគ្គហៈក្នុងឧទ្ធច្ចនិទ្ទេសនៃនិទ្ទេសវារៈដូចតទៅនេះថា

បទថា **ចិត្តស្ស** គឺមិនមែនរបស់សត្វ មិនមែនរបស់បុគ្គល ។ អាការ

ដែលរាយមាយ ឈ្មោះថា ឧទ្ធច្ចៈ ។ សភាវៈដែលឈ្មោះថា **អវូបសម** ព្រោះអត្ថថា ការមិនចូលទៅស្ងប់នៃចិត្ត ។ ដែលឈ្មោះថា **ចេតសោ វិក្ខេ-បោ** ព្រោះអត្ថថា ចិត្តរាយមាយទៅ ។ បទថា **ភន្តត្តំ ចិត្តស្ស** បានដល់ភាពដែលចិត្តវិលទៅ ។ ដោយបទនេះ លោកពោលចិត្តដែលស្ទុះទៅក្នុងអារម្មណ៍មួយប៉ុណ្ណោះ ដូចយានដែលស្ទុះទៅ និងគោដែលស្ទុះទៅជាដើម ។ ពិតណាស់ ឧទ្ធច្ចៈរមែងស្ទុះទៅក្នុងអារម្មណ៍មួយ វិចិកិច្ឆារមែងស្ទុះទៅក្នុងអារម្មណ៍ផ្សេងៗ ។ ពាក្យដ៏សេសគ្រប់វារៈ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងខាងដើមនុ៎ះឯង ។

ឥឡូវនេះនឹងវិនិច្ឆ័យបកិណ្ណកៈក្នុងចិត្ត ២ ដួងនេះដូចតទៅនេះថា

កាលមានអ្នកពោលថា ឈ្មោះថា ចិត្តដែលប្រព្រឹត្តទៅក្នុងអារម្មណ៍មានប៉ុន្មាន គប្បីឆ្លើយថា មានបានទាំង ២ ដួងនោះឯង ។ បណ្ដាចិត្ត ២ ដួងនោះ ចិត្តដែលសហគតដោយវិចិកិច្ឆា រមែងប្រព្រឹត្តទៅដោយពិតប្រាកដ ចំណែកចិត្តដែលសហគតៈដោយឧទ្ធច្ចៈ បានទីអាស្រ័យ ព្រោះបានអធិមោក្ខហើយ ទើបប្រកាន់ស្ថិត ហើយក៏ប្រព្រឹត្តទៅតាមទីអាស្រ័យ ។ ដូចក្នុងកែវមណី ២ កែវមណី ១ មូល កែវមណីមួយ ៤ ជ្រុង ដែលគេឲ្យរមៀលទៅក្នុងទីចោត កែវមណីដែលមូលរមែងរមៀលទៅដោយពិតប្រាកដ ចំណែកកែវមណីដែលមានរាង ៤ ជ្រុង រមែងប្រព្រឹត្តទៅតាមទីតាំងយ៉ាងណា ពាក្យឧបមេយ្យជាគ្រឿងប្រៀបធៀបនេះ គប្បីជ្រាបយ៉ាងនោះ ។

ក្នុងអកុសលចិត្តទាំងអស់ ទ្រង់មិនបានលើកឡើងសម្ដែងការផ្សេងគ្នា

ដោយភាពថោកទាបជាដើម ព្រោះអកុសលទាំងអស់ មានសភាពថោកទាប ដោយចំណែកមួយ សហជាតាធិបតិសូម្បីបាន ក៏ទ្រង់មិនលើកឡើងសម្តែង ព្រោះមានន័យដូចទ្រង់សម្តែងទុកខាងដើមហើយ ។ ក្នុងអកុសលចិត្តទាំងនេះ ឈ្មោះថា វីមំសាធិបតិ រមែងមិនមាន ព្រោះមិនមានបញ្ញា ។ ក្នុងចិត្ត ២ ដួងចុងក្រោយ ( ដែលសម្បយុត្តដោយវិចិកិច្ឆានិងឧទ្ធច្ចៈ ) មិនមានការប្លែកគ្នាឡើយ ព្រោះហេតុអ្វី ព្រោះមិនកើតឡើងធ្វើធម៌ណាមួយឲ្យជាធំ និងព្រោះទ្រង់បដិសេធទុកក្នុងបដ្ឋានបករណ៍ហើយ ។

កាលកម្មដែលអកុសលចិត្ត ១២ ដួងនេះ ប្រមូលមកហើយវៀរអកុសលចិត្ត ដែលសហគតៈដោយឧទ្ធច្ចៈ អកុសលចិត្តដ៏សេស ១១ ដួងប៉ុណ្ណោះ រមែងទាញយកបដិសន្ធិមក ( គឺឲ្យបដិសន្ធិ ) ។

សួរថា កាលអកុសលចិត្ត ដែលសហគតដោយវិចិកិច្ឆា សូម្បីមិនបានអធិមោក្ខ មានកម្លាំងខ្សោយក៏គង់ទាញបដិសន្ធិមកបាន អកុសលចិត្តដែលសហគតដោយឧទ្ធច្ចៈ បានអធិមោក្ខ មានកម្លាំងខ្លាំង ទាញបដិសន្ធិមកមិនបាន តើព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនជាធម៌ដែលសោតាបត្តិមគ្គ គប្បីលះ ។ បើចិត្តដែលសហគតដោយឧទ្ធច្ចៈ គប្បីទាញបដិសន្ធិមកសោត ក៏គប្បីត្រាស់ទុកក្នុងវិភង្គនៃបទថា **ទស្សនេន បហាតព្វា** ព្រោះហេតុនោះ អកុសលចិត្តដ៏សេស ១១ ដួង វៀរឧទ្ធច្ចសម្បយុត្តចិត្តនោះ រមែងទាញបដិសន្ធិមកបាន ។ ពិតណាស់ កាលកម្មដែលអកុសលចិត្តដួងណាមួយ បណ្តាអកុសលចិត្តទាំងនោះប្រមូលមក ហើយបដិសន្ធិក្នុងអបាយ ៤ រមែង

មានដោយចេតនានោះ ។ បណ្ដាអកុសលវិបាកចិត្តទាំងឡាយ ចេតនាដែលសហគតៈដោយឧបេក្ខា គឺអហេតុកមនោវិញ្ញាណធាតុ រមែងកាន់យកបដិសន្ធិ ។ ការឲ្យបដិសន្ធិក្នុងអបាយ ៤ នុ៎ះឯងនៃចិត្តដែលសហគតៈដោយឧទ្ធច្ចៈក្រៅអំពីនេះក៏គប្បីមាន ។ តែព្រោះការឲ្យបដិសន្ធិក្នុងអបាយ ៤ នៃចិត្តដែលសហគតដោយឧទ្ធច្ចៈនោះមិនមាន ហេតុនោះទើបមិនត្រាស់ទុកក្នុងវិភង្គនៃពាក្យថា **ឧបេក្ខេន បហាតព្វា** ដូច្នេះ ។

**អកុសលចិត្តដួងទី ១២ ចប់**

**បទនៃអកុសលធម៌ ចប់**

# អភិធម្មបិដក

## អព្យាកតបទ

## កាមាវចរកុសលវិបាក

## អហេតុកកុសលវិបាក

## វិញ្ញាណ ៥ ដែលជាកុសលវិបាក

[ ៣៣៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ ចក្ខុវិញ្ញាណ ជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើងហើយព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាកាមាវចរកុសល ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត ឧបេក្ខា ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ ជាអព្យាក្រឹត ។

[ ៣៣៩ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។

[ ៣៤០ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសា ដែលប្រព្រឹត្តទៅក្នុងចិត្តដែលកើតអំពីសម្ផស្សនៃចក្ខុវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខ ដែលកើតអំពី

សម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ៣៨១ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា ការចងចាំ ភាពចំណាំដែលកើតអំពីសម្ផស្សនៃចក្ខុវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះសញ្ញាកើតមានក្នុងសម័យនោះ ។

[ ៣៨២ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា ការគិត ភាពគិតដែលកើតអំពីសម្ផស្សនៃចក្ខុវិញ្ញាណធាតុដ៏សមគួរ ដល់ធម៌នោះ ណាក្នុងសម័យនោះ នេះចេតនាកើតមានក្នុងសម័យនោះ ។

[ ៣៨៣ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ចក្ខុវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៨៤ ] ឧបេក្ខា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខាកើតមានក្នុងសម័យនោះ ។

[ ៣៨៥ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៤៦ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត ការដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺកវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ ចក្ខុវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះមនិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៤៧ ] ឧបេក្ខិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៤៨ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណាក្នុងសម័យនោះ នេះជីវិ-តិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៤៩ ] ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុកើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៥០ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ ចក្ខុវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យា-

កើត ។បេ។

[ ៣៥១ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៥២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ សោតវិញ្ញាណជាវិបាកប្រទ្បំដោយឧបេក្ខា មានសំឡេងជាអារម្មណ៍ កើតឡើងហើយព្រោះបានធ្វើបានសន្សំនូវកម្មជាកាមាវចរកុសល ។បេ។ ឃានវិញ្ញាណប្រទ្បំដោយឧបេក្ខា មានក្លិនជាអារម្មណ៍កើតឡើងហើយ ។បេ។ ជិវ្ហាវិញ្ញាណប្រទ្បំដោយឧបេក្ខា មានរសជាអារម្មណ៍កើតឡើងហើយ ។បេ។ កាយវិញ្ញាណប្រទ្បំដោយសុខ មានផោដ្ឋព្វៈជាអារម្មណ៍កើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត សុខ ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ សុខិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៥៣ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។

[ ៣៥៤ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តី

ឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងកាយ សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ដែលកើតអំពីសម្ផស្សនៃកាយវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃកាយ វេទនាដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ៣៥៥ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា សេចក្តីសម្គាល់ សេចក្តីចាំបានដែលកើតអំពីសម្ផស្សនៃកាយវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះសញ្ញាកើតមាន ក្នុងសម័យនោះ ។

[ ៣៥៦ ] ចេតនា កើតមាន ក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា សេចក្តីរិះគិត ការតាក់តែងដែលកើតអំពីសម្ផស្សនៃកាយវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះចេតនាកើតមានក្នុងសម័យនោះ ។

[ ៣៥៧ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងនូវអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺកវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ កាយវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះចិត្តកើតមាន ក្នុងសម័យនោះ ។

[ ៣៥៨ ] សុខ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងកាយ សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ការទទួលអា-

រម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃកាយ វេទនាដ៏ឆ្ងាញ់ពិសា ជាសុខ ដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះសុខកើតមានក្នុងសម័យនោះ ។

[ ៣៥៩ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៦០ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ កាយវិញ្ញាណ-ធាតុដ៏សមគួរដល់ធម៌នោះ ណា ក្នុងសម័យនោះ នេះមនិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៦១ ] សុខិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងកាយ សេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃកាយ វេទនាដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះសុខិ-ន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៦២ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា ក្នុងសម័យនោះ នេះជីវិ-

តិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៦៣ ] ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុកើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៦៤ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ កាយវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុកើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យា-ក្រឹត ។បេ។

[ ៣៦៥ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ បញ្ចវិញ្ញាណ មានវិបាកជាកុសល ។**

## មនោធាតុដែលជាកុសលវិបាក

[ ៣៦៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោធាតុជាវិបាក ប្រទ្បំដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផោដ្ឋព្វៈជាអារម្មណ៍ក្តី

ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗកើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាកាមាវចរកុសល ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៦៧ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។

[ ៣៦៨ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្តដែលកើតអំពីសម្ផស្សនៃមនោធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍មិនទុក្ខមិនសុខ កើតអំពីសម្ផស្សនៃចិត្ត វេទនា មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ៣៦៩ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា សេចក្តីសម្គាល់ សេចក្តីចាំបានដែលកើតអំពីសម្ផស្សនៃមនោធាតុ ដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះសញ្ញាកើតមានក្នុងសម័យនោះ ។

[ ៣៧០ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា សេចក្តីរិះគិត ការតាក់តែងដែលកើតអំពីសម្ផស្សនៃមនោធាតុដ៏សមគួរដល់

ធម៌ នោះណា ក្នុងសម័យនោះ នេះចេតនាកើតមានក្នុងសម័យនោះ ។

[ ៣៧១ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោធាតុដ៏សមគួរដល់ធម៌ នោះណា ក្នុងសម័យនោះ នេះចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៧២ ] វិតក្កៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើងណា ក្នុងសម័យនោះ នេះវិតក្កៈកើតមានក្នុងសម័យនោះ ។

[ ៣៧៣ ] វិចារៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសម្លឹងមើលណា ក្នុងសម័យនោះ នេះវិចារៈកើតមានក្នុងសម័យនោះ ។

[ ៣៧៤ ] ឧបេក្ខា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខាកើតមាន ក្នុងសម័យនោះ ។

[ ៣៧៥ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៧៦ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះមនិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៧៧ ] ឧបេក្ខិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៧៨ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា ក្នុងសម័យនោះ នេះជីវិ-តិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៧៩ ] ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុកើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៨០ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ មនោធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យា-

ក្រឹត ។បេ។

[ ៣៨១ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ មនោធាតុ មានវិបាកជាកុសល ។**

## មនោវិញ្ញាណធាតុដែលជាកុសលវិបាក សហគតដោយសោមនស្ស

[ ៣៨២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអារម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗកើតឡើងហើយ ព្រោះហេតុបានធ្វើបានសន្សំនូវកម្មជាកាមាវចរកុសល ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ បីតិ សុខ ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៨៣ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណាក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។

[ ៣៨៤ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្តដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណាក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ៣៨៥ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា ការសម្គាល់ ការចាំបាន ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះសញ្ញាកើតមានក្នុងសម័យនោះ ។

[ ៣៨៦ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា សេចក្តីរិះគិត ការតាក់តែងដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះចេតនាកើតមានក្នុងសម័យនោះ ។

[ ៣៨៧ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណាក្នុងសម័យនោះ នេះចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៨៨ ] វិតក្កៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តី

ត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកចិត្តឡើងណា ក្នុងសម័យនោះ នេះវិតក្កៈកើតមានក្នុងសម័យនោះ ។

[ ៣៨៩ ] វិចារៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសម្លឹងមើលណា ក្នុងសម័យនោះ នេះវិចារៈកើតមានក្នុងសម័យនោះ ។

[ ៣៩០ ] បីតិ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្អែតចិត្ត សេចក្ដីរីករាយ សេចក្ដីសប្បាយ សេចក្ដីស្រួលចិត្ត សេចក្ដីស្រស់ស្រាយ ការញញឹមញញែម ការបាននូវអំណរ ការអណ្ដែតអណ្ដូង សេចក្ដីត្រេកអរនៃចិត្តណា ក្នុងសម័យនោះ នេះបីតិកើតមានក្នុងសម័យនោះ ។

[ ៣៩១ ] សុខ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសាជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសុខកើតមាន ក្នុងសម័យនោះ ។

[ ៣៩២ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ការឋិតនៅណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ៣៩៣ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ចិត្ត សេចក្ដីដឹងអារម្មណ៍ សេចក្ដីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺកវន្គចិត្ត

ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញា-ណធាតុដ៏សមគួរដល់ធម៌នោះ ណាក្នុងសម័យនោះ នេះមនិន្ទ្រិយ កើតមានក្នុងសម័យនោះ ។

[ ៣៩៤ ] សោមនស្សិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត សេចក្ដីសុខប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍ដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាដ៏ឆ្ងាញ់ពិសា ជាសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះសោមនស្សិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៩៥ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ អាយុការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា ក្នុងសម័យនោះ នេះជីវិ-តិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៣៩៦ ] ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុកើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៩៧ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ មនោវិញ្ញាណធាតុ ១ ធម្មា-យតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៣៩៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ បីតិ ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើក ទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមាន ក្នុង សម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ កុសលវិបាកសោមនស្សសហគតមនោវិញ្ញាណធាតុ ។**

## មនោវិញ្ញាណធាតុដែលជាកុសលវិបាក សហគតដោយឧបេក្ខា

[ ៣៩៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោវិញ្ញាណធាតុជា វិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារ-ម្មណ៍ក្តី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗ កើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាកាមាវចរកុសល ក្នុងសម័យណា ផស្សៈក៏កើតមានក្នុង សម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតា របស់ចិត្ត មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ឬ ក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុង សម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤០០ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការ

ពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។

[ ៤០១ ] វេទនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងចិត្ត ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុ ដ៏សមគួរដល់ធម៌នោះ ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។

[ ៤០២ ] សញ្ញា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សញ្ញា ការសម្គាល់ ការចាំបាន ដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះសញ្ញាកើតមានក្នុងសម័យនោះ ។

[ ៤០៣ ] ចេតនា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចេតនា ការត្រិះរិះ ការតាក់តែងដែលកើតអំពីសម្ផស្សនៃមនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះចេតនាកើតមានក្នុងសម័យនោះ ។

[ ៤០៤ ] ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺកវគ្គចិត្ត ហៅថាមនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះចិត្តកើតមាន ក្នុងសម័យនោះ ។

[ ៤០៥ ] វិតក្កៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តី

ត្រិះរិះ ការរិះគិត តម្រិះ ការរំពឹង ការជញ្ជឹង ការលើកឡើងនូវចិត្តណា ក្នុងសម័យនោះ នេះវិតក្កៈកើតមានក្នុងសម័យនោះ ។

[ ៤០៦ ] វិចារៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការត្រួតត្រា ការពិចារណា ការពិនិត្យមើល ការសង្កេតមើល ការផ្គងនូវចិត្ត ការសម្លឹងមើលណា ក្នុងសម័យនោះ នេះវិចារៈកើតមានក្នុងសម័យនោះ ។

[ ៤០៧ ] ឧបេក្ខា កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា មិនមែនជាមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខាកើតមាន ក្នុងសម័យនោះ ។

[ ៤០៨ ] ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។

[ ៤០៩ ] មនិន្ទ្រិយ កើតមានក្នុងសម័យនោះតើដូចម្តេច ។ ចិត្ត សេចក្តីដឹងអារម្មណ៍ សេចក្តីប្រាថ្នា ហឫទ័យ ធម្មជាតដ៏ផូរផង់ គឺភវង្គចិត្ត ហៅថា មនោ មនាយតនៈ មនិន្ទ្រិយ វិញ្ញាណ វិញ្ញាណក្ខន្ធ មនោវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះណា ក្នុងសម័យនោះ នេះមនិន្ទ្រិយកើតមានក្នុងសម័យ

នោះ ។

[ ៤១០ ] ឧបេក្ខិន្ទ្រិយ កើតមានក្នុងសម័យនោះតើដូចម្តេច ។ សេចក្តីមិនធ្ងាញ់ពិសា មិនមែនជាមិនធ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងចិត្ត ការទទួលអារម្មណ៍មិនទុក្ខមិនសុខ ដែលកើតអំពីសម្ផស្សនៃចិត្ត វេទនាមិនទុក្ខមិនសុខ ដែលកើតអំពីសម្ផស្សនៃចិត្តណា ក្នុងសម័យនោះ នេះឧបេក្ខិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៤១១ ] ជីវិតិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវអរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា នេះជីវិតិន្ទ្រិយកើតមានក្នុងសម័យនោះ ។

[ ៤១២ ] ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤១៣ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ មនោវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤១៤ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ កុសលវិបាកឧបេក្ខាសហគតមនោវិញ្ញាណធាតុ ។**

# អព្យាកតបទ

## អដ្ឋកថា អហេតុកកុសលវិបាក

## វិញ្ញាណ ៥ ដែលជាកុសលវិបាក

[ ៣៣៨-៣៦៥ ] ឥឡូវនេះព្រះអង្គទ្រង់បំណងនឹងសម្ដែងចែកបទអព្យាកតធម៌ ទើបផ្ដើមពាក្យថា **កតមេ ធម្មា អព្យាកតា** ជាដើម ។

ក្នុងព្រះបាលីនោះ អព្យាកតមាន ៤ យ៉ាង គឺវិបាក កិរិយា រូប ព្រះនិព្វាន បណ្ដាអព្យាកតៈទាំងនោះ ព្រះអង្គត្រាស់បំណងយកអព្យាកតវិបាក សូម្បីក្នុងអព្យាកតវិបាក ក៏ទ្រង់បំណងយកកុសលវិបាក សូម្បីក្នុងកុសលវិបាកក៏ទ្រង់បំណងយកកាមាវចរវិបាក សូម្បីក្នុងកាមាវចរវិបាកក៏ទ្រង់បំណងយកអហេតុក សូម្បីក្នុងអហេតុកក៏ទ្រង់បំណងយកបញ្ចវិញ្ញាណ ( វិញ្ញាណ ៥ ) សូម្បីក្នុងបញ្ចវិញ្ញាណ ក៏ទ្រង់បំណងយកចក្ខុវិញ្ញាណតាមលំដាប់ទ្វារ ដើម្បីទ្រង់សម្ដែងការកើតឡើងនៃចក្ខុវិញ្ញាណនោះ ដោយអំណាចកម្មប្បច្ច័យ ដែលមិនទូទៅប៉ុណ្ណោះ វៀរសាធារណប្បច្ច័យតាមទ្វារ និងអារម្មណ៍ជាដើម ទើបត្រាស់ព្រះតម្រាស់ថា **កាមាវចរស្ស កុសលស្ស កម្មស្ស កតត្តា** ជាដើម ។

បណ្ដាបទទាំងនោះ បទថា **កតត្តា** បានដល់ ព្រោះហេតុដែលធ្វើទុកហើយ ។ បទថា **ឧបចិតត្តា** បានដល់ សន្សំទូទៅហើយ គឺធ្វើឲ្យចម្រើនឡើងហើយ ។ បទថា **ចក្ខុវិញ្ញាណំ** សេចក្ដីថា ដែលឈ្មោះថា ចក្ខុវិញ្ញាណ ព្រោះអត្ថថា ជាវិញ្ញាណនៃចក្ខុដែលមានហេតុសម្រេចហើយឬវិញ្ញាណដែល

ប្រព្រឹត្តទៅតាមផ្លូវភ្នែក ឬវិញ្ញាណដែលអាស្រ័យភ្នែក សូម្បីក្នុងសោតវិញ្ញាណជាដើមខាងមុខក៏ន័យនេះឯង ។

ក្នុងវិញ្ញាណទាំង ៥ នោះ ចក្ខុវិញ្ញាណ **ចក្ខុសន្និស្សិតរូបវិជាននលក្ខណំ** មានការដឹងច្បាស់រូបារម្មណ៍ដែលអាស្រ័យចក្ខុបសាទ ជាលក្ខណៈ **រូបមត្តារម្មណរសំ** មានការទទួលអារម្មណ៍ត្រឹមតែរូប ជាកិច្ច **រូបាភិមុខភាវបច្ចុបដ្ឋានំ** មានមុខឆ្ពោះទៅកាន់រូប ជាអាការប្រាជក **រូបារម្មណាយ កិរិយមនោធាតុយា អបគមបទដ្ឋានំ** មានការទៅប្រាសនៃកិរិយាមនោធាតុដែលមានរូបជាអារម្មណ៍ ជាហេតុជិត ។

សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ដែលនឹងមកខាងមុខ ក៏មានការដឹងច្បាស់សទ្ទារម្មណ៍ជាដើម ដែលអាស្រ័យសោតៈបសាទជាដើមជាលក្ខណៈ មានការទទួលអារម្មណ៍ត្រឹមតែសំឡេងជាដើមជាកិច្ច មានមុខឆ្ពោះទៅកាន់សំឡេងជាដើមជាអាការប្រាកដ មានការទៅប្រាសនៃកិរិយាមនោធាតុដែលមានសំឡេងជាដើមជាអារម្មណ៍ ជាហេតុជិត ។

ក្នុងអព្យាកតវិបាកនេះ មានបទធម៌តាមលំដាប់ ១០ បទ ពោលដោយការកាន់យកបទដែលមិនត្រួតគ្នាក៏បាន ៧ បទ ។ បណ្តាបទទាំង ៧ នោះ បទដែលចែកមិនបាន មាន ៥ បទ បទដែលចែកបាន មាន ២ បទ ។ បណ្តាបទដែលចែកបាននោះ ចិត្តដល់នូវការចែក ក្នុងទីទាំង ២ គឺដោយអំណាចនៃផស្សបញ្ចកៈ និងដោយអំណាចនៃឥន្ទ្រិយ វេទនាដល់នូវការចែកក្នុងទីទាំង ៣ គឺដោយអំណាចនៃផស្សបញ្ចកៈ អង្គឈាននិងឥន្ទ្រិយ ។

សម្បយុត្តធម៌ទាំងនេះក៏មាន ៣ ដូចគ្នា យេវាបនកធម៌មានមួយ គឺមនសិការប៉ុណ្ណោះ ។

ក្នុងនិទ្ទេសវារៈ ត្រាស់ចក្ខុវិញ្ញាណដោយវត្ថុថា **បណ្ឌរំ** ។ មែនពិតកុសល ឈ្មោះថា បណ្ឌរៈ ព្រោះខ្លួនបរិសុទ្ធ ។ អកុសល ក៏ឈ្មោះថាបណ្ឌរៈ ព្រោះផលដែលហូរចេញចាកភវង្គ វិបាកក៏ឈ្មោះថា បណ្ឌរៈ ព្រោះផូរផង់ដោយវត្ថុ ។

ក្នុងនិទ្ទេសឯកគ្គតានៃចិត្ត ត្រាស់បទតែមួយប៉ុណ្ណោះថា **ចិត្តស្ស ឋិតិ** ( ការឋិតនៅរបស់ចិត្ត ) ។ ព្រោះថា ចក្ខុវិញ្ញាណនេះ ជាចិត្តមានកម្លាំងខ្សោយក្នុងអព្យាកតវិបាកនេះ រមែងបានត្រឹមតែតាំងនៅប្រព្រឹត្តទៅប៉ុណ្ណោះ មិនអាចដល់នូវការតាំងនៅនៃចិត្ត ( សណ្ឋិតិ ) ការតាំងមាំនៃចិត្ត ( អវដ្ឋិតិ ) ក្នុងសង្គហវារៈ ទ្រង់មិនលើកអង្គឈាន និងអង្គមគ្គឡើងសម្តែង ។ ព្រោះហេតុអ្វី ព្រោះធម្មតាឈានមានខាងក្រោយវិតក្កៈ ធម្មតាមគ្គក៏មានខាងក្រោយហេតុ ។ ដោយប្រក្រតីអង្គឈាន មិនមានក្នុងចិត្តដែលមិនមានវិតក្កៈ អង្គមគ្គក៏មិនមានក្នុងអហេតុកចិត្តដូចគ្នា ព្រោះហេតុនោះ អង្គឈាននិងអង្គមគ្គ សូម្បីទាំង ២ ទើបទ្រង់មិនលើកឡើងសម្តែង ក្នុងចក្ខុវិញ្ញាណនេះ ។ សង្ខារក្ខន្ធក្នុងចក្ខុវិញ្ញាណនេះ ទ្រង់ចែកទុក ៤ អង្គ ( ផស្សៈ ចេតនា ឯកគ្គតានៃចិត្ត ជីវិតិន្ទ្រិយ ) ប៉ុណ្ណោះ ។ សុញ្ញតវារៈ ប្រព្រឹត្តទៅតាមប្រក្រតីទុំះឯង ។ សូម្បីនិទ្ទេសនៃសោតវិញ្ញាណជាដើម គប្បីជ្រាបដោយន័យនេះដូចគ្នា ។

ក្នុងវិញ្ញាណ ៥ នោះ មានសេចក្ដីប្លែកគ្នាតែមយ៉ាង គឺក្នុងចក្ខុវិញ្ញាណជាដើម ទ្រង់ចាត់ជាឧបេក្ខាវេទនា ក្នុងកាយវិញ្ញាណទ្រង់ចាត់ជាសុខវេទនា ។ សូម្បីសេចក្ដីផ្សេងគ្នានោះក៏គប្បីជ្រាបថា រមែងមានដោយអំណាចការប៉ះខ្ទប់ ព្រោះក្នុងទ្វារ ៤ មានចក្ខុទ្វារជាដើម ឧបាទារូប រមែងប៉ះខ្ទប់នឹងឧបាទារូបប៉ុណ្ណោះ កាលឧបាទារូបទាំងឯងប៉ះខ្ទប់ឧបាទារូប ការប៉ះទង្គិចកើតអំពីការប៉ះខ្ទប់ រមែងមិនមានកម្លាំង រមែងត្រឹមតែជាការប៉ះប៉ុណ្ណោះ រមែងមិនប៉ះខ្ទប់គ្នាខ្លាំង ដូចវេលាដែលគេដាក់សម្លី ៤ ដុំ ទុកលើសម្លី ៤ ដុំ ហើយយកសម្លីនុះឯងវាយ ។ វេទនារមែងតាំងនៅក្នុងឋានៈជាកណ្ដាល ( ឧបេក្ខា ) តែក្នុងកាយទ្វារ អារម្មណ៍ដែលជាមហាភូតរូបខាងក្រៅប៉ះខ្ទប់កាយបសាទដែលជាខាងក្នុងហើយ រមែងញាប់ញ័រមហាភូតរូបទាំងឡាយ ដែលជាបច្ច័យដល់បសាទរូប ដូចបុគ្គលដាក់សម្លីលើដែកទ្រនាប់ ហើយយកញញួរដំ ញញួរក៏កន្ទុងសម្លីទៅប៉ះនឹងដែកទ្រនាប់ ទើបការប៉ះទង្គិចជាសភាពមានកម្លាំងយ៉ាងណា ការប៉ះទង្គិចដែលកើតអំពីការប៉ះខ្ទប់ក៏យ៉ាងនោះដូចគ្នា ។ កាយវិញ្ញាណដែលសហគតដោយសុខ រមែងកើតឡើងក្នុងឥដ្ឋារម្មណ៍ កាយវិញ្ញាណដែលសហគតដោយទុក្ខ រមែងកើតឡើងក្នុងអនិដ្ឋារម្មណ៍ ។

វត្ថុទ្វារនិងអារម្មណ៍របស់ចិត្តទាំង ៥ នេះ រមែងមាំទាំពិត ឈ្មោះថាការប្រែប្រួលទៅមកនៃវត្ថុជាដើម ក្នុងបញ្ចវិញ្ញាណនេះរមែងមិនមាន ព្រោះថាចក្ខុវិញ្ញាណដែលជាកុសលវិបាក ធ្វើចក្ខុបសាទឲ្យជាវត្ថុហើយញ៉ាំងទស្សនកិច្ចឲ្យសម្រេចក្នុងរូបារម្មណ៍ ដែលមានសមុដ្ឋាន ៤ ដែលជាឥដ្ឋារម្មណ៍និង

ឥដ្ឋមជ្ឈត្តារម្មណ៍ តាំងនៅក្នុងចក្ខុទ្វារទើបសម្រេចផល ។ សោតវិញ្ញាណជាដើម ធ្វើសោតបសាទជាដើមឲ្យជាវត្ថុហើយ ឲ្យសម្រេចសវនកិច្ច ឃាយនកិច្ច សាយនកិច្ច និងផុសនកិច្ចក្នុងអារម្មណ៍ មានសំឡេងជាដើម ដែលជាឥដ្ឋារម្មណ៍ និងឥដ្ឋមជ្ឈត្តារម្មណ៍ តាំងនៅក្នុងសោតទ្វារជាដើម ទើបសម្រេចផល ។ ក្នុងអារម្មណ៍ទាំងនោះ សទ្ទារម្មណ៍ មានសមុដ្ឋាន ២ ប៉ុណ្ណោះ ។

# មនោធាតុដែលជាកុសលវិបាក

[ ៣៦៦-៣៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃមនោធាតុ ដូចតទៅនេះថា

ធាតុ គឺចិត្ត ឈ្មោះថា **មនោធាតុ** ដោយអត្ថថា ជាសភាវៈទទេ និងមិនមែនសត្វ ។ មនោធាតុនោះ **ចក្ខុវិញ្ញាណាទីនំ អនន្តរំ រូបាទិវិជាននលក្ខណា** មានការដឹងច្បាស់រូបារម្មណ៍ជាដើម ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើមជាលក្ខណៈ **រូបាទីនំ សម្បដិច្ឆនរសា** មានការទទួលរូបារម្មណ៍ជាដើមជាកិច្ច **តថាភាវបច្ចុបដ្ឋានា** មានភាវៈដូចការទទួលអារម្មណ៍យ៉ាងនោះជាអាការប្រាកដ **ចក្ខុវិញ្ញាណាទិអបគមបទដ្ឋានា** មានការទៅប្រាសនៃចក្ខុវិញ្ញាណជាដើមជាហេតុជិត ។ ធម្មុទ្ទេសក្នុង មនោធាតុនេះមាន ១២ បទ ពោលដោយបទដែលមិនត្រួតគ្នាមាន ៩ បទ ។ ក្នុង ៩ បទនោះ ៧ បទ ចែកមិនបាន ២ បទចែកបាន ។ យេវាបនកធម៌ មាន ២ គឺអធិមោក្ខនិង

មនសិការ ។

និទ្ទេសនៃវិតក្កៈ ព្រះអង្គទ្រង់កំណត់ឲ្យដល់ត្រឹមការលើកចិត្តឡើងកាន់អារម្មណ៍ ។ ព្រោះចិត្តដួងនេះ ជាកុសលក៏មិនមែន ជាអកុសលក៏មិនមែន ព្រោះហេតុនោះ ទើបមិនត្រាស់ថា ជាសម្មាសង្កប្បៈ ឬជាមិច្ឆាសង្កប្បៈ ។ អង្គឈានសូម្បីបានក្នុងសង្គហវារៈក៏ធ្លាក់ទៅក្នុងក្រសែនៃបញ្ចវិញ្ញាណ ព្រោះហេតុនោះទើបទ្រង់មិនលើកឡើងសម្តែង ចំណែកអង្គមគ្គរមែងមិនបានដោយពិត ព្រោះហេតុនោះទើបទ្រង់មិនលើកឡើងសម្តែង សុញ្ញតវារៈប្រព្រឹត្តទៅតាមប្រក្រតីទុំះឯង ។ ទីតាំងដែលកើតរបស់ចិត្តនេះមាំទាំ គឺហទយវត្ថុនោះឯង ។ ទ្វារនិងអារម្មណ៍មិនមាំទាំ បណ្តាទ្វារនិងអារម្មណ៍ដែលមិនមាំទាំទាំងនោះ ទ្វារនិងអារម្មណ៍ប្រែប្រួលទៅមកក៏ពិត តែក៏មានស្ថានតែមួយស្ថាននោះ គឺសម្បដិច្ឆន្នកិច្ចនោះឯង ។ ពិតណាស់ ចិត្តដួងនេះជាចិត្តទទួលអារម្មណ៍ ៥ ក្នុងបញ្ចទ្វាររមែងសម្រេចផល កាលចក្ខុវិញ្ញាណជាដើមដែលជាកុសលវិបាករលត់ហើយ សម្បដិច្ឆន្នចិត្តនោះក៏ទទួលអារម្មណ៍ជាដើមទាំងនោះទុំះឯងដែលដល់ស្ថានបន្ទាប់អំពីនោះ ។

## មនោវិញ្ញាណធាតុ ២ ដួង

[ ៣៨២-៤១៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃសន្តីរណមនោវិញ្ញាណធាតុ ដូចតទៅនេះថា

បីតិជាពាក្យបន្ថែមចូលមកក្នុងមនោវិញ្ញាណធាតុជួនទីមួយ សុខវេទនាក៏ជាសោមនស្សវេទនា ព្រោះថា មនោវិញ្ញាណធាតុ ជួនទីមួយនេះ រមែងប្រព្រឹត្តទៅ ក្នុងឥដ្ឋារម្មណ៍តែម្យ៉ាង ។ ចំណែកមនោវិញ្ញាណធាតុជួនទីពីររមែងប្រព្រឹត្តទៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ព្រោះហេតុនោះ ក្នុងមនោវិញ្ញាណ-ធាតុជួនទីពីរនេះ ទើបវេទនាជាឧបេក្ខាវេទនា ។ បទទាំងឡាយដូចគ្នានឹងបទក្នុងនិទ្ទេសនៃមនោធាតុនុ៎ះឯង ។ ក្នុងមនោវិញ្ញាណធាតុ សុខវេទនាទាំង ២ ជួនទ្រង់មិនបានលើកអង្គឈានឡើងសម្តែង ព្រោះមនោវិញ្ញាណធាតុ ២ ជួននោះ ជាធម្មជាតធ្លាក់ទៅក្នុងក្រសែនៃបញ្ចវិញ្ញាណនោះឯង អង្គមគ្គក៏ដូចគ្នាទ្រង់មិនបានលើកឡើងសម្តែង ព្រោះមិនបានដោយពិត ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយក្នុងទីទាំងអស់នុ៎ះឯង ។

មួយទៀត ពោលដោយលក្ខណៈជាដើម មនោវិញ្ញាណធាតុទាំង ២ ជាអហេតុកវិបាក ។ គប្បីជ្រាបថា **ឆឡារម្មណាវិជាននលក្ខណា** មានការដឹងច្បាស់អារម្មណ៍ ៦ ជាលក្ខណៈ **សន្តីរណាទិរសា** មានការពិចារណាអា-រម្មណ៍ជាដើមជាកិច្ច **តថាភាវបច្ចុបដ្ឋានា** មានការពិចារណាអារម្មណ៍ជាដើមយ៉ាងនោះជាអាការប្រាកដ **ហទយវត្ថុបទដ្ឋានា** មានហទយវត្ថុជាហេតុជិត ។

បណ្តាមនោវិញ្ញាណធាតុ ២ ជួននោះ ជួនទី ១ រមែងសម្រេចផលក្នុងឋានទាំង ២ ។ ពិតណាស់ កាលមនោធាតុដែលជាវិបាក ( សម្បដិច្ឆន្ន-ចិត្ត ) បន្ទាប់អំពីចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាកក្នុងទ្វារ ៥ ទទួលអារម្មណ៍នោះ ហើយរលត់ទៅ មនោវិញ្ញាណធាតុជួនទី ១ នោះ ក៏ញុំាង

សន្តីរណកិច្ចក្នុងអារម្មណ៍នោះឯងឲ្យសម្រេច តាំងនៅក្នុងទ្វារ ៥ ហើយទើបសម្រេចផល ។ ក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ ជាតទារម្មណចិត្ត រមែងសម្រេចផល ។ សេចក្តីនេះដូចម្តេច គឺប្រៀបដូចកាលទូកទទឹងផ្លូវទឹកក្នុងស្ទឹង ដែលមានក្រសែទឹកហូរខ្ចូលខ្លាញ់ ទឹកក៏ញែកជាប់តាមទូក អស់ចម្ងាយបន្តិច ហើយក៏ហូរទៅតាមក្រសែទឹកនុ៎ះឯងយ៉ាងណា សេចក្តីនេះក៏យ៉ាងនោះដូចគ្នា កាលអារម្មណ៍មានកម្លាំងក្នុងទ្វារប្រាកដច្បាស់ទៅកាន់គន្លងជវនចិត្តរមែងស្ទុះទៅ កាលជវននោះស្ទុះទៅហើយក៏ជាភារៈរបស់កវង្គ ប៉ុន្តែចិត្តនេះ មិនឲ្យភារៈដល់កវង្គទទួលអារម្មណ៍ ដែលជវនចិត្តទទួលហើយ ក៏ប្រព្រឹត្តទៅអស់ ១ វារចិត្ត ២ វារចិត្តក៏ធ្លាក់ចុះកាន់កវង្គនោះឯង ។ បណ្ឌិតគប្បីញុំាងឧបមា ឲ្យពិស្តារដោយអាការយ៉ាងនេះនុ៎ះឯង សូម្បីក្នុងហ្វូងគោដែលកំពុងឆ្លងស្ទឹង ។ មនោវិញ្ញាណធាតុដួងទីមួយនេះ ឈ្មោះថា ជាតទា-រម្មណចិត្ត ព្រោះមនោវិញ្ញាណធាតុ ទទួលអារម្មណ៍ដែលជវនចិត្តទទួលមក ហើយនោះឯង រមែងសម្រេចផល ។

ចំណែកមនោវិញ្ញាណធាតុដួងទី ២ រមែងឲ្យផលក្នុង ៥ ស្ថាន សេចក្តីនេះតើដូចម្តេច គឺក្នុងខាងដើមឲ្យផលជាបដិសន្ធិចិត្ត ក្នុងវេលាចាប់បដិសន្ធិរបស់មនុស្សដែលខ្វាក់អំពីកំណើត ថ្លង់អំពីកំណើត គអំពីកំណើត ឆ្កួតអំពីកំណើត ជាឧភតោព្យញ្ជនកនិងជាខ្ទើយក្នុងមនុស្សលោក ប្រការ ១ កាលបដិសន្ធិកន្លងទៅហើយ ក៏ឲ្យផលជាកវង្គចិត្តរហូតដល់អាយុក្ខ័យ ប្រការ ១ រមែងឲ្យផលជាសន្តីរណៈក្នុងវិថីនៃអារម្មណ៍ ៥ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ប្រការ

១ រមែងឲ្យផលជាតទារម្មណចិត្តក្នុងអារម្មណ៍ដែលមានកម្លាំង ក្នុងទ្វារ ៦ ប្រការ ១ រមែងឲ្យផលជាចុតិចិត្តក្នុងវេលាស្លាប់ប្រការ ១ មនោវិញ្ញាណ-ជាតុដួងទី ២ នេះ រមែងឲ្យផលក្នុង ៥ ស្ថាននេះ ដោយប្រការដូច្នេះ ។

## មនោវិញ្ញាណធាតុ ២ ដួង ចប់

# អភិធម្មបិដក

## មហាវិបាក ៨ ដួង

[ ៤១៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ មនោវិញ្ញាណធាតុ ជាវិបាក ប្រទ្បំដោយសោមនស្ស ប្រកបដោយញាណ កើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាកាមាវចរកុសល ។បេ។ ប្រទ្បំដោយសោ-មនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយសោ-មនស្ស ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្ដី ។បេ។ មានធម៌ជាអា-រម្មណ៍ក្ដី ឬក៏ប្រារព្ធនូវអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤១៦ ] អលោភៈ មានអព្យាក្រឹតជាមូល ។បេ។ អទោសៈ មានអព្យាក្រឹតជាមូល ។បេ។ អមោហៈ មានអព្យាក្រឹតជាមូល ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ មហាវិបាក ៨ ។**

# អដ្ឋកថា
# មហាវិបាក ៨ ដួង

[ ៤១៥-៤១៦ ] ឥឡូវនេះទ្រង់បំណាន់នឹងសម្តែងមហាវិបាកចិត្ត ៨ ដួង ទើបទ្រង់ផ្តើមព្រះតម្រាស់ជាដើមថា **កតមេ ធម្មា អព្យាកតា** ទៀត ។

ក្នុងមហាវិបាកចិត្តទាំង ៨ នោះទ្រង់សម្តែងត្រឹមតែន័យទុកក្នុងព្រះបាលី ហើយទ្រង់សង្ខេបវារៈទុកទាំងអស់ ។ បណ្ឌិតគប្បីជ្រាបសេចក្តីនៃវារៈទាំងនោះដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ។ ព្រះមានព្រះភាគ ទ្រង់បំណាន់នឹងសម្តែងសេចក្តីប្លែកគ្នាក្នុងមហាវិបាកចិត្តទាំងនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា **អលោភោ អព្យាកតមូលំ** ដូច្នេះជាដើម ។ ព្រះតម្រាស់ណាសូម្បីមិនបានត្រាស់ទុក ព្រះតម្រាស់នោះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា

ការផ្សេងគ្នានៃកម្ម ទ្វារ កម្មបថ បុញ្ញកិរិយាវត្ថុឯណា ដែលត្រាស់ទុកក្នុងកាមាវចរកុសលចិត្តទាំងឡាយ ការផ្សេងគ្នានោះមិនមានក្នុងមហាវិបាក-ចិត្តទាំង ៨ នេះ សេចក្តីនោះព្រោះហេតុអ្វី ព្រោះមហាវិបាកចិត្ត ឲ្យវិញ្ញត្តិកើតមិនបាន ព្រោះមហាវិបាកចិត្តជាធម៌មិនឲ្យវិបាក និងព្រោះមហាវិបាកចិត្តមិនប្រព្រឹត្តទៅយ៉ាងនោះ ។ ករុណានិងមុទិតាពួកណា ដែលត្រាស់ទុកក្នុងយេវាបនកធម៌ទាំងឡាយ ករុណានិងមុទិតានោះក៏មិនមាននៅក្នុងមហាវិបាក-ចិត្តទាំងឡាយ ព្រោះករុណានិងមុទិតាមានសត្វជាអារម្មណ៍ ដ្បិតថា កាមា-វចរវិបាកចិត្តទាំងឡាយជាបរិត្តារម្មណ៍តែម្យ៉ាង ។ មិនមែនករុណានិងមុទិតាប៉ុណ្ណោះទេ ដែលមិនមាន សូម្បីវិរតិទាំងឡាយ ក៏មិនមានក្នុងវិបាកចិត្តទាំង

នេះ ។ សេចក្ដីនេះសមដូចព្រះតម្រាស់ថា សិក្ខាបទ ៥ ជាកុសលតែម្យ៉ាង ដូច្នេះ ។

ក្នុងមហាវិបាកចិត្តនេះ គប្បីជ្រាបការចែកជាអសង្ខារនិងសសង្ខារដោយកុសល និងដោយការផ្សេងគ្នានៃបច្ច័យ ។ ពិតណាស់ កុសលចិត្តជាអសង្ខារិក វិបាកចិត្តក៏ជាអសង្ខារិកដូចគ្នា កុសលចិត្តជាសសង្ខារិក វិបាកចិត្តក៏ជាសសង្ខារិក ។ មួយទៀត វិបាកចិត្តដែលកើតឡើងដោយបច្ច័យ ដែលមានកម្លាំងជាអសង្ខារិក ដែលកើតឡើងដោយបច្ច័យក្រៅនេះជាសសង្ខារិក ។ ក្នុងការផ្សេងគ្នានៃហីនជាដើម មហាវិបាកចិត្តទាំងនេះ មិនឈ្មោះថា ហីនមជ្ឈិមនិងបណីត ព្រោះហីនជាដើម មិនសម្រេចហើយដោយធម៌ មានឆន្ទៈជាដើម ដែលថោកទាប កណ្ដាល និងបណីត ។ តែកុសលចិត្តថោកទាប វិបាកចិត្តក៏ថោកទាប កុសលចិត្តជាកណ្ដាល វិបាកចិត្តក៏ជាកណ្ដាល កុសលចិត្តបណីត វិបាកចិត្តក៏បណីត ។ ក្នុងមហាវិបាកចិត្តទាំងនេះ សូម្បីធម៌ដែលជាអធិបតីទាំងឡាយក៏មិនមាន ។ តើព្រោះហេតុអ្វី ព្រោះមហាវិបាកចិត្តមិនធ្វើឆន្ទៈជាដើមឲ្យជាធំហើយកើតឡើង ។ ពាក្យដ៏សេសទាំងអស់ ដូចពាក្យដែលពោលទុកក្នុងមហាកុសលចិត្ត ៨ ដួង នុ៎ះឯង ។

ឥឡូវនេះ គប្បីជ្រាបទីជាទីឲ្យផលរបស់មហាវិបាកចិត្តទាំង ៨ នេះ ដូចតទៅនេះថា

ពិតណាស់ មហាវិបាកចិត្តទាំងនេះ រមែងឲ្យផលក្នុងឋានៈ ៤ គឺ ក្នុងបដិសន្ធិ ១ ក្នុងភវង្គ ១ ក្នុងចុតិ ១ ក្នុងតទារម្មណៈ ១ ។ ឲ្យផលដូចម្ដេច

គឺដំបូង រមែងឲ្យផលជាបដិសន្ធិចិត្ត ក្នុងវេលាបដិសន្ធិរបស់អ្នកមានបុណ្យទាំងឡាយដែលជាទុហេតុកបុគ្គល និងតិហេតុកបុគ្គល ក្នុងពួកមនុស្សនិងក្នុងពួកទេវតា ជាន់កាមាវចរ កាលបដិសន្ធិចិត្តកន្លងទៅហើយ ក៏ឲ្យផលជាភវង្គចិត្តក្នុងបវត្តិកាល រហូតដល់អាយុ ៦០ ឆ្នាំខ្លះ ៨០ ឆ្នាំខ្លះ អស់មួយអសង្ខេយ្យខ្លះ រមែងឲ្យផលជាតទារម្មណចិត្ត ក្នុងអារម្មណ៍ដែលមានកម្លាំងក្នុងទ្វារ ៦ និងរមែងឲ្យផលជាចុតិចិត្តក្នុងវេលាស្លាប់ មហាវិបាកចិត្តរមែងឲ្យផលក្នុង ៤ ឋានៈ ដោយប្រការដូច្នេះ ។

ក្នុងមហាវិបាកចិត្តទាំង ៨ នោះ ព្រះសព្វញ្ញូពោធិសត្វទាំងអស់ រមែងបដិសន្ធិដោយមហាវិបាកចិត្តដែលជាអសង្ខារិក សហគតៈដោយសោមនស្សជា**តិហេតុកៈ**ដួងទីមួយក្នុងបដិសន្ធិក្នុងភពជាតិចុងក្រោយ ។ មហាវិបាកចិត្តដួងនោះ ជាវិបាករបស់ចិត្តមានមេត្តាជាចំណែកខាងដើម ។ កាលមហាវិបាក-ចិត្ត មានមេត្តាជាចំណែកខាងដើមដួងនោះឲ្យបដិសន្ធិហើយ អាយុរមែងរាប់មិនបាន តែរមែងប្រែប្រួលទៅដោយអំណាចនៃកាល ។

ចំណែកព្រះមហាសីវត្ថេរពោលថា មហាវិបាកចិត្តដែលសហគតដោយឧបេក្ខា មានកម្លាំងជាងមហាវិបាកចិត្តដែលសហគតៈដោយសោមនស្ស ព្រះសព្វញ្ញូពោធិសត្វ រមែងបដិសន្ធិដោយមហាវិបាកចិត្តដែលសហគតៈដោយឧបេក្ខានោះ ព្រោះថា អ្នកបដិសន្ធិដោយមហាវិបាកចិត្តដែលសហគតៈដោយឧបេក្ខានោះ រមែងជាអ្នកមានអជ្ឈាស្រ័យធំ រមែងជាអ្នកមិនត្រេកអរ ក្នុងអារម្មណ៍ទាំងឡាយដ៏ជាទិព្វ ដូចព្រះថេរៈទាំងឡាយ មានព្រះបូឡូនាគត្ថេរ

អ្នកទ្រទ្រង់ព្រះត្រៃបិដកជាដើម ។ តែក្នុងអដ្ឋកថាលោកបដិសេធថា នេះជាការគាប់ចិត្តរបស់ព្រះថេរៈ សេចក្តីនេះមិនមែនដូច្នោះឡើយ ហើយពោលថា ការបំពេញប្រយោជន៍របស់ព្រះសព្វញ្ញុពោធិសត្វទាំងឡាយ ជាសភាវៈមានកម្លាំងច្រើន ព្រោះហេតុនោះទើបព្រះសព្វញ្ញុពោធិសត្វទាំងឡាយ បដិសន្ធិដោយកាមាវចរកុសលវិបាកចិត្តដែលសហគតៈដោយសោមនស្ស ជា**តិហេតុកៈ** ជាអសង្ខារិកដែលមានមេត្តាជាចំណែកខាងដើម ។

## វិបាកុទ្ធារកថា

ឥឡូវនេះគួរនឹងតាំងមាតិកាក្នុងកថា ពោលអំពីវិបាក ដូចតទៅនេះថា

ព្រះចូឡនាគត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលទុកមុនថា ក្នុងកុសល-ចេតនាមួយដួង រមែងកើតវិបាកចិត្តបាន ១៦ ដួង ក្នុងកុសលចេតនានេះឯង ជាហេតុឲ្យកើតវិបាកចិត្ត ១២ ដួងខ្លះ ជាអហេតុកចិត្ត ៨ ដួងខ្លះ ដូច្នេះ ។

ចំណែកព្រះមហាទត្តត្ថេរអ្នកនៅក្នុងមោរវាបិវិហារពោលថា ក្នុងកុសលចេតនាមួយដួង រមែងកើតវិបាកចិត្តបាន ១២ ដួង ក្នុងកុសលចេតនានេះឯង ជាហេតុឲ្យកើតវិបាកចិត្ត ១០ ដួងខ្លះ ជាអហេតុកចិត្ត ៨ ដួងខ្លះ ។

តែព្រះមហាធម្មរក្ខិតត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា ក្នុងកុសល-ចេតនាមួយដួង រមែងកើតវិបាកចិត្ត ១០ ដួង ក្នុងកុសលចេតនានេះឯង ជាអហេតុកចិត្ត ៨ ដួង ។

ក្នុងឋានៈនេះ ព្រះថេរៈទាំងនោះកាន់យករឿង ឈ្មោះថា សាកេតកបញ្ហា ។ បានឮថា ពួកឧបាសកអ្នកនៅក្នុងនគរសាកេត អង្គុយក្នុងសាលាតាំងបញ្ហាថា ក្នុងកម្មដែលប្រកបហើយដោយចេតនាមួយដួង មានបដិសន្ធិតែមួយ ឬច្រើនយ៉ាង មិនអាចវិនិច្ឆ័យបាន ទើបនាំគ្នាទៅសួរព្រះថេរៈអ្នកទ្រទ្រង់ព្រះអភិធម្ម ។ ព្រះថេរៈទាំងឡាយ ឲ្យពួកឧបាសកទាំងនោះ ព្រមទទួលដោយពាក្យថា ពន្លកមួយប៉ុណ្ណោះ រមែងចេញពីគ្រាប់ស្វាយតែមួយយ៉ាងណា បដិសន្ធិក៏មានតែមួយប៉ុណ្ណោះក៏យ៉ាងនោះ ។ ក្នុងថ្ងៃតមកក៏តាំងបញ្ហាថា ក្នុងកម្មដែលបុគ្គលប្រកបហើយ ដោយចេតនាផ្សេងៗ រមែងមានបដិសន្ធិផ្សេងៗ ឬមានបដិសន្ធិមួយ ដូច្នេះ កាលមិនអាចវិនិច្ឆ័យបានទើបនាំគ្នាទៅសួរព្រះថេរៈទាំងឡាយ ព្រះថេរៈទាំងឡាយ ញុំាងឧបាសកទាំងនោះឲ្យព្រមទទួលដោយពាក្យថា កាលគ្រាប់ស្វាយច្រើន ពន្លកក៏រមែងដុះឡើងច្រើន យ៉ាងណា បដិសន្ធិរមែងមានច្រើនក៏យ៉ាងនោះ ។

ម្យ៉ាងវិញទៀត ក្នុងឋានៈនេះ ព្រះថេរៈទាំងនោះកាន់យករឿងឈ្មោះថា ឧស្សទកិត្តនៈ ( ការសម្តែងដល់វត្ថុដែលចម្រើនឡើង ជាគោលអាង ) ព្រោះថា សត្វទាំងឡាយនេះ មានលោភៈចម្រើនឡើងខ្លះ មានទោសៈ មានមោហៈ មានអលោភៈ មានអទោសៈ មានអមោហៈ ចម្រើនឡើងខ្លះ ។ សួរថា អ្វីកំណត់ភាវៈដែលលោភៈជាដើមនោះចម្រើនឡើង ឆ្លើយថា បុព្វហេតុ រមែងកំណត់សេចក្តីផ្សេងគ្នា រមែងមានក្នុងខណៈនៃការប្រកបកម្មនុ៎ះឯង សេចក្តីនេះតើដូចម្តេច គឺក្នុងខណៈប្រកបកម្ម លោភៈរបស់បុគ្គលណាមាន

កម្លាំងខ្លាំង អលោភៈមានកម្លាំងខ្សោយ អទោសៈនិងអមោហៈ មានកម្លាំងខ្លាំង ទោសៈនិងមោហៈមានកម្លាំងខ្សោយ អលោភៈមានកម្លាំងខ្សោយរបស់បុគ្គលនោះ រមែងមិនអាចគ្របសង្កត់លោភៈបាន តែអទោសៈនិងអមោហៈមានកម្លាំងខ្លាំង រមែងអាចគ្របសង្កត់ទោសៈនិងមោហៈបាន ព្រោះហេតុនោះ បុគ្គលនោះកើតដោយអំណាចបដិសន្ធិដែលកម្មនោះឲ្យហើយ ទើបជាមនុស្សលោភលន់ ចូលចិត្តសប្បាយ មិនសូវខឹងក្រោធ ជាអ្នកមានបញ្ញា មានញាណប្រៀបដូចវក្កលិ ។

មួយទៀត ក្នុងខណៈដែលប្រកបកម្ម លោភៈនិងទោសៈ របស់បុគ្គលណាមានកម្លាំងខ្លាំង អលោភៈនិងអទោសៈមានកម្លាំងខ្សោយ អមោហៈមានកម្លាំងខ្លាំង មោហៈមានកម្លាំងខ្សោយ បុគ្គលនោះ ជាអ្នកលោភលន់ដោយន័យមុនទុំះឯង ជាអ្នកច្រើនដោយសេចក្តីក្រោធ តែជាអ្នកមានបញ្ញា មានញាណប្រៀបដូចវក្កលិ ដូចព្រះទត្តាភយត្ថេរ ។

មួយទៀត ក្នុងខណៈប្រកបកម្ម លោភៈ អទោសៈ មោហៈរបស់បុគ្គលណាមានកម្លាំងខ្លាំង ក្រៅអំពីនេះ ( អលោភៈ ទោសៈ និងអមោហៈ ) មានកម្លាំងខ្សោយ បុគ្គលនោះជាអ្នកច្រើនដោយលោភៈដោយន័យមុនទុំះឯង ជាមនុស្សល្ងង់ខ្លៅ តែជាអ្នកមានចិត្តត្រជាក់ មិនច្រើនដោយសេចក្តីក្រោធ ។

មួយទៀត ក្នុងខណៈប្រកបកម្ម លោភៈ ទោសៈ មោហៈ ធម៌ទាំង ៣ នេះ របស់បុគ្គលណាមានកម្លាំងខ្លាំង អលោភៈជាដើម មានកម្លាំងខ្សោយ បុគ្គលនោះជាអ្នកច្រើនដោយការចង់បាន តាមន័យមុនទុំះឯងផង ជាអ្នកច្រើន

ដោយការខឹងក្រោធផង ជាអ្នកល្ងង់ផង ។

មួយទៀត ក្នុងខណៈប្រកបកម្ម អលោភៈ ទោសៈ មោហៈ របស់បុគ្គលណាមានកម្លាំងខ្លាំង ធម៌ក្រៅអំពីនេះ ( លោភៈ អទោសៈ អមោហៈ ) មានកម្លាំងខ្សោយ បុគ្គលនោះមានកិលេសតិចដោយន័យមុនទុ៎ះឯង គេឃើញសូម្បីអារម្មណ៍ដ៏ជាទិព្វក៏មិនញាប់ញ័រ តែជាអ្នកច្រើនដោយសេចក្ដីក្រោធនិងមានបញ្ញាទន់ខ្សោយ ដូច្នេះ ។

មួយទៀត ក្នុងខណៈប្រកបកម្ម អលោភៈ អទោសៈ និងមោហៈរបស់បុគ្គលណា មានកម្លាំងខ្លាំង ធម៌ក្រៅអំពីនេះ ( លោភៈ ទោសៈនិងអមោហៈ ) មានកម្លាំងខ្សោយ បុគ្គលនោះជាមនុស្សមិនច្រើនដោយការចង់បានដោយន័យមុននោះឯងផង ជាបុគ្គលមានចិត្តត្រជាក់ផង តែជាអ្នកល្ងង់ខ្លៅ ។

មួយទៀត ក្នុងខណៈប្រកបកម្ម អលោភៈ ទោសៈនិងអមោហៈរបស់បុគ្គលណាមានកម្លាំងខ្លាំង ធម៌ក្រៅអំពីនេះ ( លោភៈ អទោសៈនិងមោហៈ ) មានកម្លាំងខ្សោយ បុគ្គលនោះជាអ្នកមិនច្រើនដោយការចង់បាន ដោយន័យមុនទុ៎ះឯងផង មានបញ្ញាផង តែជាអ្នកច្រើនដោយសេចក្ដីក្រោធ ។

មួយទៀត ក្នុងខណៈប្រកបកម្ម អលោភៈជាដើម គឺធម៌ទាំង ៣ របស់បុគ្គលណាមានកម្លាំងខ្លាំង លោភៈជាដើមមានកម្លាំងខ្សោយ បុគ្គលនោះជាអ្នកមិនច្រើនដោយការចង់បាន មិនច្រើនដោយការខឹងក្រោធ និងជាអ្នកមានបញ្ញា ដូចព្រះមហាសង្ឃរក្ខិតត្ថេរ ដូច្នេះ ។

ម្យ៉ាងទៀត ក្នុងឋានៈនេះ ព្រះថេរៈទាំងនោះកាន់យករឿង ឈ្មោះថា

ហេតុកិត្តនៈ ( ការសម្តែងហេតុ ជាគោលអាង ) ។ មែនពិត កម្មដែលជា **តិហេតុកៈ** រមែងឲ្យវិបាកជា**តិហេតុកៈ**ខ្លះ ជាទុហេតុកៈខ្លះ ជាអហេតុកៈខ្លះ ។ កម្មដែលជាទុហេតុកៈ រមែងមិនឲ្យវិបាកជា**តិហេតុកៈ** ឲ្យតែវិបាកក្រៅអំពីនេះ ។ ដោយកម្មដែលជា**តិហេតុកៈ** បដិសន្ធិរមែងជា**តិហេតុកៈ**ខ្លះ ជាទុ-ហេតុកៈខ្លះ មិនជាអហេតុកៈ ដោយកម្មដែលជាទុហេតុកៈ បដិសន្ធិរមែងជាទុហេតុកៈខ្លះ ជាអហេតុកៈខ្លះ មិនជា**តិហេតុកៈ** ។ កុសលកម្មដែលជាអសង្ខារិក រមែងឲ្យវិបាកជាអសង្ខារិកខ្លះ ជាសសង្ខារិកខ្លះ ។ កុសលដែលជាសសង្ខារិក រមែងឲ្យវិបាកជាសសង្ខារិកខ្លះ ជាអសង្ខារិកខ្លះ ។ វេទនាគប្បីផ្លាស់ប្តូរទៅតាមអារម្មណ៍ ។ តទារម្មណៈគប្បីកំណត់ដោយជវន ។

ឥឡូវនេះ គប្បីជ្រាបហេតុកើតវិបាក ១៦ ដួងជាដើម ក្នុងវាទៈរបស់ព្រះថេរៈនោះៗ ។ សត្វដែលបដិសន្ធិដោយមហាវិបាកចិត្តដួងទីមួយ ដូចគ្នានឹងកាមាវចរកុសលចិត្តដួងទីមួយ ចេញចាកការនៅក្នុងផ្ទៃហើយ ចូលដល់ភាពជាអ្នកអាចដើម្បីផ្តើមតាំងនៅក្នុងសំវរៈនិងអសំវរៈ កាលឥដ្ឋារម្មណ៍មកកាន់គន្លងក្នុងចក្ខុទ្វារហើយ កាលកិរិយាមនោធាតុមិនធ្វើកវង្គឲ្យផ្លាស់ប្តូរទៅប្រមាណនៃអារម្មណ៍ ដែលឈានឡើងកាន់វិថិរមែងមិនមាន ព្រោះហេតុអ្វីទើបជាដូច្នោះ ព្រោះអារម្មណ៍មានកម្លាំងខ្សោយ នេះជាមោឃវារៈ ។

បើកវង្គផ្លាស់ប្តូរទៅ ពាក្យថា កាលកិរិយាមនោធាតុញ៉ាំងកវង្គឲ្យផ្លាស់ប្តូរទៅ ចិត្តនោះមិនទាន់ដល់វោដ្ឋព្វនៈឡើយ តាំងនៅក្នុងចក្ខុវិញ្ញាណ ឬក្នុងសម្បដិច្ឆនៈ ឬក្នុងសន្តីរណៈហើយនឹងត្រឡប់ក្នុងចន្លោះ មិនមែនឋានៈដែល

មានបាន ។ តែចិត្តមួយដួងខ្វះ ពីរដួងខ្វះតាំងនៅក្នុងវោដ្ឋព្វនៈប្រព្រឹត្តទៅ ។ ចិត្តនោះ បានអាសេវនៈអំពីវោដ្ឋព្វនៈនោះហើយ តាំងនៅក្នុងឋានៈនៃជវន ហើយឈមចុះកាន់ភវង្គទៀត ចិត្តនេះរមែងបែបនេះ ព្រោះអារម្មណ៍មានកម្លាំងខ្សោយ តែវារៈនេះរមែងបានក្នុងវេលាដែលពោលពាក្យជាដើមថា រូបនេះដូចខ្ញុំឃើញហើយ សំឡេងនេះដូចខ្ញុំឮហើយ ។ នេះក៏ជាមោឃវារៈទីពីរ ។

កាលមនោធាតុនៃអារម្មណ៍ដទៃ ធ្វើភវង្គឲ្យផ្លាស់ប្តូរហើយ វីថិចិត្តទាំងឡាយ រមែងកើត ជវនរមែងស្ទុះទៅ ។ ក្នុងទីបំផុតនៃជវន ជាវារៈរបស់តទារម្មណៈ កាលតទារម្មណៈនោះមិនទាន់កើត ចិត្តក៏ឈមចុះកាន់ភវង្គ ។ ក្នុងសេចក្តីនោះ មានឧបមាដូច្នេះ ដូចកាលគេសង់ទំនប់ទប់ទឹកស្ទឹង ធ្វើឲ្យទឹកហូរទៅកាន់ព្រែកធំ ទឹករមែងហូរពេញប្រាំងព្រែកទាំងសងខាង ចំណែកដែលលើសក៏ហូរហៀរទៅតាមផ្លូវទាំងឡាយ មានផ្លូវក្តាមជាដើម ហើយក៏ហូរចុះទៅកាន់ស្ទឹងនុ៎ះឯងទៀតយ៉ាងណា សេចក្តីឧបមេយ្យនេះ គប្បីជ្រាបយ៉ាងនោះចុះ ។ ក្នុងឧបមាឧបមេយ្យនេះ វេលាដែលភវង្គវិថីប្រព្រឹត្តទៅ ដូចវេលាប្រព្រឹត្តទៅរបស់ទឹកក្នុងស្ទឹង ។ វេលាដែលកិរិយាមនោធាតុ ធ្វើភវង្គឲ្យផ្លាស់ប្តូរទៅ ដូចវេលាដែលគេធ្វើទំនប់ក្នុងស្ទឹង ការប្រព្រឹត្តទៅនៃវីថិចិត្ត ដូចវេលាដែលទឹកហូរទៅក្នុងព្រែកធំ ជវនដូចការពេញប្រាំងព្រែក ទាំងសងខាង ។ ការដែលជវនស្ទុះទៅហើយ តែកាលតទារម្មណៈមិនទាន់កើត ក៏ធ្លាក់ចុះកាន់ភវង្គទៀត ដូចការដែលទឹកហូរទៅតាមផ្លូវទាំងឡាយមានផ្លូវក្តាមជាដើម ហើយហូរទៅកាន់ស្ទឹងវិញ ចិត្តដែលឈមចុះកាន់ភវង្គយ៉ាងនេះរាប់

មិនអស់ ។ ចិត្តនេះរមែងបែបនេះ ព្រោះអារម្មណ៍មានកម្លាំងខ្សោយ នេះជាមោឃវារៈទីបី ។

បើអារម្មណ៍ដែលមានកម្លាំងខ្លាំង មកកាន់គន្លងសោត កាលកិរិយាមនោធាតុធ្វើកវង្គឲ្យផ្លាស់ប្តូរទៅហើយ ចិត្តទាំងឡាយ មានចក្ខុវិញ្ញាណជាដើម រមែងកើតឡើង ។ ក្នុងឋានៈនៃជវន កាមាវចរកុសលចិត្តដួងទីមួយជាជវនហើយក៏ស្ទុះទៅ ៦-៧ វារៈ ហើយទើបឲ្យវារៈដល់តទារម្មណៈ តទារម្មណៈកាលតាំងនៅ ក៏រមែងតាំងនៅជាមហាវិបាកចិត្ត ដូចគ្នានឹងកាមាវចរកុសលចិត្តដួងទីមួយនុ៎ះឯង មហាវិបាកចិត្តដួងនេះ មានឈ្មោះ ២ យ៉ាងគឺ មូលភវង្គ ព្រោះដូចបដិសន្ធិចិត្ត និងឈ្មោះថា តទារម្មណៈ ព្រោះចិត្តនោះទទួលអារម្មណ៍ដែលជវនចិត្តទទួលមកហើយ ។ ក្នុងឋានៈនេះវិបាកចិត្តរមែងដល់ការរាប់បាន ៤ យ៉ាងគឺ ចក្ខុវិញ្ញាណ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ តទារម្មណៈ ១ ។

កាលណាកុសលចិត្តដួងទី ២ ជាជវន កាលនោះកុសលវិបាកចិត្តដួងទី ២ ដូចគ្នានឹងកុសលចិត្តដួងទីពីរនោះ រមែងជាតទារម្មណៈ ។ សូម្បីវិបាកចិត្តដួងទី ២ នេះ រមែងបានឈ្មោះ ២ យ៉ាងគឺ ឈ្មោះថា អាគន្តុកភវង្គ ព្រោះមិនដូចគ្នានឹងបដិសន្ធិចិត្ត និងឈ្មោះថា តទារម្មណៈ ដោយន័យមុននុ៎ះឯង ។ វិបាកចិត្តដួងមុនៗ ៤ ដួង និងវិបាកចិត្តដួងនេះ រួមជាចិត្ត ៥ ដួង ។

កាលណាកុសលចិត្តដួងទី ៣ ជាជវន កាលនោះវិបាកចិត្តដួងទី ៣ ដូចគ្នានឹងកុសលចិត្តដួងទី ៣ នោះ រមែងជាតទារម្មណៈ ។ វិបាកចិត្តដួងទី ៣

នេះ រមែងបានឈ្មោះ ២ យ៉ាង គឺឈ្មោះថា អាគន្តុកភវង្គ និងតទារម្មណៈ ដោយន័យដែលពោលហើយនុ៎ះឯង ។ វិបាកចិត្តដួងមុនៗ ៥ ដួងនិងវិបាក-ចិត្តដួងនេះ រួមជាចិត្ត ៦ ដួង ។

កាលណាកុសលចិត្តដួងទី ៤ ជាជវន កាលនោះវិបាកចិត្តដួងទី ៤ ដូចគ្នានឹងកុសលចិត្តដួងទី ៤ នោះ រមែងជាតទារម្មណៈ ។ វិបាកចិត្តដួងទី ៤ នេះ រមែងបានឈ្មោះ ២ យ៉ាង គឺឈ្មោះថា អាគន្តុកភវង្គនិងតទារម្មណៈ ដោយន័យដែលពោលហើយនុ៎ះឯង វិបាកចិត្តដួងមុនៗ ៦ ដួង និងវិបាកចិត្តដួងនេះ រួមជាចិត្ត ៧ ដួង ។

កាលណាឥដ្ឋមជ្ឈត្តារម្មណ៍មកកាន់គន្លងក្នុងទ្វារនោះ កាលនោះ រមែងបានមោឃវារៈ ៣ វារៈ ដោយន័យដែលពោលទុកក្នុងឥដ្ឋារម្មណ៍នោះ ។ តែព្រោះវេទនាផ្លាស់ប្តូរទៅតាមអារម្មណ៍ ហេតុនោះក្នុងឥដ្ឋមជ្ឈត្តារម្មណ៍នោះ ទើបសន្តីរណៈសហគតៈដោយឧបេក្ខា ។ មហាវិបាកចិត្ត ដែលសហគតដោយឧបេក្ខា ៤ ដួង ក្នុងទីបំផុតនៃជវនដែលមហាកុសលចិត្តដែលសហគតដោយឧបេក្ខា ៤ ដួង រមែងជាតទារម្មណៈ ។ សូម្បីមហាវិបាកចិត្ត ដែលសហគតៈដោយឧបេក្ខាទាំង ៤ ដួងនោះ រមែងបានឈ្មោះ ២ យ៉ាង គឺ អាគន្តុកភវង្គ និងតទារម្មណៈ ដោយន័យដែលពោលហើយនុ៎ះឯង ហៅថា បិដ្ឋិកវង្គដូច្នេះក៏មាន វិបាកចិត្ត ៥ ដួងនេះ និងវិបាកចិត្ត ៧ ដួងមុន រួមជា ១២ ដួង ដោយប្រការដូច្នេះ ។ វិបាកចិត្តក្នុងចក្ខុទ្វារមាន ១២ ដួង ក្នុងសោតទ្វារជាដើមក៏មានមួយទ្វារៗ ១២ ដួង ទើបរួមជាវិបាកចិត្ត ៦០ ដោយ

បរិបូណ៌ ដោយប្រការដូច្នេះ ។

កាលធ្វើកម្មដោយកុសលចេតនាមួយដួង វិបាកចិត្ត ៦០ រមែងកើតឡើងបានដោយប្រការដូច្នេះ ។ តែកាលរាប់វិបាកចិត្តដែលមិនត្រួតគ្នា រមែងបានវិបាកចិត្ត ១៦ ដួង គឺវិបាកចិត្ត ១២ ដួង ក្នុងចក្ខុទ្វារ និងវិបាកចិត្ត ៤ ដួង គឺសោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ និងកាយ-វិញ្ញាណ ១ ។

ក្នុងឋានៈនេះលោកកាន់យកឧបមាដោយផ្លែស្វាយ បានឮថា បុរសម្នាក់ដេកទទូរក្បាលត្រង់គល់ស្វាយ ដែលមានផ្លែទុំហើយលក់ទៅ ខណៈនោះផ្លែស្វាយទុំមួយជ្រុះចាកទងធ្លាក់លើផែនដី សំឡេងខ្ទាំង ដូចចាក់ត្រចៀករបស់គេ បុរសនោះភ្ញាក់ដោយសំឡេងរបស់ផ្លែស្វាយនោះហើយបើកភ្នែកក្រឡេកមើល បន្ទាប់អំពីនោះ ទើបលាតដៃទៅចាប់យកផ្លែស្វាយ មកច្របាច់មើលហិតក្លិនហើយបរិភោគ ។

ក្នុងពាក្យឧបមានោះ វេលាដែលចិត្តនៅក្នុងភវង្គប្បវត្តិជាបថា ដូចវេលាដែលបុរសនោះដេកលក់ក្បែរគល់ស្វាយ វេលាដែលអារម្មណ៍ប៉ះខ្ទប់នឹងបសាទ ដូចវេលាដែលផ្លែស្វាយទុំជ្រុះចាកទងធ្លាក់ចុះមកបៀតបៀននូវត្រចៀក វេលាដែលកិរិយាមនោធាតុ ធ្វើភវង្គឲ្យផ្លាស់ប្តូរទៅ ដូចវេលាដែលបុរសនោះភ្ញាក់ឡើងដោយសំឡេងស្វាយធ្លាក់ វេលាដែលចក្ខុវិញ្ញាណ ធ្វើទស្សនកិច្ច ឲ្យសម្រេច ដូចវេលាបុរសនោះ បើកភ្នែកក្រឡេកមើល វេលាដែលវិបាក-មនោធាតុទទួលអារម្មណ៍ ដូចវេលាដែលបុរសលាតដៃទៅចាប់ផ្លែស្វាយនោះ

វេលាដែលវិបាកមនោវិញ្ញាណធាតុពិចារណាអារម្មណ៍ ដូចវេលាដែលបុរសចាប់ផ្លែស្វាយមកប្របាច់មើល វេលាដែលកិរិយាមនោវិញ្ញាណធាតុ កំណត់អារម្មណ៍ ដូចវេលាស្រេចក្នុងស្វាយ វេលាដែលជវនចិត្តសោយរសអារម្មណ៍ ដូចវេលាដែលបុរសនោះបរិភោគស្វាយ ។

សួរថា ឧបមានេះសម្តែងសេចក្តីអ្វី ឆ្លើយថា សម្តែងកិច្ចរបស់អារម្មណ៍ គឺការប៉ះខ្ទប់បសាទ ។ កាលអារម្មណ៍នោះមកប៉ះខ្ទប់បសាទហើយ កិច្ចរបស់កិរិយាមនោធាតុ គឺការធ្វើកវត្តចិត្តឲ្យផ្លាស់ប្តូរទៅ កិច្ចរបស់ចក្ខុវិញ្ញាណ គឺត្រឹមតែការឃើញ កិច្ចរបស់វិបាកមនោធាតុ គឺត្រឹមតែការទទួលអារម្មណ៍ កិច្ចរបស់វិបាកមនោវិញ្ញាណធាតុ គឺត្រឹមតែការពិចារណាអារម្មណ៍ កិច្ចរបស់កិរិយាមនោវិញ្ញាណធាតុ គឺត្រឹមតែការកំណត់អារម្មណ៍ ជវនតែម្យ៉ាងប៉ុណ្ណោះរមែងសោយរសនៃអារម្មណ៍ ។

ក្នុងការប្រព្រឹត្តទៅនៃចិត្តនេះ បុគ្គលណាមួយជាអ្នកធ្វើឬអ្នកបញ្ជាឲ្យធ្វើថា អ្នកចូរឈ្មោះថា កវត្ត អ្នកចូរឈ្មោះថា អាវជ្ជនៈ អ្នកចូរឈ្មោះថា ទស្សនៈ អ្នកចូរឈ្មោះថា សម្បដិច្ឆន្នៈ អ្នកចូរឈ្មោះថា សន្តីរណៈ អ្នកចូរឈ្មោះថា វោដ្ឋព្វនៈ អ្នកចូរឈ្មោះថា ជវន អ្នកចូរឈ្មោះថា តទារម្មណៈ រមែងមិនមាន ។

ក្នុងឋានៈនេះ លោកកាន់យកនិយាម ៥ គឺ ពីជនិយាម ទំនៀមរបស់ពូជ ១ ឧតុនិយាម ទំនៀមរបស់រដូវ ១ កម្មនិយាម ទំនៀមរបស់កម្ម ១ ធម្មនិយាម ទំនៀមរបស់ធម៌ ១ ចិត្តនិយាម ទំនៀមរបស់ចិត្ត ១ ។

បណ្ដានិយាមទាំង ៥ នោះ ការដែលពូជនោះៗ ឲ្យផលដូចគ្នានឹងពូជនោះ គឺវល្លិធ្វេងបោះត្រួយទៅខាងធ្វេង វល្លិទូទៅឡើងដើមឈើ បោះត្រួយទៅខាងស្ដាំ ផ្កាឈូករ័ត្នបែរមុខទៅរកព្រះអាទិត្យ ពួរជ្រៃធ្លោះមុខទៅកាន់ដើមឈើ ផ្លែដូង ( ត្រឡោកដូង ) មានប្រហោងខាងលើ ឈ្មោះថា ពីជ-និយាម ( យោជនាថា ជាធម្មតារបស់ពូជ ) ។ កាលដែលដើមឈើនោះៗចេញផ្កា ចេញផ្លែ និងមានស្លឹកខ្ចីព្រមៗគ្នាក្នុងសម័យនោះៗ ឈ្មោះថា ឧតុ-និយាម ។ កាលដែលកម្មនោះ ៗ ឲ្យផលដូចគ្នានឹងកម្មនោះ ៗ យ៉ាងនេះគឺតិហេតុកកម្មឲ្យវិបាកជា**តិហេតុកៈ** ទុហេតុកៈ និងអហេតុកៈ ។ ទុហេតុកកម្មឲ្យវិបាកជាទុហេតុកៈ និងអហេតុកៈ មិនឲ្យវិបាកជា**តិហេតុកៈ** ឈ្មោះថាកម្មនិយាម ។

ម្យ៉ាងទៀត ជាកម្មនិយាមដោយអំណាចនៃវិបាក ដូចគ្នានឹងកម្មទុំះឯងដើម្បីសម្ដែងកម្មនិយាមនោះ អាចារ្យទាំងឡាយ ពោលរឿងទុកដូច្នេះ ក្នុងសម័យនៃព្រះសម្មាសម្ពុទ្ធ ស្រុកជិតទ្វារក្រុងសាវត្ថីត្រូវភ្លើងឆេះ រង្វេលស្មៅឆេះភ្លើងសន្ធោសន្ធៅអំពីស្រុកត្រូវភ្លើងឆេះនោះ អណ្ដែតឡើងទៅពាក់កក្អែកហើរលើអាកាស ក្អែកនោះស្រែកធ្លាក់ស្លាប់លើផែនដី ។

សំពៅមួយកឿងនៅស្ងៀម សូម្បីអណ្ដែតនៅក្នុងសមុទ្រ កាលពួកជនទាំងនោះមិនឃើញវត្ថុអ្វីដែលជាប់ខាងក្រោម ទើបចាប់ស្លាករកមនុស្សកាឡ-កណ្ណី ស្លាកនោះបានធ្លាក់ទៅក្នុងដៃស្រីករិយាស្និទ្ធស្នាល របស់នាយសំពៅនោះឯង ពេលនោះជនទាំងឡាយក៏និយាយថា សូមអ្នកទាំងឡាយកុំបីវិនាស

ព្រោះហេតុតែស្រីម្នាក់ ពួកយើងនឹងបោះនាងចូលទៅក្នុងទឹក នាយសំពៅនិយាយថា យើងមិនអាចឃើញស្រីនេះ អណ្តែតទៅក្នុងទឹកបានទេ ទើបឲ្យយកឆ្នាំងដាក់ដីខ្សាច់ចងភ្ជាប់នឹងក បោះចុះទៅ ក្នុងខណៈនោះឯង សំពៅក៏អណ្តែតទៅ ដូចកូនសរដែលបាញ់ចេញទៅ ដូច្នោះ ។

ភិក្ខុមួយរូបនៅក្នុងគុហា កំពូលភ្នំធំធ្លាក់មកបិទទ្វារគុហា ក្នុងថ្ងៃទី ៧ កំពូលភ្នំនោះក៏បើកឯង ។

កាលព្រះសម្មាសម្ពុទ្ធគង់សម្តែងធម៌ ក្នុងវត្តជេតពន ពួកភិក្ខុក្រាបទូលរឿងទាំង ៣ នេះ ព្រមគ្នានោះឯង ព្រះសាស្តាត្រាស់ថា កម្មនោះមិនមែនអ្នកដទៃធ្វើ នោះជាកម្មដែលពួកជនទាំងនោះធ្វើហើយ កាលទ្រង់នាំរឿងក្នុងអតីតមកសម្តែង ទើបត្រាស់ថា ក្នុងអត្តភាពមុនក្អែកកើតជាមនុស្សមិនអាចបង្វឹកគោកៀចមួយ ទើបចងរង្វេលចំបើងត្រង់កគោដុតភ្លើង គោនោះស្លាប់ដោយហេតុនោះឯង ឥឡូវនេះក្អែកនោះសូម្បីហើរទៅតាមអាកាស កម្មនោះក៏មិនបោះបង់ ។ សូម្បីស្ត្រីនេះក៏ជាស្ត្រីម្នាក់ទុំះឯង ក្នុងអត្តភាពមុន ឆ្កែមួយស្និទ្ធស្នាលនឹងនាង កាលនាងទៅព្រៃ ក៏ទៅជាមួយ កាលមក ក៏មកជាមួយ ពួកមនុស្សទាំងឡាយដែលចេញទៅ ចំអន់នាងថា ឥឡូវនេះ ព្រានសុនខរបស់ពួកយើងចេញហើយ នាងចង្អៀតចង្អល់ចិត្តដោយសុនខនោះ កាលមិនអាចហាមសុនខបាន ទើបយកឆ្នាំងដាក់ដីខ្សាច់ចងក ហើយបោះចូលទៅក្នុងទឹក ទើបកម្មនោះមិនបោះបង់នាងក្នុងកណ្តាលសមុទ្រ ។ សូម្បីភិក្ខុនោះក៏ជានាយគោបាល ក្នុងអត្តភាពមុន កាលសត្វទន្សងចូលទៅក្នុងរូង ក៏កាប់មែក

ឈើមួយក្ដាប់បិទរន្ធចោល ខាងក្រោយអំពីនោះ ៧ ថ្ងៃ គេទើបមកបើករន្ធទន្សងនោះ មានខ្ទួនញ័រលូនចេញមក ដោយសេចក្ដីករុណា ទើបបុរសនោះមិនសម្លាប់ កម្មនោះមិនលះបង់ភិក្ខុនោះដែលចូលទៅកាន់ញកភ្នំអន្ធយនៅ ។ កាលទ្រង់ប្រជុំរឿងទាំង ៣ នេះ ដោយប្រការដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា

**ន អន្តលិក្ខេ ន សមុទ្ទមជ្ឈេ ន បព្វតានំ វិវរំ បវិស្ស**
**ន វិជ្ជតេ សោ ជគតិប្បទេសោ យត្ថដ្ឋិតោ មុច្ចេយ្យ បាបកម្មា ។**

បុគ្គលអ្នកធ្វើបាបកម្មហើយ ទោះបីចូលទៅឰដ៏អាកាស ក្នុងកណ្ដាលសមុទ្ទ កាន់ចន្លោះភ្នំទាំងឡាយ ក៏មិនគប្បីរួចចាកបាបកម្ម ព្រោះប្រទេសលើផែនដី ដែលបុគ្គលឋិតនៅហើយគប្បីរួចចាកបាបកម្មបាននោះ មិនដែលមានឡើយ ដូច្នេះ ។

និយាមនេះក៏ឈ្មោះថា កម្មនិយាមដូចគ្នា ។ រឿងដទៃៗដែលមានទំនងបែបនេះក៏គួរសម្ដែង ។

មួយទៀត ក្នុងវេលាបដិសន្ធិ ក្នុងវេលាចេញចាកព្រះឧទររបស់មាតា ក្នុងវេលាត្រាស់ដឹងអភិសម្ពោធិញ្ញាណ របស់ព្រះពោធិសត្វទាំងឡាយ ក្នុងវេលាប្រកាសព្រះធម្មចក្ក ក្នុងវេលាដែលទ្រង់ដាក់អាយុសង្ខារ ក្នុងវេលាបរិនិព្វានរបស់ព្រះតថាគត ចក្កវាឡមួយម៉ឺនញាប់ញ័រ នេះឈ្មោះថា ធម្មនិយាម ។

មួយវិញទៀត កាលអារម្មណ៍ប៉ះខ្ទប់នឹងបសាទ បុគ្គលណាមួយជាអ្នក

ធ្វើ ឬប្រើឲ្យធ្វើថា អ្នកចូរឈ្មោះថា អាវជ្ជនៈ ។បេ។ អ្នកចូរឈ្មោះថា ជវនរមែងមិនមាន ។ ពោលតាមធម្មតារបស់ខ្លួនតាំងអំពីវេលាដែលអារម្មណ៍ប៉ះខ្ទប់នឹងបសាទហើយ ចិត្តដែលជាកិរិយាមនោធាតុ ក៏ធ្វើកវត្តឲ្យផ្លាស់ប្តូរទៅចក្ខុវិញ្ញាណក៏ធ្វើទស្សនកិច្ចឲ្យសម្រេច វិបាកមនោធាតុ ក៏ធ្វើសម្បដិច្ឆន្នកិច្ចឲ្យសម្រេច វិបាកមនោវិញ្ញាណធាតុ ក៏ធ្វើសន្តីរណកិច្ចឲ្យសម្រេច កិរិយាមនោវិញ្ញាណធាតុ ក៏ធ្វើវោដ្ឋព្វនកិច្ចឲ្យសម្រេច ជវនរមែងសោយរសនៃអារម្មណ៍ នេះឈ្មោះថា ចិត្តនិយាម ក្នុងអធិការនេះ ទ្រង់បំណងយកចិត្តនិយាមនេះ ។

កាលធ្វើកម្មដោយកុសលចិត្ត ដែលជា**តិហេតុកៈ** សសង្ខារិកក្តី ដោយកុសលចិត្តដែលជាអសង្ខារិកនិងសសង្ខារិក ដែលសហគតៈដោយឧបេក្ខាក្តី ក្នុងបដិសន្ធិដែលវិបាកចិត្តដូចគ្នានឹងកុសលចិត្តនោះឲ្យផល ក៏មានន័យនេះដូចគ្នា ។ តែចិត្តដែលសហគតៈដោយឧបេក្ខា ២ ដួង បណ្ឌិតគប្បីសម្តែងការប្រព្រឹត្តទៅដោយអំណាចឥដ្ឋមជ្ឈត្តារម្មណ៍ ខាងក្រោយទើបគួរសម្តែងការប្រព្រឹត្តទៅដោយអំណាចឥដ្ឋារម្មណ៍ ។

ក្នុងទ្វារនីមួយៗ បានវិបាកចិត្ត ១២ ដួង រួមជាចិត្ត ៦០ ដួង ដោយប្រការដូច្នេះ ។ កាលរាប់ចិត្តដែលមិនត្រួតគ្នា ក៏បានវិបាកចិត្ត ១៦ ដួង ។

ក្នុងឋានៈនេះ លោកកាន់យកឧបមាដោយឃ្នាបអំពៅ ។ សេចក្តីថា ក្នុងវេលាដែលគាបអំពៅ មានអ្នកគាបអំពៅ ១១ នាក់ កាន់ឃ្នាបអំពៅ ជួបចម្ការអំពៅមួយកន្លែង ដឹងថាអំពៅនោះចាស់ហើយទើបចូលទៅរកម្ចាស់

អំពៅហើយនិយាយថា ពួកយើងស៊ីឈ្នួលគាបអំពៅ ម្ចាស់អំពៅ ឆ្លើយថា ខ្ញុំកំពុងរកពួកអ្នកដូចគ្នា ហើយនាំជនទាំងនោះទៅរោងគាបអំពៅ ពួកជនអ្នកស៊ីឈ្នួលទាំងនោះ ត្រៀមគ្រឿងគាបអំពៅ ក្នុងរោងគាបអំពៅនោះ ហើយនិយាយថា ពួកយើងមានគ្នា ១១ នាក់ គួរបានមនុស្សម្នាក់ បន្ថែមទៀត សូមលោកជួលមនុស្សមកបន្ថែម ដោយចំណែកនៃថ្លៃឈ្នួលនោះ ។ ម្ចាស់អំពៅពោលថា ខ្ញុំនេះឯងនឹងជាសម្មាញ់ជួយពួកអ្នក ហើយជញ្ជូនអំពៅដាក់ពេញរោង ជាសម្មាញ់ជួយជនទាំងនោះ ។ ជនទាំងនោះ ធ្វើកិច្ចរៀងៗខ្លួន កាលម្ចាស់ទឹកអំពៅខាប់ហើយក៏ធ្វើជាស្ករអំពៅ កាលម្ចាស់អំពៅថ្លឹងហើយឲ្យចំណែកដែលបែងចែក ក៏កាន់យកចំណែករៀងៗខ្លួន ប្រគល់រោងអំពៅឲ្យដល់ម្ចាស់អំពៅដោយឧបាយនេះឯង ធ្វើការងារក្នុងរោងអំពៅ ៤ ខួង ដទៃទៀតហើយចៀសចេញទៅ ។

ក្នុងសេចក្តីនោះបសាទទាំង ៥ គប្បីឃើញដូចរោងគាបអំពៅ ៥ កន្លែង អារម្មណ៍ ៥ គប្បីឃើញដូចចំការអំពៅ ៥ កន្លែង វិបាកចិត្ត ១១ ដួង គប្បីឃើញដូចអ្នកស៊ីឈ្នួលគាបអំពៅ ១១ នាក់ វិញ្ញាណ ៥ គប្បីឃើញដូចម្ចាស់របស់រោងគាបអំពៅ ៥ នាក់ ។ វេលាដែលវិបាកចិត្ត ១១ ដួង រួមជាមួយនឹងចក្ខុវិញ្ញាណ ធ្វើកិច្ចរៀងៗខ្លួនក្នុងរូបារម្មណ៍តាមចក្ខុទ្វារ គប្បីឃើញដូចវេលាអ្នកស៊ីឈ្នួលគាបអំពៅ ១១ នាក់ រួមជាមួយនឹងម្ចាស់របស់រោងគាបអំពៅក្នុងរោងដំបូងធ្វើការងារហើយទទួលចំណែកដែលចែក ។ ការដែលចក្ខុវិញ្ញាណមិនកន្លងទ្វារទៅ គប្បីឃើញដូចវេលាដែលម្ចាស់របស់រោង

អំពៅទទួលពេងអំពៅមកវិញ ។ វេលាដែលវិបាកចិត្ត ១១ ដួង រួមជាមួយនឹងកាយវិញ្ញាណធ្វើកិច្ចរៀងៗខ្លួនក្នុងផោដ្ឋព្វារម្មណ៍តាមកាយទ្វារ គប្បីឃើញដូចវេលាដែលអ្នកស៊ីឈ្នួលគាបអំពៅ ១១ នាក់ រួមជាមួយម្ចាស់ពេងគាបអំពៅក្នុងពេងទី ២ ទី ៣ ទី ៤ និងទី ៥ ធ្វើការងារហើយទទួលចំណែកដែលចែក ។ ការដែលកាយវិញ្ញាណមិនឈានកន្លងទ្វារគប្បីឃើញដូចវេលាដែលម្ចាស់ពេងទទួលពេងមកវិញ ។ វារៈដែលលោកពោលទុកថា បដិសន្ធិដែលជា**តិហេតុក** រមែងមានដោយតិហេតុកកម្ម មានប្រមាណប៉ុណ្ណេះ ។ ចំណែកទុហេតុកបដិសន្ធិ មានដោយតិហេតុកកម្មនោះនៅកំបាំងនៅឡើយ ។

ឥឡូវនេះគួរពោលវារៈដែលថាទុហេតុកបដិសន្ធិរមែងមានដោយទុហេតុកកម្ម ។ មែនពិត កាលធ្វើកម្មដោយចិត្តដែលជាអសង្ខារិកសហគតៈដោយសោមនស្ស ដែលជាទុហេតុកៈ សម្រាប់សត្វដែលបដិសន្ធិដោយវិបាកចិត្តដែលជាទុហេតុកៈដូចគ្នានឹងចិត្តដួងនេះនោះឯង កាលឥដ្ឋារម្មណ៍មកកាន់គន្លងចក្ខុទ្វារដោយន័យដែលពោលហើយនោះឯង មោឃវារៈរមែងមាន ៣ វារៈ ។ កាលជវនចិត្តដែលជាអសង្ខារិកសហគតៈដោយសោមនស្សដែលជាទុហេតុកៈរលត់ តទារម្មណៈ ពោលគឺមូលកវគ្គដូចគ្នានឹងជវនចិត្តនោះឯង ក៏កើតឡើង ។ កាលជវនចិត្តដែលជាសសង្ខារិករលត់ តទារម្មណៈ ពោលគឺអាគន្តុកកវគ្គដូចគ្នានឹងជវនចិត្តនុ៎ះឯង ក៏កើតឡើង ។ កាលជវនចិត្តដែលសហគតៈដោយឧបេក្ខា ២ ដួង ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍រលត់ទៅ តទារម្មណចិត្ត ២ ដួង ដូចគ្នានឹងជវនចិត្តនោះឯង ក៏កើតឡើង ។ ក្នុងអធិការនេះ

ប៉ុណ្ណោះ ក្នុងទ្វារនីមួយៗមានចិត្ត ៨ ដួង ទើបរួមជាចិត្ត ៤០ ដួង តែកាលរាប់ចិត្តដែលមិនត្រួតគ្នា រមែងបានវិបាកចិត្ត ១២ ដួង គឺ ៨ ដួង ក្នុងចក្ខុទ្វារ និង ៤ ដួងទៀត គឺសោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ ។ កាលធ្វើកម្មដោយចេតនា ១ ដួង រមែងកើតវិបាកចិត្ត ១២ ដួង ដោយប្រការដូច្នេះ ។ កថាពោលដោយការប្រៀបដោយផ្ទៃស្វាយ និងនិយាម ៥ ប្រព្រឹត្តទៅតាមប្រក្រតីនុ៎ះឯង ។ ក្នុងសត្វដែលបដិសន្ធិដោយវិបាកចិត្តដូចគ្នានឹងទុហេតុកចិត្ត ២ ដួងដ៏សេស ក៏ន័យនេះដូចគ្នា ។ ក្នុងវារៈនេះ ពោលដោយការប្រៀបធៀបនឹងអ្នកគាបអំពៅ ក៏បានអ្នកគាបអំពៅ ៧ នាក់ ។ គប្បីជ្រាបការប្រកបសេចក្តីតាមគន្លងន័យដែលពោលហើយ កាលមនុស្សអ្នកគាបអំពៅ ៧ នាក់នោះ ត្រៀមឃ្នាបអំពៅក្នុងរោងគាបអំពៅហើយ ធ្វើម្ចាស់អំពៅឲ្យជាអ្នកទី ៨ នុ៎ះឯង ។ វារៈដែលពោលទុកថា ទុហេតុកបដិសន្ធិ រមែងមានដោយទុហេតុកកម្ម មានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះជាកថាពោលដោយអហេតុកបដិសន្ធិ អធិប្បាយថា កាលធ្វើកម្មដោយកុសលចិត្តដែលជាទុហេតុកៈ ៤ ដួង ដួងណាមួយ បដិសន្ធិរបស់សត្វដែលបដិសន្ធិដោយអហេតុកៈ មនោវិញ្ញាណធាតុចិត្ត សហគតៈដោយឧបេក្ខា ជាកុសលវិបាក មិនគួរពោលថា ដូចគ្នានឹងកម្ម ។ ព្រោះកម្មជាទុហេតុកៈ ចំណែកបដិសន្ធិជាអហេតុកៈ ។ កាលសត្វបដិសន្ធិដោយអហេតុកចិត្តនោះ ដល់នូវការចម្រើនឡើងហើយ កាលឥដ្ឋមជ្ឈត្តារម្មណ៍មកកាន់

គន្ធនចក្ខុទ្វារ គប្បីជ្រាបមោឃវារៈ ៣ វារៈ ដោយន័យមុនទុំះឯង តែកាល ជវននៃកុសលចិត្តដែលជាទុហេតុកៈ ៤ ដួង ដួងណានីមួយរលត់ អហេតុក-ចិត្តរមែងតាំងនៅជាតទារម្មណៈ ។ អហេតុកចិត្តនោះ បានឈ្មោះ ២ យ៉ាង គឺមូលកវគ្គនិងតទារម្មណៈ ។ ក្នុងទីនេះ បណ្ដាចិត្តទាំងនេះគឺ ចក្ខុវិញ្ញាណ សម្បដិច្ឆនៈ សន្តីរណៈដែលសហគតៈដោយឧបេក្ខា សុម្បីតទារម្មណៈដែល សហគតៈដោយឧបេក្ខាដូចគ្នា កាន់យកមក ១ ដួង រមែងរាប់បាន ៣ ដួង ប៉ុណ្ណោះ ដោយប្រការដូច្នេះ ។ តែក្នុងឥដ្ឋារម្មណ៍ សន្តីរណៈក្តី តទារម្មណៈ ក្តី រមែងសហគតៈដោយសោមនស្សប៉ុណ្ណោះ ។ បណ្ដាចិត្តទាំងនេះ ព្រោះ កាន់យកមក ១ ដួង រួមនឹងវិបាកចិត្ត ៣ ដួងមុន ទើបជាវិបាកចិត្ត ៤ ដួង ។ ដោយប្រការដូច្នេះ ក្នុងទ្វារទាំង ៥ ទ្វារនីមួយ ៗ មានចិត្ត ៤ ដួង កាលធ្វើ កម្មដោយចេតនា ១ ដួង គប្បីជ្រាបថា រមែងកើតវិបាកចិត្ត ២០ ដួង ។ តែបើរាប់ចិត្តដែលមិនត្រួតគ្នា រមែងបានវិបាកចិត្ត ៨ ដួង គឺ ៤ ដួង ក្នុង ចក្ខុទ្វារ ៤ ដួងទៀត គឺសោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ ។ នេះឈ្មោះថា អហេតុកចិត្ត ៨ ដួង ។ អហេតុក-ចិត្ត ៨ ដួងនេះ មិនកាន់យកមនុស្សលោក ។

ចំណែកក្នុងអបាយ ៤ រមែងបានចិត្ត ៨ ដួងនេះ ក្នុងបវត្តិកាល ។ វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើម យ៉ាងនេះគឺ កាលណាព្រះមហាមោគ្គ-ល្លានត្ថេរនិម្មិតផ្កាឈូកក្នុងនរក អង្គុយនៅលើត្របកផ្កាឈូកសម្ដែងធម្មកថា ដល់ពួកសត្វនរក កាលនោះចក្ខុវិញ្ញាណដែលជាកុសលវិបាក ក៏កើតឡើង

ដល់ពួកសត្វនរកដែលឃើញព្រះថេរៈ សោតវិញ្ញាណដែលជាកុសលវិបាកក៏កើតឡើង ដល់ពួកសត្វនរកដែលស្តាប់សំឡេង ឃានវិញ្ញាណដែលជាកុសលវិបាកក៏កើតឡើង ក្នុងវេលាហិតក្លិនចីវររបស់ព្រះថេរៈដែលទៅអន្ទុយសម្រាកក្នុងពេលថ្ងៃ ត្រង់ព្រៃចន្ទន៍ ជិវ្ហាវិញ្ញាណដែលជាកុសលវិបាកក៏កើតឡើង ក្នុងវេលាដែលព្រះថេរៈបណ្តាលជាភ្លៀងឲ្យធ្លាក់រំលត់ភ្លើងនរក ហើយឲ្យផឹកទឹកដែលគួរផឹក កាយវិញ្ញាណដែលជាកុសលវិបាកក៏កើតឡើង ក្នុងវេលាដែលព្រះថេរៈបណ្តាលខ្យល់បក់មកត្រសៀក ៗ សម្បដិច្ឆន្នៈ ១ ដួងទៀត សន្តីរណៈ ២ ដួងទៀត ព្រោះហេតុនោះ ទើបជាអហេតុកចិត្ត ៨ ដួង ។ សូម្បីពួកនាគ គ្រុឌ និងវេមានិកប្រេត រមែងបដិសន្ធិដោយអកុសលវិបាកចិត្ត តែក្នុងបវត្តិកាល កុសលក៏ឲ្យផលបាន ដំរីមង្គល សេះមង្គលជាដើមរបស់ស្តេចចក្កពត្តិក៏ដូចគ្នា ។ នេះជាកថាមគ្គដោយអំណាចនៃជវនចិត្ត ដែលជាកុសលក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ទាំងឡាយ ។

តែក្នុងឥដ្ឋារម្មណ៍ កាលអកុសលចិត្តដែលសហគតៈដោយសោមនស្ស ៤ ដួង សេពជវនហើយ អហេតុកចិត្តសហគតៈដោយសោមនស្ស ដែលជាកុសលវិបាក ជាតទារម្មណៈ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ កាលអកុសលចិត្តដែលសម្បយុត្តដោយលោភៈ សហគតៈដោយឧបេក្ខា ៤ ដួង សេពជវនហើយ អហេតុកចិត្តសហគតៈដោយឧបេក្ខាដែលជាកុសលវិបាក ជាតទា-រម្មណៈ ។ ពាក្យណាដែលលោកពោលថា ជវនកំណត់តទារម្មណៈ ពាក្យនោះគប្បីជ្រាបថា លោកពោលសំដៅដល់កុសល ។

សួរថា តទារម្មណៈ កាលកើតឡើងក្នុងលំដាប់នៃជវនដែលសហគតៈដោយទោមនស្ស ចិត្តអ្វីរមែងកើត ឆ្លើយថា អហេតុកមនោវិញ្ញាណធាតុចិត្តខាងអកុសលវិបាក រមែងកើតឡើង ។

សួរថា អ្វីកំណត់ជវននេះឲ្យជាកុសលឬអកុសល ឆ្លើយថា អាវជ្ជនៈនិងវោដ្ឋព្វនៈ រមែងកំណត់ទុកដោយភាពជាកុសល ឬអកុសល ឆ្លើយថា អាវជ្ជនៈនិងវោដ្ឋព្វនៈកំណត់ ។ មែនពិត កាលអាវជ្ជនៈផ្លាស់ប្តូរមកដោយត្រូវទំនងហើយ វោដ្ឋព្វនៈកំណត់ដោយមិនត្រូវទំនង ជវននឹងជាអកុសល សេចក្តីនេះប្រព្រឹត្តទៅមិនបាន កាលអាវជ្ជនៈផ្លាស់ប្តូរមកដោយមិនត្រូវទំនងហើយ វោដ្ឋព្វនៈកំណត់ដោយត្រូវទំនង ជវននឹងជាកុសល សេចក្តីនេះប្រព្រឹត្តទៅមិនបាន ។ តែកាលអាវជ្ជនៈនិងវោដ្ឋព្វនៈទាំង ២ ផ្លាស់ប្តូរមកនឹងកំណត់ដោយត្រូវទំនង គប្បីជ្រាបថា ជវនជាកុសល បើមិនត្រូវទំនងក៏ជាអកុសល ។

សួរថា ក្នុងឥដ្ឋារម្មណ៍ កាលចិត្តសង្ស័យនិងរាយមាយ តទារម្មណៈរមែងជាចិត្តអ្វី ឆ្លើយថា ក្នុងឥដ្ឋារម្មណ៍ មានសេចក្តីសង្ស័យក្តី មិនមានសេចក្តីសង្ស័យក្តី មានសេចក្តីរាយមាយក្តី មិនមានសេចក្តីរាយមាយក្តី អហេតុកចិត្តដែលសហគតៈដោយសោមនស្ស ខាងកុសលវិបាកប៉ុណ្ណោះ ជាតទារម្មណៈ ។ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ អហេតុកចិត្តដែលសហគតៈដោយឧបេក្ខាខាងកុសលវិបាក ជាតទារម្មណៈ ។ ក្នុងការកំណត់តទារម្មណៈនេះ ការសម្តែងសេចក្តីដោយសង្ខេបនេះ ឈ្មោះថា ជាវាទៈរបស់ព្រះមហាធម្ម-

វត្ថិតត្រៃ ។ កាលជវនដែលសហគតៈដោយសោមនស្ស សេពអារម្មណ៍ហើយ គប្បីស្វែងរកតទារម្មណចិត្ត ៥ ដួង ( ដែលសហគតៈដោយសោ-មនស្ស ) កាលជវនដែលសហគតៈដោយឧបេក្ខា សេពអារម្មណ៍ហើយ គប្បីស្វែងរកតទារម្មណៈចិត្ត ៦ ដួង ( ដែលសហគតៈដោយឧបេក្ខា ) ។

បើមានពាក្យសួរថា ក្នុងកាលណា កាលបុគ្គលមានបដិសន្ធិដែលសហ-គតៈដោយសោមនស្ស ញុំាងឈានឲ្យកើតក្នុងបវត្តិកាលហើយ សាបសូន្យចាកឈានព្រោះសេចក្ដីប្រមាទ ពិចារណាថា ធម៌ដ៏ប្រណីតរបស់អញវិនាសហើយ ទោមនស្សរមែងកើតឡើងដោយអំណាចវិប្បដិសារ ក្នុងកាលនោះ ចិត្តអ្វីរមែងកើតឡើងព្រោះទោមនស្សកើតបន្ទាប់អំពីសោមនស្ស ឬសោមនស្សកើតបន្ទាប់អំពីទោមនស្ស បដិសេធហើយក្នុងគម្ពីរបដ្ឋាន កាលជវនចិត្តប្រារព្ធមហគ្គតធម៌សេពអារម្មណ៍ហើយ សូម្បីតទារម្មណ៍ក៏បដិសេធហើយក្នុងគម្ពីរបដ្ឋាននោះដូចគ្នា ។ ឆ្លើយថា អហេតុកមនោវិញ្ញាណធាតុសហគតៈដោយឧបេក្ខាដែលជាកុសលវិបាក ឬអកុសលវិបាក រមែងកើតឡើង ។

សួរថា អាវជ្ជនៈរបស់អហេតុកមនោវិញ្ញាណធាតុនោះ ធ្វើអ្វី ឆ្លើយថា កិច្ចនៃអាវជ្ជនៈរបស់អហេតុកមនោវិញ្ញាណធាតុនោះមិនមាន ដូចកិច្ចនៃអាវជ្ជនៈរបស់ភវង្គមិនមាន ។ សួរថា អាវជ្ជនៈទាំងនោះកើតឡើង ព្រោះខ្លួនបង្អោនទៅក្នុងអារម្មណ៍ ព្រោះខ្លួនធ្លាប់សេពអារម្មណ៍ និងព្រោះខ្លួនសេពអារម្មណ៍ជានិច្ចក៏ដោយចុះ អហេតុកមនោវិញ្ញាណធាតុនេះ រមែងកើតដូចម្ដេច ឆ្លើយថា កាលមិនមានអាវជ្ជនៈអហេតុកមនោវិញ្ញាណធាតុ រមែងកើតឡើងដោយ

ការបង្អោនទៅ ដោយការផ្តាច់សេពនិងដោយការដែលសេពជានិច្ច ដូចនេវ-សញ្ញានាសញ្ញាយតនៈ ដែលជាអនន្តរប្បច្ច័យដល់និរោធ ( គឺរលត់ចិត្តនិងចេតសិក ) ចិត្តដែលប្រកបដោយផលសមាបត្តិរបស់ព្រះអរិយបុគ្គលដែលចេញចាកនិរោធ អរិយមគ្គចិត្ត និងផលចិត្តដែលជាលំដាប់នៃមគ្គ ។ ពិតណាស់ ចិត្តវៀរចាកអាវជ្ជនៈ រមែងកើតឡើងបាន តែចិត្តនោះវៀរចាកអា-រម្មណ៍រមែងកើតឡើងមិនបាន ។ សួរថា កាលបើយ៉ាងនោះ អ្វីជាអារម្មណ៍របស់អហេតុកមនោវិញ្ញាណធាតុនេះ ឆ្លើយថា ធម៌ឯណានីមួយក្នុងបរិត្តធម៌ ( កាមាវចរធម៌ ) មានរូបជាដើម ។ ពិតណាស់ ក្នុងបរិត្តធម៌ មានរូបជាដើមនោះ អារម្មណ៍ណានោះឯងមកកាន់គន្លងក្នុងសម័យនោះ គប្បីជ្រាបថាចិត្តនេះរមែងកើតឡើងប្រារព្ធអារម្មណ៍នោះ ។

ឥឡូវនេះដើម្បីសេចក្ដីជាក់ច្បាស់នៃចិត្តទាំងអស់នេះ ទើបលោកពោលបកិណ្ណកន័យនេះថា

> រឿងសរសៃពីងពាង ១ រឿងនាយទ្វារ ១ រឿងក្មេងអ្នកស្រុក
> ១ រឿងស្វាយនិងម្ចាស់នៃរោងគាបអំពៅ ១ រឿងអាខ្វាក់និង
> អាខ្វិន ១ រឿងការទទួលអារម្មណ៍ដោយឧបនិស្សយប្បច្ច័យ
> និងដោយអត្ត ១ ។

បណ្ដាបកិណ្ណកន័យមានរឿងពីងពាងជាដើមទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សរសៃពីងពាង ដូចតទៅនេះថា

ពីងពាងមួយ រាយសរសៃ ៥ ទិស ធ្វើសំណាញ់ហើយដេកនៅត្រង់

កណ្តាល កាលសរសៃដែលសន្ធឹងទៅក្នុងទិសទីមួយត្រូវប៉ះដោយសត្វតូចៗ កណ្តូបឬរុយ វាក៏នឹងកម្រើកចេញចាកទីជាទីដេកទៅតាមខ្សែសំណាញ់ បឹតជីវជាតិរបស់សត្វនោះ ហើយត្រឡប់មកដេកក្នុងទីដើមនោះឯង សូម្បីក្នុងវេលាដែលសរសៃក្នុងទិសទី ២ ជាដើម ត្រូវប៉ះហើយក៏ធ្វើយ៉ាងនោះឯង ។

ក្នុងសេចក្តីនោះ បសាទទាំង ៥ គប្បីជ្រាបថា ដូចសរសៃពីងពាងដែលសន្ធឹងទៅទាំង ៥ ទិស ។ ចិត្តដូចពីងពាងដេកនៅត្រង់កណ្តាល ។ វេលាដែលអារម្មណ៍មកប៉ះខ្ទប់បសាទ ដូចវេលាដែលសត្វតូចៗជាដើម មកប៉ះនឹងសរសៃសំណាញ់ ។ វេលាដែលកិរិយាមនោធាតុ ទទួលអារម្មណ៍ដែលប៉ះខ្ទប់នឹងបសាទហើយញ៉ាំងភវង្គឲ្យផ្លាស់ប្តូរទៅ ដូចការកម្រើកនៃពីងពាងដែលដេកនៅត្រង់កណ្តាល ។ ការប្រព្រឹត្តទៅរបស់វិថិចិត្តដូចការទៅតាមសរសៃរបស់ពីងពាង ។ វេលាដែលជវនចិត្តសេពអារម្មណ៍ ដូចការចោះក្បាលបឹតជីវជាតិ ។ ការដែលចិត្តអាស្រ័យហទយវត្ថុប្រព្រឹត្តទៅ ដូចពីងពាងត្រឡប់មកដេកត្រង់កណ្តាលសំណាញ់ទៀត ។

ឧបមានេះសម្តែងឲ្យជ្រាបអ្វី សម្តែងឲ្យជ្រាបថា កាលអារម្មណ៍ប៉ះខ្ទប់នឹងបសាទហើយ ចិត្តដែលអាស្រ័យហទយរូបកើត រមែងកើតឡើងមុនចិត្តដែលអាស្រ័យបសាទរូបកើត គឺអធិប្បាយឲ្យជ្រាបថា អារម្មណ៍នីមួយៗរមែងមកកាន់គន្លងក្នុងទ្វារទាំងពីរ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា នាយទ្វារដូចតទៅនេះថា ព្រះរាជាមួយព្រះអង្គ ផ្ទុំលក់នៅលើក្រឡាព្រះបន្ទំ មហាតលិករបស់ព្រះអង្គ អង្គុយគក់

ប្របាប់ព្រះយុគលបាទ មាននាយទ្វារត្រចៀកថ្ងន់ ឈរនៅត្រង់ទ្វារ មានសេវកៈ ៣ នាក់ ឈររៀងគ្នាតាមលំដាប់ គ្រានោះមានអ្នកជនបទម្នាក់នាំយកគ្រឿងបណ្ណាការមកគោះទ្វារហៅ នាយទ្វារត្រចៀកថ្ងន់មិនបានឮសំឡេងមហាតលិកអ្នកថ្វាយការគក់ប្របាប់ព្រះយុគលបាទ ទើបឲ្យសញ្ញា ។ ដោយសញ្ញានោះទើបគេបើកទ្វារសម្លឹងមើល សេវកៈទី ១ ទទួលគ្រឿងបណ្ណាការហើយបញ្ជូនឲ្យមនុស្សទី ២ មនុស្សទី ២ បញ្ជូនឲ្យមនុស្សទី ៣ មនុស្សទី ៣ យកទៅថ្វាយព្រះរាជា ព្រះរាជាទើបទ្រង់ប្រើប្រាស់ ។

ក្នុងសេចក្ដីនោះ គប្បីឃើញជវនចិត្ត ដូចព្រះរាជាអង្គនោះ អាវជ្ជនចិត្តដូចមហាតលិកដែលគក់ប្របាប់ព្រះយុគលបាទ ។ ចក្ខុវិញ្ញាណដូចនាយទ្វារត្រចៀកថ្ងន់ ។ វិថីចិត្ត ៣ ដួង មានសម្បដិច្ឆន្នៈជាដើម ដូចសេវកៈ ៣ នាក់ ។ ការដែលអារម្មណ៍មកប៉ះខ្ទប់បសាទ ដូចអ្នកជនបទនាំយកគ្រឿងបណ្ណាការមកគោះទ្វារហៅ វេលាដែលកិរិយាមនោធាតុធ្វើកវង្គឲ្យផ្លាស់ប្ដូរទៅដូចវេលាដែលមហាតលិក ដែលគក់ប្របាប់ព្រះយុគលបាទឲ្យសញ្ញា វេលាដែលចក្ខុវិញ្ញាណធ្វើកិច្ចឃើញអារម្មណ៍ឲ្យសម្រេច ដូចវេលាដែលនាយទ្វារត្រចៀកថ្ងន់ បើកទ្វារមើលដោយសញ្ញាដែលមហាតលិកនោះឲ្យ វេលាដែលវិបាកមនោធាតុទទួលអារម្មណ៍ ដូចវេលាដែលសេវកៈទី ១ ទទួលបណ្ណាការវេលាដែលវិបាកមនោវិញ្ញាណធាតុពិចារណាអារម្មណ៍ដូចវេលាដែលសេវកៈទី ១ បញ្ជូនបណ្ណាការឲ្យសេវកៈទី ២ វេលាដែលកិរិយាមនោវិញ្ញាណធាតុកំណត់អារម្មណ៍ដូចវេលាដែលសេវកៈទី ២ បញ្ជូនបណ្ណាការឲ្យសេវកៈទី ៣

វេលាដែលវោដ្ឋព្វនចិត្តប្រគល់អារម្មណ៍ដល់ជវនចិត្ត ដូចវេលាដែលសេវកៈទី ៣ ទូលថ្វាយបណ្ណាការដល់ព្រះរាជា វេលាដែលជវនសោយរសអារម្មណ៍ ដូចវេលាដែលព្រះរាជាទ្រង់ប្រើប្រាស់ ។

ឧបមានេះ សម្តែងឲ្យជ្រាបអ្វី ឧបមានេះសម្តែងឲ្យជ្រាបថា កិច្ចរបស់អារម្មណ៍មានត្រឹមតែការប៉ះខ្ទប់បសាទប៉ុណ្ណោះ ។ កិច្ចរបស់កិរិយាមនោធាតុមានត្រឹមតែការប្តូរភវង្គប៉ុណ្ណោះ កិច្ចរបស់ចក្ខុវិញ្ញាណជាដើម មានត្រឹមតែការឃើញអារម្មណ៍ ការទទួលអារម្មណ៍ ការពិចារណាអារម្មណ៍ និងការកំណត់អារម្មណ៍ប៉ុណ្ណោះ ជវនចិត្តតែម្យ៉ាងប៉ុណ្ណោះសោយរសនៃអារម្មណ៍ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ក្មេងអ្នកស្រុក ដូចតទៅនេះថា ពួកក្មេងអ្នកស្រុកជាច្រើន លេងធូលីនៅត្រង់វាងផ្លូវ បណ្តាពួកក្មេងទាំងនោះ កុមារម្នាក់ប៉ះកហាបណៈទើបពោលថា នោះអ្វីប៉ះដៃខ្ញុំ លំដាប់នោះកុមារម្នាក់ទៀតក៏ពោលថា នោះពណ៌ស កុមារម្នាក់ទៀត ក៏ក្តាប់ទុកយ៉ាងណែនមួយអន្ទើដោយធូលី កុមារម្នាក់ទៀតពោលថា នោះជារបស់ក្រាស់ ៤ ជ្រុង ម្នាក់ទៀតពោលថា នោះកហាបណៈ លំដាប់នោះទើបពួកគេនាំកហាបណៈនោះមកឲ្យមាតា មាតាក៏នាំទៅប្រើក្នុងការងារ ។

ក្នុងសេចក្តីនោះ គប្បីយល់ឃើញការប្រព្រឹត្តទៅនៃភវង្គចិត្ត ដូចវេលាដែលពួកក្មេងជាច្រើននាំគ្នាអង្គុយលេងត្រង់វាងផ្លូវ វេលាដែលអារម្មណ៍ប៉ះខ្ទប់បសាទ ដូចវេលាដែលកហាបណៈប៉ះដៃ វេលាដែលកិរិយាមនោធាតុទទួលអារម្មណ៍នោះហើយធ្វើភវង្គឲ្យផ្លាស់ប្តូរ ដូចវេលាដែលក្មេងម្នាក់និយាយ

ថា នុ៎ះអ្វី វេលាដែលចក្ខុវិញ្ញាណធ្វើទស្សនកិច្ចឲ្យសម្រេច ដូចវេលាដែលក្មេងម្នាក់និយាយថា នុ៎ះពណ៌ស វេលាដែលវិបាកមនោធាតុទទួលអារម្មណ៍ ដូចវេលាដែលក្មេងម្នាក់កាន់កហាបណៈព្រមទាំងជូលីទុកយ៉ាងមាំ វេលាដែលវិបាកមនោវិញ្ញាណធាតុពិចារណាអារម្មណ៍ ដូចវេលាដែលក្មេងម្នាក់និយាយថា នុ៎ះជារបស់គ្រាស់បួនជ្រុង វេលាដែលកិរិយាមនោវិញ្ញាណធាតុកំណត់អារម្មណ៍ ដូចវេលាដែលក្មេងម្នាក់និយាយថា នុ៎ះកហាបណៈ គប្បីជ្រាបភាពដែលជវនចិត្តសោយរសនៃអារម្មណ៍ ដូចវេលាដែលមាតានាំកហាបណៈទៅប្រើក្នុងការងារ ។

ឧបមានេះ សម្តែងឲ្យជ្រាបអ្វី សម្តែងឲ្យជ្រាបថា កិរិយាមនោធាតុមិនឃើញឡើយរមែងធ្វើកវត្តឲ្យផ្លាស់ប្តូរទៅ វិបាកមនោធាតុក៏មិនឃើញ រមែងទទួលអារម្មណ៍ វិបាកមនោវិញ្ញាណធាតុក៏មិនឃើញ រមែងពិចារណាអារម្មណ៍ កិរិយាមនោវិញ្ញាណធាតុក៏មិនឃើញ រមែងកំណត់អារម្មណ៍ ជវនចិត្តក៏មិនឃើញ រមែងសោយរសនៃអារម្មណ៍ ចំណែកចក្ខុវិញ្ញាណប៉ុណ្ណោះរមែងធ្វើកិច្ចគឺការឃើញឲ្យសម្រេច ដូច្នេះ ។

ពាក្យថា ស្វាយនិងម្ចាស់នៃរោងគាបអំពៅនេះធ្លាប់អធិប្បាយមកហើយ ។ ពាក្យនេះពោលសំដៅយកឧបមាដោយផ្លែស្វាយ និងឧបមាដោយម្ចាស់នៃរោងគាបអំពៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អាខ្វាក់និងអាខ្វិន ដូចតទៅនេះថា បានឮថា ក្នុងសាលាជិតទ្វារនគរ មានបុរសខ្វាក់ភ្នែកអំពីកំណើត និងបុរសខ្វិន

អន្ធុយនៅ ។ ក្នុងជនទាំងពីរនោះ អាខ្វិននិយាយថា អាខ្វាក់ ព្រោះហេតុអ្វី ឯងទើបកើតទុក្ខនៅក្នុងទីនេះ ប្រទេសឯណោះ មានកិច្ចារកបានងាយ មានបាយទឹកច្រើន ឯងទៅក្នុងទីនោះនឹងរស់នៅសប្បាយមិនគួរឬ អាខ្វាក់និយាយថា ឯងគ្រាន់តែប្រាប់យើង តែឯងសោត ទៅក្នុងទីនោះនឹងរស់នៅសប្បាយមិនសមគួរឬ ។ អាខ្វិននិយាយថា អញមិនមានជើងដើរទៅ អាខ្វាក់ពោលថា អញមិនមានភ្នែកសម្រាប់មើល អាខ្វិននិយាយថា បើយ៉ាងនោះឯងជាជើង អញជាភ្នែក ។ ជនទាំងពីរក៏ព្រមព្រៀងគ្នា ហើយអាខ្វាក់ឲ្យអាខ្វិនជិះកទៅ អាខ្វិននោះអង្គុយជិះករបស់អាខ្វាក់ យកដៃឆ្វេងឱបក្បាលអាខ្វាក់ យកដៃស្តាំកំណត់ផ្លូវ ប្រាប់ថា ក្នុងទីនេះមានឫសឈើដុះទទឹងមាត់ផ្លូវ ក្នុងទីនេះមានថ្ម ឯងចូរលះបង់ផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្តាំ ឯងចូរលះបង់ផ្លូវខាងស្តាំ កាន់យកផ្លូវខាងឆ្វេង ។ ដោយប្រការដូច្នេះ ជើងជារបស់បុរសខ្វាក់អំពីកំណើត ភ្នែកជារបស់បុរសខ្វិន ជនទាំងពីរទៅហើយ កាន់ទីដែលខ្ជូនប្រាថ្នាដោយសេចក្តីព្យាយាមរួមគ្នា រស់នៅហើយជាសុខ ។

ក្នុងសេចក្តីឧបមានោះ រូបកាយគប្បីឃើញដូចបុរសខ្វាក់ភ្នែកអំពីកំណើត អរូបកាយ ( នាមកាយ ) ដូចបុរសខ្វិន ។ រូបកាយវៀរនាមកាយ ក៏មិនអាចឲ្យដល់ការកាន់ ការចាប់ និងការកម្រើកបាន ដូចវេលាដែលបុរសខ្វាក់ភ្នែក តែវៀរបុរសខ្វិន ក៏មិនកើតការតាំងចិត្តដែលនឹងធ្វើដំណើរ ទៅកាន់ប្រទេសផ្សេងៗបាន ។ អរូបកាយ ( នាមកាយ ) វៀររូបចេញ ក៏ប្រព្រឹត្តទៅមិនបានក្នុងបញ្ចវោការភព ដូចបុរសខ្វិនវៀរបុរសខ្វាក់អំពីកំណើត ក៏មិន

កើតការតាំងចិត្តដែលនឹងធ្វើដំណើរទៅកាន់ប្រទេសផ្សេងៗបាន ។ រូបធម៌និង អរូបធម៌ មានសភាពប្រព្រឹត្តទៅក្នុងកិច្ចទាំងពួងបាន ដោយការប្រកបនូវគ្នានឹងគ្នា ដូចវេលាដែលបុរសខ្វាក់និងបុរសខ្វិនទាំងពីរទៅកាន់ទីដែលខ្លួនប្រាថ្នាដោយសេចក្ដីព្យាយាមរួមគ្នា ហើយរស់នៅជាសុខ ដូច្នោះ ។ បញ្ហានេះលោកអាចារ្យពោលទុកដោយអំណាចបញ្ចវោការភព ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ការទទួលអារម្មណ៍ ដូចតទៅនេះថា

ចក្ខុរមែងទទួលអារម្មណ៍ចំពោះរូប ។ សោតៈជាដើមក៏ទទួលអារម្មណ៍ចំពោះសំឡេងជាដើម ។ ពាក្យថា ដោយឧបនិស្សយប្បច្ច័យ និងដោយអត្ថ គឺដោយឧបនិស្សយប្បច្ច័យ ( ត្រូវអាស្រ័យពិតប្រាកដខ្វះមិនបាន ) និងដោយអត្ថ ( ផលឬប្រយោជន៍ ) ។

ក្នុងសេចក្ដីថា ដោយឧបនិស្សយប្បច្ច័យនិងដោយអត្ថនោះ ចក្ខុវិញ្ញាណកើតឡើងព្រមគ្នាជាមួយនឹងសម្បយុត្តធម៌ទាំងឡាយ បានព្រោះបច្ច័យ ៤ គឺ **អសម្ភិន្នត្តា ចក្ខុស្ស** ចក្ខុបសាទមិនទាន់បែកធ្លាយ ១ **អាបាថគតត្តា រូបានំ** រូបមកកាន់គន្លង ១ **អាលោកសន្និស្សិតំ** អាស្រ័យនូវពន្លឺ ១ **មន-សិការហេតុកំ** មានមនសិការជាហេតុ ១ ។

បណ្ដាបច្ច័យទាំង ៤ នោះ ចក្ខុរបស់មនុស្សដែលស្លាប់ រមែងជារបស់បែកធ្លាយ ។ ចក្ខុរបស់មនុស្សនៅមានជីវិតត្រូវបែកទៅក្ដី ឬត្រូវទឹកប្រមាត់ ស្លេស្ម ឈាម រាំងហើយក្ដី មិនអាចជាបច្ច័យដល់ចក្ខុវិញ្ញាណ ឈ្មោះថាបែកធ្លាយទៅហើយ កាលអាចជាបច្ច័យបាន ឈ្មោះថា មិនបែកធ្លាយ ។

សូម្បីក្នុងសោតវិញ្ញាណជាដើម ក៏ន័យនេះឯង ។

ចក្ខុបសាទ សូម្បីមិនទាន់បែកធ្លាយ កាលរូបារម្មណ៍ខាងក្រៅ មិនទាន់មកកាន់គន្លងចក្ខុបសាទ ចក្ខុវិញ្ញាណក៏កើតឡើងមិនបាន កាលរូបារម្មណ៍នោះមកកាន់គន្លងហើយ កាលបច្ច័យដែលអាស្រ័យ គឺពន្លឺមិនមាន ចក្ខុ-វិញ្ញាណក៏កើតមិនបាន ។ សូម្បីបានបច្ច័យដែលអាស្រ័យ គឺពន្លឺនោះហើយ កាលកិរិយាមនោធាតុមិនធ្វើកវគ្គឲ្យផ្លាស់ប្តូរទៅ ចក្ខុវិញ្ញាណក៏កើតឡើងមិនបាន ។ ចក្ខុវិញ្ញាណកាលកើតឡើងដោយអាការយ៉ាងនេះ រមែងកើតឡើងព្រមជាមួយសម្បយុត្តធម៌ទាំងឡាយ ដោយពិត ។ ចក្ខុវិញ្ញាណបានបច្ច័យទាំង ៤ នេះឯង ទើបកើតឡើងបាន ។

សោតវិញ្ញាណ រមែងកើតឡើងព្រមជាមួយនឹងសម្បយុត្តធម៌ទាំងឡាយបានព្រោះបច្ច័យ ៤ គឺ **អសម្ភិន្នត្តា សោតស្ស** សោតបសាទមិនទាន់បែកធ្លាយ ១ **អាបាថគតត្តា សទ្ទានំ** សំឡេងទាំងឡាយមកកាន់គន្លង ១ **អាកាសសន្និស្សិតំ** អាស្រ័យអាកាស ១ **មនសិការហេតុកំ** មានមនសិការជាហេតុ ១ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យអាកាស គឺសោត-វិញ្ញាណនោះ បានទីអាស្រ័យ គឺអាកាស ទើបកើតឡើង វៀរទីអាស្រ័យ គឺអាកាសនោះ ក៏កើតឡើងមិនបាន ព្រោះកាលបុគ្គលបិទរន្ធត្រចៀក សោត-វិញ្ញាណក៏មិនប្រព្រឹត្តទៅ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុនទុះឯង ។ ក្នុងឃានវិញ្ញាណជាដើមក្រៅអំពីនេះ ក៏គប្បីជ្រាបសេចក្តី ដូចក្នុងសោត-

វិញ្ញាណនេះ ខ្ញុំនឹងពោលតែសេចក្តីដែលផ្សេងគ្នាប៉ុណ្ណោះ ។

ឃានវិញ្ញាណកើតឡើងព្រមជាមួយសម្បយុត្តធម៌ទាំងឡាយបាន ព្រោះបច្ច័យ ៤ គឺ **អសម្ភិន្នត្តា ឃានស្ស** ឃានបសាទមិនទាន់បែកធ្លាយ ១ **អាបាថគតត្តា គន្ធានំ** ក្លិនទាំងឡាយមកកាន់គន្លង ១ **វាយោសន្និស្សិតំ** អាស្រ័យខ្យល់ ១ **មនសិការហេតុកំ** មានមនសិការជាហេតុ ១ ។

បណ្តាហេតុទាំង ៤ នោះ ពាក្យថា អាស្រ័យខ្យល់ អធិប្បាយថា កាលខ្យល់នាំក្លិនទាំងឡាយ ចូលទៅកាន់រន្ធច្រមុះនុ៎ះឯង ឃានវិញ្ញាណទើបកើតឡើង កាលខ្យល់នោះមិនមាន ឃានវិញ្ញាណក៏កើតឡើងមិនបាន ។

ជិវ្ហាវិញ្ញាណ កើតឡើងព្រមជាមួយសម្បយុត្តធម៌ទាំងឡាយបាន ព្រោះបច្ច័យ ៤ គឺ **អសម្ភិន្នត្តា ជិវ្ហាយ** ជិវ្ហាបសាទមិនទាន់បែកធ្លាយ ១ **អាបាថគតត្តា រសានំ** រសទាំងឡាយមកកាន់គន្លង ១ **អាបោសន្និស្សិតំ** អាស្រ័យទឹក ១ **មនសិការហេតុកំ** មានមនសិការជាហេតុ ១ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យទឹក សេចក្តីថា បានទឹកធ្វើអណ្តាតឲ្យសើម ជិវ្ហាវិញ្ញាណទើបកើតឡើង វៀរទឹកនោះក៏កើតឡើងមិនបាន ។ ព្រោះកាលបុគ្គលស្ងួតអណ្តាត សូម្បីដាក់ខាទនីយៈដែលស្ងួតទុកត្រង់អណ្តាត ជិវ្ហាវិញ្ញាណក៏កើតឡើងមិនបាន ។

កាយវិញ្ញាណកើតព្រមជាមួយសម្បយុត្តធម៌ទាំងឡាយបាន ព្រោះបច្ច័យ ៤ គឺ **អសម្ភិន្នត្តា កាយស្ស** បសាទកាយមិនទាន់បែកធ្លាយ ១ **អាបាថគតត្តា ផោដ្ឋព្វានំ** ផោដ្ឋព្វៈទាំងឡាយមកកាន់គន្លង ១ **បថវីសន្និស្សិតំ**

អាស្រ័យដី ១ **មនសិការហេតុកំ** មានមនសិការជាហេតុ ១ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា អាស្រ័យដី បានដល់ បានទីអាស្រ័យ គឺដីដែលមានកាយបសាទជាបច្ច័យនុ៎ះឯង កាយវិញ្ញាណ ក៏កើតឡើង វៀរទីអាស្រ័យ គឺដីនោះហើយក៏កើតឡើងមិនបាន ព្រោះថា មហាភូតរូបដែលជាអារម្មណ៍ខាងក្រៅ ប៉ះខ្ទប់កាយបសាទដែលជាខាងក្នុង ត្រង់កាយទ្វារហើយ រមែងប៉ះខ្ទប់ត្រង់មហាភូតរូបទាំងឡាយ ដែលជាបច្ច័យនៃបសាទ ។

មនោវិញ្ញាណរកើតឡើងព្រមជាមួយសម្បយុត្តធម៌ទាំងឡាយបាន ព្រោះបច្ច័យ ៤ គឺ **អសម្ភិន្នត្តា មនស្ស** មនោមិនទាន់បែកធ្លាយ ១ **អាបាថគតត្តា ធម្មានំ** ធម្មារម្មណ៍ទាំងឡាយ មកកាន់គន្លង ១ **វត្ថុសន្និស្សិតំ** អាស្រ័យវត្ថុ ១ **មនសិការហេតុកំ** មានមនសិការជាហេតុ ១ ។

បណ្តាបច្ច័យទាំង ៤ នោះ ពាក្យថា **មនោ** បានដល់ ភវង្គចិត្ត អធិប្បាយថា ភវង្គចិត្តនោះបែកធ្លាយហើយក្តី មានកម្លាំងខ្សោយប្រព្រឹត្តទៅមិនអាចជាបច្ច័យដល់អាវជ្ជនចិត្តក្តី ឈ្មោះថា បែកធ្លាយហើយ តែដែលអាចជាបច្ច័យដល់អាវជ្ជនចិត្តបាន ឈ្មោះថា នៅមិនទាន់បែកធ្លាយ ។ ពាក្យថា ធម្មារម្មណ៍ទាំងឡាយមកកាន់គន្លង បានដល់ កាលធម្មារម្មណ៍ មកប្រាកដ ។ ពាក្យថា អាស្រ័យវត្ថុ បានដល់ បានទីអាស្រ័យ គឺហទយវត្ថុនោះឯងទើបមនោវិញ្ញាណកើតឡើង វៀរទីអាស្រ័យ គឺហទយវត្ថុនោះ ក៏កើតឡើងមិនបាន ។ បញ្ហានេះលោកពោលសំដៅដល់បញ្ចវោការភព ។ ពាក្យថា មាន

មនសិការជាហេតុ អធិប្បាយថា កាលកិរិយាមនោវិញ្ញាណធាតុ ធ្វើកវត្តឲ្យផ្លាស់ប្តូរទៅនោះឯង ទើបមនោវិញ្ញាណកើតឡើង ។ ការពណ៌នាឧបនិស្សយប្បច្ច័យក្នុងពាក្យនេះថា ដោយឧបនិស្សយប្បច្ច័យ និងដោយអត្ថ មានប្រមាណប៉ុណ្ណោះ ។

កាលពោលដោយអត្ថ ចក្ខុ ឈ្មោះថា ទស្សនត្ថ: ( មានការឃើញជាអត្ថ ) សោត: ឈ្មោះថា សវនត្ថ: ( មានការឮជាអត្ថ ) ឃាន: ឈ្មោះថា ឃានត្ថ: ( មានការហិតក្លិនជាអត្ថ ) ជិវ្ហា ឈ្មោះថា សាយនត្ថ: ( មានការលិទ្ធរសជាអត្ថ ) កាយ ឈ្មោះថា ផុសនត្ថ: ( មានការប៉ះខ្ទប់ជាអត្ថ ) មនោ ឈ្មោះថា វិជាននត្ថ: ( មានការដឹងជាអត្ថ ) ។ ក្នុងពាក្យទាំងនោះ មានវិគ្គហ:ដូចតទៅនេះថា ការឃើញជាអត្ថរបស់ចក្ខុវិញ្ញាណនោះ ព្រោះហេតុនោះទើបចក្ខុវិញ្ញាណនោះ ឈ្មោះថា ទស្សនត្ថ: មែនពិត ការឃើញនោះ ដែលចក្ខុនោះគប្បីឲ្យសម្រេច ព្រោះហេតុនោះ ទើបឈ្មោះថា ទស្សនត្ថ: សូម្បីក្នុងសោតវិញ្ញាណជាដើមដ៏សេស ក៏ន័យនេះឯង ។

អធិប្បាយវិបាកចិត្ត ១៦ មួយអន្លើយដោយអធិប្បាយវិបាកចិត្ត ១២ និងអហេតុក: ៨ ក្នុងវាទ:របស់ព្រះចូឡនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះជាកថាអធិប្បាយវិបាកចិត្ត ១២ ដួង ក្នុងវាទ:របស់ព្រះមហាទត្តត្ថេរ អ្នកនៅក្នុងមោរវាបីវិហារ ។ ក្នុងវាទ:នោះ សាកេតបញ្ហាឧស្សទកិត្តន ( បញ្ហាក្នុងក្រុងសាកេតសម្តែងដល់វត្ថុដែលចម្រើនឡើង ) និងការ

សម្តែងហេតុប្រព្រឹត្តទៅតាមប្រក្រតីទាំងនោះ ។ តែព្រះថេរៈនេះ ឃើញការខ្វះខាតក្នុងចិត្តដែលជាអសង្ខារិកនិងសសង្ខារិក ទើបពោលថា កម្មដែលជាអសង្ខារិក រមែងឲ្យវិបាកដែលជាអសង្ខារិកប៉ុណ្ណោះ មិនឲ្យវិបាកដែលជាសសង្ខារិក សូម្បីកម្មដែលជាសសង្ខារិក ក៏រមែងឲ្យវិបាក ជាសសង្ខារិកប៉ុណ្ណោះ មិនឲ្យវិបាកជាអសង្ខារិក ។ ព្រះថេរៈនេះ មិនពោលចិត្តនិយាមដោយជវន តែពោលវេទនានិយាមដោយអារម្មណ៍ ដោយហេតុនោះ ក្នុងវិបាកុទ្ធារកថារបស់លោកនោះ ទើបមានការអធិប្បាយវិបាកចិត្ត ១២ ដួង ក្នុងវាទៈនេះឯង មានការអធិប្បាយវិបាកចិត្ត ១០ ដួងខ្វះ អហេតុកចិត្ត ៨ ដួងខ្វះ ។

ក្នុងការអធិប្បាយវិបាកចិត្តជាដើម មានន័យដូច្នេះថា កាលធ្វើកម្មដោយចិត្តដែលជាអសង្ខារិក ជា**តិហេតុកៈ**សហគតៈដោយសោមនស្ស សម្រាប់សត្វដែលបដិសន្ធិដោយវិបាកចិត្តបែបនោះឯង ដល់នូវការចម្រើនវ័យហើយ កាលឥដ្ឋារម្មណ៍មកប្រាកដក្នុងគន្លងចក្ខុទ្វារ មោឃវារៈ ៣ វារៈ រមែងមានដោយន័យដែលធ្លាប់ពោលមកហើយនោះឯង ។ ក្នុងឥដ្ឋារម្មណ៍នោះ កាលចិត្ត ១៣ ដួងនេះ គឺចិត្តដែលសហគតដោយសោមនស្ស ខាងកុសល ៤ ដួង ចិត្តដែលសហគតៈដោយសោមនស្ស ខាងអកុសល ៤ ដួង និងចិត្តដែលសហគតៈដោយសោមនស្សខាងកិរិយាចិត្ត ៥ ដួង ដួងណាមួយសេពអារម្មណ៍ហើយ វិបាកចិត្តដែលជា**តិហេតុកៈ** ជាអសង្ខារិក សហគតៈដោយសោមនស្សក្តី វិបាកចិត្តដែលជាទុហេតុកៈ ជាអសង្ខារិកក្តី រមែងតាំងនៅជា

តទារម្មណៈនោះឯង ។ ដោយអាការៈយ៉ាងនេះ ក្នុងចក្ខុទ្វាររបស់បុគ្គលនោះ ទើបរាប់វិបាកចិត្តបាន ៥ ដួង គឺវិបាកចិត្ត ៣ ដួង មានចក្ខុវិញ្ញាណជាដើម និងតទារម្មណៈចិត្ត ២ ដួង ។

មួយទៀត កាលចិត្តដែលសហគតដោយឧបេក្ខា ១២ ដួង គឺខាងកុសល ៤ ដួង ខាងអកុសល ៤ ដួង ខាងកិរិយា ៤ ដួង ដួងណាមួយធ្វើវេទនាឲ្យប្រែប្រួលទៅតាមអារម្មណ៍ សេពអារម្មណ៍ហើយរលត់ វិបាក-ចិត្តដែលជាអសង្ខារិកជា**តិហេតុកៈ**សហគតៈដោយឧបេក្ខាក្តី វិបាកចិត្តដែលជាអសង្ខារិកជាទុហេតុកៈក្តី រមែងកើតឡើងជាតទារម្មណៈ ដោយប្រការដូច្នេះ ក្នុងចក្ខុទ្វាររបស់បុគ្គលនោះទើបរាប់ចិត្តបាន ៣ ដួងនេះ គឺសន្តីរណ-ចិត្តសហគតៈដោយឧបេក្ខា ១ តទារម្មណចិត្តទាំងនេះ ២ ដួង ។ ចិត្តទាំង ៣ ដួងនោះ រួមជាមួយចិត្ត ៥ ដួងមុន ជាចិត្ត ៨ ដួង សូម្បីក្នុងសោតទ្វារជាដើមក៏បានមួយទ្វារៗ ៨ ដួង ។ កាលធ្វើកម្មដោយចេតនា ១ ដួង ចិត្ត ៤០ ដួង រមែងកើតឡើងបាន តែកាលរាប់ចិត្តដែលមិនត្រូតគ្នា រមែងបានចិត្ត ១២ ដួង គឺ ៨ ដួងក្នុងចក្ខុទ្វារ ៤ ដួងទៀត មានសោតវិញ្ញាណជាដើម ។ ក្នុងវាទៈរបស់ព្រះមហាទត្តត្ថេរនេះ គប្បីជ្រាបមូលកវគ្គ អាគន្តុក-កវគ្គនិងកថាពោលដោយឧបមាអំពីផ្លែស្វាយ និងកថាពោលដោយនិយាម ៥ ដោយន័យដែលពោលហើយនុ៎ះឯង ។ ក្នុងកម្មដែលធ្វើដោយកុសលចិត្តដែលជាសសង្ខារិក តិហេតុកៈសហគតៈដោយសោមនស្ស ក្នុងកម្មដែលធ្វើដោយកុសលចិត្តដែលជាអសង្ខារិកនិងសសង្ខារិក ជា**តិហេតុកៈ** សហគតៈដោយ

ឧបេក្ខា ក៏ន័យនេះឯង ។

សេចក្ដីឧបមាដោយឃ្នាបអំពៅ ក្នុងវាទៈរបស់ព្រះចូឡនាគត្ថេរនោះ ក៏ជាឧបមាដែលប្រើបានដូចគ្នានោះឯង ក្នុងវាទៈរបស់ព្រះថេរៈនេះ ។ វារៈជាតិហេតុកៈបដិសន្ធិមានបានដោយតិហេតុកកម្ម លោកពោលទុកហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ចំណែកវារៈថា ទុហេតុកៈបដិសន្ធិមានបាន ( ដោយតិហេតុកកម្ម ) នៅកំបាំងនៅឡើយ ។

ឥឡូវនេះនឹងពោលដោយទុហេតុកៈបដិសន្ធិ មានបានដោយទុហេតុកកម្ម កាលធ្វើកម្មដោយចិត្តដែលជាអសង្ខារិក ទុហេតុកៈ សហគតៈដោយសោមនស្ស សម្រាប់សត្វដែលបដិសន្ធិដោយវិបាកចិត្តបែបនោះឯង ដល់នូវការចម្រើនហើយ កាលឥដ្ឋារម្មណ៍មកប្រាកដតាមចក្ខុទ្វារ មោឃវារៈរមែងមាន ៣ វារៈ ដោយន័យដែលធ្លាប់ពោលមកហើយនោះឯង ។ ចំណែកសត្វដែលជាទុហេតុកបដិសន្ធិ មិនមានជវនដែលជាកិរិយាចិត្ត ព្រោះហេតុនោះ កាលចិត្តទាំង ៨ ដួងនេះ គឺចិត្តដែលសហគតៈដោយសោមនស្សខាងកុសល ៤ ដួង និងខាងអកុសល ៤ ដួង ដួងណាមួយ សេពអារម្មណ៍ហើយរលត់ តទារម្មណៈ ជាវិបាកចិត្តដែលជាទុហេតុកៈប៉ុណ្ណោះ ជាអសង្ខារិកសហគតៈដោយសោមនស្សប៉ុណ្ណោះ ។ ដោយប្រការដូច្នេះទើបរាប់ចិត្តរបស់ទុហេតុកៈសត្វនោះបាន ៤ ដួង គឺចិត្ត ៣ ដួងមានចក្ខុវិញ្ញាណជាដើម និងតទារម្មណៈនេះ ១ ដួង ចំណែកក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ កាលចិត្ត ៨ ដួង គឺចិត្តដែលសហគតៈដោយឧបេក្ខាខាងកុសល ៤ ដួង និងខាងអកុសល ៤ ដួង ដួង

ណាមួយសេពអារម្មណ៍រលត់ទៅ តទារម្មណ៍ជាវិបាកចិត្តដែលជាទុហេតុកៈ ប៉ុណ្ណោះ ជាអសង្ខារិក សហគតៈដោយឧបេក្ខា ។ ដោយប្រការដូច្នេះ ទើបរាប់ចិត្តរបស់ទុហេតុកៈសត្វនោះបាន ២ ដួង គឺសន្តីរណៈដែលសហគតៈដោយឧបេក្ខានិងតទារម្មណៈដួងនេះ ។ ចិត្តទាំងនេះនិងចិត្ត ៤ ដួងមុន ទើបរួមជាវិបាកចិត្ត ៦ ដួង ។ ក្នុងសោតទ្វារជាដើម ក៏មានមួយទ្វារ ៦ ដួង ។ កាលធ្វើកម្មដោយចេតនាមួយដួង ចិត្ត ៣០ រមែងកើតឡើងបាន តែកាលរាប់ចិត្តដែលមិនត្រួតគ្នា រមែងបានចិត្ត ១០ ដួង គឺ ៦ ដួងក្នុងចក្ខុទ្វារ ៤ ដួងទៀតមានសោតវិញ្ញាណជាដើម ។ កថាពោលដោយឧបមាអំពីផ្លែស្វាយ និងកថាពោលដោយនិយាម ៥ មានដូចមុននោះឯង សេចក្តីឧបមាដោយឃ្នាបអំពៅ លោកពោលថា លើកយកមកឧបមាក្នុងទីនេះមិនបាន ។

ក្នុងការធ្វើកម្មដោយកុសលចិត្តដែលជាសសង្ខារិក ជាទុហេតុកៈ សហគតៈដោយសោមនស្សក្តី ក្នុងការធ្វើកម្មដោយចិត្ត ដែលជាអសង្ខារិក និងសសង្ខារិកជាទុហេតុកៈ សហគតៈដោយឧបេក្ខាក្តី ក៏មានន័យនេះដូចគ្នា ។ វារៈថា ទុហេតុកៈបដិសន្ធិមានដោយទុហេតុកកម្ម លោកពោលទុកហើយដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

ចំណែកវារៈថា អហេតុកៈបដិសន្ធិរមែងមានបាន គប្បីជ្រាបយ៉ាងនេះថា កាលធ្វើកម្មដោយកុសលចិត្តដែលជាញាណវិប្បយុត្ត ៤ ដួង កាលកាន់យកបដិសន្ធិដោយមនោវិញ្ញាណធាតុដែលជាអហេតុក កុសលវិបាកដែលសហគតៈដោយឧបេក្ខា បណ្ឌិតមិនគប្បីជ្រាបថា បដិសន្ធិដូចគ្នានឹងកម្ម ។ តាំង

អំពីនេះទៅ គប្បីជ្រាបការកើតឡើងនៃចិត្ត ក្នុងឥដ្ឋារម្មណ៍ខ្លះ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ខ្លះ ដែលពោលទុកហើយដោយន័យដែលធ្លាប់ពោលមកហើយនោះឯង ។ ក្នុងវាទៈរបស់ព្រះថេរៈនេះ ក្រមជវនរមែងសេពអារម្មណ៍ ។ គប្បីជ្រាបពាក្យដ៏សេសទាំងអស់មានពាក្យថា អ្វីកំណត់ជវននេះឲ្យជាកុសល ឬអកុសលជាដើមដោយន័យដែលពោលទុកហើយក្នុងទីនោះៗឯង[១] អធិប្បាយវិបាកចិត្ត ១២ ដួង និងអធិប្បាយវិបាកចិត្ត ១០ ដួង និងអហេតុកចិត្ត ៨ ដួង ក្នុងវាទៈរបស់ព្រះមហាទត្តត្ថេរ អ្នកនៅក្នុងមោរវាបីវិហារ ចប់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

ឥឡូវនេះ ជាពាក្យអធិប្បាយវិបាកចិត្ត ១០ ដួង ក្នុងវាទៈរបស់ព្រះមហាធម្មរក្ខិតត្ថេរដូចតទៅ ក្នុងវាទៈនោះ សាកេតកបញ្ហានិងឧស្សន្នកិត្តនៈប្រព្រឹត្តទៅតាមប្រក្រតីនោះឯង ។ ចំណែកក្នុងការសម្តែងហេតុមានការផ្សេងគ្នាដូចតទៅនេះថា កម្មដែលជា**តិហេតុក** រមែងឲ្យវិបាកជា**តិហេតុកៈ**ខ្លះ ឲ្យវិបាកជាទុហេតុកៈខ្លះ ឲ្យវិបាកជាអហេតុកៈខ្លះ ។ កម្មដែលជាទុហេតុកៈរមែងមិនឲ្យវិបាកជា**តិហេតុកៈ**ប៉ុណ្ណោះតែឲ្យវិបាកក្រៅអំពីនេះបាន ។ ដោយកម្មដែលជា**តិហេតុកៈ** បដិសន្ធិរមែងជា**តិហេតុកៈ**ប៉ុណ្ណោះ មិនជាទុហេតុកៈឬអហេតុកៈ ។ ដោយកម្មដែលជាទុហេតុកៈ បដិសន្ធិរមែងជាទុហេតុកៈនិងអហេតុកៈ មិនជា**តិហេតុកៈ** ។ កម្មដែលជាអសង្ខារិក រមែងឲ្យវិបាកដែលជាអសង្ខារិកប៉ុណ្ណោះមិនឲ្យវិបាកជាសសង្ខារិកសូម្បីកម្មដែលជាសសង្ខារិក

---

១-ក្នុងវាទៈរបស់ព្រះចូឡនាគត្ថេរ ។

ក៏ឲ្យវិបាកដែលជាសសង្ខារិកប៉ុណ្ណោះ មិនឲ្យវិបាកជាអសង្ខារិក ។ វេទនាគប្បីផ្លាស់ប្តូរទៅតាមអារម្មណ៍ ។ ជវនជាក្រុមជវននោះឯង[១] រមែងសេពអារម្មណ៍ ។ បណ្ឌិតគប្បីពោលអធិប្បាយចិត្តទាំងឡាយ តាំងពីដើមតទៅ ។

ក្នុងសេចក្តីនោះ មានអធិប្បាយដូចតទៅនេះថា បុគ្គលម្នាក់ធ្វើកម្មដោយកុសលចិត្តដួងទីមួយ រមែងចាប់បដិសន្ធិដោយវិបាកចិត្តដួងទីមួយប៉ុណ្ណោះ ។ បដិសន្ធិចិត្តនេះដូចគ្នានឹងកម្មដែលធ្វើ ។ កាលបុគ្គលនោះចម្រើនវ័យហើយ កាលឥដ្ឋារម្មណ៍ មកកាន់គន្លងក្នុងចក្ខុទ្វារ មោឃវារៈ ៣ រមែងមានដោយន័យដែលពោលហើយនុ៎ះឯង លំដាប់នោះក្នុងវេលាដែលជវនចិត្ត សហគតៈដោយសោមនស្ស ១៣ ដួង តាមដែលធ្លាប់ពោលមកហើយនោះឯង ដួងណាមួយរបស់បុគ្គលនោះសេពអារម្មណ៍ហើយរលត់ទៅ វិបាកចិត្តដួងទីមួយប៉ុណ្ណោះ រមែងជាតទារម្មណៈ ។ វិបាកចិត្តនោះ រមែងបានឈ្មោះ ២ យ៉ាង គឺមូលភវង្គនិងតទារម្មណៈ ដោយអាការៈយ៉ាងនេះ ទើបរាប់វិបាកចិត្តរបស់បុគ្គលនោះបាន ៤ ដួង គឺវិបាកចិត្ត ៣ ដួង មានចក្ខុវិញ្ញាណជាដើម និងតទារម្មណៈដួងនេះ ។ ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ក្នុងវេលាដែលជវនចិត្តសហគតៈដោយឧបេក្ខា ១២ ដួង ដោយន័យដែលធ្លាប់ពោលមកហើយនោះឯង ដួងណានីមួយសេពអារម្មណ៍ ហើយរលត់ទៅ ចិត្តដែលជាអសង្ខារិក ជា **តិហេតុកៈ** សហគតៈដោយឧបេក្ខាក៏តាំងនៅជាតទារម្មណៈ ។ វិបាកចិត្តនោះ

---

១-ពាក្យថា ក្រុមជវន គឺជវនទាំងខាងកុសល អកុសលនិងកិរិយាដែលលោករួមពោលក្នុងតទារម្មណៈមួយ ។

រមែងបានឈ្មោះ ២ យ៉ាងគឺ អាគន្តុកភវង្គនិងតទារម្មណៈ ។ ដោយប្រការដូច្នេះ ទើបរាប់វិបាកចិត្តរបស់បុគ្គលនោះបាន ២ ដួង គឺសន្តីរណចិត្តដែលសហគតដោយឧបេក្ខានិងតទារម្មណៈដួងនេះ ។ វិបាកចិត្ត ២ ដួងនេះនិងវិបាកចិត្ត ៤ ដួងមុន ទើបរួមជាវិបាកចិត្ត ៦ ដួង សូម្បីក្នុងសោតទ្វារជាដើមក៏បានវិបាកចិត្តមួយទ្វារ ៦ ដួង ។ ដោយប្រការយ៉ាងនេះ កាលធ្វើកម្មដោយចេតនាមួយដួង វិបាកចិត្ត ៣០ ដួង រមែងកើតឡើងក្នុងទ្វារ ៥ ។ ពោលដោយការរាប់ចិត្តដែលមិនត្រួតគ្នា រមែងបានវិបាកចិត្ត ១០ ដួង គឺ ៦ ដួងក្នុងចក្ខុទ្វារ ៤ ដួងទៀត មានសោតវិញ្ញាណជាដើម ។ កថាពោលឧបមាអំពីផ្ទៃស្វាយ និងកថាពោលដោយកម្មនិយាម ប្រព្រឹត្តទៅតាមប្រក្រតីនុ៎ះឯង ។

កាលធ្វើកម្មដោយកុសលចិត្តដួងទី ២ ទី ៣ ទី ៤ រមែងមានវិបាកចិត្តប្រមាណប៉ុណ្ណេះយ៉ាងនេះនោះឯង ។ ក្នុងការធ្វើកម្មដោយចិត្តដែលសហគតដោយឧបេក្ខា ៤ ដួង ក៏ន័យនេះដូចគ្នា ។ ក្នុងវាទៈនេះ គប្បីសម្តែងឥដ្ឋមជ្ឈត្តារម្មណ៍មុន ខាងក្រោយទើបផ្លាស់ប្តូរវេទនាដោយឥដ្ឋារម្មណ៍ ។ ក្នុងសេចក្តីនោះ កថាពោលដោយការឧបមាដោយផ្ទៃស្វាយនិងកថាដោយនិយាម ៥ ប្រព្រឹត្តទៅដូចគ្នាមុននោះឯង ។ សេចក្តីឧបមាដោយឃ្លាបអំពៅ នាំមកប្រើមិនបាន បណ្ឌិតគប្បីពោលអហេតុកចិត្ត ៨ ដួងទាំងអស់ឲ្យពិស្តារតាំងអំពីនេះថា កាលធ្វើកម្មដោយកុសលចិត្ត ដែលជាញាណវិប្បយុត្ត ៤ ដួងដួងណាមួយ ។ អធិប្បាយវិបាកចិត្ត ១០ ដួង មួយអន្លើដោយអហេតុកចិត្ត

៨ ដួង ក្នុងវាទៈរបស់ព្រះមហាធម្មរក្ខិតត្ថេរ ចប់ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

សួរថា វាទៈរបស់ព្រះថេរៈទាំង ៣ នេះ របស់អង្គណា គួរកាន់យក ឆ្លើយថា មិនគួរកាន់យករបស់លោកម្ចាស់អង្គណាត្រឹមតែមួយរូប តែក្នុងវាទៈរបស់ព្រះថេរៈទាំងអស់ ពាក្យណាដែលត្រឹមត្រូវគប្បីកាន់យកពាក្យនោះ ដ្បិតថា ក្នុងវាទៈរបស់ព្រះថេរៈអង្គដំបូង លោកបំណងចាត់ប្រភេទចិត្តដែលជាសសង្ខារនិងអសង្ខារ ដោយសេចក្ដីផ្សេងគ្នានៃបច្ច័យ ។ ដោយហេតុនោះ ក្នុងវាទៈរបស់ព្រះថេរៈអង្គដំបូងនេះ ទើបលោកពោលអធិប្បាយ វិបាកចិត្ត ១៦ ដួង ដោយអំណាចនៃព្រះសេក្ខៈនិងបុថុជ្ជន ដោយកាន់យកវិបាកដែលជាសសង្ខារិកដែលកើតដោយបច្ច័យ ដែលខ្សោយកម្លាំងនៃកុសលដែលជាអសង្ខារិក និងវិបាកដែលជាអសង្ខារិកដែលកើតឡើងដោយបច្ច័យដែលមានកម្លាំងនៃកុសល ដែលជាសសង្ខារិក ហើយលះកិរិយាជវនទាំងឡាយដែលបាន ហើយកំណត់តទារម្មណៈដោយកុសលជវនទាំងឡាយ និងកំណត់វេទនាដោយអារម្មណ៍ ។ ក្នុងវាទៈរបស់ព្រះថេរៈទីមួយនេះ លោកសម្ដែងតទា-រម្មណៈឯណាដែលជាអហេតុកវិបាកប៉ុណ្ណោះ ក្នុងទីបំផុតនៃអកុសលជវនចិត្ត តទារម្មណៈនោះ លោកមិនសម្ដែងទុកក្នុងវាទៈក្រៅពីនេះឡើយ ព្រោះហេតុនោះ ក្នុងវាទៈរបស់លោកនោះ តទារម្មណៈដែលជាអហេតុកវិបាកនោះ និងតទារម្មណៈដែលជាសហេតុកៈវិបាកដែលពោលទុកក្នុងវាទៈក្រៅអំពីនេះនោះ វាទៈទាំងអស់នេះរមែងបានក្នុងអធិការនេះឯង ។

សេចក្តីនោះ មានន័យដូចតទៅនេះថា

ក្នុងកាលណា អកុសលចិត្តសេពអារម្មណ៍ក្នុងចន្លោះៗ ( ឆ្លាស់វិថីគ្នា ) នៃកុសលជវនចិត្តទាំងឡាយ ក្នុងកាលនោះ តទារម្មណៈ ក៏គួរជាសហេតុកៈ ( វិបាកចិត្ត ) ក្នុងទីបំផុតនៃអកុសលជវនចិត្ត ដូចដែលកើតក្នុងទីបំផុតនៃកុសលជវនចិត្តនុ៎ះឯង ។ ក្នុងកាលណា អកុសលចិត្តកើតជាប់តគ្នាទៅមិនដាច់ខ្សែ ក្នុងកាលនោះតទារម្មណៈទើបគួរជាអហេតុកវិបាក ។ គប្បីកាន់យកសេចក្តីដែលត្រឹមត្រូវក្នុងវាទៈរបស់ព្រះថេរៈអង្គទីមួយ យ៉ាងនេះមុន ។

ចំណែកក្នុងវាទៈរបស់ព្រះថេរៈអង្គទី ២ លោកបំណងចាត់ប្រភេទចិត្តដែលជាអសង្ខារនិងសសង្ខារដោយកុសល ដោយហេតុនោះ ក្នុងវាទៈទី ២ នេះ ទើបពោលអធិប្បាយវិបាកចិត្ត ១២ ដួង ដោយអំណាចនៃក្រុមជវនប៉ុណ្ណោះ ដែលសមគួរដល់ការកើតឡើង ដល់ព្រះសេក្ខៈ ព្រះអសេក្ខៈនិងបុថុជ្ជនទាំងអស់ ។ ដោយកាន់យកវិបាកចិត្តដែលជាអសង្ខារិកនៃកុសលចិត្តដែលជាអសង្ខារិកតែម្យ៉ាង និងវិបាកចិត្តដែលជាសសង្ខារិកនៃកុសល ដែលជាសសង្ខារិកតែម្យ៉ាង មិនធ្វើការកំណត់តទារម្មណៈដោយជវនចិត្ត ។ តែក្នុងវាទៈទី ២ នេះ កាលជវនចិត្តជា**តិហេតុកៈ**រលត់ទៅ តទារម្មណៈក៏សមគួរជា**តិហេតុកៈ**វិបាកចិត្ត ។ កាលជវនចិត្តជាទុហេតុកៈរលត់ទៅ តទារម្មណៈក៏សមគួរជាទុហេតុកវិបាកចិត្ត កាលជវនចិត្តជាអហេតុកៈរលត់ទៅ តទារម្មណៈក៏សមគួរជាអហេតុកវិបាកចិត្ត តែសេចក្តីនេះលោកមិនបានចែកទុក ។ គប្បីកាន់យកសេចក្តីដែលត្រឹមត្រូវក្នុងវាទៈទី ២ យ៉ាងនេះ ។

សូម្បីក្នុងវាទៈរបស់ព្រះថេរៈអង្គទី ៣ លោកក៏បំណាងចាត់ប្រភេទចិត្ត ដែលជាសសង្ខារនិងអសង្ខារដោយកុសលនុ៎ះឯង ព្រោះពាក្យថា កម្មដែលជា**តិហេតុកៈ** រមែងឲ្យវិបាកជា**តិហេតុកៈ**ខ្លះ ឲ្យវិបាកជាទុហេតុកៈខ្លះ ឲ្យវិបាកជាអហេតុកៈខ្លះ ដូច្នេះ សត្វដែលបដិសន្ធិដោយចិត្តដែលជាអសង្ខារិក-តិហេតុកៈ គប្បីមានតទារម្មណៈ សូម្បីដែលជាអសង្ខារិកទុហេតុកៈបាន ។ លោកមិនសម្ដែងតទារម្មណៈនោះ សម្ដែងតែតទារម្មណៈ ដែលដូចគ្នានឹងតិហេតុកចិត្តប៉ុណ្ណោះ តទារម្មណៈនោះ មិនសមនឹងពាក្យសម្ដែងហេតុដែលមានមកខាងដើម ។ ការដែលលោកពោលទុកយ៉ាងនេះ ដើម្បីបំភ្លឺសេចក្ដីអធិប្បាយវិបាកចិត្ត ១០ ដួងប៉ុណ្ណោះ តែតទារម្មណៈក្រៅអំពីនេះ ក៏រកបាននុ៎ះឯង គួរកាន់យកសេចក្ដីដែលត្រឹមត្រូវ ក្នុងវាទៈទី ៣ យ៉ាងនេះ ។

មួយទៀត ពាក្យទាំងអស់នេះ ជាពាក្យពោលដោយតទារម្មណៈសំដៅយកវិបាករបស់កម្មដែលឲ្យកើតបដិសន្ធិប៉ុណ្ណោះ ។ តទារម្មណៈចិត្តដែលជាសហេតុកវិបាក រមែងកើតឡើងដល់សត្វ ដែលបដិសន្ធិដោយអហេតុកចិត្តដោយកម្មផ្សេងៗគ្នា ដោយព្រះតម្រាស់ ( ក្នុងអភិធម្មមហាបដ្ឋាន ) ថា សហេតុកភវង្គជាបច្ច័យនៃអហេតុកភវង្គ ដោយអនន្តរប្បច្ច័យ ដូច្នេះ ។ ការចែកការកើតឡើងនៃតទារម្មណៈនោះ នឹងជាក់ច្បាស់ក្នុងមហាបករណ៍នោះឯង ។

## អធិប្បាយកាមាវចរកុសលវិបាកចិត្ត ចប់

# អភិធម្មបិដក

## រូបាវចរវិបាក

[ ៤១៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងរូបភព បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានដីជាកសិណ ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជារូបាវចរកុសលនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានដីជាកសិណក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈានមានដីជាកសិណក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជារូបាវចរកុសលនោះឯង បានលះបង់សុខផង ។បេ។ បានដល់បញ្ចមជ្ឈាន មានដីជាកសិណ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

ចប់ រូបាវចរវិបាក ។

# អរូបាវចរវិបាក

[ ៤១៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងនូវពួករូបសញ្ញា ដោយប្រការទាំងពួង កម្ចាត់បង់នូវពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកាសានញ្ចាយតនៈ-សញ្ញាក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំ នូវកម្មជាអរូបាវចរកុសលនោះឯង ព្រោះកន្លងនូវពួករូបសញ្ញាដោយប្រការទាំងពួង កម្ចាត់បង់នូវពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា បានលះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកាសានញ្ចាយតនសញ្ញា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤១៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងនូវអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយវិញ្ញា-ណញ្ចាយតនសញ្ញាក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាអរូបាវចរកុសលនោះឯង ព្រោះកន្លងនូវអាកាសានញ្ចាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។

បានដល់ចតុត្ថជ្ឈាន ប្រកបដោយវិញ្ញាណញ្ចាយតនសញ្ញា ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួងលះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកិញ្ចញ្ញាយតនសញ្ញា ក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាអរូបាវចរកុសលនោះឯង ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយអាកិញ្ចញ្ញាយតនសញ្ញា ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវមគ្គ ដើម្បីទៅកើតក្នុងអរូបភព ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈានប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាអរូបាវចរកុសល

នោះឯង ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រកបដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ អរូបាវចរវិបាក ។

# អដ្ឋកថា

## អធិប្បាយ រូបាវចរវិបាកនិងអរូបាវចរវិបាក

[ ៤១៨-៤២១ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់បំណាចទីងសម្តែង វិបាកចិត្តដែលជារូបាវចរជាដើម ទើបទ្រង់ផ្តើមព្រះតម្រាស់ថា **កតមេ ធម្មា អព្យាកតា** ជាដើមទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ជាអព្យាក្រឹតនោះ ដូចតទៅនេះថា

កាមាវចរវិបាករមែងឲ្យផលដូចគ្នាខ្លះ មិនដូចគ្នាខ្លះ នឹងកុសលចិត្តរបស់ខ្លួន ព្រោះហេតុនោះទើបកាមាវចរវិបាកនោះទ្រង់មិនចែកឲ្យជាវិបាកអនុលោមតាមកុសល ។ ចំណែករូបាវចរវិបាកនិងអរូបាវចរវិបាក រមែងដូចគ្នានឹងកុសលរបស់ខ្លួននោះឯង ដូចស្រមោលដ៏រី សេះនិងដើមឈើជាដើម រមែងដូចគ្នានឹងដំរី សេះ និងដើមឈើជាដើម យ៉ាងនោះ ទើបទ្រង់ចែកឲ្យជាវិបាកអនុលោមតាមកុសល ។

មួយទៀត កាមាវចរកម្ម រមែងឲ្យវិបាកក្នុងកាលខ្លះ ក្នុងគ្រាខ្លះក៏បាន ចំណែករូបាវចរកម្មនិងអរូបាវចរកម្ម រមែងឲ្យវិបាកចំពោះក្នុងអត្តភាពក្នុងភពទីពីរនោះឯងដោយមិនមានអន្តរាយ ព្រោះហេតុនេះទើបទ្រង់ចែកឲ្យជាវិបាកអនុលោមតាមកុសលនោះឯង ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយក្នុងកុសលទុ៎ះឯង ។

ចំណែកសេចក្តីផ្សេងគ្នាមានដូច្នេះថា

គប្បីជ្រាបប្រភេទមានបដិបទាជាដើម និងភាពជាហីនចិត្ត បណីតចិត្តនិង

មជ្ឈិមចិត្ត ដោយការមកដល់នៃឈាន ក្នុងរូបាវចរវិបាកនិងអរូបាវចរវិបាក ទាំងនេះ ។ តែវិបាកទាំងនេះ មិនមានអធិបតីឡើយ ព្រោះមិនធ្វើធម៌ មានឆន្ទៈជាដើម ដួងណាមួយឲ្យជាធុរៈកើតឡើងនោះឯង ។

## អធិប្បាយរូបាវចរវិបាកនិងអរូបាវចរវិបាក ចប់

# អភិធម្មបិដក

# មហាន័យ ២០

# សុទ្ធិកប្បដិបទាជាដើម

[ ៤២២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរៈនោះឯង ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានមានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ( សូន្យចាកកិលេស ) ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ

ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរៈនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្តៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរៈនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវបឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោ-

កុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជូច្នេះជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈដូច្នេះ ជាវិបាក ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្តដូច្នេះ ជាវិបាក ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានការត្រាស់ដឹងយឺតយូរ ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន

មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអនិមិត្តៈ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ សុទ្ធិកប្បដិបទា ។

[ ៤២៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរៈនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើងដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរៈនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអនិមិត្តៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤២៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោ-

កុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈទាំងឡាយ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ជាសុញ្ញតៈ ដូច្នេះ ជាកុសល ។បេ។ ជាសុញ្ញតៈ ដូច្នេះ ជាវិបាក ។បេ។ ជាសុញ្ញតៈ ដូច្នេះ ជាកុសល ។បេ។ ជាអនិមិត្ត ដូច្នេះ ជាវិបាក ។បេ។ ជាសុញ្ញតៈ ដូច្នេះ ជាកុសល ។បេ។ ជាអប្បណិហិតៈ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ សុទ្ធិកសុញ្ញតៈ ។

[ ៤៣១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរៈនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន

ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះ ជាវិបាក

ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ដូច្នេះជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ដូច្នេះជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ដូច្នេះជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ជាសុញ្ញតៈដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអនិមិត្តដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ជាអប្បណិហិតៈដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ សុញ្ញតប្បដិបទា ។

[ ៤៣៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះ

បង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអនិមិត្ត ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។

បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៣៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ជាអប្បណិហិតៈដូច្នេះ ជាកុសល ។បេ។ ជាអប្បណិហិតៈ ដូច្នេះជាវិបាក ។បេ។ ជាអប្បណិហិតៈដូច្នេះ ជាកុសល ។បេ។ ជាអនិមិត្តដូច្នេះ ជាវិបាក ។បេ។ ជាអប្បណិហិតៈដូច្នេះ ជាកុសល ។បេ។ ជាសុញ្ញតៈ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ សុទ្ធិកអប្បណិហិតៈ ។

[ ៤៤០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះ

បង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៤១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្តៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួក

ធម៌ជាអព្យាក្រឹត ។

[ ៤៤២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៤៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្ដី

ប្រតិបត្តិលំបាក មានការត្រាស់ដឹង យឺតយូរ ជាអប្បណិហិតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាកមានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៤៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់

ដឹងធាប់ ជាអនិមិត្ត ដូច្នេះ ជាវិបាក ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានការត្រាស់ដឹងធាប់ ជាអប្បណិហិតៈ ដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិងាយ មានការត្រាស់ដឹងធាប់ ជាសុញ្ញតៈ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ អប្បណិហិតប្បដិបទា ។

[ ៤៤៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរមគ្គ ។បេ។ ចម្រើននូវលោកុត្តរសតិប្បដ្ឋាន ។បេ។ ចម្រើននូវលោកុត្តរសម្មប្បធាន ។បេ។ ចម្រើននូវលោកុត្តរឥទ្ធិបាទ ។បេ។ ចម្រើននូវលោកុត្តរឥន្ទ្រិយ ។បេ។ ចម្រើននូវលោកុត្តរពលៈ ។បេ។ ចម្រើននូវលោកុត្តរពោជ្ឈង្គ ។បេ។ ចម្រើននូវលោកុត្តរសច្ចៈ ។បេ។ ចម្រើននូវលោកុត្តរសមថៈ ។បេ។ ចម្រើននូវលោកុត្តរធម៌ ។បេ។ ចម្រើននូវលោកុត្តរក្ខន្ធ ។បេ។ ចម្រើននូវលោកុត្តរអាយតនៈ ។បេ។ ចម្រើននូវលោកុត្តរធាតុ ។បេ។ ចម្រើននូវលោកុត្តរអាហារ ។បេ។ ចម្រើននូវលោកុត្តរផស្សៈ ។បេ។ ចម្រើននូវលោកុត្តរវេទនា ។បេ។ ចម្រើននូវលោកុត្តរសញ្ញា ។បេ។ ចម្រើននូវលោកុត្តរចេតនា ។បេ។ ចម្រើននូវលោកុត្តរចិត្ត ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ក្នុងសម័យណា

ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលចិត្ត ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ។បេ។ ជាអនិមិត្ត ។បេ។ ជាអប្បណិហិតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

## ចប់ មហាន័យ ២០ ។

[ ៤៤៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៤៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៤៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ ពួកធម៌ជាកុសលទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិ-

បត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៤៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ បានដល់ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាធន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធន្ទាធិបតេយ្យ ដូច្នេះជាវិបាក ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាធន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្តៈ ជាធន្ទាធិបតេយ្យដូច្នេះ ជាវិបាក ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាធន្ទាធិបតេយ្យ ដូច្នេះជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោ-

កុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ជាឆន្ទាធិបតេយ្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងយឺតយូរ ជាឆន្ទាធិបតេយ្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាឆន្ទាធិបតេយ្យ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអនិមិត្ត ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះ

បង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអនិមិត្តៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោ-

កុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈានជាអប្បណិហិតៈ ជាធម្មាធិបតេយ្យ ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន ជាសុញ្ញតៈ ជាធម្មាធិបតេយ្យដូច្នេះ ជាកុសល ។បេ។ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ ជាអនិមិត្ត ជាធម្មាធិបតេយ្យ ដូច្នេះ ជា វិបាក ។បេ។ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យដូច្នេះ ជាកុសល ។បេ។ ជាអប្បណិហិតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។

នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះ ជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង

បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិ-បត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ជាធម្មាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោ-កុត្តរជ្ឈានជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯងបានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិ-បត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធម្មាធិបតេយ្យក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោ-កុត្តរជ្ឈានជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិ-យជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។

បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ជាធម្មាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធម្មាធិបតេយ្យ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៥៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាធម្មាធិបតេយ្យ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។

បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអនិមិត្ត ជាឆន្ទាធិបតេយ្យដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យក្នុងសម័យណា ផស្សៈ

ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអនិមិត្ត ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បាន

ដល់បឋមជ្ឈាន ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៣ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈានជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះជាកុសល ។បេ។ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះជាកុសល ។បេ។ ជាអនិមិត្ត ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុង

សម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ជាឆន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះ

បង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈានជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាធន្ទាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈានជាគ្រឿងចេញចាកវដ្ដៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិដើម្បីដល់នូវភូមិជាប្រថម បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធន្ទាធិបតេយ្យដូច្នេះ ជាវិបាក ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាធន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្ដីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាអនិមិត្ត ជាធន្ទាធិប-

តេយ្យ ដូច្នេះជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹង យឺតយូរ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មាន សេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ជាឆន្ទាធិប-តេយ្យដូច្នេះ ជាវិបាកក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោ-កុត្តរជ្ឈានជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ជា អប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការ ត្រាស់ដឹងយឺតយូរ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ។បេ។ មានសេចក្តី ប្រតិបត្តិងាយមានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជា អប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះជាកុសល ។បេ។ មានសេចក្តីប្រតិ-បត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាវិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្ប-ណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះជាកុសល ។បេ។ មានសេចក្តីប្រតិ-បត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអនិមិត្ត ជាឆន្ទាធិបតេយ្យ ដូច្នេះ ជា

វិបាក ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាអប្ប-ណិហិតៈ ជាឆន្ទាធិបតេយ្យ ដូច្នេះ ជាកុសល ។បេ។ មានសេចក្តីប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ជាសុញ្ញតៈ ជាឆន្ទាធិបតេយ្យដូច្នេះ ជាវិបាក ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៦៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរមគ្គ ។បេ។ ចម្រើននូវលោកុត្តរសតិប្បដ្ឋាន ។បេ។ ចម្រើននូវលោកុត្តរសម្មប្បធាន ។បេ។ ចម្រើននូវលោកុត្តរឥទ្ធិបាទ ។បេ។ ចម្រើននូវលោកុត្តរឥន្ទ្រិយ ។បេ។ ចម្រើននូវលោកុត្តរពលៈ ។បេ។ ចម្រើននូវលោ-កុត្តរពោជ្ឈង្គ ។បេ។ ចម្រើននូវលោកុត្តរសច្ចៈ ។បេ។ ចម្រើននូវលោ-កុត្តរសមថៈ ។បេ។ ចម្រើននូវលោកុត្តរធម៌ ។បេ។ ចម្រើននូវលោកុត្ត-រក្ខន្ធ ។បេ។ ចម្រើននូវលោកុត្តរអាយតនៈ ។បេ។ ចម្រើននូវលោកុត្តរ-ធាតុ ។បេ។ ចម្រើននូវលោកុត្តរអាហារ ។បេ។ ចម្រើននូវលោកុត្តរ-ផស្សៈ ។បេ។ ចម្រើននូវលោកុត្តរវេទនា ។បេ។ ចម្រើននូវលោកុត្តរ-សញ្ញា ។បេ។ ចម្រើននូវលោកុត្តរចេតនា ។បេ។ ចម្រើននូវលោកុត្តរចិត្ត ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីលះបង់នូវទិដ្ឋិ ដើម្បីដល់នូវភូមិជាប្រថម បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាឆន្ទា-ធិបតេយ្យ ក្នុងសម័យណា ផស្សៈ ក៏កើតមាន ក្នុងសម័យនោះ ។បេ។

អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាកព្រោះហេតុបានធ្វើ បានចម្រើននូវកុសលចិត្ត ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ។បេ។ ជាអនិមិត្ត ។បេ។ ជាអប្បណិហិតៈ ជាឆន្ទាធិបតេយ្យ ។បេ។ ជាវីរិយាធិបតេយ្យ ។បេ។ ជាចិត្តាធិបតេយ្យ ។បេ។ ជាវីមំសាធិបតេយ្យ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ វិបាកក្នុងបឋមមគ្គ ។

[ ៤៧០ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវលោកុត្តរជ្ឈាន ជាគ្រឿងចេញចាកវដ្តៈ ដល់នូវការមិនសន្សំកពូនឡើង ដើម្បីធ្វើកាមរាគនិងព្យាបាទឲ្យស្រាលស្តើង ដើម្បីដល់នូវទុតិយភូមិ ។បេ។ ដើម្បីលះកាមរាគនិងព្យាបាទមិនឲ្យមានសេសសល់ដើម្បីដល់នូវតតិយភូមិ ។បេ។ ដើម្បីលះរូបរាគ អរូបរាគ មានះ ឧទ្ធច្ចៈនិងអវិជ្ជា មិនឲ្យមានសេសសល់ ដើម្បីដល់នូវចតុត្ថភូមិ បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អញ្ញិន្ទ្រិយ ក៏កើតមានក្នុង

សម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ កុសលធម៌ទាំងនេះជាវិបាក ព្រោះហេតុបានធ្វើ បានចម្រើននូវកុសលជ្ឈាន ជាលោកុត្តរនោះឯង បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានសេចក្តីប្រតិបត្តិលំបាក មានការត្រាស់ដឹងយឺតយូរ ជាសុញ្ញតៈ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អញ្ញាតាវិន្ទ្រិយក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៧១ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈការពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។បេ។ អញ្ញាតាវិន្ទ្រិយ កើតមានក្នុងសម័យនោះតើដូចម្តេច ។ សេចក្តីដឹងទួទៅ ការដឹងសព្វនូវធម៌ទាំងនោះដែលបុគ្គលដឹងទួទៅ ការពិចារណា ការជ្រើសរើស ការជ្រើសរើសសព្វ ការពិចារណាធម៌ ការកំណត់ ការកត់សម្គាល់ ការកត់ត្រា ភាពនៃបណ្ឌិត ភាពនៃអ្នកឈ្លាស ភាពនៃអ្នកជ្រះស្អាត ភាពនៃអ្នកភ្លឺច្បាស់ ការគិត ការត្រិះរិះ ធម្ម-ជាតិដូចផែនដី ធម្មជាតិកម្ចាត់កិលេស ធម្មជាតិណែនាំ ធម្មជាតិឃើញច្បាស់ការដឹងល្អ សភាពដូចជាជន្លួញគឺបញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សស្ត្រាគឺ

បញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា ឱភាសគឺបញ្ញា គ្រឿងផ្ទុះគឺបញ្ញា រតនៈគឺបញ្ញា អមោហៈ ធម្មវិចយៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គជាអង្គនៃមគ្គ រាប់បញ្ចូលក្នុងមគ្គណា នេះអញ្ញាតាវិន្ទ្រិយ កើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

## ចប់ លោកុត្តរវិបាក ។

# អដ្ឋកថា

# អធិប្បាយ លោកុត្តរវិបាក

[ ៤២២-៤៧១ ] សូម្បីលោកុត្តរវិបាក ព្រះអង្គក៏ទ្រង់ចែកធ្វើឲ្យស្របតាមកុសលទាំងឡាយ ព្រោះដូចគ្នានឹងលោកុត្តរកុសល ។ តែព្រោះតេភូមិកកុសលរមែងសន្សំ រមែងញ៉ាំងវដ្តៈឲ្យចម្រើនដោយអំណាចនៃចុតិនិងបដិសន្ធិ ហេតុនោះ ក្នុងវិបាកនៃកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ទើបត្រាស់ទុកថា ព្រោះកាមាវចរកុសលកម្មដែលបានធ្វើទុកហើយ បានសន្សំទុកហើយ ដូច្នេះ ។ ចំណែកលោកុត្តរៈ សូម្បីត្រូវកម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះសន្សំទុកក៏រមែងក្លាយការសន្សំ សូម្បីខ្លួនឯងក៏មិនសន្សំទុកដោយអំណាចចុតិនិងបដិ-សន្ធិ ព្រោះហេតុនោះ ក្នុងលោកុត្តរវិបាកនេះទើបមិនត្រាស់ថា ព្រោះហេតុបានធ្វើ បានសន្សំ ដូច្នេះ តែត្រាស់ថា ព្រោះហេតុបានធ្វើ បានចម្រើន ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងព្រះបាលី មានបទថា **សុញ្ញតំ** ជាដើមថា មគ្គរមែងបានឈ្មោះព្រោះហេតុ ៣ គឺព្រោះការមកដល់ ១ ព្រោះគុណរបស់ខ្លួន ១ ព្រោះអារម្មណ៍ ១ ។ សុញ្ញតៈនេះ ខ្ញុំឲ្យពិស្តារទុកក្នុងអធិការនៃកុសលក្នុងខាងដើមហើយ ។ ក្នុងអធិការនោះ ដោយបរិយាយនៃព្រះសូត្រ មគ្គរមែងបានឈ្មោះដោយគុណរបស់ខ្លួនខ្លះ ដោយអារម្មណ៍ខ្លះ ។ បរិយាយនេះជាបរិយាយទេសនា ។ ចំណែកអភិធម្មកថា ជានិប្បរិយាយទេសនា ។ ព្រោះហេតុនោះ ក្នុងនិប្បរិយាយទេសនានេះ ទើបមគ្គមិនបានឈ្មោះដោយ

គុណរបស់ខ្លួន ឬដោយអារម្មណ៍ តែរមែងបានឈ្មោះដោយការមកដល់តែម្យ៉ាង ។ ព្រោះការមកដល់ប៉ុណ្ណោះជាធុរៈ ការមកដល់នោះមាន ២ យ៉ាង គឺ មកដល់ដោយវិបស្សនានិងមកដល់ដោយមគ្គ ។

ក្នុងការមកដល់ដោយពីរយ៉ាងនោះ ការមកដល់ដោយវិបស្សនាជាធុរៈក្នុងឋានៈដែលមគ្គមកដល់ហើយ ការមកដល់ដោយមគ្គជាធុរៈក្នុងឋានៈដែលផលមកដល់ហើយនោះឯង សូម្បីពាក្យទាំងពីរនេះ ខ្ញុំក៏ធ្លាប់ពោលទុកហើយនោះឯង ។ បណ្ដាឋានៈទាំងពីរនោះ ឋានៈនេះជាឋានៈដែលផលមកដល់ហើយ ព្រោះហេតុនោះ គប្បីជ្រាបថា ការមកដល់ដោយមគ្គជាធុរៈក្នុងឋានៈនេះ ។

មគ្គនេះឈ្មោះថា **សុញ្ញត** ព្រោះការមកដល់ហើយ នៅហៅបានថាអនិ-មិត្ត អប្បណិហិត ព្រោះគុណរបស់ខ្លួននិងព្រោះអារម្មណ៍ ។ ព្រោះហេតុនោះ ខ្លួនឯងតាំងនៅក្នុងឋានៈដែលគួរមកដល់បានហើយ ទើបឲ្យឈ្មោះ ៣ យ៉ាង ដល់ផលរបស់ខ្លួន ។ ឲ្យឈ្មោះយ៉ាងដូចម្ដេច គឺថា សុញ្ញតមគ្គនេះបានឈ្មោះដោយអំណាចការមកដល់សុទ្ធៗប៉ុណ្ណោះ តាំងនៅក្នុងឋានៈដែលគួរមកដល់ឯងហើយ កាលនឹងឲ្យឈ្មោះដល់ផលរបស់ខ្លួនទើបឲ្យឈ្មោះថា **សុញ្ញត** ។ សុញ្ញតអនិមិត្តមគ្គ តាំងនៅក្នុងឋានៈដែលគួរមកដល់ឯងហើយ កាលនឹងឲ្យឈ្មោះដល់ផលរបស់ខ្លួន ទើបឲ្យឈ្មោះថា **អនិមិត្ត** ។ សុញ្ញត-អប្បណិហិតមគ្គ តាំងនៅក្នុងឋានៈដែលគួរមកដល់ឯងហើយ កាលនឹងឲ្យឈ្មោះដល់ផលរបស់ខ្លួន ទើបឲ្យឈ្មោះថា **អប្បណិហិត** ។ ឈ្មោះ ៣

យ៉ាងនេះ រមែងបានដោយន័យនេះ ក្នុងផលចិត្តក្នុងលំដាប់នៃមគ្គប៉ុណ្ណោះ ។ រមែងមិនបានក្នុងផលសមាបត្តិដែលនាំទៅប្រើក្នុងកាលដទៃ ។ តែក្នុងវេលាខាងក្រោយ ព្រះអរិយបុគ្គលអាចឃើញច្បាស់បានដោយវិបស្សនា ៣ មានអនិច្ចានុបស្សនាជាដើម ។ បន្ទាប់អំពីនោះ ផលទាំង ៣ ពោលគឺអនិមិត្តៈ អប្បណិហិតៈ សុញ្ញតៈ រមែងកើតឡើងដល់ព្រះអរិយបុគ្គលនោះ ដោយអំណាចវិបស្សនាដែលចេញហើយ ។ ញាណទាំងនោះឯង របស់ផលទាំង ៣ នោះ មានអនិច្ចានុបស្សនាជាដើម មានសង្ខារជាអារម្មណ៍ ឈ្មោះថាដល់ផលទាំង ៣ នោះ ។

សូម្បីក្នុងអប្បណិហិតមគ្គ ក៏មានន័យនេះ ដូចដែលលោកពោលទុកក្នុងសុញ្ញតមគ្គ ។ ពិតណាស់ អប្បណិហិតមគ្គនោះ បានឈ្មោះដោយអំណាចនៃការមកដល់សុទ្ធៗនោះឯង តាំងនៅក្នុងឋានៈ ដែលគួរមកដល់ឯងហើយ កាលនឹងឲ្យឈ្មោះដល់ផលរបស់ខ្លួន ទើបឲ្យឈ្មោះថា **អប្បណិហិត** ។ អប្បណិហិតអនិមិត្តមគ្គ តាំងនៅក្នុងឋានៈដែលគួរមកដល់ឯងហើយ កាលនឹងឲ្យឈ្មោះ ដល់ផលរបស់ខ្លួន ទើបឲ្យឈ្មោះថា **អនិមិត្ត** ។ អប្បណិ-ហិតសុញ្ញតមគ្គ តាំងនៅក្នុងឋានៈដែលគួរមកដល់ឯងហើយ កាលនឹងឲ្យឈ្មោះដល់ផលរបស់ខ្លួន ទើបឲ្យឈ្មោះថា **សុញ្ញត** ឈ្មោះទាំង ៣ នេះ រមែងបានដោយន័យនេះក្នុងផលចិត្តក្នុងលំដាប់នៃមគ្គប៉ុណ្ណោះ រមែងមិនបានក្នុងផលសមាបត្តិដែលនាំទៅប្រើក្នុងវេលាដទៃ ។ ក្នុងនិទ្ទេសនៃវិបាកចិត្តនេះ គប្បីជ្រាបវិបាកចិត្តទាំងឡាយ ដែលគុណនឹង ៣ ដោយកុសលចិត្តយ៉ាង

នេះ ។ ដូចកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រមែងមិនអាចញុំាងវិបាករបស់ខ្លួនឲ្យបានអធិបតីយ៉ាងណា លោកុត្តរកុសលទាំងឡាយរមែងជាយ៉ាងនោះក៏មិនមែន ព្រោះហេតុអ្វី ព្រោះវេលាដែលប្រកបកម្មរបស់កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាម្យ៉ាង វេលាឲ្យវិបាកក៏ជាម្យ៉ាង ព្រោះហេតុនោះកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ទើបមិនអាចធ្វើវិបាករបស់ខ្លួនឲ្យបាននូវអធិបតី ។ ចំណែកលោកុត្តរៈទាំងឡាយ កាលសទ្ធានោះ កាលវិរិយៈនោះ កាលសតិនោះ កាលសមាធិនោះ កាលបញ្ញានោះនៅមិនទាន់ចូលទៅស្ងប់រម្ងាប់ ( គឺនៅប្រព្រឹត្តទៅ ) ក៏រមែងបានវិបាកក្នុងលំដាប់នៃមគ្គនោះឯង មិនខុសក្បាំងក្បាត់ ដោយហេតុនោះ ទើបលោកុត្តរកុសលនោះអាចធ្វើវិបាករបស់ខ្លួនឲ្យបានអធិបតី ។

ដូចក្នុងទីដែលគេបង្កាត់ភ្លើង ទុកមួយគំនរតូច កាលភ្លើងរលត់ហើយប៉ុណ្ណោះ អាការក្តៅក៏រលត់មិនមានអ្វីៗ ។ តែកាលយកអាចម៍គោ រោយជុំវិញ រំលត់គំនរភ្លើងធំដែលកំពុងឆេះសន្ធោសន្ធៅឡើងហើយ អាការៈគឺកម្តៅរមែងមិនស្ងប់ភ្លាមយ៉ាងណា សេចក្តីនេះក៏យ៉ាងនោះដូចគ្នា ក្នុងកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ខណៈនៃកម្ម ( ការធ្វើ ) ម្យ៉ាង ខណៈនៃវិបាកម្យ៉ាង ដូចវេលាដែលអាការៈ គឺកម្តៅរលត់ទៅនៃភ្លើងគំនរតូច ព្រោះហេតុនោះ កុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ទើបមិនអាចធ្វើវិបាករបស់ខ្លួនឲ្យបានអធិបតី ។ ចំណែកលោកុត្តរកុសល កាលសទ្ធានោះ ។បេ។ កាលបញ្ញានោះ នៅមិនចូលទៅស្ងប់ ផលក៏កើតឡើងក្នុងលំដាប់នៃមគ្គភ្លាម

ព្រោះហេតុនោះ លោកុត្តរកុសលនោះ បណ្ឌិតគប្បីជ្រាបថា រមែងធ្វើវិបាករបស់ខ្លួនឲ្យបានអធិបតី ដោយហេតុនោះទើបបោរាណាចារ្យទាំងឡាយពោលថា អធិបតីមិនមានក្នុងវិបាកចិត្ត វៀរតែលោកុត្តរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃផលដែលកើតអំពីមគ្គទី ៤ ដូចតទៅ

បទថា **អញ្ញាតាវិន្ទ្រិយំ** បានដល់ ឥន្ទ្រិយរបស់លោកអ្នកដឹងទូទៅ គឺអ្នកមានញាណកិច្ចសម្រេច ក្នុងសច្ចៈ ៤ ម្យ៉ាងទៀត ឈ្មោះថា **ឥន្ទ្រិយ** ព្រោះឲ្យសម្រេចអត្ថនៃភាពជាធំក្នុងខាងក្នុងធម៌ទាំងឡាយ ដែលដឹងទូទៅ គឺដែលមានកិច្ចសម្រេចហើយ ក្នុងសច្ចៈ ៤ គឺដែលដឹងហើយ ចាក់ធ្លុះសច្ចៈ ៤ ហើយតាំងនៅ ។

សូម្បីក្នុងនិទ្ទេសនៃអញ្ញាតាវិន្ទ្រិយនោះមានអធិប្បាយថា បទថា **អញ្ញាតាវីនំ** បានដល់ ដឹងហើយតាំងនៅ ។ បទថា **ធម្មានំ** បានដល់ ក្នុងខាងក្នុងនៃសម្បយុត្តធម៌ទាំងឡាយ ។ បទថា **អញ្ញា** បានដល់ ការដឹងទូទៅ ។ បទថា **បញ្ញា បជានា** ជាដើម មានសេចក្តីតាមដែលពោលហើយនុ៎ះឯង ។ បទថា **មគ្គង្គំ មគ្គបរិយាបន្នំ** ដែលជាអង្គនៃមគ្គនិងផល និងទាក់ទងក្នុងមគ្គនិងផល ។

ម្យ៉ាងទៀត ក្នុងលោកុត្តរវិបាកនេះ មានបកិណ្ណកៈដូចតទៅនេះថា

ឥន្ទ្រិយដល់ឋានៈមួយមានម្យ៉ាង ឥន្ទ្រិយដល់ឋានៈប្រាំមួយមានម្យ៉ាងនិងឥន្ទ្រិយដល់ឋានៈមួយមានម្យ៉ាង មានអធិប្បាយថា អនញ្ញតញ្ញស្សាមីតិន្ទ្រិយមួយ ដល់ឋានៈមួយ គឺសោតាបត្តិមគ្គ ។ អញ្ញិន្ទ្រិយមួយដល់ឋានៈ ៦ គឺ

ផលខាងក្រោម ៣ មគ្គខាងលើ ៣ ។ អញ្ញាតាវិន្ទ្រិយមួយដល់ឋានៈ ១ គឺ អរហត្តផល ។

ពោលដោយអត្ថក្នុងមគ្គនិងផលទាំងអស់ត្រាស់ឥន្ទ្រិយដែលជាលោកុត្តរ ទុក ៦៤ គឺមគ្គនិងផលនីមួយៗ ៨ ឥន្ទ្រិយ តែក្នុងព្រះបាលីជាឥន្ទ្រិយ ៧២ ព្រោះធ្វើមគ្គនិងផលនីមួយៗ ៩ ឥន្ទ្រិយ ។ ក្នុងមគ្គ ក៏ត្រាស់ថា **មគ្គង្គ** ( អង្គនៃមគ្គ ) សូម្បីក្នុងផល ក៏ត្រាស់ថា **មគ្គង្គ** ។ ក្នុងមគ្គត្រាស់ថា **ពោជ្ឈង្គ** ក្នុងផលក៏ត្រាស់ថា **ពោជ្ឈង្គ** ។ សូម្បីក្នុងខណៈនៃមគ្គក៏ត្រាស់ថា **អារតិ វិរតិ** ។ សូម្បីក្នុងខណៈនៃផលក៏ត្រាស់ថា **អារតិ វិរតិ** ។

បណ្ដាមគ្គនិងផលទាំងនោះ **មគ្គ** ឈ្មោះថា **មគ្គ** ដោយភាពជាមគ្គនុ៎ះឯង ។ ចំណែកផល ឈ្មោះថា **មគ្គ** ព្រោះអាស្រ័យមគ្គ ។ សូម្បីនឹងពោលថា អង្គនៃផលទាក់ទងក្នុងផល ដូច្នេះក៏គួរ ។

ក្នុងមគ្គ ត្រាស់ហៅថា សម្ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃបុគ្គលអ្នកត្រាស់ដឹង ។ ក្នុងផល ត្រាស់ហៅថា សម្ពោជ្ឈង្គៈ ព្រោះអត្ថថា ជាអង្គនៃអ្នកត្រាស់ដឹងហើយ ។ ក្នុងមគ្គត្រាស់ថា **អារតិ វិរតិ** ដោយអំណាចការវៀរចាកអារម្មណ៍នុ៎ះឯង ។ ក្នុងផលត្រាស់ថា **អារតិ វិរតិ** ដោយអំណាចការវៀរនុ៎ះឯង ។

## អធិប្បាយលោកុត្តរវិបាក ចប់

# អភិធម្មបិដក

## អកុសលវិបាកជាអព្យាក្រឹត

[ ៤៧២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ ចក្ខុវិញ្ញាណ ជាវិបាក ប្រទូសំដោយឧបេក្ខា មានរូបជាអារម្មណ៍ កើតឡើងហើយព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាអកុសល ។បេ។ សោតវិញ្ញាណប្រទូសំដោយឧបេក្ខា មាន សំឡេងជាអារម្មណ៍ កើតឡើងហើយ ។បេ។ ឃានវិញ្ញាណ ប្រទូសំដោយ ឧបេក្ខា មានក្លិនជាអារម្មណ៍ កើតឡើងហើយ ។បេ។ ជិវ្ហាវិញ្ញាណ ប្រទូសំ ដោយឧបេក្ខា មានរសជាអារម្មណ៍ កើតឡើងហើយ ។បេ។ កាយវិញ្ញាណ ប្រទូសំដោយទុក្ខ មានផោដ្ឋព្វៈជាអារម្មណ៍ កើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត ទុក្ខ ឯកគ្គតា របស់ចិត្ត មនិន្ទ្រិយ ទុក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែល កើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជា អព្យាក្រឹត ។

[ ៤៧៣ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ការ ពាល់ត្រូវ ការប៉ះពាល់ ការទង្គិកទង្គិចណាក្នុងសម័យនោះ នេះផស្សៈកើត មានក្នុងសម័យនោះ ។ វេទនា កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ សេចក្ដីមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងកាយ ដែល កើតអំពីសម្ផស្សនៃកាយវិញ្ញាណធាតុដ៏សមគួរដល់ធម៌នោះ ការទទួលអា- រម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃកាយ វេទនាមិនឆ្ងាញ់

ពិសាជាទុក្ខដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះវេទនាកើតមានក្នុងសម័យនោះ ។បេ។ ទុក្ខកើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសា ប្រព្រឹត្តទៅក្នុងកាយ សេចក្តីលំបាកប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសាជាទុក្ខដែលកើតអំពីសម្ផស្សនៃកាយ វេទនាមិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះទុក្ខកើតមានក្នុងសម័យនោះ ។បេ។ ទុក្ខិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីមិនឆ្ងាញ់ពិសាប្រព្រឹត្តទៅក្នុងកាយ សេចក្តីលំបាកប្រព្រឹត្តទៅក្នុងកាយ ការទទួលអារម្មណ៍មិនឆ្ងាញ់ពិសា ជាទុក្ខដែលកើតអំពីសម្ផស្សនៃកាយ វេទនាមិនឆ្ងាញ់ពិសាជាទុក្ខដែលកើតអំពីសម្ផស្សនៃកាយណា ក្នុងសម័យនោះ នេះទុក្ខិន្ទ្រិយកើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៧៤ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ កាយវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៧៥ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើត

ឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៧៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោធាតុជាវិបាកប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានផោដ្ឋព្វៈជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាអកុសលក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៧៧ ] ខន្ធ ៤ កើតមានក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ មនោធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៧៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ

ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៧៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោវិញ្ញាណធាតុជាវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗ កើតឡើងហើយ ព្រោះហេតុបានធ្វើ បានសន្សំនូវកម្មជាអកុសល ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៨០ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ មនោវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៨១ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ អកុសលវិបាកជាអព្យាក្រឹត ។**

# អដ្ឋកថា

## អធិប្បាយ អកុសលវិបាក

[ ៤៧២-៤៨១ ] ចិត្តខាងមុខអំពីលោកុត្តរវិបាកនេះ ជាអកុសលវិបាក មាន ៧ ដួងនេះគឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ រួមជា ៥ ដួង មនោធាតុ ១ ដួង និងមនោវិញ្ញាណធាតុ ១ ដួង ដូចគ្នានឹងកុសលវិបាកចិត្តបែបនោះឯងដែលធ្លាប់ពោលទុកហើយ ទាំងដោយព្រះបាលី និងដោយអត្ថ ។

ពិតណាស់ កុសលវិបាកទាំងនោះ មានកុសលកម្មជាបច្ច័យតែម្យ៉ាង អកុសលវិបាកទាំងនេះក៏មានអកុសលកម្មជាបច្ច័យ ។ មួយទៀត កុសល-វិបាកទាំងនោះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលជាឥដ្ឋារម្មណ៍ និងឥដ្ឋ-មជ្ឈត្តារម្មណ៍ ។ អកុសលវិបាកទាំងនេះ រមែងប្រព្រឹត្តទៅក្នុងអនិដ្ឋារម្មណ៍ និងអនិដ្ឋមជ្ឈត្តារម្មណ៍ ។

មួយវិញទៀត ក្នុងកុសលវិបាកនោះ កាយវិញ្ញាណចិត្តសហគតៈដោយសុខ តែក្នុងអកុសលវិបាកនេះ កាយវិញ្ញាណចិត្ត សហគតៈដោយទុក្ខ ។ម្យ៉ាងទៀត ក្នុងកុសលវិបាកនោះ មនោវិញ្ញាណធាតុសហគតៈដោយឧបេក្ខា រមែងឲ្យផលក្នុងឋានៈទាំង ៥ ចាប់ផ្តើមអំពីបដិសន្ធិ របស់មនុស្សខ្វាក់ក្អែក អំពីកំណើតជាដើម ក្នុងពួកមនុស្ស ។ តែក្នុងអកុសលវិបាកនេះ កាលធ្វើកម្មដោយអកុសលចិត្តទាំង ១១ ដួង ( វៀរមោហមូលចិត្តសម្បយុត្តដោយឧទ្ធច្ចៈ ) មនោវិញ្ញាណធាតុដែលសហគតៈដោយឧបេក្ខា ធ្វើកម្ម កម្មនិមិត្ត

និងគតិនិមិត្តឯណានីមួយ ឲ្យជាអារម្មណ៍ហើយ រមែងឲ្យផលក្នុងឋានៈទាំង ៥ យ៉ាងនេះ គឺឲ្យផលបដិសន្ធិក្នុងអបាយបួន ១ ឲ្យផលជាភវង្គជាបដល់អស់អាយុ តាំងអំពីវារៈទីពីរ ( បន្ទាប់អំពីបដិសន្ធិចិត្តរលត់ទៅ ) ១ ឲ្យផលជាសន្តីរណៈក្នុងបញ្ចវិញ្ញាណវិថីដែលជាអនិដ្ឋារម្មណ៍ និងអនិដ្ឋមជ្ឈត្តារម្មណ៍ ១ ឲ្យផលជាតទារម្មណៈក្នុងទ្វារ ៦ ក្នុងអារម្មណ៍ដែលមានកម្លាំង ១ ឲ្យផលជាចុតិចិត្តក្នុងមរណកាល ១ ។

## អធិប្បាយអកុសលវិបាក ចប់

# អភិធម្មបិដក

## កាមាវចរកិរិយា

[ ៤៨២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ មនោធាតុជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្ដី ។បេ។ មានផោដ្ឋព្វៈជាអារម្មណ៍ក្ដីឬក៏ប្រារព្ធអារម្មណ៍ណាៗ កើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៨៣ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៣ ផស្សៈ ១ ។បេ។ មនោធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៨៤ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្ដេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធ កើតមានក្នុង

សម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៨៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោវិញ្ញាណធាតុជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាកប្រកបដោយសោមនស្ស មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ បីតិ សុខៈ ឯកគ្គតារបស់ចិត្ត វិរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ សោមនស្សិន្ទ្រិយ ជីវិតិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យា-ក្រឹត ។

[ ៤៨៦ ] ផស្សៈ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ការប៉ះពាល់ ការពាល់ត្រូវ ការទង្គិកទង្គិចណា ក្នុងសម័យនោះ នេះផស្សៈកើតមានក្នុងសម័យនោះ ។បេ។ ឯកគ្គតារបស់ចិត្ត កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតាំងនៅស៊ប់ ការតាំងនៅមាំ ការមិនឃ្លេងឃ្លោងការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់រម្ងាប់ គឺសមា-ធិន្ទ្រិយ សមាធិពលៈណារបស់ចិត្ត ក្នុងសម័យនោះ នេះឯកគ្គតារបស់ចិត្តកើតមានក្នុងសម័យនោះ ។បេ។ វិរិយិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ សេចក្តីប្រារព្ធព្យាយាម ប្រព្រឹត្តទៅក្នុងចិត្ត សេចក្តីសង្វាត ឧហាតខិតខំ ព្យាយាម ឧស្សាហ៍ ប្រឹងប្រែង ខ្នះខ្នែង ខ្មីឃ្មាត សេចក្តីសង្វាតមិន

ធុរថយ ការមិនដាក់សេចក្តីប៉ុនប៉ង ការមិនដាក់ធុរៈ សេចក្តីផ្គងនូវធុរៈ គឺវីរិយៈ វីរិយិន្ទ្រិយ វីរិយពលៈណាក្នុងសម័យនោះ នេះវីរិយិន្ទ្រិយកើតមានក្នុងសម័យនោះ ។ សមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ការឋិតនៅ ការតម្កល់នៅស៊ប់ ការតម្កល់នៅនឹង ការមិនឃ្លេងឃ្លោង ការមិនរាយមាយ ភាពនៃចិត្តមិនឃ្លេងឃ្លោង សេចក្តីស្ងប់ម្ងាប់ គឺសមាធិន្ទ្រិយ សមាធិពលៈណារបស់ចិត្ត ក្នុងសម័យនោះ នេះសមាធិន្ទ្រិយ កើតមានក្នុងសម័យនោះ ។បេ។ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៨៧ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ផស្សៈ ១ ។បេ។ មនោវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៨៨ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ បីតិ ឯកគ្គតារបស់ចិត្ត វីរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៨៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោវិញ្ញាណធាតុជា

កិរិយា មិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ប្រកបដោយឧបេក្ខា មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ វេទនា សញ្ញា ចេតនា ចិត្ត វិតក្កៈ វិចារៈ ឧបេក្ខា ឯកគ្គតារបស់ចិត្ត វិរិយិន្ទ្រិយ សមាធិន្ទ្រិយ មនិន្ទ្រិយ ឧបេក្ខិន្ទ្រិយ ជីវិតិន្ទ្រិយ ក៏កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ ក៏កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៩០ ] ខន្ធ ៤ កើតមាន ក្នុងសម័យនោះ អាយតនៈ ២ ធាតុ ២ អាហារ ៣ ឥន្ទ្រិយ ៥ ផស្សៈ ១ ។បេ។ មនោវិញ្ញាណធាតុ ១ ធម្មាយតនៈ ១ ធម្មធាតុ ១ កើតមានក្នុងសម័យនោះ ឬក៏ពួកអរូបធម៌ដទៃណាដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៩១ ] សង្ខារក្ខន្ធ កើតមានក្នុងសម័យនោះ តើដូចម្តេច ។ ផស្សៈ ចេតនា វិតក្កៈ វិចារៈ ឯកគ្គតារបស់ចិត្ត វិរិយិន្ទ្រិយ សមាធិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏ពួកអរូបធម៌ដទៃណា ដែលកើតឡើងព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ លើកទុកតែវេទនាខន្ធ សញ្ញាខន្ធ វិញ្ញាណក្ខន្ធចេញ នេះសង្ខារក្ខន្ធកើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៩២ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ មនោវិញ្ញាណធាតុជាកិរិយា មិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក

កើតឡើងហើយ ប្រទ្បំដោយសោមនស្ស ប្រកបដោយញាណ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយសោមនស្ស ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយសោមនស្សប្រាសចាកញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រកបដោយញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រកបដោយញាណ ប្រកបដោយសង្ខារ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ។បេ។ ប្រទ្បំដោយឧបេក្ខា ប្រាសចាកញាណ ប្រកបដោយសង្ខារ មានរូបជាអារម្មណ៍ក្តី ។បេ។ មានធម៌ជាអារម្មណ៍ក្តី ឬក៏ប្រារព្ធអារម្មណ៍ណាៗកើតឡើងហើយក្នុងសម័យណា ផស្សៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៩៣ ] អលោភៈ មានអព្យាក្រឹតជាមូល ។បេ។ អទោសៈ មានអព្យាក្រឹតជាមូល ។បេ។ អមោហៈ មានអព្យាក្រឹត្យជាមូល ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ កាមាវចរកិរិយា ។**

# អដ្ឋកថា

## អធិប្បាយ កិរិយាអព្យាកត

## អធិប្បាយ កិរិយាមនោធាតុចិត្ត

[ ៤៨២ ] *ឥឡូវនេះព្រះមានព្រះភាគ បំណងនឹងសម្ដែងចែកកិរិយា-អព្យាកត ទើបទ្រង់ផ្ដើមពាក្យជាដើមថា* **កតមេ ធម្មា អព្យាកតា** *ដូចតទៅនេះថា*

*បណ្ដាបទកិរិយាអព្យាកតទាំងនោះ បទថា* **កិរិយា** *បានដល់ ត្រឹមតែការធ្វើ ។ មែនពិត ក្នុងកិរិយាចិត្តគ្រប់ជួននោះឯង កិរិយាចិត្តណាមិនដល់ភាពជាជវន កិរិយាចិត្តនោះរមែងមិនមានផល ដូចផ្កាឈើខ្យល់ ( ផ្កាចោលផ្កាមិនផ្លែ ) កិរិយាចិត្តណាដល់ភាពជាជវន កិរិយាចិត្តនោះក៏មិនមានផល ដូចផ្កាឈើដែលមានឫសដាច់ហើយ រមែងត្រឹមតែជាការធ្វើប៉ុណ្ណោះ ព្រោះប្រព្រឹត្តទៅដោយអំណាចញុំាងកិច្ចនោះៗឲ្យសម្រេច ព្រោះហេតុនោះ ទើបត្រាស់ថា* **កិរិយា** *( ការធ្វើ ) ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា* **នេវ កុសលា នាកុសលា** *ជាដើមដូចតទៅនេះថា*

*សភាវធម៌ដែលឈ្មោះថា មិនមែនជាកុសល ព្រោះការមិនមានកុសល-ហេតុ ពោលគឺកុសលមូល ។ ដែលឈ្មោះថា មិនមែនជាអកុសល ព្រោះការមិនមានអកុសលហេតុ ពោលគឺអកុសលមូល ដែលឈ្មោះថា មិនមែនជាកុសល មិនមែនជាអកុសល ព្រោះការមិនមានកុសលនិងអកុសល ជា*

បច្ច័យ ពោលគឺមិនមានយោនិសោមនសិការនិងអយោនិសោមនសិការ ។ ដែលឈ្មោះថា មិនមែនកម្មវិបាក ព្រោះមិនមានហេតុឲ្យកើតឡើង ពោលគឺកុសលនិងអកុសល ។

ក្នុងនិទ្ទេសនៃឯកគ្គតានៃចិត្តដែលជាកិរិយាមនោធាតុនេះ រមែងបានត្រឹមតែការតាំងនៅក្នុងបវត្តិកាលប៉ុណ្ណោះ ។ មែនពិត ចិត្ត ១៧ ដូចនេះ គឺ ទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ មនោវិញ្ញាណធាតុ ៣ វិចិកិច្ឆាសហគតចិត្ត ១ រមែងមិនបានសភាពជាដើមថា **សណ្ឋិតិ អវដ្ឋិតិ** ( ការតាំងនៅនៃចិត្ត ការតាំងមាំនៃចិត្ត ) ព្រោះជាសភាពទុព្វល ។ ពាក្យដ៏សេសទាំងអស់គប្បីជ្រាបដោយន័យដែលពោលហើយក្នុងនិទ្ទេសនៃវិបាកមនោធាតុ វៀរតែទីនៃការកើតឡើង ព្រោះចិត្តនោះ ( មនោធាតុដែលជាវិបាក ) រមែងកើតឡើងក្នុងលំដាប់បញ្ចវិញ្ញាណ ។ តែមនោធាតុដែលជាកិរិយាចិត្តនេះ រមែងកើតមុនចិត្តគ្រប់ដូងក្នុងបវត្តិកាល ក្នុងវិថីនៃបញ្ចទ្វារ ។

សេចក្តីនេះតើដូចម្តេច គឺថា ក្នុងចក្ខុទ្វារ មុនកាលរូបារម្មណ៍ទាំងឡាយដែលជាឥដ្ឋារម្មណ៍ ឥដ្ឋមជ្ឈត្តារម្មណ៍ អនិដ្ឋារម្មណ៍និងអនិដ្ឋមជ្ឈត្តារម្មណ៍ អារម្មណ៍ណានីមួយ ប៉ះខ្ទប់បសាទ មនោធាតុដែលជាកិរិយាចិត្ត ក៏ទទួលអារម្មណ៍នោះ ជាចិត្តប្រព្រឹត្តទៅមុនដោយអំណាចនៃអាវជ្ជនៈ ធ្វើភវង្គឲ្យផ្លាស់ប្តូរទៅកើតឡើង ។ សូម្បីក្នុងសោតទ្វារជាដើមក៏ន័យនេះឯង ។

**អធិប្បាយកិរិយាមនោធាតុចិត្ត ចប់**

# អធិប្បាយ
# កិរិយាមនោវិញ្ញាណធាតុចិត្តសហគតដោយសោមនស្ស

[ ៤៨៥ ] ចិត្តនេះ ក្នុងព្រះបាលីថា **មនោវិញ្ញាណធាតុ ឧប្បន្នា ហោតិ ។បេ។ សោមនស្សសហគតា** ដូច្នេះ ជាចិត្តចំពោះបុគ្គលមិនទូទៅដល់ពួកសត្វដទៃក្រៅអំពីព្រះខីណាស្រពប៉ុណ្ណោះ រមែងបានក្នុងទ្វារ ៦ ។

មែនពិត ក្នុងចក្ខុទ្វារ ព្រះខីណាស្រព ឃើញទីដែលសមគួរដល់ការធ្វើសេចក្តីព្យាយាម រមែងដល់សោមនស្សដោយចិត្តនេះ ។ ក្នុងសោតទ្វារព្រះខីណាស្រពដល់ទីដែលគួរដល់ការចែកកណ្ឌៈ កាលបុគ្គលដែលលោភលន់ធ្វើសំឡេងខ្លាំងកាន់យក លោកក៏ដល់សោមនស្សដោយចិត្តនេះថា តណ្ហាជាហេតុឲ្យញាប់ញ័រថែបនេះ អាត្មាអញលះបង់បានហើយ ដូច្នេះ ។ ក្នុងឃានទ្វារ កាលព្រះខីណាស្រពបូជាព្រះចេតិយដោយគ្រឿងក្រអូប ឬផ្កា ក៏ដល់នូវសោមនស្សដោយចិត្តនេះ ។ ក្នុងជិវ្ហាទ្វារ ព្រះខីណាស្រពចែកបិណ្ឌបាតដែលដល់ព្រមដោយរសដែលបានមក កាលធាន់ក៏ដល់សោមនស្ស ដោយចិត្តនេះថា សារាណីយធម៌ ( ធម៌ដែលគួររឭកដល់គ្នានឹងគ្នា ) អាត្មាអញបំពេញហើយហ្ន៎ ដូច្នេះ ។ ក្នុងកាយទ្វារ ព្រះខីណាស្រពបំពេញអភិសមាចារិកវត្ត ក៏ដល់សោមនស្សដោយចិត្តនេះថា វត្តក្នុងកាយទ្វាររបស់អញពេញជុំវិញហើយ ។ កិរិយាមនោវិញ្ញាណធាតុ រមែងបានក្នុងបញ្ចទ្វារយ៉ាងនេះ ។

តែក្នុងមនោទ្វារ ចិត្តដួងនេះ រមែងកើតឡើងប្រារព្ធអតីតនិងអនាគត ។ ពិតណាស់ ព្រះតថាគតទ្រង់រឭកដល់ហេតុដែលទ្រង់ធ្វើហើយ ក្នុងគ្រាដែលព្រះអង្គសោយព្រះជាតិ ជាជោតិបាលមាណព ជាមឃទេវរាជនិងជាកណ្ហ-

តាបសជាដើម ទើបទ្រង់ធ្វើការញញឹមឲ្យប្រាកដ ការរឭកនោះជាកិច្ចរបស់បុព្វេនិវាសញ្ញាណនិងសព្វញ្ញុតញ្ញាណ ក្នុងវេលាចុងក្រោយបំផុតនៃការប្រព្រឹត្តទៅរបស់ញាណទាំងពីរនោះ ចិត្តដួងនេះរមែងកើតការរីករាយ ។ ទ្រង់បានធ្វើការញញឹមឲ្យប្រាកដថា ក្នុងអនាគតនឹងមានព្រះបច្ចេកពុទ្ធមានសំឡេងពីរោះដូចសំឡេងពិណនិងដូចសំឡេងសម្ភោរ ។ ការរឭកនោះជាកិច្ចរបស់អនាគតំសញ្ញាណនិងសព្វញ្ញុតញ្ញាណ ។ ក្នុងវេលាជាទីបំផុតនៃការប្រព្រឹត្តទៅរបស់ញាណទាំងពីនោះ ចិត្តនេះរមែងកើតការរីករាយ ។

ក្នុងនិទ្ទេសវារៈនៃហសិតុប្បាទចិត្តនេះ ទ្រង់តាំងឯកគ្គតានៃចិត្តទុក ដល់សមាធិពលៈ ព្រោះមានកម្លាំងជាងអហេតុកចិត្តដ៏សេស ដល់វីរិយិន្ទ្រិយទ្រង់ក៏តាំងទុកដល់វីរិយពលៈ តែព្រោះក្នុងឧទ្ទេសមិនបានត្រាស់ទុកថា សមាធិពលៈរមែងមាន វីរិយពលៈរមែងមាន ដូច្នេះ ។ ពាក្យទាំង ២ នេះ ឈ្មោះថា **៣ល** ដោយអត្ថថា ជាកម្លាំងដែលបរិបូណ៌ក៏មិនមែន ព្រោះចិត្តដួងនេះមិនមែនកុសល មិនមែនអកុសល ហេតុនោះទើបមិនត្រាស់ទុកថាជា **៣លៈ** ដូច្នេះ និងព្រោះចិត្តដួងនេះ មិនមែនពលៈ ដោយនិប្បរិយាយ ( ដោយត្រង់ ) ហេតុនោះ សូម្បីក្នុងសង្គហវារៈ ក៏មិនបានត្រាស់ថា ពលៈ ២ ( សតិពលៈនិងវីរិយពលៈ ) រមែងមាន ដូច្នេះ ។ ពាក្យដ៏សេសទាំងអស់គប្បីជ្រាបដោយន័យដែលពោលហើយក្នុងនិទ្ទេសនៃអហេតុកមនោវិញ្ញាណធាតុដែលសហគតៈដោយសោមនស្សន្ទ៉ុះឯង ។

# អធិប្បាយ
# កិរិយាមនោវិញ្ញាណធាតុចិត្ត
# សហគតដោយឧបេក្ខា

[ ៤៨៩ ] បទថា **ឧបេក្ខាសហគតំ** មានវិនិច្ឆ័យដូចតទៅនេះថា ចិត្តដូងនេះ ទូទៅដល់សត្វអ្នកមានចិត្តគ្រប់ចំពូក ក្នុងភពទាំង ៣ ឈ្មោះថា រមែងមិនកើតឡើងដល់សត្វដែលមានចិត្តពូកខ្វះមិនមាន ។ តែកាលកើតក្នុងបញ្ចទ្វារ រមែងជាវោដ្ឋព្វនកិច្ច កាលកើតក្នុងមនោទ្វាររមែងជាអាវជ្ជនកិច្ច ។ សូម្បីអសាធារណញ្ញាណ ៦ រមែងទទួលអារម្មណ៍ដែលចិត្តនេះទទួលហើយដូចគ្នា ។

ចិត្តនេះ ឈ្មោះថា **មហាគជ** ( ដំរីធំ ) ឈ្មោះថា វត្ថុដែលមិនជាអារម្មណ៍របស់ចិត្តនេះមិនមាន ។ កាលមានពាក្យសួរថា ចិត្តដែលមិនមែនសព្វញ្ញុតញ្ញាណ តែឈ្មោះថាមានគតិដូចសព្វញ្ញុតញ្ញាណ ជាចិត្តដូងណា គប្បីឆ្លើយថា ចិត្តដួងនេះ ( មនោវិញ្ញាណធាតុជាកិរិយាចិត្តសហគតៈដោយឧបេក្ខា ) ពាក្យដ៏សេសក្នុងចិត្តនេះគប្បីជ្រាបដោយន័យដែលពោលទុកក្នុងចិត្តដួងមុន ( មនោវិញ្ញាណធាតុជាកិរិយាចិត្តសហគតៈដោយសោមនស្ស ) នុ៎ះឯង តែក្នុងហសនចិត្ត ( មនោវិញ្ញាណធាតុជាកិរិយាចិត្តសហគតៈដោយសោមនស្ស ) នោះ ទ្រង់ចែកសង្ខារក្ខន្ធ មានអង្គ ៩ ព្រោះមានបីតិ តែក្នុងចិត្តដួងនេះ ទ្រង់ចែកសង្ខារក្ខន្ធ មានអង្គ ៨ ព្រោះមិនមានបីតិ ។

# អធិប្បាយ

## មហាកិរិយាចិត្ត ៨ ដួង

[ ៤៩២ ] មហាកិរិយាចិត្ត ៨ ដួងទុំះឯង ខាងកុសលពួកណាជាកិរិយាចិត្ត ព្រោះការកើតឡើងដល់ព្រះខីណាស្រព ព្រោះហេតុនោះឥឡូវនេះគប្បីជ្រាបមហាកិរិយាចិត្តទាំងនោះ ដោយន័យតាមដែលពោលក្នុងកុសលនិទ្ទេសទុំះឯង ។

**អធិប្បាយមហាកិរិយាចិត្ត ៨ ដួង ចប់**

## ពោលដោយ ហសនកចិត្ត ១៣ ដួង

បណ្ឌិតគប្បីញ៉ាំងហសនកចិត្តឲ្យប្រជុំចុះក្នុងទីនេះ ។ សួរថា ហសនកចិត្តទាំងនេះ មានប៉ុន្មាន ឆ្លើយថា មាន ១៣ ដួង ។ មែនពិត បុថុជ្ជនរមែងសើចដោយចិត្ត ៨ ដួង គឺកុសលចិត្តសហគតៈដោយសោមនស្ស ៤ ដួង អកុសលចិត្តសហគតៈដោយសោមនស្ស ៤ ដួង ។ ព្រះសេក្ខៈរមែងសើចដោយចិត្ត ៦ ដួង គឺកុសលចិត្តដែលសហគតៈដោយសោមនស្ស ៤ ដួង អកុសលចិត្តដែលសហគតៈដោយសោមនស្ស មិនប្រកបដោយទិដ្ឋិ ២ ដួង ។ ព្រះខីណាស្រព រមែងសើចដោយកិរិយាចិត្ត ដែលសហគតៈដោយសោមនស្ស ៥ ដួង គឺហសិតុប្បាទចិត្តសហគតៈដោយសោមនស្ស ១ ដួង មហាកិរិយាចិត្តសហគតៈដោយសោមនស្ស ៤ ដួង ។

**អធិប្បាយកាមាវចរកិរិយា ចប់**

# អភិធម្មបិដក

## រូបាវចរកិរិយា និងអរូបាវចរកិរិយា

[ ៤៩៤ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវរូបាវចរជ្ឈាន ជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់បឋមជ្ឈាន មានដីជាកសិណ ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

[ ៤៩៥ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវរូបាវចរជ្ឈាន ជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានរម្ងាប់វិតក្កៈនិងវិចារៈ ។បេ។ ទុតិយជ្ឈាន ។បេ។ តតិយជ្ឈាន ។បេ។ ចតុត្ថជ្ឈាន ។បេ។ បឋមជ្ឈាន ។បេ។ បានដល់បញ្ចមជ្ឈាន មានដីជាកសិណ ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។បេ។

### ចប់ រូបាវចរកិរិយា ។

[ ៤៩៦ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវអរូបាវចរជ្ឈាន ជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានកន្លងបង់នូវពួករូបសញ្ញា

ដោយប្រការទាំងពួង បានកម្ចាត់បង់ពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈានប្រឡំដោយអាកាសានញ្ចាយតនសញ្ញា ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៩៧ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវអរូបាវចរជ្ឈាន ជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានកន្លងបង់នូវអាកាសានញ្ចាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រឡំដោយវិញ្ញាណញ្ចាយតនសញ្ញា ក្នុងសម័យណា ផស្សៈក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៩៨ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវអរូបាវចរជ្ឈាន ជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានកន្លងបង់នូវវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈាន ប្រឡំដោយអាកិញ្ចញ្ញាយតនសញ្ញាក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមាន ក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៤៩៩ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្តេច ។ បុគ្គលចម្រើននូវអរូបាវចរជ្ឈាន ជាកិរិយាមិនមែនជាកុសល មិនមែនជាអកុសល ទាំងមិនមែនជាកម្មវិបាក ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន បានកន្លងបង់នូវអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង លះបង់នូវសុខផង ។បេ។ បានដល់ចតុត្ថជ្ឈានប្រឡំដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ក្នុងសម័យណា ផស្សៈ ក៏កើតមានក្នុងសម័យនោះ ។បេ។ អវិក្ខេបៈក៏កើតមានក្នុងសម័យនោះ ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

[ ៥០០ ] អលោភៈ មានអព្យាក្រឹតជាមូល ។បេ។ អទោសៈ មានអព្យាក្រឹតជាមូល ។បេ។ អមោហៈ មានអព្យាក្រឹតជាមូល ។បេ។ នេះពួកធម៌ជាអព្យាក្រឹត ។

**ចប់ អរូបាវចរកិរិយា ។**

**ចប់ ចិត្តុប្បាទកណ្ឌ ។**

# អដ្ឋកថា

## អធិប្បាយ រូបាវចរ និងអរូបាវចរកិរិយា

[ ៤៩៤-៥០០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរូបាវចរកិរិយានិងអរូបាវចរកិរិយា ដូចតទៅនេះថា

បទថា **ទិដ្ឋធម្មសុខវិហារំ** បានដល់ ត្រឹមតែនៅជាសុខក្នុងទិដ្ឋធម៌ គឺក្នុងអត្តភាពនេះប៉ុណ្ណោះ ។ ក្នុងទិដ្ឋធម្មសុខវិហារនោះ សមាបត្តិដែលព្រះខីណាស្រពឲ្យកើតឡើង ក្នុងវេលានៅជាបុថុជ្ជន ជាកុសលប៉ុណ្ណោះ ដរាបណាដែលលោកមិនទាន់ចូលដល់ទិដ្ឋធម្មសុខវិហារនោះ ក្នុងវេលាដែលលោកចូលដល់ហើយ សមាបត្តិនោះរមែងជាកិរិយា តែសមាបត្តិដែលព្រះខីណាស្រពនោះឲ្យកើតឡើងក្នុងវេលាដែលលោកជាព្រះខីណាស្រពហើយ រមែងជាកិរិយាប៉ុណ្ណោះ ។ ពាក្យដ៏សេសទាំងអស់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងកុសលនិទ្ទេសនោះឯង ព្រោះដូចគ្នានឹងកុសលនោះ ដូច្នេះ ។

អធិប្បាយរូបាវចរនិងអរូបាវចរកិរិយា ចប់

កថាពោលដោយចិត្តុប្បាទកណ្ឌ

ក្នុងអដ្ឋសាលិនីអដ្ឋកថាធម្មសង្គហ ( ធម្មសង្គណី ) ចប់

ការចែកអព្យាកតបទ ( រូបនិងនិព្វាន ) មិនទាន់ចប់នៅឡើយទេ

អដ្ឋកថាចិត្តុប្បាទកណ្ឌ ចប់

# អភិធម្មបិដក

## ធម្មសង្គណី ទុតិយភាគ

## (រូបកណ្ឌ)

## ធម៌មានប្រមាណមួយជាដើម

[ ១ ] ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ វិបាកនៃពួកធម៌ជាកុសល និងអកុសលជាកាមាវចរ រូបាវចរ អរូបាវចរ ជាអបរិយាបន្ន ( មិនរាប់ចូលក្នុងភូមិវដ្ដៈទាំង ៣ ) វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ទាំងពួកធម៌ដែលជាកិរិយា មិនមែនជាកុសល មិនមែនជាអកុសលក្ដី មិនមែនជាកម្មវិបាកក្ដី រូបទាំងអស់ក្ដី ធាតុដែលបច្ច័យមិនបានប្រជុំតាក់តែង ( ព្រះនិព្វាន ) ក្ដី នេះពួកធម៌ជាអព្យាក្រឹត ។

[ ២ ] បណ្ដាធម៌ទាំងនោះ រូបទាំងអស់ តើដូចម្ដេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ នេះ ហៅថា រូបទាំងអស់ ។

[ ៣ ] រូបទាំងអស់មិនមែនជាហេតុ ឥតហេតុ ប្រាសចាកហេតុ ប្រកបដោយបច្ច័យ រូបដែលបច្ច័យតាក់តែង ជាលោកិយៈ ប្រកបដោយអាសវៈ ជាប្រយោជន៍ដល់សញ្ញោជនៈ ដែលគន្ថៈគប្បីដោតក្រង ដែលឱឃៈគប្បីប្រព្រឹត្តកន្លង ដែលយោគៈគប្បីប្រព្រឹត្តកន្លង ជាប្រយោជន៍ដល់នីវរណៈ ដែលបរាមាសស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន គួរដល់សេចក្ដីសៅហ្មង ជាអព្យាក្រឹត មិនមានអារម្មណ៍ មិនមែនជាចេតសិក ប្រាសចាកចិត្ត ជាសភាវៈមិនមែនជាវិបាក មិនមែនមានវិបាកជាប្រក្រតី ជារូបមិនសៅហ្មង

ដែលគួរដល់សេចក្តីសៅហ្មង មិនមែនប្រកបដោយវិតក្កៈប្រកបដោយវិចារៈទេ មិនមែនមិនមានវិតក្កៈ ហើយមានត្រឹមតែវិចារៈទេ ជារូបមិនមានវិតក្កៈ មិនមានវិចារៈ មិនប្រកបដោយបីតិ មិនប្រកបដោយសុខៈ មិនប្រកបដោយឧបេក្ខា ជារូបមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ជារូបមានហេតុ មិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ជារូបមិនមែនជាដល់នូវការសន្សំកពូនឡើង មិនមែនជាមិនដល់នូវការសន្សំកពូនឡើង មិនមែនជាសេក្ខៈ មិនមែនជាអសេក្ខៈ មានសភាពតូចឆ្មារ ជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ រាប់ចូលក្នុងវដ្តៈ មិនមែនជាមិនរាប់ចូលក្នុងវដ្តៈ ជាអនិយតៈ មិនមែនជានិយ្យានិកៈ ជាឧប្បន្នរូប ជារូបត្រូវដឹងដោយវិញ្ញាណ ៦ ជារូបមិនទៀងដែលជរាគ្របសង្កត់ ការសង្គ្រោះរូបដោយចំណែកមួយយ៉ាងនេះ ។

## ចប់ ធម៌មានប្រមាណមួយ ។

[ ៤ ] ការសង្គ្រោះរូបដោយចំណែក ២ គឺរូបជាឧបាទានិងរូបមិនមែនជាឧបាទា រូបជាឧបាទិន្នៈនិងរូបជាអនុបាទិន្នៈ រូបជាឧបាទិន្នុបាទានិយៈនិងរូបជាអនុបាទិន្នុបាទានិយៈ រូបជាសនិទស្សនៈនិងរូបជាអនិទស្សនៈ រូបជាសប្បដិឃៈនិងរូបជាអប្បដិឃៈ រូបជាឥន្ទ្រិយនិងរូបមិនមែនជាឥន្ទ្រិយ រូបជាមហាភូតរូបនិងរូបមិនមែនជាមហាភូតរូប រូបជាវិញ្ញត្តិនិងរូបមិនមែនជាវិញ្ញត្តិ រូបជាចិត្តសមុដ្ឋាននិងរូបមិនមែនជាចិត្តសមុដ្ឋាន រូបកើតជាមួយនឹងចិត្តនិងរូបមិនកើតជាមួយនឹងចិត្ត រូបប្រព្រឹត្តទៅតាមចិត្តនិងរូបមិនប្រព្រឹត្តទៅតាមចិត្ត

រូបខាងក្នុងនិងរូបខាងក្រៅ រូបគ្រោតគ្រាតនិងរូបល្អិត រូបឆ្ងាយនិងរូបជិត ។ រូបជាវត្ថុនៃចក្ខុសម្ផស្ស និងរូបមិនមែនជាវត្ថុនៃចក្ខុសម្ផស្ស រូបជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណ និងរូបមិនមែនជាវត្ថុនៃចក្ខុវិញ្ញាណ រូបជាវត្ថុនៃសោតសម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្សនិងរូបមិនមែនជាវត្ថុនៃកាយសម្ផស្ស រូបជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណនិងរូបមិនមែនជាវត្ថុនៃកាយវិញ្ញាណ ។ រូបជាអារម្មណ៍នៃចក្ខុសម្ផស្ស និងរូបមិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្ស រូបជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណ និងរូបមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណ ។ រូបជាអារម្មណ៍នៃសោតសម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្ស និងរូបមិនមែនជាអារម្មណ៍នៃកាយសម្ផស្ស រូបជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនា ដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណ និងរូបមិនមែនជាអារម្មណ៍នៃកាយវិញ្ញាណ ។ រូបជាចក្ខាយតនៈ និងរូបមិនមែនជាចក្ខាយតនៈ រូបជាសោតាយតនៈនិងរូបមិនមែនជាសោតាយតនៈ រូបជាឃានាយតនៈ ។បេ។ ជាជិវ្ហាយតនៈ ។បេ។ ជាកាយាយតនៈ និងរូបមិនមែនជាកាយាយតនៈ រូបជារូបាយតនៈនិងរូបមិនមែនជារូបាយតនៈ រូបជាសទ្ទាយតនៈ ។បេ។ ជាគន្ធាយតនៈ ។បេ។ ជារសាយតនៈ ។បេ។

ជាផោដ្ឋព្វាយតនៈនិងរូបមិនមែនជាផោដ្ឋព្វាយតនៈ ។ រូបជាចក្ខុធាតុនិងរូប មិនមែនជាចក្ខុធាតុ រូបជាសោតធាតុ ។បេ។ ជាឃានធាតុ ។បេ។ ជាជិវ្ហា-ធាតុ ។បេ។ ជាកាយធាតុនិងរូបមិនមែនជាកាយធាតុ រូបជារូបធាតុនិងរូបមិន មែនជារូបធាតុ រូបជាសទ្ទធាតុ ។បេ។ ជាគន្ធធាតុ ។បេ។ ជារសធាតុ ។បេ។ ជាផោដ្ឋព្វធាតុ និងរូបមិនមែនជាផោដ្ឋព្វធាតុ ។ រូបជាចក្ខុន្ទ្រិយ និងរូបមិន មែនជាចក្ខុន្ទ្រិយ រូបជាសោតិន្ទ្រិយ ។បេ។ ជាឃានិន្ទ្រិយ ។បេ។ ជាជិវ្ហិ-ន្ទ្រិយ ។បេ។ ជាកាយិន្ទ្រិយនិងរូបមិនមែនជាកាយិន្ទ្រិយ រូបជាឥត្ថិន្ទ្រិយនិង រូបមិនមែនជាឥត្ថិន្ទ្រិយ រូបជាបុរិសិន្ទ្រិយនិងរូបមិនមែនជាបុរិសិន្ទ្រិយ រូបជា ជីវិតិន្ទ្រិយនិងរូបមិនមែនជាជីវិតិន្ទ្រិយ ។ រូបជាកាយវិញ្ញត្តិនិងរូបមិនមែនជា កាយវិញ្ញត្តិ រូបជាវចីវិញ្ញត្តិនិងរូបមិនមែនជាវចីវិញ្ញត្តិ រូបជាអាកាសធាតុនិង រូបមិនមែនជាអាកាសធាតុ រូបជាអាបោធាតុនិងរូបមិនមែនជាអាបោធាតុ រូប ជារូបស្សលហុតានិងរូបមិនមែនជារូបស្សលហុតា រូបជារូបស្សមុទុតានិងរូប មិនមែនជារូបស្សមុទុតា រូបជារូបស្សកម្មញ្ញតានិងរូបមិនមែនជារូបស្សកម្ម-ញ្ញតា រូបជារូបស្សឧបចយនិងរូបមិនមែនជារូបស្សឧបចយ រូបជារូបស្ស-សន្តតិនិងរូបមិនមែនជារូបស្សសន្តតិ រូបជារូបស្សជរតានិងរូបមិនមែនជារូប-ស្សជរតា រូបជារូបស្សអនិច្ចតានិងរូបមិនមែនជារូបស្សអនិច្ចតា រូបជាកពឡិង្ការាហារនិងរូបមិនមែនជាកពឡិង្ការាហារ ការសង្គ្រោះរូបដោយចំណែក ២ យ៉ាងនេះ ។

**ចប់ ធម៌មានប្រមាណពីរ ។**

[ ៥ ] ការសង្គ្រោះរូបដោយចំណែក ៣ គឺរូបណាខាងក្នុង រូបនោះជាឧបាទា រូបណាខាងក្រៅ រូបនោះជាឧបាទា និងមិនមែនជាឧបាទាក៏មាន រូបណាខាងក្នុង រូបនោះជាឧបាទិន្នៈ រូបណាខាងក្រៅ រូបនោះជាឧបាទិន្នៈ និងជាអនុបាទិន្នក៏មាន រូបណាខាងក្នុងរូបនោះជាឧបាទិន្នុបាទានិយៈ រូបណាខាងក្រៅ រូបនោះជាឧបាទិន្នុបាទានិយៈ និងជាអនុបាទិន្នុបាទានិយៈក៏មាន រូបណាខាងក្នុង រូបនោះជាអនិទស្សនៈ រូបណាខាងក្រៅ រូបនោះជាសនិទស្សនៈ និងជាអនិទស្សនៈក៏មាន រូបណាខាងក្នុង រូបនោះជាសប្បដិឃៈ រូបណាខាងក្រៅ រូបនោះជាសប្បដិឃៈ និងជាអប្បដិឃៈក៏មាន រូបណាខាងក្នុង រូបនោះជាឥន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាឥន្ទ្រិយ និងមិនមែនជាឥន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាមហាភូត រូបណាខាងក្រៅ រូបនោះជាមហាភូត និងមិនមែនជាមហាភូតក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាវិញ្ញត្តិ រូបណាខាងក្រៅ រូបនោះជាវិញ្ញត្តិ និងមិនមែនជាវិញ្ញត្តិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាចិត្តសមុដ្ឋាន រូបណាខាងក្រៅ រូបនោះជាចិត្តសមុដ្ឋាន និងមិនមែនជាចិត្តសមុដ្ឋានក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាចិត្តសហភូ រូបណាខាងក្រៅ រូបនោះជាចិត្តសហភូ និងមិនមែនជាចិត្តសហភូក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាចិត្តានុបរិវត្តិ រូបណាខាងក្រៅ រូបនោះជាចិត្តានុបរិវត្តិ និងមិនមែនជាចិត្តានុបរិវត្តិក៏មាន រូបណាខាងក្នុង រូបនោះជាឱឡារិកៈ រូបណាខាងក្រៅ រូបនោះជាឱឡារិកៈ និងជាសុខុមក៏មាន រូបណាខាងក្នុង រូបនោះជាសន្តិកេរូប រូបណាខាងក្រៅ រូបនោះជា

ទូរេរូប និងជាសន្តិកេរូបក៏មាន ។ រូបជាខាងក្រៅ រូបនោះមិនមែនជាវត្ថុនៃចក្ខុសម្ផស្ស រូបណាខាងក្នុង រូបនោះជាវត្ថុនៃចក្ខុសម្ផស្សនិងមិនមែនជាវត្ថុនៃចក្ខុសម្ផស្សក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណក៏មាន រូបណាខាងក្នុង រូបនោះជាវត្ថុនៃចក្ខុវិញ្ញាណនិងមិនមែនជាវត្ថុនៃចក្ខុ-វិញ្ញាណក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុនៃសោតសម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្ស រូបណាខាងក្នុង រូបនោះជាវត្ថុនៃកាយសម្ផស្ស និងមិនមែនជាវត្ថុនៃកាយសម្ផស្សក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណ រូបណាខាងក្នុង រូបនោះជាវត្ថុនៃកាយវិញ្ញាណនិងមិនមែនជាវត្ថុនៃកាយវិញ្ញាណក៏មាន ។ រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្ស រូបណាខាងក្រៅ រូបនោះជាអារម្មណ៍នៃចក្ខុសម្ផស្ស និងមិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្សក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណ រូបណាខាងក្រៅ រូបនោះជាអារម្មណ៍នៃចក្ខុវិញ្ញាណ និងមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍នៃសោត-សម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយ-សម្ផស្ស រូបណាខាងក្រៅ រូបនោះជាអារម្មណ៍នៃកាយសម្ផស្ស និងមិនមែន

ជាអារម្មណ៍នៃកាយសម្ផស្សក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណ រូបណាខាងក្រៅ រូបនោះជាអារម្មណ៍នៃកាយវិញ្ញាណ និងមិនមែនជាអារម្មណ៍នៃកាយវិញ្ញាណក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាចក្ខាយតនៈ រូបណាខាងក្នុង រូបនោះជាចក្ខាយតនៈ និងមិនមែនជាចក្ខាយតនៈក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាសោតាយតនៈ ។បេ។ មិនមែនជាឃានាយតនៈ ។បេ។ មិនមែនជាជិវ្ហាយតនៈ ។បេ។ មិនមែនជាកាយាយតនៈ រូបណាខាងក្នុង រូបនោះជាកាយាយតនៈ និងមិនមែនជាកាយាយតនៈក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបាយតនៈ រូបណាខាងក្រៅ រូបនោះជារូបាយតនៈ និងមិនមែនជារូបាយតនៈក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាសទ្ទាយតនៈ ។បេ។ មិនមែនជាគន្ធាយតនៈ ។បេ។ មិនមែនជារសាយតនៈ ។បេ។ មិនមែនជាផោដ្ឋព្វាយតនៈ រូបណាខាងក្រៅ រូបនោះជាផោដ្ឋព្វាយតនៈ និងមិនមែនជាផោដ្ឋព្វាយតនៈ ក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាចក្ខុធាតុ រូបណាខាងក្នុង រូបនោះជាចក្ខុធាតុ និងមិនមែនជាចក្ខុធាតុក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាសោតធាតុ ។បេ។ មិនមែនជាឃានធាតុ ។បេ។ មិនមែនជាជិវ្ហាធាតុ ។បេ។ មិនមែនជាកាយធាតុ រូបណាខាងក្នុង រូបនោះជាកាយធាតុនិងមិនមែនជាកាយធាតុក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបធាតុ រូបណាខាងក្រៅ រូបនោះជារូបធាតុ និងមិនមែនជារូបធាតុក៏មាន រូបណាខាង

ក្នុង រូបនោះមិនមែនជាសទ្ទធាតុ ។បេ។ មិនមែនជាគន្ធធាតុ ។បេ។ មិនមែនជារសធាតុ ។បេ។ មិនមែនជាផោដ្ឋព្វធាតុ រូបណាខាងក្រៅ រូបនោះជាផោដ្ឋព្វធាតុនិងមិនមែនជាផោដ្ឋព្វធាតុក៏មាន ។ រូបណាខាងក្រៅ រូបនោះមិនមែនជាចក្ខុន្ទ្រិយ រូបណាខាងក្នុង រូបនោះជាចក្ខុន្ទ្រិយនិងមិនមែនជាចក្ខុន្ទ្រិយក៏មាន រូបណាខាងក្រៅ រូបនោះមិនមែនជាសោតិន្ទ្រិយ ។បេ។ មិនមែនជាឃានិន្ទ្រិយ ។បេ។ មិនមែនជាជិវ្ហិន្ទ្រិយ ។បេ។ មិនមែនជាកាយិន្ទ្រិយ រូបណាខាងក្នុង រូបនោះជាកាយិន្ទ្រិយ និងមិនមែនជាកាយិន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាឥត្ថិន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាឥត្ថិន្ទ្រិយនិងមិនមែនជាឥត្ថិន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាបុរិសិន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាបុរិសិន្ទ្រិយ និងមិនមែនជាបុរិសិន្ទ្រិយក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាជីវិតិន្ទ្រិយ រូបណាខាងក្រៅ រូបនោះជាជីវិតិន្ទ្រិយ និងមិនមែនជាជីវិតិន្ទ្រិយក៏មាន ។ រូបណាខាងក្នុង រូបនោះមិនមែនជាកាយវិញ្ញត្តិ រូបណាខាងក្រៅ រូបនោះជាកាយវិញ្ញត្តិនិងមិនមែនជាកាយវិញ្ញត្តិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាវចីវិញ្ញត្តិ រូបណាខាងក្រៅ រូបនោះជាវចីវិញ្ញត្តិ និងមិនមែនជាវចីវិញ្ញត្តិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអាកាសធាតុ រូបណាខាងក្រៅ រូបនោះជាអាកាសធាតុ និងមិនមែនជាអាកាសធាតុក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាអាបោធាតុ រូបណាខាងក្រៅ រូបនោះជាអាបោធាតុ និងមិនមែនជាអាបោធាតុក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្ស លហុតា រូបណាខាងក្រៅ រូបនោះជារូ-

បស្សលហុតា និងមិនមែនជារូបស្សលហុតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សមុទុតា រូបណាខាងក្រៅ រូបនោះជារូបស្សមុទុតា និងមិនមែនជារូបស្សមុទុតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សកម្មញ្ញតា រូបណាខាងក្រៅ រូបនោះជារូបស្សកម្មញ្ញតា និងមិនមែនជារូបស្សកម្មញ្ញតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សឧបចយៈ រូបណាខាងក្រៅ រូបនោះជារូបស្សឧបចយៈ និងមិនមែនជារូបស្សឧបចយៈក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សសន្តតិ រូបណាខាងក្រៅ រូបនោះជារូបស្សសន្តតិ និងមិនមែនជារូបស្សសន្តតិក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សជរតា រូបណាខាងក្រៅ រូបនោះជារូបស្សជរតានិងមិនមែនជារូបស្សជរតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជារូបស្សអនិច្ចតា រូបណាខាងក្រៅ រូបនោះជារូបស្សអនិច្ចតា និងមិនមែនជារូបស្សអនិច្ចតាក៏មាន រូបណាខាងក្នុង រូបនោះមិនមែនជាកពឡិង្ការាហារ រូបណាខាងក្រៅ រូបនោះជាកពឡិង្ការាហារនិងមិនមែនជាកពឡិង្ការាហារក៏មាន ការសង្គ្រោះរូបដោយចំណែក ៣ យ៉ាងនេះ ។

## ចប់ រូបមានប្រមាណ ៣ ។

[ ៦ ] ការសង្គ្រោះរូប ដោយចំណែក ៤ គឺរូបណាជាឧបាទា រូបនោះជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន រូបណាជាអនុបាទា រូបនោះជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន រូបណាជាឧបាទា រូបនោះជាឧបាទិន្នុបាទានិយៈក៏មាន ជាអនុបាទិន្នុបាទានិយៈក៏មាន រូបណាជាអនុបាទា រូបនោះជាឧបាទិន្នុ-

បាទិយៈក៏មាន ជាអនុបាទិន្នុបាទានិយៈក៏មាន រូបណាជាឧបាទា រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទា រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាឧបាទា រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាអនុបាទា រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឧបាទា រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាជាអនុបាទា រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ រូបណាជាឧបាទិន្ន រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាឧបាទិន្ន រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាឧបាទិន្ន រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាឧបាទិន្ន រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឧបាទិន្ន រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាជាអនុបាទិន្ន រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាសនិទស្សនៈ ក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាអនុបាទិន្នុបាទានិយៈ រូបនោះជាសនិទស្សនៈក៏មាន ជាអនិទស្សនៈក៏មាន រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាសប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាអនុបាទិន្នុបានិយៈ រូបនោះជា

សប្បដិឃៈក៏មាន ជាអប្បដិឃៈក៏មាន រូបណាជាឧបាទិន្នុបាទានិយៈ រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាអនុបាទិន្នុបាទានិយៈ រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាឧបាទិន្នុបា-ទានិយៈ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាអនុបាទិន្នុ-បាទានិយៈ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឧបាទិន្នុ-បាទានិយៈ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាជាអនុបា-ទិន្នុបាទានិយៈ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ រូបណាជាសប្បដិឃៈ រូបនោះជាឥន្ទ្រិយក៏មាន មិនមែនជាឥន្ទ្រិយក៏មាន រូបណាជាអប្បដិឃៈ រូបនោះជាឥន្ទ្រិយក៏មាន មិនមែនជាឥន្ទ្រិយក៏មាន រូបណាជាសប្បដិឃៈ រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន រូបណាជាអប្បដិឃៈ រូបនោះជាមហាភូតក៏មាន មិនមែនជាមហាភូតក៏មាន ។ រូបណាជាឥន្ទ្រិយ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាមិនមែនជាឥន្ទ្រិយ រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាឥន្ទ្រិយ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាមិនមែនជាឥន្ទ្រិយ រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ រូបណាជាមហាភូត រូបនោះជាឱឡា-រិកៈក៏មាន ជាសុខុមៈក៏មាន រូបណាមិនមែនជាមហាភូត រូបនោះជាឱឡារិកៈក៏មាន ជាសុខុមៈក៏មាន រូបណាជាមហាភូត រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន រូបណាមិនមែនជាមហាភូត រូបនោះជាទូរេរូបក៏មាន ជាសន្តិកេរូបក៏មាន ។ ( បានដល់ ) រូបដែលបុគ្គលឃើញ ឮ លិទ្ធ ភ្លក្ស

ដឹងច្បាស់ ការសង្គ្រោះរូបដោយចំណែក ៤ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៤ ។

[ ៧ ] ការសង្គ្រោះរូបដោយចំណែក ៥ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុនិងឧបាទារូប ការសង្គ្រោះរូបដោយចំណែក ៥ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៥ ។

[ ៨ ] ការសង្គ្រោះរូបដោយចំណែក ៦ គឺរូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដោយច្រមុះ រូបដែលគប្បីដឹងដោយអណ្តាត រូបដែលគប្បីដឹងដោយកាយ រូបដែលគប្បីដឹងដោយចិត្ត ការសង្គ្រោះរូបដោយចំណែក ៦ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៦ ។

[ ៩ ] ការសង្គ្រោះរូបដោយចំណែក ៧ គឺរូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដោយច្រមុះ រូបដែលគប្បីដឹងដោយអណ្តាត រូបដែលគប្បីដឹងដោយកាយ រូបដែលគប្បីដឹងដោយមនោធាតុ រូបដែលគប្បីដឹងដោយមនោវិញ្ញាណធាតុ ការសង្គ្រោះរូបដោយចំណែក ៧ យ៉ាងនេះ ។

ចប់ រូបមានប្រមាណ ៧ ។

[ ១០ ] ការសង្គ្រោះរូបដោយចំណែក ៨ គឺរូបដែលគប្បីដឹងដោយភ្នែក រូបដែលគប្បីដឹងដោយត្រចៀក រូបដែលគប្បីដឹងដោយច្រមុះ រូបដែលគប្បីដឹងដោយអណ្តាត រូបដែលគប្បីដឹងដោយកាយ រូបមានសម្ផស្សជាសុខមានសម្ផស្សជាទុក្ខ រូបដែលគប្បីដឹងដោយមនោធាតុ រូបដែលគប្បីដឹងដោយមនោវិញ្ញាណធាតុ ការសង្គ្រោះរូបដោយចំណែក ៨ យ៉ាងនេះ ។

## ចប់ រូបមានប្រមាណ ៨ ។

[ ១១ ] ការសង្គ្រោះរូបដោយចំណែក ៩ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយនិងរូបដែលមិនមែនជាឥន្ទ្រិយ ការសង្គ្រោះរូបដោយចំណែក ៩ យ៉ាងនេះ ។

## ចប់ រូបមានប្រមាណ ៩ ។

[ ១២ ] ការសង្គ្រោះរូបដោយចំណែក ១០ គឺចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ រូបមិនមែនជាឥន្ទ្រិយ រូបជាសប្បដិឃៈ ជាអប្បដិឃៈ ការសង្គ្រោះរូបដោយចំណែក ១០ យ៉ាងនេះ ។

## ចប់ រូបមានប្រមាណ ១០ ។

[ ១៣ ] ការសង្គ្រោះរូបដោយចំណែក ១១ គឺចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ

គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈនិងរូបជាអនិទស្សនៈ ជាអប្បដិឃៈ ដែលរាប់ចូលក្នុងធម្មាយតនៈ ការសង្គ្រោះរូបដោយចំណែក ១១ យ៉ាងនេះ ។

**ចប់ រូបមានប្រមាណ ១១ ។**

**ចប់ មាតិកា ។**

# អដ្ឋកថា

# រូបកណ្ឌ

# អធិប្បាយ ឧទ្ទេស

[ ១ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់បំណងនឹងចែករូបកណ្ឌ ទើបទ្រង់ផ្ដើមពាក្យថា **កតមេ ធម្មា អព្យាកតា** ដូច្នេះទៀត ។ ក្នុងពាក្យថា ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេចនោះ ទ្រង់ចែកវិបាកដែលជាអព្យាកតៈ និងកិរិយាដែលជាអព្យាកតៈទុកទាំងអស់ហើយ ក្នុងចិត្តុប្បាទកណ្ឌដែលកន្លងមកហើយក៏ពិត តែទ្រង់មិនទាន់បានត្រាស់អព្យាកត គឺរូប និងអព្យាកតៈគឺព្រះនិព្វាន ។ កាលទ្រង់ប្រមូលអព្យាក្រឹតទាំង ៤ មកសម្ដែង ដើម្បីត្រាស់អព្យាកតៈទាំងពីរ ដែលនៅសល់នោះ ទើបត្រាស់ថា **កុសលាកុសលានំ ធម្មានំ វិបាកា** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **កុសលាកុសលានំ** បានដល់ កុសលនិងអកុសលទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ ព្រះអង្គទ្រង់កាន់យកបទទាំងពីរ គឺកុសលវិបាកនិងអកុសលវិបាក សម្ដែងអព្យាកតវិបាកចិត្តទុកដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ តែព្រោះអព្យាកតៈទាំងអស់នោះ ជាកាមាវចរក៏មាន ជាធម៌យ៉ាងណានីមួយមានរូបាវចរជាដើមក៏មាន ហេតុនោះទើបទ្រង់សម្ដែងអព្យាកតៈ គឺវិបាកនោះនុ៎ះឯង កាន់យកការផ្សេងគ្នានៃភូមិដោយន័យមានពាក្យថា **កាមាវចរា** ជាដើម មួយទៀត ព្រោះអព្យាក្រឹតនោះ ជាវេទនាខន្ធក៏មាន ។បេ។ ជាវិញ្ញាណក្ខន្ធក៏មាន ហេតុនោះទើបទ្រង់

កាន់យកអព្យាក្រឹតនោះ សម្តែងដោយអំណាចខន្ធ ៤ ដែលសម្បយុត្តគ្នា ។

កាលទ្រង់សម្តែងអព្យាកតៈ គឺវិបាកចិត្តយ៉ាងនេះ ដោយកាន់យកន័យទាំង ៣ គឺដោយអំណាចកុសលនិងអកុសល ដោយអំណាចសេចក្តីផ្សេងគ្នានៃភូមិ និងដោយអំណាចខន្ធដែលសម្បយុត្តគ្នាយ៉ាងនេះហើយ កាលទ្រង់សម្តែងអព្យាកតៈ គឺកិរិយាចិត្តទៀត ទើបត្រាស់ពាក្យជាដើមថា **យេ ច ធម្មា កិរិយា** ដូច្នេះ ។

ក្នុងព្រះបាលីនោះ កិរិយាចិត្តនោះគប្បីពោលថា ជាកាមាវចរ រូបាវចរ អរូបាវចរ គឺវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ។ ព្រះអង្គទ្រង់សម្តែងន័យថា វិបាកចិត្តនិងកិរិយាចិត្តនោះធ្លាប់លើកយកមកត្រាស់ទុកហើយនោះឯង ទើបទ្រង់វៀរចេញ ។ ឥឡូវនេះ កាលទ្រង់សម្តែងធម៌ដែលមិនទាន់បានចែកទុក ទើបត្រាស់ថា **សព្ពញ្ច រូបំ អសង្ខតា ច ធាតុ** ដូច្នេះ ។

ក្នុងព្រះបាលីនោះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់កាន់យករូប ២៥[១] កោដ្ឋាសៈនៃរូប ៩៦[២] សម្តែងទុកដោយមិនសេសសល់ដោយបទថា **សព្ពញ្ច រូបំ** ដូច្នេះ ។ ដោយបទថា **អសង្ខតា ច ធាតុ** នេះ ទ្រង់កាន់យកព្រះនិព្វានដោយឥតសេសសល់ ។ បទថា **អព្យាកតា ធម្មា** ព្រះមានព្រះភាគទ្រង់លើកឡើងសម្តែងទុកហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

---

១-បានដល់ អាយតនៈ ១០ និងសុខុមរូប ១៥ ដែលពោលទុកហើយក្នុងបាលី ( ដីកា ) ។

២-បានដល់ពួក ១០ មានចក្ខុជាដើម ៧ ពួក ( ស្មើ ៧០ ) ពួក ៨ ដែលមានឧតុជាសមុដ្ឋានជាដើម ៣ ពួក ( ស្មើ ២៤ ) សំឡេង ២ ដែលកើតអំពីឧតុនិងចិត្ត ( ស្មើ ២ ) ( ដីកា ) ។

[ ២ ] ទ្រង់កាន់យកពាក្យនេះថា **តត្ថ កតមំ សព្វំ រូបំ** ព្រោះហេតុអ្វី ព្រោះកន្លងមកត្រាស់អព្យាកតៈ គឺរូបទុកដោយសង្ខេប ឥឡូវនេះទ្រង់បំណង នឹងចែករូបនោះដោយពិស្តារ ដោយអំណាចនៃរូបពួក ១ ពួក ២ ពួក ៣ ពួក ៤ ។បេ។ ពួក ១១ ទើបទ្រង់កាន់យករូបនេះ ។

សេចក្តីនៃព្រះតម្រាស់នោះមានអធិប្បាយថា ក្នុងព្រះតម្រាស់ ២ ដែល ត្រាស់ទុកថា **សព្វញ្ច រូបំ អសង្ខតា ច ធាតុ** នោះ ដែលឈ្មោះថា **សព្វំ រូបំ** តើដូចម្តេច ឥឡូវនេះកាលទ្រង់សម្តែងរូបនោះ ទើបត្រាស់ពាក្យជាដើម ថា **ចត្តារោ ច មហាភូតា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ចត្តារោ** ជាពាក្យកំណត់ចំនួន ។ ដោយ បទថា **ចត្តារោ** នោះ ទ្រង់បដិសេធការខ្វះនិងលើសរបស់រូបទាំងនោះ **ច** សព្ទ ជាសម្បិណ្ឌនត្ថ ( គឺចុះក្នុងអត្ថថាប្រមូលមក ) ដោយ **ច** សព្ទនោះ ព្រះមានព្រះភាគទ្រង់ប្រមូលមកនូវឧបាទាយរូបថា មិនមែនតែមហាភូតរូប ៤ ជារូបប៉ុណ្ណោះទេ សូម្បីរូបដទៃក៏មាន ។

ក្នុងពាក្យថា **មហាភូតា** នេះ គប្បីជ្រាបថាជាមហាភូតរូប ព្រោះហេតុ ទាំងឡាយ មានភាពប្រាកដជារបស់ធំជាដើម ។ រូបទាំងនេះ ត្រាស់ហៅថា **មហាភូត** ព្រោះហេតុទាំងនេះ គឺព្រោះភាពប្រាកដជារបស់ធំ ១ ព្រោះស្មើ ដោយមហាភូត គឺអ្នកលេងកលជាដើម ១ ព្រោះត្រូវថែរក្សាច្រើន ១ ព្រោះវិការៈ គឺការប្រែប្រួលធំ ១ ព្រោះជារបស់ធំដែលមាននៅ ១ ។

បណ្តាហេតុទាំងនោះ ពាក្យថា ព្រោះភាពប្រាកដជារបស់ធំ បានដល់

រូបទាំងនោះប្រាកដជារបស់ធំ ក្នុងអនុបាទិន្នកសន្តានខ្លះ ក្នុងឧបាទិន្នកសន្តានខ្លះ បណ្តាសន្តានទាំង ២ នោះ គប្បីជ្រាបក្នុងអនុបាទិន្នកសន្តានដោយភាពជារបស់ធំយ៉ាងនេះថា

មែនពិត ចក្កវាឡមួយបណ្តោយនិងទទឹងដល់ទៅ ១,២០៣,៤៥០ យោជន៍ ( មួយលានពីរសែនបីពាន់បួនរយហាសិបយោជន៍ ) ។ វាស់ដោយជុំវិញតាមគាថាដែលលោកចងទុកដូច្នេះថា

ចក្កវាឡទាំងអស់ មានសណ្ឋានមូល វាស់ដោយជុំវិញបាន ៣,៦១០,៣៥០ យោជន៍ ( បីលានប្រាំមួយសែនមួយម៉ឺនបីរយហាសិបយោជន៍ ) ដូច្នេះ ។

ក្នុងចក្កវាឡនោះ មានគាថាថា

ផែនដីនេះ វាស់ដោយកម្រាស់បានប៉ុណ្ណេះ គឺ ២៤០,០០០ យោជន៍ ( ពីរសែនបួនម៉ឺនយោជន៍ ) ដូច្នេះ ។

ផែនដីនោះឯង មានទឹកទ្រផែនដី ដូចគាថាថា

ទឹកទ្រផែនដីកម្រាស់ដល់ ៤៨០,០០០ យោជន៍ ( បួនសែនប្រាំបីម៉ឺនយោជន៍ ) តាំងនៅលើខ្យល់ ដូច្នេះ ។

សូម្បីទឹកនោះឯង ក៏មានខ្យល់ទ្រ ដូចគាថាថា

ខ្យល់ខ្ពស់ឡើងទៅកាន់នភា ដល់ ៩៦០,០០០ យោជន៍ ( ប្រាំបួនសែនប្រាំមួយម៉ឺនយោជន៍ ) នេះជាការតាំងនៅរបស់លោក ដូច្នេះ ។

កាលលោកតាំងនៅយ៉ាងនេះ

មានភ្នំសិនេរុរាជ ចាក់ចុះទៅក្នុងមហាសមុទ្ទដល់ ៨៤,០០០ យោជន៍ ( ប៉ែតសិបបួនពាន់យោជន៍ ) ខ្ពស់ផុតចាកមហាសមុទ្ទ បាន ៨៤,០០០ យោជន៍ដូចគ្នា ។

បន្ទាប់អំពីនោះ ចេញមកខាងក្រៅមានភ្នំធំសម្រេចដោយថ្មដ៏ក្រាស់ ៧ ជាន់ គឺភ្នំយុគន្ធរ ភ្នំឦសធរ ភ្នំករវិក ភ្នំសុទស្សន ភ្នំនេមិន្ធរ ភ្នំវិនតក ភ្នំអស្សកណ្ណ សុទ្ធតែវិចិត្រដោយរតនៈផ្សេងៗដ៏ជាទិព្វ ចាក់ឫសចុះទៅក្នុងមហាសមុទ្ទ និងខ្ពស់ផុតចាកមហាមុទ្ទ ប្រមាណពាក់កណ្តាលៗ ដោយជុំវិញភ្នំសិនេរុរាជនោះតាមលំដាប់ ជាទីស្ថិតនៅរបស់មហារាជទាំងឡាយ ជាទីនៅជាប្រចាំរបស់ពួកទេវតានិងពួកយក្ខ ។

នៅមានភ្នំឈ្មោះហិមពាន្ត កម្ពស់ ៥០០ យោជន៍ បណ្តោយនិងទទឹង ៣,០០០ យោជន៍ ប្រដាប់ដោយកំពូល ៨៤,០០០ ជម្ពូទ្វីបប្រាកដហើយ ដោយអានុភាពនៃដើមព្រីងឈ្មោះនគៈ ទំហំដើមវាស់ដោយជុំវិញបាន ១៥ យោជន៍ មានមែកប្រវែង ៥០ យោជន៍ រំកាយមែក ពីម្ខាងទៅម្ខាង ១០០ យោជន៍ កម្ពស់ ១០០ យោជន៍ដូចគ្នា ។

មួយទៀត ប្រមាណនៃដើមជម្ពូណា ដើមចិត្តបាដលី ( ដើមប្រទៀង ) របស់ពួកអសុរក្តី ដើមសិម្ពលី ( ដើមរកា ) របស់ពួកគ្រុឌក្តី ដើមកទម្ព

( ដើមកូដ្ឋ ) ក្នុងអបរគោយានទ្វីបក្តី ដើមកប្បព្រឹក្សក្នុងឧត្តរកុរុទ្វីបក្តី ដើមសិរីសក្នុងបុព្វវិទេហទ្វីបក្តី ដើមបារិច្ឆត្តកៈក្នុងឋានតាវត្តិង្សទាំងឡាយក្តីក៏មានប្រមាណនោះដូចគ្នា ដោយហេតុនោះ ទើបបោរាណាចារ្យទាំងឡាយពោលថា

ដើមបាដលី ១ ដើមសិម្ពលី ១ ដើមព្រីង ១ ដើមបារិច្ឆត្តក
( ដើមរលួសផ្កុង ) របស់ពួកទេវតា ១ ដើមកទម្ព ១ ដើម
កប្បព្រឹក្ស ១ ដើមសិរីស ( ដើមប្រេស ) ជាគម្រប់ ៧ ។

ភ្នំកណ្តាប់ចក្កវាឡចាក់ចុះក្នុងមហាសមុទ្ទ ៨២,០០០ យោជន៍ ខ្ពស់ផុតចាកមហាសមុទ្ទ ៨២,០០០ យោជន៍ ដូចគ្នា បានតាំងឡោមព័ទ្ធលោកធាតុទុកនោះឯង ។ ( នេះឈ្មោះថាអនុបាទិន្នកសន្តាន ) ។

សូម្បីក្នុងឧបាទិន្នកសន្តាន ក៏ប្រាកដជារបស់ធំទុំឯង ដោយអំណាចនៃសរីរៈ មានត្រី អណ្តើក ទេវតានិងទានវជាដើម សេចក្តីនេះសមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយអដ្ឋកនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ មហាសមុទ្ទមានអត្តភាព ១០០ យោជន៍ខ្លះ ដូច្នេះជាដើម ។

ពាក្យថា ព្រោះស្មើដោយមហាភូត គឺអ្នកលេងកលជាដើម សេចក្តីថា មហាភូតរូបទាំងនេះ ខ្លួនឯងមិនមែនជាពណ៌ខៀវ ក៏សម្តែងឧបាទាយរូបឲ្យជាពណ៌ខៀវ ខ្លួនឯងមិនមែនជាពណ៌លឿង ក៏សម្តែងឧបាទាយរូបឲ្យជាពណ៌លឿង មិនមែនពណ៌ក្រហម... មិនមែនជាពណ៌ស ក៏សម្តែងឧបាទាយរូបឲ្យ

ជាពណ៌សបាន ដូចមាយាការរមែងសម្តែងទឹកដែលមិនមែនកែវមណី ឲ្យជាកែវមណី រមែងសម្តែងដុំដី ដែលមិនមែនជាមាស ឲ្យជាមាសបាន ខ្លួនឯងមិនមែនជាយក្ស មិនមែនជាបក្សី រមែងសម្តែងភាពជាយក្សខ្លះ ជាបក្សីខ្លះបាន ព្រោះហេតុនោះ ទើបរូបទាំងនោះឈ្មោះថា មហាភូតរូប ព្រោះដូចជាមហាភូត គឺអ្នកលេងកល ។

ម្យ៉ាងទៀត មហាភូតគឺយក្សជាដើម រមែងសណ្ឋិតក្នុងវត្ថុណា ឬសត្វណា ទីដែលជាខាងក្នុងឬខាងក្រៅរបស់វត្ថុនោះ ឬរបស់សត្វនោះ សម្រាប់មហាភូត ( យក្ខ ) ទាំងនោះរមែងរកមិនបាន និងមិនមែនមហាភូត (យក្ខ) ទាំងនោះមិនអាស្រ័យវត្ថុនោះឬសត្វនោះក៏ទេ សេចក្តីនេះយ៉ាងណា មហាភូតរូបទាំងនេះ ក៏យ៉ាងនោះដូចគ្នា នឹងតាំងនៅខាងក្នុងឬខាងក្រៅនៃគ្នានឹងគ្នា រមែងប្រព្រឹត្តទៅមិនបាន ទាំងមិនអាស្រ័យនូវគ្នានឹងគ្នាក៏មិនមែន ព្រោះហេតុនោះ ទើបរូបទាំងនេះ ឈ្មោះមហាភូត ព្រោះដូចនឹងមហាភូត មានយក្សជាដើម ព្រោះភាពជាឋានៈដែលនរណាៗ មិនគប្បីគិត ។

មួយទៀត មហាភូត គឺយក្ខិនី បិទបាំងភាវៈនៃខ្លួនជាបិសាច គួរខ្លាច ហើយលួងលោមសត្វទាំងឡាយដោយពណ៌សម្បុរ ទ្រង់ទ្រាយ និងការកែក្រាយដែលគួរជាទីគាប់ចិត្ត យ៉ាងណា មហាភូតទាំងនោះក៏យ៉ាងនោះដូចគ្នា បិទបាំងលក្ខណៈដែលជាសភាវៈរបស់ខ្លួនដោយភាពជារបស់រឹងជាដើមរបស់ខ្លួនទុកដោយពណ៌ដែលគួរជាទីគាប់ចិត្ត ដោយទ្រង់ទ្រាយនៃអវយវៈតូចធំគួរជាទីគាប់ចិត្ត ដោយការលើកដៃជើង លើកម្រាមដៃ និងញាក់ចិញ្ចើមដែល

គួរជាទីត្រេកអរ ក្នុងរាងកាយស្ត្រីបុរសជាដើម ហើយបោកបញ្ឆោតបុគ្គល ល្ងង់ខ្លៅ មិនឲ្យឃើញសភាវៈរបស់ខ្លួន ព្រោះហេតុនោះ ទើបរូបឈ្មោះថា មហាភូត ព្រោះខ្លួនដូចមហាភូត គឺនាងយក្ខិនី ព្រោះធ្វើនូវការបោកបញ្ឆោត ដោយប្រការដូច្នេះ ។

ពាក្យថា ព្រោះត្រូវថែរក្សាច្រើន គឺព្រោះត្រូវបរិហារដោយបច្ច័យ ជាច្រើន ។ មែនពិត រូបទាំងនេះ ឈ្មោះថា មហាភូត ដោយអត្ថថា ត្រូវឲ្យប្រព្រឹត្តទៅដោយការស៊ី ការរស់នៅ និងគ្រឿងស្លៀកដណ្ដប់ជាច្រើន ព្រោះត្រូវបង្ហូរចូលទៅរាល់ៗថ្ងៃ ម្យ៉ាងទៀត ដែលឈ្មោះថា **មហាភូត** ព្រោះអត្ថថា ជាវត្ថុត្រូវទំនុកបម្រុងច្រើន ដូច្នេះក៏មាន ។

ពាក្យថា ព្រោះវិការៈ គឺការប្រែប្រួលធំ បានដល់ ព្រោះមហាភូតទាំងឡាយប្រែប្រួលច្រើន មែនពិត រូបទាំងនេះជារូបដែលមានចិត្តគ្រប់គ្រងក្ដី ជារូបដែលមិនមានចិត្តគ្រប់គ្រងក្ដី រមែងជារបស់ប្រែប្រួលច្រើន បណ្ដារូបទាំង ២ នោះ រូបដែលមិនមានចិត្តគ្រប់គ្រង រមែងប្រាកដជាការប្រែប្រួលច្រើនក្នុងកាលកប្បវិនាស ចំណែករូបដែលមានចិត្តគ្រប់គ្រង រមែងប្រាកដជាការប្រែប្រួលច្រើន ក្នុងវេលាធាតុកម្រើក ។ ពិតយ៉ាងនោះ ដូចដែលលោកពោលថា

ក្នុងកាលណា លោកនឹងវិនាស ដោយអំណាចភ្លើងដុត
បំផ្លាញ ក្នុងកាលនោះភ្លើងរមែងឆេះសន្ធោសន្ធៅឡើង តាំង
អំពីផែនដី រហូតដល់ព្រហ្មលោក ។

ក្នុងកាលណាលោកនឹងវិនាសសាបសូន្យដោយទឹកកម្រើក ក្នុងកាលនោះ សែនកោដិចក្កវាឡ រមែងរលាយទៅដោយទឹកក្រុត ។

ក្នុងកាលណា លោកនឹងវិនាសសាបសូន្យ ដោយខ្យល់កម្រើក ក្នុងកាលនោះ ខ្យល់រមែងញាំងសែនកោដិចក្កវាឡឲ្យខ្ចាត់ខ្ចាយទៅ ។

កាយណាដែលត្រូវពស់ឈ្មោះកដ្ឋមុខ ( ពស់មាត់ឈើ ) ខាំហើយរមែងរឹងក្រញង់យ៉ាងណា កាយនោះ រមែងដូចជាត្រូវពស់ឈ្មោះកដ្ឋមុខខាំ ព្រោះបឋវីធាតុកម្រើកក៏យ៉ាងនោះ កាយណា ដែលត្រូវពស់ឈ្មោះបូតិមុខ ( ពស់មាត់ស្អុយ ) ខាំហើយរមែងរលួយយ៉ាងណា កាយនោះរមែងដូចត្រូវពស់ឈ្មោះបូតិមុខខាំ ព្រោះអាបោធាតុកម្រើកក៏យ៉ាងនោះ កាយណាដែលត្រូវពស់ ឈ្មោះអគ្គិមុខ ( ពស់មាត់ភ្លើង ) ខាំហើយរមែងក្តៅយ៉ាងណា កាយនោះរមែងដូចត្រូវពស់ឈ្មោះអគ្គិមុខខាំ ព្រោះតេជោធាតុកម្រើកក៏យ៉ាងនោះ កាយណាដែលត្រូវពស់ ឈ្មោះសត្ថមុខ ( ពស់មាត់សស្ត្រា ) ខាំហើយ រមែងដាច់ជាកំណាត់យ៉ាងណា កាយនោះ រមែងដូចត្រូវពស់ឈ្មោះសត្ថមុខខាំ ព្រោះវាយោធាតុកម្រើក ក៏យ៉ាងនោះ ។

រូបដែលឈ្មោះថា **មហាភូត** ព្រោះជារបស់វិការៈគឺប្រែប្រួលធំ ដោយប្រការដូច្នេះ ។

ពាក្យថា ព្រោះជារបស់ធំដែលមាននៅ សេចក្ដីថា ពិតណាស់ រូបទាំងនោះ ឈ្មោះថាជារបស់ធំ ព្រោះជារបស់ដែលត្រូវផ្គងដោយសេចក្ដីព្យាយាមធំ និងដែលឈ្មោះថា មាន ព្រោះជារបស់ដែលមាននៅ ព្រោះហេតុនោះទើបរូបទាំងនោះ ឈ្មោះថា **មហាភូត** ព្រោះជារបស់ធំដែលមាន ។ រូបទាំងឡាយ ឈ្មោះថា មហាភូតរូប ព្រោះហេតុមានភាពប្រាកដ ជារបស់ធំជាដើម ដោយប្រការដូច្នេះ ។

ពាក្យថា **ចតុន្នំ ច មហាភូតានំ ឧបាទាយ រូបំ** នេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ប្រែថា អាស្រ័យនូវមហាភូតរូប ៤ អធិប្បាយថា រូបដែលអាស្រ័យ ពឹងផ្អែកមិនអាចបោះបង់មហាភូតរូបទាំង ៤ ប្រព្រឹត្តទៅ ។

បទថា **ឥទំ វុច្ចតិ សព្វំ រូបំ** សេចក្ដីថា រូបនេះមានប្រភេទ ២៧ គឺមហាភូតរូប ៤ ឧបាទាយរូប ២៣ តាមដែលលើកឡើងសម្ដែងដោយលំដាប់នៃបទ ឈ្មោះថា រូបទាំងអស់ ។

## សង្គ្រោះរូបពួក ១

[ ៣ ] ឥឡូវនេះព្រះមានព្រះភាគ ទ្រង់បំណងនឹងសម្ដែងរូបនោះដោយពិស្ដារ កាលទ្រង់តាំងមាតិកាដោយការសង្គ្រោះរូប ១១ ពួក មានរូបពួកមួយជាដើម ទើបត្រាស់ថា **សព្វំ រូបំ ន ហេតុ** ជាដើម ។

ក្នុងព្រះបាលីទាំងនោះ បទថា **សព្វំ រូបំ** នេះ បណ្ឌិតគប្បីប្រកបជាមួយ

នីងបទទាំងពួង យ៉ាងនេះថា **សព្វំ រូបំ ន ហេតុ សព្វំ រូបំ អហេតុកំ** ដូច្នេះ ។ បទទាំងអស់ដែលទ្រង់តាំងទុក ៤៣ បទ មានពាក្យថា **ន ហេតុ** ជាដើម ទ្រង់លើកឡើងសម្តែងហើយ ។

បណ្តាបទទាំង ៤៣ នោះ បទ ៤០ តាមលំដាប់ ទ្រង់កាន់យកអំពីមាតិកា មកតាំងទុក ៣ បទចុងក្រោយយកមកអំពីក្រៅមាតិកា ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបការកំណត់ព្រះបាលី ក្នុងសង្គហៈទីមួយយ៉ាងនេះមុន ក្នុងសង្គហៈទី ២ ជាដើមក៏យ៉ាងនោះ ។

## សង្គ្រោះរូបទ្វុក ២

[ ៤ ] បណ្តាសង្គហៈទាំងនោះ មានន័យដូចតទៅនេះថា

សង្គហៈទី ២ មាន ១០៤ ទុកៈ ។ ក្នុងទុកៈទាំងនោះ ទុកៈ ១៤ ក្នុងខាងដើមជាដើមថា **អត្ថិ រូបំ ឧបាទា អត្ថិ រូបំ នោ ឧបាទា** ឈ្មោះថា **បកិណ្ណកទុក** ព្រោះមិនមានសេចក្តីសម្ពន្ធនូវគ្នានឹងគ្នា ។

ទុកៈតអំពីនោះ ២៥ មានពាក្យជាដើមថា **អត្ថិ រូបំ ចក្ខុសម្ផស្សស្ស វត្ថុ** ឈ្មោះថា **វត្ថុទុក** ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការពិចារណាវត្ថុ និងអវត្ថុ ។ តអំពីនោះ ទុកៈ ២៥ ជាដើមថា **អត្ថិ រូបំ ចក្ខុសម្ផស្សស្ស អារម្មណំ** ឈ្មោះថា **អារម្មណទុក** ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការពិចារណាអារម្មណ៍និងអនារម្មណ៍ ។ តអំពីនោះទុកៈ ១០ ជាដើមថា **អត្ថិ រូបំ ចក្ខាយតនំ** ឈ្មោះថា **អាយតនទុក** ព្រោះប្រព្រឹត្តទៅដោយអំណាចនៃការពិចារណាអាយតនៈ និងមិនមែនអាយតនៈ ។ តអំពីនោះ ទុកៈ ១០

ជាដើមថា **អត្ថិ រូបំ ចក្ខុធាតុ** ឈ្មោះថា **ធាតុទុក** ព្រោះប្រព្រឹត្តទៅដោយអំណាចពិចារណាធាតុនិងមិនមែនធាតុ ។ តអំពីនោះ ទុកៈ ៨ មានជាដើមថា **អត្ថិ រូបំ ចក្ខុន្ទ្រិយំ** ឈ្មោះថា **ឥន្ទ្រិយទុក** ព្រោះប្រព្រឹត្តទៅដោយអំណាចពិចារណាឥន្ទ្រិយនិងមិនមែនឥន្ទ្រិយ ។ តអំពីនោះ ទុកៈ ១២ ជាដើមថា **អត្ថិ រូបំ កាយវិញ្ញត្តិ** ឈ្មោះថា **សុខុមរូបទុក** ព្រោះប្រព្រឹត្តទៅដោយអំណាចរពិចារណាសុខុមរូបនិងមិនមែនសុខុមរូប នេះជាការកំណត់ព្រះបាលីក្នុងសង្គហៈទី ២ ។

## សង្គ្រោះរូបត្តិក ៣

[ ៥ ] ក្នុងសង្គហៈទី ៣ មាន ១០៣ តិកៈ បណ្ដាតិកៈទាំងនោះ តិកៈ ១៣ ដែលទ្រទ្រង់ប្រកបអជ្ឈត្តិកទុកៈ ១ ក្នុងបកិណ្ណកទុកៈ ១៤ តាមដែលពោលហើយ ក្នុងសង្គហៈទី ២ ចូលជាមួយទុកៈ ១៣ ដ៏សេសហើយតាំងទុកដោយន័យជាដើមថា **យំ តំ រូបំ អជ្ឈត្តិកំ តំ ឧបាទា យំ តំ រូបំ ពាហិរំ តំ អត្ថិ ឧបាទា អត្ថិ នោ ឧបាទា** រូបណាខាងក្នុង រូបនោះជាឧបាទា រូបណាខាងក្រៅ រូបនោះជាឧបាទា និងមិនមែនជាឧបាទាក៏មានដូច្នេះ ឈ្មោះថា **បកិណ្ណកតិក** ។ តអំពីនោះ ទ្រង់ប្រកបទុកៈនោះនុ៎ះឯងជាមួយនឹងទុកៈដ៏សេស ហើយទ្រង់តាំងតិកៈដ៏សេស ដោយន័យជាដើមថា **យំ តំ រូបំ ពាហិរំ តំ ចក្ខុសម្ផស្សស្ស ន វត្ថុ យំ តំ រូបំ អជ្ឈត្តិកំ តំ អត្ថិ ចក្ខុសម្ផស្សស្ស វត្ថុ អត្ថិ ចក្ខុសម្ផស្សស្ស ន វត្ថុ** រូបណាខាងក្រៅ រូបនោះមិនមែនជាវត្ថុនៃចក្ខុសម្ផស្ស រូបណាខាងក្នុង រូបនោះជាវត្ថុនៃចក្ខុ-

សម្ផស្ស និងមិនមែនជាវត្ថុនៃចក្ខុសម្ផស្សក៏មាន ដូច្នេះ ។ គប្បីជ្រាបឈ្មោះ និងការរាប់នៃតិកៈទាំងនោះ ដោយអំណាចនៃ វត្ថុទុកៈ ជាដើមទាំងនោះនុ៎ះ ឯង ។ នេះជាការកំណត់ព្រះបាលីក្នុងសង្គហៈទី ៣ ។

# សង្គ្រោះរូបពួក ៤ ជាដើម

[ ៦-១៣ ] ក្នុងសង្គហៈទី ៤ មាន ២២ ចតុក្កៈ បណ្ដាចតុក្កៈទាំងនោះ ចតុក្កៈចុងក្រោយ ទ្រង់មិនបានកាន់យកមាតិកាតាមដែលពោលទុក ក្នុងរូបសង្គហៈនេះយ៉ាងនេះថា រូបជាឧបាទាក៏មាន រូបមិនជាឧបាទាក៏មាន ដូច្នេះ ហើយទ្រង់តាំងទុក តែទ្រង់កាន់យកមាតិកាក្រៅអំពីនេះមកតាំងទុក សេចក្ដីនេះដូចម្ដេច គឺទុកៈ ៣ ខាងដើមក្នុងបកិណ្ណកទុកៈទាំងឡាយក្នុងការសង្គ្រោះរូបពួក ២ ពួកណាមុន ក្នុងទុកៈ ៣ នោះ ទ្រង់កាន់យកទុកៈនីមួយៗប្រកបជាមួយទុកៈនីមួយៗ ៥ ទុកៈ ដោយន័យជាដើមថា **យំ តំ រូបំ ឧបាទា តំ អត្ថិ ឧបាទិន្នំ អត្ថិ អនុបាទិន្នំ** រូបណាជាឧបាទា រូបនោះជាឧបាទិន្នក៏មាន ជាអនុបាទិន្នក៏មាន ដូច្នេះហើយទ្រង់តាំងចតុក្កៈ ១៥ ខាងដើមដែលមាន ៣ ទុកៈជាមូល ។

ឥឡូវនេះ សនិទស្សនទុកៈទី ៤ នេះ មិនដល់ការប្រកបជាមួយទុកៈខាងចុងដោយន័យជាដើមថា រូបជាសនិទស្សនៈដែលប៉ះខ្ទប់បានក៏មាន ដែលប៉ះខ្ទប់មិនបានក៏មាន ដូច្នេះ ឬប្រកបជាមួយទុកៈខាងដើមដោយន័យជាដើមថា ជាឧបាទាក៏មាន មិនមែនជាឧបាទាក៏មាន ព្រោះមិនមានអត្ថ ព្រោះមិនមានលំដាប់ប្រព្រឹត្តទៅនិងព្រោះមិនមានការផ្សេងគ្នា ។ ពិតណាស់ រូបដែល

ជាសនិទស្សន ឈ្មោះថា ប៉ះខ្ទប់មិនបាន ឬថាមិនជាឧបាទា រមែងមិនមាន ព្រោះហេតុនោះ ទើបរូបនោះមិនដល់នូវការប្រកប ព្រោះមិនមានអត្ថ តែរូបដែលជាឧបាទិន្នានិងអនុបាទិន្នមាន ព្រោះហេតុនោះ ទើបរូបនោះមិនដល់នូវការប្រកប ព្រោះមិនមានលំដាប់ប្រព្រឹត្តទៅ ។ ដ្បិតថា ទុកៈទាំងអស់ ទ្រង់ប្រកបជាមួយទុកៈក្រោយៗប៉ុណ្ណោះ នេះជាលំដាប់ដែលប្រព្រឹត្តទៅក្នុងអធិការនេះ តែមិនមានលំដាប់ប្រព្រឹត្តទៅជាមួយពួកទុកៈខាងដើមឡើយ ។ បើមានអ្នកចោទសួរថា កាលអត្ថមាន ការមិនមានលំដាប់ប្រព្រឹត្តទៅក៏មិនមែនហេតុសំខាន់ ព្រោះហេតុនោះ គួរប្រកបនិទស្សនទុកៈ ជាមួយបទដែលជាឧបាទិន្នៈជាដើម ឆ្លើយថា នឹងប្រកបជាមួយសនិទស្សនទុកៈមិនបាន ព្រោះមិនមានការផ្សេងគ្នា ។ ដោយបទថា ដែលជាឧបាទិន្នជាដើម ទ្រង់ប្រកបហើយជាមួយបទសនិទស្សនៈនេះ ។ ក្នុងអធិការនេះ កាលពោលថា រូបជាឧបាទិន្នដែលជាសនិទស្សន ឬរូបជាសនិទស្សនៈដែលជាឧបាទិន្នៈ ការផ្សេងគ្នាក៏មិនមាន ព្រោះហេតុនោះទើបមិនដល់នូវការប្រកបគ្នា ព្រោះមិនមានការផ្សេងគ្នា ព្រោះហេតុដូចពោលមកទាំងអស់នេះ ទើបព្រះមានព្រះភាគមិនកាន់យកទុកៈទី ៤ នោះ ទ្រង់ប្រកបម្តង ២ ទុកៈ ដែលប្រកបដោយន័យជាដើមថា **យំ តំ រូបំ សប្បដិឃំ តំ អត្ថិ ឥន្ទ្រិយំ អត្ថិ ន ឥន្ទ្រិយំ យំ តំ រូបំ អប្បដិឃំ តំ អត្ថិ ឥន្ទ្រិយំ អត្ថិ ន ឥន្ទ្រិយំ** រូបណាជាសប្បដិឃៈ រូបនោះជាឥន្ទ្រិយក៏មាន មិនមែនជាឥន្ទ្រិយក៏មាន រូបណាជាអប្បដិឃៈ រូបនោះជាឥន្ទ្រិយក៏មាន មិនមែនជាឥន្ទ្រិយក៏មាន ដូច្នេះ ជាមួយនឹង ៣ ទុកៈ

ខាងចុងបន្ទាប់អំពីទុកៈទី ៤ ( សនិទស្សនៈទុកៈ ) នោះ មានជាដើមថា **អត្ថិ រូបំ សប្បដិឃំ** ដូច្នេះ ហើយទ្រង់តាំងចតុក្កៈទុក ៦ ចតុក្កៈ ។ ទុកៈទី ៤ នេះ មិនដល់នូវការប្រកបយ៉ាងណា សូម្បីទុកៈដើម ក៏មិនដល់នូវការប្រកបជាមួយទុកៈទី ៤ នោះក៏យ៉ាងនោះ ព្រោះហេតុអ្វី ព្រោះរូបដែលមិនជាឧបាទា ជាអនិទស្សនរូបដោយចំណែកមួយ ។ ទុកៈខាងដើម ( ឧបាទាទុកៈ ) នោះ កាលប្រកបជាមួយទុកៈទី ៤ យ៉ាងនេះថា រូបជាឧបាទាដែលជាសនិទស្សនៈក៏មាន ដែលជាអនិទស្សនៈក៏មាន ដូច្នេះ រមែងមិនដល់ការប្រកបបាន ។ ព្រោះហេតុនោះ ទើបត្រូវកន្លងទុកៈនោះ ទៅប្រកបជាមួយនឹងទុកៈទី ៥ ។ គប្បីជ្រាបទុកៈដើមនោះថា ដល់នូវការប្រកបបាន ប្រកបមិនបានជាមួយបទដែលនាំមកប្រកប ដោយប្រការដូច្នេះ នេះជាការកំណត់ព្រះបាលីក្នុងសង្គហៈទី ៤ ។

ខាងមុខអំពីនេះ សង្គហៈ ៧ យ៉ាង មានការសង្គ្រោះរូប ៥ យ៉ាងជាដើម ជាការសង្គ្រោះមិនលាយឡំគ្នាដោយបទដទៃទាំងឡាយឡើយ ។ គប្បីជ្រាបការកំណត់ព្រះបាលីក្នុងមាតិកាសូម្បីទាំងអស់ ដោយប្រការដូច្នេះ ។

**អធិប្បាយឧទ្ទេស ចប់**

# អភិធម្មបិដក

## ឯកកនិទ្ទេស

[ ១៤ ] រូបទាំងអស់សុទ្ធតែគ្មានហេតុ សុទ្ធតែឥតហេតុ សុទ្ធតែប្រាសចាកហេតុ សុទ្ធតែប្រកបដោយបច្ច័យ សុទ្ធតែមានបច្ច័យតាក់តែង សុទ្ធតែជារូបតែម្យ៉ាង សុទ្ធតែជាប់នៅក្នុងលោក សុទ្ធតែប្រកបដោយអាសវៈ សុទ្ធតែជាប្រយោជន៍ដល់សញ្ញោជនៈ សុទ្ធតែជារូបដែលគន្ថៈគប្បីដោតក្រង សុទ្ធតែជារូបដែលឱឃៈគប្បីប្រព្រឹត្តកន្លង សុទ្ធតែជារូបដែលយោគៈគប្បីប្រព្រឹត្តកន្លង សុទ្ធតែជាប្រយោជន៍ដល់នីវរណៈ សុទ្ធតែជារូបដែលបរាមាសស្ទាបអង្អែល សុទ្ធតែជាប្រយោជន៍ដល់ឧបាទាន សុទ្ធតែគួរដល់សេចក្តីសៅហ្មង សុទ្ធតែជាអព្យាក្រឹត សុទ្ធតែគ្មានអារម្មណ៍ សុទ្ធតែមិនមែនជាចេតសិក សុទ្ធតែប្រាសចាកចិត្ត សុទ្ធតែមិនមែនជាវិបាក មិនមែនមានវិបាកជាធម្មតា ជារូបមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង មិនមែនប្រកបដោយវិតក្កៈប្រកបដោយវិចារៈទេ មិនមែនមិនមានវិតក្កៈ មានត្រឹមតែវិចារៈទេ សុទ្ធតែមិនមានវិតក្កៈ មិនមានវិចារៈ មិនមែនប្រកបដោយបីតិ មិនប្រកបដោយសុខៈ មិនប្រកបដោយឧបេក្ខា ជារូបមិនគប្បីលះដោយទស្សនៈ មិនគប្បីលះដោយភាវនា ជារូបមានហេតុមិនគប្បីលះដោយទស្សនៈ មិនគប្បីលះដោយភាវនា មិនដល់នូវការសន្សំកពូនឡើង មិនមែនជាការមិនដល់នូវការសន្សំកពូនឡើង មិនមែនជាសេក្ខៈ មិនមែនជាអសេក្ខៈ ជារូបតូចឆ្មារ ជាកាមាវចរ មិនមែនជារូបាវចរ មិនមែនជាអរូបាវចរ រាប់ចូលក្នុងវដ្តៈ មិនមែនមិនរាប់ចូលក្នុងវដ្តៈ ជាអនិយតៈ មិនមែនជានិយ្យានិកៈ ជារូបកើតឡើង

ហើយ គប្បីដឹងដោយវិញ្ញាណ ៦ ជារូបមិនទៀង សុទ្ធតែត្រូវជរាគ្របសង្កត់បាន ការសង្គ្រោះរូបដោយចំណែក ១ យ៉ាងនេះ ។

## ចប់ ឯកកនិទ្ទេស

# អដ្ឋកថា
# ការចែករូប
# អធិប្បាយ ឯកកនិទ្ទេស

[ ១៤ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់បំណងនឹងចែករូបវិកត្តិនោះ ទើបផ្ដើមត្រាស់ពាក្យជាដើមថា **សព្វំ រូបំ ន ហេតុមេវ** ដូច្នេះ ។

សួរថា ក្នុងឯកកនិទ្ទេសនេះ ព្រោះហេតុអ្វីទើបព្រះមានព្រះភាគមិនបាន ធ្វើសំណួរថា រូបទាំងអស់នោះមិនមែនជាហេតុ តើដូចម្ដេច ដូច្នេះ ឆ្លើយថា ព្រោះមិនមានសេចក្ដីផ្សេងគ្នា ។

ពិតណាស់ ក្នុងឯកកនិទ្ទេសនេះ ក្នុងសេចក្ដីដែលផ្សេងគ្នាយ៉ាងនេះថា រូបទាំងអស់ មិនមែនហេតុខ្លះ ជាហេតុខ្លះ រមែងមិនមាន ដូចក្នុងរូបទុកៈ ជាដើម រូបជាឧបាទាក៏មាន មិនជាឧបាទាក៏មាន ព្រោះហេតុនោះ ទើបទ្រង់ មិនបានតាំងសំណួរចែកទុក ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **សព្វំ** បានដល់ ទាំងអស់ គឺមិនមាន សេសសល់ ។

ពាក្យថា **រូបំ** នេះ ទ្រង់ពង្រីកដល់សាមញ្ញលក្ខណៈដែលសម្ដែងដល់ រូបដែលត្រូវប្រែប្រួលទៅ ដោយវិរោធិប្បច្ច័យ ( បច្ច័យដែលជាសត្រូវនឹង គ្នា ) មានត្រជាក់ជាដើម ។

ពាក្យថា **ន ហេតុមេវ** ទ្រង់ពង្រីកសេចក្ដីដល់ការបដិសេធហេតុទូទៅ ។ ក្នុងបទថា **ន ហេតុមេវ** នោះ ហេតុមាន ៤ យ៉ាងគឺ ហេតុហេតុ ១

បច្ចយហេតុ ១ ឧត្តមហេតុ ១ សាធារណហេតុ ១ ។

បណ្តាហេតុទាំង ៤ យ៉ាងនោះ ហេតុនេះគឺ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ ឈ្មោះថា ហេតុហេតុ ។ ហេតុនេះទ្រង់ត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយឧបរិបណ្ណាសក ) ថា ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូត ទាំង ៤ ជាបច្ច័យដែលនាំឲ្យបញ្ញត្តនូវរូបក្ខន្ធ ដូច្នេះ ឈ្មោះថា បច្ចយហេតុ ។ ហេតុដែលលោកពោលទុកថា កុសលធម៌និងអកុសលធម៌ជាហេតុដ៏ប្រសើរ ក្នុងឋានៈនៃការឲ្យផលរបស់ខ្លួន ឥដ្ឋារម្មណ៍ជាហេតុប្រសើរក្នុងឋានៈនៃកុសលវិបាក អនិដ្ឋារម្មណ៍ជាហេតុប្រសើរក្នុងឋានៈនៃអកុសលវិបាក ឈ្មោះថា ឧត្តមហេតុ ។ សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ព្រះតថាគតរមែងដឹងច្បាស់នូវវិបាកនៃកុសលកម្មនិងអកុសលកម្មដែលសត្វបានធ្វើហើយទាំងអតីត អនាគត និងបច្ចុប្បន្ន តាមបច្ច័យ តាមហេតុដោយសេចក្តីពិតមែន ដូច្នេះ ។ ហេតុដែលលោកពោលទុកថា អវិជ្ជាដែលជាហេតុ ជាបច្ច័យដល់សង្ខារទាំងឡាយ រមែងជាហេតុទូទៅ ដល់សង្ខារទាំងឡាយ រមែងផ្សាយទៅកាន់អត្ថន័យថា ជាបច្ច័យ ឈ្មោះថា សាធារណហេតុ ដូចលោកពោលទុកថា បឋវីរស អាបោរស ជាបច្ច័យដល់រសឆ្ងាញ់ខ្លះ ដល់រសមិនឆ្ងាញ់ខ្លះយ៉ាងណា អវិជ្ជាក៏ជាសាធារណប្បច្ច័យដល់សង្ខារ ដែលជាកុសលខ្លះ ដែលជាអកុសលខ្លះក៏យ៉ាងនោះ ។ ក្នុងទីនេះទ្រង់បំណងយកហេតុហេតុ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់កំណត់បដិសេធដល់ភាពដែលរូប

ជាហេតុ ដែលមកហើយក្នុងមាតិកាថា **ហេតូ ធម្មា ន ហេតូ ធម្មា** ទើប ត្រាស់ថា រូបទាំងអស់ សុទ្ធតែគ្មានហេតុ ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបការពង្រីកសេចក្ដីដល់ការបដិសេធ និងការមិនបដិសេធក្នុងបទទាំងអស់ ដោយន័យនេះ ។ ចំណែកវចនត្ថនៃបទទាំងពួង ខ្ញុំពោលទុកក្នុងការពណ៌នាបទមាតិកាហើយនុ៎ះឯង ។

ក្នុងពាក្យថា **សប្បច្ចយមេវ** នេះ បានដល់ មានកម្មជាសមុដ្ឋាន មានកម្មជាបច្ច័យដូចគ្នា គប្បីជ្រាបសេចក្ដីនៃរូបនុ៎ះឯង ដោយអំណាចបច្ច័យ ៤ តាមដែលពោលទុកយ៉ាងនេះថា រូបដែលមានអាហារជាសមុដ្ឋាន ជាដើម មានអាហារជាដើមជាបច្ច័យនោះឯង ។

បទថា **រូបមេវ** បានដល់ ទ្រង់បដិសេធការមិនមានរូប តាមដែលត្រាស់ទុក ក្នុងមាតិកាថា **រូបិនោ ធម្មា អរូបិនោ ធម្មា** ដូច្នេះ ។ ក្នុងបទថា **ឧប្បន្នំ ឆហិ វិញ្ញាណេហិ** គឺរូបនោះឯងកើតឡើងចំពោះមុខដែលវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើមគប្បីដឹងបាន តែការកំណត់លោកសង្គ្រោះសំដៅយកចក្ខុវិញ្ញាណជាដើម ។ មែនពិត ចក្ខុវិញ្ញាណជាដើមនោះ រមែងមិនដឹងអតីតនិងអនាគត ចំណែកមនោវិញ្ញាណ រមែងដឹងអតីតខ្លះ អនាគតខ្លះ ។ មនោវិញ្ញាណនោះ ឈ្មោះថា ធ្លាក់ទៅតាមក្រសែនោះឯង ព្រោះធ្លាក់ទៅក្នុងក្រសែនៃវិញ្ញាណ ៥ នេះ ។ រូបទាំងអស់ ឈ្មោះថា **អនិច្ចមេវ** ព្រោះអត្ថថា មានហើយត្រឡប់ទៅជាមិនមាន ។ ឈ្មោះថា **ជរាភិភូតមេវ** ព្រោះជាធម៌ដែលជរាគប្បីគ្របសង្កត់ ។ ម្យ៉ាងទៀត ព្រោះជរា រមែងប្រាកដក្នុងរូប-

កាយ ទើបទ្រង់ត្រាស់ថា **ជរាភិភូតមេវ** ដូច្នេះ ។

**វិធ** សព្ទ ក្នុងព្រះបាលីនេះថា **ឯវំ ឯកវិធេន រូបសង្គហោ** ប្រើក្នុងអត្ថថា មានះ សណ្ឋាន និងកោដ្ឋាសៈ ។

មែនពិត មានះ ឈ្មោះថា វិធា ដូចក្នុងប្រយោគជាដើមថា **សេយ្យោហមស្មីតិ វិធា សទិសោហមស្មីតិ វិធា** ការឆ្មើងឆ្មៃព្រោះតាំងខ្លួនថា អញប្រសើរជាងគេ ១ ការឆ្មើងឆ្មៃព្រោះតាំងខ្លួនថា អញស្មើនឹងគេ ១ ដូច្នេះ ។

សណ្ឋាន ឈ្មោះថា វិធា ដូចក្នុងប្រយោគជាដើមថា **កថំវិធំ សីលវន្តំ វទន្តិ កថំវិធំ បញ្ញវន្តំ វទន្តិ** អ្នកប្រាជ្ញទាំងឡាយ ហៅបុគ្គលដូចម្តេចថា ជាអ្នកមានសីល ហៅបុគ្គលដូចម្តេចថា ជាអ្នកមានបញ្ញា ដូច្នេះ ពាក្យថា **កថំវិធំ** មានអត្ថដូចពាក្យថា **កថំសណ្ឋិតំ** ។

កោដ្ឋាសៈ ឈ្មោះថា វិធា ដូចក្នុងប្រយោគជាដើមថា **ឯកវិធេន ញាណវត្ថុំ ទុវិធេន ញាណវត្ថុ** ញាណវត្ថុមានប្រការ ១ ញាណវត្ថុមាន ២ ដូច្នេះ ។ សូម្បីក្នុងអធិការនេះ ក៏ទ្រង់បំណងយកកោដ្ឋាសៈ ។

សង្គហៈ សព្ទ មាន ៤ យ៉ាង ដោយអំណាចនៃជាតិសង្គហៈ សញ្ជាតិសង្គហៈ កិរិយាសង្គហៈ និងគណនសង្គហៈ ។

ក្នុងសង្គហៈទាំង ៤ នោះ សង្គហៈ គឺការសង្គ្រោះនេះថា **សព្វេ ខត្តិយា អាគច្ឆន្តុ សព្វេ ព្រាហ្មណា សព្វេ វេស្សា សព្វេ សុទ្ទា អាគច្ឆន្តុ យា ចាវុសោ វិសាខ សម្មាវាចា យោ ច សម្មាកម្មន្តោ យោ ច សម្មាអាជីវោ ឥមេ ធម្មា សីលក្ខន្ធេ សង្គហិតា** ក្សត្រទាំងឡាយចូរមក

ព្រាហ្មណ៍ទាំងឡាយចូរមក វេស្សៈទាំងឡាយចូរមក សូទ្រៈទាំងឡាយចូរមក និងបាលីថា ម្នាលអាវុសោវិសាខ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ ធម៌ទាំង ( ៣ ) នេះ លោកសង្គ្រោះចូលក្នុងសីលក្ខន្ធ ដូច្នេះ ឈ្មោះថា ជាតិសង្គហៈ ។ ពិតណាស់ ក្នុងជាតិសង្គហៈនេះទាំងអស់នោះគឺការរួមគ្នាតែមួយដោយជាតិ ដូចលោកពោលថា ពួកជនដែលមានជាតិដូចគ្នាចូរមក ។

សង្គហៈនេះថា ពួកអ្នកដែនកោសលទាំងអស់ចូរមក ពួកអ្នកដែនមគធៈទាំងអស់ចូរមក ពួកជាងឈើទាំងអស់ចូរមក និងពាក្យថា ម្នាលអាវុសោវិសាខ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ធម៌ទាំង ( ៣ ) នេះលោកសង្គ្រោះចូលក្នុងសមាធិក្ខន្ធ ដូច្នេះ ឈ្មោះថា សញ្ជាតិសង្គហៈ ។

ពិតណាស់ ក្នុងសញ្ជាតិសង្គហៈនេះ ទាំងអស់នោះដល់នូវការរួមគ្នាតែមួយដោយឋានៈនៃសញ្ជាតិ ដោយទីនៅអាស្រ័យ ដូចលោកពោលថា បុគ្គលកើតក្នុងទីជាមួយគ្នា ជាប់ទាក់ទងគ្នាដោយជាតិចូរមក បានសព្វកាល ។

សង្គហៈនេះថា ពលដំរីទាំងពួងចូរមក ពលសេះទាំងពួងចូរមក ពលរថទាំងពួងចូរមក និងព្រះបាលីថា ម្នាលអាវុសោវិសាខ សម្មាទិដ្ឋិ ១ សម្មា-សង្កប្ប ១ ធម៌ទាំង ( ២ ) នេះ លោកសង្គ្រោះចូលក្នុងបញ្ញាខន្ធ ដូច្នេះ ឈ្មោះថា កិរិយាសង្គហៈ ។ ពិតណាស់ ទាំងអស់នោះដល់នូវការសង្គ្រោះជាមួយគ្នាដោយការធ្វើកិរិយារបស់ខ្លួន ។

ការសង្គ្រោះនេះថា **ចក្ខាយតនំ កតមក្ខន្ធគណនំ គច្ឆតិ ចក្ខាយ-**

**តនំ រូបក្ខន្ធគណនំ គច្ឆតិ ។ ហញ្ចិ ចក្ខាយតនំ រូបក្ខន្ធគណនំ គច្ឆតិ តេន វត រេ វត្តព្វេ ចក្ខាយតនំ រូបក្ខន្ធេន សង្គហិតំ** *អាយតនៈ គឺភ្នែក ដល់នូវការរាប់ដោយខន្ធណា ដល់នូវការរាប់ដោយរូបក្ខន្ធ ។ បើអាយតនៈ គឺភ្នែកដល់នូវការរាប់ដោយរូបក្ខន្ធយ៉ាងនេះ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុ នោះ អ្នកគួរពោលថា អាយតនៈគឺភ្នែកសង្គ្រោះដោយរូបក្ខន្ធ ដូច្នេះ ឈ្មោះ ថា គណនសង្គហៈ ។ ក្នុងទីនេះ លោកបំណងយកគណនសង្គហៈ ព្រោះ គណនសង្គហៈនេះ លោកអធិប្បាយថា បានដល់ ការរាប់រូបដោយចំណែក មួយ ។ ក្នុងបទទាំងពួងក៏ន័យនេះ ។*

*អធិប្បាយឯកកនិទ្ទេស ចប់*

# អភិធម្មបិដក

## ធុកនិក្ខេបជាដើម

[ ១៥ ] រូបជាឧបាទានោះ តើដូចម្តេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្សសន្តតិ រូបស្សជរតា រូបស្សអនិច្ចតា កពឡិង្ការាហារ ។

[ ១៦ ] រូបជាចក្ខាយតនៈនោះ តើដូចម្តេច ។ ភ្នែកណា គឺប្រសាទអាស្រ័យមហាភូតរូបទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ ( ឬថា ) បុគ្គលឃើញហើយក្តី កំពុងឃើញក្តី នឹងឃើញក្តី គប្បីឃើញក្តីនូវរូបដែលប្រកបដោយការឃើញ ប្រកបដោយការប៉ះពាល់ដោយភ្នែកណា ដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ភ្នែកនុ៎ះ ហៅថា ចក្ខុក៏បាន ( ព្រោះជាអ្នកត្រួតត្រាខាងការឃើញ ) ហៅថា ចក្ខាយតនៈក៏បាន ( ព្រោះជាទីប្រជុំចុះនៃកំណើតរបស់ខ្លួន ) ហៅថា ចក្ខុធាតុក៏បាន ( ព្រោះជាសភាវៈសូន្យទាំងមិនមែន ) ហៅថា ចក្ខុន្ទ្រិយក៏បាន ( ព្រោះមាននាទីខាងការឃើញ ) ហៅថា លោកក៏បាន ( ព្រោះជារបស់សម្រាប់វិនាស ) ហៅថា ទ្វារក៏បាន ( ព្រោះជារបស់សម្រាប់បើកបិទ ) ហៅថា សមុទ្ទក៏បាន ( ព្រោះបំពេញបានដោយក្រ ) ហៅថា បណ្ឌរក៏បាន ( ព្រោះជារបស់ថ្លាបរិសុទ្ធិ ) ហៅថា ខេត្តក៏បាន ( ព្រោះជាកន្លែងកើតផស្សៈជាដើម ) ហៅថា វត្ថុក៏បាន ( ព្រោះជា

ទីតម្កល់ផស្សៈជាដើម ) ហៅថា នេត្រក៏បាន ( ព្រោះបង្ហាញទីស្មើនឹងទីមិនស្មើហើយនាំអត្តភាពទៅ ) ហៅថា នយនៈក៏បាន ( ព្រោះសេចក្ដីដូចគ្នានឹងនេត្រនោះ ) ហៅថា ត្រើយអាយក៏បាន ( ព្រោះរាប់បញ្ចូលខាងកាយខ្លួន ) ហៅថា ស្រុកទំនេរ ក៏បាន ( ព្រោះជារបស់សាធារណ៍ដល់របស់ច្រើនទាំងគ្មានម្ចាស់ ) នេះរូបជាចក្ខាយតនៈ ។ រូបជាចក្ខាយតនៈនោះ តើដូចម្ដេច ។ ភ្នែកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ ដែលរាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ ( ឬថា ) បុគ្គលខ្ញុំងខ្ញុប់ហើយក្ដី កំពុងខ្ញុំងខ្ញុប់ក្ដី នឹងខ្ញុំងខ្ញុប់ក្ដី គប្បីខ្ញុំងខ្ញុប់ក្ដីនូវរូប ដែលប្រកបដោយការឃើញ ប្រកបដោយការប៉ះពាល់ក្នុងភ្នែកណា ដែលមិនអាចឃើញដោយចក្ខុវិញ្ញាណ ប្រកបដោយការប៉ះពាល់ ភ្នែកនុ៎ះហៅថា ចក្ខុក៏បាន ថាចក្ខាយតនៈក៏បាន ថាចក្ខុធាតុក៏បាន ថាចក្ខុន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថានេត្រក៏បាន ថានយនៈក៏បាន ថាត្រើយខាងអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។ រូបជាចក្ខាយតនៈនោះ តើដូចម្ដេច ។ ភ្នែកណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញដោយចក្ខុវិញ្ញាណបាន ប្រកបដោយការប៉ះពាល់ ឬថា ភ្នែកណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ញុំងខ្ញុប់ហើយក្ដី កំពុងខ្ញុំងខ្ញុប់ក្ដី នឹងខ្ញុំងខ្ញុប់ក្ដី គប្បីខ្ញុំងខ្ញុប់ក្ដីក្នុងរូបដែលប្រកបដោយការឃើញ ប្រកបដោយការប៉ះពាល់ ភ្នែកនុ៎ះហៅថា ចក្ខុក៏បាន ថា

ចក្ខាយតនៈក៏បាន ថាចក្ខុធាតុក៏បាន ថាចក្ខុន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថានេត្រក៏បាន ថានយនៈក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។ រូបជាចក្ខាយតនៈនោះ តើដូចម្តេច ។ ភ្នែកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថា ចក្ខុសម្ផស្ស ប្រារព្ធរូប កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យភ្នែកណា ។បេ។ វេទនាកើតអំពីចក្ខុសម្ផស្ស ប្រារព្ធរូប ព្រោះអាស្រ័យនូវភ្នែកណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ចក្ខុវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ ចក្ខុសម្ផស្សមានរូបជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តីព្រោះអាស្រ័យភ្នែកណា ។បេ។ វេទនាកើតអំពីចក្ខុសម្ផស្សមានរូបជាអារម្មណ៍ព្រោះអាស្រ័យភ្នែកណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ចក្ខុវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ភ្នែកនុ៎ះហៅថា ចក្ខុក៏បាន ថាចក្ខាយតនក៏បាន ថាចក្ខុធាតុក៏បាន ថាចក្ខុន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថានេត្រក៏បាន ថានយនៈក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។

[ ១៧ ] រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពមិនអាចឃើញបាន

តែប្រកបដោយការប៉ះពាល់ ឬថាបុគ្គលស្តាប់ហើយក្តី កំពុងស្តាប់ក្តី នឹងស្តាប់ក្តី គប្បីស្តាប់ក្តីនូវសំឡេងដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ដោយត្រចៀកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ត្រចៀកនុ៎ះហៅថា សោតៈក៏បាន ថាសោតាយតនៈក៏បាន ថាសោតធាតុក៏បាន ថាសោតិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។ រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន ប្រកបដោយការប៉ះពាល់ ឬថាសំឡេងដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងត្រចៀកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ត្រចៀកនុ៎ះ ហៅថា សោតៈក៏បាន ថាសោតាយតនៈក៏បាន ថាសោតធាតុក៏បាន ថាសោតិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។ រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណាគឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាត្រចៀកណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បី

ខ្ទាំងខ្ទប់ក្តី ក្នុងសំឡេងដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ត្រចៀកនុ៎ះ ហៅថា សោតៈក៏បាន ថាសោតាយតនៈក៏បាន ថាសោតធាតុក៏បាន ថាសោតិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។ រូបជាសោតាយតនៈនោះ តើដូចម្តេច ។ ត្រចៀកណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពមិនអាចឃើញបានតែប្រកបដោយការប៉ះពាល់ ឬថាសោតសម្ផស្ស ប្រារព្ធនូវសំឡេង កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យត្រចៀកណា ។បេ។ វេទនាកើតអំពីសោតសម្ផស្ស ប្រារព្ធនូវសំឡេងព្រោះអាស្រ័យត្រចៀកណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សោតវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ សោតសម្ផស្ស មានសំឡេងជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យត្រចៀកណា ។បេ។ វេទនាកើតអំពីសោតសម្ផស្ស មានសំឡេងជាអារម្មណ៍ អាស្រ័យនូវត្រចៀកណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សោតវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ត្រចៀកនុ៎ះ ហៅថា សោតៈក៏បាន ថាសោ-តាយតនៈក៏បាន ថាសោតធាតុក៏បាន ថាសោតិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាសោតាយតនៈ ។

[ ១៨ ] រូបជាឃានាយតនៈនោះ តើដូចម្ដេច ។ ប្រមុះណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាបុគ្គលធុំហើយក្ដី កំពុងធុំក្ដី នឹងធុំក្ដី គប្បីធុំក្ដីនូវក្លិនដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ដោយប្រមុះណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ប្រមុះនុ៎ះ ហៅថាឃានក៏បាន ថាឃានាយតនៈក៏បាន ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាឃានាយតនៈ ។ រូបជាឃានាយតនៈនោះ តើដូចម្ដេច ។ ប្រមុះណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាក្លិនដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ខ្ទាំងខ្ទប់ហើយក្ដី កំពុងខ្ទាំងខ្ទប់ក្ដី នឹងខ្ទាំងខ្ទប់ក្ដី គប្បីខ្ទាំងខ្ទប់ក្ដីក្នុងប្រមុះណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ប្រមុះនុ៎ះ ហៅថាឃានក៏បាន ថាឃានាយតនៈក៏បាន ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាឃានាយតនៈ ។ រូបជាឃានាយតនៈនោះ តើដូចម្ដេច ។ ប្រមុះណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបានតែប្រកបដោយការប៉ះពាល់ ឬថាប្រមុះណា ដែលមិនអាចឃើញបាន

តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងក្លិនដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ប្រមុះនុ៎ះ ហៅថា ឃានក៏បាន ថាឃានាយតនៈក៏បាន ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាឃានាយតនៈ ។ រូបជាឃានាយតនៈនោះ តើដូចម្តេច ។ ប្រមុះណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាឃានសម្ផស្ស ប្រារព្ធនូវក្លិនកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យនូវប្រមុះណា ។បេ។ វេទនាកើតអំពីឃានសម្ផស្សៈប្រារព្ធនូវក្លិនព្រោះអាស្រ័យនូវប្រមុះណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ឃានវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ ឃានសម្ផស្សមានក្លិនជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យនូវប្រមុះណា ។បេ។ វេទនាកើតអំពីឃានសម្ផស្សៈមានក្លិនជាអារម្មណ៍ព្រោះអាស្រ័យនូវប្រមុះណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ឃានវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ប្រមុះនុ៎ះ ហៅថាឃានក៏បាន ថាឃានាយតនៈក៏បាន ថាឃានធាតុក៏បាន ថាឃានិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏

បាន នេះរូបជាឃានាយតនៈ ។

[ ១៩ ] រូបជាជិវ្ហាយតនៈនោះ តើដូចម្តេច ។ អណ្តាតណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថា បុគ្គលលិទ្ធភក្សត្តិ កំពុងលិទ្ធភក្សត្តិ នឹងលិទ្ធភក្សត្តិ គប្បីលិទ្ធភក្សត្តិនូវរសដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ដោយអណ្តាតណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ អណ្តាតនុ៎ះ ហៅថា ជិវ្ហាក៏បាន ថាជិវ្ហាយតនៈក៏បាន ថាជិវ្ហាធាតុក៏បាន ថាជិវ្ហិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយ អាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាជិវ្ហាយតនៈ ។ រូបជាជិវ្ហាយតនៈនោះ តើដូចម្តេច ។ អណ្តាតណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកដដោយការប៉ះពាល់ ឬថារសដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ បានខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងអណ្តាតណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ អណ្តាតនុ៎ះ ហៅថា ជិវ្ហាក៏បាន ថាជិវ្ហាយតនៈក៏បាន ថាជិវ្ហាធាតុក៏បាន ថាជិវ្ហិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាជិវ្ហាយតនៈ ។ រូបជាជិវ្ហាយតនៈនោះ តើដូចម្តេច ។ អណ្តាតណា គឺប្រសាទ អាស្រ័យនូវមហាភូតទាំង ៤ រាប់ចូល

ក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកដដោយការប៉ះពាល់ ឬថាអណ្តាត ណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ បានខ្ទាំងខ្ទប់ ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តីក្នុងរសដែលមិនអាច ឃើញបាន តែប្រកបដោយការប៉ះពាល់ អណ្តាតនុ៎ះហៅថា ជិវ្ហាក៏បាន ថា ជិវ្ហាយតនៈក៏បាន ថាជិវ្ហាធាតុក៏បាន ថាជិវ្ហិន្ទ្រិយក៏បាន ថាលោកក៏បាន ថា ទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថា ត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាជិវ្ហាយតនៈ ។ រូបជាជិវ្ហា-យតនៈនោះ តើដូចម្តេច ។ អណ្តាតណា គឺប្រសាទ អាស្រ័យមហាភូត ទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះ ពាល់ ឬថាជិវ្ហាសម្ផស្ស ប្រារព្ធនូវរស កើតឡើងហើយក្តី កំពុងកើតក្តី នឹង កើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យអណ្តាតណា ។បេ។ វេទនាកើតអំពីជិវ្ហា-សម្ផស្ស ប្រារព្ធនូវរស ព្រោះអាស្រ័យអណ្តាតណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ជិវ្ហាវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ ជិវ្ហាសម្ផស្ស មានរសជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យអណ្តាតណា វេទនាកើត អំពីជិវ្ហាសម្ផស្ស មានរសជាអារម្មណ៍ព្រោះអាស្រ័យនូវអណ្តាតណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ជិវ្ហាវិញ្ញាណ កើតហើយក្តី កំពុងកើតក្តី នឹង កើតក្តី គប្បីកើតក្តី អណ្តាតនុ៎ះ ហៅថា ជិវ្ហាក៏បាន ថាជិវ្ហាយតនៈក៏បាន ថា ជិវ្ហាធាតុក៏បាន ថាជិវ្ហិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទ

ក៏បាន ថាបណ្ណរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាជិវ្ហាយតនៈ ។

[ ២០ ] រូបជាកាយាយតនៈនោះ តើដូចម្តេច ។ កាយណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាព ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬបុគ្គលបានពាល់ត្រូវហើយក្តី កំពុងពាល់ត្រូវក្តី នឹងពាល់ត្រូវក្តី គប្បីពាល់ត្រូវក្តីនូវផោដ្ឋព្វៈដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ដោយកាយណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ កាយនុ៎ះ ហៅថា កាយក៏បាន ថាកាយាយតនៈក៏បាន ថាកាយធាតុក៏បាន ថាកាយិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថា សមុទ្ទក៏បាន ថាបណ្ណរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាកាយាយតនៈ ។ រូបជាកាយាយតនៈនោះ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែក្រុបកដោយការប៉ះពាល់ ឬផោដ្ឋព្វៈ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងកាយណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ កាយនុ៎ះ ហៅថា កាយក៏បាន ថាកាយាយតនៈក៏បាន ថាកាយធាតុក៏បាន ថាកាយិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ណរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាកាយា-

យតនៈ ។ រូបជាកាយាយតនៈនោះ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាកាយណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ បានខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងផោដ្ឋព្វៈដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ កាយនុ៎ះ ហៅថា កាយក៏បាន ថាកាយាយតនៈក៏បាន ថាកាយធាតុក៏បាន ថាកាយិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាកាយាយតនៈ ។ រូបជាកាយាយតនៈនោះ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ រាប់ចូលក្នុងអត្តភាពដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬថាកាយសម្ផស្ស ប្រារព្ធនូវផោដ្ឋព្វៈ កើតហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យកាយណា ។បេ។ វេទនាកើតអំពីកាយសម្ផស្ស ប្រារព្ធនូវផោដ្ឋព្វៈ ព្រោះអាស្រ័យកាយណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ កាយវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ កាយសម្ផស្សមានផោដ្ឋព្វៈជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យកាយណា វេទនាកើតអំពីកាយសម្ផស្ស មានផោដ្ឋព្វៈជាអារម្មណ៍ព្រោះអាស្រ័យកាយណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ កាយវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី កាយ

ន្ទុំះ ហៅថា កាយក៏បាន ថាកាយាយតនៈក៏បាន ថាកាយធាតុក៏បាន ថាកាយិន្ទ្រិយក៏បាន ថាលោកក៏បាន ថាទ្វារក៏បាន ថាសមុទ្ទក៏បាន ថាបណ្ឌរៈក៏បាន ថាខេត្តក៏បាន ថាវត្ថុក៏បាន ថាត្រើយអាយក៏បាន ថាស្រុកទំនេរក៏បាន នេះរូបជាកាយាយតនៈ ។

[ ២១ ] រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌ អាស្រ័យមហាភូតទាំង ៤ ជាវត្ថុដែលអាចឃើញបាន ប្រកបដោយការប៉ះពាល់ ជាពណ៌ខៀវ លឿង ក្រហម ស ខ្មៅ ហង្សបាទ ដាំដែង បៃតង ពណ៌ដូចពន្លកស្វាយ វែង ខ្លី តូច ធំ មូល សំប៉ែត មូលក្តុំ ៤ ជ្រុង ៦ ជ្រុង ៨ ជ្រុង ១៦ ជ្រុង ទំនាប ទួល ស្រមោល កម្តៅថ្ងៃ ភ្លឺ ងងឹត ពពក ផែនដីផ្សែង ធូលី ពណ៌មណ្ឌលព្រះចន្ទ ពណ៌មណ្ឌលព្រះអាទិត្យ ពណ៌រូបផ្កាយ ពណ៌មណ្ឌលកញ្ចក់ ពណ៌កែវមណី ស័ង្ខ កែវមុក្តានិងកែវពិទូរ្យ ពណ៌មាសនិងពណ៌ប្រាក់ ឬថាវត្ថុណាមួយសូម្បីដទៃ ដែលជារូបមានពណ៌ អាស្រ័យមហាភូតទាំង ៤ ជាវត្ថុអាចឃើញបាន ប្រកបដោយការប៉ះពាល់ ឬថា បុគ្គលឃើញហើយក្តី កំពុងឃើញក្តី នឹងឃើញក្តី គប្បីឃើញក្តីនូវរូបណាដែលប្រកបដោយការឃើញបាន ទាំងប្រកបដោយការប៉ះពាល់ដោយចក្ខុដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ រូបន្ទុំះ ហៅថា រូបក៏បាន ថារូបាយតនៈក៏បាន ថារូបធាតុក៏បាន នេះរូបជារូបាយតនៈ ។ រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌ អាស្រ័យមហាភូតរូបទាំង ៤ ជាវត្ថុដែលអាចឃើញបាន ទាំងប្រកបដោយការប៉ះពាល់ ជាពណ៌ខៀវ

លឿង ក្រហម ស ខ្មៅ ហង្សបាទ ដាំដែង ពណ៌បៃតង ពណ៌ដូចពន្លក ស្វាយ វែង ខ្លី តូច ធំ មូល សំប៉ែត មូលក្តុំ ៤ ជ្រុង ៦ ជ្រុង ៨ ជ្រុង ១៦ ជ្រុង ទំនាប ទួល ស្រមោល កម្តៅថ្ងៃ ភ្លឺ ងងឹត ពពក ផែនដី ផ្សែង ធូលី ពណ៌មណ្ឌលព្រះចន្ទ ពណ៌មណ្ឌលព្រះអាទិត្យ ពណ៌ពួករូបផ្កាយ ពណ៌មណ្ឌលកញ្ចក់ ពណ៌កែវមណី ស័ង្ខ មុក្តានិងកែវពិទូរ្យ ពណ៌មាស និងពណ៌ប្រាក់ ឬថាវត្ថុណាមួយសូម្បីដទៃដែលជារូបមានពណ៌ អាស្រ័យមហាភូតទាំង ៤ ដែលអាចឃើញបាន ប៉ះពាល់បាន ឬចក្ខុដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ចំពោះរូបណាដែលអាចឃើញបាន ប៉ះពាល់បាន រូបនុ៎ះ ហៅថា រូបក៏បាន ជារូបាយតនៈក៏បាន ជារូបធាតុក៏បាន នេះរូបជារូបាយតនៈ ។ រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតទាំង ៤ អាចឃើញបាន ប៉ះពាល់បាន ជាពណ៌ខៀវ លឿង ក្រហម ស ខ្មៅ ហង្សបាទ ដាំដែង ពណ៌បៃតង ពណ៌ដូចពន្លក ស្វាយ វែង ខ្លី តូច ធំ មូល សំប៉ែត មូលក្តុំ ៤ ជ្រុង ៦ ជ្រុង ៨ ជ្រុង ១៦ ជ្រុង ទំនាប ទួល ស្រមោល កម្តៅថ្ងៃ ភ្លឺ ងងឹត ពពក ផែនដី ផ្សែង ធូលី ពណ៌មណ្ឌលព្រះចន្ទ ពណ៌មណ្ឌលព្រះអាទិត្យ ពណ៌ពួករូបផ្កាយ ពណ៌មណ្ឌលកញ្ចក់ ពណ៌កែវមណី ស័ង្ខ មុក្តា កែវពិទូរ្យ ពណ៌មាសនឹងប្រាក់ ឬវត្ថុណាមួយសូម្បីដទៃដែលជារូបមានពណ៌ អាស្រ័យមហាភូតទាំង ៤ ជាវត្ថុអាចឃើញបាន ប៉ះពាល់បាន ឬថា រូបណាដែលអាចឃើញបាន

ប៉ះពាល់បាន ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ចំពោះភ្នែកដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ រូបនុ៎ះហៅថា រូបក៏បាន ថារូបាយតនៈក៏បាន ថារូបធាតុក៏បាន នេះរូបជារូបាយតនៈ ។ រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌អាស្រ័យមហាភូតទាំង ៤ ជាវត្ថុអាចឃើញបាន ប៉ះពាល់បាន ជាពណ៌ខៀវ លឿង ក្រហម ស ខ្មៅ ហង្សបាទ ដាំដែង ពណ៌បៃតង ពណ៌ដូច ពន្លកស្វាយ វែង ខ្លី តូច ធំ មូល សំប៉ែត មូលក្នុំ ៤ ជ្រុង ៦ ជ្រុង ៨ ជ្រុង ១៦ ជ្រុង ទំនាប ទួល ស្រមោល កម្តៅថ្ងៃ ភ្លឺ ងងឹត ពពក ផែនដី ធូលី ផ្សែង ពណ៌មណ្ឌលព្រះចន្ទ ពណ៌មណ្ឌលព្រះអាទិត្យ ពណ៌ពួករូបផ្កាយ ពណ៌មណ្ឌលកញ្ចក់ ពណ៌កែវមណី ស័ង្ខ មុក្តា កែវពិទូរ្យ ពណ៌មាសនិងប្រាក់ ឬថាវត្ថុណាមួយជារូបមានពណ៌ អាស្រ័យមហាភូតទាំង ៤ ជាវត្ថុអាចឃើញបាន ប៉ះពាល់បាន ឬថា ចក្ខុសម្ផស្សប្រារព្ធនូវរូបណាកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យភ្នែក ។បេ។ វេទនាកើតអំពីចក្ខុសម្ផស្ស ប្រារព្ធនូវរូបណា ព្រោះអាស្រ័យភ្នែក ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ចក្ខុវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ ចក្ខុសម្ផស្សមានរូបជាអារម្មណ៍ អាស្រ័យភ្នែកណា កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ វេទនាកើតអំពីចក្ខុសម្ផស្សមានរូបជាអារម្មណ៍ព្រោះអាស្រ័យភ្នែកណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ចក្ខុវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី

នឹងកើតក្តី គប្បីកើតក្តី រូបនុ៎ះ ហៅថា រូបក៏បាន ថារូបាយតនៈក៏បាន ថារូបធាតុក៏បាន នេះរូបជារូបាយតនៈ ។

[ ២២ ] រូបជាសទ្ទាយតនៈនោះ តើដូចម្តេច ។ សំឡេងណាអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន ប្រកបដោយការប៉ះពាល់ គឺសំឡេងស្គរ សំឡេងសម្ភោរ សំឡេងស័ង្ខ សំឡេងស្គរជ័យ សំឡេងច្រៀង សំឡេងប្រគំ សំឡេងរនាត សំឡេងទះដៃ សំឡេងខ្ទារខ្ទរនៃពួកសត្វ សំឡេងពួកធាតុ ប៉ះពាល់គ្នា សំឡេងខ្យល់ សំឡេងទឹក សំឡេងមនុស្ស សំឡេងអមនុស្ស ឬសំឡេងណាមួយសូម្បីដទៃ ដែលអាស្រ័យមហាភូតទាំង ៤ មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬបុគ្គលស្តាប់ហើយក្តី កំពុងស្តាប់ក្តី គប្បីស្តាប់ក្តីនូវសំឡេងណា ដែលមិនអាចឃើញបាន តែប៉ះពាល់បានដោយត្រចៀក ដែលមិនអាចឃើញបាន តែប៉ះពាល់បាន សំឡេងនុ៎ះហៅថា សទ្ទៈក៏បាន ថាសទ្ទាយតនៈក៏បាន ថាសទ្ទធាតុក៏បាន នេះរូបជាសទ្ទាយតនៈ ។ រូបជាសទ្ទាយតនៈនោះ តើដូចម្តេច ។ សំឡេងណា អាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប៉ះពាល់បាន គឺសូរស្គរធំ សូរសម្ភោរ សូរស័ង្ខ សូរស្គរជ័យ សំឡេងច្រៀង សូរប្រគំ សូររនាត សូរទះដៃ សូរខ្ទារខ្ទរនៃពួកសត្វ សូរធាតុទង្គិចគ្នា សូរខ្យល់ សូរទឹក សំឡេងមនុស្ស សំឡេងអមនុស្ស ឬថាសូរសត្វណាមួយ សូម្បីដទៃដែលអាស្រ័យមហាភូតទាំង ៤ មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ មួយទៀត ត្រចៀកដែលមិនអាចឃើញបាន តែ

ប្រកបដោយការប៉ះពាល់ ខ្ញុំឯខ្ញុំហើយក្តី កំពុងខ្ញុំឯខ្ញុំក្តី នឹងខ្ញុំឯខ្ញុំក្តី គប្បីខ្ញុំឯខ្ញុំក្តីចំពោះសំឡេងណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ សូរសព្ទនុ៎ះ ហៅថា សទ្ទៈក៏បាន ថាសទ្ទាយតនៈក៏បាន ថាសទ្ទធាតុក៏បាន នេះរូបជាសទ្ទាយតនៈ ។ រូបជាសទ្ទាយតនៈនោះ តើដូចម្តេច ។ សំឡេងណា អាស្រ័យមហាភូតទាំង ៤ មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺសូរស្គរធំ សូរសម្ភោរ សូរស័ង្ខ សូរស្គរជ័យ សំឡេងច្រៀង សូរប្រគំ សូររនាត សូរទះដៃ សូរខ្ជារខ្ជរនៃពួកសត្វ សូរពួកធាតុទង្គិចគ្នា សូរខ្យល់ សូរទឹក សំឡេងមនុស្ស សំឡេងអមនុស្ស ឬថា សូរសព្ទណាមួយសូម្បីដទៃ ដែលអាស្រ័យមហាភូតទាំង ៤ មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬសំឡេងណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ញុំឯខ្ញុំហើយក្តី កំពុងខ្ញុំឯខ្ញុំក្តី នឹងខ្ញុំឯខ្ញុំក្តី គប្បីខ្ញុំឯខ្ញុំក្តីចំពោះត្រចៀកដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ សូរសព្ទនុ៎ះ ហៅថា សទ្ទៈក៏បាន ថាសទ្ទាយតនក៏បាន ថាសទ្ទធាតុក៏បាន នេះរូបជាសទ្ទាយតនៈ ។ រូបជាសទ្ទាយតនៈនោះ តើដូចម្តេច ។ សំឡេងណា អាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺសូរស្គរធំ សូរសម្ភោរ សូរស័ង្ខ សូរស្គរជ័យ សំឡេងច្រៀង សូរប្រគំ សូររនាត សូរទះដៃ សូរខ្ជារខ្ជរនៃពួកសត្វ សូរពួកធាតុទង្គិចគ្នា សូរខ្យល់ សូរទឹក សំឡេងមនុស្ស សំឡេងអមនុស្ស ឬថា សូរសព្ទណាមួយសូម្បីដទៃដែលអាស្រ័យមហាភូតទាំង ៤ ដែលមិន

អាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬសោតសម្ផស្ស ប្រារព្ធនូវសំឡេងណាកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យត្រចៀកណា ។បេ។ វេទនាកើតអំពីសោតសម្ផស្ស ប្រារព្ធសំឡេងណាព្រោះអាស្រ័យត្រចៀក ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សោតវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ សោតសម្ផស្ស មានសំឡេងជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យត្រចៀកណា ។បេ។ វេទនាកើតអំពីសោតសម្ផស្ស មានសំឡេងជាអារម្មណ៍ព្រោះអាស្រ័យត្រចៀកណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ សោតវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី សូរសព្ទនុ៎ះ ហៅថា សទ្ទៈក៏បាន ថាសទ្ទាយតនៈក៏បាន ថាសទ្ទធាតុក៏បាន នេះរូបជាសទ្ទាយតនៈ ។

[ ២៣ ] រូបជាគន្ធាយតនៈនោះ តើដូចម្តេច ។ ក្លិនណាអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបានតែប្រកបដោយការប៉ះពាល់ គឺក្លិនមើម ក្លិនខ្លឹម ក្លិនសម្បក ក្លិនស្លឹក ក្លិនផ្កា ក្លិនផ្លែ ក្លិនធ្លាប ក្លិនក្រពុល ក្លិនក្រអូប ក្លិនស្អុយ ឬក្លិនណាមួយសូម្បីដទៃដែលអាស្រ័យមហាភូតទាំង ៤ មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬបុគ្គលធុំហើយក្តី កំពុងធុំក្តី នឹងធុំក្តី គប្បីធុំក្តីនូវក្លិនណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ដោយច្រមុះ ដែលមិនអាចឃើញបាន តែប្រកបដោយ ការប៉ះពាល់ ក្លិននុ៎ះ ហៅថា គន្ធៈក៏បាន ថាគន្ធាយតនៈក៏បាន ថាគន្ធធាតុក៏បាន

នេះរូបជាគន្ធាយតនៈ ។ រូបជាគន្ធាយតននោះ តើដូចម្តេច ។ ក្លិនណាដែលអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺក្លិនមើម ក្លិនខ្លឹម ក្លិនសម្បក ក្លិនស្លឹក ក្លិនផ្កា ក្លិនផ្លែ ក្លិនឆ្អាប ក្លិនក្រពុល ក្លិនក្រអូប ក្លិនស្អុយ ឬក្លិនណាមួយសូម្បីដទៃ ដែលអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬប្រមុះដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តីចំពោះក្លិនណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ក្លិននុ៎ះ ហៅថា គន្ធៈក៏បាន ជាគន្ធាយតនៈក៏បាន ជាគន្ធធាតុក៏បាន នេះរូបជាគន្ធាយតនៈ ។ រូបជាគន្ធាយតនៈនោះ តើដូចម្តេច ។ ក្លិនណា អាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបានតែប្រកបដោយការប៉ះពាល់ គឺក្លិនមើម ក្លិនខ្លឹម ក្លិនសម្បក ក្លិនស្លឹក ក្លិនផ្កា ក្លិនផ្លែ ក្លិនឆ្អាប ក្លិនក្រពុល ក្លិនក្រអូប ក្លិនស្អុយ ឬក្លិនណាមួយសូម្បីដទៃ ដែលអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ មួយទៀត ក្លិនណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តីចំពោះប្រមុះ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ក្លិននុ៎ះ ហៅថា គន្ធៈក៏បាន ជាគន្ធាយតនៈក៏បាន ជាគន្ធធាតុក៏បាន នេះរូបជាគន្ធាយតនៈ ។ រូបជាគន្ធាយតនៈនោះ តើដូចម្តេច ។ ក្លិនណាអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការ

ប៉ះពាល់ គឺក្លិនមើម ក្លិនខ្លឹម ក្លិនសម្បក ក្លិនស្លឹក ក្លិនផ្កា ក្លិនផ្លែ ក្លិនផ្អាប ក្លិនក្រពុល ក្លិនក្រអូប ក្លិនស្អុយ ឬក្លិនណាមួយសូម្បីដទៃដែលអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬឃានៈសម្ផស្ស ប្រារព្ធនូវក្លិនណាកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តីព្រោះអាស្រ័យប្រមុះ ។បេ។ វេទនាកើតអំពីឃានសម្ផស្សប្រារព្ធនូវក្លិនណា ព្រោះអាស្រ័យប្រមុះ ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ឃានវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ ឃានសម្ផស្សមានក្លិនជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តីព្រោះអាស្រ័យប្រមុះណា ។បេ។ វេទនាកើតអំពីឃានសម្ផស្សមានក្លិនជាអារម្មណ៍ ព្រោះអាស្រ័យប្រមុះណា ។បេ។ សញ្ញា ។បេ។ ចេ-តនា ។បេ។ ឃានវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ក្លិននុ៎ះ ហៅថា គន្ធៈក៏បាន ថាគន្ធាយតនៈក៏បាន ថាគន្ធធាតុក៏បាន នេះរូបជាគន្ធាយតនៈ ។

[ ២៤ ] រូបជារសាយតនៈនោះ តើដូចម្តេច ។ រសជាតិណាអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺរសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ រសជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ រសលាយជូរ ចត់ ធ្លាញ់ មិនធ្លាញ់ ឬរសណាមួយសូម្បីដទៃ អាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬបុគ្គលលិទ្ធភក្សហើយក្តី កំពុងលិទ្ធភក្សក្តី នឹងលិទ្ធភក្ស

ក្តី គប្បីលិទ្ធភ្លក្សក្តីនូវរសណា ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ដោយអណ្តាត ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ រសជាតិនុ៎ះ ហៅថា រសក៏បាន ថារសាយតនៈក៏បាន ថារសធាតុក៏បាន នេះរូបជារសាយតនៈ ។ រូបជារសាយតនៈនោះ តើដូចម្តេច ។ រសណាអាស្រ័យមហាភូតទាំង ៤ មិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺរសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ រសជូរ រសផ្អែម ល្វីង ហឹរ ប្រៃ ខារ រសលាយជូរ ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ឬរសណាមួយសូម្បីដទៃដែលអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬអណ្តាតដែលមិនអាចឃើញបានដែលប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ចំពោះរសណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ រសជាតិនេះ ហៅថា រសក៏បាន ថារសាយតនៈក៏បាន ថារសធាតុក៏បាន នេះរូបជារសាយតនៈ ។ រូបជារសាយតនៈនោះ តើដូចម្តេច ។ រសណាអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺរសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ ជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ រសលាយជូរ ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ឬរសណាមួយសូម្បីដទៃអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ឬរសណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី

ចំពោះអណ្តាត ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ រស ជាតិទុំះ ហៅថា រសក៏បាន ថារសាយតនៈក៏បាន ថារសធាតុក៏បាន នេះរូបជារសាយតនៈ ។ រូបជារសាយតនៈនោះ តើដូចម្តេច ។ រសណាអាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ គឺ រសមើម រសដើម រសសម្បក រសស្លឹក រសផ្កា រសផ្លែ ជូរ ផ្អែម ល្វីង ហឹរ ប្រៃ ខារ រសឈាយជូរ ចត់ ឆ្ងាញ់ មិនឆ្ងាញ់ ឬរសណាមួយសូម្បីដទៃ អាស្រ័យមហាភូតទាំង ៤ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ មួយទៀត ជិវ្ហាសម្ផស្សប្រារព្ធនូវរសកើតហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យអណ្តាតណា ។បេ។ វេទនាកើតអំពីជិវ្ហាសម្ផស្សប្រារព្ធនូវរសណាព្រោះអាស្រ័យអណ្តាត ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ជិវ្ហាវិញ្ញាណ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ ជិវ្ហាសម្ផស្ស មានរសជាអារម្មណ៍ កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ព្រោះអាស្រ័យអណ្តាតណា ។បេ។ វេទនា កើតអំពីជិវ្ហាសម្ផស្ស មានរសជាអារម្មណ៍ព្រោះ អាស្រ័យអណ្តាតណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ ជិវ្ហាវិញ្ញាណកើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី រសជាតិទុំះ ហៅថា រសក៏បាន ថារសាយតនៈក៏បាន ថារសធាតុក៏បាន នេះរូបជារសាយតនៈ ។

[ ២៥ ] រូបជាឥត្ថិន្ទ្រិយនោះ តើដូចម្តេច ។ ទ្រង់ទ្រាយជាស្រី គ្រឿងចំណាំជាស្រី កិរិយាជាស្រី អាការជាស្រី លំនាំជាស្រី ភាពជាស្រីណា

របស់ស្រី រូបនេះជាឥត្ថិន្ទ្រិយ ។

[ ២៦ ] រូបជាបុរិសិន្ទ្រិយនោះ តើដូចម្តេច ។ ទ្រង់ទ្រាយជាប្រុស គ្រឿងចំណាំជាប្រុស កិរិយាជាប្រុស អាការជាប្រុស លំនាំជាបុរស ភាពជាប្រុសណារបស់ប្រុស នេះរូបជាបុរិសិន្ទ្រិយ ។

[ ២៧ ] រូបជាជីវិតិន្ទ្រិយនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការរស់នៅយឺនយូរ ការស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវរូបធម៌ ទាំងនោះគឺជីវិត ជីវិតិន្ទ្រិយណា នេះរូបជាជីវិតិន្ទ្រិយ ។

[ ២៨ ] រូបជាកាយវិញ្ញត្តិនោះ តើដូចម្តេច ។ ការទប់កាយ ការគាំទ្រកាយ ការទប់ទល់កាយ ការកម្រើកកាយ អាការញុំាងកាយ ឲ្យកម្រើក ភាពញុំាងកាយឲ្យកម្រើកណានៃបុគ្គលមានចិត្តជាកុសលក្តី មានចិត្តជាអកុសលក្តី មានចិត្តជាអព្យាក្រឹតក្តី កាលឈានទៅមុខក្តី ឈានទៅក្រោយក្តី សម្លឹងមើលក្តី ក្រឡេកមើលក្តី បត់ចូលក្តី លាចេញក្តី នេះរូបជាកាយវិញ្ញត្តិ ។

[ ២៩ ] រូបជាវចីវិញ្ញត្តិនោះ តើដូចម្តេច ។ វាចា ការបន្លឺ គន្លងពាក្យ ការពោល ការគឹកកង កម្មគឺការគឹកកង គឺវាចា វចីភេទណានៃបុគ្គលមានចិត្តជាកុសលក្តី មានចិត្តជាអកុសលក្តី មានចិត្តជាអព្យាក្រឹតក្តី នេះហៅថាវាចា គឺការកម្រើកសម្តី ការញុំាងសម្តីឲ្យកម្រើក ភាពនៃការញុំាងសម្តីឲ្យកម្រើក នេះរូបជាវចីវិញ្ញត្តិ ។

[ ៣០ ] រូបជាអាកាសធាតុនោះ តើដូចម្តេច ។ កន្លែងដែលមិនអាចប៉ះពាល់ដោយ

រាស់បាន អាកាស ទីឥតទើស ទីអាកាស ទីចន្លោះ វាលដែលមិនប៉ះពាល់ ដោយមហាភូតទាំង ៤ ណា នេះរូបជាអាកាសធាតុ ។

[ ៣១ ] រូបជារូបស្សលហុតានោះ តើដូចម្តេច ។ ការរហ័សរហួន ការប្រែប្រួលរហ័ស ការមិនយឺតយូរ ការមិនបន្ទន់ណានៃរូប នេះរូបជារូបស្សលហុតា ។

[ ៣២ ] រូបជារូបស្សមុទុតានោះ តើដូចម្តេច ។ ការទន់ ភាពទន់ ការមិនរឹង ការមិនស្ពូកស្ពឹងណានៃរូប នេះរូបជារូបស្សមុទុតា ។

[ ៣៣ ] រូបជារូបស្សកម្មញ្ញតានោះ តើដូចម្តេច ។ ភាពនៃរូប គួរដល់ការងារ ការធ្វើការងារបាន ភាពគួរធ្វើការងារបានណា នេះរូបជារូបស្សកម្មញ្ញតា ។

[ ៣៤ ] រូបជារូបស្សឧបចយៈនោះ តើដូចម្តេច ។ ការសន្សំណានៃពួកអាយតនៈ នោះជារូបស្សឧបចយៈ នេះរូបជារូបស្សឧបចយៈ ។

[ ៣៥ ] រូបជារូបស្សសន្តតិនោះ តើដូចម្តេច ។ ការកកើតណានៃរូបនោះជារូបស្សសន្តតិ គឺការតរូប នេះរូបជារូបស្សសន្តតិ ។

[ ៣៦ ] រូបជារូបស្សជរតានោះ តើដូចម្តេច ។ ជរា សេចក្តីគាំគ្រា ការបាក់ធ្មេញ សក់ស្កូវ ស្បែកជ្រីវ ការថយអាយុ ការចាស់ទុំនៃពួកឥន្ទ្រិយណានៃរូប នេះរូបជារូបស្សជរតា ។

[ ៣៧ ] រូបជារូបស្សអនិច្ចតានោះ តើដូចម្តេច ។ ការអស់ទៅ ការសូន្យទៅ ការបែកធ្លាយ ការបាក់បែក ការមិនទៀង ការបាត់បង់ណានៃរូប

នេះរូបជារូបស្សអនិច្ចតា ។

[ ៣៨ ] រូបជាកពឡិង្ការាហារនោះ តើដូចម្តេច ។ បាយ នំ សដូវ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ ឬរូបណាមួយ សូម្បីដទៃ គឺជារបស់សម្រាប់ស៊ីក្នុងមាត់ ទំពាដោយធ្មេញ លេបចូលក្នុងបំពង់ក ប្រកក្នុងផ្ទៃនៃពួកសត្វនោះៗ ក្នុងជនបទណាៗ ឬពួកសត្វញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយឱជាណា រូបនេះជាកពឡិង្ការាហារ ។

## រូបទាំងនេះ ជាឧបាទា ។

## ចប់ ឧបាទាភាជនីយៈ ។

## ចប់ បឋមភាណវារៈ ក្នុងរូបកណ្ឌ ។

[ ៣៩ ] រូបមិនមែនជាឧបាទានោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ ។

[ ៤០ ] រូបជាផោដ្ឋព្វាយតនៈនោះ តើដូចម្តេច ។ រូបជាបឋវីធាតុ តេជោធាតុ វាយោធាតុ ជារូបរឹង ទន់ ល្អិត គ្រោតគ្រាត មានសម្ផស្សជាសុខ មានសម្ផស្សជាទុក្ខ ជារូបធ្ងន់ រូបស្រាល បុគ្គលពាល់ត្រូវហើយក្តី កំពុងពាល់ត្រូវក្តី នឹងពាល់ត្រូវក្តី គប្បីពាល់ត្រូវក្តីនូវផ្សព្វណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ដោយកាយ ដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ផ្សព្វនុ៎ះ ហៅថា ផោដ្ឋព្វៈក៏បាន ថាផោដ្ឋព្វាយតនៈក៏បាន ថាផោដ្ឋព្វធាតុក៏បាន នេះរូបជាផោដ្ឋព្វាយតនៈ ។ រូបជា

ផោដ្ឋព្វាយតនៈនោះ តើដូចម្ដេច ។ រូបជាបឋវីធាតុ តេជោធាតុ វាយោធាតុ ជារូបរឹង ទន់ ល្អិត គ្រោតគ្រាត មានសម្ផស្សជាសុខ មានសម្ផស្សជាទុក្ខ ជារូបធ្ងន់ រូបស្រាល ឬកាយដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ចំពោះផស្សព្វណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ផស្សព្វទ្ទុំះ ហៅថា ផោដ្ឋព្វៈក៏បាន ថាផោដ្ឋព្វាយតនៈក៏បាន ថាផោដ្ឋព្វធាតុក៏បាន នេះរូបជាផោដ្ឋព្វាយតនៈ ។ រូបជាផោដ្ឋព្វាយតនៈនោះ តើដូចម្ដេច ។ រូបជាបឋវីធាតុ តេជោធាតុ វាយោធាតុ ជារូបរឹង ទន់ ល្អិត គ្រោតគ្រាត មានសម្ផស្សជាសុខ មានសម្ផស្សជាទុក្ខ ជារូបធ្ងន់ រូបស្រាល ឬផោដ្ឋព្វៈណាដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ខ្ទាំងខ្ទប់ហើយក្តី កំពុងខ្ទាំងខ្ទប់ក្តី នឹងខ្ទាំងខ្ទប់ក្តី គប្បីខ្ទាំងខ្ទប់ក្តី ក្នុងកាយដែលមិនអាចឃើញបាន តែប្រកបដោយការប៉ះពាល់ ផស្សព្វទ្ទុំះ ហៅថា ផោដ្ឋព្វក៏បាន ថាផោដ្ឋ-ព្វាយតនៈក៏បាន ថាផោដ្ឋព្វធាតុក៏បាន នេះរូបជាផោដ្ឋព្វាយតនៈ ។ រូបជាផោដ្ឋព្វាយតនៈនោះ តើដូចម្ដេច ។ រូបជាបឋវីធាតុ តេជោធាតុ វាយោធាតុ ជារូបរឹង ទន់ ល្អិត គ្រោតគ្រាត មានសម្ផស្សជាសុខ មានសម្ផស្សជាទុក្ខ ជារូបធ្ងន់ រូបស្រាល ឬកាយសម្ផស្ស អាស្រ័យនូវកាយ ព្រោះប្រារព្ធនូវផស្សព្វណា កើតឡើងហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ វេទនាដែលកើតអំពីកាយសម្ផស្ស អាស្រ័យនូវកាយ ព្រោះប្រារព្ធនូវផស្សព្វណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ កាយវិញ្ញាណ កើតឡើងហើយ

ក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ កាយសម្ផស្ស មានផោដ្ឋព្វជាអារម្មណ៍ អាស្រ័យនូវកាយណាកើតហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី ។បេ។ វេទនា ដែលកើតអំពីកាយសម្ផស្ស មានផោដ្ឋព្វជាអារម្មណ៍ អាស្រ័យនូវកាយណា ។បេ។ សញ្ញា ។បេ។ ចេតនា ។បេ។ កាយវិញ្ញាណ កើតហើយក្តី កំពុងកើតក្តី នឹងកើតក្តី គប្បីកើតក្តី សភាវៈនុ៎ះហៅថា ផោដ្ឋព្វក៏បាន ថាផោដ្ឋព្វាយតនៈក៏បាន ថាផោដ្ឋព្វធាតុក៏បាន នេះរូបជាផោដ្ឋព្វាយតនៈ ។

[ ៤១ ] រូបជាអាបោធាតុនោះ តើដូចម្តេច ។ សភាពជាទឹក ការតាំងនៅ គឺទឹក សភាពសើមជ្រាប ការតាំងនៅ គឺសភាពសើមជ្រាប ការតខ្ជាប់នៃរូប នេះរូបជាអាបោធាតុ ។

## រូបទាំងនេះ មិនមែនជាឧបាទា ។

[ ៤២ ] រូបជាឧបាទិន្នទោះ តើដូចម្តេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ ( ការសន្សំនៃរូប ) រូបស្សសន្តតិ ( តំណនៃរូប ) កពឡិង្ការាហារ ( អាហារដែលធ្វើឲ្យជាពំនូត ) ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្ន ។ រូបជាអនុបាទិន្នទោះ តើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ ( ការកម្រើកនៃកាយ ) វចីវិញ្ញត្តិ ( ការកម្រើកនៃវាចា ) រូបស្សលហុតា ( ភាពនៃរូបស្រាល )

រូបស្សមុទុតា ( ភាពនៃរូបទន់ ) រូបស្សកម្មញ្ញតា ( ភាពនៃរូបគួរដល់ការងារ ) រូបស្សជរតា ( ភាពនៃរូបគ្រាំគ្រា ) រូបស្សអនិច្ចតា ( ភាពនៃរូបមិនទៀង ) ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាអនុបាទិន្ន ។

[ ៤៣ ] រូបជាឧបាទិន្នុបាទានិយៈនោះតើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ ។ រូបជាអនុបាទិន្នុបាទានិយៈនោះ តើដូចម្ដេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាអនុបាទិន្នុបាទានិយៈ ។

[ ៤៤ ] រូបជាសនិទស្សនៈនោះ តើដូចម្ដេច ។ រូបាយតនៈ នេះរូបជាសនិទស្សនៈ ។ រូបជាអនិទស្សនៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។

កពឡឹង្គារាហារ នេះរូបជាអនិទស្សនៈ ។

[ ៤៥ ] រូបជាសប្បដិឃៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ នេះរូបជាសប្បដិឃៈ ។ រូបជាអប្បដិឃៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡឹង្គារាហារ នេះរូបជាអប្បដិឃៈ ។

[ ៤៦ ] រូបជាឥន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខុន្ទ្រិយ សោតិន្ទ្រិយ ឃានិន្ទ្រិយ ជិវ្ហិន្ទ្រិយ កាយិន្ទ្រិយ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ នេះរូបជាឥន្ទ្រិយ ។ រូបមិនមែនជាឥន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡឹង្គារាហារ នេះរូបមិនមែនជាឥន្ទ្រិយ ។

[ ៤៧ ] រូបជាមហាភូតរូបនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ និងអាបោធាតុ នេះរូបជាមហាភូត ។ រូបមិនមែនជាមហាភូតនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡឹង្គារាហារ នេះរូបមិនមែនជាមហាភូត ។

[ ៤៨ ] រូបជាវិញ្ញត្តិនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះរូបជាវិញ្ញត្តិ ។ រូបមិនមែនជាវិញ្ញត្តិនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡឹង្គារាហារ នេះរូបមិនមែនជាវិញ្ញត្តិ ។

[ ៤៩ ] រូបជាចិត្តសមុដ្ឋាន ( រូបមានចិត្តជាសមុដ្ឋាន ) នោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ ឬក៏រូបដទៃណា គឺរូបកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសា-

យតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សលហុតា រូបស្ស មុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ នេះ រូបជាចិត្តសមុដ្ឋាន ។ រូបមិនមែនជាចិត្តសមុដ្ឋាននោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ រូ-បស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបមិនមែនកើតអំពីចិត្ត មិនមែនមានចិត្តជាហេតុ មិនមែនជាចិត្តសមុដ្ឋាន គឺរូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្ស លហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ នេះរូបមិនមែនជាចិត្តសមុដ្ឋាន ។

[ ៥០ ] រូបជាចិត្តសហភូ ( រូបកើតព្រមគ្នានឹងចិត្ត ) នោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះរូបជាចិត្តសហភូ ។ រូបមិនមែនជាចិត្តសហភូនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាចិត្តសហភូ ។

[ ៥១ ] រូបជាចិត្តានុបរិវត្តិ ( រូបប្រព្រឹត្តទៅតាមចិត្ត ) នោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះរូបជាចិត្តានុបរិវត្តិ ។ រូបមិនមែនជាចិត្តានុបរិវត្តិនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះ រូបមិនមែនជាចិត្តានុបរិវត្តិ ។

[ ៥២ ] រូបជាអជ្ឈត្តិក ( រូបខាងក្នុង ) នោះ តើដូចម្តេច ។ ចក្ខា-យតនៈ ។បេ។ កាយាយតនៈ នេះរូបជាអជ្ឈត្តិក ។ រូបជាពាហិរៈ ( រូប

ខាងក្រៅ ) នោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបជាពាហិរៈ ។

[ ៥៣ ] រូបជាឱឡារិកៈ ( រូបគ្រោតគ្រាត ) នោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបជាឱឡារិកៈ ។ រូបជាសុខុមៈ ( រូបល្អិត ) នោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបជាសុខុមៈ ។

[ ៥៤ ] ទូរេរូប ( រូបក្នុងទីឆ្ងាយ ) នោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះទូរេរូប ។ សន្តិកេរូប ( រូបក្នុងទីជិត ) នោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះសន្តិកេរូប ។

[ ៥៥ ] រូបជាវត្ថុនៃចក្ខុសម្ផស្សនោះ តើដូចម្តេច ។ ចក្ខាយតនៈ នេះរូបជាវត្ថុនៃចក្ខុសម្ផស្ស ។ រូបមិនមែនជាវត្ថុនៃចក្ខុសម្ផស្សនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាវត្ថុនៃចក្ខុសម្ផស្ស ។

[ ៥៦ ] រូបជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនា ដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ នេះរូប ជាវត្ថុនៃចក្ខុវិញ្ញាណ ។ រូបមិនមែនជាវត្ថុនៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាវត្ថុនៃចក្ខុវិញ្ញាណ ។

[ ៥៧ ] រូបជាវត្ថុនៃសោតសម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្សនោះ តើដូចម្តេច ។ កាយាយតនៈ

នេះរូបជាវត្ថុនៃកាយសម្ផស្ស ។ រូបមិនមែនជាវត្ថុនៃកាយសម្ផស្សនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាវត្ថុនៃកាយសម្ផស្ស ។

[ ៥៨ ] រូបជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនា ដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណនោះ តើដូចម្តេច ។ កាយាយតនៈ នេះរូបជាវត្ថុនៃកាយវិញ្ញាណ ។ រូបមិនមែនជាវត្ថុនៃកាយវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាវត្ថុនៃកាយវិញ្ញាណ ។

[ ៥៩ ] រូបជាអារម្មណ៍នៃចក្ខុសម្ផស្សនោះ តើដូចម្តេច ។ រូបាយតនៈ នេះរូបជាអារម្មណ៍នៃចក្ខុសម្ផស្ស ។ រូបមិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្សនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្ស ។

[ ៦០ ] រូបជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ រូបាយតនៈ នេះរូបជាអារម្មណ៍នៃចក្ខុវិញ្ញាណ ។ រូបមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណ ។

[ ៦១ ] រូបជាអារម្មណ៍នៃសោតសម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្សនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ

នេះរូបជាអារម្មណ៍នៃកាយសម្ផស្ស រូបមិនមែនជាអារម្មណ៍នៃកាយសម្ផស្ស នោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាអារម្មណ៍នៃកាយសម្ផស្ស ។

[ ៦២ ] រូបជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនា ដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបជាអារម្មណ៍នៃកាយវិញ្ញាណ ។ រូបមិនមែនជាអារម្មណ៍នៃកាយវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាអារម្មណ៍នៃកាយវិញ្ញាណ ។

[ ៦៣ ] រូបជាចក្ខាយតនៈនោះ តើដូចម្តេច ។ ចក្ខុណា គឺប្រសាទអាស្រ័យនូវមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ ។ រូបមិនមែនជាចក្ខាយតនៈនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាចក្ខាយតនៈ ។

[ ៦៤ ] រូបជាសោតាយតនៈ ។បេ។ ជាឃានាយតនៈ ។បេ។ ជាជិវ្ហាយតនៈ ។បេ។ ជាកាយាយតនៈនោះ តើដូចម្តេច ។ កាយណាគឺប្រសាទដែលអាស្រ័យនូវមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបជាកាយាយតនៈ ។ រូបមិនមែនជាកាយាយតនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាកាយាយតនៈ ។

[ ៦៥ ] រូបជារូបាយតនៈនោះ តើដូចម្តេច ។ រូបណា គឺពណ៌ អាស្រ័យនូវមហាភូតទាំង ៤ ។បេ។ ហៅថា រូបធាតុក៏បាន នេះរូបជារូបា-

យតនៈ ។ រូបមិនមែនជារូបាយតនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបាយតនៈ ។

[ ៦៦ ] រូបជាសទ្ទាយតនៈ ។បេ។ ជាគន្ធាយតនៈ ។បេ។ ជារសាយតនៈ ។បេ។ ជាផោដ្ឋព្វាយតនៈនោះ តើដូចម្តេច ។ បឋវីធាតុ ។បេ។ ហៅថា ផោដ្ឋព្វធាតុក៏បាន នេះរូបជាផោដ្ឋព្វាយតនៈ ។ រូបមិនមែនជាផោដ្ឋព្វាយតនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាផោដ្ឋព្វាយតនៈ ។

[ ៦៧ ] រូបជាចក្ខុធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ នេះរូបជាចក្ខុធាតុ ។ រូបមិនមែនជាចក្ខុធាតុនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាចក្ខុធាតុ ។

[ ៦៨ ] រូបជាសោតធាតុ ។បេ។ ជាឃានធាតុ ។បេ។ ជាជិវ្ហាធាតុ ។បេ។ ជាកាយធាតុនោះ តើដូចម្តេច ។ កាយាយតនៈ នេះរូបជាកាយធាតុ ។ រូបមិនមែនជាកាយធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាកាយធាតុ ។

[ ៦៩ ] រូបជារូបធាតុនោះ តើដូចម្តេច ។ រូបាយតនៈ នេះរូបជារូបធាតុ ។ រូបមិនមែនជារូបធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ កពឡិង្ការាហារ នេះរូបមិនមែនជារូបធាតុ ។

[ ៧០ ] រូបជាសទ្ទធាតុ ។បេ។ ជាគន្ធធាតុ ។បេ។ ជារសធាតុ ។បេ។ ជាផោដ្ឋព្វធាតុនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបជាផោដ្ឋព្វធាតុ ។

រូបមិនមែនជាផោដ្ឋព្វធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាផោដ្ឋព្វធាតុ ។

[ ៧១ ] រូបជាចក្ខុន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខុណា គឺប្រសាទ ដែលអាស្រ័យមហាភូត ៤ ។បេ។ ហៅថាស្រុកទំនេរក៏បាន នេះរូបជាចក្ខុន្ទ្រិយ ។ រូបមិនមែនជាចក្ខុន្ទ្រិយនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាចក្ខុន្ទ្រិយ ។

[ ៧២ ] រូបជាសោតិន្ទ្រិយ ។បេ។ ជាឃានិន្ទ្រិយ ។បេ។ ជាជិវ្ហិន្ទ្រិយ ។បេ។ ជាកាយិន្ទ្រិយនោះ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូត ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបជាកាយិន្ទ្រិយ ។ រូបមិនមែនជាកាយិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាកាយិន្ទ្រិយ ។

[ ៧៣ ] រូបជាឥត្ថិន្ទ្រិយនោះ តើដូចម្តេច ។ ទ្រង់ទ្រាយជាស្រី គ្រឿងចំណាំជាស្រី កិរិយាជាស្រី អាការជាស្រី លំនាំជាស្រី ភាពជាស្រីណា របស់ស្រី នេះរូបជាឥត្ថិន្ទ្រិយ ។ រូបមិនមែនជាឥត្ថិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាឥត្ថិន្ទ្រិយ ។

[ ៧៤ ] រូបជាបុរិសិន្ទ្រិយនោះ តើដូចម្តេច ។ ទ្រង់ទ្រាយជាប្រុស គ្រឿងចំណាំជាប្រុស កិរិយាជាប្រុស អាការជាប្រុស លំនាំជាប្រុស ភាពជាប្រុសណារបស់ប្រុស នេះរូបជាបុរិសិន្ទ្រិយ ។ រូបមិនមែនជាបុរិសិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជា

បុរិសិន្ទ្រិយ ។

[ ៧៥ ] រូបជាជីវិតិន្ទ្រិយនោះ តើដូចម្ដេច ។ អាយុ ការឋិតនៅ ការនៅឃើនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវរូបធម៌ទាំងនោះ គឺជីវិត ជីវិតិន្ទ្រិយណា នេះរូបជាជីវិតិន្ទ្រិយ ។ រូបមិនមែនជាជីវិតិន្ទ្រិយនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាជីវិតិន្ទ្រិយ ។

[ ៧៦ ] រូបជាកាយវិញ្ញត្តិនោះ តើដូចម្ដេច ។ ការទប់កាយ ការគាំទ្រកាយ ការទប់ទល់កាយ ការកម្រើកកាយ អាការៈញុំាងកាយឲ្យកម្រើក ភាពនៃការញុំាងកាយឲ្យកម្រើក ណានៃបុគ្គលមានចិត្តជាកុសលក្ដី មានចិត្តជាអកុសលក្ដី មានចិត្តជាអព្យាក្រឹតក្ដី កាលឈានទៅមុខក្ដី កាលឈានថយក្រោយក្ដី កាលសម្លឹងមើលក្ដី កាលក្រឡេកមើលក្ដី កាលបត់ចូលក្ដី កាលលាចេញក្ដី នេះរូបជាកាយវិញ្ញត្តិ ។ រូបមិនមែនជាកាយវិញ្ញត្តិនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាកាយ-វិញ្ញត្តិ ។

[ ៧៧ ] រូបជាវចីវិញ្ញត្តិនោះ តើដូចម្ដេច ។ វាចា ការបន្លឺ គន្លងពាក្យ ការពោល ការគឹកកង កម្មគឺការគឹកកង គឺវាចា វចីភេទណានៃបុគ្គលមានចិត្តជាកុសលក្ដី មានចិត្តជាអកុសលក្ដី មានចិត្តជាអព្យាក្រឹតក្ដី នេះលោកហៅថា វាចា បានដល់ ការកម្រើកសម្ដី ការញុំាងសម្ដីឲ្យកម្រើក ភាពនៃការញុំាងសម្ដីឲ្យកម្រើក នេះរូបជាវចីវិញ្ញត្តិ ។ រូបមិនមែនជាវចីវិញ្ញត្តិនោះ

តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កវឡិង្ការាហារ នេះរូបមិនមែនជា វចី-
វិញ្ញត្តិ ។

[ ៧៨ ] រូបជាអាកាសធាតុនោះ តើដូចម្ដេច ។ កន្លែងដែលមិនអាច
ក្ដួរាស់បាន អាកាស ទីឥតទើស ទីអាកាស ទីចន្លោះ វាល ដែលមិនប៉ះ
ពាល់ដោយមហាភូតទាំង ៤ ណា នេះរូបជាអាកាសធាតុ ។ រូបមិនមែនជា
អាកាសធាតុនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះ
រូបមិនមែនជាអាកាសធាតុ ។

[ ៧៩ ] រូបជាអាបោធាតុនោះ តើដូចម្ដេច ។ សភាពជាទឹក ការតាំង
នៅគឺទឹក សភាពសើមជ្រាប ការតាំងនៅគឺសភាពសើមជ្រាប ការតភ្ជាប់នៃ
រូបណា នេះរូបជាអាបោធាតុ ។ រូបមិនមែនជាអាបោធាតុនោះ តើដូចម្ដេច ។
ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាអាបោធាតុ ។

[ ៨០ ] រូបជារូបស្សលហុតានោះ តើដូចម្ដេច ។ ការរហ័សរហួន ការ
ប្រែប្រួលរហ័ស ការមិនយឺតយូរ ការមិនបន្ធន់ណានៃរូប នេះរូបជារូបស្ស-
លហុតា ។ រូបមិនមែនជារូបស្សលហុតានោះ តើដូចម្ដេច ។ ចក្ខា-
យតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបស្សលហុតា ។

[ ៨១ ] រូបជារូបស្សមុទុតានោះ តើដូចម្ដេច ។ ភាពទន់ ភាពទន់ភ្លន់
ភាពមិនរឹង ភាពមិនស្កកស្កឹងណានៃរូប នេះរូបជារូបស្សមុទុតា ។ រូបមិន
មែនជារូបស្សមុទុតានោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ
នេះរូបមិនមែនជារូបស្សមុទុតា ។

[ ៨២ ] រូបជារូបស្សកម្មញ្ញតានោះ តើដូចម្ដេច ។ ភាពគួរដល់ការងារ ការធ្វើការងារបាន ភាពគួរធ្វើការងារបានណានៃរូប នេះរូបជារូបស្សកម្ម-ញ្ញតា ។ រូបមិនមែនជារូបស្សកម្មញ្ញតានោះ តើដូចម្ដេច ។ ចក្ខា-យតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបស្សកម្មញ្ញតា ។

[ ៨៣ ] រូបជារូបស្សឧបចយៈនោះ តើដូចម្ដេច ។ ការសន្សំណានៃពួកអាយតនៈ ការសន្សំនោះ ឈ្មោះថា រូបស្សឧបចយៈ នេះរូបជារូបស្សឧប-ចយៈ ។ រូបមិនមែនជារូបស្សឧបចយៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបស្សឧបចយៈ ។

[ ៨៤ ] រូបជារូបស្សសន្តតិនោះ តើដូចម្ដេច ។ ការសន្សំ ណានៃរូប ការសន្សំនោះ ឈ្មោះថា រូបស្សសន្តតិ នេះរូបជារូបស្សសន្តតិ ។ រូបមិនមែនជារូបស្សសន្តតិនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបស្សសន្តតិ ។

[ ៨៥ ] រូបជារូបស្សជរតានោះ តើដូចម្ដេច ។ ជរា សេចក្ដីគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកយ៉ុរយារ ការថយអាយុ ចាស់ទុំនៃឥន្ទ្រិយ ណានៃរូប នេះរូបជារូបស្សជរតា ។ រូបមិនមែនជារូបស្សជរតានោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបស្សជរតា ។

[ ៨៦ ] រូបជារូបស្សអនិច្ចតានោះ តើដូចម្ដេច ។ ការអស់ទៅ ការវិនាស ការបែកធ្លាយ ការប្រេះធា ការមិនទៀងទាត់ ការបាត់បង់ណានៃរូប នេះរូបជារូបស្សអនិច្ចតា ។ រូបមិនមែនជារូបស្សអនិច្ចតានោះ តើដូចម្ដេច ។

ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជារូបសម្បអនិច្ចតា ។

[ ៨៧ ] រូបជាកពឡិង្ការាហារនោះ តើដូចម្តេច ។ បាយ នំ សដូវ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះរាវ ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅឬក៏រូបណាសូម្បីដទៃ គឺរូបជារបស់សម្រាប់ស៊ីក្នុងមាត់ ទំពាដោយធ្មេញ គប្បីលេបចូលក្នុងបំពង់ក ប្រកក្នុងផ្ទៃនៃពួកសត្វនោះៗ ក្នុងជនបទណាៗ ឬពួកសត្វញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅដោយឱជាណា នេះរូបជាកពឡិង្ការាហារ ។ រូបមិនមែនជាកពឡិង្ការាហារនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ភាពនៃរូបមិនទៀង នេះរូបមិនមែនជាកពឡិង្ការាហារ ។

## ការសង្គ្រោះរូបដោយចំណែក ២ យ៉ាងនេះ ។

## ចប់ ទុកនិទ្ទេស ។

[ ៨៨ ] រូបខាងក្នុងជាឧបាទានោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងជាឧបាទា ។ រូបខាងក្រៅជាឧបាទានោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ ជាឧបាទា ។ រូបខាងក្រៅមិនមែនជាឧបាទានោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈនិងអាបោធាតុ នេះរូបខាងក្រៅមិនមែនជាឧបាទា ។

[ ៨៩ ] រូបខាងក្នុងជាឧបាទិន្នទនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងជាឧបាទិន្ន ។ រូបខាងក្រៅជាឧបាទិន្នទនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូ-

បស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបខាងក្រៅជាឧបាទិន្ន ។ រូបខាងក្រៅជាអនុបាទិន្ននោះ តើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើទេ នេះរូបខាងក្រៅជាអនុបាទិន្ន ។

[ ៩០ ] រូបខាងក្នុង ជាឧបាទិន្នុបាទានិយៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងជាឧបាទិន្នុបាទានិយៈ ។ រូបខាងក្រៅ ជាឧបាទិន្នុបាទានិយៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបខាងក្រៅ ជាឧបាទិន្នុបាទានិយៈ ។ រូបខាងក្រៅជាអនុបាទិន្នុបាទានិយៈនោះ តើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណាគឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្ម ដែលបុគ្គលធ្វើហើយទេ នេះរូបខាងក្រៅជាអនុបាទិន្នុបាទានិយៈ ។

[ ៩១ ] រូបខាងក្នុងជាអនិទស្សនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងជាអនិទស្សនៈ ។ រូបខាងក្រៅជាអនិទស្សនៈនោះ តើដូចម្តេច ។ រូបាយតនៈ នេះរូបខាងក្រៅជាសនិទស្សនៈ ។ រូបខាងក្រៅជាអនិទស្សនៈនោះ តើដូចម្តេច ។ សទ្ទាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅជាអនិទស្សនៈ ។

[ ៩២ ] រូបខាងក្នុងជាសប្បដិឃៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង ជាសប្បដិឃៈ ។ រូបខាងក្រៅជាសប្បដិឃៈនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបខាងក្រៅជាសប្បដិឃៈ ។ រូបខាងក្រៅជាអប្បដិឃៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅជាអប្បដិឃៈ ។

[ ៩៣ ] រូបខាងក្នុងជាឥន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខុន្ទ្រិយ ។បេ។ កាយិន្ទ្រិយ នេះរូបខាងក្នុងជាឥន្ទ្រិយ ។ រូបខាងក្រៅជាឥន្ទ្រិយនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ នេះរូបខាងក្រៅជាឥន្ទ្រិយ ។ រូបខាងក្រៅ មិនមែនជាឥន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាឥន្ទ្រិយ ។

[ ៩៤ ] រូបខាងក្នុង មិនមែនជាមហាភូតនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាមហាភូត ។ រូបខាងក្រៅជាមហាភូតនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ នេះរូបខាងក្រៅជាមហាភូត ។ រូបខាងក្រៅមិនមែនជាមហាភូតនោះ តើដូចម្តេច ។

រូបាយតនៈ ។បេ។ កពឡីង្ការាហារ នេះរូបខាងក្រៅមិនមែនជាមហាភូត ។

[ ៩៥ ] រូបខាងក្នុងមិនមែនជាវិញ្ញត្តិនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាវិញ្ញត្តិ ។ រូបខាងក្រៅជាវិញ្ញត្តិនោះ តើដូចម្ដេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះរូបខាងក្រៅជាវិញ្ញត្តិ ។ រូបខាងក្រៅមិនមែនជាវិញ្ញត្តិនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡីង្ការាហារ នេះរូបខាងក្រៅមិនមែនជាវិញ្ញត្តិ ។

[ ៩៦ ] រូបខាងក្នុងមិនមែនជាចិត្តសមុដ្ឋាននោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាចិត្តសមុដ្ឋាន ។ រូបខាងក្រៅ ជាចិត្តសមុដ្ឋាននោះ តើដូចម្ដេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ ឬក៏រូបដទៃណា គឺរូបកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន ឬរូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្សសន្តតិ កពឡីង្ការាហារ នេះរូបខាងក្រៅជាចិត្តសមុដ្ឋាន ។ រូបខាងក្រៅមិនមែនជាចិត្តសមុដ្ឋាននោះ តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបមិនមែនកើតអំពីចិត្ត មិនមែនមានចិត្តជាហេតុ មិនមែនមានចិត្តជាសមុដ្ឋាន ឬរូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សឧបចយៈ រូបស្សសន្តតិ កពឡីង្ការាហារ នេះរូបខាងក្រៅមិនមែនជាចិត្ត-

សមុដ្ឋាន ។

[ ៩៧ ] រូបខាងក្នុង មិនមែនជាចិត្តសហភូនោះ តើដូចម្ដេច ។ ចក្ខា-យតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាចិត្តសហភូ ។ រូបខាងក្រៅជាចិត្តសហភូនោះ តើដូចម្ដេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះរូបខាងក្រៅជាចិត្តសហភូ ។ រូបខាងក្រៅ មិនមែនជាចិត្តសហភូនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាចិត្តសហភូ ។

[ ៩៨ ] រូបខាងក្នុងមិនមែនជាចិត្តានុបរិវត្តិនោះ តើដូចម្ដេច ។ ចក្ខា-យតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាចិត្តានុបរិវត្តិ ។ រូបខាងក្រៅជាចិត្តានុបរិវត្តិនោះ តើដូចម្ដេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះរូបខាងក្រៅ ជាចិត្តានុបរិវត្តិ ។ រូបខាងក្រៅ មិនមែនជាចិត្តានុបរិវត្តិនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាចិត្តានុបរិវត្តិ ។

[ ៩៩ ] រូបខាងក្នុងជាឱឡារិកៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងជាឱឡារិកៈ ។ រូបខាងក្រៅ ជាឱឡារិកៈនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបខាងក្រៅជាឱឡា-រិកៈ ។ រូបខាងក្រៅជាសុខុមៈនោះ តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ ។បេ។ កព-ឡិង្ការាហារ នេះរូបខាងក្រៅជាសុខុមៈ ។

[ ១០០ ] រូបខាងក្នុងជាសន្តិកេរូបនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។

កាយាយតនៈ នេះរូបខាងក្នុងជាសន្តិកេរូប ។ រូបខាងក្រៅជាទូរេរូបនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅជាទូរេ-រូប ។ រូបខាងក្រៅ ជាសន្តិកេរូបនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបខាងក្រៅជាសន្តិកេរូប ។

[ ១០១ ] រូបខាងក្រៅមិនមែនជាវត្ថុនៃចក្ខុសម្ផស្សនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាវត្ថុនៃចក្ខុ-សម្ផស្ស ។ រូបខាងក្នុងជាវត្ថុនៃចក្ខុសម្ផស្សនោះ តើដូចម្តេច ។ ចក្ខាយតនៈ នេះរូបខាងក្នុង ជាវត្ថុនៃចក្ខុសម្ផស្ស ។ រូបខាងក្នុង មិនមែនជាវត្ថុនៃចក្ខុ-សម្ផស្សនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កាយាយតនៈ នេះរូប ខាងក្នុង មិនមែនជាវត្ថុនៃចក្ខុសម្ផស្ស ។

[ ១០២ ] រូបខាងក្រៅមិនមែនជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជា វត្ថុនៃចក្ខុ-វិញ្ញាណ ។ រូបខាងក្នុងជាវត្ថុនៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ នេះរូបខាងក្នុង ជាវត្ថុនៃចក្ខុវិញ្ញាណ ។បេ។ រូបខាងក្នុង មិនមែនជាវត្ថុនៃ ចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កាយាយាតនៈ នេះ រូបខាងក្នុងមិនមែនជាវត្ថុនៃចក្ខុវិញ្ញាណ ។

[ ១០៣ ] រូបខាងក្រៅមិនមែនជាវត្ថុនៃសោតសម្ផស្ស ។បេ។ នៃឃាន-សម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្សនោះ តើដូច

ម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាវត្ថុនៃកាយសម្ផស្ស ។ រូបខាងក្នុង ជាវត្ថុនៃកាយសម្ផស្សនោះ តើដូចម្ដេច ។ កាយាយតនៈ នេះរូបខាងក្នុងជាវត្ថុនៃកាយសម្ផស្ស ។ រូបខាងក្នុង មិនមែនជាវត្ថុនៃកាយសម្ផស្សនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ ជិវ្ហាយតនៈ នេះរូបខាងក្នុងមិនមែនជាវត្ថុនៃកាយសម្ផស្ស ។

[ ១០៤ ] រូបខាងក្រៅមិនមែនជាវត្ថុនៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាវត្ថុនៃកាយវិញ្ញាណ ។ រូបខាងក្នុង ជាវត្ថុនៃកាយវិញ្ញាណនោះ តើដូចម្ដេច ។ កាយាយតនៈ នេះរូបខាងក្នុងជាវត្ថុនៃកាយវិញ្ញាណ ។ រូបខាងក្នុងមិនមែនជាវត្ថុនៃកាយវិញ្ញាណនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ ជិវ្ហាយតនៈ នេះរូបខាងក្នុងមិនមែនជាវត្ថុនៃកាយវិញ្ញាណ ។

[ ១០៥ ] រូបខាងក្នុង មិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្សនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្ស ។ រូបខាងក្រៅជាអារម្មណ៍នៃចក្ខុសម្ផស្សនោះ តើដូចម្ដេច ។ រូបាយតនៈ នេះរូបខាងក្រៅជាអារម្មណ៍នៃចក្ខុសម្ផស្ស ។ រូបខាងក្រៅ មិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្សនោះ តើដូចម្ដេច ។ សទ្ទាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាអារម្មណ៍នៃចក្ខុសម្ផស្ស ។

[ ១០៦ ] រូបខាងក្នុងមិនមែនជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីចក្ខុសម្ផស្ស ។បេ។ នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណ ។ រូបខាងក្រៅ ជាអារម្មណ៍នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ រូបាយតនៈ នេះរូបខាងក្រៅជាអារម្មណ៍នៃចក្ខុវិញ្ញាណ ។ រូបខាងក្រៅមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណនោះ តើដូចម្តេច ។ សទ្ទាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាអារម្មណ៍នៃចក្ខុវិញ្ញាណ ។

[ ១០៧ ] រូបខាងក្នុង មិនមែនជាអារម្មណ៍នៃសោតសម្ផស្ស ។បេ។ នៃឃានសម្ផស្ស ។បេ។ នៃជិវ្ហាសម្ផស្ស ។បេ។ នៃកាយសម្ផស្សនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាអារម្មណ៍នៃកាយសម្ផស្ស ។ រូបខាងក្រៅជាអារម្មណ៍នៃកាយសម្ផស្សនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបខាងក្រៅជាអារម្មណ៍នៃកាយសម្ផស្ស ។ រូបជាខាងក្រៅ មិនមែនជាអារម្មណ៍នៃកាយសម្ផស្សនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាអារម្មណ៍នៃកាយសម្ផស្ស ។

[ ១០៨ ] រូបខាងក្នុងមិនមែនជាអារម្មណ៍នៃវេទនា ។បេ។ នៃសញ្ញា ។បេ។ នៃចេតនាដែលកើតអំពីកាយសម្ផស្ស ។បេ។ នៃកាយវិញ្ញាណនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាអារម្មណ៍នៃកាយវិញ្ញាណ ។ រូបខាងក្រៅជាអារម្មណ៍នៃកាយវិញ្ញាណនោះ តើ

ដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបខាងក្រៅជាអារម្មណ៍នៃកាយវិញ្ញាណ ។ រូបខាងក្រៅ មិនមែនជាអារម្មណ៍នៃកាយវិញ្ញាណនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាអារម្មណ៍នៃកាយវិញ្ញាណ ។

[ ១០៩ ] រូបខាងក្រៅមិនមែនជាចក្ខាយតនៈនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាចក្ខាយតនៈ ។ រូបខាងក្នុងជាចក្ខាយតនៈនោះ តើដូចម្តេច ។ ចក្ខុណាគឺប្រសាទ អាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបខាងក្នុង ជាចក្ខាយតនៈ ។ រូបខាងក្នុង មិនមែនជាចក្ខាយតនៈនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាចក្ខាយតនៈ ។

[ ១១០ ] រូបខាងក្រៅ មិនមែនជាសោតាយតនៈ ។បេ។ មិនមែនជាឃានាយតនៈ ។បេ។ មិនមែនជាជិវ្ហាយតនៈ ។បេ។ មិនមែនជាកាយាយតនៈនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាកាយាយតនៈ ។ រូបខាងក្នុងជាកាយាយតនៈនោះ តើដូចម្តេច ។ កាយណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថាស្រុកទំនេរក៏បាន នេះរូបខាងក្នុង ជាកាយាយតនៈ ។ រូបខាងក្នុង មិនមែនជាកាយាយតនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ជិវ្ហាយតនៈ នេះរូបខាងក្នុងមិនមែនជាកាយាយតនៈ ។

[ ១១១ ] រូបខាងក្នុង មិនមែនជារូបាយតនៈនោះ តើដូចម្តេច ។ ចក្ខា-

យតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជារូបាយតនៈ ។ រូបខាងក្រៅជារូបាយតនៈនោះ តើដូចម្ដេច ។ រូបណាគឺពណ៌និងរស្មី អាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា រូបធាតុក៏បាន នេះរូបខាងក្រៅ ជារូបាយតនៈ ។ រូបខាងក្រៅ មិនមែនជារូបាតនៈនោះ តើដូចម្ដេច ។ សទ្ទាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបាយតនៈ ។

[ ១១២ ] រូបខាងក្នុង មិនមែនជាសទ្ទាយតនៈ ។បេ។ មិនមែនជាគន្ធាយតនៈ ។បេ។ មិនមែនជារសាយតនៈ ។បេ។ មិនមែនជាផោដ្ឋព្វាយតនៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាផោដ្ឋព្វាយតនៈ ។ រូបខាងក្រៅជាផោដ្ឋព្វាយតនៈនោះ តើដូចម្ដេច ។ បឋវីធាតុ ។បេ។ ហៅថាផោដ្ឋព្វធាតុក៏បាន នេះរូបខាងក្រៅជាផោដ្ឋព្វាយតនៈ ។ រូបខាងក្រៅមិនមែនជាផោដ្ឋព្វាតនៈនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាផោដ្ឋព្វាយតនៈ ។

[ ១១៣ ] រូបខាងក្រៅមិនមែនជាចក្ខុធាតុនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាចក្ខុធាតុ ។ រូបខាងក្នុងជាចក្ខុធាតុនោះ តើដូចម្ដេច ។ ចក្ខាយតនៈ នេះរូបខាងក្នុងជាចក្ខុធាតុ ។ រូបខាងក្នុង មិនមែនជាចក្ខុធាតុនោះ តើដូចម្ដេច ។ សោតាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាចក្ខុធាតុ ។

[ ១១៤ ] រូបខាងក្រៅមិនមែនជាសោតធាតុ ។បេ។ មិនមែនជាឃានធាតុ ។បេ។ មិនមែនជាជិវ្ហាធាតុ ។បេ។ មិនមែនជាកាយធាតុនោះ តើដូច

ម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាកាយធាតុ ។ រូបខាងក្នុងជាកាយធាតុនោះ តើដូចម្តេច ។ កាយាយតនៈ នេះ រូបខាងក្នុងជាកាយធាតុ ។ រូបខាងក្នុងមិនមែនកាយធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ជិវ្ហាយតនៈ នេះរូបខាងក្នុងមិនមែនជាកាយធាតុ ។

[ ១១៥ ] រូបខាងក្នុង មិនមែនជារូបធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជារូបធាតុ ។ រូបខាងក្រៅជារូបធាតុនោះ តើដូចម្តេច ។ រូបាយតនៈ នេះរូបខាងក្រៅជារូបធាតុ ។ រូបខាងក្រៅ មិនមែនជារូបធាតុនោះ តើដូចម្តេច ។ សទ្ទាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបធាតុ ។

[ ១១៦ ] រូបខាងក្នុងមិនមែនជាសទ្ទធាតុ ។បេ។ មិនមែនជាគន្ធធាតុ ។បេ។ មិនមែនជារសធាតុ ។បេ។ មិនមែនជាផោដ្ឋព្វធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជាផោដ្ឋព្វធាតុ ។ រូបខាងក្រៅជាផោដ្ឋព្វធាតុនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបខាងក្រៅជាផោដ្ឋព្វធាតុ ។ រូបខាងក្រៅមិនមែនជាផោដ្ឋព្វធាតុនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាផោដ្ឋព្វធាតុ ។

[ ១១៧ ] រូបខាងក្រៅ មិនមែនជាចក្ខុន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាចក្ខុន្ទ្រិយ ។ រូប

ខាងក្នុង ជាចក្ខុន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខុណា គឺប្រសាទ អាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបខាងក្នុងជាចក្ខុន្ទ្រិយ ។ រូបខាងក្នុងមិនមែនជាចក្ខុន្ទ្រិយនោះ តើដូចម្តេច ។ សោតាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាចក្ខុន្ទ្រិយ ។

[ ១១៨ ] រូបខាងក្រៅមិនមែនជាសោតិន្ទ្រិយ ។បេ។ មិនមែនជាឃានិន្ទ្រិយ មិនមែនជាជិវ្ហិន្ទ្រិយ ។បេ។ មិនមែនជាកាយិន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាកាយិន្ទ្រិយ ។ រូបខាងក្នុងជាកាយិន្ទ្រិយនោះ តើដូចម្តេច ។ កាយណាគឺប្រសាទ អាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបខាងក្នុងជាកាយិន្ទ្រិយ ។ រូបខាងក្នុងមិនមែនជាកាយិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ជិវ្ហាយតនៈ នេះរូបខាងក្នុងមិនមែនជាកាយិន្ទ្រិយ ។

[ ១១៩ ] រូបខាងក្នុង មិនមែនជាឥត្ថិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាឥត្ថិន្ទ្រិយ ។ រូបខាងក្រៅជាឥត្ថិន្ទ្រិយនោះ តើដូចម្តេច ។ ទ្រង់ទ្រាយជាស្ត្រី គ្រឿងចំណាំជាស្ត្រី កិរិយាជាស្ត្រី អាការជាស្ត្រី លំនាំជាស្ត្រី ភាពជាស្ត្រីណារបស់ស្ត្រី នេះរូបខាងក្រៅជាឥត្ថិន្ទ្រិយ ។ រូបខាងក្រៅមិនមែនជាឥត្ថិន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជាឥត្ថិន្ទ្រិយ ។

[ ១២០ ] រូបខាងក្នុងមិនមែនជាបុរិសិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខា-

យតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាបុរិសិន្ទ្រិយ ។ រូបខាងក្រៅ ជាបុរិសិន្ទ្រិយនោះ តើដូចម្តេច ។ ទ្រង់ទ្រាយជាបុរស គ្រឿងចំណាំជាបុរស កិរិយាជាបុរស អាការជាបុរស លំនាំជាបុរស ភាពជាបុរសណារបស់បុរស នេះរូបខាងក្រៅជាបុរិសិន្ទ្រិយ ។ រូបខាងក្រៅមិនមែនជាបុរិសិន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាបុរិសិន្ទ្រិយ ។

[ ១២១ ] រូបខាងក្នុងមិនមែនជាជីវិតិន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាជីវិតិន្ទ្រិយ ។ រូបខាងក្រៅ ជាជីវិតិន្ទ្រិយនោះ តើដូចម្តេច ។ អាយុ ការឋិតនៅ ការនៅយឺនយូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សា គឺជីវិត ជីវិតិន្ទ្រិយណានៃរូបធម៌ទាំងនោះ នេះរូបខាងក្រៅជាជីវិតិន្ទ្រិយ ។ រូបខាងក្រៅមិនមែនជាជីវិតិន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាជីវិតិន្ទ្រិយ ។

[ ១២២ ] រូបខាងក្នុងមិនមែនជាកាយវិញ្ញត្តិនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាកាយវិញ្ញត្តិ ។ រូបខាងក្រៅជាកាយវិញ្ញត្តិនោះ តើដូចម្តេច ។ ការទប់កាយ ការគ្រាំទ្រកាយ ការទប់ទល់កាយ ការកម្រើកកាយ អាការញុំាងកាយឲ្យកម្រើក ភាពនៃការញុំាងកាយ ឲ្យកម្រើកណានៃបុគ្គលមានចិត្តជាកុសលក្តី មានចិត្តជាអកុសលក្តី មានចិត្តជាអព្យាក្រឹតក្តី កាលឈានទៅមុខក្តី កាលឈានថយ

ក្រោយក្តី កាលសម្លឹងមើលក្តី កាលក្រឡេកមើលក្តី កាលបត់ចូលក្តី កាលលាចេញក្តី នេះរូបខាងក្រៅជាកាយវិញ្ញត្តិ ។ រូបខាងក្រៅមិនមែនជាកាយ-វិញ្ញត្តិ នោះតើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាកាយវិញ្ញត្តិ ។

[ ១២៣ ] រូបខាងក្នុងមិនមែនជាវចីវិញ្ញត្តិនោះ តើដូចម្តេច ។ ចក្ខា-យតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជាវចីវិញ្ញត្តិ ។ រូបខាងក្រៅ ជាវចីវិញ្ញត្តិនោះ តើដូចម្តេច ។ វាចា សម្តី គន្លងពាក្យ ការពោល ការតឹកកង កម្មតឹការតឹកកង វាចា វចីភេទណានៃបុគ្គលមានចិត្តជាកុសលក្តី មានចិត្តជាអកុសលក្តី មានចិត្តជាអព្យាក្រឹតក្តី នេះហៅថា វាចាបានដល់ ការកម្រើកសម្តី ការញុំាងសម្តីឲ្យកម្រើក ភាពនៃការញុំាងសម្តីឲ្យកម្រើក នេះរូបខាងក្រៅជាវចីវិញ្ញត្តិ ។ រូបខាងក្រៅមិនមែនជាវចីវិញ្ញត្តិនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាវចីវិញ្ញត្តិ ។

[ ១២៤ ] រូបខាងក្នុង មិនមែនជាអាកាសធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាអាកាសធាតុ ។ រូបខាងក្រៅជាអាកាសធាតុនោះ តើដូចម្តេច ។ កន្លែងណាដែលមិនអាចក្ដួរាស់បាន អាកាស ទីឥតទើស ទីអាកាស ទីចន្លោះ វាលមិនប៉ះពាល់ដោយមហាភូតទាំង ៤ នេះរូបខាងក្រៅ ជាអាកាសធាតុ ។ រូបខាងក្រៅមិនមែនជាអាកាសធាតុនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ

នេះរូបខាងក្រៅមិនមែនជាអាកាសធាតុ ។

[ ១២៥ ] រូបខាងក្នុង មិនមែនជាអាបោធាតុនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាអាបោធាតុ ។ រូបខាងក្រៅជាអាបោធាតុនោះ តើដូចម្តេច ។ សភាពជាទឹក ការតាំងនៅគឺទឹក សភាពដែលសើបជ្រាប ការតាំងនៅ គឺសភាពសើបជ្រាប ការភ្ជាប់នៃរូបណា នេះរូបខាងក្រៅជាអាបោធាតុ ។ រូបខាងក្រៅ មិនមែនជាអាបោធាតុនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជាអាបោធាតុ ។

[ ១២៦ ] រូបខាងក្នុង មិនមែនជារូបស្រាលហុតានោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជារូបស្រាលហុតា ។ រូបខាងក្រៅជារូបស្រាលហុតានោះ តើដូចម្តេច ។ ការរហ័សរហួន ការប្រែប្រួលរហ័ស ការមិនយឺតយូរ ការមិនបង្អង់នៅណានៃរូប នេះរូបខាងក្រៅជារូបស្រាលហុតា ។ រូបខាងក្រៅ មិនមែនជារូបស្រាលហុតានោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅ មិនមែនជារូបស្រាលហុតា ។

[ ១២៧ ] រូបខាងក្នុង មិនមែនជារូបស្រមុទុតានោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជារូបស្រមុទុតា ។ រូបខាងក្រៅជារូបស្រមុទុតានោះ តើដូចម្តេច ។ ភាពទន់ ភាពទន់ភ្លន់ ភាពមិនរឹង ភាពមិនស្លូកស្លឹងណានៃរូប នេះរូបខាងក្រៅ ជារូបស្រមុទុតា ។

រូបខាងក្រៅមិនមែនជារូបស្សមុទុតានោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការហារ នេះរូបខាងក្រៅមិនមែនជារូបស្សមុទុតា ។

[ ១២៨ ] រូបខាងក្នុង មិនមែនជារូបស្សកម្មញ្ញតានោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជារូបស្សកម្មញ្ញតា ។ រូបខាងក្រៅជារូបស្សកម្មញ្ញតានោះ តើដូចម្ដេច ។ ភាពគួរដល់ការងារ ការធ្វើការងារបាន ភាពគួរធ្វើការងារបានណានៃរូប នេះរូបខាងក្រៅជារូបស្សកម្មញ្ញតា ។ រូបខាងក្រៅមិនមែនជារូបស្សកម្មញ្ញតានោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបស្សកម្មញ្ញតា ។

[ ១២៩ ] រូបខាងក្នុង មិនមែនជារូបស្សឧបចយៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជារូបស្សឧបចយៈ ។ រូបខាងក្រៅជារូបស្សឧបចយៈនោះ តើដូចម្ដេច ។ ការសន្សំណានៃពួកអាយតនៈ នោះឈ្មោះថា ការសន្សំនៃរូប នេះរូបខាងក្រៅជារូបស្សឧបចយៈ ។ រូបខាងក្រៅ មិនមែនជារូបស្សឧបចយៈនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបស្សឧបចយៈ ។

[ ១៣០ ] រូបខាងក្នុងមិនមែនជារូបស្សសន្តតិនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជារូបស្សសន្តតិ ។ រូបខាងក្រៅ ជារូបស្សសន្តតិនោះ តើដូចម្ដេច ។ ការសន្សំណានៃរូបនោះ

ឈ្មោះថា តំណនៃរូប នេះរូបខាងក្រៅជារូបសន្តតិ ។ រូបខាងក្រៅមិនមែនជារូបសន្តតិនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបសន្តតិ ។

[ ១៣១ ] រូបខាងក្នុង មិនមែនជារូបជរតានោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជារូបជរតា ។ រូបខាងក្រៅជារូបជរតានោះ តើដូចម្តេច ។ ជរា ការគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកយុរយារ ការថយអាយុ ចាស់ទុំនៃឥន្ទ្រិយណានៃរូប នេះរូបខាងក្រៅជារូបជរតា ។ រូបខាងក្រៅមិនមែនជារូបជរតានោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបជរតា ។

[ ១៣២ ] រូបខាងក្នុង មិនមែនជារូបអនិច្ចតានោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុង មិនមែនជារូបអនិច្ចតា ។ រូបខាងក្រៅជារូបអនិច្ចតានោះ តើដូចម្តេច ។ ការអស់ ការវិនាស ការបែកធ្លាយ ការប្រេះឆា ការមិនទៀងទាត់ ការបាត់បង់ណានៃរូប នេះរូបខាងក្រៅ ជារូបអនិច្ចតា ។ រូបខាងក្រៅមិនមែនជារូបអនិច្ចតានោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបខាងក្រៅមិនមែនជារូបអនិច្ចតា ។

[ ១៣៣ ] រូបខាងក្នុង មិនមែនជាកពឡិង្ការាហារនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ នេះរូបខាងក្នុងមិនមែនជាកពឡិង្ការាហារ ។

រូបខាងក្រៅជាកពឡិង្ការាហារនោះ តើដូចម្ដេច ។ បាយ នំ សដូវ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ឬក៏រូបដទៃណាក្នុងជនបទណាៗដែលជាភោជន គេគប្បីស៊ីដោយមាត់ ទំពាស៊ីដោយធ្មេញ លេបចូលក្នុងបំពង់កសម្រាប់ចំអែតផ្ទៃរបស់ពួកសត្វនោះៗ ពួកសត្វរមែងរស់នៅដោយឱជាណា នេះរូបខាងក្រៅ ជាកពឡិង្ការាហារ ។ រូបខាងក្រៅមិនមែនជាកពឡិង្ការាហារនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ រូបស្សអនិច្ចតា នេះរូបខាងក្រៅមិនមែនជាកពឡិង្ការាហារ ។

**ការសង្គ្រោះរូបដោយប្រការ ៣ យ៉ាងនេះឯង ។**

**ចប់ តិកនិទ្ទេស ។**

## អដ្ឋកថា
## អធិប្បាយ ទុកនិទ្ទេសជាដើម

[ ១៥ ] ឥឡូវនេះ កាលទ្រង់សម្តែងចែកបទសំណួរដែលជាបទផ្តើម ដោយសភាវៈដែលផ្សេងគ្នា ក្នុងការសង្រ្គោះរូបពួក ២ ជាដើមយ៉ាងនេះថា **អត្ថិ រូបំ ឧបាទា អត្ថិ រូបំ នោ ឧបាទា** ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា **កតមំ តំ រូបំ ឧបាទា** ដូច្នេះ ។ ក្នុងព្រះបាលីនោះ រូបដែលឈ្មោះថា **ឧបាទា** ព្រោះអត្ថថា អាស្រ័យ អធិប្បាយថា ឧបាទារូបនោះ កាន់យកមហាភូតរូបនោះមិនលែង គឺអាស្រ័យមហាភូតរូបនោះប្រព្រឹត្តទៅ ។

[ ១៦ ] ឥឡូវនេះ កាលនឹងសម្តែងរូបនោះដោយប្រភេទផ្សេងៗទើបត្រាស់ពាក្យជាដើមថា **ចក្ខាយតនំ** ដូច្នេះ ។ ព្រះមានព្រះភាគកាលលើកឧបាទារូបឡើងសម្តែងដោយសង្ខេបថា មាន ២៣ យ៉ាងនេះហើយ កាលទ្រង់អធិប្បាយឧបាទារូបនោះឯង ដោយពិស្តារទៀត ទើបត្រាស់ថា **កតមំ តំ រូបំ ចក្ខាយតនំ** ដូច្នេះជាដើម ។

ក្នុងពាក្យថា **ចក្ខាយតន** នោះ ចក្ខុមាន ២ យ៉ាង គឺ មំសចក្ខុនិងបញ្ញាចក្ខុ ក្នុងចក្ខុទាំងនោះ បញ្ញាចក្ខុមាន ៥ យ៉ាងគឺ ពុទ្ធចក្ខុ ១ សមន្តចក្ខុ ១ ញាណចក្ខុ ១ ទិព្វចក្ខុ ១ ធម្មចក្ខុ ១ ។

បណ្តាបញ្ញាចក្ខុទាំង ៥ នោះ ចក្ខុដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ កាលតថាគត កំពុងប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក ( ខ្វះ ) ។បេ។ ឲ្យត្រាស់ដឹងបានដោយកម្រ ( ខ្វះ ) ដូច្នេះ នេះ

ឈ្មោះថា ពុទ្ធចក្ខុ ។ ចក្ខុដែលត្រាស់ទុក ( ក្នុងខុទ្ទកនិកាយចូឡនិទ្ទេស ) ថា សព្វញ្ញុតញ្ញាណ លោកហៅថា សមន្តចក្ខុ ដូច្នេះ នេះឈ្មោះថា សមន្ត-ចក្ខុ ។ ចក្ខុដែលត្រាស់ទុក ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ចក្ខុកើតឡើង ញាណកើតឡើង ដូច្នេះ នេះឈ្មោះថា ញាណចក្ខុ ។ ចក្ខុដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយតថាគតបានឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ ដូច្នេះ នេះឈ្មោះថា ទិព្វចក្ខុ ។ ញាណ គឺមគ្គ ៣ ខាងក្រោមដែលត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយ មជ្ឈិម-បណ្ណាសក ) ថា ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិលក៏កើតឡើង ( ដល់ឧបាលិគហបតី ) ក្នុងកន្លែងអង្គុយនោះឯង ដូច្នេះ នេះឈ្មោះថា ធម្មចក្ខុ ។

សូម្បីមំសចក្ខុក៏មាន ២ យ៉ាង គឺសសម្ភារចក្ខុ ១ បសាទចក្ខុ ១ ។

បណ្ដាមំសចក្ខុទាំង ២ នោះ ដុំសាច់នេះ តាំងនៅចំពោះក្នុងប្រឡង់ភ្នែកខាងក្រោម កំណត់ដោយឆ្អឹងប្រឡង់ភ្នែក ខាងលើកំណត់ដោយឆ្អឹងចិញ្ចើមខាងទាំងពីរ កំណត់ដោយប្រឡង់ភ្នែក ក្នុងខាងក្នុងកំណត់ដោយខួរក្បាលខាងក្រៅកំណត់ដោយរោមភ្នែក ។ ពោលដោយសង្ខេប ចក្ខុនេះមានចំណែកប្រកប ( សសម្ភារ ) ១៤ គឺធាតុ ៤ វណ្ណៈ គន្ធៈ រសៈ ឱជា សម្ភវៈ ( ទឹកសុក្កៈ ) សណ្ឋាន ជីវិត ភាវៈ កាយបសាទ ចក្ខុបសាទ ។ ពោលដោយពិស្ដារមានសសម្ភារៈ គឺចំណែកប្រកប ៤៤ យ៉ាង ដោយអំណាចនៃរូបទាំង ៤៤ នេះ គឺរូប ១០ នេះ គឺធាតុ ៤ វណ្ណៈ គន្ធៈ រសៈ ឱជា

សណ្ឋាននិងសម្ភារៈដែលអាស្រ័យធាតុ ៤ កើតឡើងរួមជា ៤០ រូប ព្រោះកើតអំពីសមុដ្ឋាន ៤ និងរូបកើតដោយមានកម្មជាសមុដ្ឋានតែម្យ៉ាង ៤ រូប គឺជីវិតៈ ភាវៈ កាយបសាទ ចក្ខុបសាទ ។ សត្វលោក ( ពាលបុថុជ្ជន ) សម្គាល់ដុំសាច់ណា ថាជាភ្នែកពណ៌ស ភ្នែកធំ ភ្នែកបរិសុទ្ធ ភ្នែកទូលាយ រមែងមិនស្គាល់ចក្ខុបសាទ រមែងសម្គាល់វត្ថុថាជាចក្ខុ ។ ដុំសាច់នោះតាំងនៅចំពោះក្នុងប្រឡង់ភ្នែក ដែលសរសៃរួបរឹតទុកជាមួយនឹងខួរក្បាល ។ ដុំសាច់ណា ជាពណ៌សក៏មាន ជាពណ៌ខ្មៅក៏មាន ជាពណ៌ក្រហមក៏មាន ជាបឋវីក៏មាន ជាអាបោក៏មាន ជាតេជោក៏មាន ជាវាយោក៏មាន ។ ដុំសាច់ណា មានពណ៌ស ព្រោះច្រើនដោយស្លេស្ម មានពណ៌ខ្មៅ ព្រោះច្រើនដោយទឹកប្រមាត់ មានពណ៌ក្រហម ព្រោះច្រើនដោយឈាម មានការរឹងព្រោះច្រើនដោយបឋវី មានទឹកភ្នែកហូរចេញ ព្រោះច្រើនដោយអាបោ មានការស្ងួតក្រៀម ព្រោះច្រើនដោយតេជោ មានការកម្រើកបានព្រោះច្រើនដោយវាយោ ដុំសាច់នេះឈ្មោះថា សសម្ភារចក្ខុ ។

ចំណែកបសាទរូបណា អាស្រ័យមហាភូតរូបទាំង ៤ នេះ នៅក្នុងសសម្ភារចក្ខុនេះ ជាប់ទាក់ទងចំពោះក្នុងសសម្ភារចក្ខុនេះ រូបនេះ ឈ្មោះថា បសាទចក្ខុ ចក្ខុបសាទនេះ ជ្រួតជ្រាបរហូតស្រទាប់ភ្នែក ៧ ជាន់ ដូចប្រេងដែលលាបនៅលើប៉ុយគ ៧ ជាន់ ក្នុងរង្វង់ភ្នែកដែលឃើញរូបជាទីកើតឡើងនៃសរីរសណ្ឋានរបស់បុគ្គលទាំងឡាយអ្នកឈរនៅចំពោះមុខ ក្នុងកណ្តាលនៃវង្វង់ភ្នែកពណ៌ខ្មៅ ព័ទ្ធជុំវិញដោយរង្វង់ភ្នែកពណ៌សនៃសសម្ភារចក្ខុនោះ

មានធាតុទាំង ៤ ធ្វើឧបការៈដោយកិច្ចមានការឲ្យទ្រទ្រង់ទុក ឲ្យសើម ឲ្យក្តៅ ឲ្យកម្រើកទៅមកបាន ប្រៀបដូចមេដោះ ៤ នាក់ ធ្វើកិច្ចចិញ្ចឹមបីបាច់ខត្តិយកុមារដោយកិច្ចទាំងឡាយ មានការពរឲ្យស្រេពស្រង់ ឲ្យប្រដាប់តាក់តែងព្រះកាយនិងរង់ចាំបក់ថ្វាយ ដែលឧតុ ចិត្តនិងអាហារឧបត្ថម្ភ ដែលអាយុគឺជីវិតិន្ទ្រិយរង់ចាំអនុបាល ហោមរោមដោយគោចររូប មានវណ្ណៈ គន្ធៈនិងរសៈជាដើម កាលពោលដោយប្រមាណ ចក្ខុបសាទនេះ មានប្រមាណប៉ុនក្បាលចៃ ឲ្យសម្រេចភាពជាវត្ថុនិងទ្វាររបស់វិញ្ញាណទាំងឡាយ មានចក្ខុ-វិញ្ញាណជាដើមតាមសមគួរ ។ សមដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្តពោលទុកថា

> សត្វរមែងឃើញរូបទាំងឡាយ ដោយចក្ខុបសាទណា ចក្ខុ-
> បសាទនេះ តូចល្អិត មានប្រមាណប៉ុនក្បាលចៃ ដូច្នេះ ។

ចក្ខុនោះផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា **ចក្ខា-យតន** បទថា **មហាភូតានំ** ក្នុងបទនេះថា **យំ ចក្ខុ ចតុន្នំ មហាភូតានំ ឧបាទាយ បសាទោ** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ អធិប្បាយថា បសាទរូបអាស្រ័យមហាភូតរូប ៤ ប្រព្រឹត្តទៅ ។ ដោយបទនេះ លោកកាន់យកចក្ខុបសាទប៉ុណ្ណោះ បដិសេធចក្ខុដ៏សេស ។

ចំណែកពាក្យណាដែលត្រាស់ទុកក្នុងឥន្ទ្រិយគោចរសូត្រថា បសាទរូបអាស្រ័យមហាភូតរូបមួយ គឺបឋវីធាតុ សង្គ្រោះបាន ដោយភូតរូប ៣ គឺអាបោធាតុ តេជោធាតុ វាយោធាតុជាដើម និងក្នុងចតុបរិវត្តសូត្រពោលទុក

ថា បសាទរូបអាស្រ័យមហាភូតរូប ២ គឺបឋវីធាតុនិងអាបោធាតុ សង្គ្រោះបានដោយមហាភូតរូប ២ គឺតេជោធាតុនិងវាយោធាតុ ពាក្យនោះត្រាស់ទុកដោយអម ។ ពិតណាស់ សុត្តន្តិកកថានេះជាទេសនាដោយអម ។ ទេសនាក្នុងសុត្តន្តិកកថានេះត្រាស់ទុកដោយបរិយាយនេះថា បសាទរូបណាអាស្រ័យមហាភូតរូប ៤ បសាទរូបនោះ ជាបសាទរូបនៃមហាភូតរូបក្នុងមហាភូតរូបទាំងនោះឯង នីមួយៗម្យ៉ាងខ្លះ នីមួយៗពីរយ៉ាងខ្លះ ដូច្នេះ ។

តែព្រះអភិធម្ម ឈ្មោះថា ទេសនាដោយត្រង់ ព្រោះហេតុនោះ ក្នុងព្រះអភិធម្មនេះ ទើបត្រាស់ថា ប្រសាទអាស្រ័យមហាភូតទាំង ៤ ដូច្នេះ ។

សរីរៈក្តី ខន្ធបញ្ចកៈក្តី ហៅថា អត្តភាព ព្រោះបុគ្គលពាលកំណត់កាន់យកថា នេះជាអត្តារបស់អញ ចក្ខុដែលទាក់ទងក្នុងអត្តភាពនោះ ដែលអាស្រ័យអត្តភាពនោះ ឈ្មោះថា **អត្តភាវបរិយាបន្នោ** រាប់ចូលក្នុងអត្តភាព ។ ដែលឈ្មោះថា **អនិទស្សនោ** ព្រោះអត្ថថា មិនអាចឃើញបានដោយចក្ខុវិញ្ញាណ ។ ដែលឈ្មោះថា **សប្បដិឃោ** ព្រោះអត្ថថា ការប៉ះខ្ទប់ ការជ្រៀតបៀត រមែងកើតក្នុងបសាទនេះ ។

ក្នុងពាក្យទាំងឡាយ មានពាក្យថា **យេន** ជាដើម មានសេចក្តីដោយសង្ខេបដូចតទៅនេះថា សត្វនេះឃើញរូបមានប្រការដូចពោលមកហើយនេះក្នុងអតីត ឬកំពុងឃើញក្នុងបច្ចុប្បន្ន ឬនឹងឃើញក្នុងអនាគតដោយចក្ខុណាដែលជាហេតុ បើចក្ខុរបស់សត្វនោះ នៅមិនទាន់បែកធ្លាយទៅ ពេលនោះគេក៏គប្បីឃើញរូបដែលមកកាន់គន្លងបានដោយចក្ខុនេះ ឬបានឃើញរូបអតីត

ដោយចក្ខុដែលជាអតីត ឃើញរូបបច្ចុប្បន្នដោយចក្ខុដែលជាបច្ចុប្បន្ន ឬនឹងឃើញរូបអនាគត ដោយចក្ខុដែលជាអនាគត ។ ក្នុងអធិការនេះ មានការកំណត់ដូច្នេះថា បើរូបនោះគប្បីមកកាន់គន្លងនៃចក្ខុសោត សត្វនោះក៏គប្បីឃើញរូបនោះបានដោយចក្ខុ ដូច្នេះ ។

បទថា **ចក្ខុំបេតំ** ដោយអត្ថថា ជាអ្នកនាំទៅក្នុងការឃើញ ។ នេះហៅថា **ចក្ខាយតនំបេតំ** ដោយអត្ថថា ជាដែនកើត និងជាទីប្រជុំនៃធម៌ មានផស្សៈជាដើម ។ នេះហៅថា **ចក្ខុធាតុបេសា** ដោយអត្ថថា ទទេ ជាសភាវៈនិងមិនមែនសត្វ ។ នេះហៅថា **ចក្ខុន្ទ្រិយំបេតំ** ព្រោះអត្ថថា គ្រប់គ្រងភាពជាធំក្នុងលក្ខណៈនៃការឃើញ ។ នេះហៅថា **លោកោបេសោ** ព្រោះអត្ថថា វិនាស ។ នេះហៅថា **ទ្វារាបេសា** ព្រោះអត្ថថា សម្រាប់ប្រើប្រាស់ ។ នេះហៅថា **សមុទ្ទោបេសោ** ព្រោះអត្ថថា ឲ្យពេញបានដោយកម្រ ។ នេះហៅថា **បណ្ឌរំបេតំ** ព្រោះអត្ថថា បរិសុទ្ធិ ។ នេះហៅថា **ខេត្តំបេតំ** ព្រោះអត្ថថា ជាទីកើតចំពោះនៃធម៌ មានផស្សៈជាដើម ។ នេះហៅថា **វត្ថុំបេតំ** ព្រោះអត្ថថា ជាទីអាស្រ័យនៃធម៌ មានផស្សៈជាដើម ទាំងនោះឯង ។ នេះហៅថា **នេត្តំបេតំ** ព្រោះអត្ថថា សម្ដែងផ្លូវដែលស្មើនិងមិនស្មើ នាំអត្តភាពទៅ ។ នេះហៅថា **នយនំបេតំ** ព្រោះអត្ថនោះដូចគ្នា ។ នេះហៅថា **ឱរិមំតីរំបេតំ** ព្រោះអត្ថថា រាប់បញ្ចូលក្នុងកាយរបស់ខ្លួន ។ និងរូបនេះហៅថា **សុញ្ញោ គាមោបេសោ** ព្រោះអត្ថថា ជាទីសាធារណៈ ដល់សត្វជាច្រើន និងព្រោះអត្ថថា មិនមានម្ចាស់ ដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណោះ បណ្ឌិតគប្បីប្រកបឈ្មោះ ១៤ យ៉ាង មានពាក្យថា **ចក្ខុំបេតំ** ជាដើម ដោយបទ ៤ បទ មានបទថា **បស្សិ វា** ជាដើម ហើយគប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់ន័យជាគ្រឿងកំណត់ ៤ របស់ចក្ខាយតនៈទុក ។ គប្បីជ្រាបយ៉ាងដូចម្ដេច ក្នុងសេចក្ដីនេះ គប្បីជ្រាបន័យមួយដូច្នេះថា សត្វនេះឃើញហើយនូវរូបដែលជារបស់ឃើញបាន និងប៉ះខ្ទប់បានដោយចក្ខុណា ដែលជារបស់ឃើញមិនបាន តែប៉ះខ្ទប់បាន នេះហៅថា ចក្ខុខ្លះ ។បេ។ ស្រុកទំនេរខ្លះ រូបទាំងនេះហៅថា ចក្ខាយតនៈ ។ សូម្បីន័យដ៏សេសក៏គប្បីជ្រាបយ៉ាងនេះ ។

ឥឡូវនេះព្រោះក្នុងវេលាដែលមានផ្ទេកបន្ទោរជាដើម សូម្បីបុគ្គលដែលមិនត្រូវការមើល រូបក៏រមែងប៉ះខ្ទប់ចក្ខុបសាទបាន ហេតុនោះ ព្រះអង្គទ្រង់បំណងនឹងប្រកាសអាការៈនោះ ទើបផ្ដើមនិទ្ទេសវារៈ ( ទីពីរតទៅ ) ។

បណ្ដាបទទាំងនោះ បទថា **យម្ហិ** បានដល់ ត្រង់ចក្ខុណាដែលជាហេតុ ។ បទថា **រូបំ** នោះ ជាបឋមាវិភត្តិ ។ បណ្ដាបទទាំងនោះ បទថា **បដិហញ្ញិ វា** ជាសេចក្ដីអតីត ។ បទថា **បដិហញ្ញតិ វា** ជាសេចក្ដីបច្ចុប្បន្ន ។ បទថា **បដិហញ្ញិស្សតិ វា** ជាសេចក្ដីអនាគត ។ បទថា **បដិហញ្ញេ វា** ជាសេចក្ដីកំណត់ ។

ពិតណាស់ រូបអតីត ឈ្មោះថា ប៉ះខ្ទប់ហើយត្រង់ចក្ខុដែលជាអតីត ។ រូបបច្ចុប្បន្ន ឈ្មោះថា ប៉ះខ្ទប់ត្រង់ចក្ខុដែលជាបច្ចុប្បន្ន ។ រូបអនាគតឈ្មោះថា នឹងប៉ះខ្ទប់ត្រង់ចក្ខុដែលជាអនាគត ។ ក្នុងព្រះបាលីនេះ មានសេចក្ដី

កំណត់ទុកថា បើរូបនោះគប្បីមកកាន់គន្លងចក្ខុសោត រូបនោះ ក៏គប្បីប៉ះខ្ទប់ត្រង់ចក្ខុ ដូច្នេះ ។ តែកាលពោលដោយអត្ថហើយ រូបកាលកំពុងប៉ះខ្ទប់នូវបសាទប៉ុណ្ណោះ ទើបឈ្មោះថា រមែងប៉ះខ្ទប់ ។ សូម្បីក្នុងអធិការនេះគប្បីជ្រាបន័យទាំង ៤ ដោយន័យដែលពោលទុកមុនន៎ុះឯង ។

កាលបុគ្គលបំណងនឹងមើលដោយសេចក្ដីប្រាថ្នារបស់ខ្លួន ទើបបែរចក្ខុទៅខាងរូប ចក្ខុទើបប៉ះខ្ទប់រូបនោះ ហេតុនោះឥឡូវនេះ ព្រះមានព្រះភាគទ្រង់បំណងប្រកាសអាការនោះទើបផ្ដើមនិទ្ទេសវារៈទី ៣ តទៅ ។ ពោលដោយអត្ថ និទ្ទេសវារៈទី ៣ នោះ ជាក់ច្បាស់ហើយដោយពិត តែក្នុងអធិការនេះ ចក្ខុទទួលអារម្មណ៍ហើយប៉ុណ្ណោះ ទើបឈ្មោះថា ប៉ះខ្ទប់ត្រង់រូប ។ បណ្ឌិតគប្បីជ្រាបន័យការកំណត់ ៤ យ៉ាង ក្នុងនិទ្ទេសទី ៣ នេះ ដោយន័យមុនន៎ុះឯង ។

ចាប់ផ្ដើមអំពីនេះទៅ ទ្រង់សម្ដែងវារៈ ១០ គឺវារៈ ៥ ដោយអំណាចនៃការសម្ដែងការកើតផស្សបញ្ចកៈ និងវារៈ ៥ ដោយអំណាចនៃការសម្ដែងការកើតឡើង ដោយមានអារម្មណ៍ជាប់ទាក់ទងគ្នានៃធម៌ពួក ៥ មានផស្សៈជាដើមទាំងនោះឯង ។

បណ្ដាបទទាំងនោះ បទថា **ចក្ខុំ និស្សាយ** បានដល់ អាស្រ័យចក្ខុ គឺធ្វើនូវចក្ខុឲ្យជាបច្ច័យ ។ បទថា **រូបំ អារព្ភ** បានដល់ មកដល់ សំដៅគឺអាស្រ័យរូបារម្មណ៍ ។ ដោយព្រះបាលីនេះ ទ្រង់សម្ដែងភាពដែលរូបជាបច្ច័យដោយភាពជាបុរេជាតប្បច្ច័យដល់ធម៌ មានផស្សៈជាដើម ដែលមាន

ចក្ខុបសាទជាទីអាស្រ័យកើត និងដោយអារម្មណាធិបតិប្បច្ច័យ អារម្មណូ-បនិស្សយប្បច្ច័យដល់ធម៌ទាំងឡាយ ដែលរាប់បញ្ចូលក្នុងជវនវិថី តាមចក្ខុ-ទ្វារ ។ ក្នុង ៥ វារៈក្រៅអំពីនេះ ទ្រង់សំដែងភាពដែលរូបជាបច្ច័យ ដោយត្រឹមតែជាអារម្មណប្បច្ច័យប៉ុណ្ណោះ យ៉ាងនេះថា រូបជាអារម្មណ៍របស់ចក្ខុ-សម្ផស្សនោះ ព្រោះហេតុនោះទើបចក្ខុសម្ផស្សនោះឈ្មោះថា **រូបារម្មណោ** ។ គប្បីជ្រាបន័យការកំណត់ទីមួយៗ ៤ ន័យ ក្នុងវារៈ ១០ ទាំងនេះ ដូចក្នុង ៣ វារៈខាងដើម ។ ព្រះមានព្រះភាគ ទ្រង់បំណងសំដែងចក្ខុដែលទ្រង់លើកឡើងជាពាក្យសួរថា រូបជាចក្ខាយតនៈនោះ តើដូចម្ដេច ដោយប្រការផ្សេងៗថា **ឥទំ** ( នេះរូប ) ទើបទ្រង់សំដែងនិទ្ទេសវារៈ ១៣ គឺន័យមុន ៣ វារៈ ន័យនេះ ១០ វារៈ ។ ក្នុង ១៣ វារៈនេះ គប្បីជ្រាបថា ទ្រង់សំដែងវារៈប្រដាប់ដោយន័យ ៥២ ព្រោះការកំណត់វារៈទីមួយៗទុកជា ៤ ន័យ ។

[ ១៧-២០ ] ក្នុងនិទ្ទេសនៃសោតាយតនៈជាដើម ខាងមុខអំពីចក្ខុនិទ្ទេសនេះក៏ន័យនេះដូចគ្នា តែក្នុងសោតាយតនៈនិទ្ទេសជាដើមនេះ គប្បីជ្រាបពាក្យដែលផ្សេងគ្នាយ៉ាងនេះថា

ធម៌ដែលឈ្មោះថា **សោត** ព្រោះអត្ថថា បានឮ ។ សោតៈនោះតាំងនៅក្នុងប្រទេសមានសណ្ឋានដូចវង់ចិញ្ចៀន មានរោមក្រហមល្អិត ដុះឡើងខាងក្នុងប្រហោងនៃសសម្ភារសោតៈ ដែលធាតុទាំងឡាយ មានប្រការដូចពោលហើយ ធ្វើឧបការៈ ដែលឧតុ ចិត្តនិងអាហារឧបត្ថម្ភ ដែលអាយុ គឺជីវិតរូប ចាំអនុបាល ដែលគោចររូប មានវណ្ណៈជាដើមចោមរោមហើយ ឲ្យ

សម្រេចភាពជាវត្ថុនិងទ្វារនៃសោតវិញ្ញាណជាដើម តាមសមគួរ ។

ធម៌ដែលឈ្មោះថា **ឃាន** ព្រោះអត្ថថា រមែងស្រង់ក្លិន ។ ឃានៈដែលជាបសាទរូបនោះ តាំងនៅក្នុងប្រទេសមានសណ្ឋានដូចក្រចកជើងពពែ ខាងក្នុងប្រហោងសសម្ភារឃានៈ បានទទួលឧបការៈ ឧបត្ថម្ភ អនុបាលនិងការចោមរោម តាមដែលពោលមកហើយ ឲ្យសម្រេចភាពជាវត្ថុនិងទ្វារនៃឃានវិញ្ញាណជាដើម តាមសមគួរ ។

ធម៌ដែលឈ្មោះថា **ជិវ្ហា** ដោយអត្ថថា ភ្លក្សរស ។ ជិវ្ហាដែលជាបសាទរូបនោះ តាំងនៅក្នុងប្រទេសមានសណ្ឋានដូចចុងត្របកឧប្បល ខាងលើត្រង់កណ្តាលសសម្ភារជិវ្ហា មានការឧបការៈ ឧបត្ថម្ភ អនុបាលនិងការចោមរោម តាមដែលពោលមកហើយ ឲ្យសម្រេចភាពជាវត្ថុនិងទ្វារនៃជិវ្ហា-វិញ្ញាណជាដើម តាមសមគួរ ។

ឈ្មោះថា ឧបាទិន្នករូប មាននៅក្នុងកាយនេះត្រឹមណា កាយាយតនៈក៏មាននៅទូទៅក្នុងកាយទាំងអស់ ដូចសរសៃក្នុងសម្លីត្រឹមនោះ បានឧបការៈ ឧបត្ថម្ភ អនុបាលនិងការចោមរោមតាមប្រការដែលពោលហើយ ឲ្យសម្រេចភាពជាវត្ថុនិងទ្វារនៃកាយវិញ្ញាណជាដើម តាមសមគួរ ។ នេះជាសេចក្តីផ្សេងគ្នាក្នុងឧបាទារូបទាំងនេះ ។ ប្រភេទនៃព្រះបាលីដ៏សេសនិងអត្ថដ៏សេសគប្បីជ្រាបដោយន័យដែលពោលក្នុងចក្ខុនិទ្ទេសនុ៎ះឯង ។ តែក្នុងទីនេះ ពាក្យថា សោតៈជាដើម មកជំនួសទីនៃពាក្យថា ចក្ខុ ពាក្យថា សំឡេងជាដើម មកជំនួសទីនៃពាក្យថា រូប ពាក្យថា ឮជាដើម មកជំនួសទីនៃពាក្យទាំង

ឡាយ មានពាក្យថា ឃើញជាដើម ។ មួយវិញទៀត ព្រោះមិនមានពាក្យ ២ នេះ គឺនេត្តខ្វះ នយនៈខ្វះទើបមានឈ្មោះនីមួយៗ ១២ ។ ពាក្យដ៏សេស ដូចពាក្យដែលពោលទុកក្នុងបទទាំងពួងនុ៎ះឯង ។

ក្នុងអធិការនៃកាយាយតនៈនោះបើមានអ្នកចោទសួរថា ឈ្មោះថា **ឧបាទិន្នករូប** មាននៅក្នុងកាយនេះដរាបណា កាយាយតនៈ ក៏មាននៅទូទៅក្នុងកាយទាំងអស់ ដូចសរសៃក្នុងសម្ពីដរាបនោះ កាលបើយ៉ាងនោះ គុណលក្ខណៈចំពោះខ្លួន ក៏នឹងប្រឡូកប្រឡំគ្នា ។ ឆ្លើយថា មិនប្រឡូកប្រឡំគ្នាទេ ។ ព្រោះហេតុអ្វី ព្រោះការមិនមាននៃអាយតនៈណាមួយក្នុងអាយតនៈដទៃណាមួយ ។ សួរថា បើយ៉ាងនោះ កាយាយតនៈក៏មិនមានទូទៅ ក្នុងកាយទាំងពួង ។ ឆ្លើយថា ដោយបរមត្ថ កាយាយតនៈក៏មិនមានក្នុងកាយទាំងពួង តែការធ្វើឲ្យផ្សេងគ្នានៃកាយាយតនៈនោះ បុគ្គលណាមួយ មិនអាចញែកចេញហើយបញ្ញត្តបាន ព្រោះហេតុនោះទើបបានពោលទុកយ៉ាងនេះ ។

ដូចរូបនិងរសជាដើមដែលលោកពោលថា ជារបស់ជ្រួតជ្រាបក្នុងគ្នានឹងគ្នា ព្រោះរូបនិងរសនោះ បុគ្គលណាមួយ មិនអាចញែកចាកគ្នាបាន ដូចខ្សាច់និងធូលី តែដោយបរមត្ថ រសក៏មិនមានក្នុងរូបទេ បើនឹងគប្បីមានសោត រសក៏គប្បីប្រាកដដោយសព្វថារូបដូចគ្នាយ៉ាងណា សូម្បីកាយាយតនៈក៏យ៉ាងនោះ ពោលដោយបរមត្ថមិនមាននៅពេញកាយ តែមិនមានពេញកាយទាំងអស់ក៏មិនមែន ព្រោះបុគ្គលណាមួយ មិនអាចញែកចាកគ្នាបាន ហេតុនោះ បណ្ឌិតគប្បីជ្រាបថា គុណលក្ខណៈចំពោះខ្លួន រមែងមិន

លាយឡំគ្នា ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបការមិនលាយឡំគ្នារបស់បសាទរូបទាំងនេះដោយកំណត់ដោយលក្ខណៈជាដើម ។ មែនពិត បណ្ដាបសាទរូបទាំងនេះ ចក្ខុ **រូបាភិឃាតារហភូតប្បសាទលក្ខណំ** ចក្ខុមានភាពថា របស់ភូតរូបដែលគួរដល់ការប៉ះខ្ទប់រូប ជាលក្ខណៈ **ទដ្ឋុកាមតានិទានកម្មសមុដ្ឋានភូតប្ប-សាទលក្ខណំ វា** ឬមានភាពថារបស់ភូតរូបដែលមានកម្មជាសមុដ្ឋានដែលជាហេតុរបស់បុគ្គលអ្នកប្រាថ្នានឹងមើល ជាលក្ខណៈ **រូបេសុ អាវិញ្ឆនរសំ** មានការទាញមកក្នុងរូបទាំងឡាយ ជាកិច្ច **ចក្ខុវិញ្ញាណស្ស អាធារភាវ-បច្ចុបដ្ឋានំ** មានភាពជាទីទ្រទ្រង់នូវចក្ខុវិញ្ញាណ ជាអាការប្រាកដ **ទដ្ឋុកាម-តានិទានកម្មជភូតបទដ្ឋានំ** មានភូតរូប ដែលកើតអំពីកម្មជាហេតុ របស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងមើល ជាហេតុជិត ។

សោតៈ **សទ្ទាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថានៃភូតរូបដែលគួរដល់ការប៉ះខ្ទប់សំឡេង ជាលក្ខណៈ **សោតុកាមតានិទានកម្មស-មុដ្ឋានភូតប្បសាទលក្ខណំ វា** ឬមានភាពថារបស់ភូតរូប ដែលមានកម្មជាសមុដ្ឋាន ដែលជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងស្ដាប់ ជាលក្ខណៈ **សទ្ទេសុ អាវិញ្ឆនរសំ** មានការទាញមកក្នុងសំឡេងទាំងឡាយ ជាកិច្ច **សោ-ត វិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានំ** មានភាពជាទីទ្រទ្រង់សោតវិញ្ញាណ ជាអាការប្រាកដ **សោតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតអំពីកម្មដែលជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងស្ដាប់ជាហេតុជិត ។

ឃានៈ **គន្ធាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថ្លានៃភូតរូប ដែលគួរដល់ការប៉ះខ្ទប់ក្លិន ជាលក្ខណៈ **ឃាយិតុកាមតានិទានកម្មស-មុដ្ឋានភូតប្បសាទលក្ខណំ វា** ឬមានភាពថ្លានៃភូតរូប ដែលមានកម្មជាសមុដ្ឋានដែលជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងស្រង់ក្លិន ជាលក្ខណៈ **គន្ធេសុ អាវិញ្ឆនរសំ** មានការទាញមកក្នុងក្លិនទាំងឡាយ ជាកិច្ច **ឃាន-វិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានំ** មានភាពជាទីទ្រទ្រង់ឃានវិញ្ញាណជាអាការប្រាកដ **ឃាយិតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតអំពីកម្ម ដែលជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងស្រង់ក្លិន ជាហេតុជិត ។

ជិវ្ហា **រសាភិឃាតារហភូតប្បសាទលក្ខណា** មានភាពថ្លានៃភូតរូប ដែលគួរដល់ការប៉ះខ្ទប់រស ជាលក្ខណៈ **សាយិតុកាមតានិទានកម្មសមុ-ដ្ឋានភូតប្បសាទលក្ខណា វា** ឬមានភាពថ្លានៃភូតរូបដែលមានកម្មជាសមុដ្ឋានជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងភ្លក្សរសជាលក្ខណៈ **រសេសុ អាវិញ្ឆនរសា** មានការទាញមកក្នុងរសទាំងឡាយជាកិច្ច **ជិវ្ហាវិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានា** មានភាពជាទីទ្រទ្រង់ជិវ្ហាវិញ្ញាណ ជាអាការប្រាកដ **សាយិតុកាមតានិទានកម្មជភូតបទដ្ឋានា** មានភូតរូប ដែលកើតអំពីកម្ម ដែលជាហេតុរបស់បុគ្គលដែលប្រាថ្នាដើម្បីនឹងភ្លក្សរសជាហេតុជិត ។

កាយ **ផោដ្ឋព្វាភិឃាតារហភូតប្បសាទលក្ខណោ** មានភាពថ្លានៃភូតរូបដែលគួរដល់ការប៉ះខ្ទប់ផោដ្ឋព្វៈ ជាលក្ខណៈ **ផុសិតុកាមតានិទាន-**

**កម្មសមុដ្ឋានភូតប្បសាទលក្ខណោ** វា ឬមានភាពថារបស់ភូតរូបដែលមានកម្មជាសមុដ្ឋាន ជាហេតុរបស់បុគ្គល អ្នកប្រាថ្នាដើម្បីនឹងពាល់ត្រូវ ជាលក្ខណៈ **ផោដ្ឋព្វេសុ អាវិញ្ឆនរសោ** មានការទាញមក ក្នុងផោដ្ឋព្វៈទាំងឡាយ ជាកិច្ច **កាយវិញ្ញាណស្ស អាធារភាវបច្ចុបដ្ឋានោ** មានភាពជាទីទ្រទ្រង់កាយវិញ្ញាណ ជាអាការប្រាកដ **ផុសិតុកាមតានិទានកម្មជភូតបទដ្ឋានោ** មានភូតរូបដែលកើតអំពីកម្មដែលជាហេតុរបស់បុគ្គលអ្នកប្រាថ្នាដើម្បីនឹងប៉ះខ្ទប់ ជាហេតុជិត ។

អាចារ្យពួកខ្លះពោលថា បសាទរបស់ភូតរូបទាំងឡាយដែលមានតេជោ-ធាតុច្រើនជា **ចក្ខុ** បសាទទាំងឡាយរបស់ភូតរូបទាំងឡាយដែលមានវាយោច្រើន បឋវីច្រើននិងអាបោច្រើនជា **សោត** ជា **ឃាន** និងជា **ជិវ្ហា** បសាទរបស់ភូតរូបទាំងអស់ ( ទាំង ៤ ) ជា **កាយ** ។

បរវាទីអាចារ្យមួយពួកទៀតពោលថា បសាទរបស់ភូតរូបដែលមានតេ-ជោធាតុច្រើនជា **ចក្ខុ** បសាទទាំងឡាយរបស់ភូតរូបដែលមានអាកាសធាតុវាយោធាតុ អាបោធាតុ បឋវីធាតុច្រើន ក៏ជាសោត ឃាន ជិវ្ហានិងកាយ ។ គប្បីពោលជំទាស់អាចារ្យបរវាទីទាំងនោះថា ចូរនាំព្រះសូត្រមកអាង ។ ជាការពិតប្រាកដ បរវាទីអាចារ្យទាំងនោះនឹងមិនឃើញព្រះសូត្រឡើយ ។ តែអាចារ្យពួកខ្លះពោលដល់ហេតុក្នុងបសាទរូបទាំងនេះថា ព្រោះបសាទរូបទាំងនោះដែលរូបជាដើម ដែលជាគុណនៃភូតរូប មានតេជោធាតុជាដើម គប្បីឧបការៈ ។ គប្បីចោទសួរអាចារ្យទាំងនោះថា អ្នកណានឹងពោលយ៉ាងនេះ

ថា រូបជាដើមជាគុណរបស់ភូតរូប មានតេជោធាតុជាដើម ព្រោះក្នុងអវិ-និព្ភោគរូបទាំងឡាយ ( រូបដែលបែកចាកគ្នាមិនបាន ៨ យ៉ាង ) បុគ្គលណាមួយមិនបានដើម្បីនឹងពោលថា ក្នុងភូតរូបទាំងនោះ រូបនេះជាគុណរបស់រូបនេះ រូបនេះជាគុណរបស់រូបនេះ ដូច្នេះ ។

បើបរវាទីគប្បីពោលទៀតថា ពួកអ្នកទទួលកិច្ចទាំងឡាយ មានការទ្រទ្រង់ទុកជាដើមនៃបឋវីធាតុជាដើម ព្រោះភូតរូបនោះៗមានច្រើន ក្នុងសម្ភារៈនោះៗយ៉ាងណា ពាក្យនេះថា រូបជាដើមជាគុណរបស់ភូតរូប មានតេជោ-ធាតុជាដើម គប្បីព្រមទទួលបានយ៉ាងនោះដូចគ្នា ព្រោះសម្តែងភាពដែលរូបជាដើម មានច្រើនក្នុងសម្ភារៈ ដែលមានតេជោធាតុជាដើមច្រើន ។

គប្បីជំទាស់ពួកបរវាទីនោះថា ពួកខ្ញុំក៏គប្បីព្រមទទួលបាន បើក្លិនក្នុងកប្បាស ដែលមានបឋវីធាតុច្រើន គប្បីមានច្រើនជាងក្លិនរបស់គ្រឿងត្រាំ ដែលមានអាបោធាតុច្រើន និងពណ៌របស់ទឹកត្រជាក់ក៏គប្បីមានតិចជាងពណ៌របស់ទឹកក្តៅ ដែលមានតេជោធាតុច្រើន តែពាក្យដែលពោលហើយទាំង ២ នេះ មិនមានទេ ព្រោះហេតុនោះ ការកំណត់ភាពផ្សេងគ្នានៃភូតរូបដែលជាទីអាស្រ័យនៃបសាទរូបទាំងនោះ គប្បីប្រើមិនបាន រូបនិងរសជាដើមរបស់ភូតរូបទាំងឡាយ ក្នុងកលាបៈមួយដែលមិនប្លែកគ្នា ក៏នៅមិនដូចគ្នានឹងគ្នាយ៉ាងណា ការដែលលោកគប្បីកាន់យកថា កាលហេតុប្លែកគ្នាដទៃៗមិនមានចក្ខុបសាទជាដើម ក៏មិនដូចគ្នានឹងគ្នា ក៏យ៉ាងនោះ ។

សួរថា អ្វីដែលមិនទូទៅដល់គ្នានឹងគ្នា ឆ្លើយថា កម្មនោះឯងជាហេតុ

ផ្សេងគ្នារបស់បសាទរូបទាំងនោះ ។ ព្រោះហេតុនោះ សេចក្ដីផ្សេងគ្នានៃបសាទរូបទាំងនេះមានព្រោះការផ្សេងគ្នានៃកម្ម មិនមែនមានព្រោះការផ្សេងគ្នានៃភូតរូបឡើយ ព្រោះថា កាលមានការផ្សេងគ្នានៃភូតរូប បសាទរូបនុ៎ះឯងរមែងមិនកើតឡើង បោរាណាចារ្យទាំងឡាយពោលទុកថា កាលមហាភូតរូបទាំងឡាយស្មើគ្នា បសាទរូបរមែងកើតបាន កាលមិនស្មើគ្នារមែងមិនកើត ។

បណ្ដាបសាទរូបទាំងនេះដែលមានការផ្សេងគ្នា ព្រោះការផ្សេងគ្នានៃកម្ម ចក្ខុបសាទរូបនិងសោតបសាទរូប ជាអសម្បត្តវិសយគាហកៈ ( គឺទទួលអារម្មណ៍ដែលមិនទាន់មកដល់ខ្លួន ) ព្រោះជាហេតុកើតនៃវិញ្ញាណក្នុងអារម្មណ៍ដែលជាទីអាស្រ័យ ដែលមិនជាប់គ្នាជាមួយមហាភូតរូបដែលជាទីអាស្រ័យរបស់ខ្លួន ។ ឃានៈ ជិវ្ហានិងកាយជាសម្បត្តវិសយគាហកៈ ( ទទួលអារម្មណ៍ដែលមកដល់ខ្លួន ) ព្រោះជាហេតុកើតនៃវិញ្ញាណ ក្នុងអារម្មណ៍ដែលជាប់គ្នានឹងមហាភូតរូប ដែលជាទីអាស្រ័យរបស់ខ្លួន ដោយអំណាចនៃវត្ថុដែលអាស្រ័យនិងដោយខ្លួននុ៎ះឯង ។

តែក្នុងអដ្ឋកថាពោលថា អារម្មណ៍ ឈ្មោះថា **សម្បត្ត** ( ដែលមកដល់ខ្លួន ) ព្រោះអារម្មណ៍មកកាន់គន្លង ( នៃចក្ខុនិងសោតៈ ) នោះឯង ។ មែនពិត ពណ៌របស់មណ្ឌលនៃព្រះចន្ទនិងព្រះអាទិត្យ ដែលតាំងនៅចម្ងាយដល់ ៤២,០០០ យោជន៍ ក៏នៅប៉ះខ្ទប់នឹងចក្ខុបសាទ ពណ៌នោះសូម្បីប្រាកដតាំងនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា **សម្បត្ត** ដូចគ្នា ។ ចក្ខុ ឈ្មោះថា មាន

អារម្មណ៍ដែលមកដល់ខ្លួននោះឯង ព្រោះពណ៌នោះជាអារម្មណ៍ ។ កាយ-វិការរបស់បុគ្គលទាំងឡាយដែលកាប់ដើមឈើក្តី របស់ជាងជ្រលក់អ្នកបោកគក់សំពត់ក្តី រមែងប្រាកដសូម្បីក្នុងទីឆ្ងាយ ។ តែសំឡេងមកដោយការបន្តៗគ្នានៃធាតុ ប៉ះខ្ទប់សោតៈហើយគង់កំណត់បាន ។

ក្នុងអដ្ឋកថានោះពោលថា អារម្មណ៍ ឈ្មោះថា សម្បត្ត ព្រោះអារម្មណ៍មកកាន់គន្លងក៏ពិត តែពណ៌នៃមណ្ឌលព្រះចន្ទជាដើម មិនមកដល់ចក្ខុ តាំងនៅក្នុងទីឆ្ងាយនុ៎ះឯង រមែងប្រាកដបាន បើសំឡេងគប្បីសោត់មកសន្សឹមៗសោត សូម្បីកើតក្នុងទីឆ្ងាយក៏គប្បីបានឮយឺត ព្រោះមកដោយការប៉ះខ្ទប់តៗគ្នា កាលប៉ះខ្ទប់សោត ក៏មិនប្រាកដថា សំឡេងនោះឈ្មោះថា នៅក្នុងទិសឈ្មោះនោះ ព្រោះហេតុនោះ ចក្ខុនិងសោតៈទើបមានអារម្មណ៍ជាអសម្បត្តនោះឯង ។

បសាទរូបទាំងនេះប្រៀបដូចសត្វ មានពស់ជាដើម ដូចឈ្មោះថាពស់រមែងមិនពេញចិត្តក្នុងទីខាងក្រៅ ដែលរងា ត្រជាក់និងស្រឡះ ក្នុងវេលាចូលទៅដេកត្រង់គំនរស៊ំរាម គុម្ពស្មៅ ស្លឹកឈើ ព្រៃស្បាតនិងជំបូកនុ៎ះឯងរមែងពេញចិត្ត រមែងដល់នូវភាពជាសត្វមានចិត្តស្ងប់យ៉ាងណា សូម្បីចក្ខុនេះក៏យ៉ាងនោះដូចគ្នា ពេញចិត្តក្នុងវត្ថុដែលមិនរាបស្មើ រមែងមិនពេញចិត្តក្នុងទីដែលមានជញ្ជាំងមាសជាដើម ដែលរលោងៗមិនប្រាថ្នាសូម្បីមើល តែរមែងពេញចិត្តក្នុងទីដែលវិចិត្រដោយរូប វិចិត្រដោយផ្កានិងវល្លិជាដើមនោះឯង ។ ព្រោះក្នុងទីបែបនោះ ជនទាំងឡាយកាលភ្នែកនៅមិនទាន់គ្រប់គ្រាន់

ក៏ត្រូវប្រហមាត់សម្ពឹងមើល ។

សូម្បីក្រពើ កាលចេញទៅខាងក្រៅ មិនឃើញវត្ថុដែលខ្លួនគប្បីត្របាក់ ក៏បិទភ្នែកត្រាច់ទៅ តែក្នុងកាលណា ចុះទៅកាន់ទឹកប្រមាណមួយរយព្យាម ចូលទៅកាន់រូងដេកហើយ ក្នុងកាលនោះ ចិត្តរបស់ក្រពើក៏ដល់នូវសេចក្ដីស្ងប់ ដេកយ៉ាងសប្បាយយ៉ាងណា សូម្បីសោតៈនេះ ក៏យ៉ាងនោះដូចគ្នា ពេញចិត្តក្នុងទីដែលមានប្រហោង អាស្រ័យអាកាស ពេញចិត្តក្នុងប្រហោងត្រចៀកប៉ុណ្ណោះ ។ អាកាសប្រហោងត្រចៀកប៉ុណ្ណោះ ជាបច្ច័យក្នុងការបានឮសំឡេងនោះ សូម្បីអជដាកាសក៏សមគួរដូចគ្នា ដ្បិតថា កាលធ្វើការស្វាធ្យាយខាងក្នុងល្អាង សំឡេងមិនទម្លុះល្អាងចេញទៅខាងក្រៅទេ តែក៏ចេញទៅតាមចន្លោះទ្វារបង្អួច ប៉ះខ្ទប់តៗគ្នាទៅនៃធាតុនោះឯងហើយប៉ះខ្ទប់សោតបសាទ ។ ក្នុងកាលនោះ ជនដែលអង្គុយខាងលើគុហា រមែងដឹងថា បុគ្គលឈ្មោះឯណោះ រមែងស្វាធ្យាយ ដូច្នេះ ។

កាលបើយ៉ាងនេះ សោតៈក៏មានអារម្មណ៍ជាសម្បត្ត ។ សួរថា ក៏សោតៈនេះ មានអារម្មណ៍ជាសម្បត្តឬ ឆ្លើយថា មែនហើយ មានអារម្មណ៍ជាសម្បត្ត ។ សួរថា បើយ៉ាងនោះ កាលស្គរជាដើមលាន់ឮក្នុងទីឆ្ងាយ ក៏មិនដឹងថាជាសំឡេងក្នុងទីឆ្ងាយ ។ ឆ្លើយថា មិនគប្បីដឹងក៏មិនមែន ព្រោះកាលសំឡេងប៉ះខ្ទប់សោតបសាទ រមែងមានការដឹងដោយប្រការនោះៗថា សំឡេងឆ្ងាយ សំឡេងជិត សំឡេងនៅត្រើយខាងនាយ សំឡេងនៅត្រើយខាងអាយ ដូច្នេះ សេចក្ដីនេះជាធម្មតា ។

ធម្មតានោះ តើមានប្រយោជន៍ដូចម្ដេច ប្រហែងមានអំពីទីណា ការស្ដាប់ក៏មានអំពីទីនោះៗ ដូចការឃើញព្រះចន្ទនិងព្រះអាទិត្យជាដើម ព្រោះហេតុនោះ ទើបសោតប្បសាទនេះ មានអារម្មណ៍ជាអសម្បត្តៈដោយពិត ។

សូម្បីបក្សីក៏មិនត្រេកអរលើដើមឈើ ឬផ្ទៃដី តែក្នុងវេលាណាបក្សីហើរឡើង កន្ទងការគប់ដុំដីមួយរយៈ ឬពីររយៈទៅកាន់អាកាសទទេ ក្នុងកាលនោះ បក្សីក៏នឹងមានចិត្តស្ងប់យ៉ាងណា សូម្បីឃានៈក៏យ៉ាងនោះដូចគ្នា មានសេចក្ដីពេញចិត្តក្នុងអាកាស មានក្លិនដែលអាស្រ័យខ្យល់ ជាអារម្មណ៍ ។ ពិតយ៉ាងនោះ គោទាំងឡាយ កាលភ្លៀងធ្លាក់ថ្មីៗក៏ស្រង់ក្លិនផែនដីហើយ ក៏ងើបមុខទៅរកអាកាសស្រង់ក្លិន និងវេលាដែលបុគ្គលសូម្បីយកម្រាមដៃចាប់ដុំដែលមានក្លិនហើយហិត មិនស្រូបខ្យល់ក៏មិនដឹងក្លិនរបស់ដុំដែលមានក្លិន ។

សូម្បីឆ្កែស្រុក កាលត្រាច់ទៅខាងក្រៅ រមែងមិនឃើញទីដែលផុតភ័យ ត្រូវប្រទូស្តដោយការត្រូវគប់គ្រវែង ដោយដុំដីជាដើម តែចូលទៅខាងក្នុងស្រុកហើយ កាយផេះក្នុងជើងក្រាន ហើយដេក ក៏រមែងជាសុខយ៉ាងណា សូម្បីជិវ្ហាក៏យ៉ាងនោះដូចគ្នា មានការពេញចិត្តក្នុងស្រុក មានរសដែលអាស្រ័យអាបោធាតុជាអារម្មណ៍ ពិតយ៉ាងនោះ ភិក្ខុសូម្បីធ្វើសមណធម៌អស់កាលបីយាមនៃរាត្រីហើយ កាន់យកបាត្រនិងចីវរ ចូលទៅកាន់ស្រុក អំពីព្រឹកព្រលឹម ព្រោះថាកាលរបស់ទំពាស្ងួតមិនទទឹកដោយទឹកមាត់ នរណាៗក៏មិនអាចដើម្បីដឹងនូវរសបាន ។

សូម្បីឆ្កែចចក កាលត្រាច់ទៅខាងក្រៅ ក៏មិនជួបការត្រេកអរ តែកាល

ទំពាស៊ីសាច់សាកសពមនុស្សក្នុងព្រៃខ្មោច ហើយដេកទ្រនុំះឯងទើបមានសេចក្តីសុខយ៉ាងណា សូម្បីកាយក៏យ៉ាងនោះដូចគ្នា មានការពេញចិត្តក្នុងឧបាទិន្នកៈរូប មានផោដ្ឋព្វៈអាស្រ័យបឋវីធាតុជាអារម្មណ៍ ។ ពិតយ៉ាងនោះ ជនទាំងឡាយកាលមិនបានឧបាទិន្នករូបដទៃ ក៏យកបាតដៃរបស់ខ្លួនទ្រនុំះឯង ទ្រក្បាលដេក បឋវីធាតុទាំងខាងក្នុងនិងខាងក្រៅ រមែងជាបច្ច័យក្នុងការទទួលអារម្មណ៍នៃកាយបសាទនោះ ។ ពិតណាស់ បុគ្គលមិនបានអង្គុយ មិនអាចដឹងការរឹង ឬការទន់របស់សេយ្យាសនៈដែលក្រាលទុកហើយយ៉ាងល្អ ឬបុគ្គលមិនបានប្រេបាច់មិនអាចដឹងការរឹង ឬការទន់របស់ផ្លែឈើដែលគេដាក់លើតាំង ព្រោះហេតុនោះ ទើបបឋវីធាតុខាងក្នុងនិងខាងក្រៅ ជាបច្ច័យ ក្នុងការដឹងផោដ្ឋព្វៈនៃកាយបសាទនេះ ។ គប្បីជ្រាបការមិនលាយឡំគ្នានៃបសាទរូបទាំងនោះ ដោយការកំណត់ធម៌ មានលក្ខណៈជាដើម ដោយអាការយ៉ាងនេះ ។

ពិតណាស់ លក្ខណៈ កិច្ច អាការប្រាកដ ហេតុជិត អារម្មណ៍ អធ្យាស្រ័យ និងវត្ថុដែលអាស្រ័យរបស់ចក្ខុបសាទមួយបែប របស់សោតបសាទជាដើមក៏មួយបែប ព្រោះហេតុនោះចក្ខាយតនៈជាដើម ទើបមិនលាយឡំគ្នាដោយពិត ។

ម្យ៉ាងទៀត គប្បីជ្រាបសូម្បីឧបមានេះក្នុងភាពដែលបសាទរូបទាំងនោះមិនលាយឡំគ្នា ដូចតទៅនេះថា កាលលើកទង់ ៥ ពណ៌ ឡើងហើយស្រមោលហាក់ដូចជាជាប់គ្នាតែមួយក៏ពិត ទោះបីជាយ៉ាងនោះ ស្រមោល

របស់ទន់ក៏មិនលាយឡំគ្នានឹងគ្នាយ៉ាងណា មួយទៀត កាលគេយកកប្បាស ៥ ពណ៌ មូរធ្វើជាប្រឆេះប្រទីបអុជឲ្យឆេះហើយ អណ្តាតភ្លើងដូចគ្នាតែមួយក៏ពិត តែសរសៃរបស់កប្បាសនោះៗ ក៏ជារបស់បែកគ្នា អណ្តាតភ្លើងក៏មិនលាយឡំគ្នានឹងគ្នាយ៉ាងណា អាយតនៈ ៥ នេះ សូម្បីរួមគ្នានៅក្នុងអត្តភាពមួយក៏ពិត តែក៏មិនលាយឡំគ្នានឹងគ្នាយ៉ាងនោះដូចគ្នា ។ មិនមែនតែអាយ-តនៈទាំង ៥ នេះប៉ុណ្ណោះទេ សូម្បីរូបដ៏សេសក៏មិនលាយឡំគ្នា ។

ពិតណាស់ ក្នុងសរីរៈនេះមានកាយ ៣ កំណាត់ គឺកាយកំណាត់ក្រោម ១ កាយកំណាត់កណ្តាល ១ កាយកំណាត់លើ ១ ។

បណ្តាកាយទាំង ៣ កំណាត់នោះ កាយក្នុងខាងក្រោមចាប់ពីផ្ចិតចុះទៅ ឈ្មោះថា កាយកំណាត់ក្រោម ក្នុងកាយកំណាត់ក្រោមនោះមានរូប ៤៤ គឺ កាយទសកៈ ១០ ភាវទសកៈ ១០ រូបមានអាហារជាសមុដ្ឋាន ៨ មានឧតុជាសមុដ្ឋាន ៨ មានចិត្តជាសមុដ្ឋាន ៨ ។ កាយខាងលើចាប់តាំងពីផ្ចិតឡើងទៅដល់គល់ក ឈ្មោះថា កាយកំណាត់កណ្តាល ក្នុងកាយកំណាត់កណ្តាលនោះមានរូប ៥៤ រូប គឺកាយទសកៈ ១០ ភាវទសកៈ ១០ វត្ថុ-ទសកៈ ១០ រូបទាំង ៣ មានរូបដែលមានអាហារជាសមុដ្ឋានជាដើមនីមួយៗ ៨ ។ កាយខាងលើចាប់តាំងពីគល់កឡើងទៅ ឈ្មោះថា កាយកំណាត់លើ ។ ក្នុងកាយកំណាត់ខាងលើនោះ មានរូប ៨៤ គឺចក្ខុទសកៈ ១០ សោត-ទសកៈ ១០ ឃានទសកៈ ១០ ជិវ្ហាទសកៈ ១០ កាយទសកៈ ១០ ភាវ-ទសកៈ ១០ រូប ៣ មានរូបដែលមានអាហារជាសមុដ្ឋានជាដើម នីមួយៗ

៨ ។

បណ្តារូបទាំងនោះ រូបនោះគឺ មហាភូតរូប ៤ ជាបច្ច័យដល់ចក្ខុបសាទ វណ្ណៈ គន្ធៈ រសៈ ឱជា ជីវិតិន្ទ្រិយនិងចក្ខុបសាទ ឈ្មោះថា ចក្ខុទសកៈ ដោយអំណាចនៃនិប្ផន្នរូប ១០ ដែលជារូបបែកគ្នាមិនបាន ។ រូបសូម្បីដ៏សេសក៏គប្បីជ្រាបដោយន័យនេះ ។

បណ្តាកាយទាំង ៣ កំណាត់នោះ រូបក្នុងកាយកំណាត់ក្រោម មិនលាយឡំគ្នានិងរូបកាយកំណាត់កណ្តាល និងក្នុងកាយកំណាត់លើ រូប ២ កំណាត់ក្នុងកាយដ៏សេស ក៏មិនលាយឡំគ្នានឹងរូបកាយក្រៅនេះ ។ ដូចស្រមោលភ្នំនិងស្រមោលដើមឈើ ក្នុងវេលាល្ងាច ដូចជាប់គ្នាតែមួយក៏ពិត តែក៏មិនលាយឡំគ្នាយ៉ាងណា ក្នុងកាយទាំងនេះក៏យ៉ាងនោះ រូប ៤៤ ក្តី រូប ៥៤ ក្តី រូប ៨៤ ក្តី ហាក់ដូចជាប់គ្នាតែមួយក៏ពិត តែក៏មិនលាយឡំនូវគ្នានឹងគ្នាដូច្នេះ ។

[ ២១-២៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរូបាយតនៈ ដូចតទៅនេះថា

វណ្ណៈនុ៎ះឯង ហៅថា **វណ្ណនិភា** ម្យ៉ាងទៀត ដែលឈ្មោះថា **និភា** ព្រោះអត្ថថា រមែងបញ្ចេញពន្លឺ អធិប្បាយថា ប្រាកដដល់ចក្ខុវិញ្ញាណ ។ ពន្លឺ គឺពណ៌ ឈ្មោះថា **វណ្ណនិភា** ។ រូបដែលប្រព្រឹត្តទៅព្រមជាមួយការឃើញ ឈ្មោះថា **សនិទស្សនំ** អធិប្បាយថា គប្បីឃើញដោយចក្ខុវិញ្ញាណ ។ រូបដែលប្រព្រឹត្តទៅព្រមជាមួយនឹងការប៉ះខ្ទប់ ឈ្មោះថា **សប្បដិឃំ** អធិប្បាយថា ពាល់ត្រូវ ធ្វើឲ្យកើតនូវការប៉ះទង្គិច ។

បណ្ដាពណ៌ មានពណ៌ខៀវចាស់ ដូចផ្កាត្រកៀត ពណ៌លឿង ដូចផ្កាកណិការ ពណ៌ក្រហមដូចផ្កាច្បា ពណ៌សដូចផ្កាយព្រឹក ពណ៌ខ្មៅដូចធ្យូង ពណ៌ហង្សបាទ ក្រហមព្រឿងៗដូចផ្កាកន្ទឹស[1] និងផ្កាឃើថោក្រពុំ ។ មាសត្រាស់ហៅថា **ហរិ** ដូចក្នុងប្រយោគ ( ក្នុងហំសជាតក ) ថា **ហរិត្តច ហេមវណ្ណ កាមំ សុមុខ បក្កម** ម្នាលសុមុខៈ មានសម្បុរដូចមាស អ្នកចូរកៀសខ្លួនទៅចុះ ដូច្នេះ តាមពិតទោះបីជាដូច្នោះ ព្រោះព្រះតម្រាស់ថា មាសនោះ ទ្រង់កាន់យកដោយសព្ទថា **ជាតរូប** ខាងមុខ តែក្នុងទីនេះពណ៌ដាំដែង ឈ្មោះថា **ហរិ** ។ ពណ៌ ៧ យ៉ាងនេះ ទ្រង់មិនបានកាន់យកដល់វត្ថុ តែទ្រង់សម្ដែងដោយសការៈប៉ុណ្ណោះ ។

បទថា **ហរិវណ្ណំ** គឺពណ៌ដូចស្មៅស្រស់ ។ បទថា **អម្ពង្កុរវណ្ណំ** គឺពណ៌ដូចជាពន្លកស្វាយ ។ វត្ថុទាំង ២ ពួកនេះ ទ្រង់កាន់យកសម្ដែងទុកហើយ ។ វត្ថុ ១២ យ៉ាង មានវែងជាដើម ទ្រង់សម្ដែងដោយវោហារ ឯវោហារនោះនៃបទវែងជាដើមទាំងនោះ សម្រេចហើយដោយការប្រៀបធៀប និងសម្រេចហើយដោយបញ្ញត្តកំណត់ឡើង ។ ពិតណាស់ ពាក្យថា វែងជាដើម ជាបទសម្រេចដោយការបញ្ញត្ត ប្រៀបធៀបនូវគ្នានឹងគ្នា ពាក្យថា មូលជាដើម សម្រេចដោយផ្សេងគ្នានៃការបញ្ញត្តតាំងឡើង ។ ក្នុងពីរយ៉ាងនោះ ព្រោះប្រៀបធៀបរូបដែលខ្លី វែងជាងនោះទើបឈ្មោះថា **ទីឃំ** ព្រោះប្រៀបធៀបនឹងរូបដែលវែងនោះ ខ្លីជាងនោះ ទើបឈ្មោះថា **រស្សំ** ព្រោះ

---

១-បាលីថា សិន្ទុវារ ក្នុងវេស្សន្តរជាតក លោកប្រែថា ដើមឈើទាលខ្សាច់ ។

ប្រៀបធៀបនឹងរូបដែលគ្រោតគ្រាត ល្អិតជាងនោះ ទើបឈ្មោះថា **អណុំ** ព្រោះប្រៀបធៀបនឹងរូបដែលល្អិតនោះ ធំជាងនោះ ឈ្មោះថា **ថូលំ** ។ រូបដែលមានសណ្ឋានដូចកង់រទេះ ឈ្មោះថា **វដ្ដំ** រូបមានសណ្ឋានដូចពងមាន់ ឈ្មោះថា **បរិមណ្ឌលំ** រូបប្រកបដោយជ្រុងទាំង ៤ ឈ្មោះថា **ចតុរំសំ** ។ សូម្បីរូប ៦ ជ្រុង ជាដើមក៏ន័យនេះឯង ។ បទថា **និន្នំ** បានដល់ រូបដែលទំនាប ។ បទថា **ថលំ** បានដល់ រូបដែលប៉ោងឡើង ( ទួល ) ។

បណ្ដារូបវែងជាដើមទាំងនោះ គប្បីជ្រាបថា ព្រោះបុគ្គលសូម្បីពាល់ត្រូវរូបវែងជាដើម អាចដើម្បីដឹងបាន តែរូបពណ៌ខៀវជាដើម បុគ្គលពាល់ត្រូវហើយ មិនអាចដឹងបាន ហេតុនោះរូបាយតនៈដែលវែង ទើបមិនបានត្រាស់ទុកដោយត្រង់ រូបាយតនៈដែលខ្លីជាដើមក៏ដូចគ្នា ។ តែក្នុងទីនេះត្រាស់ហៅរូបាយតនៈដែលអាស្រ័យការបញ្ញត្តកំណត់ឡើងនៃរូបវែងជាដើមនោះៗហើយ តាំងនៅដោយវោហារនោះៗថា វែង ខ្លី ។

បទនេះថា **ឆាយា អាតបោ** ទ្រង់កំណត់ដោយអាស្រ័យគ្នានឹងគ្នា ភ្លឺ និងងងឹត ក៏កំណត់ដោយអាស្រ័យគ្នានឹងគ្នាដូចគ្នា ។ បទ ៤ មានបទថា **អព្ភា មហិកា** ជាដើម ទ្រង់សម្ដែងទុកដោយវត្ថុប៉ុណ្ណោះ ។ បណ្ដាបទទាំង ៤ នោះ បទថា **អព្ភា** បានដល់ ភ្លៀង ។ បទថា **មហិកា** បានដល់ សន្សើម[១] ។ ពណ៌នៃពពកជាដើម ទ្រង់សម្ដែងទុកដោយបទទាំង ៤ នេះ ។ ដោយបទថា **ចន្ទមណ្ឌលស្ស វណ្ណនិភា** ជាដើម ទ្រង់សម្ដែងពណ៌ គឺរស្មី

១-បិដកខ្មែរ ពាក្យថា មហិកា លោកប្រែថា ផែនដី ។

នៃវត្ថុទាំងនោះ ។

ក្នុងបទទាំងនោះ គប្បីជ្រាបការផ្សេងគ្នានៃវត្ថុទាំងឡាយ មានព្រះចន្ទជាដើមយ៉ាងនេះ ។ វិមានរបស់ចន្ទទេវបុត្ត បណ្តោយនិងទទឹង ៤៩ យោជន៍ សម្រេចដោយកែវមណីពាសដោយប្រាក់ ឈ្មោះថា ចន្ទមណ្ឌល ។ វិមានរបស់សុរិយទេវបុត្ត បណ្តោយនិងទទឹង ៥០ យោជន៍ សម្រេចដោយមាសពាសដោយកែវផលិកឈ្មោះថា សុរិយមណ្ឌល ។ វិមានរបស់ទេវបុត្តនោះៗ បណ្តោយនិងទទឹង ៧ យោជន៍ ៨ យោជន៍ ១០ យោជន៍ ១២ យោជន៍ សម្រេចដោយរតនៈ ៧ ប្រការ ឈ្មោះថា ផ្កាយ ។

បណ្តាទេវបុត្តទាំងនោះ ព្រះចន្ទនៅខាងក្រោម ព្រះអាទិត្យនៅខាងលើ ចន្លោះព្រះចន្ទនិងព្រះអាទិត្យទាំង ២ មានមួយយោជន៍ ( ខ្ពស់ជាងគ្នាមួយយោជន៍ ) ដោយទីបំផុត ខាងក្រោមរបស់ព្រះចន្ទ និងដោយចំណែកបំផុតខាងលើរបស់ព្រះអាទិត្យ មានរយៈ ១០០ យោជន៍ ផ្កាយនក្ខត្តឫក្សទាំងឡាយ រមែងគោចរទៅត្រង់ខាងទាំងពីរ ។ បណ្តាវត្ថុទាំង ៣ ពួកនោះ ព្រះចន្ទគោចរទៅយឺត ព្រះអាទិត្យគោចរទៅរហ័ស ផ្កាយទាំងឡាយ ទៅរហ័សជាងគេទាំងអស់ គ្រាខ្លះគោចរទៅខាងមុខព្រះចន្ទនិងព្រះអាទិត្យ គ្រាខ្លះ ក៏គោចរទៅខាងក្រោយ ។

បទថា **អាធាសមណ្ឌលំ** បានដល់ វត្ថុសម្រេចដោយសំរឹទ្ធ ។ កញ្ចក់កែវពិទូរ្យ កែវដ៏សេសមានច្រើនប្រភេទ មានកែវមណីជោតិរស ឈ្មោះថា **មណិ** ។ បទថា **សង្ខា** បានដល់ វត្ថុដែលកើតក្នុងសមុទ្ទ ។ បទថា **មុត្តា**

បានដល់ វត្ថុដ៏សេសដែលកើតក្នុងសមុទ្ទ ។ បទថា **វេឡុរិយោ** បានដល់ កែវមណី មានពណ៌ដូចឫស្សី ។ វណ្ណៈរបស់ព្រះសាស្តា ហៅថា **ជាតរូប** ។ មែនពិត ព្រះសាស្តា មានវណ្ណៈដូចពណ៌មាស សូម្បីវណ្ណៈរបស់មាស ក៏ដូចវណ្ណៈព្រះសាស្តា ។ កហាបណៈក្តី មាសកៈដែលធ្វើដោយជាតិលោហៈក្តី មាសកៈធ្វើដោយឈើក្តី មាសកៈធ្វើដោយជ័រក្តី រមែងដល់នូវវោហារ ( គេចាយវាយបាន ) ហៅថា **រជតំ** ។ វត្ថុទាំងអស់នោះ ទ្រង់កាន់យកក្នុងបទថា **រជតំ** នេះ ។

ដោយបទថា **យំ វា បនញ្ញម្បិ** នេះ វៀររូបដែលត្រាស់ទុកក្នុងបាលី ទ្រង់កាន់យករូបដ៏សេស ដែលមានពណ៌កន្ទុលផែង ពណ៌សំពត់ចាស់និងពណ៌នៃហោជាងជាដើម ព្រោះពណ៌ទាំងអស់នោះរួមនៅក្នុងរូបដែលជាយេ-វាបនកធម៌ទាំងឡាយ ។ រូបនេះឯងសូម្បីមានដោយប្រភេទ មានពណ៌ខៀវជាដើម តែរូបទាំងអស់នោះ ក៏មិនបានប្លែកផ្សេងគ្នាដោយលក្ខណៈជាដើម ។

ពិតណាស់ រូប ( វណ្ណរូប ) ទាំងអស់ **ចក្ខុបដិហននលក្ខណំ** មានការប៉ះខ្ទប់នឹងចក្ខុជាលក្ខណៈ **ចក្ខុវិញ្ញាណស្ស វិសយភាវរសំ** មានភាពជាអារម្មណ៍របស់ចក្ខុវិញ្ញាណជាកិច្ច **តស្សេវ គោចរបច្ចុបដ្ឋានំ** មានភាពជាគោចររបស់ចក្ខុវិញ្ញាណនោះឯង ជាអាការប្រាកដ **ចតុមហាភូតបទដ្ឋានំ** មានមហាភូតរូប ៤ ជាហេតុជិត ។ ឧបាទារូបទាំងអស់ ដូចគ្នានឹងរូបនេះ ។ ខ្ញុំនឹងពោលចំពោះក្នុងទីដែលមានសេចក្តីប្លែកគ្នា ពាក្យដ៏សេសក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងចក្ខាយតននិទ្ទេសនុ៎ះឯង ។

តែក្នុងចក្ខាយតននិទ្ទេសនោះមានចក្ខុជាប្រធាន ក្នុងរូបាយតននិទ្ទេសនេះមានរូបជាប្រធាន ។ ក្នុងចក្ខាយតននិទ្ទេសនោះ មានឈ្មោះ ១៤ យ៉ាង មានពាក្យថា **ចក្ខុំបេតំ** ជាដើម ។ ក្នុងរូបាយតននិទ្ទេសនេះ មានឈ្មោះ ៣ យ៉ាង មានពាក្យថា **រូបំបេតំ** ជាដើម ។ ពាក្យដ៏សេសដូចគ្នាទាំងឯង ក្នុងរូបាយតននិទ្ទេសនេះ ក៏ត្រាស់វារៈទាំងឡាយទុក ដូចត្រាស់ទុក ១៣ វារៈប្រដាប់ដោយនយវារៈនីមួយៗ ៤ ន័យ ដើម្បីកំណត់ចក្ខុ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃសទ្ទាយតនៈ ដូចតទៅនេះថា

បទថា **ភេរិសទ្ទោ** បានដល់ សំឡេងស្គរធំនិងស្គរតូចដែលគេវាយ ។ សូម្បីសំឡេងសម្ភោរ សំឡេងសង្ខ សំឡេងស្គរជ័យ ក៏ជាសំឡេង មានសំឡេងសម្ភោរជាដើមជាបច្ច័យ ។ សំឡេងច្រៀង ហៅថា **គីតសទ្ទោ** ។ សំឡេងដេញមានសំឡេងពិណាជាដើម ក្រៅអំពីដែលពោលហើយ ឈ្មោះថា **វាទិតសទ្ទោ** ។

បទថា **សម្មសទ្ទោ** បានដល់ សំឡេងគង និងសំឡេងបន្ទះឈើ ( រនាត ) ។ បទថា **ចាណិសទ្ទោ** បានដល់ សំឡេងទះដោយបាតដៃ ។ បទថា **សត្តានំ និគ្ឃោសសទ្ទោ** បានដល់ សំឡេងដែលបន្លឺដោយមានបទនិងព្យញ្ជនៈមិនប្រាកដរបស់សត្វច្រើនដែលប្រជុំគ្នា ។ បទថា **ធាតូនំ សន្និ-ឃាតសទ្ទោ** បានដល់ សំឡេងជ្រៀតបៀតគ្នានឹងគ្នា របស់ដើមឈើទាំងឡាយ និងសំឡេងវាយរគាំងជាដើម ។ សំឡេងរបស់ខ្យល់បក់ ឈ្មោះថា **វាតសទ្ទោ** ។ សំឡេងរបស់ទឹកកំពុងហូរ ឬទឹកប៉ះខ្ទប់គ្នា ឈ្មោះថា **ឧទក-**

**សទ្ទោ** ។ សំឡេងសទ្ទនាជាដើមរបស់ពួកមនុស្ស ឈ្មោះថា **មនុស្សសទ្ទោ** ។ វៀរសំឡេងមនុស្សនោះហើយ សំឡេងដ៏សេសទាំងអស់ ឈ្មោះថា **អម-នុស្សសទ្ទោ** ។ ដោយបទទាំង ២ នេះ សំឡេងទាំងអស់ ឈ្មោះថាកាន់យកហើយ ។ កាលបើដូច្នោះ សំឡេងដែលមិនត្រាស់ទុកក្នុងព្រះបាលីដែលប្រព្រឹត្តទៅក្នុងវេលាកាប់ឫស្សី និងសំឡេងហែកសំពត់ចាស់ជាដើម គប្បីជ្រាបថារួមចូលក្នុងបទថា យេវាបនកៈ សំឡេងផ្សេងគ្នាដោយប្រភេទ មានសំឡេងស្គរជាដើមយ៉ាងនេះ តែមិនបានផ្សេងគ្នាដោយលក្ខណៈជាដើម ។

សំឡេងទាំងអស់នោះ **សោតបដិហននលក្ខណោ** មានការប៉ះខ្ទប់នឹងសោតៈ ជាលក្ខណៈ **សោតវិញ្ញាណស្ស វិសយភាវរសោ** មានភាពជាអារម្មណ៍របស់សោតវិញ្ញាណជាកិច្ច **តស្សេវ គោចរបច្ចុបដ្ឋានោ** មានភាពជាគោចររបស់សោតវិញ្ញាណនោះឯង ជាអាការប្រាកដ ។ ពាក្យដ៏សេស ( មានហេតុជិតជាដើម ) គប្បីជ្រាបដោយន័យដែលពោលក្នុងចក្ខាយតន-និទ្ទេសនុ៎ះឯង សូម្បីក្នុងសទ្ទាយតននិទ្ទេសនេះក៏ត្រាស់វារៈ ១៣ ប្រដាប់ដោយន័យវារៈនីមួយៗ ៤ ន័យ ។ សេចក្តីនៃវារៈទាំងនោះ អាចនឹងដឹងបានដោយន័យដែលពោលទុកហើយនុ៎ះឯង ហេតុនោះទើបមិនបានឲ្យពិស្តារ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃគន្ធាយតនៈ ដូចតទៅនេះថា

បទថា **មូលគន្ធោ** បានដល់ ក្លិនដែលកើតឡើង អាស្រ័យមើមឈើឯណានីមួយ ។ សូម្បីក្លិនខ្លឹមជាដើមក៏ន័យនេះដូចគ្នា ។ ក្លិនបន្លែត្រាំជាដើមដែលនៅមិនសម្រេចហើយឬសម្រេចហើយមិនល្អ ឈ្មោះថា **អាមកគន្ធោ** ។

ក្លិនស្រកាត្រី ក្លិនសាច់ស្អុយ ក្លិនទឹកដោះថ្លាខូចជាដើម ឈ្មោះថា **ទុគ្គន្ធោ** ។

បទថា **សុគន្ធោ** បានដល់ ក្លិនដែលគួរប្រាថ្នា ។ បទថា **ទុគ្គន្ធោ** បានដល់ ក្លិនមិនគួរប្រាថ្នា ។ ដោយបទទាំង ២ នេះ ក្លិនទាំងអស់ ឈ្មោះថា ទ្រង់កាន់យកហើយ ។ កាលបើដូច្នោះ ក្លិនទាំងអស់ដែលមិនត្រាស់ទុកក្នុងព្រះបាលី មានក្លិនផ្កាកណិការ និងក្លិនសំពត់ចាស់ជាដើម គប្បីជ្រាបថាសង្គ្រោះចូលក្នុងពាក្យថា យេវាបនកៈ ។

ក្លិននេះ សូម្បីផ្សេងគ្នាដោយភាពជាក្លិនមើមជាដើមយ៉ាងនេះ ពោលដោយលក្ខណៈហើយ ក៏មិនផ្សេងគ្នាឡើយ ។

ក្លិនទាំងអស់នោះ **ឃានបដិហននលក្ខណោ** មានការប៉ះខ្ទប់ឃានៈជាលក្ខណៈ **ឃានវិញ្ញាណស្ស វិសយភាវរសោ** មានភាពជាអារម្មណ៍របស់ឃានវិញ្ញាណជាកិច្ច **តស្សេវ គោចរបច្ចុបដ្ឋានោ** មានភាពជាគោចររបស់ឃានវិញ្ញាណនោះឯងជាអាការប្រាកដ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលក្នុងចក្ខាយតននិទ្ទេសនុ៎ះឯង សូម្បីក្នុងគន្ធាយតននិទ្ទេសនេះក៏ត្រាស់វារៈ ១៣ ប្រដាប់ដោយន័យ ៥២ ដូចគ្នានុ៎ះឯង ។ ពោលដោយអត្ថវារៈទាំងនោះ ជាក់ច្បាស់ហើយនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរសាយតនៈ ដូចតទៅនេះថា

បទថា **មូលរសោ** បានដល់ រសដែលអាស្រ័យមើមឯណានីមួយកើតឡើង ។ សូម្បីក្នុងរសដើមជាដើមក៏ន័យនេះឯង ។ បទថា **អម្ពិលំ** បាន

ដល់ ទឹកដោះជូរជាដើម ។ បទថា **មធុរំ** បានដល់ រសមានទឹកដោះថ្លា របស់គោជាដើមនោះឯង ។ ចំណែកទឹកឃ្មុំលាយនឹងរសចត់ រក្សាទុកមិនយូរក៏ជារសចត់ ។ ទឹកអំពៅលាយដោយរសល្វីង រក្សាទុកមិនយូរក៏ជារសល្វីង តែសប្បិរក្សាទុកយូរ សូម្បីលះបង់ពណ៌និងក្លិនក៏មិនលះបង់រស ព្រោះហេតុនោះ សប្បិនោះនុ៎ះឯង ទើបឈ្មោះថា ផ្អែមដោយចំណែកមួយ ។

បទថា **តិត្តកំ** បានដល់ ស្លឹកស្ដៅជាដើម ។ បទថា **កដុកំ** បានដល់ ខ្ញីនិងម្រេចជាដើម ។ បទថា **លោណិកំ** បានដល់ អំបិលសមុទ្រជាដើម ។ បទថា **ខារិកំ** បានដល់ ត្រប់ខារនិងទំពាំងជាដើម ។ បទថា **លម្ពិលំ** បានដល់ ពុទ្រា កន្ទួតព្រៃនិងខ្វិតជាដើម ។ បទថា **កសាវំ** បានដល់ សម៉ជាដើម ។ រសទាំងអស់នេះ ត្រាស់ទុកដោយអំណាចវត្ថុ ។ តែក្នុងនិទ្ទេសនេះ គប្បីជ្រាបថា រសត្រាស់ទុកដោយឈ្មោះ មានជូរជាដើម អំពីវត្ថុនោះៗ ។

បទថា **សាទុ** បានដល់ រសដែលគួរប្រាថ្នា ។ បទថា **អសាទុ** បានដល់ រសដែលមិនគួរប្រាថ្នា ។ ដោយបទទាំង ២ នេះ រសទាំងអស់ ឈ្មោះថា ទ្រង់កំណត់កាន់យកហើយ កាលបើយ៉ាងនោះ រសទាំងអស់ដែលមិនត្រាស់ទុកក្នុងព្រះបាលី មានរសជុំដី រសជញ្ជាំងផ្ទះ និងរសសំពត់ចាស់ជាដើម គប្បីជ្រាបថា សង្គ្រោះចូលក្នុងពាក្យថាយេវាបនកៈ ។ រសនេះសូម្បីផ្សេងគ្នាដោយភាពជារសមើមឈើជាដើមយ៉ាងនេះ តែពោលដោយលក្ខណៈជាដើម ក៏មិនផ្សេងគ្នាឡើយ ។

រសទាំងអស់នោះ **ជិវ្ហាបដិហននលក្ខណោ** មានការប៉ះខ្ទប់នឹងអណ្ដាត

ជាលក្ខណៈ **ជិវ្ហាវិញ្ញាណស្ស វិសយភាវរសោ** មានភាពជាអារម្មណ៍របស់ជិវ្ហាវិញ្ញាណជាកិច្ច **តស្សេវ គោចរបច្ចុបដ្ឋានោ** មានភាពជាគោចររបស់ជិវ្ហាវិញ្ញាណនោះឯងជាអាការប្រាកដ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យដែលពោលហើយក្នុងចក្ខាយតននិទ្ទេសនុ៎ះឯង សូម្បីក្នុងនិទ្ទេសនេះ ក៏ត្រាស់វារៈ ១៣ ប្រដាប់ដោយន័យ ៥២ ដូចគ្នានុ៎ះឯង ។

[ ២៥-២៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឥត្ថិន្ទ្រិយ ដូចតទៅនេះថា

បទថា **យំ** ជាតតិយាវិភត្តិ ។ ក្នុងបទនេះ អធិប្បាយថា ទ្រង់ទ្រាយស្ត្រីជាដើម របស់ស្ត្រី រមែងមានដោយហេតុណា ។ បណ្ដាបទទាំងនោះ បទថា **លិង្គំ** បានដល់ សណ្ឋានមែនពិត សណ្ឋាននៃអវយវៈមានដៃជើង កនិងទ្រូងជាដើម របស់ស្ត្រីមិនដូចបុរស ព្រោះកាយកំណាត់ខាងក្រោមរបស់ស្ត្រីទាំងឡាយមាំមួន កាយកំណាត់ខាងលើមិនមាំមួន ដៃជើងតូច មាត់តូច ។

បទថា **និមិត្តំ** បានដល់ ជាហេតុដឹងបាន ពិតណាស់ សាច់ជើងរបស់ស្ត្រីទាំងឡាយមាំមួន មាត់មិនមានពុកមាត់ ។ សូម្បីយកសំពត់បងសក់ ក៏មិនដូចរបស់ពួកបុរស ។ បទថា **កុត្តំ** បានដល់ កិរិយា អាការ ដ្បិតថា ពួកស្ត្រីទាំងឡាយក្នុងវេលានៅក្មេង រមែងលេងចង្អេរនិងអង្រែតូចៗ រមែងលេងកូនក្រមុំ យកដីស្អិតនិងឆ្នៃមកធ្វើជាអំបោះ ។

បទថា **អាកប្បោ** បានដល់ អាការ មានការដើរជាដើម ដ្បិតថា ស្រីទាំងឡាយ កាលដើរក៏ដើរមិនរហ័ស កាលឈរ កាលដេក កាលអង្គុយ កាលទំពា កាលបរិភោគក៏ឈរ ដេក អង្គុយ ទំពា បរិភោគមិនរហ័ស ។

ពិតណាស់ ជនទាំងឡាយឃើញមនុស្ស សូម្បីជាបុរសដែលមិនរហ័សរហួន ក៏ពោលថា បុរសនេះដើរ ឈរ ដេក អង្គុយ ទំពា បរិភោគ ដូចមនុស្សស្រី ដូច្នេះ ។

បទថា **ឥត្ថត្តំ ឥត្ថិភាវោ** ទាំង ២ នេះ មានសេចក្តីតែមួយដូចគ្នា គឺ ជាសភាវៈរបស់ស្ត្រី ។ ក៏សភាវៈរបស់ស្ត្រីនេះកើតអំពីកម្ម តាំងឡើងព្រម ជាមួយនឹងចិត្តក្នុងបដិសន្ធិកាល ចំណែកទ្រង់ទ្រាយរបស់ស្ត្រីជាដើមប្រាកដ ឃើញបានក្នុងបវត្តិកាល មិនដូចឥត្ថិន្ទ្រិយ ។ ដូចកាលពូជ មានដើមឈើ អាស្រ័យពូជ ព្រោះមានពូជជាបច្ច័យទើបចម្រើនលូតលាស់ បរិបូណ៌ដោយ មែក និងប្រគាបតាំងនៅពេញអាកាសយ៉ាងណា កាលឥត្ថិន្ទ្រិយ គឺភាពជា ស្ត្រីមាន ទ្រង់ទ្រាយនៃស្ត្រីជាដើម ក៏មានយ៉ាងនោះដូចគ្នា ។ ក៏ឥត្ថិន្ទ្រិយ ប្រៀបដូចពូជ ទ្រង់ទ្រាយស្ត្រីជាដើមអាស្រ័យឥត្ថិន្ទ្រិយ រមែងតាំងឡើងក្នុង បវត្តិកាល ប្រៀបដូចដើមឈើអាស្រ័យពូជចម្រើនលូតលាស់ហើយ តាំង នៅពេញអាកាស ដូច្នោះ ។

បណ្តាឥត្ថិន្ទ្រិយទាំងឡាយនោះ ឥត្ថិន្ទ្រិយ មិនគប្បីដឹងបានដោយចក្ខុ-វិញ្ញាណ គប្បីដឹងបានដោយមនោវិញ្ញាណប៉ុណ្ណោះ ។ ទ្រង់ទ្រាយរបស់ស្ត្រី ជាដើម ដឹងបានតាមចក្ខុវិញ្ញាណខ្លះ តាមមនោវិញ្ញាណខ្លះ ។

បទថា **ឥទំ តំ រូបំ ឥត្ថិន្ទ្រិយំ** សេចក្តីថា រូបនេះមិនដូចនឹងចក្ខុន្ទ្រិយ ជាដើមដែលជារបស់បុរស តែកាលពោលដោយនិយម ឥន្ទ្រិយចំពោះរបស់ ស្ត្រី ឈ្មោះថា **ឥត្ថិន្ទ្រិយ** ។

សូម្បីក្នុងបុរិសិន្ទ្រិយ ក៏ន័យនេះដូចគ្នា តែទ្រង់ទ្រាយរបស់ប្រុសជាដើម គប្បីជ្រាបដោយភាពផ្ទុយគ្នានឹងទ្រង់ទ្រាយរបស់ស្ត្រីជាដើម ព្រោះថាសណ្ឋាននៃអវយវៈមានដៃជើង កនិងទ្រូងជាដើម របស់ប្រុសមិនដូចរបស់ស្រី ដ្បិតថា កាយកំណាត់លើរបស់ប្រុសមាំមួន កាយកំណាត់ក្រោមមិនមាំមួន ដៃជើងក៏ធំ មាត់ធំ សាច់ជើងមិនធំ ពុកមាត់ពុកចង្កាកើតឡើង ការប្រើសំពត់ចងសក់ ក៏មិនដូចរបស់ស្រីទាំងឡាយ ក្នុងវេលាជាក្មេងរមែងលេងរថនិងនង្គ័លជាដើម រមែងធ្វើភ្លឺដោយខ្សាច់ រមែងជីកបឹង សូម្បីការដើរជាដើម ក៏អង់អាច ជនទាំងឡាយឃើញស្រីអ្នកធ្វើការដើរជាដើមយ៉ាងអង់អាច រមែងនិយាយពាក្យជាដើមថា នាងនេះដើរដូចមនុស្សប្រុស ដូច្នេះ ។ ពាក្យដ៏សេស ដូចពាក្យដែលពោលទុកក្នុងឥត្ថិន្ទ្រិយនុ៎ះឯង ។

បណ្តាឥន្ទ្រិយទាំង ២ នោះ ឥត្ថិន្ទ្រិយ **ឥត្ថិភាវលក្ខណំ** មានភាពជាស្រីជាលក្ខណៈ **ឥត្ថីតិ បកាសនរសំ** មានការប្រកាសថា ជាស្រីជាកិច្ច **ឥត្ថិលិង្គនិមិត្តកុត្តាកប្បានំ ការណភាវបច្ចុបដ្ឋានំ** មានការធ្វើទ្រង់ទ្រាយ និមិត្ត កិរិយា និងអាការរបស់ស្រីជាអាការប្រាកដ ។

បុរិសិន្ទ្រិយ **បុរិសភាវលក្ខណំ** មានភាពជាប្រុសជាលក្ខណៈ **បុរិសោតិ បកាសនរសំ** មានការប្រកាសថាជាប្រុសជាកិច្ច **បុរិសលិង្គនិមិត្តកុត្តាកប្បានំ ការណភាវបច្ចុបដ្ឋានំ** មានការធ្វើទ្រង់ទ្រាយ និមិត្ត កិរិយា និងអាការរបស់ប្រុសជាអាការប្រាកដ ។

ភាវរូបទាំង ២ នេះ របស់បុគ្គលអ្នកកើតក្នុងបឋមកប្ប រមែងតាំងឡើង

ក្នុងបវត្តិកាល ខាងក្រោយតមក ភាវរូបទាំង ២ នេះ តាំងឡើងក្នុងបដិ-សន្ធិកាល សូម្បីតាំងឡើងក្នុងបដិសន្ធិកាលក៏រមែងញាប់ញ័រ រមែងផ្លាស់ប្តូរបានក្នុងបវត្តិកាល ។

ដូចព្រះតម្រាស់ដែលត្រាស់ទុកក្នុងព្រះបាលីនៃបឋមបារាជិកថា សម័យនោះឯង ភិក្ខុ ១ រូប ក្លាយភេទខ្លួនប្រែទៅជាស្រី សម័យនោះឯង ភិក្ខុនី ១ រូប ក្លាយភេទខ្លួនទៅជាប្រុស ដូច្នេះ ។

បណ្តាភេទទាំង ២ នោះ ភេទប្រុសជាឧត្តមភេទ ភេទស្រីជាហីនភេទ ព្រោះហេតុនោះ ភេទប្រុសរមែងអន្តរធានទៅ ព្រោះអកុសលមានកម្លាំង ភេទស្រីរមែងតាំងឡើង ព្រោះកុសលមានកម្លាំងខ្សោយ តែភេទស្រីកាលអន្តរធាន រមែងអន្តរធានទៅ ព្រោះអកុសលដែលមានកម្លាំងខ្សោយ ភេទប្រុសរមែងតាំងឡើង ព្រោះកុសលមានកម្លាំង ។ គប្បីជ្រាបថា ភាវរូបទាំង ២ យ៉ាងនេះ រមែងអន្តរធានទៅព្រោះអកុសល រមែងតាំងឡើងព្រោះកុសលដោយប្រការដូច្នេះ ។

សួរថា បុគ្គលដែលជាឧភតោព្យញ្ជនកៈ មានឥន្ទ្រិយមួយឬមានឥន្ទ្រិយពីរ ។ ឆ្លើយថា មានឥន្ទ្រិយមួយ ក៏ឥត្ថិន្ទ្រិយនោះឯងរបស់ស្រី ដែលជាឧភតោព្យញ្ជនកៈនោះឯងជាឥត្ថិន្ទ្រិយ របស់ប្រុសដែលជាឧភតោព្យញ្ជនកៈជាបុរិសិន្ទ្រិយ ។ សួរថា កាលបើដូច្នោះ ព្យញ្ជនកៈទី ២ ក៏មិនប្រាកដដ្បិតថា ឥន្ទ្រិយលោកពោលថាជាហេតុប្រដាប់ភេទ និងឥន្ទ្រិយរបស់បុគ្គលដែលជាឧភតោព្យញ្ជនកៈនោះក៏មិនមាន ។ ឆ្លើយថា ឥន្ទ្រិយជាហេតុប្រដាប់

ភេទរបស់បុគ្គលដែលជាឧភតោព្យញ្ជនកៈនោះមិនមាន ព្រោះហេតុអ្វី ព្រោះមិនមានសព្វកាល ។

ដ្បិតថា សម្រាប់បុគ្គលដែលជាឥត្ថីឧភតោព្យញ្ជនកៈ ក្នុងកាលណាកើតតម្រេកក្នុងស្ត្រី ក្នុងកាលនោះប្រជាប់ភេទបុរសរមែងប្រាកដ ប្រជាប់ភេទស្ត្រីរមែងបិទបាំង ។ សម្រាប់បុគ្គលដែលជាបុរិសឧភតោព្យញ្ជនកៈ ប្រជាប់ភេទក៏កើតដូចគ្នា ។

បើឥន្ទ្រិយរបស់ឧភតោព្យញ្ជនកៈទាំងពីរនោះ គប្បីមានជាហេតុនៃប្រជាប់ភេទទី ២ សោត ប្រជាប់ភេទទាំង ២ ក៏គប្បីតាំងនៅសព្វកាល តែមិនបានតាំងនៅឡើយ ព្រោះហេតុនោះគប្បីជ្រាបពាក្យនេះថា ឥន្ទ្រិយនោះជាហេតុនៃប្រជាប់ភេទរបស់ឧភតោព្យញ្ជនកៈនោះក៏មិនមែន តែក្នុងទីនេះចិត្តសម្បយុត្តដោយរាគៈ មានកម្មជាសម្ភារៈប៉ុណ្ណោះ ជាហេតុ ព្រោះឥន្ទ្រិយរបស់ឧភតោព្យញ្ជនកៈនោះ មានត្រឹមតែមួយប៉ុណ្ណោះ ហេតុនោះឥត្ថីឧភតោព្យញ្ជនកៈ សូម្បីខ្លួនឯងក៏តាំងគភ៌បាន រមែងធ្វើឲ្យបុគ្គលដទៃតាំងគភ៌ ក៏បាន ចំណែកបុរិសឧភតោព្យញ្ជនកៈ រមែងធ្វើបុគ្គលដទៃឲ្យតាំងគភ៌បាន តែខ្លួនឯងរមែងតាំងគភ៌មិនបាន ។

[ ២៧ ] ពាក្យណាដែលខ្ញុំគួរពោលក្នុងជីវិតិន្ទ្រិយនិទ្ទេសនេះ ពាក្យនោះខ្ញុំពោលទុកហើយ ក្នុងអរូបជីវិតិន្ទ្រិយនោះឯង តែក្នុងអរូបជីវិតិន្ទ្រិយនោះត្រាស់ទុកថា នៃអរូបធម៌ទាំងនោះណា តែក្នុងជីវិតិន្ទ្រិយនិទ្ទេសនេះត្រាស់ថា នូវរូបធម៌ទាំងនោះណា ព្រោះភាពជារូបជីវិតិន្ទ្រិយ នេះប៉ុណ្ណោះជាសេចក្តី

ផ្សេងគ្នា ។ ចំណែកលក្ខណៈជាដើម របស់រូបជីវិតិន្ទ្រិយនោះ គប្បីជ្រាប យ៉ាងនេះថា

ជីវិតិន្ទ្រិយ **សហជាតរូបានុបាលនលក្ខណំ** មានការតាមរក្សារូបដែលកើតព្រមគ្នាជាលក្ខណៈ **តេសំ បវត្តនរសំ** មានការប្រព្រឹត្តទៅរបស់រូបធម៌ទាំងនោះជាកិច្ច **តេសំ យេវ ឋបនបច្ចុបដ្ឋានំ** មានការតាំងនៅនៃរូបធម៌ទាំងនោះឯង ជាអាការប្រាកដ **យាបយិតព្វភូតបទដ្ឋានំ** មានភូតរូបដែលញុំាងរូបធម៌ឲ្យប្រព្រឹត្តទៅជាហេតុជិត ។

[ ២៨-២៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកាយវិញ្ញត្តិនិទ្ទេស ដូចតទៅនេះថា

ជាបឋមនិងពណ៌នាកាយវិញ្ញត្តិ សត្វតិរច្ឆានទាំងឡាយក្តី មនុស្សទាំងឡាយក្តី រមែងដឹងការៈរបស់មនុស្សទាំងឡាយឬរបស់សត្វតិរច្ឆានទាំងឡាយ ដែលបំណងនឹងឲ្យដឹងការៈរបស់ខ្លួនផ្ទាល់កាយដោយធម្មជាតនោះ ដែលសត្វតិរច្ឆានឬមនុស្សកំណត់ហើយ ដោយទំនងនៃការកំណត់កាយ ព្រោះហេតុនោះ ធម្មជាតនោះឈ្មោះថា វិញ្ញត្តិ ។ ម្យ៉ាងទៀត ដែលឈ្មោះថា **វិញ្ញត្តិ** ព្រោះអត្ថថា ខ្លួនឯងដឹងការៈបានដោយទំនងនៃការកំណត់កាយ ។ វិញ្ញត្តិគឺកាយ ពោលគឺការកម្រើកកាយ ដែលត្រាស់ទុកក្នុងព្រះបាលី ( ខុទ្ទកនិកាយធម្មបទ ) ជាដើមថា **កាយេន សំវរោ សាធុ** ការសង្រួមកាយប្រពៃដូច្នេះ ឈ្មោះថា **កាយវិញ្ញត្តិ** ។

ម្យ៉ាងទៀត ដែលឈ្មោះថា **កាយវិញ្ញត្តិ** ព្រោះអត្ថថា សម្តែងឲ្យដឹងផ្ទាល់កាយ ព្រោះជាហេតុឲ្យដឹងបំណងបានដោយការកម្រើកកាយផ្សេងៗ និង

ព្រោះខ្លួនឯងក៏នឹងគប្បីដឹងដោយប្រការនោះ ។

ក្នុងពាក្យជាដើមថា **កុសលចិត្តស្ស វា** អធិប្បាយថា របស់បុគ្គលដែលមានចិត្តជាកុសលដោយកុសលចិត្ត ៩ ដួងគឺកាមាវចរកុសលចិត្ត ៨ ដួង អភិញ្ញាចិត្ត ១ ដួង ឬអ្នកមានចិត្តជាអកុសលដោយអកុសលចិត្ត ១២ ដួង ឬមានចិត្តដែលជាអព្យាកតដោយកិរិយាចិត្ត ១១ ដួង គឺមហាកិរិយា-ចិត្ត ៨ ដួង អហេតុកកិរិយាចិត្ត ២ ដួង អភិញ្ញាដែលជារូបាវចរកិរិយាចិត្ត ១ ដួង ។ ចិត្តដទៃអំពីនេះ រមែងមិនញុំាងវិញ្ញត្តិឲ្យកើតឡើងបាន ។ ព្រះសេក្ខៈ ព្រះអសេក្ខៈនិងបុថុជ្ជនក៏មានវិញ្ញត្តិ ដោយចិត្តមានប្រមាណប៉ុណ្ណោះឯង ព្រោះហេតុនោះទើបព្រះអង្គទ្រង់សម្តែងវិញ្ញត្តិដោយភាពជាហេតុ ដោយបទទាំង ៣ ដោយអំណាចនៃធម៌ មានកុសលជាដើមទាំងនេះ ( គឺកុសល អកុសល កិរិយា ) ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងវិញ្ញត្តិដោយផល ដោយបទទាំង ៦ ទើបត្រាស់ថា **អភិក្កមន្តស្ស វា** ជាដើម ។ មែនពិត ការឈានទៅមុខជាដើមឈ្មោះថា ផលរបស់វិញ្ញត្តិ ព្រោះប្រព្រឹត្តទៅដោយអំណាចវិញ្ញត្តិ ។ បណ្តាបទទាំងនោះ បទថា **អភិក្កមន្តស្ស** បានដល់ នាំកាយទៅខាងមុខ ។ បទថា **បដិក្កមន្តស្ស** បានដល់ នាំកាយត្រឡប់មកខាងក្រោយ ។ បទថា **អាលោកេន្តស្ស** បានដល់ សម្លឹងមើលទៅមុខ ។ បទថា **វិលោកេន្តស្ស** បានដល់ ក្រឡេកមើលខាងណោះ ក្រឡេកមើលខាងណេះ ។ បទថា **ស-មិញ្ជេន្តស្ស** បានដល់ បត់សន្លាក់ទាំងឡាយ ។ បទថា **បសារេន្តស្ស** បាន

ដល់ លាសន្ទាក់ទាំងឡាយ ។

ឥឡូវនេះដើម្បីសម្តែងវិញ្ញត្តិដោយសការៈដោយបទទាំង ៦ ទើបត្រាស់ថា **កាយស្ស ថម្ភនា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **កាយស្ស** បានដល់ នៃសរីរៈ ។ សការៈដែលឈ្មោះថា **ថម្ភនា** ព្រោះអត្ថថា ធ្វើកាយឲ្យតឹង ។ សការៈដែលតឹងនុ៎ះឯង ត្រាស់ហៅថា **សន្ថម្ភនា** ព្រោះបន្ថែមឧបសគ្គ ម្យ៉ាងទៀត ការតឹងមានកម្លាំងខ្លាំង ឈ្មោះថា **សន្ថម្ភនា** ។ ការៈដែលកាយតឹងដោយល្អ ឈ្មោះថា **សន្ថម្ភិតត្តំ** ។ ឈ្មោះថា **វិញ្ញត្តិ** ដោយអំណាចនៃការឲ្យដឹងសេចក្តី ។ អាការដែលឲ្យដឹងសេចក្តី ឈ្មោះថា **វិញ្ញា-បនា** ។ ការៈដែលសម្តែងឲ្យដឹងសេចក្តី ឈ្មោះថា **វិញ្ញាបិតត្តំ** ។ ពាក្យដ៏សេសណាដែលគប្បីពោលក្នុងកាយវិញ្ញត្តិនេះ ពាក្យនោះខ្ញុំពោលទុកហើយនោះឯងក្នុងទ្វារកថា ។ ក្នុងវចីវិញ្ញត្តិក៏ដូចគ្នា ។

តែសេចក្តីរបស់បទថា វចីវិញ្ញត្តិ និងអត្ថរបស់បទនិទ្ទេសទាំងឡាយដែលខ្ញុំមិនទាន់បានពោលទុកក្នុងទ្វារកថានោះ គប្បីជ្រាបយ៉ាងនេះថា

សត្វតិរច្ឆានទាំងឡាយក្តី មនុស្សទាំងឡាយក្តីរមែងដឹងការៈរបស់មនុស្សទាំងឡាយ ឬរបស់សត្វតិរច្ឆានទាំងឡាយ ដែលបំណងឲ្យដឹងការៈរបស់ខ្លួនតាមវាចាដោយធម្មជាតនោះ ដែលសត្វតិរច្ឆានឬមនុស្សកំណត់ហើយដោយទំនងនៃការកំណត់វាចា ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **វិញ្ញត្តិ** ។ ម្យ៉ាងទៀត ដែលឈ្មោះថា វិញ្ញត្តិ ព្រោះអត្ថថា រមែងដឹងការៈបានដោយទំនងនៃការកំណត់វាចា ។ វិញ្ញត្តិ គឺវចី ពោលគឺការកម្រើក ដែលត្រាស់

ទុកក្នុងព្រះបាលី ( ខុទ្ទកនិកាយធម្មបទ ) ជាដើមថា **សាធុ វាចាយ សំ-វរោ** ការសង្រួមវាចាប្រពៃ ដូច្នេះ ឈ្មោះថា **វចីវិញ្ញត្តិ** ។

មួយទៀត ដែលឈ្មោះថា **វចីវិញ្ញត្តិ** ព្រោះអត្ថថា សម្តែងឲ្យដឹងតាមវាចា ព្រោះជាហេតុឲ្យដឹងបំណងបានដោយសំឡេងនៃវាចា និងព្រោះខ្លួនឯងក៏នឹងគប្បីដឹងដោយប្រការនោះ ។

គប្បីជ្រាបវិគ្គហៈ ក្នុងពាក្យថា **វាចា គិរា** ជាដើម ដូចតទៅនេះថា

ដែលឈ្មោះថា **វាចា** ព្រោះអត្ថថា ជាសភាវៈដែលគេពោល ។ ដែលឈ្មោះថា **គិរា** ព្រោះអត្ថថា ដែលបុគ្គលបន្លឺ ។ ការចរចា ឈ្មោះថា **ព្យប្បថោ** ។ ម្យ៉ាងទៀត ដែលឈ្មោះថា **ព្យប្បថោ** ព្រោះអត្ថថា វាចានោះផង ជាគន្លងរបស់បុគ្គល ដែលបំណងនឹងដឹងសេចក្តី និងបំណងញុំាងអ្នកដទៃឲ្យដឹងសេចក្តីផង ។ ដែលឈ្មោះថា **ឧទីរណំ** ព្រោះអត្ថថា ដែលគេពោល ។ ដែលឈ្មោះថា **ឃោសោ** ព្រោះអត្ថថា ដែលគេប្រកាស ។ ដែលឈ្មោះថា **កម្មំ** ព្រោះអត្ថថា ដែលគេធ្វើ ។ កម្ម គឺការឃោសនា ឈ្មោះថា **ឃោសកម្មំ** អធិប្បាយថា ការប្រកាសដែលគេធ្វើដោយប្រការផ្សេងៗ ។ ការបន្លឺវាចា ឈ្មោះថា **វចីភេទោ** ។ ព្រះមានព្រះភាគត្រាស់ថា **វាចា វចី ភេទោ** ដើម្បីបំណងឲ្យដឹងថា វចីភេទនោះមិនមែនការទម្លាយជាវាចាដែលផ្សេងគ្នាប៉ុណ្ណោះ ។ វាចាគឺសំឡេងនោះឯង ទ្រង់សម្តែងដោយពាក្យទាំងពួងនេះ ។ ឥឡូវនេះ ទ្រង់បំណងសម្តែងវចីវិញ្ញត្តិនោះ ដោយសភាវៈដោយអាការ ៣ យ៉ាង ដោយអំណាចនៃបទទាំងឡាយ មានបទថា

វិញ្ញត្តិជាដើម ដែលមានន័យថាប់ពោលហើយ មកប្រកបជាមួយវាចានោះ ទើបត្រាស់បទជាដើមថា **យា តាយ វាចាយ វិញ្ញត្តិ** ដូច្នេះ ។ ពាក្យនោះមានអត្ថងាយទាំងអស់ ព្រោះមានន័យតាមដែលថាប់ពោលហើយនុ៎ះឯង ។

ឥឡូវនេះដើម្បីមិនឲ្យវង្វេងក្នុងចិត្ត ដែលញុំាងវិញ្ញត្តិឲ្យតាំងឡើង គប្បីជ្រាបបកិណ្ណកធម៌នេះ គឺចិត្ត ៣២ ដួង ចិត្ត ២៦ ដួង ចិត្ត ១៩ ដួង ចិត្ត ១៦ ដួងចុងក្រោយ ។ ចិត្ត ៣២ ដួង រមែងញុំាងរូបខាងក្រៅឲ្យតាំងឡើង រមែងឧបត្ថម្ភឥរិយាបថ រមែងញុំាងវិញ្ញត្តិសូម្បីទាំង ២ ឲ្យកើតឡើង ។ ចិត្ត ២៦ ដួង មិនធ្វើវិញ្ញត្តិនុ៎ះឯងឲ្យកើតឡើង រមែងធ្វើទាំង ២ យ៉ាងក្រៅនេះ ។ ចិត្ត ១៩ ដួង រមែងញុំាងរូបនុ៎ះឯង ឲ្យតាំងឡើង តែមិនធ្វើ ២ យ៉ាងក្រៅអំពីនេះ ។ ចិត្ត ១៦ ដួង មិនធ្វើកិច្ចសូម្បីត្រឹមតែមួយយ៉ាងបណ្ដា ៣ យ៉ាងនោះ ។

ក្នុងបកិណ្ណកធម៌ទាំងនោះ ពាក្យថា ចិត្ត ៣២ គឺចិត្តដែលពោលក្នុងខាងដើមនុ៎ះឯង គឺកុសលចិត្ត ៨ អកុសលចិត្ត ១២ កាមាវចរកិរិយាចិត្ត ១០ អភិញ្ញាចិត្តរបស់ព្រះសេក្ខៈនិងបុថុជ្ជន ១ អភិញ្ញាចិត្តរបស់ព្រះខីណាស្រពទាំងឡាយ ១ ។ ពាក្យថា ចិត្ត ២៦ ដួង គឺរូបាវចរកុសលចិត្ត ៥ រូបាវចរកិរិយាចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ អរូបាវចរកិរិយាចិត្ត ៤ មគ្គចិត្ត ៤ ផលចិត្ត ៤ ។ ពាក្យថា ចិត្ត ១៩ គឺ កាមាវចរកុសលវិបាក ១១ អកុសលវិបាក ២ កិរិយាមនោធាតុ ១ រូបាវចរវិបាកចិត្ត ៥ ។ ពាក្យថា ចិត្ត ១៦ គឺ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ បដិសន្ធិចិត្តរបស់សត្វទាំងអស់ ១

ចុតិចិត្តរបស់ព្រះខីណាស្រព ១ អរូបាវចរវិបាកចិត្ត ៤ ។ ចិត្ត ១៦ នេះ រមែងមិនធ្វើឲ្យរូបកើត មិនឧបត្ថម្ភឥរិយាបថ និងមិនធ្វើឲ្យកើតវិញ្ញត្តិ សូម្បីត្រឹមតែមួយឡើយ ។ អរូបាវចរចិត្ត សូម្បីដទៃទៀតច្រើនកើតឡើងហើយក្នុងអរូប ក៏មិនធ្វើរូបឲ្យកើតឡើង ព្រោះមិនមានឱកាស ។ ចិត្តទាំងឡាយណា រមែងញ៉ាំងកាយវិញ្ញត្តិឲ្យតាំងឡើងបាន ចិត្តទាំងឡាយនោះ រមែងធ្វើវចីវិញ្ញត្តិឲ្យតាំងឡើងបានផងដែរ ។

[ ៣០ ] គប្បីជ្រាបវិគ្គហៈក្នុងនិទ្ទេសនៃអាកាសធាតុ ដូចតទៅនេះថា

សភាវៈដែលឈ្មោះថា **អាកាស** ព្រោះអត្ថថា ដែលនរណាៗ រមែងក្ករមិនបាន ធ្វើឲ្យជាស្នាមគំនូសមិនបាន គឺថា មិនអាចដើម្បីនឹងក្ករ ឬដើម្បីនឹងកាត់ ឬដើម្បីធ្វើឲ្យបែក ។ អាកាសនុ៎ះឯង ហៅថា **អាកាសគតំ** ដូចពាក្យថា **ខេឡគតំ** ( ដល់នូវការរាប់ថាជាទឹកមាត់ ) ជាដើម ។ ម្យ៉ាងទៀត ដែលឈ្មោះថា **អាកាសគតំ** ព្រោះសត្វដឹងហើយថាជាអាកាស ។ ដែលឈ្មោះថា **អឃំ** ព្រោះដែលរបស់ណាមួយមិនប៉ះខ្ទប់ គឺមិនមានអ្វីពាល់ត្រូវបាន ។ អឃៈនុ៎ះឯង ហៅថា **អឃគតំ** ។ ដែលឈ្មោះថា **វិវរោ** ព្រោះអត្ថថា ជាប្រហោង ។ **វិវរោ** នោះឯង ឈ្មោះថា **វិវរគតំ** ។ បទថា **អសម្ផុដ្ឋំ ចតូហិ មហាភូតេហិ** នេះ ព្រះមានព្រះភាគត្រាស់ដល់អាកាសដែលជាទីទទេ ដែលមហាភូតរូបទាំងនេះ ពាល់ត្រូវមិនបានហើយ តែបើពោលដោយលក្ខណៈជាដើម

អាកាសធាតុ **រូបបរិច្ឆេទលក្ខណា** មានការខណ្ឌទុកនូវរូបជាលក្ខណៈ

**រូបបរិយន្តប្បកាសនរសា** មានការប្រកាសទីបំផុតរបស់រូបជាកិច្ច **រូបមរិ-យាទបច្ចុបដ្ឋានា** មានព្រំដែនរបស់រូបជាអាការប្រាកដ **អសម្ពុដ្ឋភាវជិទ្ទ-វិវរភាវបច្ចុបដ្ឋានា វា** ឬមានការៈដែលមហាភូតរូបពាល់ត្រូវមិនបានមានការៈដែលជាប្រហោង ជាចន្លោះ ជាទីវាលជាអាការប្រាកដ **បរិច្ឆិន្នរូប-បទដ្ឋានា** មានរូបដែលខណ្ឌទុក ជាហេតុជិត ។ មយ៉ាងទៀត ក្នុងរូបទាំងឡាយដែលអាកាសធាតុណា ខណ្ឌទុកហើយនឹងមានពាក្យថា រូបនេះមានខាងលើ ខាងក្រោមនិងខាងទទឹង អំពីអាកាសធាតុនោះ ។

[ ៣១-៣៣ ] ខាងមុខអំពីនេះ គប្បីជ្រាបនិទ្ទេសនៃធម៌ទាំងឡាយ មានរូបលហុតាជាដើម ដោយន័យដែលពោលទុក ក្នុងធម៌ទាំងឡាយ មានចិត្តលហុតាជាដើមនុ៎ះឯង តែក្នុងទីនេះពោលដោយលក្ខណៈជាដើម រូបល-ហុតា **អទន្ធតាលក្ខណា** មានការមិនយឺតយូរ ជាលក្ខណៈ **រូបានំ គរុ-ភាវវិនោទនរសា** មានការបន្ទោបង់ភាពធ្ងន់នៃរូបទាំងឡាយជាកិច្ច **លហុ-បរិវត្តិតាបច្ចុបដ្ឋានា** មានការផ្លាស់ប្តូរបានរហ័សជាអាការប្រាកដ **លហុ-រូបបទដ្ឋានា** មានរូបស្រាលជាហេតុជិត ។

រូបមុទុតា **អថទ្ធតាលក្ខណា** មានការមិនរឹង ជាលក្ខណៈ **រូបានំ ថទ្ធភាវវិនោទនរសា** មានការបន្ទោបង់ភាពរឹងរបស់រូបទាំងឡាយ ជាកិច្ច **សព្វកិរិយាសុ អវិរោធិតាបច្ចុបដ្ឋានា** មានភាពមិនជាសត្រូវ ក្នុងការធ្វើទាំងពួង ជាអាការប្រាកដ **មុទុរូបបទដ្ឋានា** មានរូបដែលទន់ ជាហេតុជិត ។

រូបកម្មញ្ញតា **សរីរកិរិយានុកូលកម្មញ្ញភាវលក្ខណា** មានការគួរដល់

ការងារដោយសមគួរដល់ការធ្វើសរីរៈ ជាលក្ខណៈ **អកម្មញ្ញភាវវិនោទន-រសា** មានការបន្ទោបង់ការមិនគួរដល់ការងារជាកិច្ច **អទុព្វលភាវបច្ចុប-ដ្ឋានា** មានការមិនទុព្វល ជាអាការប្រាកដ **កម្មញ្ញរូបបទដ្ឋានា** មានរូបដែលគួរដល់ការងារ ជាហេតុជិត ។

វិការរូបទាំង ៣ ពួកនេះ មិនលះបង់នូវគ្នានឹងគ្នា កាលបើហេតុយ៉ាងនោះមាន បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃរូបទាំង ៣ នោះ យ៉ាងនេះថា វិការរូបដែលរូបទាំងឡាយមានភាពស្រាល គឺការមិនយឺតយូរដូចការស្រាល ការមិនយឺតយូរនៃបុគ្គលមិនមានរោគ មានការផ្លាស់ប្តូរ ( ឥរិយាបថ ) បានរហ័ស មានសមុដ្ឋានកើតអំពីបច្ច័យ ដែលជាបដិបក្ខចំពោះធាតុកម្រើក ដែលធ្វើឲ្យរូបយឺតយូរឯណា វិការរូបនោះ ឈ្មោះថា **រូបលហុតា** ។ វិការរូប ដែលរូបទាំងឡាយ មានភាពទន់ ដូចស្បែកដែលគេសម្លាប់ទុកល្អ ហើយ មានការទន់ក្នុងការប្រព្រឹត្តទៅតាមអំណាច ក្នុងកិរិយាទាំងពួង បានផ្សេង ៗ គ្នា មានសមុដ្ឋានកើតអំពីបច្ច័យដែលជាបដិបក្ខចំពោះធាតុកម្រើក ដែលធ្វើឲ្យរូបរឹងឯណា វិការរូបនោះ ឈ្មោះថា **រូបមុទុតា** ។ ចំណែក វិការរូបដែលរូបទាំងឡាយ គួរដល់ការងារ ដូចមាសដែលរំលាយទុកល្អ ហើយ មានការសមគួរដល់កិរិយានៃសរីរៈ មានសមុដ្ឋានកើតអំពីបច្ច័យ ដែលជាបដិបក្ខ ចំពោះធាតុកម្រើក ដែលធ្វើឲ្យរូបមិនសមគួរដល់កិរិយានៃសរីរៈឯណា វិការរូបនោះ ឈ្មោះថា **រូបកម្មញ្ញតា** ។

មួយទៀត វិការរូបសូម្បីទាំង ៣ នុ៎ះ រមែងមិនអាចដើម្បីធ្វើការងារ

បាន ។ រូបដែលកើតអំពីអាហារជាដើមប៉ុណ្ណោះ រមែងធ្វើការងារបាន ។ ពិតយ៉ាងនោះ ពួកព្រះយោគាវចរនិយាយគ្នាថា ថ្ងៃនេះពួកយើងបានអាហារជាទីសប្បាយ ទើបកាយរបស់ពួកយើងស្រាល ទន់ គួរដល់ការងារ ថ្ងៃនេះពួកយើងបានឧតុជាទីសប្បាយ ថ្ងៃនេះចិត្តរបស់ពួកយើងទើបស្ងប់ កាយរបស់ពួកយើងស្រាល ទន់ គួរដល់ការងារ ដូច្នេះ ។

[ ៣៤-៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឧបចយនិងសន្តតិ ដូចតទៅនេះថា

បទថា **អាយតនានំ** បានដល់ អាយតនៈ គឺរូប ១០ កន្លះ ។ បទថា **អាចយោ** បានដល់ ការកើតឡើង ។ បទថា **សោ រូបស្ស ឧបចយោ** បានដល់ ការកើតសន្សំនៃអាយតនៈដែលកើតឡើងរឿយ ៗ ឯណា នោះឯងឈ្មោះថា ការកើតនៃរូប ( **រូបស្ស ឧបចយោ** ) អធិប្បាយថា សេចក្តីចម្រើន ។

បទថា **យោ រូបស្ស ឧបចយោ សា រូបស្ស សន្តតិ** សេចក្តីថា ការចម្រើនរបស់រូបទាំងឡាយ ដែលសន្សំហើយ ដោយអាការៈយ៉ាងនេះឯណា ក្នុងវេលាដែលរូបប្រព្រឹត្តទៅក្រៃលែងជាងនោះ ការចម្រើននោះឈ្មោះថា ការបន្តនៃរូប ( **រូបស្ស សន្តតិ** ) អធិប្បាយថា ការប្រព្រឹត្តទៅ ។ គប្បីជ្រាបថា ឧបចយរូបដែលសន្សំ ដូចវេលាទឹកឡើងក្នុងរណ្តៅដែលជីកទុកក្បែរមាត់ស្ទឹង ឧបចយរូបដែលកកើត ដូចវេលាដែលទឹកពេញរណ្តៅ សន្តតិរូបមែងប្រព្រឹត្តទៅ ដូចវេលាដែលទឹកពេញរណ្តៅហើយហូរទៅ ។

សួរថា ដោយអាការយ៉ាងនេះ ព្រះមានព្រះភាគត្រាស់អ្វីទុក ឆ្លើយថា ទ្រង់ត្រាស់ការសន្សំដោយអាយតនៈ ត្រាស់អាយតនៈដោយការសន្សំឈ្មោះថា ត្រាស់ការសន្សំនិងត្រាស់អាយតនៈទុំះឯងទុកហើយ ។ សួរថា កាលបើយ៉ាងនេះទ្រង់ត្រាស់អ្វីទុក ឆ្លើយថា ព្រះអង្គត្រាស់ដល់ការសន្សំ ការកកើត ការកើតហើយ ការចម្រើនរបស់សន្តតិរូបទាំង ៤ ។

មែនពិត កាលពោលដោយអត្ថ រូបទាំង ២ នេះ ( ឧបចយៈនិងសន្តតិ ) ជាឈ្មោះរបស់ជាតិរូបប៉ុណ្ណោះ តែពោលដោយការផ្សេងគ្នានៃអាការនិងដោយអំណាចរបស់វេនេយ្យសត្វ ទើបព្រះមានព្រះភាគ ទ្រង់ធ្វើឧទ្ទេសនិងនិទ្ទេស ដោយពាក្យថា **ឧបចយោ សន្តតិ** តែព្រោះក្នុងឧទ្ទេសនេះ មិនមានការផ្សេងគ្នាដោយអត្ថ ហេតុនោះទើបត្រាស់ទុកក្នុងនិទ្ទេសថា ការសន្សំណានៃពួកអាយតនៈ នោះជារូបស្សឧបចយៈ និងការកកើតណានៃរូប នោះជារូបស្សសន្តតិ គឺការតរូប ដូច្នេះ ។

មួយទៀត ព្រោះរូបទាំង ២ នេះ ( ឧបចយៈនិងសន្តតិ ) ជាឈ្មោះរបស់ជាតិរូបនោះឯង ហេតុនោះក្នុងនិទ្ទេសនេះបណ្ឌិតគប្បីជ្រាប ( លក្ខណៈជាដើមរបស់រូបទាំង ២ នោះ ) ថា

ឧបចយរូប **អាចយលក្ខណោ** មានការសន្សំ ជាលក្ខណៈ **បុព្វន្តតោ រូបានំ ឧម្មុជ្ជាបនរសោ** មានការញ៉ាំងរូបទាំងឡាយឲ្យកើតអំពីចំណែកខាងដើម ជាកិច្ច **និយ្យាតនបច្ចុបដ្ឋានោ** មានការប្រគល់ឲ្យ ជាអាការប្រាកដ **បរិបុណ្ណភាវបច្ចុបដ្ឋានោ វា** ឬមានការបរិបូណ៌ ជាអាការប្រាកដ **ឧបចិ-**

**ត រូបបទដ្ឋានោ** មានរូបដែលកើតហើយ ( គឺរូបដែលដល់ឧប្បាទក្ខណៈ ) ជាហេតុជិត ។

សន្តតិរូប **បវត្តិលក្ខណា** មានការប្រព្រឹត្តទៅ ( គឺប្រព្រឹត្តទៅដោយអំណាចការបន្ត ) ជាលក្ខណៈ **អនុប្បពន្ធរសា** មានការបន្តគ្នាតាមលំដាប់ ( គឺការបន្តដោយអំណាចរូបខាងដើមនិងខាងចុង ) ជាកិច្ច **អនុបច្ឆេទ-បច្ចុបដ្ឋានា** មានការមិនដាច់ចាកគ្នា ( មានការមិនដាច់ចាករូបខាងដើមនិងខាងចុង ) ជាអាការប្រាកដ **អនុប្បពន្ធរូបបទដ្ឋានា** មានរូបដែលបន្តគ្នាជាហេតុជិត ។

[ ៣៦-៣៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃជរតា ដូចតទៅនេះថា

ដែលឈ្មោះថា **ជរា** ដោយអំណាចនៃរូបដែលចាស់ ។ ក្នុងនិទ្ទេសនៃជរានេះមានការពន្រ្យល់សភាវៈថា អាការៈនៃការចាស់គ្រាំគ្រា ឈ្មោះថា **ជី-រណតា** ។ អាការៈទាំង ៣ មានពាក្យថា ការបាក់ធ្មេញជាដើមជាការពន្រ្យល់កិច្ច គឺកន្លងកាល កន្លងផុតវ័យទៅនោះឯង អាការ ២ ខាងចុង ជាការពន្រ្យល់សេចក្តីតាមប្រក្រតី ( គឺប្រព្រឹត្តទៅតាមធម្មតា ) ។

មែនពិត ដោយបទថា **ជរា** នេះ ទ្រង់សម្តែងជរានេះ ដោយសភាវៈព្រោះហេតុនោះ ពាក្យថា **ជរា** នេះ ទើបជាការអធិប្បាយសភាវៈរបស់ជរានោះ ។ ដោយបទថា **ជីរណតា** នេះ ទ្រង់សម្តែងដោយអាការៈ ព្រោះហេតុនោះ ទើបពាក្យថា **ជីរណតា** នេះ ជាការអធិប្បាយអាការរបស់រូប-ជីរណតានោះ ។ ដោយបទថា **ខណ្ឌិច្ចំ** នេះ ទ្រង់សម្តែងដោយកិច្ច គឺការ

ធ្វើការៈ ដែលធ្មេញនិងក្រចកបាក់ដោយការកន្លងផុតនូវវ័យ ។ ដោយបទថា **ចាលិច្ចំ** នេះ ទ្រង់សម្តែងដោយកិច្ច គឺភាពដែលសក់ និងរោមទាំងឡាយស្កូវ ។ ដោយបទថា **វលិត្តចតា** នេះ ទ្រង់សម្តែងដោយកិច្ច គឺការធ្វើសាច់ឲ្យស្ងួត ហើយធ្វើស្បែកឲ្យរួញជាផ្នត់ ព្រោះហេតុនោះ ពាក្យទាំង ៣ មានពាក្យថា ការបាក់ធ្មេញជាដើមនេះ ទើបជាការពង្រីកសេចក្តីដល់កិច្ចក្នុងការកន្លងវ័យនៃរូបជរតានោះ ។ ដោយពាក្យទាំង ៣ នោះ ទ្រង់សម្តែង **ចាកជជរា** គឺការចាស់ដែលប្រាកដដោយអំណាចនៃការឃើញភាពប្រែប្រួលនៃរូបទាំងនេះ ។ ដូចផ្លូវដែលទឹកហូរទៅឬខ្យល់បក់ទៅ រមែងប្រាកដដោយការដែលស្មៅនិងដើមឈើជាដើមត្រូវកាច់បំបាក់ ឬផ្លូវដែលភ្លើងឆេះទៅរមែងប្រាកដដោយដើមឈើស្មៅត្រូវភ្លើងឆេះ តែផ្លូវមានទឹកជាដើមធ្លងកាត់ហើយនោះប្រាកដ តែទឹកជាដើមទាំងនោះនឹងប្រាកដក៏មិនមែនយ៉ាងណា ផ្លូវដែលជរាធ្លងទៅហើយ ដោយអំណាចនៃធ្មេញបាក់ជាដើម ក្នុងអវយវៈមានធ្មេញជាដើមរមែងប្រាកដ សូម្បីបុគ្គលដែលបើកភ្នែកមើល ក៏ឃើញបានតែធ្មេញបាក់ជាដើមប្រាកដ ជរារមែងប្រាកដក៏មិនមែន ព្រោះជរាជារបស់ដែលចក្ខុ-វិញ្ញាណដឹងមិនបាន ។

ដោយប្រភេទបទទាំងនេះថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** ដូច្នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងជរាតាមប្រក្រតី ដោយការអស់ទៅនៃអាយុ និងការចាស់ជុំវិញនៃឥន្ទ្រិយ មានចក្ខុជាដើមដែលដឹងបានយ៉ាងជាក់ច្បាស់ ព្រោះឈានកន្លងវ័យនោះឯង ដោយហេតុនោះ គប្បីជ្រាបបទពីរ

ប្រការក្រោយនេះថា ជាការសម្តែងចេញតាមប្រក្រតីនៃជរតា ។ ក្នុងអាការៈទាំងពីនោះ ព្រោះអាយុរបស់បុគ្គលអ្នកដល់នូវការចាស់ហើយ រមែងថយចុះ ហេតុនោះទើបត្រាស់ជរាដោយសម្ពឹងដល់ផលថា **អាយុនោ សំហានិ** ដូច្នេះ ម្យ៉ាងវិញទៀត ព្រោះក្នុងវេលាដែលមនុស្សនៅក្មេង ឥន្ទ្រិយទាំងឡាយ មានចក្ខុជាដើមថ្លាផូរផង់ អាចទទួលអារម្មណ៍របស់ខ្លួនបានសូម្បីដ៏ល្អិតបានដោយងាយទុ៎ះឯង តែកាលដល់ជរាហើយ ឥន្ទ្រិយទាំងឡាយក៏នឹងចាស់ ព្រិលស្រអាប់ទៅ មិនអាចទទួលអារម្មណ៍របស់ខ្លួនសូម្បីគ្រោតគ្រាតបាន ហេតុនោះទើបត្រាស់ជរាដោយផលូបចារន័យថា ការចាស់ទុំនៃពួកឥន្ទ្រិយ ដូច្នេះ ។

ជរាដែលទ្រង់លើកឡើងសម្តែងទុកយ៉ាងនោះ ទាំងអស់មាន ២ យ៉ាង គឺ បាកដជរា ( ជរាដែលប្រាកដ ) ១ បដិច្ឆន្នជរា ( ជរាដែលបិទបាំង ) ១ ។ បណ្តាជរាទាំង ២ នោះ ជរាក្នុងរូបធម៌ទាំងឡាយ ឈ្មោះថា **បាកដ-ជរា** ព្រោះសម្តែងភាពបែកបាក់ជាដើម ក្នុងអវយវៈមានធ្មេញជាដើម តែជរាក្នុងអរូបធម៌ទាំងឡាយ ឈ្មោះថា **បដិច្ឆន្នជរា** ព្រោះមិនសម្តែងការប្រែប្រួលបែបនោះទេ ។

នៅមានជរា ២ យ៉ាងទៀត គឺ **អវីចិជរា** ( ជរាមិនមានរលក ) ១ **សវីចិជរា** ( ជរាមានរលក ) ១ ។

ក្នុងជរាទាំង ២ យ៉ាងនោះ គប្បីជ្រាបថា ជរាដែលឈ្មោះថា **អវីចិជរា** ព្រោះដឹងការផ្សេងគ្នានៃវណ្ណៈជាដើម ខាងក្នុងចន្លោះៗបានដោយក្រ ដូចជរារបស់កែវមណី មាស ប្រាក់ កែវប្រពាល ព្រះចន្ទ ព្រះអាទិត្យជាដើម ដូច

ជរាបស់សត្វមានជីវិតទាំងឡាយ ក្នុងវេលាដែលតាំងនៅក្នុងមនុស្សកៈវ័យ ( ពីមួយឆ្នាំដល់ដប់ឆ្នាំ ) ជាដើម និងដូចជរារបស់វត្ថុ មិនមានជីវិតទាំងឡាយ មានក្នុងផ្កា ផ្លែឈើនិងស្លឹកឈើជាដើម អធិប្បាយថា **និរន្តរជរា** ។ ចំណែកជរាដែលឈ្មោះថា **សវីចិជរា** ព្រោះដឹងការផ្សេងគ្នានៃវណ្ណៈជាដើម ខាងក្នុងចន្លោះៗ ក្នុងវត្ថុតាមដែលពោលហើយពួកដទៃ ក្រៅពីនោះបានដោយងាយ ដូច្នេះ ។

ពោលដោយលក្ខណៈជាដើម គប្បីជ្រាបថា

រូបជរតា **រូបបរិបាកលក្ខណា** មានការចាស់ដោយជុំវិញនៃរូប ជាលក្ខណៈ **ឧបនយរសា** មានការបង្អោនចូលទៅជិតសេចក្តីស្លាប់ ជាកិច្ច **សភាវានបគមេបិ នវភាវាបគមបច្ចុបដ្ឋានា** មានការប្រាសចាកភាពជារបស់ថ្មី សូម្បីមិនទាន់ប្រាសចាកភាវៈរបស់ខ្លួន ជាអាការប្រាកដ **វីហិបុ-រាណភាវោ វិយ បរិបច្ចមានរូបបទដ្ឋានា** មានរូបដែលចាស់ដូចស្រូវដំណើបចាស់ ជាហេតុជិត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអនិច្ចតារូប ដូចតទៅនេះថា

រូបដែលឈ្មោះថា **ខយោ** ដោយអំណាចនៃការដល់នូវការអស់ទៅ ដែលឈ្មោះថា **វយោ** ដោយអំណាចនៃការដល់សេចក្តីវិនាស ដែលឈ្មោះថា **ភេទោ** ដោយអំណាចនៃការបែកធ្លាយ ។

ម្យ៉ាងទៀត រូបដែលឈ្មោះថា **ខយោ** ព្រោះអត្ថថា ជាទីអស់ទៅ ដែលឈ្មោះថា **វយោ** ព្រោះអត្ថថា ជាទីសូន្យទៅ ដែលឈ្មោះថា **ភេទោ** ព្រោះ

អត្ថថា ជាទីបែកធ្លាយទៅ ព្រោះរូបដល់អាការៈនោះហើយ រមែងអស់ទៅ រមែងសូន្យទៅនិងរមែងបែកធ្លាយទៅ ការបាក់បែកទៅនុ៎ះឯងឈ្មោះថា **បរិភេទោ** ព្រោះទ្រង់បន្ថែមបទឧបសគ្គ ។

សភាវៈដែលឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា មិនទៀង គឺមានហើយប្រែទៅជាមិនមាន ។ ភាវៈនៃអនិច្ចំនោះ ឈ្មោះថា **អនិច្ចតា** ដែលឈ្មោះថា **អន្តរធានំ** ព្រោះអត្ថថា ជាទីអន្តរធានទៅ ។ មែនពិត រូបដល់នូវមរណៈហើយ រមែងអន្តរធានទៅ គឺដល់នូវការមិនឃើញ រូបប៉ុណ្ណោះអន្តរធានទៅតែម្យ៉ាងក៏មិនមែន បញ្ចក្ខន្ធសូម្បីទាំងអស់ ក៏អន្តរធានទៅ ព្រោះហេតុនោះ គប្បីជ្រាបថា រូបនេះឯងជាលក្ខណៈនៃការមិនទៀងនៃខន្ធទាំង ៥ ។ កាលពោលដោយលក្ខណៈជាដើម គប្បីជ្រាបថា

រូបអនិច្ចតា **បរិភេទលក្ខណា** មានការបែកធ្លាយ ជាលក្ខណៈ **សំសីទនរសា** មានការលិចចុះ ជាកិច្ច **ខយវយបច្ចុបដ្ឋានា** មានការអស់ទៅសូន្យទៅ ជាអាការប្រាកដ **បរិភិជ្ជមានរូបបទដ្ឋានា** មានរូបដែលកំពុងបែកធ្លាយទៅជាហេតុជិត ។

កន្លងមកព្រះមានព្រះភាគ ទ្រង់កាន់យកជាតិនិងជរា ម្យ៉ាងទៀត ក្នុងទីនេះ ទ្រង់កាន់យកមរណៈ ។ ធម៌ទាំង ៣ នេះ ដូចបច្ចាមិត្ត ដែលងារដាវឡើងប្រហារសត្វទាំងឡាយនេះ ។ ដូចបច្ចាមិត្ត ៣ នាក់ ត្រាច់ស្វែងរកឱកាសប្រទូស្តបុរស បណ្តាបច្ចាមិត្ត ៣ នាក់នោះ មានម្នាក់និយាយយ៉ាងនេះថា ការនាំបុរសនេះចេញអំពីស្រុក ចូលទៅកាន់ព្រៃ ជាកិច្ចរបស់អញ

បុរសទី ២ និយាយថា ក្នុងវេលាដែលបុរសនោះទៅដល់ព្រៃហើយ ការវាយឲ្យដួលចុះលើផែនដី ជាកិច្ចរបស់អញ បុរសទី ៣ និយាយថា ចាប់ផ្តើមអំពីវេលាដែលបុរសនោះ ដួលចុះលើផែនដីហើយ ការយកដាវកាត់ក្បាលជាកិច្ចរបស់អញដូច្នេះយ៉ាងណា ធម៌ទាំងឡាយនេះ មានជាតិជាដើម មានសភាពបែបនេះក៏យ៉ាងនោះដូចគ្នា **ជាតិ** ដូចបច្ចាមិត្តដែលនាំបុរសចេញអំពីស្រុកឲ្យចូលទៅកាន់ព្រៃ ព្រោះឲ្យសត្វកើតក្នុងទីនោះៗ ។ **ជរា** ដូចបច្ចាមិត្តអ្នកវាយបុរសដែលចូលទៅដល់ព្រៃ ហើយឲ្យដួលលើផែនដី ព្រោះធ្វើខន្ធដែលកើតឡើង ហើយឲ្យទុព្វល ឲ្យអាស្រ័យជនដទៃ ឲ្យផ្តោះមុខទៅកាន់គ្រែដេក ។ **មរណា** ដូចបច្ចាមិត្ត ដែលយកដាវកាត់ក្បាលរបស់បុរសដែលដួលនៅក្នុងព្រៃ ព្រោះធ្វើខន្ធទាំងឡាយដែលដល់ជរាហើយ ឲ្យដល់នូវការអស់ជីវិត ដូច្នេះ ។

[ ៣៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃកពឡិង្ការាហារ ដូចតទៅនេះថា

អាហារដែលឈ្មោះថា **កពឡិង្ការ** ព្រោះត្រូវធ្វើឲ្យជាពំនូត ឈ្មោះថា **អាហារ** ព្រោះអត្ថថា ត្រូវទំពាលេប អធិប្បាយថា បុគ្គលធ្វើពំនូតបាយហើយទំពាលេប ។ ម្យ៉ាងទៀត ដែលឈ្មោះថា **អាហារ** ព្រោះអត្ថថា នាំមកនូវរូប ។

ព្រះមានព្រះភាគ កាលទ្រង់លើកឈ្មោះឡើងសម្តែង ដោយអំណាចនៃវត្ថុយ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងអាហារនោះឯង ដោយអំណាចនៃវត្ថុទៀតទើបត្រាស់ពាក្យថា **ឱទនោ កុម្មាសោ** ដូច្នេះជាដើម មែនពិត អាហារ

១២ យ៉ាង មានបាយជាដើម មានទឹកអំពៅជាទីបំផុត ជាអាហារវត្ថុដែលទ្រង់បំណាងយកក្នុងទីនេះ ។ អាហារមានឫសឈើនិងផ្លែឈើជាដើម ដែលមិនបានត្រាស់ទុកក្នុងព្រះបាលី ក៏រួមចូលក្នុងយេវាបនកធម៌ ។

ឥឡូវនេះ ដើម្បីសម្តែងអាហារទាំងនោះ មានឫសឈើ ផ្លែឈើជាដើម ដោយសភាពដែលសត្វទាំងឡាយគប្បីធ្វើ ទើបត្រាស់ពាក្យថា **យម្ហិ យម្ហិ ជនបទេ** ជាដើម ។ ក្នុងព្រះបាលីនោះ គប្បីជ្រាបវិគ្គហៈ ដូចតទៅនេះថា អាហារដែលឈ្មោះថា **មុខាសិយំ** ព្រោះអត្ថថា គប្បីលេប គឺគប្បីបរិភោគតាមមាត់ ។ ដែលឈ្មោះថា **ទន្តវិខាទនំ** ព្រោះអត្ថថា ដែលសត្វគប្បីទំពាដោយធ្មេញ ។ ដែលឈ្មោះថា **គលជ្ឈោហរណីយំ** ព្រោះអត្ថថា ដែលសត្វគប្បីលេបតាមបំពង់ក ។ ឥឡូវនេះទ្រង់បំណាងសម្តែងអាហារនោះ ដោយអំណាចនៃកិច្ច ទើបត្រាស់ពាក្យជាដើមថា **កុច្ឆិវិត្ថម្ភនំ** ដូច្នេះ ។ មែនពិតអាហារនោះ មានឫសឈើនិងផ្លែឈើជាដើម ឬមានបាយនិងនំស្រស់ជាដើម ដែលសត្វលេបហើយ រមែងផ្អែតផ្ទៃ នេះជាកិច្ចរបស់អាហារនោះ ។

បទថា **យាយ ឱជាយ សត្តា យាបេន្តិ** សេចក្តីថា ព្រះមានព្រះភាគកាលទ្រង់សម្តែងអាហារដែលជាវត្ថុដោយបទទាំងពួងខាងដើមហើយ ឥឡូវនេះ ទ្រង់បំណាងសម្តែងឱជាប៉ុណ្ណោះ ដែលអាហារឲ្យកើតហើយទើបត្រាស់ពាក្យនេះទុក ។

សួរថា បណ្តាអាហារដែលជាវត្ថុនិងឱជាទាំងនេះ កិច្ចរបស់វត្ថុ តើដូចម្តេច កិច្ចរបស់ឱជា តើដូចម្តេច ឆ្លើយថា វត្ថុនិងឱជាទាំងនោះមានការកម្ចាត់

អន្តរាយនិងការរក្សារាងកាយជាកិច្ច មែនពិត អាហារដែលជាវត្ថុ រមែងនាំអន្តរាយចេញ តែមិនអាចដើម្បីរក្សារាងកាយ អាហារដែលជាឱជា រមែងរក្សារាងកាយតែមិនអាចដើម្បីនាំអន្តរាយចេញទៅ ។ អាហារសូម្បីទាំង ២ រួមគ្នាហើយរមែងអាចដើម្បីរក្សា រមែងអាចដើម្បីនាំចេញនូវអន្តរាយ ។

សួរថា អ្វីឈ្មោះថាជាអន្តរាយ ឆ្លើយថា តេជោធាតុដែលកើតអំពីកម្ម ។ មែនពិត កាលវត្ថុមានបាយជាដើម មិនមានខាងក្នុងពោះ តេជោធាតុដែលកើតអំពីកម្មតាំងឡើង ដុតរម្អិលក្រពះអាហារ រមែងញុំាងបុគ្គលឲ្យនិយាយថា ខ្ញុំឃ្លានហើយចូរឲ្យអាហារមកចុះ ក្នុងវេលាដែលបរិភោគអាហារហើយ តេជោធាតុ ដែលកើតអំពីកម្មនោះ ក៏លះបង់រម្អិលក្រពះអាហារ ទៅដុតវត្ថុ ( ដែលជាអាហារ ) ។ ពេលនោះសត្វក៏មានចិត្តស្ងប់ ។

ដូចឆាយារក្ខសៈ ( អារក្សដែលចាប់សត្វចូលទៅកាន់ស្រមោលដើមឈើ ) ចាប់សត្វដែលចូលទៅកាន់ស្រមោលដើមឈើ យកច្រវ៉ាក់ទិព្វចងលាមទុក រីករាយចិត្តនៅក្នុងលំនៅរបស់ខ្លួន ពេលឃ្លានក៏មកខាំត្រង់ក្បាលសត្វនោះរមែងស្រែក ព្រោះត្រូវអារក្សស៊ី ពួកមនុស្សស្តាប់សំឡេងស្រែកនោះក៏នាំគ្នាមកអំពីទីនោះៗដោយសម្គាល់ថា ក្នុងទីនេះ មានសត្វដែលបានទទួលទុក្ខ ឆាយារក្ខសៈនោះ ក៏ចាប់មនុស្សដែលមកហើយៗទំពាស៊ីហើយសប្បាយចិត្ត ក្នុងលំនៅរបស់ខ្លួនយ៉ាងណា ពាក្យឧបមេយ្យជាគ្រឿងប្រៀបធៀបនេះ គប្បីជ្រាបយ៉ាងនោះ ។ តេជោធាតុដែលកើតអំពីកម្ម ប្រៀបដូចឆាយារក្ខសៈ ។ រម្អិលក្រពះអាហារ ប្រៀបដូចសត្វដែលត្រូវឆាយារក្ខសៈ

យកប្រាក់ទិព្វលាមទុក ។ វត្ថុមានបាយជាដើម ប្រៀបដូចពួកមនុស្សដែលមកទៀត ។ ការដែលតេជោធាតុកើតអំពីកម្ម លះបង់វត្ថុ ( អស់អាហារ ) ហើយកាន់យករម្អិលក្រពះអាហារ ប្រៀបដូចធាយារក្ខសៈ ចុះមកខាំត្រង់ក្បាល ។ វេលាដែលប្រាប់ថា អ្នកចូរឲ្យអាហារ ប្រៀបដូចវេលាដែលសត្វត្រូវខាំហើយស្រែក កាលតេជោធាតុកើតអំពីកម្មលះបង់រម្អិលក្រពះអាហារទៅចាប់យកវត្ថុ ( អាហារ ) សត្វទាំងឡាយ ក៏មានចិត្តស្ងប់ ប្រៀបដូចវេលាដែលធាយារក្ខសៈ ចាប់ពួកមនុស្សដែលមកហើយ ដោយសញ្ញានោះទំពាស៊ីសប្បាយចិត្ត នៅក្នុងលំនៅរបស់ខ្លួន ។

បណ្តាអាហារទាំងនោះ ក្នុងវត្ថុគ្រោតគ្រាតឱជាមានកម្លាំងតិច ក្នុងវត្ថុល្អិតឱជាមានកម្លាំងច្រើន មែនពិត បុគ្គលបរិភោគអាហារមានស្មៅគែលលកជាដើម មួយស្របក់ប៉ុណ្ណោះក៏ឃ្លាន បុគ្គលផឹកទឹកដោះថ្លាជាដើម សូម្បីតាំងនៅពេញមួយថ្ងៃ ក៏មិនចង់បរិភោគបាយ ។ មួយទៀត ក្នុងសេចក្តីនេះគប្បីជ្រាបសេចក្តីគ្រោតគ្រាតនិងល្អិតដោយអាស្រ័យការប្រៀបធៀបគ្នា ។

មែនពិត កាលប្រៀបធៀបអាហាររបស់ពួកក្រពើហើយ អាហាររបស់ពួកក្ងោកក៏ល្អិត ។ បានឮថា ពួកក្រពើលេបដុំថ្មចូលទៅ ថ្មទាំងនោះ ដល់ពោះរបស់ក្រពើហើយក៏រមែងរលាយទៅ ពួកក្ងោករមែងស៊ីសត្វមានពស់និងខ្យដាដើម តែប្រៀបធៀបអាហារ របស់ពួកក្ងោកហើយ អាហាររបស់ពួកខ្លារខិនក៏ល្អិតជាង បានឮថា ពួកខ្លារខិនទាំងនោះ ស៊ីស្នែងនិងឆ្អឹងសត្វដែលបោះបង់ចោលដល់ ៣ ឆ្នាំបាន ។ ស្នែងនិងឆ្អឹងសត្វទាំងនោះ គ្រាន់តែសើម

ទឹកមាត់របស់ខ្វាវទិនទាំងនោះ ក៏ទន់ដូចមើមដំឡូង ។ ប្រៀបធៀបអាហារ របស់ខ្វាវទិនទាំងនោះហើយ អាហាររបស់ពួកដំរីល្អិតជាង ព្រោះពួកដំរីទាំងនោះ រមែងស៊ីមែកឈើផ្សេងៗជាដើមបាន អាហាររបស់ពួកគោព្រៃ ខ្ទីងនិងម្រឹគជាដើម ល្អិតជាងអាហាររបស់ពួកដំរី ។ បានឮថា ពួកគោព្រៃ ខ្ទីងនិងម្រឹគទាំងនោះ ទំពាស៊ីស្លឹកឈើផ្សេងៗជាដើម ដែលមិនមានខ្លឹម អាហារពួកគោស្រុក ល្អិតជាងអាហាររបស់សត្វ មានគោព្រៃជាដើមទាំងនោះ ពួកគោស្រុក រមែងទំពាស៊ីស្មៅស្រស់និងស្មៅស្ងួត អាហាររបស់ពួកទន្សាយល្អិតជាងអាហាររបស់ពួកគោទាំងនោះ អាហាររបស់ពួកបក្សីល្អិតជាងអាហាររបស់ពួកទន្សាយ អាហាររបស់ពួកជនអ្នកនៅក្នុងបច្ចន្តប្រទេស ល្អិតជាងអាហាររបស់ពួកបក្សី អាហាររបស់ពួកមេស្រុក ល្អិតជាងអាហាររបស់ពួកបច្ចន្តប្រទេស អាហាររបស់ព្រះរាជានិងរាជមហាមាត្យល្អិតជាងអាហាររបស់ពួកមេស្រុក អាហាររបស់ស្តេចចក្កពត្តិ ល្អិតជាងអាហាររបស់ព្រះរាជានិងមហាមាត្យទាំងនោះ អាហាររបស់ពួកភុម្មទេវតាល្អិតជាងអាហាររបស់ស្តេចចក្កពត្តិ អាហាររបស់ពួកចាតុម្មហារាជិកា ល្អិតជាងអាហាររបស់ពួកភុម្មទេវតា ។ ដោយអាការយ៉ាងនេះ គប្បីឲ្យពិស្តារទៅរហូតដល់អាហាររបស់ពួកទេវតាបរនិម្មិតវសវត្តី ។ អាហាររបស់ទេវតាបរនិម្មិតវសវត្តីទាំងនោះ ដល់នូវទីបំផុតហើយ ថាល្អិតបំផុត ។

ពោលដោយលក្ខណៈជាដើម

កពឡិង្ការាហារ **ឱជាលក្ខណោ** មានឱជាជាលក្ខណៈ **រូបាហារណោ-**

**រសោ** មានការនាំមកនូវរូបជាកិច្ច **ឧបត្ថម្ភនបច្ចុបដ្ឋានោ** មានការឧបត្ថម្ភជាអាការប្រាកដ **កពឡំ កត្វា អាហរិតព្វវត្ថុបទដ្ឋានោ** មានវត្ថុដែលបុគ្គលធ្វើជាពំនូតបាយហើយទំពាលេបជាហេតុជិត ។

[ ៣៩ ] គប្បីជ្រាបវិគ្គហៈក្នុងនិទ្ទេសនៃ **នោ ឧបាទា** ដូចតទៅនេះថា

ឧបាទារូបនេះ រមែងអាស្រ័យរូបដទៃតែម្យ៉ាង រមែងមិនឲ្យរូបដទៃអាស្រ័យយ៉ាងណា រូបនេះរមែងមិនអាស្រ័យរូបដទៃ ក៏យ៉ាងនោះឯង ព្រោះហេតុនោះទើបរូបនោះឈ្មោះថា **នោ ឧបាទា** ។

[ ៤០ ] ដែលឈ្មោះថា **ផោដ្ឋព្វំ** ព្រោះអត្ថថា ដែលកាយគប្បីពាល់ត្រូវ អធិប្បាយថា ពាល់ត្រូវហើយទើបដឹង ។ រូបនោះជាផោដ្ឋព្វៈផង ជាអាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា ផោដ្ឋព្វាយតនៈ ។ រូបនោះជាអាបោផង ជាធាតុផង ដោយអត្ថថា មិនមែនសត្វ ទទេ និងជាសភាវៈ ព្រោះហេតុនោះ ទើបឈ្មោះថា **អាបោធាតុ** ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងចែករូបទាំង ៣ ដែលកាយពាល់ត្រូវហើយគប្បីដឹងបានទាំងនោះ ទើបត្រាស់ថា រូបជាផោដ្ឋព្វាយតនៈនោះ តើដូចម្តេច រូបជាបឋវីធាតុជាដើម ។

បណ្តាធាតុទាំងនោះ បឋវីធាតុ **កក្ខឡត្តលក្ខណា** មានការរឹង ជាលក្ខណៈ **បតិដ្ឋានរសា** មានការតាំងមាំ ជាកិច្ច **សម្បដិច្ឆនបច្ចុបដ្ឋានា** មានការទទួល ជាអាការប្រាកដ ។

តេជោធាតុ **ឧណ្ហត្តលក្ខណា** មានការក្តៅជាលក្ខណៈ **បរិបាចនរសា**

មានការធ្វើឲ្យផ្អិន ( ការរមួយ ) ជាកិច្ច **មន្ទ៉ានុប្បទានបច្ចុបដ្ឋានា** មានការធ្វើឲ្យទន់ជាអាការប្រាកដ ។

វាយោធាតុ **វិត្ថម្ភនលក្ខណា** មានការតឹងជាលក្ខណៈ **សមុទីរណរសា** មានការកម្រើកញ័រជាកិច្ច **អភិនីហារបច្ចុបដ្ឋានា** មានការបង្អោនទៅ ជាអាការប្រាកដ ។

ចំណែកអាបោធាតុខាងដើម **បគ្ឃរណលក្ខណា** មានការហូរទៅ ជាលក្ខណៈ **ព្រូហនរសា** មានការពង្រីកទៅជាកិច្ច **សង្គហបច្ចុបដ្ឋានា** មានការរួបរួមទុកជាអាការប្រាកដ ក្នុងធាតុទាំង ៤ នោះ ធាតុនីមួយៗគប្បីជ្រាបថា **សេសត្តយបទដ្ឋានា** មានធាតុទាំង ៣ ដ៏សេសជាហេតុជិត ។

បទថា **កក្ខឡំ** បានដល់ រឹង ។ បទថា **មុទុកំ** បានដល់ មិនរឹង ។ បទថា **សណ្ហំ** បានដល់ ល្អិត ។ បទថា **ផរុសំ** បានដល់ គ្រោតគ្រាត ។ បទថា **សុខសម្ផស្សំ** បានដល់ មានសុខវេទនាជាបច្ច័យ គឺមានផោដ្ឋព្វៈដែលគួរប្រាថ្នា ។ បទថា **ទុក្ខសម្ផស្សំ** បានដល់ មានទុក្ខវេទនាជាបច្ច័យ គឺមានផោដ្ឋព្វៈដែលមិនគួរប្រាថ្នា ។ បទថា **គរុកំ** បានដល់ ពេញទៅដោយការៈ ។ បទថា **លហុកំ** បានដល់ ស្រាល មិនមានការៈធ្ងន់ ។

បណ្តាធាតុទាំងនេះ បឋវីធាតុប៉ុណ្ណោះ ទ្រង់ចែកដោយបទថា រឹង ទន់ ល្អិត គ្រោតគ្រាត ធ្ងន់ ស្រាល ។ សូម្បីក្នុងព្រះសូត្រ ( ទីឃនិកាយ មហាវគ្គ ) ថា កាលណាបើបានប្រកបដោយអាយុផង ប្រកបដោយភ្លើងធាតុផង ប្រកបដោយវិញ្ញាណផង ទើបកាយនេះទៅជាស្រាលជាងផង ទន់

ជាន់ផង គួរដល់ការងារជាន់ផង ដូច្នេះ ត្រាស់សំដៅដល់បឋវីធាតុដែលស្រាលនិងទន់ប៉ុណ្ណោះ ។

ពីរបទថា **សុខសម្ផស្សំ ទុក្ខសម្ផស្សំ** ត្រាស់ចែកមហាភូតរូប ៣ ដ្បិតថា បឋវីធាតុ មានសម្ផស្សជាសុខខ្លះ មានសម្ផស្សជាទុក្ខខ្លះ តេជោធាតុនិងវាយោធាតុក៏ដូចគ្នា ។ បណ្តាធាតុទាំង ៣ នោះ បឋវីធាតុ មានសម្ផស្សជាសុខ គឺថា កាលកូនក្មេងអ្នកមានបាតដៃទន់ គក់ប្របាច់ជើង រមែងធ្វើអាការៈ គឺឲ្យបុគ្គលត្រេកអរហើយពោលថា ឯងចូរគក់ប្របាច់ចុះ ដូច្នេះ ។ តេជោធាតុ មានសម្ផស្សជាសុខក្នុងរដូវរងា កាលបុគ្គលនាំយកអំបែងដាក់រងើកភ្លើងមកអប់កាយ រមែងធ្វើអាការៈ គឺឲ្យត្រេកអរហើយពោលថា អប់ចុះបា ។ វាយោធាតុមានសម្ផស្សជាសុខក្នុងរដូវក្តៅ កាលកិក្ខុកំលោះដែលដល់ព្រមដោយវត្ត បក់ផ្ចិតរមែងធ្វើអាការៈ គឺឲ្យត្រេកអរ ហើយពោលថា បក់ចុះបា ។

តែកាលក្មេងកំលោះមានដៃរឹងគក់ប្របាច់ជើងទាំងពីរ រមែងដូចជាវេលាដែលឆ្អឹងទាំងឡាយនឹងបែកទៅ សូម្បីគេក៏ត្រូវពោលថា ចូរឯងចេញទៅ ។ ក្នុងរដូវក្តៅ កាលមានមនុស្សនាំអំបែងរងើកភ្លើងមកឲ្យ ក៏នឹងត្រូវពោលថា ឯងចូរនាំវាចេញទៅ ។ ក្នុងរដូវរងាកាលមានមនុស្សបក់ឲ្យក៏នឹងត្រូវពោលថា ចូរចេញទៅ កុំមកបក់យើង ។ គប្បីជ្រាបភាពដែលធាតុទាំង ៣ នោះមានសម្ផស្សជាសុខនិងជាទុក្ខ ដោយប្រការដូច្នេះ ។

វារៈ ១៣ ដែលប្រដាប់ដោយន័យមួយវារៈ ៤ ន័យ ដែលត្រាស់ទុក

ដោយន័យជាដើមថា **យំ ផោដ្ឋព្វំ អនិទស្សនំ សប្បដិឃំ** ដូច្នេះ គប្បី ជ្រាបដោយន័យដែលពោលទុកហើយ ក្នុងរូបាយតនៈជាដើមនុ៎ះឯង ។

សួរថា មហាភូតរូបទាំង ៣ នេះ មកកាន់គន្លងព្រមគ្នាឬ ឆ្លើយថា មកព្រមគ្នា ។ សួរថា មហាភូតរូប ៣ មកហើយយ៉ាងនេះ ប៉ះខ្ទប់នឹងកាយ-បសាទឬទេ ឆ្លើយថា ប៉ះខ្ទប់ ។ សួរថា កាយវិញ្ញាណធ្វើមហាភូតរូបទាំង ៣ នេះ ឲ្យជាអារម្មណ៍កើតឡើងព្រមគ្នាដែរឬទេ ឆ្លើយថា មិនកើតឡើងព្រមគ្នាទេ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការដែលកាយវិញ្ញាណធ្វើមហាភូតរូប ៣ ឲ្យជាអារម្មណ៍ រមែងមានដោយអំណាចការគិតដល់ ឬដោយអំណាចធាតុដែលមានច្រើន ។

បណ្តាបទទាំង ២ នោះ ពោលដោយការនឹកគិតមុន មែនពិត កាលជនយកបាយដាក់បាត្រហូតពេញនាំមកហើយ ភិក្ខុក៏ចាប់គ្រាប់បាយមួយគ្រាប់មកពិសោធមើលថា រឹងឬទន់ ក្នុងគ្រាប់បាយមួយគ្រាប់នោះ តេជោធាតុក៏មាន វាយោធាតុក៏មានក៏ពិត ទោះបីជាដូច្នោះ ក៏រមែងនឹកគិតដល់បឋវីធាតុប៉ុណ្ណោះ ។ កាលបុគ្គលលូកដៃចូលក្នុងទឹកក្តៅ សាកមើលក្នុងទឹកក្តៅនោះ បឋវីធាតុក៏មាន វាយោធាតុក៏មាន ក៏ពិត តែបុគ្គលនឹកគិតដល់តេជោធាតុប៉ុណ្ណោះ ។ ក្នុងរដូវក្តៅ បុគ្គលបើកបង្អួចឲ្យខ្យល់បក់ប៉ះនឹងសរីរៈឈរនៅ កាលខ្យល់តិចៗ បក់មក ក្នុងខ្យល់តិចៗដែលបក់មកនោះ បឋវីធាតុក៏មាន តេជោធាតុក៏មានក៏ពិត តែបុគ្គលគិតដល់វាយោធាតុប៉ុណ្ណោះ កាយវិញ្ញាណ-ធាតុ ឈ្មោះថា រមែងធ្វើមហាភូតរូប ៣ ឲ្យជាអារម្មណ៍ដោយអំណាចនៃ

ការនឹកគិត ដោយប្រការដូច្នេះ ។

ចំណែកបុគ្គលណារមិលដួលក្តី ក្បាលបុកនឹងដើមឈើក្តី កំពុងបរិភោគអាហារខាំចំដុំក្រួសក្តី ក្នុងការរមិលដួលជាដើមនោះ តេជោធាតុក៏មាន វាយោធាតុក៏មាន ក៏ពិត តែបុគ្គលនោះរមែងធ្វើចំពោះបឋវីធាតុប៉ុណ្ណោះ ឲ្យជាអារម្មណ៍ដោយអំណាចធាតុដែលមានច្រើន បុគ្គលកាលជាន់ភ្លើងក្តី ក្នុងភ្លើងនោះ បឋវីធាតុក៏មាន វាយោធាតុក៏មានក៏ពិត តែបុគ្គលក៏ធ្វើចំពោះតេជោធាតុប៉ុណ្ណោះ ឲ្យជាអារម្មណ៍ដោយអំណាចនៃធាតុដែលមានច្រើន ។ កាលខ្យល់ខ្លាំងបក់ប៉ះក្រដាសត្រចៀក ដូចធ្វើឲ្យត្រចៀកថ្លង់ ក្នុងខ្យល់ខ្លាំងនោះ បឋវីធាតុក៏មាន តេជោធាតុក៏មានក៏ពិត តែបុគ្គលក៏ធ្វើចំពោះវាយោធាតុប៉ុណ្ណោះ ឲ្យជាអារម្មណ៍ដោយអំណាចនៃធាតុដែលមានច្រើន ។

បុគ្គលកាលធ្វើនូវធាតុយ៉ាងណាទីមួយ ឲ្យជាអារម្មណ៍ សូម្បីកាយវិញ្ញាណក៏មិនកើតឡើងព្រមគ្នា ។ កាលបុគ្គលត្រូវម្ជុលទាំងប៉ៅ ចាក់ហើយ កាយត្រូវម្ជុលទាំងនោះប៉ះខ្ទប់ព្រមគ្នា តែក្នុងទីណាៗ កាយបសាទមានច្រើន ក្នុងទីនោះៗ កាយវិញ្ញាណរមែងកើតឡើង សូម្បីក្នុងទីណាៗមានការប៉ះខ្ទប់ទង្គិកទង្គិចខ្លាំង ក្នុងទីនោះៗកាយវិញ្ញាណរមែងកើតឡើងមុន ។ កាលយករោមមាន់មកដុសលាងដំបៅ សរសៃរោមមាន់មួយសរសៃៗរមែងប៉ះខ្ទប់នឹងកាយបសាទក្នុងទីណាៗ កាយបសាទមានច្រើនក្នុងទីនោះៗនុ៎ះឯង កាយវិញ្ញាណ រមែងកើតឡើង បុគ្គលធ្វើធាតុទាំង ៣ ឲ្យជាអារម្មណ៍ ដោយអំណាចនៃធាតុដែលមានច្រើនយ៉ាងនេះ កាយវិញ្ញាណឈ្មោះថា រមែងកើត

ឡើង ដោយអំណាចនៃធាតុដែលមានច្រើនទុំះឯង ។

សួរថា ចិត្តសោត ផ្លាស់ប្តូរទៅចាកអារម្មណ៍បានយ៉ាងដូចម្តេច ឆ្លើយថា ផ្លាស់ប្តូរទៅដោយអាការៈ ២ យ៉ាង គឺដោយអធ្យាស្រ័យ ឬដោយអារម្មណ៍ដ៏មានកម្លាំង ។

ពិតណាស់ ក្នុងវេលាដែលមានបុណ្យឆ្លងព្រះវិហារជាដើម បុគ្គលទៅដោយអធ្យាស្រ័យថា អញនឹងថ្វាយបង្គំព្រះចេតិយ និងថ្វាយបង្គំព្រះបដិមានោះៗ អញនឹងមើលបោត្ថកម្ម ( មើលសៀវភៅ ) និងចិត្រកម្ម ( ការគូរគំនូរ ) ដូច្នេះ ថ្វាយបង្គំ ឬឃើញវត្ថុយ៉ាងណានីមួយ ហើយតាំងចិត្តដើម្បីថ្វាយបង្គំ ឬដើម្បីមើលវត្ថុក្រៅនេះហើយ ក៏ទៅដើម្បីថ្វាយបង្គំខ្លះ ដើម្បីមើលខ្លះ នោះឯង ។ យ៉ាងនេះ ចិត្តឈ្មោះថា ផ្លាស់ប្តូរទៅដោយអធ្យាស្រ័យ ។ តែកាលបុគ្គល ឈរសម្លឹងមើលមហាចេតិយ ដែលមានចំណែកប្រៀបដូចកំពូលភ្នំកៃលាស វេលាតមកកាលតន្ត្រីទាំងពួងបន្លឺឡើង ទើបចិត្តលះបង់រូបារម្មណ៍ផ្លាស់ប្តូរមកកាន់សទ្ទារម្មណ៍ កាលបុគ្គលនាំផ្កាឈើឬគ្រឿងក្រអូបដែលមានក្លិនគួរពេញចិត្តមក ក៏លះបង់សទ្ទារម្មណ៍ ផ្លាស់ប្តូរមកកាន់គន្ធារម្មណ៍យ៉ាងនេះ ចិត្តឈ្មោះថា ផ្លាស់ប្តូរទៅដោយអារម្មណ៍ដ៏មានកម្លាំង ។

[ ៤១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអាបោធាតុ ដូចតទៅនេះថា

បទថា **អាបោ** ជាការសម្តែងសភាវៈ ។ ការជ្រួបជ្រាបនោះឯង ឈ្មោះថា **អាបោគតំ** ។ ឈ្មោះថា **សិនេហោ** ដោយអំណាចនៃភាពស្អិត ។ ភាពស្អិតនោះឯង ឈ្មោះថា **សិនេហគតំ** ។ បទថា **ពន្ធនត្តំ រូបស្ស** បាន

ដល់ ធម្មជាតជាគ្រឿងប្រមូលផ្តុំភូតរូប មានបឋវីធាតុជាដើម ។ មែនពិត អាបោធាតុប្រមូលផ្តុំវត្ថុទាំងឡាយ មានដុំដែកជាដើមទុកហើយ រមែងធ្វើឲ្យជាប់គ្នា ។ វត្ថុទាំងឡាយ មានដុំដែកជាដើមទាំងនោះ ឈ្មោះថា ជាប់តគ្នា ព្រោះអាបោធាតុនោះប្រមូលផ្តុំទុក ។ សូម្បីក្នុងផ្ទាំងថ្ម ភ្នំ គ្រាប់ត្នោត ភ្លុកដំរី និងស្នែងគោជាដើមក៏ន័យនេះដូចគ្នា ។ អាបោធាតុប៉ុណ្ណោះប្រមូលផ្តុំវត្ថុទាំងអស់នោះធ្វើឲ្យជាប់គ្នា ។ វត្ថុទាំងនោះ ឈ្មោះថា ជារបស់ជាប់តគ្នាក៏ព្រោះត្រូវអាបោធាតុប្រមូលផ្តុំទុក ។

សួរថា បឋវីធាតុប៉ះខ្ទប់ហើយ ជាទីតាំងអាស្រ័យ ឬមិនប៉ះខ្ទប់ក៏ជាទីតាំងអាស្រ័យដល់ធាតុដ៏សេស ម្យ៉ាងទៀត អាបោធាតុកាលប្រមូលផ្តុំធាតុទាំង ៣ ដ៏សេស ប៉ះខ្ទប់ហើយប្រមូលផ្តុំ ឬមិនប៉ះខ្ទប់ហើយក៏ប្រមូលផ្តុំបាន ឆ្លើយថា ខាងដើម បឋវីធាតុមិនប៉ះខ្ទប់ ក៏ជាទីអាស្រ័យដល់អាបោធាតុបាន តែសម្រាប់តេជោធាតុនិងវាយោធាតុ បឋវីធាតុត្រូវប៉ះខ្ទប់ ទើបជាទីតាំងអាស្រ័យឲ្យបាន ចំណែកអាបោធាតុ មិនប៉ះខ្ទប់បឋវីធាតុ តេជោធាតុនិងវាយោធាតុក៏ប្រមូលផ្តុំបាន ។ បើអាបោធាតុប៉ះខ្ទប់ហើយ គប្បីប្រមូលផ្តុំសោតអាបោធាតុនោះក៏គប្បីឈ្មោះថា ផោដ្ឋព្វាយតនៈ ។

សូម្បីក្នុងការដែលតេជោធាតុនិងវាយោធាតុ ធ្វើកិច្ចរៀងៗខ្លួន ក្នុងធាតុដ៏សេសក៏ន័យនេះដូចគ្នា ។ មែនពិត តេជោធាតុប៉ះខ្ទប់ហើយដុតបឋវីធាតុ តែបឋវីធាតុនោះមិនមែនជារបស់ក្តៅហើយទើបឆេះ បើបឋវីធាតុគប្បីជារបស់ក្តៅហើយសោត បឋវីធាតុក៏គប្បីឈ្មោះថាមានការក្តៅជាលក្ខណៈ ។ មួយ

ទៀត តេជោធាតុមិនបានប៉ះខ្ទប់អាបោធាតុ ក៏ធ្វើអាបោធាតុនោះឲ្យក្តៅបាន ។ អាបោធាតុនោះ កាលត្រូវដុតក៏មិនជារបស់ក្តៅហើយដុត ។ បើអាបោធាតុនោះគប្បីជារបស់ក្តៅហើយដុតសោត អាបោធាតុនោះក៏គប្បីឈ្មោះថា មានការក្តៅជាលក្ខណៈ ។ មួយទៀត តេជោធាតុនោះ ប៉ះខ្ទប់នឹងវាយោធាតុហើយនោះឯង ទើបធ្វើវាយោធាតុឲ្យក្តៅបាន ។ វាយោធាតុនោះ កាលដុតក៏មិនមែនជារបស់ក្តៅហើយទើបដុត បើវាយោធាតុជារបស់ក្តៅ ហើយទើបដុតសោត វាយោធាតុនោះក៏គប្បីឈ្មោះថា មានការក្តៅជាលក្ខណៈ ។ វាយោធាតុប៉ះខ្ទប់នឹងបឋវីធាតុហើយ ក៏ធ្វើឲ្យតឹង ពាល់ត្រូវតេជោធាតុក៏ធ្វើឲ្យតឹងដូចគ្នា ។ វាយោធាតុនោះ សូម្បីមិនប៉ះខ្ទប់អាបោធាតុ ក៏ធ្វើឲ្យតឹងបាន ។

សួរថា កាលបុគ្គលរំលាស់ទឹកអំពៅធ្វើជាស្ករ អាបោធាតុនឹងជារបស់រឹងឬទេ ឆ្លើយថា មិនជារបស់រឹងទេ ព្រោះអាបោធាតុនោះ មានការហូរ ជាលក្ខណៈ បឋវីធាតុមានការរឹង ជាលក្ខណៈ តែអាបោធាតុមានប្រមាណតិចក៏ប្រព្រឹត្តទៅតាមបឋវីធាតុដែលមានប្រមាណច្រើន ។ មែនពិត អាបោធាតុនោះរមែងលះភាវៈដែលតាំងនៅដោយអាការជាកិច្ច តែមិនលះលក្ខណៈ ។ កាលរំលាយស្ករអំពៅ បឋវីធាតុរមែងមិនរលាយ ព្រោះបឋវីធាតុមានការរឹង ជាលក្ខណៈ អាបោធាតុមានការហូរទៅ ជាលក្ខណៈ តែបឋវីធាតុមានប្រមាណតិច ក៏នឹងប្រព្រឹត្តទៅតាមអាបោធាតុ ដែលមានប្រមាណច្រើន ។ បឋវីធាតុនោះ រមែងលះភាវៈដែលតាំងនៅដោយអាការជាដុំ តែមិនលះលក្ខណៈ ព្រោះថា មហាភូតរូបទាំង ៤ រមែង មានភាវៈកើតដោយប្រការ

ដទៃបាន តែមានលក្ខណៈកើតដោយប្រការដទៃមិនមាន ។ ការមិនមានលក្ខណៈកើតដោយប្រការដទៃនោះ ទ្រង់សម្ដែងទុក ដោយអដ្ឋានបរិកប្បសូត្រ ។ សេចក្ដីនេះសមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយតិកនិបាត ) ថា ម្នាលអានន្ទ សេចក្ដីប្រែប្រួលមានចំពោះតែមហាភូតរូប ៤ គឺបឋវីធាតុ ។បេ។ វាយោធាតុ ឯសេចក្ដីប្រែប្រួល របស់អរិយសាវក ដែលប្រកបដោយសេចក្ដីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធ មិនមានសោះឡើយ ដូច្នេះ ក្នុងអដ្ឋានបរិកប្បសូត្រនេះ មានអធិប្បាយដូច្នេះថា ម្នាលអានន្ទ បឋវីធាតុ ដែលមានភាពរឹងជាលក្ខណៈ នឹងគប្បីផ្លាស់ប្ដូរទៅជាអាបោធាតុ ដែលមានការហូរទៅជាលក្ខណៈបាន តែព្រះអរិយសាវក ឈ្មោះថា កើតដោយប្រការដទៃមិនមាន ដូច្នេះ ការកំណត់អដ្ឋានៈ ( ហេតុដែលប្រព្រឹត្តទៅមិនបាន ) មកហើយក្នុងព្រះបាលីនេះ ដោយប្រការដូច្នេះ ។

[ ៤២-៤៨ ] គប្បីជ្រាបពាក្យអធិប្បាយនៃឧបាទិន្នរូបជាដើមក្នុងនិទ្ទេសនៃឧបាទិន្នរូបជាដើមដទៃអំពីនេះ ដោយន័យដែលពោលហើយ ក្នុងមាតិកានោះឯង ។ ពាក្យអធិប្បាយចក្ខាយតនៈជាដើម ខ្ញុំឲ្យពិស្ដារហើយក្នុងខាងដើមនោះឯង តែខ្ញុំនឹងពោលចំពោះអត្ថដែលផ្សេងគ្នាក្នុងទីនោះៗប៉ុណ្ណោះ ។

ជាបឋមក្នុងនិទ្ទេសនៃឧបាទិន្នរូប ព្រះមានព្រះភាគ ត្រាស់រូបទាំងឡាយមានចក្ខាយតនៈជាដើម ព្រោះជារូបមានចិត្តគ្រប់គ្រងតែម្យ៉ាង ។ តែព្រោះរូបាយតនៈជាដើមមានចិត្តគ្រប់គ្រងក៏មាន មិនមានចិត្តគ្រប់គ្រងក៏មាន ហេតុនោះ ទើបទ្រង់សម្ដែងដោយសង្ខេបថា **យំ វា បន** ហើយឲ្យពិស្ដារទៀត

ដោយន័យថា **កម្មស្ស កតត្តា រូបាយតនំ** ជាដើម ។ សេចក្តីក្នុងយោវា-បនកធម៌ទាំងអស់ គប្បីជ្រាបដោយឧបាយនេះ ។

សួរថា ព្រោះហេតុអ្វី ទើបទ្រង់មិនបានកាន់យករូបជរតានិងរូបអនិច្ចតា ក្នុងនិទ្ទេសនៃឧបាទិន្នរូបនិងអនុបាទិន្នរូបទាំង ២ ដែលថា **កម្មស្ស កតត្តា** និង **ន កម្មស្ស កតត្តា** តែទ្រង់កាន់យកចំពោះក្នុងនិទ្ទេសទាំងឡាយនៃអនុបាទិន្នរូបជាដើមប៉ុណ្ណោះ ឆ្លើយថា ក្នុងបទថា **ន កម្មស្ស កតត្តា** នេះ ទ្រង់រួមរូបដែលមានសមុដ្ឋានកើតអំពីបច្ច័យដទៃ ក្រៅអំពីកម្ម តែក្នុងបទថា **កម្មស្ស កតត្តា** នេះ ទ្រង់រួមរូបដែលមានសមុដ្ឋានកើតអំពីកម្មតែម្យ៉ាង ។ ម្យ៉ាងទៀត រូបទាំង ២ គឺរូបជរតានិងរូបអនិច្ចតាទាំងនេះ មិនបានកើតអំពីកម្ម មិនបានកើតអំពីបច្ច័យដែលញុំាងរូបឲ្យកើតយ៉ាងដទៃ ព្រោះហេតុនោះ ទើបទ្រង់មិនកាន់យក ។ ការមិនកើតឡើងនៃរូបជរតានិងរូបអនិច្ចតាជាដើម នោះនឹងជាក់ច្បាស់ខាងមុខ ។ តែក្នុងបទជាដើមថា **អនុបាទិន្នំ** ទ្រង់បដិ-សេធរូប មានសមុដ្ឋានកើតអំពីកម្មជាដើមដោយសព្ទថា **អនុបាទិន្ន** ជាដើម ត្រឹមតែម្យ៉ាង តែទ្រង់មិនបានប្រារព្ធថា រូបមានសមុដ្ឋានកើតអំពីបច្ច័យដទៃ ព្រោះហេតុនោះ ក្នុងនិទ្ទេសនៃអនុបាទិន្នរូបនោះ គប្បីជ្រាបថា ទ្រង់កាន់យករូបជរតានិងរូបអនិច្ចតាទុក ដូច្នេះ ។

[ ៤៩ ] ក្នុងនិទ្ទេសនៃចិត្តសមុដ្ឋាន ព្រះមានព្រះភាគត្រាស់រូបទាំង ២ នេះ គឺកាយវិញ្ញត្តិ វចីវិញ្ញត្តិទុក ព្រោះរូបទាំង ២ នេះ អាស្រ័យមហា-ភូតរូប មានចិត្តជាសមុដ្ឋានតែម្យ៉ាង រមែងប្រាកដ ។ តែកាលពោលដោយ

បរមត្ថហើយ មហាភូតរូប ដែលជាទីអាស្រ័យនៃវិញ្ញត្តិរូបទាំង ២ នោះ ប៉ុណ្ណោះ មានចិត្តជាសមុដ្ឋាន សូម្បីវិញ្ញត្តិរូបទាំង ២ នេះ ក៏ឈ្មោះថាមានចិត្តជាសមុដ្ឋាន ព្រោះអាស្រ័យមហាភូតរូបនោះ ដូចជរា និងមរណៈនៃរូបដែលមិនទៀង ក៏ឈ្មោះថា មិនទៀង ។

[ ៥០ ] សូម្បីក្នុងនិទ្ទេសនៃ **ចិត្តសហភូ** ក៏ន័យនេះដូចគ្នា ។ រូបទាំង ២ ( កាយវិញ្ញត្តិនិងវចីវិញ្ញត្តិដែលជាសហភូ ) នេះប៉ុណ្ណោះ ព្រះមានព្រះភាគត្រាស់ទុក ព្រោះរូបទាំង ២ នេះ ប្រាកដនៅបានរហូតវេលាដែលចិត្តនៅប្រាកដ តែរូបទាំង ២ នេះ មិនបានកើតព្រមគ្នាជាមួយនឹងចិត្ត ដូចភូតរូប និងដូចសម្បយុត្តធម៌ មានចេតនាជាដើម ។

[ ៥១-៦២ ] សូម្បីក្នុងនិទ្ទេសនៃ **ចិត្តានុបរិវត្តិ** ក៏ន័យនេះឯង ។ រូបទាំង ២ ( កាយវិញ្ញត្តិនិងវចីវិញ្ញត្តិ ) នេះប៉ុណ្ណោះ ត្រាស់ហៅថា **ចិត្តា-នុបរិវត្តិ** ព្រោះរូបទាំង ២ នេះ ប្រាកដនៅបាន រហូតវេលាដែលចិត្តនៅប្រាកដ ។

បទថា **ឱឡារិកំ** បានដល់ គ្រោតគ្រាត ព្រោះជារូបដែលគប្បីកាន់យកដោយអំណាចនៃការប៉ះខ្ទប់ ព្រោះជាវត្ថុផង អារម្មណ៍ផង ។ គប្បីជ្រាបរូបជាសុខុមៈ ដោយសភាពផ្ទុយគ្នានឹងរូបគ្រោតគ្រាតដែលពោលហើយ ។

បទថា **ទូរេ** បានដល់ សូម្បីតាំងនៅក្នុងទីជិត ក៏ឈ្មោះថាឆ្ងាយ ព្រោះភាវៈដែលដឹងបានលំបាក ព្រោះកាន់យកមិនបាន ដោយអំណាចនៃការប៉ះខ្ទប់ ។ ចំណែករូបក្រៅនេះ សូម្បីតាំងនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថានៅជិត

ដោយការដឹងបានដោយងាយព្រោះជាភាវៈដែលដឹងបានងាយ ដ្បិតគប្បីកាន់យកបានដោយអំណាចនៃការប៉ះខ្ទប់ ។

[ ៦៣-១៣៣ ] និទ្ទេសនៃចក្ខាយតនៈជាដើម គប្បីជ្រាបដោយពិស្តារតាមន័យដែលពោលទុកហើយនុ៎ះឯង ក្នុងការសង្គ្រោះរូបពួក ២ មានសេចក្តីផ្សេងគ្នាត្រឹមប៉ុណ្ណោះ ការសង្គ្រោះរូបពួក ៣ មានអត្ថងាយយល់ហើយ ។

# អភិធម្មបិដក

## រូបមានប្រមាណ ៤

[ ១៣៤ ] រូបជាឧបាទា ឧបាទិន្នៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទា ឧបាទិន្នៈ ។ រូបជាឧបាទា អនុបាទិន្នៈនោះ តើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាឧបាទា អនុបាទិន្នៈ ។ រូបមិនមែនជាឧបាទា ឧបាទិន្នៈនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបមិនមែនជាឧបាទា ឧបាទិន្នៈ ។ រូបមិនមែនជាឧបាទា អនុបាទិន្នៈនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបមិនមែនជាឧបាទា អនុបាទិន្នៈ ។

[ ១៣៥ ] រូបជាឧបាទា ឧបាទិន្នុបាទានិយៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះ

រូបជាឧបាទា ឧបាទិន្នុបាទានិយៈ ។ រូបជាឧបាទា អនុបាទិន្នុបាទានិយៈនោះ តើដូចម្ដេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្ម ដែលបុគ្គលធ្វើហើយទេ នេះរូបជាឧបាទា អនុបាទិន្នុបាទានិយៈ ។ រូបមិនមែនជាឧបាទា ឧបាទិន្នុបាទានិយៈនោះ តើដូចម្ដេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបមិនមែនជាឧបាទា ឧបាទិន្នុបាទានិយៈ ។ រូបមិនមែនជាឧបាទា អនុបាទិន្នុបាទានិយៈនោះ តើដូចម្ដេច ។ ផោដ្ឋព្វាយតន អាបោធាតុ មិនមែនព្រោះហេតុនៃកម្ម ដែលបុគ្គលធ្វើហើយទេ នេះរូបមិនមែនជាឧបាទា អនុបាទិន្នុបាទានិយៈ ។

[ ១៣៦ ] រូបជាឧបាទា សប្បដិឃៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ រសាយតនៈ នេះរូបជាឧបាទា សប្បដិឃៈ ។ រូបជាឧបាទា អប្បដិឃៈនោះ តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបជាឧបាទា អប្បដិឃៈ ។ រូបមិនមែនជាឧបាទា សប្បដិឃៈនោះ តើដូចម្ដេច ។ ផោដ្ឋព្វាយតនៈ នេះរូបមិនមែនជាឧបាទា សប្បដិឃៈ ។ រូបមិនមែនជាឧបាទា អប្បដិឃៈនោះតើដូចម្ដេច អាបោធាតុ នេះរូបមិនមែនជាឧបាទា អប្បដិឃៈ ។

[ ១៣៧ ] រូបជាឧបាទា ឱឡារិកៈនោះ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ រសាយតនៈ នេះរូបជាឧបាទា ឱឡារិកៈ ។ រូបជាឧបាទា សុខុមៈនោះ តើ

ដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបជាឧបាទា សុខុមៈ ។ រូបមិនមែនជាឧបាទា ឱឡារិកៈនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបមិនមែនជាឧបាទា ឱឡារិកៈ ។ រូបមិនមែនជាឧបាទា សុខុមៈនោះ តើដូចម្តេច ។ អាបោធាតុ នេះរូបមិនមែនជាឧបាទា សុខុមៈ ។

[ ១៣៨ ] រូបជាឧបាទា ទូរេរូបនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបជាឧបាទា ទូរេរូប ។ រូបជាឧបាទា សន្តិកេរូបនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ រសាយតនៈ នេះរូបជាឧបាទា សន្តិកេ-រូប ។ រូបមិនមែនជាឧបាទា ទូរេរូបនោះ តើដូចម្តេច ។ អាបោធាតុ នេះរូបមិនមែនជាឧបាទា ទូរេរូប ។ រូបមិនមែនជាឧបាទា សន្តិកេរូបនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបមិនមែនជាឧបាទា សន្តិកេរូប ។

[ ១៣៩ ] រូបជាឧបាទិន្នៈ សនិទស្សនៈនោះ តើដូចម្តេច ។ រូបាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ សនិទស្សនៈ ។ រូបជាឧបាទិន្នៈ អនិទស្សនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កា-យាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណាគឺគន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ អនិទស្សនៈ ។ រូបជាអនុបាទិន្នៈ សនិទស្សនៈនោះ តើដូចម្តេច ។ រូបាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ សនិទស្សនៈ ។ រូបជាអនុបាទិន្នៈ អនិទស្សនៈនោះ តើ

ដូចម្ដេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្ស-មុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺគន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូ-បស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ អនិទស្សនៈ ។

[ ១៤០ ] រូបជាឧបាទិន្ន សប្បដិឃៈនោះ តើដូចម្ដេច ។ ចក្ខា-យតនៈ ។បេ។ កាយាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្ន សប្បដិឃៈ ។ រូបជាឧបាទិន្នៈ អប្បដិឃៈនោះ តើដូចម្ដេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយឬក៏រូបដទៃណា គឺអាកាសធាតុ អាបោ-ធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្ន អប្បដិឃៈ ។ រូបជាអនុបាទិន្ន សប្បដិឃៈនោះ តើដូចម្ដេច ។ សទ្ទាយតនៈឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ សប្បដិឃៈ ។ រូបជាអនុបាទិន្នៈ អប្បដិឃៈនោះ តើដូចម្ដេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូ-បស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការា-ហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ

អប្បដិឃៈ ។

[ ១៤១ ] រូបជាឧបាទិន្នៈ មហាភូតនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ មហាភូត ។ រូបជាឧបាទិន្នៈ មិនមែនជាមហាភូតនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ មិនមែនមហាភូត ។ រូបជាអនុបាទិន្នៈ មហាភូតនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ មហាភូត ។ រូបជាអនុបាទិន្នៈ មិនមែនមហាភូតនោះ តើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ មិនមែនជាមហាភូត ។

[ ១៤២ ] រូបជាឧបាទិន្នៈ ឱឡារិកៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ ឱឡារិកៈ ។ រូបជាឧបាទិន្នៈ សុខុមៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិ-

សិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្ស-ឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ សុខុមៈ ។ រូបជាអនុបាទិន្នៈ ឱឡារិកៈនោះ តើដូចម្តេច ។ សទ្ទាយតនៈឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ ឱឡារិកៈ ។ រូបជាអនុបាទិន្នៈ សុខុមៈនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្ម-ញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺអាកាសធាតុ អា-បោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ សុខុមៈ ។

[ ១៤៣ ] រូបជាឧបាទិន្នៈ ទូរេរូបនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិ-សិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្ស-ឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ ទូរេរូប ។ រូបជាឧបាទិន្នៈ សន្តិកេរូបនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឬក៏រូបដទៃណា គឺរូបា-យតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នៈ សន្តិកេរូប ។ រូបជាអនុបាទិន្នៈ ទូរេរូបនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺអាកាស-

ធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែន ព្រោះហេតុនៃកម្ម ដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ ទូររូប ។ រូបជាអនុបាទិន្នៈ សន្តិកេរូបនោះ តើដូចម្តេច ។ សទ្ទាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នៈ សន្តិកេរូប ។

[ ១៨៤ ] រូបជាឧបាទិន្នុបាទានិយៈ សនិទស្សនៈនោះ តើដូចម្តេច ។ រូបាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ សនិទស្សនៈ ។ រូបជាឧបាទិន្នុបាទានិយៈ អនិទស្សនៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺគន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ អនិទស្សនៈ ។ រូបជាអនុបាទិន្នុបាទានិយៈ សនិទស្សនៈនោះ តើដូចម្តេច ។ រូបាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ សនិទស្សនៈ ។ រូបជាអនុបាទិន្នុបាទានិយៈ អនិទស្សនៈនោះតើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺគន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្ម

ដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ អនិទស្សនៈ ។

[ ១៨៥ ] រូបជាឧបាទិន្នុបាទានិយៈ សប្បដិឃៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ សប្បដិឃៈ ។ រូបជាឧបាទិន្នុបាទានិយៈ អប្បដិឃៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ អប្បដិឃៈ ។ រូបជាអនុបាទិន្នុបាទានិយៈ សប្បដិឃៈនោះ តើដូចម្តេច ។ សទ្ទាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ សប្បដិឃៈ ។ រូបជាអនុបាទិន្នុបាទានិយៈ អប្បដិឃៈនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ អប្បដិឃៈ ។

[ ១៨៦ ] រូបជាឧបាទិន្នុបាទានិយៈ មហាភូតនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជា

ឧបាទិន្នុបាទានិយៈ មហាភូត ។ រូបជាឧបាទិន្នុបាទានិយៈ មិនមែនមហាភូត នោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ មិនមែនមហាភូត ។ រូបជាអនុបាទិន្នុបាទានិយៈ មហាភូតនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ អាបោធាតុ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ មហាភូត ។ រូបជាអនុបាទិន្នុបាទានិយៈ មិនមែនមហាភូតនោះ តើដូចម្តេច ។ សទ្ទាយតនៈ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ អាកាសធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ មិនមែនមហាភូត ។

[ ១៤៧ ] រូបជាឧបាទិន្នុបាទានិយៈ ឱឡារិកៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ ឱឡារិកៈ ។ រូបជាឧបាទិន្នុបាទានិយៈ សុខុមៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះ

ហេតុនៃកម្មដែលបុគ្គលធ្វើហើយ រូបនេះជាឧបាទិន្នុបាទានិយៈ សុខុមៈ ។ រូបជាអនុបាទិន្នុបាទានិយៈ ឱឡារិកៈនោះ តើដូចម្តេច ។ សទ្ទាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ ឱឡារិកៈ ។ រូបជាអនុបាទិន្នុបាទានិយៈ សុខុមៈនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ សុខុមៈ ។

[ ១៤៨ ] រូបជាឧបាទិន្នុបាទានិយៈ ទូរេរូបនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ ឬក៏រូបដទៃណា គឺអាកាសធាតុ អាបោធាតុ រូបស្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ ជាទូរេរូប ។ រូបជាឧបាទិន្នុបាទានិយៈ ជាសន្តិកេរូបនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កាយាយតនៈ ឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយ នេះរូបជាឧបាទិន្នុបាទានិយៈ ជាសន្តិកេរូប ។ រូបជាអនុបាទិន្នុបាទានិយៈ ជាទូរេរូបនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ វចីវិញ្ញត្តិ រូបស្សលហុតា រូបស្សមុទុតា រូបស្សកម្មញ្ញតា រូបស្សជរតា រូបស្សអនិច្ចតា ឬក៏រូបដទៃណាគឺអាកាសធាតុ អាបោធាតុ រូ-

បសិ្សឧបចយៈ រូបស្សសន្តតិ កពឡិង្ការាហារ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ ជាទូររូប ។ រូបជាអនុ-បាទិន្នុបាទានិយៈ ជាសន្តិកេរូបនោះ តើដូចម្តេច ។ សទ្ទាយតនៈឬក៏រូបដទៃណា គឺរូបាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មិនមែនព្រោះហេតុនៃកម្មដែលបុគ្គលធ្វើហើយទេ នេះរូបជាអនុបាទិន្នុបាទានិយៈ ជាសន្តិកេរូប ។

[ ១៤៩ ] រូបជាសប្បដិឃៈ ជាឥន្ទ្រិយនោះ តើដូចម្តេច ។ ចក្ខុ-ន្ទ្រិយ ។បេ។ កាយិន្ទ្រិយ នេះរូបជាសប្បដិឃៈ ជាឥន្ទ្រិយ ។ រូបជាសប្ប-ដិឃៈ មិនមែនឥន្ទ្រិយនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វា-យតនៈ នេះរូបជាសប្បដិឃៈ មិនមែនឥន្ទ្រិយ ។ រូបជាអប្បដិឃៈ ជាឥន្ទ្រិយនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ នេះរូបជាអប្បដិឃៈ ជាឥន្ទ្រិយ ។ រូបជាអប្បដិឃៈ មិនមែនឥន្ទ្រិយនោះ តើដូចម្តេច ។ កាយ-វិញ្ញត្តិ ។បេ។ កពឡិង្ការាហារ នេះរូបជាអប្បដិឃៈ មិនមែនឥន្ទ្រិយ ។

[ ១៥០ ] រូបជាសប្បដិឃៈ ជាមហាភូតនោះ តើដូចម្តេច ។ ផោដ្ឋព្វា-យតនៈ នេះរូបជាសប្បដិឃៈ ជាមហាភូត ។ រូបជាសប្បដិឃៈ មិនមែនមហាភូតនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ រសាយតនៈ នេះរូបជាសប្បដិឃៈ មិនមែនមហាភូត ។ រូបជាអប្បដិឃៈ ជាមហាភូតនោះ តើដូចម្តេច ។ អាបោធាតុ នេះរូបជាអប្បដិឃៈ ជាមហាភូត ។ រូបជាអប្បដិឃៈ មិនមែនមហាភូតនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះ

រូបជាអប្បដិឃៈ មិនមែនមហាភូត ។

[ ១៥១ ] រូបជាឥន្ទ្រិយជាឱឡារិកៈនោះ តើដូចម្តេច ។ ចក្ខុន្ទ្រិយ ។បេ។ កាយិន្ទ្រិយ នេះរូបជាឥន្ទ្រិយ ជាឱឡារិកៈ ។ រូបជាឥន្ទ្រិយ ជាសុខុមៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ នេះរូបជាឥន្ទ្រិយ ជាសុខុមៈ ។ រូបមិនមែនឥន្ទ្រិយ តែជាឱឡារិកៈនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបមិនមែនឥន្ទ្រិយ តែជាឱឡារិកៈ ។ រូបមិនមែនឥន្ទ្រិយ ជាសុខុមៈនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនឥន្ទ្រិយ ជាសុខុមៈ ។

[ ១៥២ ] រូបជាឥន្ទ្រិយ ជាទូរេរូបនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ នេះរូបជាឥន្ទ្រិយ ជាទូរេរូប ។ រូបជាឥន្ទ្រិយ ជាសន្តិកេរូបនោះ តើដូចម្តេច ។ ចក្ខុន្ទ្រិយ ។បេ។ កាយិន្ទ្រិយ នេះរូបជាឥន្ទ្រិយ ជាសន្តិកេរូប ។ រូបមិនមែនឥន្ទ្រិយ ជាទូរេរូបនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនឥន្ទ្រិយ ជាទូរេរូប ។ រូបមិនមែនឥន្ទ្រិយ ជាសន្តិកេរូបនោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបមិនមែនឥន្ទ្រិយ ជាសន្តិកេរូប ។

[ ១៥៣ ] រូបជាមហាភូត ជាឱឡារិកៈនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបជាមហាភូត ជាឱឡារិកៈ ។ រូបជាមហាភូត ជាសុខុមៈនោះ តើដូចម្តេច ។ អាបោធាតុ នេះរូបជាមហាភូត ជាសុខុមៈ ។ រូបមិនមែនមហាភូត ជាឱឡារិកៈនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ រសាយតនៈ

នេះរូបមិនមែនមហាភូត ជាឱឡារិកៈ រូបមិនមែនមហាភូត ជាសុខុមៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនមហាភូត ជាសុខុមៈ ។

[ ១៥៤ ] រូបជាមហាភូត ជាទូរេរូបនោះ តើដូចម្តេច ។ អាបោធាតុ នេះរូបជាមហាភូត ជាទូរេរូប ។ រូបជាមហាភូត ជាសន្តិកេរូបនោះ តើដូចម្តេច ។ ផោដ្ឋព្វាយតនៈ នេះរូបជាមហាភូត ជាសន្តិកេរូប ។ រូបមិនមែនមហាភូត ជាទូរេរូបនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនមហាភូត ជាទូរេរូប ។ រូបមិនមែនមហាភូត ជាសន្តិកេរូបនោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ រសាយតនៈ នេះរូបមិនមែនមហាភូត ជាសន្តិកេរូប ។

[ ១៥៥ ] រូបាយតនៈដែលបុគ្គលឃើញហើយ សទ្ទាយតនៈដែលបុគ្គលឮហើយ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ដែលបុគ្គលប៉ះពាល់ហើយ រូបទាំងអស់ជារូបដែលបុគ្គលដឹងហើយដោយចិត្ត ។

**ការសង្គ្រោះរូបដោយប្រការ ៤ យ៉ាងនេះ ។**

**ចប់ រូបមានប្រមាណ ៤ ។**

# អដ្ឋកថា

# អធិប្បាយ ចតុក្កនិទ្ទេស

[ ១៣៤-១៥៥ ] ក្នុងបទចុងក្រោយនៃការសង្គ្រោះរូប ៤ ពួក ព្រះមានព្រះភាគទ្រង់មិនបានតាំងសំណួរទុកអំពីខាងដើម តែត្រាស់ពាក្យថា **រូបាយតនំ ទិដ្ឋំ សទ្ទាយតនំ សុតំ** ដូច្នេះជាដើម ព្រោះមិនមានការប្លែកគ្នានៃពាក្យថា **ទិដ្ឋំ** ជាដើម ជាមួយនឹងពាក្យចុងក្រោយ គឺពាក្យថា **វិញ្ញាតំ** ។ បណ្តារូបទាំងនោះ រូបាយតនៈ ឈ្មោះថា **ទិដ្ឋំ** ព្រោះអត្ថថា អាចសម្លឹងមើលដោយចក្ខុហើយឃើញបាន ។ **សទ្ទាយតនៈ** ឈ្មោះថា **សុតំ** ព្រោះអត្ថថា អាចស្តាប់សំឡេងដោយសោតៈហើយដឹងបាន ។ ពួកបីនៃអាយតនៈមានគន្ធាយតនៈជាដើម ឈ្មោះថា **មុតំ** ដោយអត្ថថា គប្បីទទួលដឹងតាមឃានៈ ជិវ្ហា និងកាយបាន ព្រោះទទួលអារម្មណ៍ដែលដល់ហើយ ។ ព្រះមានព្រះភាគ ត្រាស់ថា ឈ្មោះថា **មុតំ** ព្រោះពាល់ត្រូវហើយ ទើបជាហេតុឲ្យវិញ្ញាណកើតឡើង ដូច្នេះ ក៏មាន ។ ចំណែករូបទាំងអស់ទុំះឯង ឈ្មោះថា **មនសា វិញ្ញាតំ** ព្រោះអត្ថថា គប្បីដឹងដោយមនោវិញ្ញាណ ។

# អភិធម្មបិដក

## រូបមានប្រមាណ ៥

[ ១៥៦ ] រូបជាបឋវីធាតុនោះ តើដូចម្តេច ។ រូបណាដែលរឹង គ្រោតគ្រាត ជាភាពរឹង មានភាពជារបស់រឹង ជាខាងក្នុងក្តី ខាងក្រៅក្តី ជាឧបាទិន្នរូបក្តី ជាអនុបាទិន្នរូបក្តី នេះរូបជាបឋវីធាតុ ។ រូបជាអាបោធាតុនោះ តើដូចម្តេច ។ រូបណាជាទឹក ការតាំងនៅជាទឹក សភាពជ្រួតជ្រាប ការតាំងនៅ ជារបស់ជ្រួតជ្រាប ការតភ្ជាប់នៃរូប ជាខាងក្នុងក្តី ខាងក្រៅក្តី ជាឧបាទិន្នរូបក្តី ជាអនុបាទិន្នរូបក្តី នេះរូបជាអាបោធាតុ ។ រូបជាតេជោធាតុនោះ តើដូចម្តេច ។ រូបណាជាភ្លើង ការតាំងនៅជាភ្លើង ធម្មជាតិសម្រាប់ចេញចំហាយ ការតាំងនៅជាចំហាយ កំសួលក្តៅ ការតាំងនៅជាកំសួលក្តៅ ជាខាងក្នុងក្តី ខាងក្រៅក្តី ជាឧបាទិន្នរូបក្តី អនុបាទិន្នរូបក្តី នេះរូបជាតេជោធាតុ ។ រូបជាវាយោធាតុនោះ តើដូចម្តេច ។ រូបណាជាខ្យល់ ការតាំងនៅជាខ្យល់ ការគាំទ្រទនូវរូប ជាខាងក្នុងក្តី ខាងក្រៅក្តី ជាឧបាទិន្នរូបក្តី អនុបាទិន្នរូបក្តី នេះរូបជាវាយោធាតុ ។ រូបជាឧបាទានោះ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបជាឧបាទា ។

**ការសង្គ្រោះរូបដោយប្រការ ៥ យ៉ាងនេះឯង ។**

**ចប់ រូបមានប្រមាណ ៥ ។**

## អដ្ឋកថា

## អធិប្បាយ បញ្ចកនិទ្ទេស

[ ១៥៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃការសង្គ្រោះរូបជាពួក ៥ ដូចតទៅនេះថា

បទថា **កក្ខឡំ** បានដល់ រឹងកំព្រឹស ។ ការរឹងទ្រនុំៈឯង ហៅថា **ខរគតំ** អធិប្បាយថា គ្រោតគ្រាត ។ បទថា **កក្ខឡត្តំ កក្ខឡភាវោ** ទាំង ២ ក្រៅអំពីនេះ ក៏ជាការអធិប្បាយសភាវៈទ្រនុំៈឯង ។

បទថា **អជ្ឈត្តំ** បានដល់ ជាខាងក្នុងដែលកើតក្នុងខ្លួន ។ បទថា **ពហិទ្ធា** បានដល់ ជាខាងក្រៅ ។ បទថា **ឧបាទិន្នំ** បានដល់ មានកម្មជាសមុដ្ឋានប៉ុណ្ណោះក៏មិនមែន ។ ពាក្យថា **ឧបាទិន្នំ** នេះ ជាការប្រាវព្ធរូបដែលតាំងនៅក្នុងសរីរៈ ដោយមិនផ្សេងគ្នា ។ មែនពិត រូបដែលតាំងនៅក្នុងសរីរៈ ជាឧបាទិន្នៈក្តី ជាអនុបាទិន្នៈក្តី ឈ្មោះថា ជាឧបាទិន្នៈទាំងអស់ដោយអំណាចនៃរូបដែលតណ្ហាកាន់យកដែលមានះប្រកាន់ និងដែលទិដ្ឋិចាប់យកហើយ ។

បទថា **តេជោគតំ** បានដល់ ធម្មជាតិដែលទៅក្នុងតេជោធាតុទាំងអស់ដែលមានការក្តៅជាលក្ខណៈ ម្យ៉ាងទៀត ធម្មជាតិដែលដល់នូវភាពជារបស់ក្តៅ គឺតេជោធាតុ ព្រោះហេតុនោះ ទើបឈ្មោះថា **តេជោគតំ** ។ បទថា **ឧស្មា** បានដល់ អាការដែលក្តៅ ។ បទថា **ឧស្មាគតំ** បានដល់ ធម្មជាតដែលដល់នូវភាវៈក្តៅ ។ ពាក្យនេះជាឈ្មោះរបស់អាការៈដែលក្តៅ ។ បទថា **ឧសុមំ** បានដល់ កម្តៅដ៏មានកម្លាំង ធម្មជាតដែលដល់នូវភាពក្តៅ គឺកម្តៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ឧសុមគតំ** ( កំសួលក្តៅ ) ។

រូបដែលឈ្មោះថា **វាយោ** ដោយអំណាចនៃធម្មជាតដែលបក់ទៅមក ។ ការបក់ទៅមកនោះឯង ឈ្មោះថា **វាយោគតំ** ព្រោះដល់នូវភាវៈដែលបក់ទៅមក ។ បទថា **ថម្ភិតត្តំ** បានដល់ ភាពដែលរូបត្រូវគាំទ្រ ដូចភាពដែលទងនិងសម្បកឧប្បលជាដើម ដែលពេញដោយខ្យល់ ត្រូវខ្យល់គាំទ្រទុក ។

# អភិធម្មបិដក

## រូបមានប្រមាណ ៦ ជាដើម

[ ១៥៧ ] រូបាយតនៈ ជារូបដែលគប្បីដឹងបានដោយភ្នែក សទ្ទាយតនៈ ជារូបដែលគប្បីដឹងបានដោយត្រចៀក គន្ធាយតនៈ ជារូបដែលគប្បីដឹងបានដោយច្រមុះ រសាយតនៈ ជារូបដែលគប្បីដឹងបានដោយអណ្តាត ផោដ្ឋព្វាយតនៈ ជារូបដែលគប្បីដឹងបានដោយកាយ រូបទាំងអស់ជារូបដែលគប្បីដឹងបានដោយចិត្ត ។

### ការសង្គ្រោះរូបដោយប្រការ ៦ យ៉ាងនេះឯង ។

### ចប់ រូបមានប្រមាណ ៦ ។

[ ១៥៨ ] រូបាយតនៈ ជារូបដែលគប្បីដឹងបានដោយភ្នែក សទ្ទាយតនៈ ជារូបដែលគប្បីដឹងបានដោយត្រចៀក គន្ធាយតនៈ ជារូបដែលគប្បីដឹងបានដោយច្រមុះ រសាយតនៈ ជារូបដែលគប្បីដឹងបានដោយអណ្តាត ផោដ្ឋព្វាយតនៈជារូបដែលគប្បីដឹងបានដោយកាយ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ( ទាំងនេះ ) ជារូបដែលគប្បីដឹងបានដោយមនោធាតុ រូបទាំងអស់ជារូបដែលគប្បីដឹងបានដោយមនោវិញ្ញាណធាតុ ។

### ការសង្គ្រោះរូបដោយប្រការ ៧ យ៉ាងនេះឯង ។

### ចប់ រូបមានប្រមាណ ៧ ។

[ ១៥៩ ] រូបាយតនៈ ជារូបដែលគប្បីដឹងបានដោយភ្នែក សទ្ទា-

យតនៈ ជារូបដែលគប្បីដឹងបានដោយត្រចៀក គន្ធាយតនៈ ជារូបដែលគប្បីដឹងបានដោយច្រមុះ រសាយតនៈជារូបដែលគប្បីដឹងបានដោយអណ្តាត ផោដ្ឋព្វៈ ( ការប៉ះពាល់ ) ជាទីពេញចិត្ត មានសម្ផស្សជាសុខ ជារូបដែលគប្បីដឹងបានដោយកាយ ផោដ្ឋព្វៈ មិនជាទីពេញចិត្ត មានសម្ផស្សជាទុក្ខ ជារូបដែលគប្បីដឹងដោយកាយ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ ( ទាំងនេះ ) ជារូបដែលគប្បីដឹងបានដោយមនោធាតុ រូបទាំងអស់ ជារូបដែលគប្បីដឹងបានដោយមនោវិញ្ញាណធាតុ ។

**ការសង្គ្រោះរូបដោយប្រការ ៨ យ៉ាងនេះឯង ។**

**ចប់ រូបមានប្រមាណ ៨ ។**

## អដ្ឋកថា

## អធិប្បាយ ចក្ខុនិទ្ទេសជាដើម

[ ១៥៧-១៥៩ ] ព្រះមានព្រះភាគទ្រង់អធិប្បាយដោយមិនបានសាកសួរអំពីខាងដើមឡើយព្រោះមិនមានសេចក្ដីផ្សេងគ្នានៃបទចុងក្រោយ ( មនោវិញ្ញេយ្យំ ) នៃការសង្គ្រោះរូបជាមួយពួក ៦ ជាដើមទាំង ៣ ពួក ។ គប្បីជ្រាបវិគ្គហៈ ក្នុងនិទ្ទេសនៃការសង្គ្រោះរូបជាមួយពួក ៦ ជាដើមនោះ ។ រូបដែលឈ្មោះថា **ចក្ខុវិញ្ញេយ្យំ** ព្រោះអត្ថថា អាចដឹងបាន ដោយចក្ខុវិញ្ញាណ ។បេ។ រូបដែលឈ្មោះថា **មនោវិញ្ញេយ្យំ** ព្រោះអត្ថថា អាចដឹងបានដោយមនោវិញ្ញាណ ។

រូបដែលឈ្មោះថា **មនោធាតុវិញ្ញេយ្យំ** ព្រោះអត្ថថា អាចដឹងបានដោយមនោធាតុ ៣ យ៉ាង ។ ក្នុងបទថា **សព្វំ រូបំ** នេះ ព្រោះសូម្បីត្រឹមតែជារូបមួយដែលមនោវិញ្ញាណធាតុមិនដឹងមិនមាន ព្រោះហេតុនោះ ទើបត្រាស់ថា **សព្វំ រូបំ** ដូច្នេះ ។ ពិតណាស់ ន័យក្នុងឋានៈដែលដល់ព្រះអភិធម្មហើយគួរធ្វើន័យដែលព្រះសម្មាសម្ពុទ្ធ មិនបានធ្វើទុក ឈ្មោះថា រមែងមិនមាន ។ ឋានៈនេះ ឈ្មោះថា ឋានៈដែលគួរនាំន័យ ព្រោះមិនមានរូប សូម្បីតែមួយដែលមនោវិញ្ញាណធាតុមិនដឹង ព្រោះហេតុនោះកាលទ្រង់ធ្វើន័យ ទើបត្រាស់ថា **សព្វំ រូបំ** ដូច្នេះ ។

បទថា **សុខសម្ពស្សោ** គឺបានសុខវេទនាជាបច្ច័យ ។ បទថា **ទុក្ខសម្ពស្សោ** គឺបានទុក្ខវេទនាជាបច្ច័យ ។ ក្នុងអដ្ឋកនិទ្ទេសនេះ ទ្រង់ប្រទានន័យនេះទុក ព្រោះសុខនិងទុក្ខមានផោដ្ឋព្វារម្មណ៍ជាភាវៈរបស់ខ្លួន ។

# អភិធម្មបិដក

## រូបមានប្រមាណ ៩ ជាដើម

[ ១៦០ ] រូបជាចក្ខុន្ទ្រិយនោះ តើដូចម្ដេច ។ ចក្ខុណា គឺប្រសាទដែលអាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបជាចក្ខុន្ទ្រិយ ។ រូបជាសោតិន្ទ្រិយ ។បេ។ ជាឃានិន្ទ្រិយ ។បេ។ ជាជិវ្ហិន្ទ្រិយ ។បេ។ ជាកាយិន្ទ្រិយ ។បេ។ ជាឥត្ថិន្ទ្រិយ ។បេ។ ជាបុរិសិន្ទ្រិយ ។បេ។ ជាជីវិតិន្ទ្រិយនោះ តើដូចម្ដេច ។ អាយុ ការឋិតនៅ ការនៅឃើនឃូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅបាន ការរក្សានូវរូបធម៌ទាំងឡាយនោះ គឺជីវិត ជីវិតិន្ទ្រិយណា នេះរូបជាជីវិតិន្ទ្រិយ ។ រូបមិនមែនជាឥន្ទ្រិយនោះ តើដូចម្ដេច ។ រូបាយតនៈ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាឥន្ទ្រិយ ។

**ការសង្គ្រោះរូបដោយប្រការ ៩ យ៉ាងនេះឯង ។**

**ចប់ រូបមានប្រមាណ ៩ ។**

[ ១៦១ ] រូបជាចក្ខុន្ទ្រិយនោះ តើដូចម្ដេច ។ ភ្នែកណាគឺប្រសាទដែលអាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបជាចក្ខុន្ទ្រិយ ។ រូបជាសោតិន្ទ្រិយ ។បេ។ ជាឃានិន្ទ្រិយ ។បេ។ ជាជិវ្ហិន្ទ្រិយ ។បេ។ ជាកាយិន្ទ្រិយ ។បេ។ ជាឥត្ថិន្ទ្រិយ ។បេ។ ជាបុរិសិន្ទ្រិយ ។បេ។ ជាជីវិតិន្ទ្រិយនោះ តើដូចម្ដេច ។ អាយុ ការឋិតនៅ ការនៅឃើនឃូរ ការរស់នៅ ការរំកិលទៅ ការប្រព្រឹត្តទៅ ការរក្សានូវរូបធម៌ទាំងឡាយនោះគឺជីវិត ជីវិតិន្ទ្រិយណា នេះរូបជាជីវិតិន្ទ្រិយ ។ រូបមិនមែនជាឥន្ទ្រិយ ជាសប្បដិឃៈ

នោះ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះរូបមិនមែនជាឥន្ទ្រិយ ជាសប្បដិឃៈ ។ រូបមិនមែនជាឥន្ទ្រិយ ជាអប្បដិឃៈនោះ តើដូចម្តេច ។ កាយវិញ្ញត្តិ ។បេ។ កពឡិង្ការាហារ នេះរូបមិនមែនជាឥន្ទ្រិយ ជាអប្បដិឃៈ ។

ការសង្គ្រោះរូបដោយប្រការ ១០ យ៉ាងនេះឯង ។

ចប់ រូបមានប្រមាណ ១០ ។

[ ១៦២ ] រូបជាចក្ខាយតនៈនោះ តើដូចម្តេច ។ ភ្នែកណា គឺប្រសាទអាស្រ័យមហាភូតទាំង ៤ ។បេ។ ហៅថា ស្រុកទំនេរក៏បាន នេះរូបជាចក្ខាយតនៈ រូបជាសោតាយតនៈ ។បេ។ ជាឃានាយតនៈ ។បេ។ ជាជិវ្ហាយតនៈ ។បេ។ ជាកាយាយតនៈ ។បេ។ ជារូបាយតនៈ ។បេ។ ជាសទ្ទាយតនៈ ។បេ។ ជាគន្ធាយតនៈ ។បេ។ ជារសាយតនៈ ។បេ។ ជាផោដ្ឋព្វាយតនៈនោះ តើដូចម្តេច ។ បឋវីធាតុ ។បេ។ ហៅថាផោដ្ឋព្វធាតុក៏បាន នេះរូបជាផោដ្ឋព្វាយតនៈ ។ រូបជាអនិទស្សនៈ ជាអប្បដិឃៈ ដែលរាប់បញ្ចូលក្នុងធម្មាយតនៈនោះ តើដូចម្តេច ។ ឥត្ថិន្ទ្រិយ ។បេ។ កពឡិង្ការាហារ នេះរូបជាអនិទស្សនៈ ជាអប្បដិឃៈ ដែលរាប់បញ្ចូលក្នុងធម្មាយតនៈ ។

ការសង្គ្រោះរូបដោយប្រការ ១១ យ៉ាងនេះឯង ។

ចប់ រូបមានប្រមាណ ១១ ។

ចប់ រូបវិភត្តិ ( ការចែករូប ) ។

ចប់ ភាណវារៈ ទី ៨ ។

## អដ្ឋកថា

## អធិប្បាយ នវកនិទ្ទេសជាដើម

[ ១៦០-១៦២ ] ក្នុងនវកនិទ្ទេស ទ្រង់ប្រទានន័យទុក ព្រោះថា រូបដែលមិនជាឥន្ទ្រិយមាន ក្នុងរូបពួក ១០ ទ្រង់ប្រទានន័យទុក ព្រោះថា រូបនោះនុ៎ះឯង ជាសប្បដិឃៈនិងអប្បដិឃៈ ក្នុងពួក ១១ ទ្រង់ចែកអាយតនៈទុក ១០ និងកន្លះ ។ បណ្ឌិតគប្បីជ្រាបនិទ្ទេសវារៈនៃអាយតនៈទាំងនោះដោយពិស្តារ តាមន័យដែលពោលទុកហើយ ។ ពាក្យដ៏សេសក្នុងបទទាំងពួង មានអត្ថងាយយល់ហើយ ។

## បកិណ្ណកកថា

ដើម្បីការមិនវង្វេងក្នុងរូបទាំងនេះ បណ្ឌិតគប្បីជ្រាបបកិណ្ណកៈនេះ គឺសមោធានគឺការប្រមូលមក សមុដ្ឋានគឺហេតុឲ្យកើតឡើង បរិនិប្ផន្នសង្ខតៈគឺរូបកើតអំពីកម្មមានបច្ច័យតាក់តែង ។

បណ្តាបកិណ្ណកទាំងនោះ ពាក្យថា សមោធាន សេចក្តីថា រូបទាំងអស់នុ៎ះឯង ពោលដោយសមោធាន រាប់បាន ២៥ រូប គឺចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ឥត្ថិន្ទ្រិយ បុរិសិន្ទ្រិយ ជីវិតិន្ទ្រិយ កាយវិញ្ញត្តិ វចីវិញ្ញត្តិ អាកាសធាតុ រូបលហុតា រូបមុទុតា រូបកម្មញ្ញតា រូបឧបចយៈ រូបសន្តតិ រូបជរតា រូបអនិច្ចតា កពឡិង្ការាហារ ផោដ្ឋព្វាយតនៈ អាបោធាតុ រួមជាមួយនឹងរូប គឺហទយវត្ថុ គប្បីជ្រាបថាមាន ២៦ ។ ឈ្មោះថា រូបដទៃ

ក្រៅពីនេះមិនមាន ។ តែអាចារ្យពួកខ្លះ អ្នកមានវាទៈថា មិទ្ធៈជារូប ទើបពោលថា ឈ្មោះថា មិទ្ធរូបមាន ។ សកវាទីអាចារ្យគប្បីពោលនឹងអាចារ្យទាំងនោះថា លោកជាអ្នកប្រាជ្ញត្រាស់ដឹងហើយដោយពិត លោក[1]មិនមាននីវរណៈទាំងឡាយឡើយ ដូច្នេះជាដើម ហើយគប្បីបដិសេធថា រូបដែលឈ្មោះថា មិទ្ធៈ មិនមាន ។ អាចារ្យមួយពួកទៀតពោលថា រូបទាំង ២៦ នោះជាមួយនឹងពលរូប ក៏ជារូប ២៧ រួមជាមួយនឹងសម្ភវរូប ក៏ជារូប ២៨ រួមជាមួយនឹងជាតិរូប ក៏ជារូប ២៩ រួមជាមួយនឹងរោគរូប ក៏ជារូប ៣០ ។ សកវាទីអាចារ្យក៏គប្បីសម្តែងការមិនមាននៃរូបទាំងនោះ ដែលចែកចេញមកដោយឡែក ហើយបដិសេធអាចារ្យទាំងនោះ ។ ពិតណាស់ ទ្រង់កាន់យកពលរូបទុំះឯងដោយវាយោធាតុដែលទ្រង់កាន់យកហើយ ឈ្មោះថា ពលរូបដទៃរមែងមិនមាន ។ ទ្រង់កាន់យកសម្ភវរូបដោយអាបោធាតុ ទ្រង់កាន់យកជាតិរូបដោយឧបចយៈនិងសន្តតិ ទ្រង់កាន់យករោគរូបដោយជរតារូប និងអនិច្ចតារូបដែលទ្រង់កាន់យកហើយ ឈ្មោះថា រោគរូបដទៃរមែងមិនមាន ។ សូម្បីអាពាធមានរោគត្រចៀកជាដើមណា អាពាធនោះក៏ត្រឹមតែជាធាតុតាំងឡើងដោយបច្ច័យដែលមិនស្មើគ្នាប៉ុណ្ណោះ ។ ឈ្មោះថា រោគរូបដទៃក្នុងរូបទាំងនោះ មិនមាន ព្រោះហេតុនោះ កាលពោលដោយសមោធានហើយ ក៏មានរូបត្រឹមតែ ២៦ ប៉ុណ្ណោះ ។

ពាក្យថា **សមុដ្ឋាន** សេចក្តីថា រូបប៉ុន្មានមានសមុដ្ឋានប៉ុន្មាន រូប ១០

---

១-ក្នុងខុទ្ទកនិកាយ សុត្តនិបាត ជាព្រះអង្គ ។

មានសមុដ្ឋាន ១ រូបមួយ មានសមុដ្ឋាន ២ រូបបី មានសមុដ្ឋាន ៣ រូបប្រាំបួន មានសមុដ្ឋាន ៤ រូបពីរមិនតាំងឡើងអំពីសមុដ្ឋានណាឡើយ បណ្ដារូបទាំងនោះ រូបដប់ ឈ្មោះថា មានសមុដ្ឋាន ១ គឺ រូបទាំង ៨ នេះ គឺចក្ខុបសាទ ។បេ។ ជីវិតិន្ទ្រិយ តាំងឡើងអំពីកម្មតែម្យ៉ាង រូប ២ គឺកាយ-វិញ្ញត្តិនិងវចីវិញ្ញត្តិតាំងឡើងអំពីចិត្តតែម្យ៉ាង រូបមួយឈ្មោះថា មានសមុដ្ឋាន ២ គឺសទ្ទរូបតាំងឡើងអំពីឧតុនិងចិត្ត ។ ក្នុងសទ្ទរូបនោះ សំឡេងដែលកើតអំពីវត្ថុ មិនមានវិញ្ញាណតាំងឡើងអំពីឧតុ សំឡេងដែលកើតអំពីវត្ថុ ដែលមានវិញ្ញាណតាំងឡើងអំពីចិត្ត ។ ចំណែកវិការរូប ៣ មានលហុតាជាដើម ឈ្មោះថា មានសមុដ្ឋាន ៣ គឺរមែងតាំងឡើងអំពីឧតុ ចិត្ត និងអាហារ ។ រូប ៩ ដ៏សេស រមែងតាំងឡើងអំពីសមុដ្ឋាន ៤ គឺអំពីឧតុ ចិត្ត អាហារនិងកម្ម ។ រូប ២ ឈ្មោះថា មិនតាំងឡើងអំពីសមុដ្ឋានណាឡើយ គឺរូបជរតានិងរូបអនិច្ចតា រមែងមិនតាំងឡើងអំពីសមុដ្ឋានទាំង ៤ នោះសូម្បីតែសមុ-ដ្ឋានមួយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះរូបទាំង ២ នេះ មិនមានការកើត ដ្បិតថា រូបទាំងពីរនេះ រមែងកើតក៏មិនមែន សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះរូបដែលកើតហើយ ក៏ត្រូវចាស់និងបែកធ្លាយ ។

មែនពិត រូបក្ដី អរូបក្ដីដែលកើតឡើងហើយ ក៏ត្រូវរលត់ ព្រោះហេតុនោះ បណ្ឌិតគប្បីព្រមទទួលពាក្យដូចពោលនេះពិតប្រាកដ ។ ព្រោះថា រូបឬអរូបដែកកើតឡើងហើយ ឈ្មោះថា មិនអស់ទៅ ប្រាកដនៅ មិនមានទេ តែដរាបណា រូបនៅមិនទាន់បែកធ្លាយ ការចាស់របស់រូបនោះ ក៏ប្រាកដនៅ

ដរាបនោះ ព្រោះហេតុនោះ សេចក្តីនេះទើបសម្រេចថា ព្រោះរូបដែលកើតហើយ ក៏ត្រូវចាស់ និងបែកធ្លាយ ។ បើរូបទាំង ២ នេះ គប្បីកើតសោត រូបទាំង ២ នេះ ក៏គប្បីចាស់ និងបែកធ្លាយទៅ ។ ការចាស់របស់រូប ក៏រមែងមិនចាស់ ឬការបែករបស់រូប ក៏រមែងមិនបែកធ្លាយ ព្រោះហេតុនោះ ទើបរូបទាំង ២ នេះ ឈ្មោះថាមិនកើត ព្រោះរូបដែលកើតហើយក៏ត្រូវចាស់ និងបែកធ្លាយ ។

ក្នុងសេចក្តីនោះ បើមានអ្នកចោទសួរថា ការកើត រមែងកើត ដូច្នេះ ជាពាក្យដែលព្រមទទួលបានដោយពាក្យថា រូបឧបចយ រូបសន្តតិ ដូច្នេះ ក្នុងនិទ្ទេសជាដើមថា រូបដែលកម្មតាក់តែងឡើងឯណា ពាក្យថា ការចាស់ក៏ចូរចាស់ ការបែកធ្លាយក៏ចូរបែកធ្លាយ ដូច្នេះ ក៏យ៉ាងនោះ ។ គប្បីឆ្លើយថា ក្នុងសេចក្តីនោះ លោកមិនបានព្រមទទួលពាក្យថា ការកើត រមែងកើត ។ ធម៌ពួកណា រមែងកើតអំពីកម្មជាដើម លោកព្រមទទួលវោហារថា ការកើតមានកម្មជាដើម ជាបច្ច័យ ដោយការកើតឡើងនៃធម៌ទាំងនោះ ។ តែកាលពោលដោយបរមត្ថ ការកើត រមែងមិនកើត ដ្បិតថា ត្រឹមតែការកើតឡើងនៃរូបដែលកើតឡើង រមែងកើត ។

ក្នុងសេចក្តីនោះ បើមានអ្នកសួរថា ការកើត គឺការកើតឡើងនៃធម៌ពួកណា រមែងបានវោហារថា មានកម្មជាដើមជាបច្ច័យ និងវោហារថា ការកើតឡើងឯណានុ៎ះឯង ការចាស់និងការបែកធ្លាយ គឺការចាស់និងការបែកធ្លាយនៃធម៌ពួកណា ក៏ចូរបានវោហារថា មានកម្មជាដើមជាបច្ច័យ និងវោហារថា

ការកើតឡើងក៏យ៉ាងនោះ កាលបើដូច្នេះ រូបទាំង ២ នេះ ក៏គប្បីពោលបានថា មានកម្មជាដើម ជាសមុដ្ឋានទុំះឯង ។

សេចក្តីនេះឆ្លើយថា ការចាស់ និងការបែកធ្លាយ នឹងបានវោហារនោះមិនមានទេ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះការចាស់ និងការបែកធ្លាយ មិនមានក្នុងខណៈនៃអានុភាពរបស់ជនកបច្ច័យ ដ្បិតថាអានុភាពនៃជនកបច្ច័យទាំងឡាយ មាននៅក្នុងឧប្បាទក្ខណៈនៃធម៌ ដែលខ្លួនគប្បីឲ្យកើតឡើងប៉ុណ្ណោះ មិនលើសអំពីនោះ ។ ក្នុងខណៈដែលជនកបច្ច័យទាំងនោះញុំាងធម៌ឲ្យកើតឡើង ជាតិកាលប្រាកដ រមែងបានវោហារថា មានកម្មជាដើមជាបច្ច័យ និងវោហារថា ការកើតឡើងព្រោះការមានព្រមក្នុងខណៈនោះ តែការចាស់និងការបែកធ្លាយទាំង ២ ក្រៅអំពីនេះ រមែងបានវោហារយ៉ាងនោះ ព្រោះការមិនមានក្នុងខណៈនោះ ព្រោះហេតុនោះ គប្បីពោលមិនបានឡើយថា រូបទាំង ២ នោះកើតឡើង ។ បើសួរតទៅទៀតថា រូបទាំង ២ នេះ ក៏នៅឈ្មោះថាកើត ព្រោះព្រះបាលី ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ជរា មរណៈមិនទៀង ជាធម្មជាតដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ដូច្នេះ ឆ្លើយថា មិនមែនដូច្នោះទេ ព្រោះព្រះបាលីនោះសម្តែងទុកដោយអម ។ ពិតណាស់ ក្នុងព្រះបាលីនោះទ្រង់ត្រាស់ ជរានិងមរណៈនោះថា ជាធម៌កើតព្រោះអាស្រ័យបច្ច័យ ដូច្នេះដោយអម ព្រោះធម៌ទាំងឡាយ ដែលអាស្រ័យហេតុកើតឡើង ជាធម្មជាតមានជរានិងមរណៈ ។

បើមានពាក្យសួរថា បើយ៉ាងនេះ រូបទាំង ៣ នោះក៏រមែងមិនមាន ដូចស្នែងទន្សាយ ព្រោះមិនកើតឡើង ឬមិនដូច្នោះទេ ក៏ជារបស់ទៀង ដូចព្រះនិព្វានពិត ឆ្លើយថា មិនមែនដូច្នោះឡើយ ព្រោះនៅមានការប្រព្រឹត្តទៅទាក់ទងដោយនិស្សយប្បច្ច័យ ។ ពិតណាស់ កាលនិស្សយប្បច្ច័យ មានបឋវីជាដើមមាន រូបទាំង ៣ មានការកើតជាដើម ក៏រមែងប្រាកដ ព្រោះហេតុនោះ នឹងថាមិនមានក៏មិនបាន មួយទៀតសោត កាលនិស្សយប្បច្ច័យទាំងនោះមិនមាន រូបទាំង ៣ នោះក៏មិនប្រាកដ ព្រោះហេតុនោះ ថាទៀងក៏មិនបាន ដើម្បីទ្រង់បដិសេធសេចក្តីប្រកាន់មាំនេះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ជរា មរណៈមិនទៀង ជាធម្មជាតដែលបច្ច័យប្រជុំតាក់តែង កើតព្រោះអាស្រ័យបច្ច័យ ដូច្នេះ ដោយន័យជាដើមយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា រូបទាំង ២ ( រូបជរតានិងរូបអនិច្ចតា ) មិន**តាំងឡើង**អំពីសមុដ្ឋានណាឡើយ ។

ម្យ៉ាងទៀត ក្នុងពាក្យថា **តាំងឡើង** នេះ គប្បីជ្រាបអត្ថយ៉ាងដទៃ ដូចតទៅនេះថា មាតិកានេះរបស់សេចក្តីនោះថា រូបកើតអំពីកម្មមានកម្មជាបច្ច័យ មានឧតុជាសមុដ្ឋាន កើតអំពីកម្មជាបច្ច័យ ។

រូបមានអាហារជាសមុដ្ឋាន មានអាហារជាបច្ច័យ មានឧតុជាសមុដ្ឋាន កើតអំពីអាហារជាបច្ច័យ ។

រូបមានឧតុជាសមុដ្ឋាន មានឧតុជាបច្ច័យ មានឧតុជាសមុដ្ឋាន កើតអំពីឧតុជាបច្ច័យ ។

រូបមានចិត្តជាសមុដ្ឋាន មានចិត្តជាបច្ច័យ មានឧតុជាសមុដ្ឋាន កើតអំពីចិត្តជាបច្ច័យ ។

បណ្ដាសមុដ្ឋាននៃរូបទាំង ៤ នោះ រូប ៨ យ៉ាង មានចក្ខុបសាទ ជាដើម មួយអន្លើដោយហទយវត្ថុ ឈ្មោះថា រូបកើតអំពីកម្ម ( កម្មជរូប ) ។ រូបទាំងនេះ គឺសក់ ពុកមាត់ ក្ដុកដ៏រ រោមកន្ទុយសេះ រោមកន្ទុយចាមរី ជាដើម ឈ្មោះថា រូបមានកម្មជាបច្ច័យ ( កម្មបច្ចយរូប ) រូបយ៉ាងនេះ គឺចក្ករតនៈ ឧទ្យាននិងវិមានជាដើមរបស់ពួកទេវតា ឈ្មោះថា រូបមានឧតុជាសមុដ្ឋាន កើតអំពីកម្មជាបច្ច័យ ( កម្មបច្ចយឧតុសមុដ្ឋានរូប ) ។

សុទ្ធដ្ឋករូបតាំងឡើងអំពីអាហារ ឈ្មោះថា រូបមានអាហារជាសមុដ្ឋាន ( អាហារសមុដ្ឋានរូប ) ។ កពឡិង្ការាហារជាបច្ច័យដល់រូបសន្តតិទាំង ២ គឺ រូបមានអាហារសមុដ្ឋាន និងឧបាទិន្នរូប ។ កពឡិង្ការាហារ ជាបច្ច័យឲ្យរូបដែលមានអាហារជាសមុដ្ឋានកើត និងតាមរក្សាកម្មជរូប ព្រោះហេតុនោះ កម្មជរូបដែលអាហាររក្សាទុកនេះ ទើបឈ្មោះថា រូបមានអាហារជាបច្ច័យ ( អាហារបច្ចយរូប ) បុគ្គលសេពអាហារ ដែលមិនសមគួរដល់ខ្លួន ធ្វើដំណើរកណ្ដាលថ្ងៃ រមែងកើតរោគជាំមុខជាដើម នេះឈ្មោះថា រូបមានឧតុជាសមុដ្ឋានកើតអំពីអាហារជាបច្ច័យ ( អាហារបច្ចយឧតុសមុដ្ឋានរូប ) ។

សុទ្ធដ្ឋករូបតាំងឡើងអំពីឧតុ ឈ្មោះថា រូបមានឧតុជាសមុដ្ឋាន ( ឧតុសមុដ្ឋានរូប ) ឧតុក្នុងសុទ្ធដ្ឋកៈនោះ ក៏ញ៉ាំងរូប ៨ យ៉ាងដទៃ ឲ្យតាំងឡើង នេះឈ្មោះថា រូបមានឧតុជាបច្ច័យ ( ឧតុបច្ចយរូប ) ឧតុក្នុងរូបពួក

៨ យ៉ាងដទៃនោះ រមែងញុំាងរូបពួក ៨ យ៉ាង ដទៃទៀត ឲ្យតាំងឡើង នេះឈ្មោះថា រូបមានឧតុជាសមុដ្ឋានកើតអំពីឧតុជាបច្ច័យ ( ឧតុបច្ចយ-ឧតុសមុដ្ឋានរូប ) ។ ដោយប្រការដូច្នេះ ឧតុអាចបន្តសន្តតិរូប ៣ ប៉ុណ្ណោះ ហួសអំពីនេះទៅ ឧតុមិនអាចដើម្បីបន្ត ។ សេចក្តីនេះសមគួរសម្តែង សូម្បីដោយអនុបាទិន្នករូប ។ ដូចពពកឈ្មោះថា មានឧតុជាសមុដ្ឋាន ដំណក់ភ្លៀង ឈ្មោះថា មានឧតុជាបច្ច័យ កាលភ្លៀងធ្លាក់ហើយ ពូជទាំងឡាយរមែងដុះឡើង ផែនដីរមែងបញ្ចូនក្លិន ភ្នំរមែងប្រាកដជាពណ៌ខៀវ ទឹកសមុទ្ររមែងច្រើនឡើង ដោយអាការយ៉ាងនេះ ឈ្មោះថា រូបមានឧតុជាសមុដ្ឋានកើតអំពីឧតុជាបច្ច័យ ( ឧតុបច្ចយឧតុសមុដ្ឋានរូប ) ។

សុទ្ធដ្ឋករូបតាំងឡើងអំពីចិត្ត ឈ្មោះថា រូបមានចិត្តជាសមុដ្ឋាន ( ចិត្ត-សមុដ្ឋានរូប ) ពាក្យ ( ក្នុងអភិធម្មមហាបដ្ឋាន ) ថា ធម៌ទាំងឡាយ គឺចិត្តនិងចេតសិកដែលកើតក្រោយ ជាបច្ច័យនៃកាយនេះដែលកើតមុន ដោយបច្ឆាជាតប្បច្ច័យ នេះឈ្មោះថា រូបមានចិត្តជាបច្ច័យ ( ចិត្តបច្ចយរូប ) ពាក្យ ( ក្នុងខុទ្ទកនិកាយបដិសម្ភិទាមគ្គ ) នេះថា ដំណែងខ្លួនជាដីខ្លះ ដំណែងខ្លួនជាសេះខ្លះ ដំណែងខ្លួនជារថខ្លះ ដំណែងខ្លួនជាពលថ្មើរជើងខ្លះ ដំណែងខ្លួនជាកងទាហានផ្សេងៗខ្លះ ( ក្នុងអាកាស ) នេះឈ្មោះថា រូបមានឧតុជាសមុដ្ឋានកើតអំពីចិត្តជាបច្ច័យ ( ចិត្តបច្ចយឧតុសមុដ្ឋានរូប ) ។

ពាក្យថា បរិនិប្ផន្នៈ បានដល់ រូប ( កើតអំពីកម្ម ) ១៥ រូប ឈ្មោះថា បរិនិប្ផន្នរូប ។ រូប ១០ ឈ្មោះថាអបរិនិប្ផន្នៈ ( រូបមិនកើតអំពីកម្ម ) ។

បើរូបជាអបរិនិប្ផន្ន រូបទាំងនោះទើបជាអសង្ខតរូប ។ តែកាយវិការរបស់រូបទាំងនោះឯង ឈ្មោះថា កាយវិញ្ញត្តិ ។ វចីវិការរបស់រូបទាំងនោះឯងឈ្មោះថា វចីវិញ្ញត្តិ ។ លំហ ទីទទេ ឈ្មោះថា អាកាសធាតុ ។ ការស្រាលនៃរូប ឈ្មោះថា លហុតា ។ ភាពទន់នៃរូប ឈ្មោះថា មុទុតា ។ ការសមគួរដល់ការងារ ឈ្មោះថា កម្មញ្ញតា ។ ការកើតឡើង ឈ្មោះថា ឧបចយ ។ ការប្រព្រឹត្តទៅ ឈ្មោះថា សន្តតិ ។ អាការ គឺការចាស់ ឈ្មោះថា ជរតា អាការដែលមានហើយត្រឡប់ជាមិនមាន ឈ្មោះថា អនិច្ចតា ។ ព្រោះហេតុនោះ ទើបអបរិនិប្ផន្នរូបទាំងអស់ជាសង្ខតៈ ( មានបច្ច័យតាក់តែង ) នោះឯង ។

## អដ្ឋកថារូបកណ្ឌ ចប់

# អភិធម្មបិដក

## និក្ខេបកណ្ឌ

[ ១៦៣ ] ពួកធម៌ជាកុសល តើដូចម្ដេច ។ កុសលមូល ៣ គឺអលោភៈ ( ការមិនលោភ ) ១ អទោសៈ ( ការមិនប្រទូស្ដ ) ១ អមោហៈ ( ការមិនវង្វេង ) ១ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកុសលមូលមានអលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកុសលមូល មានអលោភៈជាដើមនោះ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាអកុសល តើដូចម្ដេច ។ អកុសលមូល ៣ គឺលោភៈ ១ ទោសៈ ១ មោហៈ ១ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានឹងអកុសលមូល មានលោភៈជាដើមនោះ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធដែលប្រកបដោយអកុសលមូល មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីអកុសលមូល មានលោភៈជាដើមនោះ នេះពួកធម៌ជាអកុសល ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ វិបាក ជាកាមាវចរៈ រូបាវចរៈ អរូបាវចរៈនិងអបរិយាបន្ន ( លោកុត្តរ ) នៃធម៌ជាកុសលនិងអកុសល វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ទាំងពួកធម៌ដែលគ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាក ឬក៏រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ជាអព្យាក្រឹត ។

[ ១៦៤ ] ពួកធម៌ប្រកបដោយសុខវេទនា តើដូចម្ដេច វៀរតែសុខវេទនា ក្នុងសុខភូមិ ជាកាមាវចរ រូបាវចរនិងអបរិយាបន្នចេញ សញ្ញាខន្ធ

សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធដែលប្រកបដោយសុខវេទនានោះ នេះពួកធម៌ប្រកបដោយសុខវេទនា ។ ពួកធម៌ប្រកបដោយទុក្ខវេទនា តើដូចម្តេច ។ វៀរតែទុក្ខវេទនាក្នុងទុក្ខភូមិជាកាមាវចរចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធដែលប្រកបដោយទុក្ខវេទនានោះ នេះពួកធម៌ប្រកបដោយទុក្ខវេទនា ។ ពួកធម៌ប្រកបដោយវេទនា មិនជាទុក្ខមិនជាសុខ តើដូចម្តេច ។ វៀរតែអទុក្ខមសុខវេទនាក្នុងអទុក្ខមសុខភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរនិងអបរិយាបន្នចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធដែលប្រកបដោយអទុក្ខមសុខវេទនានោះ នេះពួកធម៌ប្រកបដោយវេទនាមិនជាទុក្ខមិនជាសុខ ។

[ ១៦៥ ] ពួកធម៌ជាវិបាក តើដូចម្តេច វិបាកជាកាមាវចរ រូបាវចរ អរូបាវចរ និងអបរិយាបន្នៈនៃពួកធម៌ជាកុសលនិងអកុសល និងវេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាវិបាក ។ ពួកធម៌មានវិបាកធម៌ជាប្រក្រតី តើដូចម្តេច ។ ពួកធម៌ជាកុសលនិងអកុសលជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌មានវិបាកធម៌ជាប្រក្រតី ។ ពួកធម៌មិនមែនវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី តើដូចម្តេច ។ ពួកធម៌គ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាក រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែនវិបាក ទាំងមិនមែនមានវិបាកធម៌ជាប្រក្រតី ។

[ ១៦៦ ] ពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ វិបាកប្រកប

ដោយអាសវៈ ជាកាមាវចរ រូបាវចរ អរូបាវចរនៃធម៌ជាកុសលនិងអកុ-សល វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធនិងកម្មសមុដ្ឋានរូប ( រូបដែលកម្មកំពុងធ្វើ ) នេះពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបា-ទាន តើដូចម្តេច ។ ពួកធម៌ជាកុសលនិងអកុសល ប្រកបដោយអាសវៈជាកាមាវចរ រូបាវចរ អរូបាវចរនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ឬពួកធម៌គ្រាន់តែជាកិរិយា មិនមែនកុសល មិនមែនអកុសល មិនមែនកម្មវិបាក ឬក៏រូបដែលមិនមែនកម្មសមុដ្ឋានរូប នេះពួកធម៌មិនមានកម្ម ប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ អបរិយាបន្នមគ្គ ផលដែលកើតអំពីមគ្គនិងអសង្ខតធាតុ នេះពួកធម៌មិនមានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។

[ ១៦៧ ] ពួកធម៌ដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ អកុសលមូល ៣ គឺលោភៈ ១ ទោសៈ ១ មោហៈ ១ ទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានឹងលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយលោភៈជាដើមនោះ និងកាយកម្ម វចីកម្មមនោកម្ម ដែលតាំងឡើងអំពីលោភៈជាដើមនោះ នេះពួកធម៌ដែលសៅហ្មង

ទាំងគួរដល់សេចក្តីសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ អបរិយាបន្នមគ្គ ផលដែលកើតអំពីមគ្គ និងអសង្ខតធាតុនេះ ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង ។

[ ១៦៨ ] ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ តើដូចម្តេច ។ វៀរតែវិតក្កៈនិងវិចារៈក្នុងសវិតក្កសវិចារភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នៈចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយវិតក្កៈ-វិចារនោះ នេះពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ ។ ពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ តើដូចម្តេច ។ វៀរតែវិចារៈក្នុងអវិតក្កៈ-វិចារមត្តភូមិ ជារូបាវចរ អបរិយាបន្នចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយវិចារៈនោះ នេះពួកធម៌គ្មានវិតក្កៈ មានត្រឹមតែវិចារៈ ។ ពួកធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ក្នុងអវិតក្កាវិចារភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន រូបទាំងអស់និងអសង្ខធាតុ នេះពួកធម៌គ្មានវិតក្កៈ ទាំងគ្មានវិចារៈ ។

[ ១៦៩ ] ពួកធម៌ប្រកបដោយបីតិ តើដូចម្តេច ។ វៀរតែបីតិក្នុងបីតិភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ

ដែលប្រកបដោយបីតិនោះ នេះពួកធម៌ប្រកបដោយបីតិ ។ ពួកធម៌ប្រកបដោយសុខ តើដូចម្ដេច ។ វៀរតែសុខក្នុងសុខភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយសុខនោះ នេះពួកធម៌ប្រកបដោយសុខ ។ ពួកធម៌ប្រកបដោយឧបេក្ខា តើដូចម្ដេច ។ វៀរតែឧបេក្ខាក្នុងឧបេក្ខាភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយឧបេក្ខានោះ នេះពួកធម៌ប្រកបដោយឧបេក្ខា ។

[ ១៧០ ] ពួកធម៌គួរលះដោយទស្សនៈ តើដូចម្ដេច ។ សញ្ញោជនៈ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វតបរាមាស ។

[ ១៧១ ] បណ្ដាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្ដេច ។ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងយល់ឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ យល់ឃើញវេទនាថាជាខ្លួន ឃើញខ្លួនថាមានវេទនាខ្លះ ឃើញវេទនាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវេទនាខ្លះ យល់ឃើញសញ្ញាថាជាខ្លួន ឃើញខ្លួនថាមានសញ្ញាខ្លះ ឃើញសញ្ញាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងសញ្ញាខ្លះ យល់ឃើញសង្ខារថាជាខ្លួន ឃើញខ្លួនថាមានសង្ខារខ្លះ ឃើញសង្ខារថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមាន

ក្នុងសង្ខារខ្លះ យល់ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ( ការយល់ឃើញ ) ដំណើរគឺទិដ្ឋិ ញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការប្រកបទុកគឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ស្អិត ការប្រកាន់លើសលុប ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតដែលខុស លទ្ធិដូចជាកំពង់ ការប្រកាន់ក្នុងការស្វែងរកខុសណាដែលមានសភាពបែបនេះ នេះហៅថា សក្កាយទិដ្ឋិ ។

[ ១៧២ ] បណ្តាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្តេច ។ បុគ្គលងឿងឆ្ងល់សង្ស័យចំពោះព្រះសាស្តា ងឿងឆ្ងល់សង្ស័យចំពោះព្រះធម៌ ងឿងឆ្ងល់សង្ស័យចំពោះព្រះសង្ឃ ងឿងឆ្ងល់សង្ស័យក្នុងសិក្ខា ងឿងឆ្ងល់សង្ស័យក្នុងខន្ធខាងដើម ងឿងឆ្ងល់សង្ស័យក្នុងខន្ធខាងចុង ងឿងឆ្ងល់សង្ស័យក្នុងខន្ធខាងដើមនិងខន្ធខាងចុង ងឿងឆ្ងល់សង្ស័យក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យនូវបច្ច័យនោះៗ ការងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពងឿងឆ្ងល់ ការយល់ស្ទាក់ស្ទើរ ការសង្ស័យ ការបែកចិត្តជាពីរ ការបែកចិត្តជាពីរផ្លូវ ការសង្ស័យ ការប្រកាន់យកចំណែកដ៏ច្រើន ការសាញប្រដាញ ការសាន់វាន់ចិត្ត ការប្រកាន់មិនដាច់ស្រេច ភាពនៃចិត្តរើងរូស ការរសេមរសាមនៃចិត្តណា ដែលមានសភាពបែបនេះ នេះហៅថា វិចិកិច្ឆា ។

[ ១៧៣ ] បណ្តាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាស តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ខាងក្រៅអំពីសាសនានេះ មានទិដ្ឋិ ដំណើរ

គឺទិដ្ឋិ ញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ច្រឡំគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការប្រកាន់ ការប្រកាន់ចំពោះ ការប្រកាន់លើសលុប ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតដែលខុស លទ្ធិដូចជាកំពង់ ការប្រកាន់ ក្នុងការស្វែងរកខុសថា សេចក្តីបរិសុទ្ធដោយសីល សេចក្តីបរិសុទ្ធដោយវត្ត សេចក្តីបរិសុទ្ធដោយសីលនិងវត្តដូច្នេះណា មានសភាពបែបនេះ នេះហៅថា សីលព្វតបរាមាស ។

[ ១៧៤ ] សញ្ញោជនៈទាំង ៣ នេះ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌ត្រូវលះដោយទស្សនៈ ( សោតាបត្តិមគ្គ ) ។ ពួកធម៌ត្រូវលះដោយភាវនាតើដូចម្តេច ។ លោភៈ ទោសៈ មោហៈដ៏សេសសល់ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌ត្រូវលះដោយភាវនា ។ ពួកធម៌មិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា តើដូចម្តេច ។ ពួកធម៌ជាកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ បរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនត្រូវលះដោយទស្សនៈ មិនត្រូវលះ

ដោយភាវនា ។

[ ១៧៥ ] ពួកធម៌មានហេតុត្រូវលះដោយទស្សនៈ តើដូចម្តេច ។ សញ្ញោជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វតបរាមាស ។ បណ្តាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្តេច ។បេ។ នេះហៅថា សក្កាយទិដ្ឋិ ។ បណ្តាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្តេច ។បេ។ នេះហៅថាវិចិកិច្ឆា ។ បណ្តាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាស តើដូចម្តេច ។បេ។ នេះហៅថា សីលព្វតបរាមាស ។ សញ្ញោជនៈទាំង ៣ នេះ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេសមាន លោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ។ សញ្ញោ-ជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វបរាមាស នេះពួកធម៌ត្រូវលះដោយទស្សនៈលោភៈ ទោសៈ មោហៈដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទ-នាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ។ ពួកធម៌មានហេតុត្រូវលះដោយភាវនា តើដូចម្តេច ។ លោភៈ ទោសៈ មោហៈ

ដ៏សេសសល់ នេះពួកធម៌មានហេតុត្រូវលះដោយភាវនា ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកិលេស មានលោភជាដើមនោះ នេះពួកធម៌មានហេតុត្រូវលះដោយភាវនា ។ ពួកធម៌មានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មានហេតុមិនត្រូវលះដោយទស្សនៈ មិនត្រូវលះដោយភាវនា ។

[ ១៧៦ ] ពួកធម៌ដល់នូវការសន្សំកពូនឡើង ដោយកម្មក្កិលេស តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាងកុសលនិងអកុសល ជាកាមាវចរ រូបាវចរ អរូបាវចរនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដល់នូវការសន្សំកពូនឡើងដោយកម្មក្កិលេស ។ ពួកធម៌មិនដល់នូវការសន្សំកពូនឡើង តើដូចម្តេច ។ មគ្គ ៤ និងអបរិយាបន្នៈ នេះពួកធម៌មិនដល់នូវការសន្សំកពូនឡើង ។ ពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង តើដូចម្តេច ។ វិបាក ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៈនៃធម៌ជាកុសលនិងអកុសល វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ទាំងពួកធម៌ដែលជាកិរិយាមិនមែនកុសល មិន

មែនអកុសល មិនមែនកម្មវិបាក រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាដល់នូវការសន្សំកពូនឡើង ទាំងមិនមែនជាមិនដល់នូវការសន្សំកពូនឡើង ។

[ ១៧៧ ] ពួកធម៌ជារបស់សេក្ខបុគ្គល តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នៈ និងសាមញ្ញផល ៣ ខាងក្រោម នេះពួកធម៌ជារបស់សេក្ខបុគ្គល ។ ពួកធម៌ជារបស់អសេក្ខបុគ្គល តើដូចម្តេច ។ អរហត្តផលខាងលើ នេះពួកធម៌ជារបស់អសេក្ខបុគ្គល ។ ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ។

[ ១៧៨ ] ពួកធម៌មានសភាពតូចឆ្មារ តើដូចម្តេច ។ ពួកធម៌ជាកាមាវចរទាំងអស់ ជាកុសល អកុសល អព្យាក្រឹតនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌មានសភាពតូចឆ្មារ ។ ពួកធម៌ដល់នូវសភាពធំ តើដូចម្តេច ។ ពួកធម៌ជារូបាវចរ អរូបាវចរ ជាកុសល អកុសល អព្យាក្រឹតនិងវេទនាក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដល់នូវសភាពធំ ។ ពួកធម៌ប្រមាណមិនបាន តើដូចម្តេច ។ មគ្គជាអបរិយាបន្នៈ ផលដែលកើតអំពីមគ្គនិងអសង្ខតធាតុ នេះពួកធម៌ប្រមាណមិនបាន ។

[ ១៧៩ ] ពួកធម៌មានអារម្មណ៍តូចឆ្មារ តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌មានសភាពតូចឆ្មារ នេះពួកធម៌មានអារម្មណ៍តូចឆ្មារ ។ ពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ដល់នូវសភាពធំ នេះពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ។ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ប្រមាណមិនបាន នេះពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ។

[ ១៨០ ] ពួកធម៌ដ៏ថោកទាប តើដូចម្តេច ។ អកុសលមូល ៣ យ៉ាង គឺ លោភៈ ទោសៈនិងមោហៈ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានឹងអកុសលមូល មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយអកុសលមូល មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីអកុសលមូល មានលោភៈជាដើមនោះ នេះពួកធម៌ដ៏ថោកទាប ។ ពួកធម៌ជាកណ្តាល តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាកណ្តាល ។ ពួកធម៌ដ៏ឧត្តម តើដូចម្តេច ។ មគ្គជាបរិយាបន្ន ផលដែលកើតអំពីមគ្គ និងអសង្ខតធាតុ នេះពួកធម៌ដ៏ឧត្តម ។

[ ១៨១ ] ពួកធម៌មានសភាពខុសនិងទៀង តើដូចម្តេច ។ អនន្តរិក

កម្ម ៥ និងនិយតមិច្ឆាទិដ្ឋិ នេះពួកធម៌មានសភាពខុសនិងទៀង ។ ពួកធម៌មានសភាពត្រូវនិងទៀង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្ន នេះពួកធម៌មានសភាពត្រូវនិងទៀង ។ ពួកធម៌មិនទៀង តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនទៀង ។

[ ១៨២ ] ពួកធម៌មានមគ្គ ជាអារម្មណ៍ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវអរិយមគ្គ នេះពួកធម៌មានមគ្គជាអារម្មណ៍ ។ ពួកធម៌មានមគ្គជាហេតុ តើដូចម្តេច ។ វៀរតែអង្គនៃមគ្គរបស់បុគ្គលដែលព្រមព្រៀងដោយអរិយមគ្គចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយមគ្គនោះ នេះពួកធម៌មានមគ្គ ជាហេតុ ។ សម្មាទិដ្ឋិរបស់បុគ្គលដែលព្រមព្រៀងដោយអរិយមគ្គជាមគ្គផង ជាហេតុផង វៀរលែងតែសម្មាទិដ្ឋិចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយមគ្គនិងហេតុនោះ នេះពួកធម៌មានមគ្គជាហេតុ ។ អលោភៈ អទោសៈ អ-មោហៈរបស់បុគ្គលដែលព្រមព្រៀងដោយអរិយមគ្គ នេះពួកធម៌មានមគ្គ ជាហេតុ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយមគ្គជាហេតុនោះ នេះពួកធម៌មានមគ្គជាហេតុ ។ ពួកធម៌មានមគ្គជាអធិបតី តើដូចម្តេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះធ្វើនូវអរិយមគ្គឲ្យជាអធិបតី នេះពួកធម៌មានមគ្គជាអធិបតី ។ វៀរលែងតែវីមំសារបស់បុគ្គល

ដែលព្រមព្រៀងដោយអរិយមគ្គ កាលចម្រើននូវមគ្គ មានវីមំសាជាអធិបតី ចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយវីមំសានោះ នេះពួកធម៌មានមគ្គជាអធិបតី ។

[ ១៨៣ ] ពួកធម៌កើតឡើងហើយ តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ កើតហើយ មានហើយ កើតព្រមហើយ វិលមកកើតហើយ ត្រឡប់កើតហើយ កើតប្រាកដហើយ កើតឡើងហើយ កើតឡើងព្រមហើយ តាំងឡើងហើយ តាំងឡើងព្រមហើយ កើតហើយ សង្គ្រោះហើយ ដោយចំណែកនៃធម៌ដែលកើតហើយ នេះពួកធម៌កើតឡើងហើយ ។ ពួកធម៌មិនទាន់កើតឡើង តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលមិនទាន់កើត មិនទាន់មាន មិនទាន់កើតព្រម មិនទាន់វិលមកកើត មិនទាន់ត្រឡប់មកកើត មិនទាន់កើតប្រាកដ មិនទាន់កើតឡើង មិនទាន់កើតឡើងព្រម មិនទាន់តាំងឡើង មិនទាន់តាំងឡើងព្រម មិនទាន់កើតឡើង ដែលសង្គ្រោះហើយដោយចំណែកនៃធម៌ដែលមិនទាន់កើតឡើង នេះពួកធម៌មិនទាន់កើតឡើង ។ ពួកធម៌បម្រុងនឹងកើតឡើង តើដូចម្តេច ។ វិបាកជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នៃនៃធម៌ជាកុសលនិងអកុសល ដែលមានវិបាក មិនទាន់ចាស់ក្លា វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធនិងកម្មសមុដ្ឋានរូប ដែលបម្រុងនឹងកើតឡើង នេះពួកធម៌បំរុងនឹងកើតឡើង ។

[ ១៨៤ ] ពួកធម៌ជាអតីតៈ តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា

សញ្ញា សង្ខារ វិញ្ញាណដែលកន្លងហើយ រលត់ទៅហើយ ប្រាសទៅហើយ ប្រែប្រួលទៅហើយ វិនាសទៅហើយ វិនាសទៅយូរហើយ កើតឡើងហើយ ប្រាសទៅហើយ កន្លងទៅហើយ ដែលសង្គ្រោះដោយចំណែកនៃធម៌ ដែលកន្លងហើយ នេះពួកធម៌ជាអតីតៈ ។ ពួកធម៌ជាអនាគត តើដូចម្ដេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលមិនទាន់កើត មិនទាន់មាន មិនទាន់កើតព្រម មិនទាន់វិលមកកើត មិនទាន់ត្រឡប់មកកើត មិនទាន់កើតប្រាកដ មិនទាន់កើតឡើង មិនទាន់កើតឡើងព្រម មិនទាន់តាំងឡើង មិនទាន់តាំងឡើងព្រម មិនទាន់មកដល់ ដែលសង្គ្រោះដោយចំណែកនៃធម៌ដែលមិនទាន់មកដល់ នេះពួកធម៌ជាអនាគត ។ ពួកធម៌ជាបច្ចុប្បន្ន តើដូចម្ដេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកំពុងកើតមាន កើតព្រម វិលមកកើត ត្រឡប់មកកើត កើតប្រាកដ កើតឡើង កើតឡើងព្រម តាំងឡើង តាំងឡើងព្រម កើតឡើងចំពោះមុខដែលសង្គ្រោះដោយចំណែកនៃធម៌ ដែលកើតឡើងចំពោះមុខ នេះពួកធម៌ជាបច្ចុប្បន្ន ។

[ ១៨៥ ] ពួកធម៌មានអារម្មណ៍ជាអតីតៈ តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ ដែលកន្លងហើយ នេះពួកធម៌មានអារម្មណ៍ជាអតីតៈ ។ ពួកធម៌មានអារម្មណ៍ជាអនាគត តើដូចម្ដេច ។ ពួកធម៌ណា ប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ ដែលមិនទាន់មកដល់ នេះពួកធម៌មានអារម្មណ៍ជាអនាគត ។

ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ដែលកើតឡើងចំពោះមុខ នេះពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ។

[ ១៨៦ ] ពួកធម៌ជាខាងក្នុង តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលតាំងនៅក្នុងសន្តាន តាំងនៅក្នុងខ្លួនទៀងទាត់ ជារបស់ចំពោះបុគ្គលម្នាក់ ប្រកាន់ខ្ជាប់ក្នុងសរីរៈនៃពួកសត្វនោះៗ នេះពួកធម៌ជាខាងក្នុង ។ ពួកធម៌ជាខាងក្រៅ តើដូចម្តេច ។ ពួកធម៌ណា គឺរូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលតាំងនៅក្នុងសន្តាន តាំងនៅក្នុងខ្លួនទៀងទាត់ ជារបស់ចំពោះបុគ្គលម្នាក់ប្រកាន់ខ្ជាប់ក្នុងសរីរៈនៃពួកសត្វដទៃ នៃបុគ្គលដទៃនោះៗ នេះពួកធម៌ជាខាងក្រៅ ។ ពួកធម៌ខាងក្នុងទាំងខាងក្រៅ តើដូចម្តេច ។ ប្រជុំនៃខន្ធទាំងពីរនោះ ( ខន្ធខាងក្នុងនិងខន្ធខាងក្រៅ ) នេះពួកធម៌ខាងក្នុងទាំងខាងក្រៅ ។

[ ១៨៧ ] ពួកធម៌មានអារម្មណ៍ខាងក្នុង តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ខាងក្នុង នេះពួកធម៌មានអារម្មណ៍ខាងក្នុង ។ ពួកធម៌មានអារម្មណ៍ខាងក្រៅ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើងព្រោះប្រារព្ធនូវធម៌ខាងក្រៅ នេះពួកធម៌មានអារម្មណ៍ខាងក្រៅ ។ ពួកធម៌មានអារម្មណ៍ខាងក្នុងទាំងខាងក្រៅ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅក្នុងចិត្តនិងចេតសិក កើតឡើង ព្រោះប្រារព្ធនូវធម៌ខាងក្នុងនិងខាងក្រៅ នេះពួកធម៌មានអារម្មណ៍ខាង

ក្នុងទាំងខាងក្រៅ ។

[ ១៨៨ ] ពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ រូបាយតនៈ នេះពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ ចក្ខាយតនៈ សោតាយតនៈ ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ នេះពួកធម៌មិនប្រកបដោយការឃើញតែប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណខន្ធ រូបដែលជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងអសង្ខតធាតុ នេះពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

**ចប់ ពួកតិកៈ ។**

# អដ្ឋកថា
# និក្ខេបកណ្ឌ
# អធិប្បាយ តិកនិក្ខេប

[ ១៦៣ ] ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ កុសលត្តិកៈ ឈ្មោះថា ព្រះមានព្រះភាគទ្រង់ឲ្យពិស្ដារហើយដោយន័យគឺ ការចែកបទធម៌ មានកុសលជាដើមទាំងអស់ ។ ដោយន័យ គឺការចែកបទរបស់កុសលត្តិកៈនេះណាដែលត្រាស់ទុកហើយ ន័យនេះឯង ជាន័យរបស់ការចែកតិកៈនិងទុកៈដ៏សេស ។ បណ្ឌិតទាំងឡាយ អាចកំណត់ន័យ គឺការចែកក្នុងតិកៈនិងទុកៈទាំងអស់តាមលំដាប់ជាដើមថា ពួកធម៌ប្រកបដោយសុខវេទនា តើដូចម្ដេច ។ ចិត្តជាកាមាវចរកុសល ប្រឡំដោយសោមនស្ស ប្រកបដោយញាណ មានរូបជាអារម្មណ៍ក្ដី ។បេ។ ឬថា ពួកអរូបធម៌ដទៃណាដែលកើតឡើង ព្រោះអាស្រ័យហេតុ កើតមានក្នុងសម័យនោះ ក្រៅអំពីវេទនាខន្ធ នេះពួកធម៌ប្រកបដោយសុខវេទនា ដូច្នេះ ដូចន័យគឺការចែកក្នុងកុសលត្តិកៈនេះ ក៏យ៉ាងនោះ ព្រោះហេតុនោះ ដើម្បីទ្រង់សរុបការសម្ដែងដោយពិស្ដារនោះ ហើយទ្រង់សម្ដែងការចែកធម៌ពួកតិកៈ និងទុកៈទាំងអស់ដោយន័យដទៃដែលមិនសង្ខេបពេក និងមិនពិស្ដារពេក ទើបទ្រង់ផ្ដើមនិក្ខេបកណ្ឌថា **កតមេ ធម្មា កុសលា** ពួកធម៌ជាកុសល តើដូចម្ដេច ដូច្នេះ ។ ពិតណាស់ ចិត្តុប្បាទកណ្ឌ ( ដែលពោលរួចមកហើយ ) ជាការសម្ដែងពិស្ដារ តែអដ្ឋុលជាកណ្ឌ ជាការសម្ដែងសង្ខេប តែនិក្ខេបកណ្ឌនេះ ជៀបនឹងចិត្តុប្បាទកណ្ឌ

រាប់ថាជាការសម្ដែងដោយសង្ខេប ចៀបនឹងអដ្ឋកថាកណ្ឌរាប់ថាជាការសម្ដែងដោយពិស្ដារ ព្រោះហេតុនោះ ទើបនិក្ខេបកណ្ឌនេះ ជាការសម្ដែងដែលមិនសង្ខេបពេក មិនពិស្ដារពេក ។ កណ្ឌនេះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **និក្ខេបកណ្ឌ** ព្រោះទ្រង់សរុបការសម្ដែងដោយពិស្ដារ ហើយសម្ដែងទុកខ្លះដោយអំណាចនៃហេតុដែលពោលទុកខាងដើមខ្លះ ។

មែនពិត ពាក្យនេះខ្ញុំពោលទុកហើយថា

ដែលហៅថា និក្ខេប ព្រោះទ្រង់សម្ដែងសរុបដោយមូលខ្លះ ដោយខន្ធខ្លះ ដោយទ្វារខ្លះ ដោយភូមិខ្លះ ដោយអត្ថខ្លះ ដោយធម៌ខ្លះ ដោយនាមខ្លះ ដោយលិង្គខ្លះ ដូច្នេះ ។

និក្ខេបកណ្ឌនេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងសរុបដោយមូល ដោយន័យជាដើមថា កុសលមូល ៣ ទ្រង់សម្ដែងសរុបដោយខន្ធ ដោយន័យជាដើមថា វេទនាខន្ធប្រកបដោយកុសលមូលនោះ ទ្រង់សម្ដែងសរុបដោយទ្វារ ដោយន័យជាដើមថា កាយកម្មមានកុសលមូលនោះជាសមុដ្ឋាន កម្មប្រព្រឹត្តទៅតាមកាយទ្វារ ហៅថា កាយកម្ម ទ្រង់សម្ដែងសរុបដោយភូមិដោយន័យជាដើមថា ក្នុងកាមាវចរចិត្ត ដែលជាទីកើតនៃសុខវេទនា ទ្រង់សម្ដែងសរុបដោយន័យជាដើម ព្រោះទ្រង់សម្ដែងដោយអំណាចនៃអត្ថ ធម៌ លិង្គនិងនាមក្នុងទីនោះៗ គប្បីជ្រាបថា និក្ខេបកណ្ឌ ។

ក្នុងកុសលត្តិកនោះ គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃកុសលបទមុន ។ បទថា **តីណិ** ជាពាក្យកំណត់ចំនួន ។ សភាវធម៌ដែលឈ្មោះថា **កុសល-**

**មូលានិ** ដោយអត្ថថា ធម៌ទាំងឡាយនោះ ជាកុសលផង ជាមូលផង ឬថា ជាមូល ដោយអត្ថថា ជាហេតុ ជាបច្ច័យ ជាដែនកើត ជាជនក ជាសមុដ្ឋាន និងជាធម៌ឲ្យកើតឡើងនៃកុសលធម៌ទាំងឡាយ ។

ព្រះមានព្រះភាគ កាលទ្រង់សំដែងដោយអំណាចនៃអត្ថយ៉ាងនេះហើយ ឥឡូវនេះទ្រង់ប្រាថ្នាសំដែងដោយអំណាចនៃនាម ទើបត្រាស់ថា **អលោភោ អទោសោ អមោហោ** ។ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ព្រះធម្មរាជា ឈ្មោះថា ទ្រង់កំណត់សំដែងកុសលដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ដោយមូល ៣ ព្រោះឈ្មោះថា កុសលដែលផុតចាកមូល មិនមាន ។

បទថា **តំសម្បយុត្តោ** បានដល់ ដែលសម្បយុត្តដោយមូលទាំងនោះ មានអលោភៈជាដើម ។ ក្នុងសេចក្តីនេះ ក្នុងសង្ខារក្ខន្ធ ដែលសម្បយុត្តដោយអលោភៈ សូម្បីអទោសៈ និងអមោហៈ ក៏ដល់នូវការសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ ដែលសម្បយុត្តដោយអលោភៈដូចគ្នា ។ សូម្បីក្នុងសម្បយោគ ដោយអំណាចនៃកុសលមូល ២ ដ៏សេស ក៏ន័យនេះឯង ។ ព្រះធម្មរាជា ឈ្មោះថា ទ្រង់កំណត់សំដែងកុសល ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ដោយអំណាចនៃនាមក្ខន្ធ ៤ ដែលសម្បយុត្តដោយកុសលមូលនោះទៀត ដោយប្រការដូច្នេះ ។

បទថា **តំសមុដ្ឋានំ** បានដល់ តាំងឡើងដោយកុសលមូលទាំងនោះ មានអលោភៈជាដើម ។ សូម្បីដោយន័យនេះ ព្រះធម្មរាជា ឈ្មោះថាទ្រង់កំណត់សំដែងកុសល ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ នោះឯង ដោយ

អំណាចនៃកម្មទ្វារ ៣ ។ កុសលដែលទ្រង់កំណត់សម្ដែង ក្នុងឋានៈ ៣ ដោយប្រការដូច្នេះ ។ សូម្បីក្នុងអកុសល ក៏ន័យនេះដូចគ្នា ។ មែនពិត បណ្ដាអកុសលចិត្ត ១២ សូម្បីអកុសលចិត្ត ១ ដួង ដែលឈ្មោះថា ផុតចាកមូល រមែងមិនមាន ទើបព្រះធម្មរាជា កំណត់សម្ដែងអកុសលចិត្តទាំងនោះ ទុកដោយមូលទាំង ៣ ។ ដែលឈ្មោះថា អកុសលដែលក្រៅអំពីនាមក្ខន្ធ ៤ ដែលសម្បយុត្តដោយអកុសលមូលនោះ មិនមាន ព្រោះហេតុនោះ ទើបព្រះធម្មរាជា ទ្រង់កំណត់សម្ដែងអកុសលចិត្តទាំង ១២ នោះឯងដោយអំណាចនៃនាមក្ខន្ធ ៤ ។

មួយទៀត ព្រោះអកុសលចិត្តទាំង ១២ ដួងនេះ មានសភាវៈប្រព្រឹត្តទៅដោយអំណាចនៃកាយកម្មជាដើម ទើបទ្រង់កំណត់សម្ដែងដោយអំណាចកម្មទ្វារ ។ ព្រះបាលីណាដែលត្រាស់ទុកក្នុងអកុសលនិទ្ទេសនេះ មានពាក្យថា **តទេកដ្ឋា ច កិលេសា** ជាដើម គប្បីជ្រាបវិគ្គហៈក្នុងព្រះបាលីនោះថា កិលេសឈ្មោះថា **ឯកដ្ឋ** ព្រោះអត្ថថា តាំងនៅក្នុងចិត្តតែមួយ ឬក្នុងបុគ្គលតែមួយ ។ បណ្ដាអកុសលដែលតាំងនៅក្នុងឋានៈតែមួយ ទាំង ២ ន័យនោះ អកុសលដែលតាំងនៅក្នុងចិត្តតែមួយ ឈ្មោះថា **សហជេកដ្ឋ** ( ដោយការកើតព្រមគ្នា ) ។ អកុសលដែលតាំងនៅក្នុងបុគ្គលតែមួយ ឈ្មោះថា **ប-ហានេកដ្ឋ** ( ដោយការលះ ) ។ ដែលឈ្មោះថា **តទេកដ្ឋ** ព្រោះអត្ថថា តាំងនៅក្នុងទីតែមួយ ជាមួយនឹងអកុសលមូល មានលោភៈជាដើមនោះ ឬជាមួយធម៌ដទៃដែលទ្រង់សម្ដែងទុកក្នុងទីនោះៗ ។ ក្នុងសេចក្ដីនេះ អកុសល

ដែលតាំងនៅក្នុងឋានៈតែមួយ ដោយការកើតព្រម ( សហជកដ្ឋ ) មក ហើយក្នុងទីមានប្រមាណប៉ុណ្ណេះ គឺក្នុងសំកិលិដ្ឋត្តិកៈត្រាស់ថា ពួកធម៌ដែលសៅហ្មងទាំងគួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ អកុសលមូល ៣ គឺ លោភៈ ១ ទោសៈ ១ មោហៈ ១ ទាំងពួកកិលេសដែលតាំងនៅជាមួយគ្នានឹងលោភៈជាដើមនោះ ដូច្នេះ ។ ក្នុងហីនត្តិកៈត្រាស់ថា ពួកធម៌ដ៏ថោកទាប តើដូចម្ដេច ។ អកុសលមូល ៣ យ៉ាងគឺ លោភៈ ទោសៈនិងមោហៈ ទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានឹងអកុសលមូល មានលោភៈជាដើមនោះ ដូច្នេះ ។ ក្នុងអកុសលត្តិកៈនេះត្រាស់ថា ពួកធម៌ជាអកុសល តើដូចម្ដេច ។ អកុសលមូល ៣ គឺ លោភៈ ១ ទោសៈ ១ មោហៈ ១ ទាំងពួកកិលេស ដែលតាំងនៅជាមួយគ្នានឹងអកុសលមូល មានលោភៈជាដើមនោះ ដូច្នេះ ។ ក្នុងកិលេសគោច្ឆកៈត្រាស់ថា ពួកធម៌ដែលសៅហ្មង តើដូចម្ដេច ។ អកុសលមូល ៣ យ៉ាង គឺលោភៈ ទោសៈ មោហៈ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងអកុសលមូល មានលោភៈជាដើមនោះ ដូច្នេះ ។ ក្នុងសរណទុកៈ ត្រាស់ថា ពួកធម៌ប្រកបដោយរណៈ ( សឹកសត្រូវ ) តើដូចម្ដេច ។ អកុសលមូល ៣ គឺលោភៈ ទោសៈនិងមោហៈ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងអកុសលមូលនោះ ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបថា ចំណែកអកុសលដែលតាំងនៅក្នុងឋានៈជាមួយគ្នាដោយការលះ ( បហានេកដ្ឋ ) មកហើយក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ គឺទស្សនេនបហាតព្វត្តិកៈត្រាស់ថា សំយោជនៈ ៣ នេះ ទាំងពួក

កិលេសដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ ដូច្នេះ ។ សូម្បីក្នុងទស្សនេនបហាតព្វហេតុកត្តិកៈ ក៏ត្រាស់ថា សំយោជនៈ ៣ នេះ ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ ដូច្នេះ ។ ក្នុងទស្សនេនបហាតព្វហេតុកត្តិកៈនោះឯង ត្រាស់ទៀតថា សំយោជនៈ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វតបរាមាស នេះពួកធម៌គួរលះដោយទស្សនៈ ។ លោភៈ ទោសៈ មោហៈ ដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ នេះពួកធម៌មានហេតុ គួរលះដោយទស្សនៈ ។ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ កាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ដូច្នេះ ។

ក្នុងសម្មប្បធានវិភង្គត្រាស់ថា បណ្ដាធម៌ទាំងនោះ ពួកអកុសលធម៌ដ៏លាមកដែលមិនទាន់កើតឡើង តើដូចម្ដេច ។ អកុសលមូល ៣ គឺលោភៈ ទោសៈ មោហៈនិងពួកកិលេស ដែលឋិតនៅជាមួយនឹងអកុសលមូលនោះ ដូច្នេះ ។

និទ្ទេសនៃអព្យាកតបទ មានអត្ថងាយយល់ហើយ ។ អាចារ្យទាំងឡាយពោលថា លក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើម បញ្ញត្តិ ៣[១] កសិណុគ្ឃាដិមាកាស អជដាកាស អារម្មណ៍របស់អាកិញ្ចញ្ញាយតនសមាបត្តិនិង

---

១-នាមប្បញ្ញត្តិ ១ កសិណាប្បញ្ញត្តិ ១ សត្តប្បញ្ញត្តិ ១ ( ដីកា ) ។

និរោធសមាបត្តិ រមែងមិនបានក្នុងតិកៈនេះ ដូច្នេះ ។

[ ១៦៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃវេទនាតិកៈ ដូចតទៅនេះថា ក្នុងពាក្យថា **សុខភូមិយំ** នេះ អធិប្បាយថា គេហៅផែនដីថា **តម្ពភូមិ** ( ដីពណ៌ក្រហម ) **កណ្ហភូមិ** ( ដីពណ៌ខ្មៅ ) យ៉ាងណា សុខវេទនាក៏ឈ្មោះថា **សុខភូមិ** យ៉ាងនោះដែរ ។ ទីជាទីកើតឡើងនៃអំពៅនិងស្រូវសាលី គេពោលថា **ឧច្ឆុភូមិ សាលិភូមិ** យ៉ាងណា សូម្បីចិត្តដែលជាទីកើតនៃសេចក្តីសុខ ក៏ឈ្មោះថា **សុខភូមិ** យ៉ាងនោះ ចិត្តនោះទ្រង់សំដៅយកក្នុងពាក្យថា **សុខភូមិ** នេះ ព្រោះសុខភូមិនោះ មានក្នុងកាមាវចរៈខ្លះ ក្នុងរូបាវចរៈជាដើមខ្លះ ហេតុនោះ ដើម្បីទ្រង់សម្តែងប្រភេទនៃសុខភូមិនោះ ទើបត្រាស់ពាក្យថា **កាមាវចរេ** ដូច្នេះជាដើម ។

បទថា **សុខវេទនំ ឋបេត្វា** បានដល់ វៀរសុខវេទនាក្នុងសុខភូមិនោះ ។

បទថា **តំសម្បយុត្តោ** បានដល់ ដែលសម្បយុត្តដោយសុខវេទនាដែលតាំងនៅហើយនោះ ។ សូម្បីពីរបទដ៏សេស ក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ក្នុងតិកៈនេះ រមែងមិនបានសភាវធម៌នេះ គឺវេទនា ៣ រូបទាំងអស់និងនិព្វាន ។ ពិតណាស់ តិកៈនេះ ឈ្មោះថា ផុតហើយចាកចំណែកដែលរកមិនបានក្នុងកុសលត្តិកៈ និងចំណែកទាំង ៣ នេះ ។ ពាក្យណាដែលគួរពោលដោយព្រះបាលីនិងអដ្ឋកថាក្នុងតិកៈនិងទុកៈ ដទៃអំពីតិកៈនេះ ពាក្យទាំងអស់នោះ ខ្ញុំពោលទុកហើយក្នុងមាតិកាកថាដោយលំដាប់នៃបទ និងក្នុងនិទ្ទេសនៃកុសលជាដើមនុ៎ះឯង ។ តែខ្ញុំនឹងពោលចំពោះពាក្យដែលផ្សេងគ្នា

ប៉ុណ្ណោះ ។

[ ១៦៥ ] ពាក្យណាក្នុងទីដែលមានសេចក្ដីផ្សេងគ្នា គប្បីជ្រាបវិនិច្ឆ័យក្នុងវិបាកត្តិកៈមុន ។ សូម្បីរូបធម៌ទាំងឡាយមានកម្មជាសមុដ្ឋាន ដូចអរូបធម៌ក៏ពិត តែរូបធម៌ទាំងនោះ ក៏មិនដូចជាមួយនឹងកម្ម ព្រោះរូបធម៌ទាំងនោះមិនមានអារម្មណ៍ ព្រោះហេតុនោះអរូបធម៌ដែលមានអារម្មណ៍ប៉ុណ្ណោះ ត្រាស់ហៅថា **វិបាក** ព្រោះដូចគ្នានឹងកម្ម ដូចផ្លែរបស់ពូជដូចគ្នានឹងពូជ ដូច្នោះ ។ ពិតណាស់ កាលគេព្រោះពូជស្រូវសាលីហើយ សូម្បីក្នុងវេលាដែលចេញពន្លកនិងស្លឹកជាដើមហើយ គេក៏នៅមិនទាន់ហៅថាផ្លែរបស់ស្រូវសាលី តែកាលណាកួរស្រូវសាលីទុំហើយ ឱនចុះហើយ កាលនោះស្រូវសាលីដូចគ្នានឹងពូជនុ៎ះឯងទើបគេហៅថា ផ្លែរបស់ស្រូវសាលី ។ ចំណែកពន្លកនិងស្លឹកជាដើម ដែលកើតអំពីពូជ គេហៅថា ជាវត្ថុកើតអំពីពូជយ៉ាងណា សូម្បីរូបក៏យ៉ាងនោះដូចគ្នា គួរដើម្បីនឹងហៅថា កើតអំពីកម្ម ( កម្មជៈ ) ឬហៅថា ឧបាទិន្នរូប ដូច្នេះ ។

[ ១៦៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាទិន្នត្តិកៈ ដូចតទៅនេះថា

ខន្ធទាំងឡាយរបស់ព្រះខីណាស្រព សូម្បីនឹងជាបច្ច័យដល់ឧបាទានដល់ជនពួកដទៃ ដែលនិយាយថា ព្រះថេរៈជាអ៊ំរបស់ពួកយើង ព្រះថេរៈជាមារបស់ពួកយើង ដូច្នេះក៏ពិតមែន ទោះបីជាដូច្នោះ មគ្គ ផលនិងនិព្វានដែលតណ្ហា មានះ ទិដ្ឋិមិនបពោសអង្អែល មិនប្រកាន់ មិនកាន់យកឡើយ ដ្បិតថា មគ្គ ផល និព្វានទាំងនោះ រមែងមិនជាបច្ច័យដល់សេចក្ដីប្រកាន់ដោយ

អំណាចតណ្ហា មានះ ទិដ្ឋិ ព្រោះឧត្តមដោយតេជះ ដូចដុំដែកក្រហមដែលឆេះអស់មួយថ្ងៃ មិនជាបច្ច័យដល់ការទំរបស់ពួករុយ ដូច្នោះ ដោយហេតុនោះទើបត្រាស់ថា **ឥមេ ធម្មា អនុចានិន្នអនុចា** ដូច្នេះ ។

[ ១៦៧ ] សូម្បីក្នុងអសំកិលិដ្ឋអសំកិលេសិកធម៌ទាំងឡាយ ក៏ន័យនេះឯង ។

[ ១៦៨ ] ក្នុងវិតក្កត្តិកៈ រមែងមិនបានសភាវធម៌ដែលរកមិនបាន ក្នុងកុសលត្តិកៈនិងវិចារៈដែលកើតព្រមជាមួយវិតក្កៈ ។

[ ១៦៩ ] ក្នុងបីតិសហគតត្តិកៈធម៌ មានបីតិជាដើម ធ្វើឲ្យធម៌ដែលកើតរួមជាមួយខ្លួន ជាធម៌សហគតដោយបីតិជាដើម ហើយខ្លួនឯងក៏ជាធម៌វិលទៅខាងក្រោយ ក្នុងតិកៈនេះមិនបានសភាវធម៌នេះ គឺទោមនស្សសហគតចិត្តុប្បាទ ២ ទុក្ខសហគតកាយវិញ្ញាណ ១ ឧបេក្ខាវេទនា ១ រូប ១ និព្វាន ១ ពិតណាស់ តិកៈនេះ ឈ្មោះថា ផុតហើយចាកចំណែកដែលរកមិនបានក្នុងកុសលត្តិកៈ និងអំពីចំណែកទាំង ៥ នេះ ។

[ ១៧០-១៧១ ] ក្នុងទស្សនេនបហាតព្វត្តិកៈ មានវិគ្គហៈដូចតទៅនេះថា បទថា **សញ្ញោជនានិ** បានដល់ គ្រឿងចងទាំងឡាយ ។ បទថា **សក្កាយទិដ្ឋិ** សេចក្តីថា ការឃើញខុសក្នុងកាយ ពោលគឺបញ្ចក្ខន្ធ មានដោយអត្ថថា ប្រាកដ ឬខ្លួនឯងមានសេចក្តីយល់ខុសក្នុងកាយដែលមាន ព្រោះហេតុនោះ សេចក្តីយល់ខុសនោះ ទើបឈ្មោះថា **សក្កាយទិដ្ឋិ** ។ ចំណែកសេចក្តីប្រកាន់មាំដែលប្រកាន់ថា សត្វអាចបរិសុទ្ធដោយសីល អាចបរិសុទ្ធដោយ

វគ្គ អាចបរិសុទ្ធដោយសីលនិងវគ្គ ដូច្នេះ ឈ្មោះថា **សីលព្វតបរាមាស** ។

សូម្បីពាក្យថា **ឥធ** ជានិបាត ចុះក្នុងអត្ថអាងដល់ប្រទេស **ឥធ** សព្ទនេះ ក្នុងទីខ្លះត្រាស់សំដៅដល់លោក ដូចព្រះតម្រាស់ ( ក្នុងទីឃនិកាយសីលក្ខន្ធវគ្គ ) ថា **ឥធ តថាគតោ លោកេ ឧប្បជ្ជតិ** ព្រះតថាគតកើតឡើងក្នុងលោកនេះ ដូច្នេះ ក្នុងទីខ្លះសំដៅដល់សាសនា ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា **ឥធេវ ភិក្ខវេ សមណោ ឥធ ទុតិយោ សមណោ** ម្នាលភិក្ខុទាំងឡាយ សមណៈ ( ទី ១ ) ( គឺសោតាបន្ន ) មានតែក្នុងសាសនានេះ សមណៈ ទី ២ ( គឺសកទាគាមី ) ក៏មានតែក្នុងសាសនានេះ ដូច្នេះ ក្នុងទីខ្លះសំដៅដល់ឱកាស ដូចព្រះតម្រាស់ ( ក្នុងទីឃនិកាយមហាវគ្គ ) ថា **ឥធេវ តិដ្ឋមានស្ស ទេវភូតស្ស មេ សតោ បុនរាយុ ច មេ លទ្ធោ ឯវំ ជានាហិ មារិស** កាលអាត្មាអញ កើតជាទេវតាឋិតនៅក្នុងឱកាសនេះ អាត្មាអញ បានអាយុថ្មីទៀត ម្នាលគ្នាយើងអ្នកចូរដឹងយ៉ាងនេះចុះ ដូច្នេះ ។

ក្នុងទីខ្លះត្រឹមតែធ្វើបទឲ្យពេញប៉ុណ្ណោះ ដូចព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា **ឥធាហំ ភិក្ខវេ ភុត្តាវី អស្សំ បវារិតោ** ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះតថាគតបរិភោគស្រេច ឃាត់លែងទទួលទៀត ដូច្នេះ តែក្នុងទីនេះ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គត្រាស់សំដៅដល់លោក ។

ក្នុងបទថា **អស្សុតវា បុថុជ្ជនោ** នេះ មានវិនិច្ឆ័យថា បុគ្គលដែលជាបណ្ឌិតគួរជ្រាបថា ដែលឈ្មោះថា **អស្សុតវា** ព្រោះមិនមានការសិក្សាក្នុង

បរិយត្តិនិងការសម្រេចមគ្គផល ។ ពិតណាស់ បុគ្គលណាមិនមានការសិក្សាក្នុងបរិយត្តិដែលជាឧបាយហាមមិច្ឆាទិដ្ឋិ ព្រោះវៀរការសិក្សា ការសាកសួរ ការវិនិច្ឆ័យក្នុងធម៌ មានខន្ធ ធាតុ អាយតនៈ បច្ចយាការ និងសតិប្បដ្ឋានជាដើមមិនមានមគ្គផល ព្រោះមិនបានសម្រេចមគ្គផលដែលខ្លួនគប្បីសម្រេចបានដោយការបដិបត្តិ បុគ្គលនោះ បណ្ឌិតគប្បីជ្រាបថា ឈ្មោះថា **អស្សុតវា** ព្រោះមិនមានការសិក្សាក្នុងបរិយត្តិ និងការសម្រេចមគ្គផល ដោយប្រការដូច្នេះ ។

> បុគ្គលនេះ បណ្ឌិតគប្បីជ្រាបថា ជាបុថុជ្ជន ដោយហេតុទាំងឡាយ មានការញុំាងកិលេសជាច្រើន ឲ្យកើតឡើងជាដើម ម្យ៉ាងទៀត ជននេះ ឈ្មោះថា បុថុ ( អ្នកក្រាស់ ) ព្រោះឈមចុះខាងក្នុងភាពជាបុថុជ្ជន ។

ពិតណាស់ ជននោះ ឈ្មោះថា **បុថុជ្ជន** ដោយហេតុទាំងឡាយ មានការញុំាងកិលេសជាដើមដ៏ច្រើនមានប្រការផ្សេងៗឲ្យកើតឡើងជាដើម ក៏មានដូចលោកពោលទុកថា ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ញុំាងកិលេសច្រើនឲ្យកើត ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនដែលនៅមិនទាន់បានសម្លាប់សក្កាយទិដ្ឋិ ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនដែលចាំសម្លឹងមើលមុខ ( ស្វែងរក ) សាស្តាផ្សេងៗ ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនដែលចេញទៅ ចាកគតិទាំងពួងមិនបាន ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនសាងអភិសង្ខារផ្សេងៗ ។ ឈ្មោះថា **បុថុជ្ជន**

ព្រោះអត្ថថា ជាពួកជនត្រូវអន្ទង់ឱឃៈផ្សេងៗបន្សាត់ទៅ ។ ឈ្មោះថា **បុ-ថុជ្ជន** ព្រោះអត្ថថា ជាពួកជនដែលក្តៅក្រហាយដោយសេចក្តីក្តៅក្រហាយផ្សេងៗ ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនដែលត្រូវដុតដោយសេចក្តីក្តៅក្រហាយផ្សេងៗ ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនដែលប្រកបដោយតម្រេក សេចក្តីត្រេកអរ សេចក្តីស្រឡាញ់ ងប់ជ្រប់ ជាប់ធ្លាក់ ចំពាក់ក្នុងកាមគុណ ៥ ។ ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជាពួកជនត្រូវនីវរណៈ ៥ រារាំងហើយ ឡោមព័ទ្ធហើយ គ្របដណ្តប់ហើយ បិទបាំងហើយ បិទបាំងទុកហើយ ឲ្យថយត្រឡប់ហើយ ។

ម្យ៉ាងទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះពួកជនឈមចុះខាងក្នុងនៃជនទាំងឡាយ ហួសគណនា សុទ្ធតែបែរមុខចាកធម៌របស់ព្រះអរិយៈ និងមានការប្រព្រឹត្តធម៌ថោកទាបជានិច្ច ។ ម្យ៉ាងទៀត ឈ្មោះថា **បុថុជ្ជន** ព្រោះអត្ថថា ជនទេះជាអ្នកក្រាស់ដល់នូវការរាប់ចែកទុកដោយឡែក គឺមិនទាក់ទងនឹងព្រះអរិយៈទាំងឡាយ ដែលប្រកបដោយគុណ មានសីលនិងសុតៈជាដើម ។

បណ្តាបុថុជ្ជនពីរពួកដែលលោកពោលទុកថា

ព្រះពុទ្ធជាផៅពង្សនៃព្រះអាទិត្យ ត្រាស់បុថុជ្ជនពួកណា ជា
២ ពួក គឺអន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ដូច្នេះ ។

អន្ធបុថុជ្ជនបណ្ឌិតគប្បីជ្រាបថា ត្រាស់ហើយដោយពាក្យទាំង ២ នេះថា **អស្សុតវា បុថុជ្ជនោ** ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទជាដើមថា **អរិយានំ អទស្សាវី** ដូចតទៅនេះ

ថា ព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ ពុទ្ធសាវកទាំងឡាយ ហៅថា ព្រះអរិយៈ ព្រោះឆ្ងាយចាកកិលេស ព្រោះមិនប្រព្រឹត្តទៅក្នុងផ្លូវវិនាស ព្រោះប្រព្រឹត្តទៅក្នុងផ្លូវចម្រើន និងព្រោះសត្វលោកព្រមទាំងទេវលោកគប្បីចូលទៅរក តែក្នុងទីនេះ ព្រះអរិយៈ បានដល់ ព្រះពុទ្ធទាំងឡាយ ដូចព្រះតម្រាស់ថា **សទេវកេ ភិក្ខវេ លោកេ ។បេ។ តថាគតោ អរិយោតិ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ តថាគត ។បេ។ បណ្ឌិតហៅថា អរិយៈក្នុងលោកព្រមទាំងទេវលោក ដូច្នេះ ។

ចំណែកក្នុងពាក្យថា **សប្បុរិសា** នេះ ព្រះបច្ចេកពុទ្ធទាំងឡាយ សាវករបស់ព្រះតថាគតទាំងឡាយ គប្បីជ្រាបថា ឈ្មោះថា សប្បុរស ។ ពិតណាស់ ព្រះបច្ចេកពុទ្ធជាដើមទាំងនោះ ឈ្មោះថា **សប្បុរស** ព្រោះអត្ថថា ជាបុរសស្អាតដោយការប្រកបដោយលោកុត្តរគុណ ។ ម្យ៉ាងទៀត សប្បុរសទាំងអស់នេះ ពោលទុកជា ២ ចំណែក មែនពិត សូម្បីព្រះពុទ្ធទាំងឡាយក៏ឈ្មោះថាជាព្រះអរិយៈនិងជាសប្បុរស ព្រះបច្ចេកពុទ្ធនិងពុទ្ធសាវក របស់ព្រះតថាគតក៏ឈ្មោះថា ព្រះអរិយៈនិងជាសប្បុរស ដូចព្រះតម្រាស់ក្នុងសរភង្គជាតកថា

> បុគ្គលណាជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្តល្អ មានការសេពគប់មាំ ធ្វើនូវកិច្ចដោយគោរព ចំពោះបុគ្គលអ្នកដល់នូវសេចក្ដីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះថា ជាអ្នកសប្បុរស ដូច្នេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះថា មានមិត្តល្អ មានការសេពគប់មាំ ដូច្នេះ ត្រាស់ដល់សាវ័ករបស់ព្រះពុទ្ធដោយគុណ មានភាពជាកតញ្ញូជាដើម ត្រាស់ដល់ព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធ ដូច្នេះ ។ ឥឡូវនេះ គប្បីជ្រាបថា បុគ្គលណា មានប្រក្រតីមិនឃើញព្រះអរិយៈទាំងនោះ និងមិនមានសាធុការក្នុងការឃើញ បុគ្គលនោះឈ្មោះថា មិនបានឃើញពួកព្រះអរិយៈ ។ បុគ្គលអ្នកមិនបានឃើញព្រះអរិយៈនោះមាន ២ យ៉ាងគឺ មិនឃើញដោយចក្ខុនិងមិនឃើញដោយញាណ ក្នុងការមិនឃើញទាំង ២ យ៉ាងនោះ ក្នុងទីនេះទ្រង់បំណងយកអ្នកមិនឃើញដោយញាណ មែនពិត ព្រះអរិយៈទាំងឡាយសូម្បីបុគ្គលឃើញដោយមំសចក្ខុ ឬទិព្វចក្ខុ ក៏មិនឈ្មោះថាបានឃើញ ព្រោះចក្ខុទាំងនោះ កាន់យកត្រឹមតែពណ៌ ( វណ្ណៈ ) ជាអារម្មណ៍ មិនមែនព្រោះមានភាពជាព្រះអរិយៈជាអារម្មណ៍ សូម្បីសត្វទាំងឡាយ មានឆ្កែស្រុកនិងឆ្កែចចកជាដើម ក៏រមែងឃើញព្រះអរិយៈទាំងឡាយដោយចក្ខុ តែសត្វទាំងនោះ មិនឈ្មោះថា ឃើញព្រះអរិយៈទាំងឡាយ ក្នុងសេចក្ដីនោះ មានរឿងដូចតទៅនេះ ជាឧទាហរណ៍ ។

បានឮថា ឧបដ្ឋាករបស់ភិក្ខុជាព្រះខីណាស្រព អ្នកនៅក្នុងវិហារចិត្តលបព៌ត ជាភិក្ខុបួសឯចាស់ ថ្ងៃមួយ កាលត្រាច់ទៅបិណ្ឌបាតជាមួយនឹងព្រះថេរៈ ទទួលបាត្រចីវររបស់ព្រះថេរៈហើយ ក៏ដើរតាមក្រោយទៅ សួរព្រះថេរៈថា បពិត្រលោកម្ចាស់ ឈ្មោះថា ព្រះអរិយៈទាំងឡាយ តើដូចម្ដេច ព្រះថេរៈឆ្លើយថា មនុស្សចាស់ខ្លះ ក្នុងលោកនេះ ទទួលបាត្រចីវររបស់ព្រះ

អរិយៈទាំងឡាយ ធ្វើវត្តបដិបត្តិហើយ សូម្បីត្រាច់ទៅជាមួយគ្នាក៏មិនស្គាល់ព្រះអរិយៈទាំងឡាយ ម្នាលអាវុសោ ព្រះអរិយៈទាំងឡាយ ដឹងបានដោយកម្រយ៉ាងនេះ ដូច្នេះ ។ សូម្បីព្រះថេរៈនិយាយយ៉ាងនេះ ភិក្ខុចាស់នោះក៏នៅតែមិនយល់ឡើយ ។

ព្រោះហេតុនោះ ការឃើញដោយចក្ខុ មិនឈ្មោះថាឃើញ ការឃើញដោយញាណប៉ុណ្ណោះទើបឈ្មោះថាឃើញ ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយខន្ធវារវគ្គ ) ថា ប្រយោជន៍អ្វីដោយកាយសម្អុយ ដែលអ្នកឃើញហើយនេះ ។ ម្នាលវក្កលិ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះឈ្មោះថាឃើញតថាគត ដូច្នេះ ព្រោះហេតុនោះគប្បីជ្រាបថា បុគ្គលសូម្បីឃើញព្រះអរិយៈដោយចក្ខុ តែមិនឃើញនូវលក្ខណៈ មានការមិនទៀងជាដើម ដែលព្រះអរិយៈទាំងឡាយឃើញដោយញាណ និងមិនទាន់សម្រេចធម៌ដែលព្រះអរិយៈសម្រេចហើយ មិនឈ្មោះថា ឃើញព្រះអរិយៈទាំងឡាយ ព្រោះមិនឃើញធម៌ដែលធ្វើភាពជាព្រះអរិយៈ និងភាពជាព្រះអរិយៈ ដូច្នេះ ។

បទថា **អរិយធម្មស្ស អកោវិទោ** បានដល់ ភាពជាអ្នកមិនឈ្លាសក្នុងអរិយធម៌ មានសតិប្បដ្ឋានជាដើម ។

ក្នុងព្រះបាលីថា **អរិយធម្មេ អវិនីតោ** នេះ

ឈ្មោះថា វិន័យ មាន ២ យ៉ាង ក្នុងវិន័យ ២ យ៉ាងនេះ មួយយ៉ាងៗចែកចេញជា ៥ បុគ្គលនេះ លោកហៅថា អ្នកមិនបានទូន្មានខ្លួន ព្រោះការមិនមានវិន័យនោះ ដូច្នេះ ។

មែនពិត វិន័យមាន ២ យ៉ាង គឺ **សំវរវិន័យ** និង **បហានវិន័យ** បណ្ដាវិន័យទាំង ២ នេះ វិន័យនីមួយៗចែកចេញជា ៥ យ៉ាង ពិតណាស់ សូម្បីសំវរវិន័យក៏មាន ៥ យ៉ាងគឺ សីលសំវរៈ សេចក្ដីសង្រួមដោយសីល ១ សតិសំវរៈ សេចក្ដីសង្រួមដោយសតិ ១ ញាណសំវរៈ សេចក្ដីសង្រួមដោយញាណ ១ ខន្តិសំវរៈ សេចក្ដីសង្រួមដោយខន្តិ ១ វីរិយសំវរៈ សេចក្ដីសង្រួមដោយសេចក្ដីព្យាយាម ១ ។

សូម្បីបហានវិន័យ ក៏មាន ៥ យ៉ាងគឺ តទង្គប្បហាន ការលះដោយអង្គនៃវិបស្សនាញាណនោះ ១ វិក្ខម្ភនប្បហាន ការលះដោយការគ្របសង្កត់ ១ សមុច្ឆេទប្បហាន ការលះដោយអរិយមគ្គ ១ បដិបស្សទ្ធិប្បហាន ការលះដោយអរិយផល ១ និស្សរណប្បហាន ការលះដោយនិព្វាន ១ ។

បណ្ដាសំវរៈទាំង ៥ នោះ សំវរៈនេះថា ជាអ្នកព្រមព្រៀង មូលមិត្តដោយការសង្រួមក្នុងបាតិមោក្ខនេះ ដូច្នេះ ឈ្មោះថា **សីលសំវរៈ** ។ សំវរៈនេះថា រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ដូច្នេះ ឈ្មោះថា **សតិសំវរៈ** ។ សំវរៈនេះថា ( ព្រះមានព្រះភាគ ដោះស្រាយថា ម្នាលអជិតៈ ) សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះដែលមាននៅក្នុងលោក តថាគតពោលថា សតិជាគ្រឿងរាំងខ្សែតណ្ហាទាំងឡាយ បុគ្គលគប្បីបិទខ្សែតណ្ហាទាំងនោះដោយបញ្ញា ដូច្នេះ ឈ្មោះថា **ញាណសំវរៈ** ។ សំវរៈនេះថា អត់ធន់ចំពោះត្រជាក់ ក្ដៅ ដូច្នេះ ឈ្មោះថា **ខន្តិសំវរៈ** ។ សំវរៈនេះថា មិនឲ្យកើតមាននូវកាមវិតក្កៈដែលកើតឡើង ដូច្នេះ ឈ្មោះថា **វីរិយសំវរៈ** ។

សំវរៈទាំងអស់នេះ ត្រាស់ហៅថា **សំវរៈ** ព្រោះការពារ និងត្រាស់ហៅថា **វិន័យ** ព្រោះនាំចេញនូវកាយទុច្ចរិតជាដើម ដែលគួរដល់ការរារាំង និងគួរដល់ការនាំចេញតាមសមគួរដល់ខ្លួន ។ បណ្ឌិតគប្បីជ្រាបថា សំវរ-វិន័យ ចែកចេញជា ៥ យ៉ាង ដោយប្រការដូច្នេះ ។

មួយទៀត ការលះធម៌ដែលមិនមានប្រយោជន៍នោះ ដោយវិបស្សនា-ញាណនោះៗ ក្នុងវិបស្សនាញាណទាំងឡាយ មាននាមរូបបរិច្ឆេទញ្ញាណជាដើម ព្រោះជាបដិបក្ខនឹងគ្នា ដូចការលះបោលនូវងងឹត ដោយពន្លឺនៃប្រទីបដូច្នោះ តើលះដូចម្តេច គឺការលះសក្កាយទិដ្ឋិ ដោយកំណត់ចែកនាមរូប ( នាមរូបបរិច្ឆេទញ្ញាណ ) លះបង់ទិដ្ឋិដែលឃើញថា នាមរូបមិនមានហេតុ និងមានហេតុមិនស្មើគ្នាដោយការកំណត់ដឹងបច្ច័យ ( បច្ចយបរិគ្គហញ្ញាណ ) លះសេចក្តីសង្ស័យ ដោយកង្ខាវិតរណញ្ញាណ ខាងក្រោយអំពីបច្ចយបរិគ្គ-ហញ្ញាណនោះឯង លះសេចក្តីប្រកាន់មាំថា អញ របស់អញដោយកលាប-សម្មសនញ្ញាណ លះសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនមែនផ្លូវ ថាជាផ្លូវដោយកំណត់ផ្លូវនិងមិនមែនផ្លូវ ( មគ្គាមគ្គញ្ញាណ ) លះឧច្ឆេទទិដ្ឋិ ដោយឃើញការកើត ( ឧទយទស្សនញ្ញាណ ) លះបង់សស្សតទិដ្ឋិ ដោយឃើញការសូន្យ ( វយទស្សនញ្ញាណ ) លះបង់ការសម្គាល់ក្នុងវត្ថុ ដែលមានភ័យថាមិនមានភ័យ ដោយការឃើញថាមានភ័យ ( ភយទស្សនញ្ញាណ ) លះបង់សេចក្តីសម្គាល់ក្នុងវត្ថុគួរជាទីគាប់ចិត្តដោយការឃើញថាជាទោស ( អាទីនវ-ទស្សនញ្ញាណ ) លះបង់សេចក្តីសម្គាល់ដ៏គួរជាទីគាប់ចិត្តក្រៃលែង ដោយ

និព្វិទានុបស្សនាញាណ លះបង់ភាពជាអ្នកមិនប្រាថ្នានឹងរួចផុត ដោយមុញ្ចិតុ-កម្យតាញាណ លះបង់ភាពមិនព្រងើយកន្តើយក្នុងសង្ខារ ដោយឧបេក្ខា-ញាណ លះបង់ធម្មដ្ឋិតិ ( បដិច្ចសមុប្បាទ ) ដោយអនុលោមញ្ញាណ លះបង់ភាពជាបដិលោមដោយនិព្វាន លះបង់ការកាន់យកសង្ខារនិមិត្ត ដោយគោត្រភូញាណ ឯណា នេះឈ្មោះថា **តទង្គប្បហាន** ។

ការលះបង់ធម៌មាននីវរណៈជាដើមនោះៗ ដោយហាមការប្រព្រឹត្តទៅនៃធម៌ មាននីវរណៈជាដើមនោះ ដោយសមាធិចែកជាឧបចារៈនិងអប្បនា ដូចការវែកចកលើផ្ទៃទឹកដោយការគ្រវីក្អមយ៉ាងណា នេះឈ្មោះថា **វិក្ខម្ភនប្ប-ហាន** ។ ការលះបង់ពពួកកិលេសដែលជាចំណែកសមុទ័យ ដែលត្រាស់ទុកដោយន័យជាដើមថា ដើម្បីលះបង់នូវទិដ្ឋិ ដូច្នេះ ដោយមិនឲ្យប្រព្រឹត្តទៅជាដាច់ខាតក្នុងសន្តានរបស់ខ្លួនដោយភាពជាមគ្គនោះៗ ព្រោះចម្រើនអរិយ-មគ្គ ៤ ហើយ ឯណា នេះឈ្មោះថា **សមុច្ឆេទប្បហាន** ។

ការដែលកិលេសទាំងឡាយ ស្ងប់រម្ងាប់ក្នុងខណៈនៃផលឯណា នេះឈ្មោះថា **បដិបស្សទ្ធិប្បហាន** ។

ព្រះនិព្វានដែលលះសង្ខតធម៌ទាំងពួង បានហើយ ព្រោះជាធម៌រលាស់ចោលនូវសង្ខតធម៌ទាំងពួងចេញឯណា នេះឈ្មោះថា **និស្សរណប្បហាន** ។

ព្រោះការលះបង់ទាំងអស់នេះ ហៅថា **បហានវិន័យ** ព្រោះជា បហាន ដោយអត្ថថា លះបង់ ជា **វិន័យ** ដោយអត្ថថា កម្ចាត់ ។ ម្យ៉ាងទៀត បហាននេះ ហៅថា **បហានវិន័យ** ព្រោះការកើតឡើងនៃវិន័យនោះ ដែល

មានការប្រហារនោះៗ ។ បណ្ឌិតគប្បីជ្រាបថា បហានវិន័យ ក៏ចែកបាន ៥ យ៉ាង ដោយប្រការដូច្នេះ ។

វិន័យនេះដោយសង្ខេបមាន ២ យ៉ាង ដោយការចែកមាន ១០ យ៉ាង នេះ រមែងមិនមានដល់បុថុជ្ជនដែលមិនចេះដឹងនោះ ព្រោះមានសំវរៈទម្លាយហើយ និងព្រោះលះបង់ធម៌ដែលគួរលះមិនទាន់បាន ព្រោះហេតុនោះ បុគ្គលនេះ ទើបលោកហៅថា អ្នកមិនបានទូន្មានខ្លួន ព្រោះការមិនមានវិន័យនោះ ដោយប្រការដូច្នេះ ។ សូម្បីក្នុងបទថា មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ នេះ ក៏ន័យនេះដូចគ្នា ព្រោះថា កាលពោលដោយអត្ថ ពាក្យថា ព្រះអរិយៈនិងសប្បុរសនេះ មិនមានហេតុដែលផ្សេងគ្នា ដូចកាលដែលពោលថា បុគ្គលពួកណាជាព្រះអរិយៈ បុគ្គលពួកនោះឯង ឈ្មោះថា **សប្បុរស** បុគ្គលពួកណា ជាសប្បុរស បុគ្គលពួកនោះឯង ឈ្មោះថា **អរិយៈ** ធម៌ណាជារបស់ព្រះអរិយៈ ធម៌នោះៗឯង ឈ្មោះថា ជារបស់សប្បុរស ធម៌ណាជារបស់សប្បុរស ធម៌នោះៗឯង ឈ្មោះថា ជាធម៌របស់ព្រះអរិយៈ វិន័យទាំងឡាយណាជាវិន័យរបស់ព្រះអរិយៈ វិន័យទាំងឡាយនោះឯង ជាវិន័យរបស់សប្បុរស វិន័យទាំងឡាយណា ជាវិន័យរបស់សប្បុរស វិន័យទាំងឡាយនោះឯង ជាវិន័យរបស់ព្រះអរិយៈ ។ ពាក្យថា អរិយៈ ឬពាក្យថា សប្បុរស ក៏បានដល់អរិយធម៌ ឬសប្បុរិសធម៌ ពាក្យថា អរិយវិន័យ ឬសប្បុរិសវិន័យនេះ ដូចគ្នាតែមួយ តាំងនៅក្នុងទីតែមួយស្មើគ្នា មានចំណែកស្មើគ្នា មានភាពតែមួយ

ដូចគ្នានុ៎ះឯង ។

បទថា **រូបំ អត្តតោ សមនុបស្សតិ** សេចក្តីថា បុគ្គលពួកខ្លះក្នុងលោកនេះ រមែងឃើញរូបថាជាខ្លួន រមែងឃើញរូបនិងខ្លួន មិនមែនជាការៈ ២ យ៉ាង គឺឃើញថា រូបយ៉ាងណា អញក៏យ៉ាងនោះ អញយ៉ាងណា រូបក៏យ៉ាងនោះ ប្រៀបដូចកាលប្រទីបប្រេងឆេះឡើង បុគ្គលរមែងឃើញអណ្តាតភ្លើងនិងពណ៌ភ្លើងនោះមិនមែនជា ២ យ៉ាងថា អណ្តាតភ្លើងយ៉ាងណា ពណ៌ក៏យ៉ាងនោះ ពណ៌ភ្លើងយ៉ាងណា អណ្តាតភ្លើងក៏យ៉ាងនោះ ដូច្នេះ យ៉ាងណា បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងឃើញរូបជាដើម រមែងឃើញ ។បេ។ យ៉ាងនោះដូចគ្នា បុគ្គលរមែងឃើញរូបជាដើមដោយការឃើញដែលជាមិច្ឆា-ទិដ្ឋិយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **រូបវន្តំ វា អត្តានំ** សេចក្តីថា បុគ្គលប្រកាន់ អរូប ថាជាខ្លួន ទើបឃើញខ្លួននោះមានរូប ដូចឃើញដើមឈើមានស្រមោល ដូច្នោះ ។

បទថា **អត្តនិ វា រូបំ** សេចក្តីថា បុគ្គលកាន់យកអរូប ( នាម ) នុ៎ះឯង ថាជាខ្លួន ទើបឃើញរូបក្នុងខ្លួន ដូចឃើញក្លិនមានក្នុងផ្កា ដូច្នេះ ។

បទថា **រូបស្មឹ វា អត្តានំ** សេចក្តីថា បុគ្គលប្រកាន់យកអរូបនុ៎ះឯងថាជាខ្លួន ទើបឃើញខ្លួនក្នុងរូប ដូចឃើញកែវមណីក្នុងដប ដូច្នោះ ។ សូម្បីក្នុងខន្ធ មានវេទនាខន្ធជាដើម ក៏មានន័យនេះដូចគ្នា ។

បណ្តាបទទាំងនោះ បទថា រមែងយល់ឃើញរូបថាជាខ្លួន ទ្រង់ត្រាស់រូបសុទ្ធៗប៉ុណ្ណោះ ថាជាខ្លួន ។ ត្រាស់ថា អរូប ថាជាខ្លួន ទុកក្នុងឋានៈទាំង

៧ នេះ គឺ **រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ អត្តតោ ។បេ។ សញ្ញំ ... សង្ខារេ ... វិញ្ញាណំ អត្តតោ សមនុបស្សតិ** *( ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ យល់ឃើញវេទនាថាជាខ្លួន ។បេ។ យល់ឃើញសញ្ញា... យល់ឃើញសង្ខារ... យល់ឃើញវិញ្ញាណថាជាខ្លួន ) ។ ត្រាស់សភាវៈដែលលាយឡំគ្នានៃរូបនិងអរូប ថាជាខ្លួន ក្នុងឋានៈ ១២ ដោយអំណាចនៃខន្ធនីមួយៗ ៣ យ៉ាង ក្នុងខន្ធ ៤ យ៉ាងនេះថា ឃើញខ្លួនថាមានវេទនាខ្លះ ឃើញវេទនាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថា មានក្នុងវេទនាខ្លះ ដូច្នេះ ។*

*បណ្តាទិដ្ឋិទាំងនោះ ត្រាស់ឧច្ឆេទទិដ្ឋិក្នុងឋានៈទាំង ៥ គឺ រមែងយល់ឃើញរូបថាជាខ្លួន យល់ឃើញវេទនាថាជាខ្លួន យល់ឃើញសញ្ញាថាជាខ្លួន យល់ឃើញសង្ខារថាជាខ្លួន យល់ឃើញវិញ្ញាណថាជាខ្លួន ដូច្នេះ ។ ត្រាស់សស្សតទិដ្ឋិក្នុងឋានៈដ៏សេស ។ ក្នុងទីនេះ ទើបជាភវទិដ្ឋិ ១៥ វិភវទិដ្ឋិ ៥ ដោយប្រការដូច្នេះ ។ ទិដ្ឋិទាំងអស់នោះគប្បីជ្រាបថា ហាមមគ្គ តែមិនហាមសួគ៌ ដែលមគ្គទីមួយ ( សោតាបត្តិមគ្គ ) គប្បីប្រហារ ។*

*[ ១៧២ ] បណ្តាបទទាំងនោះ បទថា* **សត្ថរិ កង្ខតិ** *សេចក្តីថា បុថុជ្ជនរមែងងឿងឆ្ងល់ក្នុងព្រះសរីរៈ ឬក្នុងគុណរបស់ព្រះសាស្តា ឬទាំង ២ យ៉ាង ។ កាលងឿងឆ្ងល់ក្នុងព្រះសរីរៈ រមែងងឿងឆ្ងល់ថា ព្រះសរីរៈឈ្មោះថាប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានឬមិនមានហ្ន៎ ដូច្នេះ ។ កាលងឿងឆ្ងល់ក្នុងព្រះគុណ រមែងងឿងឆ្ងល់ថា ព្រះសព្វញ្ញុតញ្ញាណ ដែលអាច*

ដឹងអតីត អនាគតនិងបច្ចុប្បន្ន មានឬមិនមានហ្ន៎ ដូច្នេះ ។ កាលងឿងឆ្ងល់ក្នុងវត្ថុទាំង ២ នោះ រមែងងឿងឆ្ងល់ថា ធម្មតា ព្រះពុទ្ធដែលប្រកបដោយសេចក្ដីសម្រេចនៃព្រះសរីរៈដ៏រុងរឿង ដោយអនុព្យញ្ជនៈ ៨០ ឬព្រះរស្មីផ្សាយចេញទៅមួយព្យាម ទ្រង់ចាក់ធ្លុះព្រះសព្វញ្ញុតញ្ញាណ អាចដឹងញេយ្យធម៌ទាំងពួង ហើយតាំងនៅ ទ្រង់ជាអ្នកដឹកនាំសត្វលោក មានឬមិនមានហ្ន៎ ដូច្នេះ ពិតណាស់ បុថុជ្ជននេះ កាលនៅងឿងឆ្ងល់ក្នុងអត្តភាព ឬក្នុងព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធនោះ ឈ្មោះថា ងឿងឆ្ងល់ក្នុងវត្ថុទាំងពីរនេះ ។

បទថា **វិចិកិច្ឆតិ** សេចក្ដីថា បុថុជ្ជនកាលមិនអាចសម្រេចអារម្មណ៍បាន រមែងពិបាក រមែងលំបាក ។ បទថា **នាធិមុច្ចតិ** បានដល់ រមែងមិនបានអធិមោក្ខ ( ការចុះចិត្តស៊ប់ ) ក្នុងព្រះពុទ្ធនោះឯង ។ បទថា **ន សម្បសីទតិ** បានដល់ មិនអាចធ្វើចិត្តដែលកករល្អក់ ឲ្យជ្រះថ្លា គឺមិនជ្រះថ្លាក្នុងគុណទាំងឡាយ ។

ចំណែកក្នុងបទថា **ធម្មេ កង្ខតិ** ជាដើម គប្បីជ្រាបដូចតទៅនេះថា កាលងឿងឆ្ងល់ថា ឈ្មោះថា អរិយមគ្គ ៤ ដែលលះកិលេស សាមញ្ញផល ៤ ដែលស្ងប់រម្ងាប់ចាកកិលេសទាំងឡាយ អមតមហានិព្វាន ដែលជាអារម្មណប្បច្ច័យដល់មគ្គនិងផល មានឬមិនមានហ្ន៎ ដូច្នេះក្ដី កាលងឿងឆ្ងល់ថា ធម៌នេះជានិយ្យានិកធម៌ ជាធម៌នាំចេញ ឬជាអនិយ្យានិកធម៌ ជាធម៌មិននាំចេញហ្ន៎ ដូច្នេះក្ដី ឈ្មោះថា ងឿងឆ្ងល់ចំពោះព្រះធម៌ ។ កាលងឿងឆ្ងល់ថា សង្ឃរតនៈនេះ គឺបុគ្គលអ្នកតាំងនៅក្នុងមគ្គ ៤ ពួក តាំងនៅក្នុងផល ៤ ពួក

មានឬមិនមានហ្ន៎ ដូច្នេះក្តី កាលងឿងឆ្ងល់ថា ព្រះសង្ឃនេះ ជាអ្នកបដិបត្តិល្អ ឬបដិបត្តិអាក្រក់ហ្ន៎ ដូច្នេះក្តី កាលងឿងឆ្ងល់ថា ផលនៃទានដែលប្រគេនក្នុងសង្ឃរតនៈនេះ មានឬមិនមានហ្ន៎ ដូច្នេះក្តី ឈ្មោះថា ងឿងឆ្ងល់ចំពោះព្រះសង្ឃ ។ កាលងឿងឆ្ងល់ថា សិក្ខា ៣ មានឬមិនមានហ្ន៎ ដូច្នេះក្តី កាលងឿងឆ្ងល់ថា ព្រោះការសិក្សាសិក្ខា ៣ ជាហេតុ អានិសង្សមានឬមិនមានហ្ន៎ ដូច្នេះក្តី ឈ្មោះថា ងឿងឆ្ងល់ចំពោះសិក្ខា ។

ខន្ធ ធាតុ អាយតនៈដែលកន្លងទៅហើយ ហៅថា **បុព្វន្ត** ដែលនៅមិនទាន់មកដល់ ហៅថា **អបរន្ត** ។ បណ្តាចំណែកទាំង ២ នោះ កាលងឿងឆ្ងល់ក្នុងខន្ធដែលជាចំណែកអតីតថា ខន្ធក្នុងចំណែកអតីតជាដើម មានឬមិនមានហ្ន៎ ដូច្នេះជាដើម ឈ្មោះថា ងឿងឆ្ងល់ក្នុងខន្ធជាដើម ។ កាលងឿងឆ្ងល់ក្នុងខន្ធដែលជាចំណែកអនាគតថា ខន្ធក្នុងចំណែកអនាគតជាដើម មានឬមិនមានហ្ន៎ ដូច្នេះជាដើម ឈ្មោះថា ងឿងឆ្ងល់ក្នុងខន្ធខាងចុង ។ កាលងឿងឆ្ងល់ក្នុងចំណែកទាំង ២ ឈ្មោះថា ងឿងឆ្ងល់ក្នុងខន្ធខាងដើមនិងខន្ធខាងចុង ។ កាលងឿងឆ្ងល់ថា បច្ច័យវដ្ដៈមាន ១២ បទ មានឬមិនមានហ្ន៎ ឈ្មោះថា ងឿងឆ្ងល់ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យនូវបច្ច័យនោះៗ ។ ក្នុងធម៌ដែលជាឥទប្បច្ចយតាជាដើមនោះគប្បីជ្រាបវចនត្ថៈដូចតទៅនេះថា បច្ច័យទាំងឡាយរបស់ជរានិងមរណៈជាដើមទាំងនេះ ឈ្មោះថា **ឥទប្បច្ចយា** ភាវៈនៃឥទប្បច្ចយាទាំងឡាយ ឈ្មោះថា **ឥទប្បច្ចយតា** ។ ម្យ៉ាងទៀត ឥទប្បច្ចយានុ៎ះឯង ឈ្មោះថា **ឥទប្បច្ចយតា** ។ ពាក្យថា **ឥទប្បច្ចយតា** នេះ

ជាឈ្មោះរបស់ធម៌ មានជាតិជាដើម ។ ធម៌ទាំងឡាយ ដែលអាស្រ័យធម៌នោះៗ បណ្ដាធម៌ទាំងឡាយ មានជាតិជាដើម កើតឡើងព្រមហើយ ឈ្មោះថា ពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យនូវបច្ច័យ ។ សេចក្ដីនេះ មានអធិប្បាយថា រមែងធៀងធ្ងល់ក្នុងឥទប្បច្ចយតា និងក្នុងបដិច្ចសមុប្បន្នធម៌ ។

[ ១៧៣ ] បទថា **សីលេន** បានដល់ គោសីល ( ប្រព្រឹត្តដូចគោ ) ជាដើម ។ បទថា **វតេន** បានដល់ ដោយគោវត្តជាដើម ។ បទថា **សីលព្វតេន** បានដល់ ដោយបទទាំង ២ នោះ ។ បទថា **សុទ្ធិ** បានដល់ បរិសុទ្ធិចាកកិលេស ម្យ៉ាងទៀត ព្រះនិព្វានប៉ុណ្ណោះជាសេចក្ដីបរិសុទ្ធដ៏ក្រៃលែង ។

[ ១៧៤ ] ក្នុងបទថា **ឯកដ្ឋា** នេះ បានដល់ ជាធុរៈតាំងនៅជាមួយគ្នានៃការប្រហារ ។ ក្នុងព្រះបាលីនេះ ត្រាស់កិលេស ២ យ៉ាងប៉ុណ្ណោះ គឺទិដ្ឋិកិលេសនិងវិចិកិច្ឆាកិលេស ចំណែកកិលេសទាំង ៨ នេះ គឺលោភៈ ទោសៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលមិនបានត្រាស់ទុក បណ្ឌិតគប្បីនាំមកសម្ដែង ដ្បិតថា បណ្ដាកិលេសទាំងនេះកាលទិដ្ឋិនិងវិចិកិច្ឆាត្រូវប្រហារ កិលេសទាំងអស់នេះ គឺលោភៈ ទោសៈ មោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលនាំទៅកាន់អបាយជាកិលេសតាំងនៅក្នុងឋានៈជាមួយគ្នា ក្នុងការប្រហារ រមែងត្រូវប្រហារ ។ ចំណែកកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នាដោយកើតព្រមគ្នា ក៏គួរនាំមកសម្ដែង ព្រោះចិត្តទាំង ៥ ដូចនេះ គឺចិត្តដែលសហគតៈដោយទិដ្ឋិ ៤ និងចិត្តដែលសហគតៈដោយវិចិកិច្ឆា ១ រមែងត្រូវប្រហារដោយសោតាបត្តិមគ្គ ។ បណ្ដា

ចិត្តដែលសហគតៈដោយកិលេសទាំង ៥ នោះ កាលចិត្តដែលសហគតៈដោយទិដ្ឋិជាអសង្ខារិក ២ ត្រូវប្រហារ កិលេសទាំងនេះ គឺលោភៈ ទោសៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតព្រមគ្នានឹងអសង្ខារិកទិដ្ឋិចិត្តទាំង ២ នោះ ក៏រមែងត្រូវប្រហារដោយអំណាចនៃកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នាដោយកើតព្រមគ្នា ។ ទិដ្ឋិកិលេសដ៏សេសនិងវិចិកិច្ឆាកិលេសក៏រមែងត្រូវប្រហារ ដោយអំណាចកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នាដោយការលះ ។ កាលចិត្តដែលសម្បយុត្តដោយទិដ្ឋិប្រកបដោយសង្ខារទាំងឡាយ ត្រូវប្រហារ កិលេសទាំងនេះ គឺលោភៈ ទោសៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ដែលកើតព្រមជាមួយចិត្តទាំងនោះ រមែងត្រូវប្រហារដោយអំណាចនៃកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នា ដោយការកើតព្រមគ្នា ។ ទិដ្ឋិកិលេសដ៏សេសនិងវិចិកិច្ឆាកិលេស ក៏រមែងត្រូវប្រហារដោយអំណាចនៃកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នា ដោយការលះ ។ បុគ្គលរមែងបានកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នា ដោយកើតព្រមគ្នាក្នុងកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នា ដោយការលះ ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកនាំកិលេសដែលតាំងនៅក្នុងឋានៈជាមួយគ្នា ដោយការកើតព្រមគ្នានេះមកសម្តែងទុក ។

បទថា **តំសម្បយុត្តា** បានដល់ ដែលសម្បយុត្តដោយកិលេស ៨ ទាំងនោះដែលតាំងនៅក្នុងឋានៈជាមួយគ្នានឹងសំយោជនៈ ៣ នោះ ។ម្យ៉ាងទៀត គប្បីធ្វើការចែកសម្តែងកិលេសដែលសម្បយុត្តដោយកិលេសនីមួយៗ

យ៉ាងនេះ គឺសម្បយុត្តដោយលោភៈនោះនិងសម្បយុត្តដោយទោសៈនោះ ។ បណ្តាកិលេសទាំងនោះ កាលកាន់យកលោភៈ ពួកកិលេសដែលជាសន្ទា-រក្ខន្ធនេះ គឺមោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ក៏ឈ្មោះថា សម្បយុត្តដោយលោភៈ ។ កាលកាន់យកទោសៈ ពួកកិលេសនេះគឺមោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ក៏ឈ្មោះថា សម្បយុត្តដោយទោសៈ ។ កាលកាន់យកមោហៈ ពួកកិលេសនេះ គឺលោភៈ ទោសៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ក៏ឈ្មោះថា សម្បយុត្តដោយមោហៈ ។ កាលលោភកាន់យកមានៈ ពួកកិលេសនេះ គឺលោភៈ ទោសៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈដែលកើតព្រមជាមួយនឹងមានៈនោះក៏ឈ្មោះថា សម្បយុត្តដោយមានៈ ។ ដោយឧបាយនេះ បណ្ឌិតគប្បីធ្វើការប្រកបថា សម្បយុត្តដោយថីនៈនោះ សម្បយុត្តដោយឧទ្ធច្ចៈនោះ សម្បយុត្តដោយអហិរិកៈនោះ សម្បយុត្តដោយអនោត្តប្បៈនោះ ។ បទថា **តំសម្បយុត្តា** បាន ដល់ តាំងឡើងដោយលោភៈនោះ ។បេ។ តាំងឡើងដោយអនោត្តប្បៈនោះ ។ ក្នុងបទថា **ឥមេ ធម្មា ទស្សនេន បហាតព្វា** នេះ សោតាបត្តិមគ្គ ឈ្មោះថា **ទស្សន** អធិប្បាយថា ធម៌ទាំងឡាយដែលសោតាបត្តិមគ្គនោះគប្បីប្រហារ ។ សួរថា ព្រោះហេតុអ្វីទើបសោតាបត្តិមគ្គ ឈ្មោះថា **ទស្សន** ឆ្លើយថា ព្រោះឃើញព្រះនិព្វានមុន ។ សួរថា គោត្រភូ ឃើញព្រះនិព្វានមុនគេ មិនមែនឬ ឆ្លើយថា មិនមែនមិនឃើញ តែឃើញហើយមិនបានធ្វើកិច្ចដែលគួរធ្វើ ព្រោះមិនបានលះសំយោជនៈទាំងឡាយ ព្រោះហេតុនោះ ទើបមិនគួរពោលថា

គោត្រភូញាណឃើញព្រះនិព្វានមុនទេ ។ ក្នុងសេចក្ដីនេះមានពួកអ្នកជនបទជាឧទាហរណ៍ ពួកអ្នកជនបទនោះសូម្បីឃើញព្រះរាជាក្នុងទីណាមួយហើយ ទោះបីជាដូច្នោះ ក៏នៅតែពោលថា ខ្ញុំមិនទាន់បានចូលគាល់ព្រះរាជា ព្រោះនៅមិនបានធ្វើកិច្ចថ្វាយគ្រឿងបណ្ណាការឲ្យសម្រេច ។

បទថា **អវសេសោ លោភោ** បានដល់ លោភៈដែលសេសសល់អំពីសោតាបត្តិមគ្គប្រហារហើយ ។ សូម្បីក្នុងទោសៈនិងមោហៈជាដើម ក៏មានន័យនេះដូចគ្នា ព្រោះថា សោតាបត្តិមគ្គប្រហារកិលេស ដែលនាំទៅកាន់អបាយប៉ុណ្ណោះ ។ ដើម្បីទ្រង់សម្ដែងកិលេសដទៃ អំពីកិលេសដែលសេសសល់ទាំងនោះ ទើបត្រាស់ពាក្យនេះថា **តទេកដ្ឋា** ដូច្នេះ ។ បទថា **តទេកដ្ឋា** បានដល់ កិលេស ៥ យ៉ាង ដែលតាំងនៅក្នុងឋានៈជាមួយគ្នានឹងកិលេសទាំង ៣ នោះ ដែលមកក្នុងព្រះបាលីដោយសម្បយោគខ្លះ ដោយការលះខ្លះ ។

បទថា **នេវ ទស្សនេន ន ភាវនាយ** នេះ ព្រះមានព្រះភាគ ត្រាស់សំដៅយកភាវៈនៃធម៌ ដែលមគ្គទាំងនោះ មិនគប្បីប្រហារ ដូចការប្រហារសំយោជនៈជាដើម ។ ចំណែកការប្រហារធម៌ មានកុសលជាដើមណាដែលទ្រង់អនុញ្ញាតទុក ( ក្នុងខុទ្ទកនិកាយចូឡនិទ្ទេស ) ដោយន័យជាដើមថា ធម៌ទាំងឡាយណា គឺនាមនិងរូប គប្បីកើតក្នុងសង្សារមានទីបំផុតខាងដើម ដែលគេមិនអាចដឹងបាន វៀរលែងតែកំណើត ៧ ចេញ ធម៌ទាំងនុ៎ះ រលត់រម្ងាប់ ដល់នូវការវិនាស ស្ងប់រម្ងាប់ ក្នុងសោតាបត្តិមគ្គនោះ ព្រោះកិរិយា

រលត់អភិសង្ខារវិញ្ញាណ ដោយសោតាបត្តិមគ្គញ្ញាណ ដូច្នេះ គប្បីជ្រាបថា ការប្រហារនោះ លោកពោលសំដៅយកបរិយាយនេះថា ធម៌ទាំងឡាយណា គប្បីកើតឡើងព្រោះមគ្គទាំងនោះមិនទាន់បានអប់រំ ធម៌ទាំងឡាយនោះឈ្មោះថា លះបានហើយ ព្រោះការប្រហារកិលេសទាំងឡាយ ដែលជាធម៌ជួយឧបការៈដោយភាពជាហេតុមានកម្លាំង ( ឧបនិស្សយប្បច្ចយ ) ។

[ ១៧៥ ] ក្នុងទស្សនេនបហាតព្វហេតុកត្តិកៈ ព្រះមានព្រះភាគ ទ្រង់បញ្ចប់ដោយព្រះតម្រាស់ថា **ឥមេ ធម្មា ទស្សនេន បហាតព្វហេតុកា** នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ដូច្នេះ ហើយដើម្បីទ្រង់សម្តែងធម៌ដែលគួរប្រហារ ហើយសម្តែងហេតុធម៌ និងសហេតុកធម៌ដោយធម៌ដែលតាំងនៅក្នុងឋានៈជាមួយគ្នានឹងសំយោជនៈនោះ ទើបត្រាស់ពាក្យថា **តីណិ សញ្ញោជនានិ** ដូច្នេះ ជាដើមទៀត ។ បណ្តាហេតុធម៌និងសហេតុកធម៌ទាំងនោះ ក្នុងហេតុធម៌ដែលសោតាបត្តិមគ្គ គប្បីប្រហារ មោហៈដែលសហគតដោយលោភៈ ក៏ជាធម៌មានលោភៈជាហេតុប្រកប មោហៈដែលសហគតដោយទោសៈ ក៏ជាធម៌មានទោសៈជាហេតុប្រកប មួយទៀត លោភៈនិងទោសៈក៏ជាធម៌មានមោហៈជាហេតុប្រកប ព្រោះហេតុនោះ មោហៈដែលសហគតដោយលោភៈជាដើមទាំងនោះ រមែងដល់នូវការសង្គ្រោះចូលក្នុងបទនៃធម៌មានហេតុ ដែលទស្សនៈគប្បីប្រហារក៏ពិត តែមោហៈដែលសហគតៈដោយវិចិកិច្ឆា ក៏ឈ្មោះថា ធម៌ជាហេតុតែម្យ៉ាង មិនមានហេតុប្រកប ព្រោះមិនមានហេតុដែលសម្បយុត្តដទៃ ព្រោះហេតុនោះដើម្បីទ្រង់សម្តែងការប្រហារ

មោហៈដែលសហគតៈដោយវិចិកិច្ឆានោះ ទើបត្រាស់ពាក្យថា **ឋមេ ធម្មា ទស្សនេនបហាតព្វហេតុ** ដូច្នេះ ។

ក្នុងទុតិយបទ ព្រះមានព្រះភាគទ្រង់បំណងនឹងសម្តែងការប្រហារមោហៈដែលសហគតៈដោយឧទ្ធច្ចៈ ទើបត្រាស់ពាក្យថា **ឋមេ ធម្មា ភាវនាយ បហាតព្វហេតុ** ដូច្នេះ ដ្បិតថា មោហៈដែលសហគតដោយឧទ្ធច្ចៈនោះ ធ្វើសម្បយុត្តធម៌ជាមួយនឹងខ្លួនឲ្យជាសហេតុកៈ និងរិលទៅខាងក្រោយនឹងចាត់ជាបហាតព្វហេតុកបទ ក៏មិនបាន ព្រោះមិនមានសម្បយុត្តហេតុដទៃ ដូចមោហៈដែលសហគតដោយវិចិកិច្ឆា ដូច្នោះ ។

ក្នុងតតិយបទ បទថា **អវសេសា អកុសលា** សេចក្តីថា ទ្រង់ធ្វើអកុសល សព្វ ទុក ដើម្បីរួមមោហៈទាំងឡាយដែលសហគតដោយវិចិកិច្ឆានិងឧទ្ធច្ចៈទៀត ព្រោះថា មោហៈទាំងនោះ មិនឈ្មោះថា មានហេតុដែលនឹងគប្បីលះព្រោះមិនមានសម្បយុត្តហេតុ ។

[ ១៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបរិត្តារម្មណត្តិកៈ ដូចតទៅនេះថា

បទថា **អារព្ភ** បានដល់ ធ្វើឲ្យជាអារម្មណ៍ មែនពិត ខ្លួនឯងនឹងជាបរិត្តធម៌ក្តី ជាមហគ្គតធម៌ក្តី ធម៌ដែលធ្វើបរិត្តធម៌ទាំងឡាយឲ្យជាអារម្មណ៍កើតឡើង ឈ្មោះថា **បរិត្តារម្មណា** ។ ធម៌ដែលធ្វើមហគ្គតធម៌ទាំងឡាយឲ្យជាអារម្មណ៍ កើតឡើង ឈ្មោះថា **មហគ្គតារម្មណា** ។ ធម៌ដែលធ្វើអប្បមាណធម៌ទាំងឡាយឲ្យជាអារម្មណ៍កើតឡើង ឈ្មោះថា **អប្បមាណារម្មណា** ។ អធិប្បាយថា ធម៌ទាំងនោះជាបរិត្តៈខ្លះ ជាមហគ្គតៈខ្លះ ជាអប្ប-

មាណៈខ្វះ ។

[ ១៨១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមិច្ឆត្តត្តិកៈ ដូចតទៅនេះថា

បទថា **អានន្តរិកានិ** នេះ ជាឈ្មោះនៃការធ្វើកម្ម គឺមាតុឃាតជាដើម ដែលជាធម៌ឲ្យផលដោយមិនមានអ្វីមកពាំងបានឡើយ ដ្បិតថា កាលបុគ្គល ធ្វើកម្មសូម្បីតែមួយបណ្ដាអនន្តរិយកម្មទាំងនោះ កម្មដទៃមិនអាចហាមអនន្ត-រិយកម្មនោះហើយឲ្យឱកាសដល់វិបាករបស់ខ្លួន ។ ពិតណាស់ កាលបុគ្គល សាងព្រះស្តូបមាស សូម្បីប៉ុនភ្នំសិនេរុឬសាងវិហារមានកំពែងសម្រេចដោយ រតនៈប៉ុនចក្កវាឡហើយថ្វាយបច្ច័យ ៤ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលអង្គុយពេញទីនោះ អស់មួយជីវិតក្តី កុសលកម្មនោះ ក៏មិនអាចហាម វិបាករបស់អនន្តរិយកម្មទាំងនោះបានឡើយ ។

បទថា **យា ច មិច្ឆាទិដ្ឋិ និយតា** បានដល់ ក្នុងអហេតុកវាទ អកិ-រិយវាទ នត្ថិកវាទទាំងឡាយ មិច្ឆាទិដ្ឋិឯណានីមួយ ដ្បិតថា ព្រះពុទ្ធទាំង ឡាយ មួយរយអង្គក្តី មួយពាន់អង្គក្តីក៏មិនអាចធ្វើបុគ្គលដែលប្រកាន់មិច្ឆា-ទិដ្ឋិនោះ ឲ្យត្រាស់ដឹងបាន ។

[ ១៨២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គារម្មណត្តិកៈ ដូចតទៅនេះថា

បទថា **អរិយមគ្គំ អារព្ភ** បានដល់ ធ្វើលោកុត្តរមគ្គ ឲ្យជាអារម្មណ៍ ធម៌មានមគ្គជាអារម្មណ៍ទាំងនោះ ជាបរិត្តៈខ្វះ ជាមហគ្គតៈខ្វះ ។

ក្នុងមគ្គហេតុកនិទ្ទេស ( ទុតិយបទ ) គប្បីជ្រាបថា ទ្រង់សម្តែងភាព ដែលខន្ធទាំងឡាយសម្បយុត្តដោយមគ្គជាសហេតុកៈទុកដោយហេតុ ដោយ

អត្ថថា ជាបច្ច័យដោយន័យដំបូង ។ ទ្រង់សម្ដែងភាពដែលអង្គនៃមគ្គដ៏សេស ជាសហេតុកៈដោយហេតុ ពោលគឺសម្មាទិដ្ឋិដែលជាមគ្គ ដោយន័យទី ២ ។ ទ្រង់សម្ដែងភាពដែលសម្មាទិដ្ឋិជាសហេតុកៈ ដោយបទថា ហេតុដែលកើតឡើងក្នុងមគ្គ ដោយន័យរបស់តតិយបទ ។

បទថា **អធិបតី ករិត្វា** បានដល់ ធ្វើឲ្យជាអារម្មណាធិបតី ។ ធម៌ គឺចិត្តនិងចេតសិកទាំងនោះឯងជាបរិត្តធម៌ដោយពិត ព្រោះថា ក្នុងវេលាដែលព្រះអរិយសាវ័កទាំងឡាយពិចារណាមគ្គរបស់ខ្លួនធ្វើឲ្យធ្ងន់ រមែងបានអរិយ-មគ្គដែលធ្វើឲ្យជាអារម្មណាធិបតី តែអរិយសាវ័ក កាលពិចារណាមគ្គរបស់អ្នកដទៃដោយចេតោបរិយញ្ញាណ សូម្បីធ្វើឲ្យធ្ងន់ ក៏ធ្វើឲ្យធ្ងន់ ដូចមគ្គដែលខ្លួនចាក់ធ្លុះហើយមិនបាន សួរថា ព្រះអរិយសាវ័កឃើញព្រះតថាគត ទ្រង់ធ្វើយមកប្បាដិហារិយ៍ រមែងធ្វើមគ្គរបស់ព្រះតថាគតឲ្យធ្ងន់ឬទេ ឆ្លើយថា រមែងធ្វើ តែធ្វើឲ្យធ្ងន់ដូចមគ្គរបស់ខ្លួនមិនបាន ។ ក្នុងពាក្យរបស់អដ្ឋកថានេះថា ព្រះអរហន្តមិនធ្វើធម៌អ្វីៗឲ្យធ្ងន់ វៀរតែមគ្គ ផលនិងនិព្វាន ដូច្នេះ ជាការអធិប្បាយសេចក្ដីនេះនោះឯង ។

បទថា **វីមំសាធិបតេយ្យំ** នេះ ត្រាស់ដើម្បីសម្ដែងសហជាតាធិបតិ ព្រោះថា កាលបុគ្គលចម្រើនមគ្គ ធ្វើឆន្ទៈឲ្យជាធំ ឆន្ទៈក៏ឈ្មោះថាជាអធិបតី មិនជាមគ្គ ។ ធម៌ដ៏សេសក៏ឈ្មោះថា មានឆន្ទៈជាអធិបតី មិនមែនមានមគ្គជាអធិបតី ។ សូម្បីក្នុងចិត្តៈក៏មានន័យនេះឯង តែកាលបុគ្គលចម្រើនមគ្គធ្វើវីមំសាឲ្យជាធំ វីមំសាជាអធិបតីផង ជាមគ្គផង ព្រោះហេតុនោះធម៌ដ៏សេស

ក៏ឈ្មោះថា មានមគ្គជាអធិបតី ។ សូម្បីក្នុងវីរិយៈក៏មានន័យនេះដូចគ្នា ។

[ ១៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឧប្បន្នត្តិកៈ ដូចតទៅនេះថា

បទថា **ជាតា** បានដល់ កើតឡើងហើយ គឺបានអត្តភាពហើយ ។ បទថា **ភូតា** ជាដើម ជាវេវចនៈរបស់ពាក្យថា **ជាតា** ជាដើមនោះឯង ។ មែនពិត ការកើតនុ៎ះឯង ឈ្មោះថា **ភូតា** ព្រោះការកើតឡើងនៃភាវៈ ។ ឈ្មោះថា **សញ្ជាតា** ព្រោះកើតហើយ ក្នុងការប្រកបព្រមនៃបច្ច័យទាំងឡាយ ។ ឈ្មោះថា **និព្វត្តា** ព្រោះដល់លក្ខណៈនៃការកើតឡើង ។ ចំណែកពាក្យដែលត្រាស់ថា **អភិនិព្វត្តា** ទ្រង់បន្ថែមបទឧបសគ្គ ។ ដែលឈ្មោះថា **បាតុភូតា** ព្រោះជាសភាវៈប្រាកដហើយ មានហើយ ។ ដែលឈ្មោះថា **ឧប្បន្នា** ព្រោះផុតទៅអំពីអតីត បទថា **សមុប្បន្នា** ទ្រង់បន្ថែមបទឧបសគ្គ ដែលឈ្មោះថា **ឧដ្ឋិតា** ព្រោះតាំងឡើងខាងលើ ដោយអត្ថថា កើតឡើងហើយនោះឯង ។ ឈ្មោះថា **សមុដ្ឋិតា** ព្រោះតាំងឡើងហើយដោយការប្រកបព្រមនៃបច្ច័យ ។ គប្បីជ្រាបហេតុក្នុងព្រះតម្រាស់ដែលថា **ឧប្បន្នា** ទៀត ដោយន័យដែលធ្លាប់ពោលហើយនុ៎ះឯង ។

បទថា **ឧប្បន្នំសេន សង្គហិតា** បានដល់ ដល់នូវការរាប់ដោយចំណែកដែលកើតឡើងហើយ ។ បទថា **រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណំ** នេះ ជាពាក្យសម្ដែងសភាវៈរបស់ធម៌ទាំងនោះ ។

ក្នុងនិទ្ទេសនៃបទទី ២ គប្បីជ្រាបដោយន័យការបដិសេធធម៌ដែលពោលហើយ ។ និទ្ទេសនៃបទទី ៣ មានសេចក្ដីងាយយល់ហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងតិកៈនេះ ឲ្យគ្រប់ចំនួនដោយអំណាចកាលទាំងពីរ ។ មែនពិត វិបាកនៃកម្មដែលបានឱកាសហើយ មាន ២ យ៉ាងគឺ វិបាកដែលដល់ខណៈហើយនិងដែលមិនទាន់ដល់ហើយ ។ បណ្តាវិបាកកម្មទាំង ២ នោះ វិបាកដែលដល់ខណៈ ( ទាំង ៣ ) ហើយឈ្មោះថា **ឧប្បន្ន** ។ វិបាកដែលមិនទាន់ដល់ហើយ ចូរកើតឡើងក្នុងលំដាប់នៃចិត្ត ឬក្នុងកាលឈានកន្លងទៅទៀតរាប់សែនកប្បនឹងឈ្មោះថា មិនមាន រមែងប្រព្រឹត្តទៅមិនបាន ដោយអត្ថថា ជាសភាវៈមានបច្ច័យដែលពិតប្រាកដទើបឈ្មោះថា ជាធម៌ដែលកើតឡើង ( **ឧប្បាទិនោ** ) ។ ដូចក្នុងព្រះបាលី ( ទីឃ-និកាយសីលក្ខន្ធ ) នេះថា ម្នាលពោដ្ឋបាទ ខ្លួនដែលគ្រោតគ្រាត មានរូបប្រកបដោយមហាភូតរូប ៤ មានកវលិង្ការាហារជាចំណីនេះ ចូរលើកទុកសិនចុះ កាលបើដូច្នោះសញ្ញាដទៃរបស់បុរសនេះកើតឡើង សញ្ញាឯទៀតរលត់ទៅ ដូច្នេះ មូលភវង្គសញ្ញារលត់ទៅហើយ ក្នុងបវត្តិកាលនៃកាមាវចរសញ្ញា ក្នុងអរូបភូមិក៏ពិត តែក្នុងកាលដែលសញ្ញាកាមាវចររលត់ហើយ សញ្ញាសម្បយុត្តដោយមូលភវង្គនោះ នឹងកើតឡើងពិតប្រាកដ ព្រោះហេតុនោះ អត្តា ពោលគឺអរូប ទើបមិនដល់នូវការរាប់ថា មិនមាន ទើបកើតថាឈ្មោះថា តាំងនៅពិតប្រាកដយ៉ាងណា វិបាកនៃកម្មដែលបានឱកាសហើយមាន ២ យ៉ាង ។បេ។ ឈ្មោះថា រមែងមិនមាន រមែងប្រព្រឹត្តទៅមិនបាន ដោយអត្ថថា ជាសភាវៈមានបច្ច័យដ៏ពិតប្រាកដ ទើបឈ្មោះថា ជាធម៌ដែលកើតឡើង ( ឧប្បាទិនោ ) ក៏យ៉ាងនោះដូចគ្នា ។

បើកុសលកម្មនិងអកុសលកម្មដែលធ្វើទុកហើយ គប្បីឲ្យវិបាកទាំងអស់សោត ឱកាសនៃកម្មដទៃក៏មិនគប្បីមាន ។ តែកម្មនោះ មាន ២ យ៉ាងគឺឲ្យវិបាកពិតប្រាកដ និងឲ្យវិបាកមិនពិតប្រាកដ ។

បណ្តាកម្មដែលឲ្យវិបាកពិតប្រាកដ និងមិនពិតប្រាកដទាំងនោះ កម្មនេះគឺ អនន្តរិយកម្ម ៥ សមាបត្តិ ៨ អរិយមគ្គ ៤ ឈ្មោះថា កម្មឲ្យវិបាកពិតប្រាកដ កម្មដែលឲ្យវិបាកដែលពិតប្រាកដនោះ ដល់ខណៈ ( ទាំង ៣ ) ហើយក៏មាន ដែលនៅមិនទាន់ដល់ខណៈ ក៏មាន ។ ក្នុងកម្មទាំង ២ នោះ កម្មដែលដល់ខណៈ ( ទាំង ៣ ) ហើយឈ្មោះថា ឧប្បន្នៈ ដែលនៅមិនទាន់ដល់ខណៈ ឈ្មោះថា អនុប្បន្នៈ ។ វិបាករបស់កម្មដែលនៅមិនទាន់កើតឡើងនោះ ចូរកើតឡើងក្នុងលំដាប់នៃចិត្ត ឬក្នុងកាលឈានកន្លងទៅទៀតរាប់សែនកប្ប កម្មដែលមិនទាន់កើតឡើងនោះ ឈ្មោះថា មិនកើតឡើង រមែងមិនមាន ព្រោះអត្ថថា ជាភាវៈមានបច្ច័យដែលពិតប្រាកដ ។ ធម៌នេះឯងឈ្មោះថា នឹងកើតឡើង ។ មគ្គរបស់ព្រះមេត្តេយ្យពោធិសត្វ ឈ្មោះថា អនុប្បន្នៈ ផល ឈ្មោះថា ធម៌ទាំងឡាយនឹងកើតឡើងពិតប្រាកដ ។

[ ១៨៤ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអតីតត្តិកៈ ដូចតទៅនេះថា

បទថា **អតីតា** បានដល់ កន្លងខណៈទាំង ៣ ទៅហើយ ( ឧប្បាទក្ខណៈ ឋិតិខណៈ ភង្គក្ខណៈ ) ។ បទថា **និរុទ្ធា** បានដល់ ដល់នូវសេចក្តីរលត់ហើយ ។ បទថា **វិគតា** បានដល់ ដល់នូវការមិនមានហើយ ឬប្រាសទៅហើយ ។ បទថា **វិបរិណតា** បានដល់ ដល់នូវការប្រែប្រួល

ដោយលះប្រក្រតីទៅ ។ ដែលឈ្មោះថា **អត្ថង្គតា** ព្រោះអត្ថថា ដល់ហើយនូវការបិតនៅមិនបាន ពោលគឺការរលត់ ។ បទថា **អព្ភត្ថង្គតា** ទ្រង់បន្ថែមបទឧបសគ្គ ។ បទថា **ឧប្បជ្ជិត្វា វិគតា** បានដល់ កើតឡើងហើយប្រាសទៅហើយ ។ ព្រោះព្រះតម្រាស់ថា **អតីតា** ដដែលទៀត ខ្ញុំធ្លាប់ពោលទុកហើយនោះឯង ។ ក្នុងធម៌មានអនាគតជាដើមខាងមុខ ក៏មានន័យនេះឯង ។ បទថា **អតីតំសេន សង្គហិតា** បានដល់ ដល់នូវការរាប់ដោយចំណែកនៃធម៌ដែលកន្លងហើយ ។ ធម៌ដែលកន្លងហើយទាំងនោះ តើដូចម្ដេច ធម៌ដែលកន្លងទៅហើយទាំងនោះ គឺរូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ។ សូម្បីក្នុងធម៌ដែលជាអនាគតជាដើមខាងមុខ ក៏មានន័យនេះដូចគ្នា ។

[ ១៨៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអតីតារម្មណត្តិកៈ ដូចតទៅនេះថា ក្នុងបទទាំងឡាយមានបទថា **អតីតេ ធម្មេ អារព្ភ** ជាដើម បណ្ឌិតគប្បីជ្រាបចំពោះបរិត្តធម៌ និងមហគ្គតធម៌ប៉ុណ្ណោះ ព្រោះថា ធម៌គឺចិត្ត និងចេតសិកទាំងនោះ ប្រារព្ធធម៌ដែលជាអតីតជាដើមកើតឡើង ។

[ ១៨៦ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអជ្ឈត្តត្តិកៈ ដូចតទៅនេះថា

ដោយបទទាំងពីរថា **តេសំ តេសំ** បានដល់ ទ្រង់កំណត់យកសត្វទាំងអស់ ។ បទទាំងពីរថា **អជ្ឈត្តំ បច្ចត្តំ** ជាឈ្មោះរបស់ធម៌ដែលជាខាងក្នុងកើតក្នុងខ្លួន ។ បទថា **និយតា** បានដល់ កើតហើយដល់ខ្លួន ។ បទថា **បាដិបុគ្គលិកា** បានដល់ ជារបស់មាននៅចំពោះបុគ្គលនីមួយៗ ។ បទថា **ឧបាទិន្នា** បានដល់ ជារបស់តាំងនៅក្នុងសរីរៈ មែនពិត ធម៌ទាំងនោះកើត

ដោយកម្មក្តី មិនកើតដោយកម្មក្តី តែក្នុងអជ្ឈត្តត្តិកនិទ្ទេសនេះ ត្រាស់ថា **ឧបាទិន្ន** ដោយអំណាចតណ្ហាកាន់យក មានះប្រកាន់ និងទិដ្ឋិបរាមាស អង្អែលហើយ ។

បទថា **បរសត្តានំ** បានដល់ សត្វដ៏សេសវៀរខ្លួនឯង ។ បទថា **បរ-បុគ្គលានំ** ជាវេវចនៈរបស់បទថា **បរសត្តានំ** នុ៎ះឯង ។ ពាក្យដែលនៅសល់ ដូចពាក្យដែលធ្លាប់ពោលហើយនុ៎ះឯង ។ បទថា **តទុភយំ** កាត់បទជា **តំ ឧភយំ** ប្រែថា ធម៌ទាំង ២ នោះ ។

[ ១៨៧-១៨៨ ] ក្នុងបឋមបទនៃអជ្ឈត្តារម្មណត្តិកៈ គប្បីជ្រាបធម៌ទាំងឡាយ ដែលជាបរិត្តៈនិងមហគ្គតៈ ក្នុងទុតិយបទ គប្បីជ្រាបធម៌ទាំងឡាយសូម្បីជាអប្បមាណៈផងដែរ ។ ក្នុងតតិយបទ គប្បីជ្រាបបរិត្តធម៌និងមហគ្គតធម៌ប៉ុណ្ណោះ ។ តែអប្បមាណធម៌មិនធ្វើអារម្មណ៍ខាងក្រៅតាមកាល និងក្នុងខាងក្នុងតាមកាល ( និព្វានជាកាលវិមុត្តិ ) ។ និទ្ទេសនៃសនិទស្ស-នត្តិកៈ មានសេចក្តីងាយយល់ហើយ ។

**អដ្ឋកថាតិកនិក្ខេប ចប់**

# អភិធម្មបិដក

## ហេតុគោច្ឆក

[ ១៨៩ ] ពួកធម៌ជាហេតុ តើដូចម្ដេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ កាមាវចរហេតុ ៩ រូបាវចរហេតុ ៦ អរូបាវចរហេតុ ៦ អបរិយាបន្នហេតុ ៦ ។

[ ១៩០ ] បណ្ដាហេតុទាំងនោះ កុសលហេតុ ( ហេតុនៃកុសល ) ៣ តើដូចម្ដេច ។ អលោភៈ អទោសៈ អមោហៈ ។ បណ្ដាកុសលហេតុទាំងនោះ អលោភៈ តើដូចម្ដេច ។ ការមិនជាប់ចំពាក់ ការមិនជាប់ស្អិតភាពនៃចិត្ត មិនជាប់ចំពាក់ក្នុងអារម្មណ៍ ការមិនត្រេកអរ ការមិនរីករាយ ភាពនៃចិត្តមិនត្រេកអរក្នុងអារម្មណ៍ ការមិនសម្លឹងរំពៃ សេចក្ដីមិនលោភ ជាកុសលមូលណា នេះហៅថា អលោភៈ ។ បណ្ដាកុសលមូលទាំងនោះ អទោសៈ តើដូចម្ដេច ។ ការមិនប្រទូស្ដ អាការមិនប្រទូស្ដ ភាពនៃចិត្តមិនប្រទូស្ដ ក្នុងអារម្មណ៍ ការមេត្រី ការរាប់អាន ភាពនៃចិត្តរាប់អាន ការអាណិត ការប្រព្រឹត្តអាណិត ភាពនៃចិត្តអាណិត ការស្វែងរកនូវប្រយោជន៍ ការអនុគ្រោះ ការមិនគុំគួន ការមិនបៀតបៀន សេចក្ដីមិនប្រទូស្ដ ជាកុសលមូលណា នេះហៅថា អទោសៈ ។ បណ្ដាកុសលមូលទាំងនោះ អមោហៈ តើដូចម្ដេច ។ ការដឹងច្បាស់ក្នុងទុក្ខ ដឹងច្បាស់ក្នុងទុក្ខសមុទយ ដឹងច្បាស់ក្នុងទុក្ខនិរោធ ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា ដឹងច្បាស់ក្នុងខន្ធ ជាចំណែកខាងដើម ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង ដឹងច្បាស់ក្នុងខន្ធជា

ចំណែកខាងដើមនិងខាងចុង ដឹងច្បាស់ក្នុងពួកធម៌ ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ ( បដិច្ចសមុប្បន្នធម៌ ) និងបញ្ញា ការដឹងច្បាស់ ការសន្សំ ការប្រមូល ការពិចារណាធម៌ ការចំណាំ ការចំណាំជាប់ ការចំណាំស្និទ្ធ ភាពជាបណ្ឌិត ការឈ្លាសវៃ ការប្រសប់ ការប៉ិនប្រសប់ ការគិតគូរ ការពិចារណា ប្រាជ្ញាដូចជាផែនដី ប្រាជ្ញាទម្លាយនូវកិលេស ធម្មជាតិសម្រាប់ណែនាំ ការយល់ ការឃើញច្បាស់ ការដឹងខ្លួនច្បាស់លាស់ ការចាក់ធ្លុះ ការដឹងច្បាស់ ឥន្ទ្រិយគឺបញ្ញា កម្លាំងគឺបញ្ញា គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា សេចក្តីមិនវង្វេង សេចក្តីពិចារណាធម៌ សេចក្តីឃើញត្រូវណាដែលមានសភាពបែបនេះ នេះហៅថា អមោហៈ ។ នេះកុសលហេតុ ៣ ។

[ ១៩១ ] បណ្តាហេតុទាំងនោះ អកុសលហេតុ ៣ តើដូចម្តេច ។ លោភៈ ទោសៈនិងមោហៈ ។ បណ្តាអកុសលហេតុទាំងនោះ លោភៈ តើដូចម្តេច ។ តម្រេក ការត្រេកអរខ្លាំង ការជាប់ចំពាក់ក្នុងអារម្មណ៍ ការស្រើបស្រាល ការរីករាយ ការរីករាយខ្លាំង តម្រេកខ្លាំងនៃចិត្ត សេចក្តីប្រាថ្នា ការជ្រុលជ្រប់ ការងល់ងប់ ការពាក់ព័ន្ធ ការរួបរឹត ការជាប់ចំពាក់ ការលិចចុះ ធម្មជាតិនាំសត្វ ឲ្យកើតក្នុងភព មាយា ធម្មជាតិបង្កើតសត្វ ធម្មជាតិឲ្យសត្វប្រកបដោយទុក្ខ ធម្មជាតិចាក់ស្រេះសត្វទុក បណ្តាញ ការបង្ហូរ ការផ្សាយទៅកាន់អារម្មណ៍ផ្សេងៗ ចំណងចងសត្វទុក ការផ្សាយទៅក្នុងអារម្មណ៍ ធម្មជាតិញ៉ាំងសត្វឲ្យបម្រើន ធម្មជាតិជាគម្រប់ពីរ ការតាំងចិត្ត

ទុក ធម្មជាតិនាំសត្វទៅកាន់ភព ធម្មជាតិដូចជាព្រៃ ដូចជាព្រៃញាតស្បាត ការមូលមិត្ត សេចក្តីស្រឡាញ់ ការអាឡោះអាល័យ ផៅពង្សតទៅ ការប៉ុនប៉ង ការប្រាថ្នា ភាពនៃចិត្តប៉ុនប៉ង ការប៉ុនប៉ងរូប ប៉ុនប៉ងសំឡេង ប៉ុនប៉ងក្លិន ប៉ុនប៉ងរស ប៉ុនប៉ងផ្សព្វ ប៉ុនប៉ងលាភ ប៉ុនប៉ងទ្រព្យ ប៉ុនប៉ងបុត្ត ប៉ុនប៉ងជីវិត ធម្មជាតិច្រួចច្រា ច្រួចច្រាជ្រុល ច្រួចច្រាខ្លាំង សេចក្តីច្រួចច្រា អាការច្រួចច្រា ភាពនៃចិត្តច្រួចច្រា ការរុលត្បុល អាការរុលត្បុល ភាពនៃចិត្តរុលត្បុល ការញាប់ញ័រ កាចង់បានឲ្យសម្រេចប្រយោជន៍ ការត្រេកអរខុសគន្លងធម៌ ការលោភហួសកំណត់ ការត្រេកត្រអាល ការចង់បានមិនឈប់ ការប្រាថ្នាសេចក្តីស្រឡាញ់ ការប្រាថ្នាព្រម ប្រាថ្នាក្នុងកាម ប្រាថ្នាក្នុងភព ប្រាថ្នាប្រាសចាកភព ប្រាថ្នាក្នុងរូបភព ប្រាថ្នាក្នុងអរូបភព ប្រាថ្នាក្នុងនិរោធ ប្រាថ្នារូប ប្រាថ្នាសំឡេង ប្រាថ្នាក្លិន ប្រាថ្នារស ប្រាថ្នាផ្សព្វ ប្រាថ្នាធម៌ កិលេសដូចជាជំនន់ គ្រឿងប្រកប គ្រឿងចងក្រង គ្រឿងប្រកាន់មាំ គ្រឿងរារាំងទូទៅ គ្រឿងរារាំងមិនសល់ គ្រឿងបិទបាំង គ្រឿងចង គ្រឿងសៅហ្មងខ្លាំង គ្រឿងដេកចាំ គ្រឿងស្ទាក់ដំណើរ តណ្ហាដូចជាវល្លិ ប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ហេតុជាដែនកើតនៃទុក្ខ អន្ទាក់នៃមារ នុយនៃមារ អារម្មណ៍នៃមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ខ្នោះគឺតណ្ហា សមុទ្រគឺតណ្ហា ការសម្លឹងរំពៃ សេចក្តីលោភ ជាអកុសលមូលណា នេះហៅថា លោភៈ ។ បណ្តាអកុសលមូលទាំងនោះ ទោសៈ តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អាត្មាអញ

គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អាត្មាអញ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្ត របស់អាត្មាអញ ។បេ។ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ។បេ។ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ថាជនឯណោះបានប្រព្រឹត្តនូវកម្មជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តរបស់អាត្មាអញ ។បេ។ កំពុងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ។បេ។ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ឬក៏គំនុំកើតឡើងក្នុងទីមិនគួរ ការគុំកួនចិត្ត ការគុំកួនតប សេចក្ដីថ្នាំងថ្នាក់ ការខឹងតប ការខឹងញាប់ញ័រ ការក្រោធខ្លាំង ក្រោធ-ញាប់ញ័រ ការប្រទូស្ត ការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចចិត្ត ការប្រទូស្តនៃចិត្ត ការក្រោធ ការខឹង ភាពនៃចិត្តខឹង សេចក្ដីប្រទូស្ត អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត សេចក្ដីវិនាស អាការវិនាស ភាពនៃចិត្តវិនាស ការខឹង ការខឹងតប ភាពនៃចិត្តកាច ការខឹង ការតូចចិត្តណា ដែលមានសភាពបែបនេះ នេះហៅថា ទោសៈ ។ បណ្ដាអកុសលមូល ទាំងនោះ មោហៈ តើដូចម្ដេច ។ ការមិនដឹងច្បាស់ក្នុងទុក្ខ មិនដឹងច្បាស់ក្នុងទុក្ខសមុ-ទ័យ មិនដឹងច្បាស់ក្នុងទុក្ខនិរោធ មិនដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម និងខាងចុង មិនដឹងច្បាស់ក្នុង

ពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ នឹងការមិនដឹងច្បាស់ការមិនឃើញ ការមិនត្រាស់ដឹង ការមិនយល់ ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានផ្ទៀងផ្ទាត់ ការមិនចុះចិត្តស៊ប់ ការមិនរំពឹងមើល ការមិនពិចារណា អំពើមិនជាក់ច្បាស់ ការយល់ស្មោគស្មើរ ភាពនៃចិត្តល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា ( ការមិនដឹងច្បាស់ ) អន្លង់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្មោគដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា ការវង្វេងជាអកុសលមូលណាដែល មានសភាពបែបនេះ នេះហៅថា មោហៈ ។ នេះអកុសលហេតុ ៣ ។

[ ១៩២ ] បណ្តាហេតុទាំងនោះ អព្យាកតៈហេតុ ៣ តើដូចម្តេច ។ អលោភៈ អទោសៈនិងអមោហៈខាងវិបាកនៃកុសលធម៌ផង ខាងកិរិយាអព្យាកតធម៌ផង នេះអព្យាតកហេតុ ៣ ។

[ ១៩៣ ] បណ្តាហេតុទាំងនោះ កាមាវចរហេតុ ៩ តើដូចម្តេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ នេះកាមាវចរហេតុ ៩ ។ បណ្តាហេតុទាំងនោះ រូបាវចរហេតុ ៦ តើដូចម្តេច ។ កុសលហេតុ ៣ អព្យាកតហេតុ ៣ នេះរូបាវចរហេតុ ៦ ។ បណ្តាហេតុទាំងនោះ អរូបាវចរហេតុ ៦ តើដូចម្តេច ។ កុសលហេតុ ៣ អព្យាតកហេតុ ៣ នេះអរូបាវចរហេតុ ៦ ។

[ ១៩៤ ] បណ្តាហេតុទាំងនោះ អបរិយាបន្នហេតុ ៦ តើដូចម្តេច ។ កុសលហេតុ ៣ អព្យាកតហេតុ ៣ នេះអបរិយាបន្នហេតុ ៦ ។ បណ្តា

ហេតុទាំងនោះ កុសលហេតុ ៣ តើដូចម្ដេច ។ អលោភៈ អទោសៈនិង អមោហៈ ។ បណ្ដាកុសលហេតុទាំងនោះ អលោភៈ តើដូចម្ដេច ។ សេចក្ដីមិនប្រាថ្នាជាប់ ការមិនជាប់ចំពាក់ ភាពនៃចិត្តមិនជាប់ចំពាក់ សេចក្ដីមិនត្រេកអរខ្លាំង ការមិនត្រេកអរ ភាពនៃចិត្តមិនត្រេកអរ ការមិនសម្លឹងរំពៃ សេចក្ដីមិនលោភ ជាកុសលមូលណា នេះហៅថា អលោភៈ ។ បណ្ដាកុសលហេតុទាំងនោះ អទោសៈ តើដូចម្ដេច ។ សេចក្ដីមិនប្រទូស្ត អាការមិនប្រទូស្ត ភាពនៃចិត្តមិនប្រទូស្ត ។បេ។ ការមិនគុំគួន ការមិនបៀតបៀន ការមិនខឹង ជាកុសលមូលណា នេះហៅថា អទោសៈ ។ បណ្ដាកុសលហេតុទាំងនោះ អមោហៈ តើដូចម្ដេច ។ ការដឹងច្បាស់ក្នុងកងទុក្ខ ដឹងច្បាស់ក្នុងទុក្ខសមុទ័យ ដឹងច្បាស់ក្នុងទុក្ខនិរោធ ដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើម ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង ដឹងច្បាស់ក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង ដឹងច្បាស់ក្នុងពួកធម៌ដែលកើតឡើងព្រោះអាស្រ័យបច្ច័យនោះៗ និងបញ្ញាការដឹងច្បាស់ ការសន្សំ ការប្រមូល ការពិចារណាធម៌ ការចំណាំ ការចំណាំស្អិទ្ធ ការចំណាំចំពោះខ្លួន ភាពជាបណ្ឌិត ការឈ្លាសវៃ ប្រសប់ ប៉ុនប៉ៅ គិតគូរ ពិចារណា ប្រាជ្ញាដូចផែនដី ប្រាជ្ញាទម្លាយនូវកិលេស ធម្មជាតិសម្រាប់ដឹកនាំការយល់ឃើញច្បាស់ ដឹងខ្លួនច្បាស់លាស់ ចាក់ធ្លុះ បញ្ញា ឥន្ទ្រិយគឺបញ្ញា កម្លាំងគឺបញ្ញា គ្រឿងសស្ត្រាគឺបញ្ញា ប្រាសាទគឺបញ្ញា ពន្លឺគឺបញ្ញា រស្មីគឺបញ្ញា ប្រទីបគឺបញ្ញា កែវគឺបញ្ញា ការមិនវង្វេង ការពិចាណាធម៌ ការយល់

ត្រូវអង្គនៃការត្រាស់ដឹង គឺការពិចារណាធម៌ អង្គនៃមគ្គ មគ្គបរិយាបន្នណា មានសភាពបែបនេះ នេះហៅថា អមោហៈ ។ នេះកុសលហេតុ ៣ ។ បណ្តាហេតុទាំងនោះ អព្យាកតហេតុ ៣ តើដូចម្តេច ។ អលោភៈ អទោសៈ និងអមោហៈ ខាងវិបាកនៃពួកកុសលធម៌ នេះអព្យាកតហេតុ ៣ ។ នេះអបរិយាបន្នហេតុ ៦ ។

## នេះពួកធម៌ជាហេតុ ។

[ ១៩៥ ] ពួកធម៌មិនមែនហេតុ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនហេតុ ។

[ ១៩៦ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅជាមួយនឹងហេតុដោយធម៌ទាំងនោះ និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណា មិនប្រព្រឹត្តទៅជាមួយនឹងហេតុដោយធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ។

[ ១៩៧ ] ពួកធម៌ប្រកបដោយហេតុ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយហេតុ ។ ពួកធម៌ប្រាសចាកហេតុ តើដូចម្តេច ។ ពួកធម៌ណា ប្រាស

ចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកហេតុ ។

[ ១៩៨ ] ពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង តើដូចម្តេច ។ លោភៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផងដោយមោហៈ ឯមោហៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផងដោយលោភៈ ទោសៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផងដោយមោហៈ ឯមោហៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផងដោយទោសៈ អលោភៈ អទោសៈនិងអមោហៈជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុទាំងនោះផង ទៅវិញទៅមក នេះពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ។ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនហេតុ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅជាមួយនឹងហេតុដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុតែមិនមែនហេតុ ។

[ ១៩៩ ] ពួកធម៌ជាហេតុផង ប្រកបដោយហេតុផង តើដូចម្តេច ។ លោភៈជាហេតុផង ប្រកបដោយហេតុផង ដោយមោហៈ ឯមោហៈជាហេតុផង ប្រកបដោយហេតុផង ដោយលោភៈ ទោសៈជាហេតុផង ប្រកបដោយហេតុផង ដោយមោហៈ ឯមោហៈជាហេតុផង ប្រកបដោយហេតុផង ដោយទោសៈ អលោភៈ អទោសៈ អមោហៈជាហេតុផង ប្រកបដោយហេតុទាំងនោះផង ទៅវិញទៅមក នេះពួកធម៌ជាហេតុផង ប្រកបដោយហេតុផង ។

ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះវៀរតែធម៌ទាំងនោះចេញនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនហេតុ ។

[ ២០០ ] ពួកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណា មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ដោយធម៌ទាំងនោះនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌មិនមែនហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកធម៌មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ ពួកធម៌ណាមិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុដោយធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនហេតុ ទាំងមិនប្រព្រឹត្តទៅជាមួយនឹងហេតុ ។

# អដ្ឋកថា ទុកនិក្ខេប

## ហេតុគោច្ឆក

[ ១៨៩-២០០ ] គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសអទោសៈ ក្នុងហេតុគោច្ឆក-ទុកៈ ដូចតទៅនេះថា

ធម៌ដែលឈ្មោះថា **មេត្តិ** ដោយអំណាចនៃកិរិយាដែលស្និទ្ធស្នាល ។ អាការៈនៃមេត្តា ឈ្មោះថា **មេត្តាយនា** ។ ភាពជាមិត្តដែលព្រមព្រៀងដោយមេត្តា ដែលមេត្តាឲ្យប្រព្រឹត្តទៅ ឈ្មោះថា **មេត្តាយិតត្តំ** ។ ដែលឈ្មោះថា **អនុទ្ទា** ព្រោះអត្ថថា អើពើ គឺរមែងឃុំគ្រង ។ អាការដែលអាណិត ឈ្មោះថា **អនុទ្ទាយនា** ។ ភាវៈនៃកិរិយាដែលអាណិត ឈ្មោះថា **អនុទ្ទាយិតត្តំ** ។ ការស្វែងរកប្រយោជន៍ ឈ្មោះថា **ហិតេសិតា** ។ ឈ្មោះថា **អនុកម្បា** ដោយអំណាចការអនុគ្រោះ ។

ព្រះអង្គត្រាស់ដល់មេត្តាដែលសម្រេចឧបចារៈនិងអប្បនានោះឯងដោយបទទាំងអស់នេះ ត្រាស់ដល់អទោសៈដែលជាលោកិយ និងលោកុត្តរៈដោយបទដ៏សេស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសអមោហៈ ដូចតទៅនេះថា

បទថា **ទុក្ខេ ញាណំ** បានដល់ បញ្ញាក្នុងទុក្ខសច្ច ។ សូម្បីក្នុងបទជាដើមថា **ទុក្ខសមុទយេ** ជាដើម ក៏មានន័យនេះដូចគ្នា ។ បណ្តាការដឹងក្នុងទុក្ខជាដើមនោះ ការដឹងច្បាស់ក្នុងទុក្ខរមែងប្រព្រឹត្តទៅក្នុងការស្តាប់ ការយល់ ការចាក់ធ្លុះនិងការពិចារណា ការដឹងច្បាស់ក្នុងទុក្ខសមុទ័យក៏ប្រព្រឹត្ត

ទៅយ៉ាងនោះ ។ តែការដឹងក្នុងនិរោធ រមែងប្រព្រឹត្តទៅព្រោះការស្តាប់ ការចាក់ធ្លុះ និងការពិចារណានុ៎ះឯង ការដឹងក្នុងទុក្ខនិរោធគាមិនីបដិបទាក៏ដូចគ្នា ។

បទថា **បុព្វន្តេ** បានដល់ ក្នុងចំណែកដែលកន្លងទៅហើយ ។ បទថា **អបរន្តេ** បានដល់ ក្នុងចំណែកដែលនៅមិនទាន់មកដល់ ។ បទថា **បុព្វន្តាបរន្តេ** បានដល់ ក្នុងចំណែកទាំង ២ នោះ ។ បទថា **ឥទប្បច្ចយតាបដិច្ចសមុប្បន្នេសុ ធម្មេសុ ញាណំ** បានដល់ ការដឹងក្នុងបច្ច័យទាំងឡាយ និងក្នុងធម៌ដែលកើតឡើង ព្រោះបច្ច័យទាំងឡាយយ៉ាងនេះថា នេះជាបច្ច័យធម៌នេះកើតឡើងព្រោះអាស្រ័យធម៌នេះ ដូច្នេះ ។

ក្នុងនិទ្ទេសនៃលោភៈ អត្ថនៃពាក្យទាំងឡាយ ដែលមិនធ្លាប់ពោលទុកគប្បីជ្រាបដូចតទៅនេះថា

សភាវៈដែលឈ្មោះថា **រាគោ** ដោយអំណាចសេចក្តីត្រេកអរ ។ ដែលឈ្មោះថា **សារាគោ** ដោយអត្ថថា សេចក្តីត្រេកអរដ៏មានកម្លាំង ។ ដែលឈ្មោះថា **អនុនយោ** ព្រោះញុំាងសត្វទាំងឡាយឲ្យអនុលោមតាមក្នុងអារម្មណ៍ទាំងឡាយ ។ ដែលឈ្មោះថា **អនុរោធោ** ព្រោះអត្ថថា ពេញចិត្ត អធិប្បាយថា ធ្វើសត្វឲ្យប្រាថ្នា ។ ដែលឈ្មោះថា **នន្ទី** ព្រោះអត្ថថា ជាហេតុឲ្យសត្វរីករាយ ក្នុងភពណាមួយឬខ្លួនឯងក៏រីករាយ ។ សេចក្តីរីករាយនោះផង តម្រេក ដោយអត្ថថា សេចក្តីត្រេកត្រអាលនោះផង ព្រោះហេតុនោះ ទើបឈ្មោះថា **នន្ទីរាគោ** ក្នុងនន្ទីរាគៈនោះ តណ្ហាកើតឡើងម្តងក្នុងអារម្មណ៍មួយ ឈ្មោះថា **នន្ទី** កាលកើតឡើងរឿយៗក៏ហៅថា **នន្ទីរាគ** ។

បទថា **ចិត្តស្ស សារាគោ** បានដល់ តម្រេកណាដែលខ្ញុំធ្លាប់ពោលទុកថា **សារាគោ** ដោយអត្ថថា សេចក្ដីត្រេកអរដែលមានកម្លាំង តម្រេកនោះ ជាតម្រេកខ្លាំងរបស់ចិត្តប៉ុណ្ណោះ មិនមែនរបស់សត្វ ។

សភាវៈដែលឈ្មោះថា **ឥច្ឆា** ព្រោះអត្ថថា ជាហេតុប្រាថ្នាក្នុងអារម្មណ៍ ។ ដែលឈ្មោះថា **មុច្ឆា** ព្រោះអត្ថថា ជាហេតុឲ្យសត្វងប់ងល់ ព្រោះកិលេសដ៏មានកម្លាំង ។ ដែលឈ្មោះថា **អជ្ឈោសានំ** ដោយអំណាចការលេបឲ្យអស់ហើយប្រកាន់ទុក ។ ដែលឈ្មោះថា **គេធោ** ព្រោះអត្ថថា ជាហេតុឲ្យសត្វប្រាថ្នាច្រើនដោយរាគៈនេះ គឺឲ្យដល់សេចក្ដីល្មោភ ។ម្យ៉ាងទៀតឈ្មោះថា **គេធោ** ដោយអត្ថថា ក្រាស់ ។ មែនពិត ពាក្យថា ព្រៃស្កុក ( ក្រាស់ ) ពោលទុកដោយអត្ថថា ក្រាស់នោះឯង ។ បទតទៅគឺ **បលិគេធោ** ទ្រង់បន្ថែមឧបសគ្គ ។ ម្យ៉ាងទៀត ឈ្មោះថា **បលិគេធោ** ព្រោះអត្ថថា ជាសេចក្ដីប្រាថ្នាដោយចំណែកទាំងពួង ។ ដែលឈ្មោះថា **សង្គោ** ព្រោះអត្ថថា ជាហេតុឲ្យសត្វជាប់នៅ ម្យ៉ាងទៀត ឈ្មោះថា **សង្គោ** ដោយអត្ថថាជាប់នៅ ។ ដែលឈ្មោះថា **បង្កោ** ដោយអត្ថថា លិចចុះ ។ ដែលឈ្មោះថា **ឯជា** ដោយអំណាចនៃការទាញមក មែនពិត លោកពោលថា ធម្មជាតដែលទាញមករមែងទាញបុរសមកដើម្បីកើតឡើងចំពោះក្នុងភពនោះៗ ដោយពិត ។ ដែលឈ្មោះថា **មាយា** ដោយអត្ថថា បោកបញ្ឆោត សត្វលោក ។ ដែលឈ្មោះថា **ជនិកា** ដោយអត្ថថា ញុំាងសត្វឲ្យកើតក្នុងវដ្ដៈ មែនពិត ដូចព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយសគាថវគ្គ ) ថា តណ្ហាតែងញុំាងបុរសឲ្យកើត ចិត្ត

របស់បុរសនោះ តែងស្អុះទៅ ដូច្នេះ ។ ដែលឈ្មោះថា **សញ្ញាណី** ព្រោះអត្ថថា ប្រកបនូវសត្វទាំងឡាយដោយទុក្ខ រមែងឲ្យកើតក្នុងវដ្ដៈ ។ ដែលឈ្មោះថា **សិព្វិនី** ព្រោះអត្ថថា រមែងដោត ក្រងសត្វទុកដោយការបន្ត មែនពិត តណ្ហានេះ រមែងដោតក្រងសត្វ គឺធ្វើសត្វឲ្យបន្តក្នុងវដ្ដៈដោយអំណាចចុតិ បដិសន្ធិ ដូចជាងដេរប៉ះសំពត់ចាស់នឹងសំពត់ចាស់ ព្រោះហេតុនោះទើបខ្ញុំពោលថា ធម្មជាតដោតក្រង ដោយអត្ថថា បន្ត ។ ដែលឈ្មោះថា **ជា-លិនី** ព្រោះអត្ថថា បណ្ដាញ គឺអារម្មណ៍ មានប្រការច្រើន ឬថា បណ្ដាញគឺការចូលទៅអន្ទះអន្ទែងនៃតណ្ហា ។

ដែលឈ្មោះថា **សរិតា** ព្រោះអត្ថថា ដូចស្ទឹង មានក្រសែខ្លួលខ្លាញ់ដោយអត្ថថា ទាញមក ម្យ៉ាងទៀត ដែលឈ្មោះថា **សរិតា** ដោយអត្ថថា ទទឹកចិត្ត ដូចព្រះតម្រាស់ ( ក្នុងខុទ្ទកនិកាយធម្មបទ ) ថា សោមនស្សទាំងឡាយដែលផ្សាយទៅហើយផង ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ផង រមែងមានដល់សត្វ ដូច្នេះ ។ ក្នុងព្រះបាលីនោះមានអធិប្បាយដូច្នេះថា សោមនស្ស ដែលធ្វើនូវការរីករាយនិងការស្និទ្ធស្នាលគ្នា ។ តណ្ហាណាផ្សាយទៅ ព្រោះហេតុនោះ តណ្ហានោះឈ្មោះថា វិសត្តិកា ។ តណ្ហាណាដ៏ទូលាយ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណាជ្រួតជ្រាបទៅ ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណាអត់ទ្រាំ ព្រោះហេតុនោះ តណ្ហានោះឈ្មោះថា វិសត្តិកា ។ តណ្ហាណាប្រមូលផ្សេងៗ ព្រោះហេតុនោះ តណ្ហានោះឈ្មោះថា វិសត្តិកា ។ តណ្ហា

ណា ញុាំងសត្វឲ្យពោលខុស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណាមានឫសគល់ជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានផ្លែជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ តណ្ហាណា មានគ្រឿងបរិភោគជាពិស ព្រោះហេតុនោះ តណ្ហានោះ ឈ្មោះថា វិសត្តិកា ។ មួយទៀត តណ្ហានោះជាកិលេសជាតិទូលាយ បាចសាចទៅ ផ្សាយទៅក្នុងរូប សំឡេង ក្លិន រសផ្សព្វ ក្នុងត្រកូល គណៈ[១]ដូច្នេះ ។ ដែលឈ្មោះថា **សុត្តំ** ព្រោះអត្ថថា ដូចសរសៃអំបោះដែលចងអណ្តើកទុក ដោយអត្ថថា ឲ្យដល់នូវសេចក្តីសាបសូន្យនិងសេចក្តីវិនាស សមដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងសំយុត្តនិកាយនិទានវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ពាក្យថា ខ្សែទុំ ជាឈ្មោះនៃនន្ទិរាគ ( តម្រេកដោយសេចក្តីត្រេកត្រអាល ) ដូច្នេះ ។ ដែលឈ្មោះថា **វិសដា** ដោយអត្ថថា ផ្សាយទៅក្នុងអារម្មណ៍ មានរូបជាដើម ។ ដែលឈ្មោះថា **អាយូហិនី** ព្រោះអត្ថថា ញុាំងសត្វឲ្យខ្វល់ខ្វាយ ដើម្បីការបានវត្ថុនោះៗ ។ ដែលឈ្មោះថា **ទុតិយា** ដោយអត្ថថា ជាសម្លាញ់ ព្រោះមិនឲ្យនឿយណាយ ។ មែនពិត តណ្ហានេះ រមែងមិនឲ្យសត្វទាំងឡាយនឿយណាយក្នុងវដ្តៈ គឺឲ្យអភិរម្យ ដូចសម្លាញ់ជាទីស្រឡាញ់ ក្នុងទីដែលខ្លួនទៅហើយ ដូច្នោះ ដោយហេតុនោះទើបត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយចតុក្កនិបាត ) ថា

---

១-ខុទ្ទកនិកាយ មហានិទ្ទេស ។

បុរសមានតណ្ហាជាគម្រប់ពីរអន្ទោលទៅ ( ក្នុងសង្សារវដ្ត ) អស់កាលដ៏វែងរមែងមិនប្រព្រឹត្តកន្លងនូវសង្សារ គឺខន្ធ ធាតុ អាយតនៈ ដែលមានក្នុងអត្តភាពនេះនិងខាងមុខ ដូច្នេះ ។

ដែលឈ្មោះថា **បណិធិ** ដោយអំណាចនៃការតាំងសេចក្តីប្រាថ្នា ។ ដែលឈ្មោះថា **ភវនេត្តិ** ព្រោះអត្ថថា នាំទៅកាន់ភព មែនពិត សត្វទាំងឡាយត្រូវតណ្ហានេះនាំទៅកាន់ទីដែលខ្លួនប្រាថ្នាហើយ ដូចគោទាំងឡាយដែលត្រូវខ្សែចងកទុក ដូច្នោះ ។ ដែលឈ្មោះថា **វនំ** ព្រោះអត្ថថា រមែងប្រជុំ គឺរមែងគប់រក រមែងប្រកាន់នូវអារម្មណ៍នោះៗ ។ម្យ៉ាងទៀត ឈ្មោះថា **វនំ** ព្រោះអត្ថថា រមែងអង្វរ ។ បទថា **វនថោ** ទ្រង់បន្ថែមបទព្យញ្ជនៈ ម្យ៉ាងទៀត ឈ្មោះថា **វនំ** ព្រោះអត្ថថា ដូចព្រៃដោយអត្ថថា ញុំាងទុក្ខដែលជាសេចក្តីវិនាសឲ្យតាំងឡើង និងដោយអត្ថថា ជាព្រៃស្តុក ។ ពាក្យថា **វនំ** នេះ ជាឈ្មោះរបស់តណ្ហាដ៏មានកម្លាំង ចំណែកតណ្ហាដែលមានកម្លាំងជាងនោះ ឈ្មោះថា **វនថោ** ដោយអត្ថថា ជាព្រៃស្តុក ដោយហេតុនោះ ទើបទ្រង់ត្រាស់ទុក ( ក្នុងខុទ្ទកនិកាយធម្មបទ ) ថា

អ្នកទាំងឡាយចូរកាត់កិលេសដូចជាព្រៃចេញ ចូរកុំកាត់ដើមឈើ ( ព្រោះ ) ភ័យកើតអំពីកិលេសដូចជាព្រៃ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរកាត់កិលេស ដូចជាព្រៃផង កិលេសដូចជាដើមឈើដុះក្នុងព្រៃផង ហើយចូរជាអ្នកកុំមានកិលេសដូចជាព្រៃឡើយ ដូច្នេះ ។

តណ្ហានោះ ឈ្មោះថា **សន្ថវោ** ដោយអំណាចស្និទ្ធស្នាល អធិប្បាយថា ប្រឡូកប្រឡំ ។ សន្ថវៈនោះ មាន ២ យ៉ាង គឺតណ្ហាសន្ថវ ១ មិត្តសន្ថវ ១ ។

បណ្តាសន្ថវៈទាំង ២ នោះ ក្នុងទីនេះ ទ្រង់ប្រាថ្នាយកតណ្ហាសន្ថវៈ ។ ដែលឈ្មោះថា **សិនេហោ** ដោយអំណាចសេចក្តីស្នេហា ។ ដែលឈ្មោះថា **អបេក្ខា** ព្រោះអត្ថថា រមែងសម្លឹងដោយអំណាចការធ្វើសេចក្តីអាល័យ សេចក្តីនេះសមដូចព្រះបាលីដែលត្រាស់ទុក ( ក្នុងមហាសុទស្សនសូត្រ ) ថា បពិត្រព្រះសម្មតិទេព នគរទាំង ៨៤០០០ របស់ព្រះអង្គនេះ មាននគរកុសាវតីរាជធានី ជាប្រធាន បពិត្រព្រះសម្មតិទេព សូមព្រះអង្គបង្កើតនូវសេចក្តីស្រឡាញ់ចំពោះនគរទាំងនុ៎ះ សូមព្រះអង្គធ្វើនូវសេចក្តីអាល័យ ក្នុងព្រះជីវិត ដូច្នេះ ក្នុងព្រះបាលីនេះមានអធិប្បាយថា ចូរធ្វើសេចក្តីអាល័យ ។

តណ្ហាដែលឈ្មោះថា **បដិពន្ធុ** ព្រោះអត្ថថា ចងទុកចំពោះអារម្មណ៍នីមួយៗ ។ ម្យ៉ាងទៀត ឈ្មោះថា **បដិពន្ធុ** ព្រោះអត្ថថា ជាផៅពង្សចំពោះបុគ្គលនីមួយៗ ដោយអត្ថថា ជាញាតិ ។ មែនពិត ឈ្មោះថា ផៅពង្សស្មើដោយតណ្ហារមែងមិនមានដល់សត្វទាំងឡាយ ដោយអត្ថថា អាស្រ័យនៅជានិច្ច ។

ដែលឈ្មោះថា **អាសា** ព្រោះប៉ុនប៉ងក្នុងអារម្មណ៍ទាំងឡាយ អធិប្បាយថា ព្រោះគ្របសង្កត់ និងព្រោះការបរិភោគមិនចេះឆ្អែត ។ ដែលឈ្មោះថា **អាសិសនា** ដោយអំណាចនៃសេចក្តីប្រាថ្នា ។ ភាវៈនៃសេចក្តីប្រាថ្នា ឈ្មោះ

ថា **អាសិសិតត្តំ** ។

ឥឡូវនេះ ដើម្បីសម្តែងឋានៈនៃការប្រព្រឹត្តទៅរបស់តណ្ហានោះ ទើបត្រាស់ពាក្យជាដើមថា **រូបាសា** ដូច្នេះ ។ ក្នុងព្រះបាលីជាដើមថា ការប៉ុនប៉ងរូបជាដើមនោះ គប្បីជ្រាបបទសូម្បី ៩ យ៉ាងនេះថា ការប៉ុនប៉ងរូបឈ្មោះថា **រូបាសា** ដោយកាន់យកអត្ថនៃការប៉ុនប៉ងថា ឈ្មោះថា **អាសា** ដោយអំណាចនៃការប៉ុនប៉ង ។ បណ្ដាបទទាំង ៩ នេះ ៥ បទខាងដើមត្រាស់ដោយអំណាចបញ្ចកាមគុណ ។ បទទី ៦ ត្រាស់ដោយអំណាចសេចក្ដីលោភក្នុងបរិក្ខារ បទទី ៦ នោះ ជារបស់ពួកបព្វជិតដោយពិសេស ៣ បទតពីនោះ ជារបស់ពួកគ្រហស្ថដោយអំណាចនៃវត្ថុ ជាអារម្មណ៍មិនចេះឆ្អែតព្រោះវត្ថុដែលជាទីស្រឡាញ់ក្រៃលែងជាងទ្រព្យ បុត្ត ជីវិតរបស់ពួកគ្រហស្ថទាំងនោះមិនមាន ។

ឈ្មោះថា **ជប្បា** ព្រោះអត្ថថា ញុំាងសត្វឲ្យនិយាយខ្សឹបៗយ៉ាងនេះថា នេះរបស់ខ្ញុំ នេះរបស់ខ្ញុំ ឬវត្ថុនេះ បុគ្គលឯណោះឲ្យដល់ខ្ញុំ វត្ថុនេះ បុគ្គលឯណោះឲ្យដល់ខ្ញុំ ដូច្នេះ ។ ពីរបទតអំពីនោះគឺ **បជប្បា អភិជប្បា** ទ្រង់បន្ថែមឧបសគ្គចូលមក ។ តអំពីនោះទៅ ទ្រង់ត្រាស់ពាក្យថា **ជប្បា** ទៀត ព្រោះទ្រង់ប្រារព្ធដើម្បីនឹងចែកដោយអាការដទៃ ។ អាការខ្សឹប ឈ្មោះថា **ជប្បនា** ។ ភាវៈនៃការខ្សឹប ឈ្មោះថា **ជប្បិតត្តំ** ។ ឈ្មោះថា **លោលុបោ** ព្រោះអត្ថថា ប្រូន់ គឺទាញមកក្នុងអារម្មណ៍រឿយៗ ។ ភាវៈនៃការលោភលន់ ឈ្មោះថា **លោលុប្បំ** ។ អាការនៃការលោភលន់ ឈ្មោះថា **លោលុប្បា-**

**យនា** ។ ភាវៈនៃបុគ្គលដែលដល់ព្រមដោយការលោភលន់ ឈ្មោះថា **លោលុប្បាយិតត្តំ** ។

បទថា **បុច្ឆញ្ជិកតា** សេចក្តីថា សត្វទាំងឡាយរមែងត្រាច់ញាប់ញ័រទៅ ដូចក្អែបក់កន្ទុយក្នុងទីជាទីតាំងនៃការចង់បានដោយតណ្ហាណា ពាក្យថា ការញាប់ញ័រនោះ ជាឈ្មោះនៃតណ្ហានោះដែលឲ្យកើតការញាប់ញ័រទៅ ។

បទថា **សាធុកម្យតា** សេចក្តីថា សភាវៈឲ្យចង់បានអារម្មណ៍ដែលគាប់ចិត្ត ដែលត្រេកអរនៃចិត្ត ព្រោះហេតុនោះ ទើបហៅថា សេចក្តីប្រាថ្នាក្នុងអារម្មណ៍ដែលល្អ ។ ភាវៈនៃសេចក្តីប្រាថ្នាក្នុងអារម្មណ៍ដែលល្អនោះ ឈ្មោះថា **សាធុកម្យតា** ។ តណ្ហាដែលឈ្មោះថា **អធម្មរាគោ** ព្រោះអត្ថថា តម្រេកក្នុងឋានៈដែលមិនគួរ មានមាតានិងមីងជាដើម ។ សេចក្តីលោភដែលកើតឡើងមានកម្លាំងខ្លាំង សូម្បីក្នុងឋានៈដែលគួរ ឈ្មោះថា **វិសមលោភោ** ម្យ៉ាងទៀត គប្បីជ្រាបថា ឆន្ទរាគៈដែលកើតឡើងក្នុងឋានៈដែលគួរក្តី ក្នុងឋានៈដែលមិនគួរក្តី ដោយព្រះបាលី ( ក្នុងអភិធម្មវិភង្គ ) ថា រាគៈជាធម្មជាតមិនរាបស្មើជាដើម ឈ្មោះថា **អធម្មរាគោ** ដោយអត្ថថាមិនជាធម៌ ឈ្មោះថា **វិសមលោភោ** ដោយអត្ថថា មិនស្មើ ។

តណ្ហាដែលឈ្មោះថា **និកន្តិ** ដោយអំណាចនៃការត្រេកត្រអាល ក្នុងអារម្មណ៍ទាំងឡាយ ។ អាការនៃការត្រេកត្រអាលក្នុងអារម្មណ៍ទាំងឡាយ ឈ្មោះថា **និកាមនា** ។ ឈ្មោះថា **បត្ថនា** ដោយអំណាចនៃការតាំងចិត្ត ។ ឈ្មោះថា **បិហនា** ដោយអំណាចនៃសេចក្តីប្រណែន ។ សេចក្តីប្រាថ្នាដោយ

ល្អ ឈ្មោះថា **សម្បត្តូធា** ។ តណ្ហាក្នុងកាមគុណ ៥ ឈ្មោះថា **កាម-តណ្ហា** តណ្ហាក្នុងរូបភពនិងអរូបភព ឈ្មោះថា **ភវតណ្ហា** តណ្ហាក្នុងវិភវៈ ពោលគឺការដាច់សូន្យ ឈ្មោះថា **វិភវតណ្ហា** តណ្ហាក្នុងរូបភពសុទ្ធៗតែ-ម្យ៉ាង ឈ្មោះថា **រូបតណ្ហា** តណ្ហាក្នុងអរូបភព ឈ្មោះថា **អរូបតណ្ហា** ។ សេចក្តីត្រេកអរប្រកបដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា **ធិដ្ឋិរាគ** តណ្ហាក្នុងនិរោធ ឈ្មោះថា **ធិរោធតណ្ហា** តណ្ហាក្នុងរូប ឈ្មោះថា **រូបតណ្ហា** តណ្ហាក្នុងសំឡេង ឈ្មោះថា **សទ្ទតណ្ហា** តណ្ហាក្នុងក្លិន ឈ្មោះថា **គន្ធតណ្ហា** ។ សូម្បីក្នុងរសជាដើមក៏មានន័យនេះឯង ។ ពាក្យថា ឱឃៈជាដើមមានសេចក្តីតាមដែលពោលហើយនុ៎ះឯង ។

ដែលឈ្មោះថា **អាវរណំ** ព្រោះអត្ថថា រាំងនូវកុសលធម៌ទាំងឡាយ ។ ដែលឈ្មោះថា **ឆាទនំ** ដោយអំណាចការបិទបាំង ។ ដែលឈ្មោះថា **ពន្ធនំ** ព្រោះអត្ថថា រមែងចងសត្វទុកក្នុងវដ្តៈ ។ ដែលឈ្មោះថា **ឧបក្កិលេសោ** ព្រោះចិត្តចូលជិតហើយនឹងសៅហ្មង គឺធ្វើចិត្តឲ្យសៅហ្មង ។ ដែលឈ្មោះថា **អនុសយោ** ព្រោះអត្ថថា ដេកត្រាំដោយអត្ថថាមានកម្លាំង ។ ដែលឈ្មោះថា **បរិយុដ្ឋានំ** ព្រោះអត្ថថា កើតឡើងរឹតរុំចិត្ត អធិប្បាយថា គ្រប់គ្រងផ្លូវកុសលដោយមិនឲ្យកុសលកើតឡើង ពិតណាស់ ដូចក្នុងប្រយោគជាដើមថា **ចោរា មគ្គេ បរិយុដ្ឋឹសុ** ពួកចោរចាំស្កាត់ត្រង់កណ្តាលផ្លូវ **ធុត្តា មគ្គេ បរិយុដ្ឋឹសុ** ពួកអ្នកលេងចាំស្កាត់ត្រង់កណ្តាលផ្លូវ ដូច្នេះ ក្នុងទីនេះក៏ដូចគ្នា គប្បីជ្រាបបរិយុដ្ឋាន ដោយអត្ថថា គ្រប់គ្រងនូវផ្លូវ ។ តណ្ហាដែលឈ្មោះថា

**លតា** ព្រោះអត្ថថា ដូចជាវល្លិ ដោយសេចក្តីថា ព័ទ្ធព័ន្ធទុកដោយជុំវិញ ។ តណ្ហានេះ ត្រាស់ហៅថា **លតា** ដែលមកហើយ ( ក្នុងខុទ្ទកនិកាយធម្មបទ ) ថា **លតា ឧព្ភិជ្ជ តិដ្ឋតិ** តណ្ហាដូចជាវល្លិ ដែលបែកខ្នែងឡើងតាំងនៅដូច្នេះ ។ ដែលឈ្មោះថា **វេវិច្ឆំ** ព្រោះអត្ថថា ប្រាថ្នាវត្ថុមានប្រការផ្សេងៗ ។ ដែលឈ្មោះថា **ទុក្ខមូលំ** ព្រោះអត្ថថា ជាមូលនៃវដ្តទុក្ខ ។ ដែលឈ្មោះថា **ទុក្ខនិទានំ** ព្រោះអត្ថថា ជាហេតុកើតនៃទុក្ខនោះឯង ។ ដែលឈ្មោះថា **ទុក្ខប្បភវោ** ព្រោះអត្ថថា ទុក្ខនោះរមែងកើតអំពីតណ្ហានេះ ។ ដែលឈ្មោះថា **បាសោ** ព្រោះអត្ថថា ដូចជាអន្ទាក់ ដោយអត្ថថា ចំណង ។ អន្ទាក់នៃមារ ឈ្មោះថា **មារបាសោ** ។ ដែលឈ្មោះថា **ពឡិសំ** ព្រោះអត្ថថា ដូចជាសន្ទូច ដោយអត្ថថា ខ្ពាក់ចេញបានដោយក្រ ។ សន្ទូចរបស់មារ ឈ្មោះថា **មារពឡិសំ** ។ សត្វដែលត្រូវតណ្ហាគ្របសង្កត់ហើយ រមែងមិនឈានកន្លងវិស័យរបស់មារ មាររមែងមានអំណាចលើសត្វទាំងនោះ ព្រោះហេតុនោះ ដោយបរិយាយនេះទើបហៅថា **មារវិសយោ** ព្រោះអត្ថថា ជាវិស័យនៃមារ ។

ស្ទឹងគឺតណ្ហា ដោយអត្ថថា ហូរទៅ ឈ្មោះថា **តណ្ហានទី** ។ បណ្តាញគឺតណ្ហា ដោយអត្ថថា គ្របទុក ឈ្មោះថា **តណ្ហាជាលំ** ។ សុនខទាំងឡាយដែលគេយកខ្សែចងទុក រមែងត្រូវនាំទៅតាមប្រាថ្នាយ៉ាងណា សត្វទាំងឡាយ ដែលត្រូវតណ្ហាចងទុកក៏យ៉ាងនោះ ព្រោះហេតុនោះ តណ្ហានោះទើបឈ្មោះថា **គទ្ទុលំ** ព្រោះដូចជាខ្សែ ដោយអត្ថថា ចងទុកយ៉ាងមាំ ។

ខ្សែគឺតណ្ហា ឈ្មោះថា **តណ្ហាគទ្ទុលំ** ។ សមុទ្ទគឺតណ្ហា ដោយអត្ថថា ឲ្យពេញបានដោយកម្រ ព្រោះហេតុនោះ ទើបឈ្មោះថា **តណ្ហាសមុទ្ទោ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទោសៈនិទ្ទេស ដូចតទៅនេះថា

បទថា **អនត្ថំ មេ អចរិ** គឺបានធ្វើសេចក្តីមិនចម្រើនដល់អាត្មាអញ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួង ដោយឧបាយនេះ ។ បទថា **អដ្ឋានេ វា បន អាឃាតោ** បានដល់ សេចក្តីក្រោធរមែងកើតឡើងក្នុងឋានៈដែលមិនមែនហេតុ មែនពិត បុគ្គលពួកខ្លះ រមែងខឹងក្រោធក្នុងឋានៈ ដែលមិនមែនហេតុថា ភ្លៀងធ្លាក់ច្រើនពេក រមែងខឹងក្រោធថា ភ្លៀងមិនធ្លាក់ រមែងខឹងក្រោធថា ព្រះអាទិត្យក្តៅ រមែងខឹងក្រោធថា ព្រះអាទិត្យមិនក្តៅ កាលខ្យល់បក់ក៏ខឹងក្រោធ ខ្យល់មិនបក់ក៏ខឹងក្រោធ កាលមិនអាចនឹងបោសទីលាន ក៏ខឹងក្រោធស្លឹកពោធិទាំងឡាយ កាលមិនអាចនឹងឃុំចីវរបានក៏ខឹងក្រោធខ្យល់ ប៉ះទង្គិចជួលក៏ខឹងក្រោធជង្គត់ឈើ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់សំដៅយកសេចក្តីក្រោធនេះ ទើបត្រាស់ថា **អដ្ឋានេ វា បន អាឃាតោ ជាយតិ** ដូច្នេះ ។ បណ្តាសេចក្តីក្រោធទាំងនោះ ការបែកធ្លាយនៃកម្មបថរមែងមាន ព្រោះគំនុំកើតឡើង ប្រារព្ធសត្វទាំងឡាយក្នុងឋានៈ ៩ ខាងដើម តែគំនុំក្នុងអដ្ឋានៈដែលកើតក្នុងសង្ខារ រមែងមិនធ្វើការទម្លាយកម្មបថ ។

ទោសៈដែលឈ្មោះថា **ចិត្តអាឃាតោ** ព្រោះអត្ថថា កើតឡើងញុំាងចិត្តឲ្យគុំកួន គំនុំដែលមានកម្លាំងជាងនោះ ឈ្មោះថា **បដិឃាតោ** ។ ដែលឈ្មោះថា **បដិឃំ** ដោយអំណាចសេចក្តីលំបាក ។ ដែលឈ្មោះថា **បដិវិ-**

**ភវោ** ព្រោះអត្ថថា ចង្អៀតចង្អល់ ។ ដែលឈ្មោះថា **កោធោ** ដោយអំណាចនៃសេចក្តីក្រោធ ។ បទថា **បកោធោ សម្បកោធោ** ទ្រង់បន្ថែមបទឧបសគ្គ ។ ដែលឈ្មោះថា **ទោសោ** ដោយអំណាចការប្រទូស្ត ។ បទថា **បទោសោ សម្បទោសោ** ទ្រង់បន្ថែមបទឧបសគ្គ ។ បទថា **ចិត្តស្ស ព្យាបត្តិ** សេចក្តីថា អាការផ្លាស់ប្តូរផ្សេងៗ ព្រោះចិត្តវិបត្តិ ។ ឈ្មោះថា **មនោបទោសោ** ព្រោះអត្ថថា កើតឡើងប្រទូស្តចិត្ត ។ ដែលឈ្មោះថា **កោធោ** ដោយអំណាចនៃការក្រោធ ។ អាការនៃការក្រោធ ឈ្មោះថា **កុជ្ឈនា** ។ ភាវៈនៃចិត្តដែលក្រោធ ឈ្មោះថា **កុជ្ឈិតត្តំ** ។

ឥឡូវនេះដើម្បីទ្រង់សម្តែងន័យដែលត្រាស់ទុកហើយក្នុងអកុសលនិទ្ទេស ទើបត្រាស់ពាក្យថា **ទោសោ ទុស្សនា** ដូច្នេះជាដើម ព្រោះហេតុនោះបណ្ឌិតគប្បីធ្វើការអធិប្បាយប្រកបក្នុងនិទ្ទេសនេះយ៉ាងនេះថា ទោសៈមានលក្ខណៈបែបនេះឯណា ដែលត្រាស់ទុកក្នុងទីនេះថា ការគុំកួននៃចិត្ត ។បេ។ ភាពនៃចិត្តខឹង និងដែលធ្លាប់ត្រាស់ទុកហើយ ដោយន័យជាដើមថា សេចក្តីប្រទូស្ត អាការប្រទូស្ត នេះហៅថា **ទោសៈ** ដ្បិតថា កាលមានពាក្យដែលពោលទុកយ៉ាងនេះ រមែងជាការដែលលោកបដិសេធនូវទោស ក្នុងការនិយាយដដែលនិទ្ទេសនៃមោហៈ គប្បីជ្រាបដោយន័យដែលជាបដិបក្ខនឹងពាក្យដែលពោលទុកហើយក្នុងនិទ្ទេសនៃអមោហៈ និទ្ទេសនៃមោហៈនេះនឹងមានជាក់ច្បាស់ក្នុងអដ្ឋកថា វិភង្គបករណ៍ ដោយអាការទាំងពួង ។

បទថា **តេហិ ធម្មេហិ យេ ធម្មា សហេតុកា** សេចក្តីថា ធម៌ទាំង

ឡាយណាដែលជាហេតុក្តី មិនជាហេតុក្តី ដទៃណា ឈ្មោះថា **សហេតុកា** ដោយធម៌ដែលជាហេតុទាំងនោះ ។ សូម្បីក្នុងបទថា **អហេតុក** ក៏មានន័យនេះដូចគ្នា ។ ក្នុងទីនេះធម៌ដែលជាហេតុ រមែងជាហេតុនោះឯង និងជាធម៌មានហេតុ ( សហេតុកៈ ) ក្នុងការកើតព្រមគ្នា ៣ ហេតុ ឬ ២ ហេតុ ។ ចំណែកមោហៈដែលសហគតដោយវិចិកិច្ឆានិងឧទ្ធច្ចៈ ជាហេតុ តែមិនមានហេតុប្រកប ។ សូម្បីក្នុងនិទ្ទេសនៃទុកៈដែលសម្បយុត្តដោយហេតុ ក៏មានន័យនេះឯង ។

# អភិធម្មបិដក

## ចូឡន្តរទុក

[ ២០១ ] ពួកធម៌ប្រកបដោយបច្ច័យ តើដូចម្ដេច ។ ខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយបច្ច័យ ។ ពួកធម៌មិនមានបច្ច័យ តើដូចម្ដេច ។ អសង្ខតធាតុ នេះពួកធម៌មិនមានបច្ច័យ ។

[ ២០២ ] ពួកធម៌មានបច្ច័យតាក់តែង តើដូចម្ដេច ។ ពួកធម៌ណាប្រកបដោយបច្ច័យ ធម៌ទាំងនោះ ជាធម៌មានបច្ច័យតាក់តែង ។ ពួកធម៌មិនមានបច្ច័យតាក់តែង តើដូចម្ដេច ។ ធម៌ណាមិនមានបច្ច័យ ធម៌នោះឯងជាធម៌មិនមានបច្ច័យតាក់តែង ។

[ ២០៣ ] ពួកធម៌ប្រកបដោយការឃើញ តើដូចម្ដេច ។ រូបាយតនៈ នេះពួកធម៌ប្រកបដោយការឃើញ ។ ពួកធម៌មិនប្រកបដោយការឃើញ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងអសង្ខតធាតុ នេះពួកធម៌មិនប្រកបដោយការឃើញ ។

[ ២០៤ ] ពួកធម៌ប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះពួកធម៌ប្រកបដោយការប៉ះពាល់ ពួកធម៌មិនប្រកបដោយការប៉ះពាល់ តើដូចម្ដេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបជាអនិទស្សនៈ ជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងអសង្ខតធាតុ

នេះ ពួកធម៌មិនប្រកបដោយការប៉ះពាល់ ។

[ ២០៥ ] ពួកធម៌មានរូប តើដូចម្តេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យនូវមហាភូតរូបទាំង ៤ នេះពួកធម៌មានរូប ។ ពួកធម៌មិនមានរូប តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធនិងអសង្ខតធាតុ នេះពួកធម៌មិនមានរូប ។

[ ២០៦ ] ពួកធម៌ជាលោកិយ តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាលោកិយ ។ ពួកធម៌ជាលោកុត្តរៈ តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលដែលកើតអំពីមគ្គផង អសង្ខតធាតុផង នេះពួកធម៌ជាលោកុត្តរៈ ។

[ ២០៧ ] ពួកធម៌គួរដឹងច្បាស់ដោយវិញ្ញាណនីមួយ មិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ តើដូចម្តេច ។ ពួកធម៌ណា ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹង

ដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយ

កាយវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយឃានវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយឃាន-វិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយជិវ្ហា-វិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោត-វិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណា ដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដាយឃានវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយជិវ្ហាវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ

ពួកធម៌នោះមិនមែនបុគ្គលដឹងដោយចក្ខុវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយចក្ខុវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយកាយ-វិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយសោតវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយសោតវិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយឃានវិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយឃាន-វិញ្ញាណ ពួកធម៌នោះ មិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ ពួកធម៌ណាដែលគប្បីដឹងដោយកាយវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយជិវ្ហា-វិញ្ញាណទេ មួយទៀត ពួកធម៌ណាដែលគប្បីដឹងដោយជិវ្ហាវិញ្ញាណ ពួកធម៌នោះមិនមែនបុគ្គលដឹងដោយកាយវិញ្ញាណទេ នេះពួកធម៌ដែលគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ មិនគួរដឹងច្បាស់ដោយវិញ្ញាណនីមួយ ។

# អដ្ឋកថា

## ចុទ្ទន្តរទុក

[ ២០១-២០៧ ] ក្នុងនិទ្ទេសសន្ទិតទុកៈ ព្រះអង្គទ្រង់ធ្វើនិទ្ទេសទុកដោយពាក្យឯកវចនៈថា **យោ ឯវ សោ ធម្មោ** ដូច្នេះ ទ្រង់សំដៅយកអសន្ទិតធាតុតាមដែលត្រាស់ទុកហើយ ក្នុងទុកៈដំបូង តែក្នុងទុកៈដំបូងនេះ ទ្រង់ធ្វើជាពហុវចនៈទុកដោយន័យបុច្ឆានុសន្ធិថា **កតមេ ធម្មា អប្បច្ចយា** ដូច្នេះ ព្រោះទ្រង់លើកឡើងសួរ ដោយអំណាចនៃពហុវចនៈ ។ សូម្បីក្នុងបទជាដើមថា **កតមេ ធម្មា សង្ខតា** ក៏ន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃកេនចិវិញ្ញេយ្យទុកៈ ដូចតទៅនេះថា

បទថា **ចក្ខុវិញ្ញេយ្យា** បានដល់ ដែលចក្ខុវិញ្ញាណគប្បីដឹងច្បាស់ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងនិទ្ទេសនេះ បទថា **កេនចិ វិញ្ញេយ្យា** គឺបណ្ដាវិញ្ញាណទាំងឡាយមានចក្ខុវិញ្ញាណជាដើម ចក្ខុវិញ្ញាណឬសោតវិញ្ញាណដូចណានីមួយគប្បីដឹងបាន ។ បទថា **កេនចិ ន វិញ្ញេយ្យា** គឺចក្ខុវិញ្ញាណ ឬសោតវិញ្ញាណនោះឯងមិនគប្បីដឹងបាន កាលបើដូច្នេះទើបមិនមានទុកៈនេះថា **យេ តេ ធម្មា ចក្ខុវិញ្ញេយ្យា ន តេ ធម្មា សោតវិញ្ញេយ្យា** ព្រោះពាក្យទាំងពីរ ខ្ញុំធ្លាប់ពោលទុកហើយថា រមែងជាពួកទុកៈបាន ព្រោះភាពផ្សេងគ្នានៃអត្ថ ។ កាលកាន់យកអត្ថនេះថា រូបដែលចក្ខុវិញ្ញាណគប្បីដឹងបាន សំឡេងដែលចក្ខុវិញ្ញាណដឹងមិនបាន ហើយគប្បីជ្រាបទុកៈមួយទុកៈនេះថា ធម៌ទាំងឡាយណាចក្ខុវិញ្ញាណដឹងបាន ធម៌ទាំងឡាយ

នោះ សោតវិញ្ញាណមិនដឹងបាន ឬធម៌ទាំងឡាយណាដែលសោតវិញ្ញាណដឹងបាន ធម៌ទាំងឡាយនោះចក្ខុវិញ្ញាណមិនដឹងបាន ។ ដោយអាការយ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា ព្រះអង្គទ្រង់ធ្វើមូលឥន្ទ្រិយនីមួយៗ ជា ៤ ទុកៈហើយ បែកចេញជា ២០ ទុកៈ ។

សួរថា ពាក្យថា ធម៌ដែលមនោវិញ្ញាណដូចខ្លះដឹងបាន ដូចខ្លះមិនដឹងបាន មិនមានឬ ព្រោះហេតុនោះ ទើបព្រះអង្គមិនបានត្រាស់ជាទុកៈទុកក្នុងទីនេះ ។ ឆ្លើយថា មិនមែនមិនមាន គឺមាននោះឯង តែព្រោះមិនមានការកំណត់ ទើបមិនបានត្រាស់ទុក ។ ពិតណាស់ ការកំណត់ថា ធម៌ដែលចក្ខុវិញ្ញាណដឹងមិនបាន មាន ដោយប្រការណា ការកំណត់ថា ធម៌ដែលមនោវិញ្ញាណដឹងមិនបាន មាន ដោយប្រការនោះ ក៏មិនមែន ព្រោះហេតុនោះ ព្រោះមិនមានការកំណត់ទើបមិនបានត្រាស់ទុកៈទុកក្នុងទីនេះ តែសេចក្តីនេះថា ធម៌ដែលមនោវិញ្ញាណដូចខ្លះ ដឹងបាន និងដូចខ្លះ ដឹងមិនបាន មាន ព្រោះហេតុនោះ សេចក្តីនោះសូម្បីមិនបានត្រាស់ទុក បណ្ឌិតក៏គប្បីជ្រាបដោយអំណាចតាមដែលរកបាន ។

មែនពិត ធម៌ គឺកាមាវចរទាំងឡាយនុ៎ះឯងដែលកាមាវចរធម៌ទាំងឡាយដែលដល់នូវការរាប់ថា មនោវិញ្ញាណដូចខ្លះ គប្បីដឹងបាន ដូចខ្លះក៏មិនគប្បីដឹងបាន សូម្បីធម៌ មានរូបាវចរជាដើមដែលកាមាវចរទាំងនោះឯង ដូចខ្លះគប្បីដឹងបាន ដូចខ្លះដឹងមិនបាន កាមាវចរទាំងឡាយដែលរូបាវចរដូចខ្លះដឹងបាន ដូចខ្លះក៏ដឹងមិនបាន រូបាវចរជាដើមដែលរូបាវចរទាំងនោះឯង ដូចខ្លះ

ដឹងបាន ដួងខ្លះដឹងមិនបាន ។

ប៉ុន្តែកាមាវចរទាំងឡាយ រូបាវចរទាំងឡាយនិងលោកុត្តរធម៌ទាំងឡាយ ដែលអរូបាវចរទាំងឡាយមិនគប្បីដឹងបាន ចំណែកអរូបាវចរទាំងឡាយដែលអរូបាវចរដួងខ្លះដឹងបាន ដួងខ្លះដឹងមិនបាន ម្យ៉ាងទៀត អរូបាវចរទាំងនោះ ដួងខ្លះប៉ុណ្ណោះដែលអរូបាវចរគប្បីដឹងបាន ដួងខ្លះមិនគប្បីដឹងបាន ។ ធម៌ទាំងឡាយ មានកាមាវចរជាដើមដែលលោកុត្តរធម៌ទាំងឡាយ ដឹងមិនបាន តែលោកុត្តរធម៌ទាំងឡាយដែលកាមាវចរជាដើម ដួងខ្លះដឹងបាន ដួងខ្លះដឹងមិនបាន ព្រោះមិនដឹងដោយនិព្វាន ។ លោកុត្តរធម៌ទាំងនោះ ដួងខ្លះនោះឯងដែលកាមាវចរជាដើម ដឹងបាន ដួងខ្លះនោះឯង ដែលកាមាវចរដឹងមិនបាន ព្រោះមិនដឹងមគ្គនិងផលទាំងឡាយ ដូច្នេះ ។

# អភិធម្មបិដក

## អាសវគោច្ឆក

[ ២០៨ ] ពួកធម៌ជាអាសវៈ តើដូចម្តេច ។ អាសវៈ ៤ យ៉ាងគឺ កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ។

[ ២០៩ ] បណ្តាអាសវៈទាំងនោះ កាមាសវៈ តើដូចម្តេច ។ សេចក្តីប្រាថ្នាក្នុងកាម តម្រេកក្នុងកាម ការរីករាយក្នុងកាម ការអន្ទះសាក្នុងកាម សេចក្តីស្រឡាញ់ក្នុងកាម ការរោលរាលក្នុងកាម ការជ្រប់នៅក្នុងកាម ការងប់ចិត្តក្នុងកាមណា ចំពោះកាមទាំងឡាយ នេះហៅថា កាមាសវៈ ។

[ ២១០ ] បណ្តាអាសវៈទាំងនោះ ភវាសវៈ តើដូចម្តេច ។ សេចក្តីប្រាថ្នាក្នុងភព តម្រេកក្នុងភព ការរីករាយក្នុងភព ការអន្ទះសាក្នុងភព សេចក្តីស្រឡាញ់ក្នុងភព ការរោលរាលក្នុងភព ការជ្រប់នៅក្នុងភព ការងប់ចិត្តក្នុងភពណា ចំពោះភពទាំងឡាយ នេះហៅថា ភវាសវៈ ។

[ ២១១ ] បណ្តាអាសវៈទាំងនោះ ទិដ្ឋាសវៈ តើដូចម្តេច ។ ការយល់ឃើញថាលោកទៀងខ្លះ ថាលោកមិនទៀងខ្លះ ថាលោកមានទីបំផុតខ្លះ ថាលោកមិនមានទីបំផុតខ្លះ ថាជីវិតនោះ គឺសរីរៈនោះខ្លះ ថាជីវិតដទៃ សរីរៈដទៃខ្លះ ថាសត្វស្លាប់ទៅកើតទៀតខ្លះ ថាសត្វស្លាប់ទៅមិនកើតទៀតខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់

ផ្លូវខុស ធម្មជាតដែលខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋាសវៈ ។ មួយទៀត មិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋាសវៈដែរ ។

[ ២១២ ] បណ្តាអាសវៈទាំងនោះ អវិជ្ជាសវៈ តើដូចម្តេច ។ ការមិនដឹងក្នុងទុក្ខ មិនដឹងក្នុងហេតុនៃទុក្ខ មិនដឹងក្នុងការរលត់ទុក្ខ មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ មិនដឹងក្នុងខន្ធជាចំណែកខាងដើម មិនដឹងក្នុងខន្ធជាចំណែកខាងចុង មិនដឹងក្នុងខន្ធជាចំណែកខាងដើមនិងខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើងព្រោះអាស្រ័យបច្ច័យនោះៗ និងការមិនដឹងការមិនឃើញ ការមិនត្រាស់ដឹង ការមិនយល់ ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក មិនចុះចិត្តស៊ប់ មិនរំពឹងមើល មិនពិចារណា អំពើមិនជាក់ច្បាស់ ការយល់បានដោយក្រ ភាពនៃចិត្តល្ងង់ ការមិនដឹងខ្លួន ការវង្វេង វង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា ( ការមិនដឹងច្បាស់ ) ជំនន់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា ការវង្វេង ជាអកុសលមូលណាដែលមានសភាពបែបនេះ នេះហៅថា អវិជ្ជាសវៈ ។

## នេះពួកធម៌ជាអាសវៈ ។

[ ២១៣ ] ពួកធម៌មិនមែនជាអាសវៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ

រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាអាសវៈ ។

[ ២១៤ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្តេច ។ ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។

[ ២១៥ ] ពួកធម៌ប្រកបដោយអាសវៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយអាសវៈ ។ ពួកធម៌ប្រាសចាកអាសវៈ តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកអាសវៈ ។

[ ២១៦ ] ពួកធម៌ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង តើដូចម្តេច ។ អាសវៈទាំងនោះឯង ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈតែមិនមែនអាសវៈ តើដូចម្តេច ។ ពួកធម៌ណាប្រព្រឹត្តទៅជាមួយនឹងអាសវៈ ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ដែលប្រព្រឹត្តទៅជាមួយនឹង

អាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូ-
បាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយ
នឹងអាសវៈ តែមិនមែនអាសវៈ ។

[ ២១៧ ] ពួកធម៌ជាអាសវៈផង ប្រកបដោយអាសវៈផង តើដូចម្តេច ។
កាមាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយអវិជ្ជាសវៈ អ-
វិជ្ជាសវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយកាមាសវៈ ភវា-
សវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយអវិជ្ជាសវៈ អវិជ្ជា-
សវៈ ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយភវាសវៈ ទិដ្ឋាសវៈ
ជាអាសវៈផង ប្រកបដោយអាសវៈផង ដោយអវិជ្ជាសវៈ អវិជ្ជាសវៈ ជា
អាសវៈផង ប្រកបដោយអាសវៈផង ដោយទិដ្ឋាសវៈ នេះពួកធម៌ជាអាសវៈ
ផង ប្រកបដោយអាសវៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែ
មិនមែនអាសវៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ វៀរ
តែធម៌ទាំងនោះចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែ
ប្រកបដោយអាសវៈ តែមិនមែនអាសវៈ ។

[ ២១៨ ] ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ
តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រព្រឹត្តទៅជា
មួយនឹងអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ

អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។

# អដ្ឋកថា

## អាសវគោច្ឆក

[ ២០៨-២១៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអាសវៈ ដូចតទៅនេះថា

រាគៈដែលប្រកបដោយបញ្ចកាមគុណ ឈ្មោះថា **កាមាសវៈ** ឆន្ទរាគៈក្នុងរូបភពនិងអរូបភព សេចក្តីប្រាថ្នាគាប់ចិត្ត ដែលប្រព្រឹត្តទៅក្នុងឈាន រាគៈសហគតដោយសស្សតទិដ្ឋិ សេចក្តីប្រាថ្នាដោយអំណាចនៃភព ឈ្មោះថា **ភវាសវោ** ទិដ្ឋិ ៦២ ឈ្មោះថា **ទិដ្ឋាសវោ** ការមិនដឹងក្នុងឋានៈ ៨ ឈ្មោះថា **អវិជ្ជាសវោ** ។

ដើម្បីមិនឲ្យវង្វេងក្នុងអាសវៈទាំងឡាយដែលត្រាស់ទុកក្នុងទីនោះៗ គប្បីជ្រាបប្រភេទនៃអាសវៈ មានអាសវៈពួកមួយជាដើម ។ ពិតណាស់ កាលពោលដោយអត្ថ អាសវៈទាំងនេះមានតែម្យ៉ាងប៉ុណ្ណោះ យ៉ាងនេះគឺ ឈ្មោះថា **អាសវៈ** ព្រោះអត្ថថា ជារបស់ត្រាំ តែក្នុងព្រះវិន័យ ត្រាស់អាសវៈ ២ យ៉ាងថា ដើម្បីរាំងអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១ ដើម្បីកម្ចាត់បង់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១ ដូច្នេះ ។ ក្នុងព្រះសូត្រក្នុងសឡាយតនវគ្គ ទ្រង់ត្រាស់អាសវៈទុក ៣ យ៉ាងថា ម្នាលអាវុសោ អាសវៈទាំងនេះមាន ៣ ប្រការ គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ដូច្នេះ ។ ក្នុងនិព្វេធិកបរិយាយសូត្រមានអាសវៈ ៥ យ៉ាង ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អាសវៈទាំងឡាយ នាំសត្វឲ្យទៅនរកក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅកាន់កំណើតតិរច្ឆានក៏មាន អាសវៈទាំងឡាយនាំសត្វ

ឲ្យទៅកាន់បិត្តិវិស័យក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅមនុស្សលោកក៏មាន អាសវៈទាំងឡាយ នាំសត្វឲ្យទៅទេវលោកក៏មាន ដូច្នេះ ។ ក្នុងឆក្កនិបាត អាហុនេយ្យសូត្រ ត្រាស់អាសវៈ ៦ យ៉ាងថា **អត្ថិ អាសវា សំវរា បហាតព្វា អត្ថិ អាសវា បដិសេវនា បហាតព្វា អត្ថិ អាសវា អធិវាសនា បហាតព្វា អត្ថិ អាសវា បរិវជ្ជនា បហាតព្វា អត្ថិ អាសវា វិនោទនា បហាតព្វា អត្ថិ អាសវា ភាវនា បហាតព្វា** អាសវៈទាំងឡាយ ដែលត្រូវលះបង់ដោយការសង្រួមក៏មាន អាសវៈទាំងឡាយដែលត្រូវលះបង់ដោយការសេពក៏មាន អាសវៈទាំងឡាយដែលត្រូវលះបង់ដោយការអត់ធន់ក៏មាន អាសវៈទាំងឡាយ ដែលត្រូវលះបង់ដោយការវៀរក៏មាន អាសវៈទាំងឡាយ ដែលត្រូវលះបង់ដោយការបន្ទោបង់ក៏មាន អាសវៈទាំងឡាយដែលត្រូវលះបង់ដោយការចម្រើនក៏មាន ដូច្នេះ ។ ក្នុងសព្វាសវបរិយាយសូត្រ ( សព្វាសវសំវរសូត្រ ) ត្រាស់អាសវៈ ៧ យ៉ាង ជាមួយនឹងទស្សនបហាតព្វធម៌ ។

តែក្នុងទីនេះ អាសវៈទាំងនោះ ត្រាស់ទុក ៤ យ៉ាង ដោយប្រភេទនៃកាមាសវៈជាដើម ។ ក្នុងអាសវៈទាំង ៤ នោះ មានវចនត្ថៈដូចតទៅនេះថា អាសវៈក្នុងកាម ពោលគឺបញ្ចកាមគុណ ឈ្មោះថា **កាមាសវៈ** ។ អាសវៈក្នុងភពទាំង ២ គឺកម្មភពនិងឧបបត្តិភព គឺរូបភពនិងអរូបភព ឈ្មោះថា **ភវាសវៈ** អាសវៈគឺទិដ្ឋិ ឈ្មោះថា **ទិដ្ឋាសវៈ** អាសវៈគឺអវិជ្ជា ឈ្មោះថា **អវិជ្ជាសវៈ** ។

បទថា **កាមេសុ** បានដល់ ក្នុងកាមគុណ ៥ ។ បទថា **កាមច្ឆន្ទោ** បានដល់ សេចក្ដីពេញចិត្ត ពោលគឺសេចក្ដីប្រាថ្នា មិនមែនសេចក្ដីពេញចិត្ត គឺការប្រាថ្នានឹងធ្វើ និងមិនមែនពេញចិត្តក្នុងធម៌ ។ តម្រេក គឺសេចក្ដីប្រាថ្នា ដោយអំណាចនៃសេចក្ដីពេញចិត្ត និងដោយអំណាចនៃតម្រេក ឈ្មោះថា **កាមរាគោ** ។ ដែលឈ្មោះថា **កាមនន្ទី** ព្រោះអត្ថថា សេចក្ដីត្រេកត្រ-អាល គឺកាមដោយអំណាចនៃសេចក្ដីប្រាថ្នា និងសេចក្ដីត្រេកត្រអាល ។ បណ្ឌិតកាលជ្រាបអត្ថនៃកាម ក្នុងបទទាំងពួងយ៉ាងនេះហើយ គប្បីជ្រាបថា ដែលឈ្មោះថា **កាមតណ្ហា** ដោយអត្ថថា ការប្រព្រឹត្តចង់បាន ដែលឈ្មោះថា **កាមសិនេហោ** ដោយអត្ថថា សេចក្ដីស្រឡាញ់ ដែលឈ្មោះថា **កាម-បរិឡាហោ** ដោយអត្ថថា ការក្ដៅក្រហាយ ដែលឈ្មោះថា **កាមមុច្ឆា** ដោយអត្ថថា ការងប់ជ្រប់ ដែលឈ្មោះថា **កាមជ្ឈោសានំ** ដោយអត្ថថា លេបហើយធ្វើឲ្យជាប់យ៉ាងមាំ ។

បទថា **អយំ វុច្ចតិ** សេចក្ដីថា អាសវៈដែលចែកដោយបទទាំង ៨ នេះ ត្រាស់ហៅឈ្មោះថា **កាមាសវៈ** ។

បទថា **ភវេសុ ភវឆន្ទោ** សេចក្ដីថា ឆន្ទៈដែលប្រព្រឹត្តទៅដោយអំណាច ការប្រាថ្នាភពនោះឯង ក្នុងរូបភពនិងអរូបភព ឈ្មោះថា **ភវឆន្ទៈ** ។ គប្បីជ្រាបបទដ៏សេសដោយន័យនេះឯង ។

ព្រះមានព្រះភាគ ត្រាស់ប្រភេទនៃទិដ្ឋិដោយអាការៈ ១០ យ៉ាង មាន **សស្សតោ លោកោ វា** ជាដើម បណ្ដាទិដ្ឋិទាំងនោះ បទថា **សស្សតោ**

**លោកោ** នេះ មានអធិប្បាយថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការនៃការប្រកាន់ថា ទៀង របស់បុគ្គលអ្នកប្រកាន់បញ្ចក្ខន្ធថាជាលោក ហើយកាន់យកថា លោកនេះទៀង បិតថេរ តាំងនៅអស់កាលជានិច្ច ។

បទថា **អសស្សតោ** សេចក្តីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការដែលប្រកាន់ការដាច់សូន្យ របស់បុគ្គលអ្នកប្រកាន់លោកនោះឯងថា រមែងដាច់សូន្យ រមែងវិនាស ។

បទថា **អន្តវា** សេចក្តីថា ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការនៃការប្រកាន់ថា លោកមានទីបំផុត ជាទិដ្ឋិរបស់បុគ្គលអ្នកបានឈាន មានបរិត្ត-កសិណជាអារម្មណ៍ ដែលចូលសមាបត្តិក្នុងកសិណ មានប្រមាណប៉ុនចង្អេរ ឬផ្តិលទឹក ហើយកាន់យករូបធម៌និងអរូបធម៌ដែលប្រព្រឹត្តទៅខាងក្នុងសមា-បត្តិថា ជាលោក និងថាមានទីបំផុត ដោយទីបំផុតនៃការកំណត់កសិណ ។ ទិដ្ឋិនោះជាសស្សតទិដ្ឋិខ្លះ ជាឧច្ឆេទទិដ្ឋិខ្លះ ។ ចំណែកទិដ្ឋិ ដែលប្រព្រឹត្តទៅដោយអាការនៃការប្រកាន់ថា លោកមិនមានទីបំផុត ជាទិដ្ឋិរបស់បុគ្គលដែលបានកសិណបរិបូណ៌ ដែលចូលសមាបត្តិក្នុងកសិណនោះ ហើយកាន់យករូបធម៌និងអរូបធម៌ដែលប្រព្រឹត្តទៅខាងក្នុងសមាបត្តិថា ជាលោក និងយល់ឃើញថា មិនមានទីបំផុតដោយទីបំផុតនៃការកំណត់កសិណ ។ ទិដ្ឋិនោះជាសស្សតទិដ្ឋិក៏បាន ជាឧច្ឆេទទិដ្ឋិក៏បាន ។

បទថា **តំ ជីវំ តំ សរីរំ** បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការនៃការកាន់យកការដាច់សូន្យថា កាលសរីរៈដាច់សូន្យ សូម្បីជីវិតក៏ដាច់សូន្យ

ព្រោះកាន់យកថា សរីរៈដែលមានការបែកធ្លាយជាធម្មតានុ៎ះឯងថា ជាជីវិត ។ ក្នុងបទទីពីរ បានដល់ ទិដ្ឋិដែលប្រព្រឹត្តទៅដោយអាការនៃការកាន់យកភាពទៀតថា កាលសរីរៈដាច់សូន្យ តែជីវិតមិនដាច់សូន្យទេ ព្រោះការប្រកាន់ថា ជីវិតជាវត្ថុដទៃអំពីសរីរៈ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទជាដើមថា **ហោតិ តថាគតោ បរំ មរណា** ដូច្នេះ សត្វឈ្មោះថា **តថាគត** ។ ទិដ្ឋិទី ១ របស់បុគ្គលដែលប្រកាន់ថា សត្វនោះកើតខាងមុខអំពីស្លាប់ ជា សស្សតទិដ្ឋិ ។ ទិដ្ឋិទី ២ របស់បុគ្គលដែលប្រកាន់ថា មិនកើត ជា ឧច្ឆេទទិដ្ឋិ ។ ទិដ្ឋិទី ៣ របស់បុគ្គលដែលប្រកាន់ថា កើតទៀតក៏មាន មិនកើតទៀតក៏មាន ជា ឯកច្ចសស្សតទិដ្ឋិ ។ ទិដ្ឋិទី ៤ របស់បុគ្គលដែលប្រកាន់ថា កើតក៏មិនមែន មិនកើតក៏មិនមែន ជា អមរាវិក្ខេបទិដ្ឋិ ( បោះពាក្យសម្តីមិនឲ្យស្លាប់ខ្លួន ) ។

បទថា **ឥមេ ធម្មា អាសវា** សេចក្តីថា សភាវធម៌ទាំងនេះ ដោយសង្ខេបកាមាសវៈនិងភវាសវៈជាធម៌តែមួយ ដោយអំណាចនៃរាគៈជាធម៌ ៣ ដោយពិស្តារជាធម៌ ៤ ឈ្មោះថា ធម៌ជាអាសវៈ ។

សួរថា ឆន្ទរាគៈ រមែងកើតឡើងក្នុងវិមានដើមកប្បព្រឹក្សនិងអាភរណៈរបស់ព្រហ្ម ជាកាមាសវៈឬទេ ឆ្លើយថា មិនមែនទេ ព្រោះហេតុអ្វី ព្រោះរាគៈដែលប្រកបដោយបញ្ចកាមគុណ លោកលះបានហើយ ក្នុងលោកនេះឯង ។

និយាយដល់ហេតុគោច្ឆកៈហើយ លោកៈឈ្មោះថាជាហេតុ ។ និយាយ

ដល់គន្ថគោច្ឆកៈហើយ លោកៈ ឈ្មោះថា អភិជ្ឈាកាយគន្ថៈ ។ និយាយដល់កិលេសគោច្ឆកៈហើយ លោកៈ ឈ្មោះថា ជាកិលេស ។

សួរថា រាគៈកើតព្រមជាមួយនឹងទិដ្ឋិ ជាកាមាសវៈឬទេ ឆ្លើយថា មិនមែនទេ ធម៌នេះ ឈ្មោះថា ទិដ្ឋិរាគៈ សេចក្តីនេះសមដូចពាក្យដែលលោកពោលទុក ( ក្នុងខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ) ថា ទានដែលបុគ្គលឲ្យហើយ ដល់បុគ្គលអ្នកត្រេកអរក្នុងទិដ្ឋិរាគៈ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើនទេ ដូច្នេះ ។

អាសវៈទាំងនេះ គួរនាំមកតាមលំដាប់កិលេសខ្លះ តាមលំដាប់នៃមគ្គខ្លះ ពោលតាមលំដាប់នៃកិលេស កាមាសវៈដែលអនាគាមិមគ្គគប្បីលះ ភវាសវៈដែលអរហត្តមគ្គគប្បីលះ ទិដ្ឋាសវៈដែលសោតាបត្តិមគ្គគប្បីលះ អវិជ្ជាសវៈដែលអរហត្តមគ្គគប្បីលះ ។ ពោលតាមលំដាប់នៃមគ្គសោតាបត្តិមគ្គលះទិដ្ឋាសវៈ អនាគាមិមគ្គលះកាមាសវៈ អរហត្តមគ្គលះភវាសវៈនិងអវិជ្ជាសវៈ ដូច្នេះ ។

# អភិធម្មបិដក

## សញ្ញោជនគោច្ឆក

[ ២១៩ ] ពួកធម៌ជាសញ្ញោជនៈ ( ធម៌ចងសត្វទុកក្នុងវដ្ដៈ ) តើដូចម្ដេច ។ សញ្ញោជនៈ ១០ ប្រការ គឺកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ មានសញ្ញោជនៈ ទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈ ភវរាគសញ្ញោជនៈ ឥស្សាសញ្ញោជនៈ មច្ឆរិយសញ្ញោជន អវិជ្ជាសញ្ញោជនៈ ១ ។

[ ២២០ ] បណ្ដាសញ្ញោជនៈទាំងនោះ កាមរាគសញ្ញោជនៈ តើដូចម្ដេច ។ សេចក្ដីប្រាថ្នាក្នុងកាម តម្រេកក្នុងកាម ការរីករាយក្នុងកាម ការអន្ទះសាក្នុងកាម សេចក្ដីស្រឡាញ់ក្នុងកាម ការរោលរាលក្នុងកាម ការជ្រប់ក្នុងកាម ការងប់ចិត្តក្នុងកាម ចំពោះកាមទាំងឡាយណា នេះហៅថា កាមរាគសញ្ញោជនៈ ។

[ ២២១ ] បណ្ដាសញ្ញោជនៈទាំងនោះ បដិឃសញ្ញោជនៈ តើដូចម្ដេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អញ គំនុំកើតឡើងថា ជនឯណោះ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អញ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនមែនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ។បេ។ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ។បេ។ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់

មិនជាទីពេញចិត្តនៃអញ ។ កំពុងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ។បេ។ នឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ មួយទៀត គំនុំកើតឡើងក្នុងហេតុមិនគួរ ការគុំកួននៃចិត្ត ការគុំកួនតប សេចក្តីថ្នាំងថ្នាក់ ការទឹងតប ការទឹងញាប់ញ័រ ការក្រោធខ្លាំង ការក្រោធញាប់ញ័រ ការប្រទូស្ត ការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចចិត្ត ការប្រទូស្តនៃចិត្ត ការក្រោធ ការទឹង ភាពនៃចិត្តទឹងសេចក្តីប្រទូស្ត អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត សេចក្តីវិនាស អាការវិនាស ភាពនៃចិត្តវិនាស ការទឹង ការទឹងតប ភាពនៃចិត្តកាច សេចក្តីទឹងការតូចចិត្តណាដែលមានសភាពបែបនេះ នេះហៅថា បដិឃសញ្ញោជនៈ ។

[ ២២២ ] បណ្តាសញ្ញោជនៈទាំងនោះ មានសញ្ញោជនៈ តើដូចម្តេច ។ សេចក្តីប្រកាន់ថា អញប្រសើរ ( ជាងគេ ) ប្រកាន់ថា អញស្មើ ( នឹងគេ ) ប្រកាន់ថា អញថោកទាប ( ជាងគេ ) និងសេចក្តីប្រកាន់ អាការប្រកាន់ ភាពនៃចិត្តប្រកាន់ ចិត្តប៉ោងឡើង ការប៉ោងឡើង អាការដូចជាទង់ ការតម្កើង ភាពនៃចិត្តប្រាថ្នាដូចដងទង់ណា ដែលមានសភាពបែបនេះ នេះហៅថា មានសញ្ញោជនៈ ។

[ ២២៣ ] បណ្តាសញ្ញោជនៈទាំងនោះ ទិដ្ឋិសញ្ញោជនៈ តើដូចម្តេច ។ ការយល់ឃើញថាលោកទៀងខ្លះ ថាលោកមិនទៀងខ្លះ ថាលោកមានទីបំផុតខ្លះ ថាលោកមិនមានទីបំផុតខ្លះ ថាជីវិតនោះ គឺសរីរៈនោះខ្លះ ថាជីវិតដទៃសរីរៈដទៃខ្លះ ថាសត្វស្លាប់ទៅកើតទៀតខ្លះ ថាសត្វស្លាប់ទៅមិនកើតទៀតខ្លះ ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានខ្លះ ថាសត្វស្លាប់

ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនខ្លះ និងទិដ្ឋិ ដំណើរ គឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតិដែលខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណាដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋិសញ្ញោជនៈ វៀរតែសីលព្វតបរាមាសសញ្ញោជនៈចេញ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ក៏ហៅថា ទិដ្ឋិសញ្ញោជនដែរ ។

[ ២២៤ ] បណ្តាសញ្ញោជនទាំងនោះ វិចិកិច្ឆាសញ្ញោជនៈ តើដូចម្តេច ។ បុគ្គលងឿងឆ្ងល់សង្ស័យចំពោះព្រះសាស្តា ងឿងឆ្ងល់សង្ស័យចំពោះព្រះធម៌ ងឿងឆ្ងល់សង្ស័យចំពោះព្រះសង្ឃ ងឿងឆ្ងល់សង្ស័យចំពោះសិក្ខា ងឿងឆ្ងល់សង្ស័យចំពោះខន្ធជាចំណែកខាងដើម ងឿងឆ្ងល់សង្ស័យចំពោះខន្ធ ជាចំណែកខាងចុង ងឿងឆ្ងល់សង្ស័យចំពោះខន្ធជាចំណែកខាងដើមនិងខាងចុង ងឿងឆ្ងល់សង្ស័យចំពោះពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងសេចក្តីងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃចិត្តងឿងឆ្ងល់ សេចក្តីយល់ឆ្វេង ការយល់ស្ទាក់ស្ទើរ ការបែកចម្លាមពីរ ការបែកផ្លូវពីរ ការសង្ស័យ ការប្រកាន់យកចំណែកច្រើន ការសាញប្រជាញ ការសាន់រ៉ាន់ចិត្ត ការប្រកាន់មិនដាច់ស្រេច ភាពនៃចិត្តរឹងរូស ការរសេមរសាមនៃចិត្តណា ដែលមានសភាពបែបនេះ នេះហៅថា វិចិកិច្ឆាសញ្ញោជនៈ ។

[ ២២៥ ] បណ្តាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាសសញ្ញោជនៈ

តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅអំពីសាសនានេះ មានទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ច្រឡំគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតដែលខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណាដែលមានសភាពបែបនេះថា សេចក្តីបរិសុទ្ធដោយសីល បរិសុទ្ធិដោយវត្ត បរិសុទ្ធិដោយសីលនិងវត្ត នេះហៅថា សី-លព្វតបរាមាសញ្ញោជនៈ ។

[ ២២៦ ] បណ្តាសញ្ញោជនៈទាំងនោះ ភវរាគសញ្ញោជនៈ តើដូចម្តេច ។ សេចក្តីប្រាថ្នាក្នុងភព តម្រេកក្នុងភព ការរីករាយក្នុងភព ការអន្ទះសាក្នុងភព សេចក្តីស្រឡាញ់ក្នុងភព ការរោលរាលក្នុងភព ការជ្រុលជ្រប់ក្នុងភព ការងប់ចិត្តក្នុងភព ក្នុងភពទាំងឡាយណា នេះហៅថា ភវរាគសញ្ញោជនៈ ។

[ ២២៧ ] បណ្តាសញ្ញោជនៈទាំងនោះ ឥស្សាសញ្ញោជនៈ តើដូចម្តេច ។ សេចក្តីប្រណែន អាការប្រណែន ភាពនៃចិត្តប្រណែន សេចក្តីឈ្នានីស អាការឈ្នានីស ភាពនៃចិត្តឈ្នានីសក្នុងលាភសក្ការៈ ការគោរព ការរាប់អាន ការសំពះ និងការបូជារបស់បុគ្គលដទៃណា នេះហៅថា ឥស្សា-សញ្ញោជនៈ ។

[ ២២៨ ] បណ្តាសញ្ញោជនៈទាំងនោះ មច្ឆរិយសញ្ញោជន តើដូចម្តេច ។ កំណាញ់ ៥ យ៉ាង គឺកំណាញ់អាវាស កំណាញ់ត្រកូល កំណាញ់លាភ កំណាញ់សេចក្តីសរសើរ កំណាញ់ធម៌និងសេចក្តីកំណាញ់ អាការកំណាញ់

ភាពនៃចិត្តកំណាញ់ ការប្រាថ្នាផ្សេងៗ ការស្និតស្នាញ ការរឹតត្បិត ភាពនៃចិត្តប្រាថ្នាប្រយោជន៍ដ៏លើសលុប ណា ដែលមានសភាពបែបនេះ នេះហៅថា មច្ឆរិយសញ្ញោជនៈ ។

[ ២២៩ ] បណ្តាសញ្ញោជនៈទាំងនោះ អវិជ្ជាសញ្ញោជនៈ តើដូចម្តេច ។ ការមិនដឹងក្នុងទុក្ខ មិនដឹងក្នុងហេតុនៃទុក្ខ មិនដឹងក្នុងការរលត់ទុក្ខ មិនដឹងក្នុងផ្លូវប្រតិបត្តិជាដំណើរដើម្បីរលត់ទុក្ខ មិនដឹងក្នុងខន្ធចំណែកខាងដើម មិនដឹងក្នុងខន្ធចំណែកខាងចុង មិនដឹងក្នុងខន្ធចំណែកខាងដើមនិងខាងចុង មិនដឹងក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងការមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនរឭកឃើញ ការមិនភ្ញាក់រឭក ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក មិនចុះចិត្តស៊ប់ មិនរំពឹងមើល មិនពិចារណា អំពើមិនជាក់ច្បាស់ ការឈ្វេងយល់បានដោយក្រ ភាពនៃបុគ្គលល្ងង់ ការមិនដឹងខ្លួន ការវង្វេង វង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា ជំនន់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា សេចក្តីវង្វេង ជាអកុសលមូលណាដែលមានសភាពបែបនេះ នេះហៅថា អវិជ្ជាសញ្ញោជនៈ ។

## នេះពួកធម៌ជាសញ្ញោជន ។

[ ២៣០ ] ពួកធម៌មិនមែនសញ្ញោជនៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ

រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែនសញ្ញោជនៈ ។

[ ២៣១ ] ពួកធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ ។ ពួកធម៌មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ ។

[ ២៣២ ] ពួកធម៌ប្រកបដោយសញ្ញោជនៈ តើដូចម្តេច ។ ពួកធម៌ណាដែលប្រកបដោយធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយសញ្ញោជនៈ ។ ពួកធម៌ប្រាសចាកសញ្ញោជនៈ តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកសញ្ញោជនៈ ។

[ ២៣៣ ] ពួកធម៌ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង តើដូចម្តេច ។ សញ្ញោជនៈទាំងនោះឯង ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង ។ ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈ តើដូចម្តេច ។ ពួកធម៌ណាជាប្រយោជន៍ដល់សញ្ញោ-ជនៈ ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេស ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែជាប្រយោជន៍

ដល់សញ្ញោជនៈ តែមិនមែនសញ្ញោជនៈ ។

[ ២៣៤ ] ពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង តើដូចម្តេច ។ កាមរាគសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយកាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយបដិឃសញ្ញោជនៈមានសញ្ញោជនៈ ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយមានសញ្ញោជនៈ ទិដ្ឋិសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយទិដ្ឋិសញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយវិចិកិច្ឆាសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈ ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយសីលព្វតបរាមាសសញ្ញោជនៈ ភវរាគសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈ

ផង ប្រកបដោយសញ្ញោជនៈផង ដោយភវរាគសញ្ញោជនៈ ឥស្សាសញ្ញោ-ជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោ-ជនៈ អវិជ្ជាសញ្ញោជនៈ ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយឥស្សាសញ្ញោជនៈ មច្ឆរិយសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយអវិជ្ជាសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ដោយមច្ឆរិយសញ្ញោជនៈ នេះពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនសញ្ញោជនៈ ។

[ ២៣៥ ] ពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោ-ជនៈ តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ។ ពួកធម៌ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកសញ្ញោជនៈ ទាំងមិនជាប្រយោជន៍ដល់សញ្ញោជនៈ ។

## អដ្ឋកថា

## សេញ្ញោជនគោច្ឆក

[ ២១៩-២៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងមានះនិទ្ទេស ក្នុងសេញ្ញោជនគោច្ឆកៈ ដូចតទៅនេះថា

បទថា **សេយ្យោ ហមស្មីតិ មានោ** បានដល់ មានះដែលកើតឡើងយ៉ាងនេះថា អញប្រសើរជាងគេ ដោយអត្ថថា ខ្ពង់ខ្ពស់ ។ បទថា **សទិសោហមស្មីតិ មានោ** បានដល់ មានះដែលកើតឡើងយ៉ាងនេះថា អញស្មើនឹងគេ ដោយអត្ថថា ស្មើៗគ្នា ។ បទថា **ហីនោហមស្មីតិ** បានដល់ មានះដែលកើតឡើង យ៉ាងនេះថា អញអន់ជាងគេ ដោយអត្ថថា អាក្រក់ជាង ។ មានះទាំង ៣ ពួកនេះ គឺមានះថាអញប្រសើរជាងគេ មានះថាស្មើនឹងគេ មានះថាអន់ជាងគេ រមែងកើតឡើងដល់ជន ៣ ពួក ដោយប្រការដូច្នេះ ។

ពិតណាស់ មានះ ៣ យ៉ាងគឺ អញប្រសើរជាងគេ ស្មើគេ អន់ជាងគេ រមែងកើតដល់ជនដែលប្រសើរជាងគេខ្លះ ដល់ជនដែលស្មើនឹងគេខ្លះ ដល់ជនដែលអន់ជាងគេខ្លះ ។

បណ្តាមានះទាំង ៣ ពួកនោះ មានះថា អញប្រសើរជាងគេរបស់បុគ្គលអ្នកប្រសើរជាងគេ ជាមានះ តាមសេចក្តីពិត មានះ ២ ក្រៅនេះ មិនមែនមានះតាមសេចក្តីពិត ។ មានះថា អញស្មើនឹងគេ របស់បុគ្គលអ្នកស្មើនឹងគេ ។បេ។ មានះថា អញអន់ជាងគេរបស់បុគ្គលអ្នកអន់ជាងគេ ជាមានះតាមសេចក្តីពិត មានះ ២ ក្រៅអំពីនេះ មិនមែនមានះតាមសេចក្តីពិត ។

ដោយពាក្យដែលពោលមកនេះ ត្រាស់ទុកយ៉ាងដូចម្តេច ត្រាស់ទុកថា មានះ ៣ រមែងកើតដល់បុគ្គលតែម្នាក់បាន ។ តែក្នុងនិទ្ទេស មានះទី ១ ក្នុងខុទ្ទកវត្ថុវិភង្គ ត្រាស់មានះមួយថា រមែងកើតឡើងបានដល់ជនទាំង ៣ ប្រភេទ ។ ដែលឈ្មោះថា **មាណោ** ដោយអំណាចការធ្វើសេចក្តីប្រកាន់ខ្លួន ។

បទថា **មញ្ញនា មញ្ញិតត្តំ** នេះ ជាការចង្អុលបង្ហាញដល់អាការនិងភាវៈ ។ ដែលឈ្មោះថា **ឧន្នតិ** ដោយអត្ថថា តម្កើងខ្លួន ។ ដែលឈ្មោះថា **ឧន្នមោ** ព្រោះអត្ថថា មានះរមែងញ៉ាំងបុគ្គលដែលកើតមានះឲ្យប៉ោង គឺលើកឲ្យតាំងឡើង ។ ដែលឈ្មោះថា **ធជោ** ដោយអត្ថថា លើកឡើងហើយ ។ ដែលឈ្មោះថា **សម្បគ្គាហោ** ព្រោះអត្ថថា រមែងផ្គងចិត្ត ដោយអត្ថថា ការលើកឡើង ។ បណ្តាទង់ទាំងឡាយច្រើន ទង់ដែលលើកឡើងខ្ពស់ជាងគេហៅថា **កេតុ** ។ ពិតណាស់ មានះកាលកើតរឿយៗអាស្រ័យមានះតៗមក ក៏ដូចជាទង់ ព្រោះអត្ថថា លើកឡើងខ្ពស់ក្រៃលែង ព្រោះហេតុនោះ ទើបហៅថា ដូចទង់ ។ ចិត្តណារមែងត្រូវការមានះដូចទង់ ព្រោះហេតុនោះ ចិត្តនោះទើបឈ្មោះថា **កេតុកម្យ** ។ ភាវៈនៃកេតុកម្យៈនោះ ឈ្មោះថា **កេតុ-កម្យតា** ។ សេចក្តីត្រូវការដូចជាទង់នោះជារបស់ចិត្ត មិនមែនជារបស់អត្តា ដោយហេតុនោះ ទើបត្រាស់ថា **កេតុកម្យតា ចិត្តស្ស** អធិប្បាយថា ចិត្តសម្បយុត្តដោយមានះ រមែងប្រាថ្នាដូចទង់ និងភាវៈនៃចិត្តនោះ ឈ្មោះថា **កេតុកម្យតា** គឺមានះដែលរាប់ថាដូចជាទង់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឥស្សានិទ្ទេស ដូចតទៅនេះថា

បទថា **យា បរលាភសក្ការគរុការមាននវន្ទនបូជាសុ ឥស្សា** សេចក្ដីថា ការប្រណែនណា ដែលមានលក្ខណៈជ្រួលច្របាលក្នុងចិត្ត ក្នុងសម្បត្តិរបស់អ្នកដទៃ ក្នុងវត្ថុទាំងឡាយមានលាភជាដើម របស់ពួកជនដទៃ បញ្ជាក់ថា លាភជាដើមនេះនឹងមានប្រយោជន៍អ្វីដល់ពួកបុគ្គលនេះ ។

ក្នុងលាភជាដើមនោះ បទថា **លាភោ** បានដល់ ការបានចំពោះបច្ច័យ ៤ មានចីវរជាដើម ។ មែនពិត បុគ្គលអ្នកប្រណែន រមែងមិនពេញចិត្តនឹងលាភនោះរបស់បុគ្គលដទៃ រមែងមិនប្រាថ្នាថា ប្រយោជន៍អ្វីដោយលាភនេះដល់បុគ្គលនេះ ដូច្នេះ ។

បទថា **សក្ការោ** បានដល់ ការបានចំពោះបច្ច័យទាំងនោះឯងដ៏ល្អដែលបុគ្គលធ្វើយ៉ាងល្អហើយ ។ បទថា **គរុការោ** បានដល់ កិរិយាដែលសរសើរគឺការធ្វើឲ្យជាភារៈ ។ បទថា **មាននំ** បានដល់ ការធ្វើឲ្យជាទីស្រឡាញ់ដោយចិត្ត ។ បទថា **វន្ទនំ** បានដល់ ការថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ បទថា **បូជនា** បានដល់ ការបូជាដោយគ្រឿងក្រអូបនិងផ្កាកម្រងជាដើម ។ ដែលឈ្មោះថា **ឥស្សា** ដោយអំណាចកិរិយាដែលប្រណែន ។ អាការនៃការប្រណែន ឈ្មោះថា **ឥស្សាយនា** ភាវៈដែលប្រណែន ឈ្មោះថា **ឥស្សាយិតត្តំ** ។ បទថា **ឧស្សូយា** ជាដើម ជាវេវចនៈរបស់ពាក្យថា ឥស្សានោះឯង ។ បណ្ឌិតគប្បីជ្រាបលក្ខណៈនៃការប្រណែននេះ ដោយបុគ្គលអ្នកគ្រប់គ្រងផ្ទះខ្លះ អ្នកមិនគ្រប់គ្រងផ្ទះខ្លះ ។

មែនពិត យរាវាសពួកខ្លះ អាស្រ័យការព្យាយាមនៃបុរសរបស់ខ្លួន

ដោយអាជីពយ៉ាងណានីមួយក្នុងការងារទាំងឡាយ មានការធ្វើស្រែនិងលក់ដូរជាដើម រមែងបានយានពាហនៈ ឬរតនៈដ៏ល្អ ម្នាក់ទៀត មានសេចក្ដីប្រាថ្នាឲ្យបុគ្គលនោះ វិនាសចាកលាភ មិនត្រេកអរដោយការបានលាភនោះ គិតតែថា កាលណាហ្ន៎ ម្នាក់នេះនឹងវិនាសចាកសម្បត្តិនេះ ជាមនុស្សក្រីក្រគ្រាប់ទៅ កាលបុគ្គលនោះវិនាសចាកសម្បត្តិនោះ ដោយហេតុណានីមួយក៏ត្រេកអរ ។

ចំណែកបព្វជិតមួយរូប មានចិត្តប្រណែន ឃើញបព្វជិតអង្គដទៃ មានលាភជាដើម ដែលកើតឡើងព្រោះអាស្រ័យសុត្តបរិយត្តិ ជាដើម របស់ខ្លួនក៏គិតថា កាលណាហ្ន៎ លោកអង្គនេះ នឹងសាបសូន្យចាកលាភទាំងនេះ ជាដើម កាលណាឃើញភិក្ខុអង្គនោះវិនាសដោយហេតុណានីមួយ កាលនោះក៏មានចិត្តរីករាយ បណ្ឌិតគប្បីជ្រាបថា ការប្រណែន មានការមិនពេញចិត្តនឹងសម្បត្តិរបស់បុគ្គលដទៃជាលក្ខណៈ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមច្ឆរិយនិទ្ទេស ដូចតទៅនេះថា

ដើម្បីទ្រង់សម្ដែងមច្ឆរិយៈដោយវត្ថុ ទើបត្រាស់ពាក្យថា **បញ្ច មច្ឆរិយានិ អាវាសមច្ឆរិយំ** ដូច្នេះជាដើម ។ ក្នុងមច្ឆរិយៈទាំងនោះ កំណាញ់ក្នុងអាវាស ឈ្មោះថា **អាវាសមច្ឆរិយំ** ។ សូម្បីបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ អារាមទាំងមូលក្ដី បរិវេណអារាមក្ដី បន្ទប់តូច ១ ក្ដី ទីសម្រាកក្នុងវេលាយប់ជាដើមក្ដី ឈ្មោះថា **អាវាស** ។ ពួកភិក្ខុដែលនៅក្នុងអាវាសនោះរមែងនៅសប្បាយ រមែងបានបច្ច័យទាំងឡាយ ។ ភិក្ខុមួយ

រូប មិនប្រាថ្នាឲ្យភិក្ខុដែលដល់ព្រមដោយវត្ត ដែលមានសីលជាទីស្រឡាញ់ មកនៅក្នុងទីនោះ គិតថា ភិក្ខុនេះមកហើយចូរទៅដោយរហ័សចុះ នេះឈ្មោះថា **អាវាសមច្ឆរិយំ** តែមិនឈ្មោះថា អាវាសមច្ឆរិយៈ ដល់ភិក្ខុដែលមិនប្រាថ្នាការនៅក្នុងទីនោះ របស់ពួកអ្នកបង្កជម្លោះជាដើម ។

ត្រកូលឧបដ្ឋាកក្តី ត្រកូលញាតិក្តី ឈ្មោះថា ត្រកូល រមែងឈ្មោះថា **កុលមច្ឆរិយំ** ដល់ភិក្ខុដែលមិនប្រាថ្នាឲ្យភិក្ខុដទៃចូលទៅកាន់ត្រកូលនោះ ។ តែមិនឈ្មោះថា មច្ឆរិយៈ ដល់ភិក្ខុដែលមិនប្រាថ្នាឲ្យបុគ្គលបាបចូលទៅក្នុងត្រកូលនោះ ព្រោះថា បុគ្គលបាបនោះរមែងបដិបត្តិដើម្បីទម្លាយសេចក្តីជ្រះថ្លារបស់ត្រកូលទាំងនោះ ។ តែឈ្មោះថា មច្ឆរិយៈ ដល់ភិក្ខុដែលមិនប្រាថ្នាការចូលទៅក្នុងត្រកូលនោះនៃភិក្ខុដែលអាចរក្សាសេចក្តីជ្រះថ្លាទុកបាន ។

ការបានបច្ច័យ ៤ នោះឯង ឈ្មោះថា លាភ កាលភិក្ខុអ្នកមានសីលរូបដទៃបាននូវបច្ច័យ ៤ នោះឯង រមែងជាលាភមច្ឆរិយ ដល់ភិក្ខុដែលគិតថា សូមកុំបាន តែភិក្ខុណាញុំាងសទ្ធាទេយ្យឲ្យធ្លាក់ទៅ រមែងធ្វើឲ្យវិនាសដោយអំណាចនៃការមិនបរិភោគ ឬបរិភោគមិនល្អជាដើម មិនឲ្យវត្ថុសូម្បីជាជូរផ្អូមដល់ភិក្ខុដទៃ មិនឈ្មោះថាមច្ឆរិយៈដល់ភិក្ខុដែលឃើញភិក្ខុនោះ ហើយគិតថា បើភិក្ខុរូបនេះមិនបានបច្ច័យនេះ ភិក្ខុដទៃដែលមានសីលគប្បីបានគប្បីបរិភោគ ។

សរីរវណ្ណៈ ( ពណ៌សម្បុរនៃសរីរៈ ) ក្តី គុណវណ្ណៈ ( ការសរសើរគុណ ) ក្តី ឈ្មោះថា **វណ្ណៈ** ក្នុងវណ្ណៈទាំង ២ នោះ បុគ្គលដែលកំណាញ់សរីរវណ្ណៈ កាលមានមនុស្សនិយាយថា បុគ្គលដទៃគួរជ្រះថ្លា មានរូបស្អាត

ដូច្នេះ មិនប្រាថ្នានឹងពោលដល់បុគ្គលនោះ ។ បុគ្គលដែលកំណាញ់គុណវណ្ណៈ រមែងមិនប្រាថ្នានឹងពោលសរសើរគុណ របស់អ្នកដទៃដោយសីល ដោយធុតង្គ ដោយបដិបទា ដោយអាចារៈ ។

បរិយត្តិធម៌និងបដិវេធធម៌ ឈ្មោះថា ធម៌ ។ ក្នុងធម៌ទាំង ២ នោះ ព្រះអរិយសាវកទាំងឡាយ រមែងមិនកំណាញ់បដិវេធធម៌ រមែងប្រាថ្នាការចាក់ធ្លុះដល់លោក ព្រមទាំងទេវលោក ក្នុងធម៌ដែលខ្លួនបានចាក់ធ្លុះហើយ ម្យ៉ាងទៀត រមែងប្រាថ្នាការចាក់ធ្លុះធម៌ទាំងនោះថា សូមសត្វពួកដទៃដឹង ឈ្មោះថា **ធម្មមច្ឆរិយៈ** រមែងមានក្នុងតន្តិធម៌ ( ធម៌និងវិន័យ ) នោះឯង បុគ្គលអ្នកប្រកបដោយការកំណាញ់ធម៌នោះ ចេះគម្ពីរដែលមានអាថ៌កំបាំងឬកថាមគ្គឯណា មិនប្រាថ្នានឹងឲ្យជនដទៃចេះគម្ពីរឬកថាមគ្គនោះ តែបុគ្គលណាពិចារណាដល់បុគ្គលហើយរមែងមិនឲ្យ ព្រោះការអនុគ្រោះធម៌ ឬពិចារណាធម៌ហើយរមែងមិនឲ្យ ព្រោះអនុគ្រោះបុគ្គល បុគ្គលនេះមិនឈ្មោះថា កំណាញ់ធម៌ទេ ។

ក្នុងសេចក្ដីនេះ បុគ្គលខ្លះ ជាជនឡេះឡោះ គ្រាខ្លះជាសមណៈ គ្រាខ្លះជាព្រាហ្មណ៍ គ្រាខ្លះជានិគ្រន្ថ ភិក្ខុណាមិនឲ្យ ដោយគិតថា បុគ្គលនេះនឹងទម្លាយតន្តិធម៌ដ៏ល្អិតសុខុម ជាធម៌ដ៏ក្រៃលែង ជាប្រពៃណីបន្តគ្នាមក ឲ្យប្របូកប្របល់ ភិក្ខុនេះពិចារណាដល់បុគ្គលហើយ ឈ្មោះថា រមែងមិនឲ្យព្រោះការអនុគ្រោះធម៌ ចំណែកភិក្ខុណា រមែងមិនឲ្យ ដោយគិតថា ធម៌នេះល្អិតសុខុម បើបុគ្គលនេះនឹងរៀនយក នឹងព្យាករអរហត្តផល នឹងសម្ដែងខ្លួន

ឲ្យដល់នូវសេចក្តីវិនាស ភិក្ខុនេះពិចារណាធម៌ហើយ ឈ្មោះថា រមែងមិនឲ្យដោយការអនុគ្រោះបុគ្គល តែបុគ្គលណា មិនឲ្យដោយគិតថា បើបុគ្គលនេះរៀនធម៌នេះ នឹងអាចទម្លាយលទ្ធិសម័យរបស់ពួកយើង ដូច្នេះ បុគ្គលនេះឈ្មោះថា ជាអ្នកកំណាញ់ធម៌ ។

បណ្តាមច្ឆរិយៈទាំង ៥ នេះ ពោលអំពីអាវាសមច្ឆរិយៈជាមុន ភិក្ខុកើតជាយក្ខ ឬជាប្រេត ហើយយកក្បាលទូលសំរាមរបស់អាវាសនោះឯង ត្រាច់ទៅ ។ ពោលអំពីកុលមច្ឆរិយៈ កាលត្រកូលនោះធ្វើទាន និងរាប់អានជាដើមចំពោះបុគ្គលដទៃ កាលបុគ្គលនោះឃើញ ក៏គិតថា ត្រកូលនេះរបស់យើងបែកហើយហ្ន៎ ឈាមនឹងខ្ទុះចេញអំពីមាត់ មានការចុះឈាមខ្លះ ពោះវៀនធំទាំងឡាយ ក៏នឹងដាច់ជាកំណាត់តូចកំណាត់ធំចេញមកខ្លះ ។ ពោលដោយលាភមច្ឆរិយៈ កំណាញ់ក្នុងលាភដែលជារបស់សង្ឃឬគណៈ ឬបុគ្គលបរិភោគដូចជាគ្រឿងប្រើប្រាស់របស់បុគ្គល រមែងកើតជាយក្ស ឬប្រេត ឬពស់ថ្លាន់ធំ ។ ពោលអំពីសរីរវណ្ណគុណវណ្ណមច្ឆរិយៈ និងបរិយត្តិធម្មមច្ឆរិយៈ ភិក្ខុ រមែងសរសើរវណ្ណៈរបស់ខ្លួន មិនសរសើរវណ្ណៈរបស់អ្នកដទៃ កាលនឹងពោលទោសដោយពាក្យថា នេះវណ្ណៈអ្វី ដូច្នេះ នឹងជាបុគ្គលមានពណ៌សម្បុរអាប់អន់ កាលមិនឲ្យបរិយត្តិធម៌ណាមួយ ដល់បុគ្គលណាមួយ នឹងជាបុគ្គលល្ងង់ខ្លៅ ។

ម្យ៉ាងទៀត ព្រោះការកំណាញ់អាវាស បុគ្គលត្រូវភ្លើងឆេះក្នុងខ្ទះដែក ។ ព្រោះសេចក្តីកំណាញ់ត្រកូល នឹងជាអ្នកមានលាភតិច ។ ព្រោះសេចក្តីកំ-

ណាញ់លាភ នឹងកើតក្នុងគូថនរក ។ ព្រោះការកំណាញ់វណ្ណៈ បុគ្គលកាល កើតគ្រប់ៗភព នឹងមិនមានពណ៌សម្បុរល្អ ។ ព្រោះសេចក្តីកំណាញ់ធម៌នឹង កើតក្នុងកុក្កុឡនរក ។

ដែលឈ្មោះថា **មច្ឆេរំ** ដោយអំណាចឃើញតែខ្លួន អាការនៃសេចក្តី កំណាញ់ ឈ្មោះថា **មច្ឆរាយនា** ។ ភាវៈនៃចិត្តដែលដល់ព្រមដោយសេចក្តី កំណាញ់ ត្រូវសេចក្តីកំណាញ់ឲ្យប្រព្រឹត្តទៅហើយ ឈ្មោះថា **មច្ឆរាយិតត្តំ** ។ បុគ្គលដែលឈ្មោះថា **វិវិច្ឆោ** ព្រោះអត្ថថា មិនប្រាថ្នាសម្បត្តិទាំងអស់របស់ ខ្លួនឲ្យវិនាសទៅដោយគិតថា សូមសម្បត្តិទាំងពួង ចូរមានដល់យើងប៉ុណ្ណោះ ចូរកុំមានដល់ជនដទៃ ដូច្នេះ ។ ភាវៈនៃបុគ្គលអ្នកប្រាថ្នាផ្សេងៗ ឈ្មោះថា **វេវិច្ឆំ** ។ បទថា **វេវិច្ឆំ** នេះ ជាឈ្មោះនៃសេចក្តីកំណាញ់ដ៏ទន់ ។

បុគ្គលដែលមិនអើពើ ហៅថា **កទរិយោ** ។ ភាវៈនៃបុគ្គលអ្នកឃើញ តែខ្លួននោះ ហៅថា **កទរិយំ** ។ បទថា **កទរិយំ** នេះ ជាឈ្មោះនៃសេចក្តី កំណាញ់ដ៏ស្វិត ព្រោះបុគ្គលអ្នកប្រកបដោយសេចក្តីកំណាញ់នោះ រមែង ហាមបុគ្គលដទៃ អ្នកឲ្យដល់បុគ្គលដទៃ សេចក្តីនេះសមដូចព្រះបាលីដែល ត្រាស់ទុកក្នុងសំយុត្តនិកាយសគាថវគ្គថា

**កទរិយោ ចាបសង្កប្បោ មិច្ឆាទិដ្ឋិ អនាទរោ**
**ទទមានំ និវារេតិ យាចមានាន ភោជនំ ។**

( បុរសទ័លក្រ ) មានតែសេចក្តីកំណាញ់ និងសេចក្តីស្មូរ-
កន្ទ្រឹស មានតម្រិះអាក្រក់ យល់ខុស មិនអើពើ ហាមឃាត់

ជនដែលកំពុងឲ្យនូវភោជនដល់ពួកស្មូម ។

បុគ្គលណាឃើញយាចកទាំងឡាយ ហើយបញ្ឈប់នូវចិត្ត គឺធ្វើចិត្តឲ្យរួញដោយសេចក្តីកំណាញ់ បុគ្គលនោះ ឈ្មោះថា **កដុកញ្ចុកោ** ( ការរឹតត្បិត ) ។ ភាវៈនៃអ្នករឹតត្បិតនោះ ឈ្មោះថា **កដុកញ្ចុកតា** ។ ន័យម្យ៉ាងទៀត បុគ្គលអ្នកមានវែកក្នុងដៃ ហៅថា **កដុកញ្ចុកតា** បុគ្គលកាលដួសបាយអំពីឆ្នាំង ដែលពេញស្មើនឹងកណ្តាប់មាត់ឆ្នាំង រមែងដួសដោយចុងវែកដែលតូចគ្រប់ចំណែក ក៏មិនអាចដើម្បីដួសឲ្យពេញយ៉ាងណា ចិត្តរបស់បុគ្គលកំណាញ់ក៏យ៉ាងនោះដែរ រមែងចង្អៀតចង្អល់ កាលចិត្តចង្អៀតចង្អល់ សូម្បីកាយក៏ចង្អៀតចង្អល់ដូចគ្នា គឺរាថយ រមែងមិនហុចឲ្យ ដើម្បីពួកជនដទៃ ព្រោះហេតុនោះ សេចក្តីកំណាញ់ ហៅថា **កដុកញ្ចុកតា** ។

បទថា **អគ្គហិតត្តំ ចិត្តស្ស** បានដល់ ការដែលចិត្តប្រកាន់ទុកដោយប្រការដែលមិនលាចេញទៅដោយអាការ មានការឲ្យទានជាដើម ក្នុងការធ្វើឧបការៈដល់ជនពួកដទៃ ។ ព្រោះបុគ្គលកំណាញ់ មិនប្រាថ្នានឹងឲ្យវត្ថុដែលមាននៅរបស់ខ្លួន ដល់ជនពួកដទៃ ចង់តែទទួលរបស់ជនដទៃ ហេតុនោះ បណ្ឌិតគប្បីជ្រាបសេចក្តីកំណាញ់នោះ មានការលាក់លៀមសម្បត្តិរបស់ខ្លួនជាលក្ខណៈ ឬសេចក្តីកំណាញ់នោះ មានការកាន់យកសម្បត្តិរបស់អ្នកដទៃជាលក្ខណៈដោយអំណាចនៃការប្រព្រឹត្តទៅថា សេចក្តីអស្ចារ្យនេះ ចូរមានដល់យើងតែម្នាក់ប៉ុណ្ណោះ កុំមានដល់អ្នកដទៃឡើយ ដូច្នេះ ។ ពាក្យដ៏សេសក្នុងគោច្ឆកៈនេះ មានសេចក្តីងាយយល់ហើយ ។

ឥឡូវនេះសំយោជនៈទាំងនេះ គួរនាំមកសម្តែងដោយលំដាប់កិលេសខ្លះ ដោយលំដាប់មគ្គខ្លះ ។ ពោលដោយលំដាប់កិលេស កាមរាគសំយោជនៈ និងបដិឃសំយោជនៈដែលអនាគាមិមគ្គរមែងប្រហារ មានសំយោជនៈដែលអរហត្តមគ្គរមែងប្រហារ ទិដ្ឋិសំយោជនៈ វិចិកិច្ឆាសំយោជនៈនិងសីលព្វតបរាមាសសំយោជនៈ ដែលសោតាបត្តិមគ្គរមែងប្រហារ ភវរាគសំយោជនៈដែលអរហត្តមគ្គ រមែងប្រហារ ឥស្សាសំយោជនៈនិងមច្ឆរិយសំយោជនៈដែលសោតាបត្តិមគ្គរមែងប្រហារ អវិជ្ជាសំយោជនៈដែលអរហត្តមគ្គ រមែងប្រហារ ។ ពោលតាមលំដាប់នៃមគ្គ សោតាបត្តិមគ្គរមែងប្រហារទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស ឥស្សា និងមច្ឆរិយៈ ។ អនាគាមិមគ្គរមែងប្រហារកាមរាគៈនិងបដិឃៈ ។ អរហត្តមគ្គ រមែងប្រហារមានះ ភវរាគៈនិងអវិជ្ជាដូច្នេះ ។

# អភិធម្មបិដក

## គន្ថគោច្ឆក

[ ២៣៦ ] ពួកធម៌ជាគន្ថៈ ( ធម៌ដោតក្រងសត្វទុកក្នុងវដ្តៈ ) តើដូច ម្ដេច ។ គន្ថៈ ៤ គឺអភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ ។

[ ២៣៧ ] បណ្ដាគន្ថៈទាំងនោះ អភិជ្ឈាកាយគន្ថៈ តើដូចម្ដេច ។ តម្រេក ការត្រេកអរខ្លាំង ការជាប់ចំពាក់ក្នុងអារម្មណ៍ ការស្រើបស្រាល ការរីករាយ ការរីករាយខ្លាំង តម្រេកខ្លាំងនៃចិត្ត សេចក្ដីប្រាថ្នា ការជ្រុលជ្រប់ ការនុលនប់ ការពាក់ព័ន្ធ ការរួបរឹត ការជាប់ចំពាក់ ការលិចចុះ ធម្មជាតិនាំសត្វឲ្យកើតក្នុងភព មាយា ធម្មជាតិបង្កើតសត្វ ការញុំាងសត្វ ឲ្យប្រកបដោយទុក្ខ ធម្មជាតិចាក់ស្រេះសត្វ បណ្ដាញ ការបង្ហូរទៅ ការផ្សាយទៅកាន់អារម្មណ៍ ចំណងចងសត្វទុក ការផ្សាយទៅក្នុងអារម្មណ៍ ធម្មជាតិញុំាងសត្វឲ្យបម្រើន ធម្មជាតិជាគម្រប់ពីរ ការតាំងចិត្តទុក ធម្មជាតិនាំសត្វទៅកាន់ភព ធម្មជាតិដូចជាព្រៃ ដូចជាព្រៃញាតស្បាត ការមូលមិត្ត សេចក្ដីស្រឡាញ់ ការអាឡោះអាល័យ ផៅពង្សតទៅ សេចក្ដីប៉ុនប៉ង អាការប៉ុនប៉ង ភាពនៃចិត្តប៉ុនប៉ង ការប៉ុនប៉ងរូប ប៉ុនប៉ងសំឡេង ប៉ុនប៉ងក្លិន ប៉ុនប៉ងរស ប៉ុនប៉ងផ្សព្វ ប៉ុនប៉ងលាភ ប៉ុនប៉ងទ្រព្យ ប៉ុនប៉ងបុត្ត ប៉ុនប៉ងជីវិត ធម្មជាតិធ្ងន់ធ្ងរ ... ធ្ងន់ធ្ងរជ្រុលពេក ធ្ងន់ធ្ងរខ្លាំង សេចក្ដីធ្ងន់ធ្ងរ អាការធ្ងន់ធ្ងរ ភាពនៃចិត្តធ្ងន់ធ្ងរ ការរុលត្បុល ការប្រព្រឹត្តរុលត្បុល ភាពនៃចិត្តរុលត្បុល ការញាប់ញ័រ ការចង់ឲ្យសម្រេច ប្រយោជន៍ ការត្រេកអរខុសគន្លងធម៌ ការលោភហួសកំណត់

ការត្រេកត្រអាល ការចង់បានមិនឈប់ សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាព្រម ការប្រាថ្នាក្នុងកាម ប្រាថ្នាក្នុងភព ប្រាថ្នាប្រាសចាកភព ប្រាថ្នាក្នុងរូបភព ប្រាថ្នាក្នុងអរូបភព ប្រាថ្នាក្នុងនិរោធ ប្រាថ្នារូប ប្រាថ្នាសំឡេង ប្រាថ្នាក្លិន ប្រាថ្នារស ប្រាថ្នាផ្សព្វ ប្រាថ្នាធម៌ កិលេសដូចជំនន់ គ្រឿងប្រកប គ្រឿងចងក្រង គ្រឿងប្រកាន់មាំ គ្រឿងរារាំងទូទៅ គ្រឿងរារាំងមិនសល់ គ្រឿងបិទបាំង គ្រឿងចង គ្រឿងចូលទៅជិតសៅហ្មង គ្រឿងដេកត្រាំ គ្រឿងស្កាត់ដំណើរ តណ្ហាដូចជាវល្លិ ការប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ហេតុជាដែនកើតនៃទុក្ខ អន្ទាក់នៃមារ ទុយនៃមារ អារម្មណ៍នៃមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ខ្នោះគឺតណ្ហា សមុទ្រគឺតណ្ហា ការសម្លឹងរំពៃ សេចក្តីជាប់ចំពាក់ ជាអកុសលមូល នេះហៅថា អភិជ្ឈាកាយគន្ថៈ ។

[ ២៣៨ ] បណ្តាគន្ថៈទាំងនោះ ព្យាបាទកាយគន្ថៈ តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះនឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ។បេ។ ជនឯណោះកំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ។បេ។ ជនឯណោះនឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជា

ទីស្រឡាញ់ មិនជាទីពេញចិត្តនៃអញ ។បេ។ ជនឯណោះ កំពុងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ។បេ។ ជនឯណោះ នឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ឬក៏គំនុំកើតឡើងក្នុងហេតុមិនគួរ នឹងការគុំកួននៃចិត្ត ការគុំកួនតប សេចក្តីថ្នាំងថ្នាក់ ការខឹងតប ការខឹងញ័រ ការក្រោធខ្លាំង ការក្រោធញ័រ ការប្រទូស្តការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចចិត្ត ការប្រទូស្តនៃចិត្ត ការក្រេវក្រោធ ការខឹង ភាពនៃចិត្តខឹង សេចក្តីប្រទូស្ត អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃចិត្តព្យាបាទ ការខឹង ការខឹងតប ភាពនៃចិត្តកាច ការខឹង ការតូចចិត្តណា ដែលមានសភាពបែបនេះ នេះហៅថា ព្យាបាទកាយគន្ថៈ ។

[ ២៣៩ ] បណ្តាគន្ថៈទាំងនោះ សីលព្វតបរាមាសកាយគន្ថៈ តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ខាងក្រៅសាសនានេះប្រកាន់ថា សេចក្តីបរិសុទ្ធដោយសីល បរិសុទ្ធិដោយវត្ត បរិសុទ្ធិដោយសីលនិងវត្ត ទាំងទិដ្ឋិដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ច្រងគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ធម្មជាតិដែលខុស លទ្ធិដូចជាកំពង់សេចក្តី ប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតបរាមាសកាយគន្ថៈ ។

[ ២៤០ ] បណ្តាគន្ថៈទាំងនោះ ឥទំសច្ចាភិនិវេសកាយគន្ថៈ តើដូចម្តេច ។ ការប្រកាន់ថា លោកទៀង ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថា

លោកមិនទៀង ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាលោកមានទីបំផុត ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាលោកមិនមានទីបំផុត ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាជីវិតនោះគឺសរីរៈនោះ ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាជីវិតដទៃ សរីរៈដទៃ ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាសត្វស្លាប់ទៅកើតទៀត ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាសត្វស្លាប់ទៅមិនកើតទៀត ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាសត្វស្លាប់ទៅកើតទៀត ក៏មាន មិនកើតទៀតក៏មាន ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការយល់នេះពិត ការយល់ដទៃជាមោឃៈក្តី និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការទាក់ទិនគឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ឥទំសច្ចាភិនិវេសកាយគន្ថៈ មួយទៀត មិច្ឆាទិដ្ឋិទាំងអស់ក៏ហៅថា ឥទំសច្ចាភិនិវេសកាយគន្ថៈដែរ ។ វៀរតែសីលព្វតបរាមាសកាយគន្ថៈចេញ ។

## នេះពួកធម៌ជាគន្ថៈ ។

[ ២៤១ ] ពួកធម៌មិនមែនគន្ថៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបា-

វចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនគន្ថៈ ។

[ ២៨២ ] ពួកធម៌ដែលគន្ថៈគប្បីដោតក្រង តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដែលគន្ថៈគប្បីដោតក្រង ។ ពួកធម៌ដែលគន្ថៈមិនគប្បីដោតក្រង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ដែលគន្ថៈមិនគប្បីដោតក្រង ។

[ ២៨៣ ] ពួកធម៌ប្រកបដោយគន្ថៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយគន្ថៈ ។ ពួកធម៌ប្រាសចាកគន្ថៈ តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកគន្ថៈ ។

[ ២៨៤ ] ពួកធម៌ជាគន្ថៈផង ដែលគន្ថៈគប្បីដោតក្រងផង តើដូចម្តេច ។ គន្ថៈទាំងនោះឯង ជាគន្ថៈផង ដែលគន្ថៈគប្បីដោតក្រងផង ។ ពួកធម៌ដែលគន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈ តើដូចម្តេច ។ ពួកធម៌ណា ដែលគន្ថៈគប្បីដោតក្រងដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេស

សល់ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដែលគន្ថៈគប្បីដោតក្រង តែមិនមែនគន្ថៈ ។

[ ២៨៥ ] ពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈផង តើដូចម្ដេច ។ សីលព្វតបរាមាសកាយគន្ថៈ ជាគន្ថៈផង ប្រកបដោយគន្ថៈផង ដោយអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈជាគន្ថៈផង ប្រកបដោយគន្ថៈផង ដោយសីលព្វតបរាមាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈជាគន្ថៈផង ប្រកបដោយគន្ថៈផង ដោយអភិជ្ឈាកាយគន្ថៈ អភិជ្ឈាកាយគន្ថៈជាគន្ថៈផង ប្រកបដោយគន្ថៈផង ដោយឥទំសច្ចាភិនិវេសកាយគន្ថៈ នេះពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនគន្ថៈ តើដូចម្ដេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនគន្ថៈ ។

[ ២៨៦ ] ពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង តើដូចម្ដេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង ។ ពួកធម៌

ប្រាសចាកគន្ថៈ តែគន្ថៈមិនគប្បីជោតក្រង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈមិនគប្បីជោតក្រង ។

[ ២៤៧ ] ពួកធម៌ជាឱឃៈ ( ធម៌ញុំាងសត្វឲ្យលង់ក្នុងវដ្តៈ ) តើដូចម្តេច ។បេ។ ពួកធម៌ជាយោគៈ ( ធម៌ប្រកបសត្វទុកក្នុងវដ្តៈ ) តើដូចម្តេច ។បេ។

## អដ្ឋកថា
## គន្ថគោច្ឆកជាដើម[១]

[ ២៣៦-២៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងគន្ថគោច្ឆកៈ ដូចតទៅនេះថា

សភាវធម៌ដែលឈ្មោះថា **កាយគន្ថ** ព្រោះអត្ថថា រមែងចងនាមកាយ គឺរមែងញ៉ាំងនាមកាយឲ្យបន្តក្នុងវដ្តៈ ដោយអំណាចបដិសន្ធិ ។ កាយគន្ថៈណាដែលបដិសេធ សូម្បីជាពាក្យពោលរបស់ព្រះសព្វញ្ញូ រមែងប្រកាន់មាំដោយអាការយ៉ាងនេះថា លោកទៀង របស់នេះពិត របស់ដទៃជាមោឃៈ ព្រោះហេតុនោះ កាយគន្ថៈនោះ ទើបឈ្មោះថា ឥទំសច្ចាភិនិវេស ព្រោះសេចក្តីផ្សេងគ្នានៃអភិជ្ឈានិងកាមរាគៈមាន ដូច្នោះ ក្នុងការចែកបទអភិជ្ឈា-កាយគន្ថៈ ទើបមិនត្រាស់ថា សេចក្តីប្រាថ្នាក្នុងកាម តម្រេកក្នុងកាមណា ដូច្នេះ តែត្រាស់ថា តម្រេក ការត្រេកអរខ្លាំងណាជាដើម ។ ដោយពុទ្ធ-វចនៈនេះ ពាក្យណាដែលខ្ញុំពោលទុកហើយថា ធនរាគៈ គឺតម្រេកដោយអំណាចសេចក្តីពេញចិត្ត ក្នុងវិមានរបស់ពួកព្រហ្មជាដើម មិនមែនជាកាមា-សវៈ និយាយដល់គន្ថគោច្ឆកៈហើយ ជាអភិជ្ឈាកាយគន្ថៈ ដូច្នេះ ពាក្យនោះបណ្ឌិតគប្បីជ្រាបថា ខ្ញុំពោលទុកល្អហើយ ។ សូម្បីក្នុងកិលេសគោច្ឆកៈខាងមុខក៏ន័យនេះឯង ។

---

១-មានឱឃៈគោច្ឆកៈនិងយោគៈនៅក្នុងនេះផង ។

*បទថា* **ឋបេត្វា សីលព្វតបរាមាសំ** *នេះ សេចក្ដីថា ព្រោះសីលព្វត-បរាមាស មិនប្រកាន់ដោយអាការជាដើមថា របស់នេះពិត ដូច្នេះ តែរមែងប្រកាន់យ៉ាងនេះថា មានសេចក្ដីបរិសុទ្ធដោយសីល ដូច្នេះ ហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់វៀរសីលព្វតបរាមាស ដែលជាមិច្ឆាទិដ្ឋិនោះ ទើបត្រាស់ថា* **ឋបេត្វា** ។

# អភិធម្មបិដក

## នីវរណគោច្ឆក

[ ២៤៨ ] ពួកធម៌ជានីវរណៈ ( ធម៌ជារនាំង ) តើដូចម្តេច ។ នីវរណៈ ៦ គឺកាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ ។

[ ២៤៩ ] បណ្តានីវរណៈទាំងនោះ កាមច្ឆន្ទនីវរណៈ តើដូចម្តេច ។ សេចក្តីប្រាថ្នាចំពោះកាម សេចក្តីត្រេកអរចំពោះកាម សេចក្តីរីករាយចំពោះកាម សេចក្តីអន្ទះសាចំពោះកាម សេចក្តីស្រឡាញ់ចំពោះកាម សេចក្តីរោលរាលចំពោះកាម សេចក្តីជ្រុលជ្រប់ចំពោះកាម សេចក្តីងប់ចិត្តចំពោះកាមក្នុងកាមទាំងឡាយណា នេះហៅថា កាមច្ឆន្ទនីវរណៈ ។

[ ២៥០ ] បណ្តានីវរណៈទាំងនោះ ព្យាបាទនីវរណៈ តើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ។បេ។ ជនឯណោះកំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ។បេ។ ជនឯណោះនឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃអញ ។បេ។ ជនឯណោះ កំពុងប្រព្រឹត្តនូវ

កម្មជាប្រយោជន៍ ។បេ។ ជនឯណោះនឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ឬក៏គំនុំកើតឡើងក្នុងហេតុមិនគួរនិងការគុំកួននៃចិត្ត ការគុំកួនតប សេចក្តីថ្នាំងថ្នាក់ ការខឹងតប ការខឹងញ័រ ការក្រោធខ្លាំង ការក្រោធញ័រ ការប្រទូស្ត ការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចនៃចិត្ត ការប្រទូស្តនៃចិត្ត ការក្រោធ ការខឹង ភាពនៃចិត្តខឹង សេចក្តីប្រទូស្ត អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត ការព្យាបាទ អាការព្យាបាទ ភាពនៃចិត្តព្យាបាទ ការខឹង ការខឹងតប ភាពនៃចិត្តកាច ការខឹង ការតូចចិត្តណាដែលមានសភាពបែបនេះ នេះហៅថា ព្យាបាទនីវរណៈ ។

[ ២៥១ ] បណ្តានីវរណៈទាំងនោះ ថីនមិទ្ធនីវរណៈ តើដូចម្តេច ។ ថីនៈ ( សេចក្តីធុញទ្រាន់ ) ក៏មាន មិទ្ធៈ ( សេចក្តីងោកងក់ ) ក៏មាន ។ បណ្តាធម៌ទាំងនោះ ថីនៈ តើដូចម្តេច ។ ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់នៅ ការសម្ងំនៅ សេចក្តីរួញរា អាការរួញរា ភាពរួញរា សេចក្តីធុញទ្រាន់ ការធុញទ្រាន់ ភាពធុញទ្រាន់ណានៃចិត្ត នេះហៅថា ថីនៈ ។ បណ្តាធម៌ទាំងនោះ មិទ្ធៈ តើដូចម្តេច ។ ភាពមិនឈ្លាស ភាពមិនគួរដល់ការងារ ការជ្រប់ ការស្រពោន ការងងឹតឈ្ងប់ខាងក្នុង ការងោកងក់ ការសុបសៅ អាការយើតក្លិះៗ សេចក្តីសុបសៅ អាការសុបសៅ ភាពសុបសៅណានៃកាយ នេះហៅថា មិទ្ធៈ ។ នេះថីនៈ នេះមិទ្ធៈ ដោយប្រការដូច្នេះឯង ។ នេះហៅថា ថីនមិទ្ធនីវរណៈ ។

[ ២៥២ ] បណ្តានីវរណៈទាំងនោះ ឧទ្ធច្ចកុក្កុច្ចនីវរណៈ តើដូចម្តេច ។

ឧទ្ធច្ចៈ ( ការអណ្ដែតអណ្ដូង ) ក៏មាន កុក្កុច្ចៈ ( ការទើសទាល់ចិត្តរង្កៀស ) ក៏មាន ។ បណ្ដាធម៌ទាំងនោះ ឧទ្ធច្ចៈ តើដូចម្ដេច ។ ការអណ្ដែតអណ្ដូង ការមិនស្ងប់រម្ងាប់ ការរាយមាយ ការភ័ន្តភាំងណានៃចិត្ត នេះហៅថា ឧទ្ធច្ចៈ ។ បណ្ដាធម៌ទាំងនោះ កុក្កុច្ចៈ តើដូចម្ដេច ។ ការសម្គាល់ថា គួរក្នុងរបស់មិនគួរ សម្គាល់ថា មិនគួរក្នុងរបស់គួរ សម្គាល់ថា ជាទោសក្នុងរបស់មិនមែនជាទោស សម្គាល់ថា មិនជាទោសក្នុងរបស់ជាទោស និងសេចក្ដីរង្កៀស អាការរង្កៀស ភាពនៃចិត្តរង្កៀស ការក្ដៅក្រហាយចិត្ត ការរសេមរសាមចិត្តណា ដែលមានសភាពបែបនេះ នេះហៅថា កុក្កុច្ចៈ នេះឧទ្ធច្ចៈ នេះកុក្កុច្ចៈ ដោយប្រការដូច្នេះឯង ។ នេះហៅថា ឧទ្ធច្ចកុក្កុច្ចនីវរណៈ ។

[ ២៥៣ ] បណ្ដានីវរណៈទាំងនោះ វិចិកិច្ឆានីវរណៈ តើដូចម្ដេច ។ បុគ្គលងឿងឆ្ងល់សង្ស័យចំពោះព្រះសាស្ដា ងឿងឆ្ងល់សង្ស័យចំពោះព្រះធម៌ ងឿងឆ្ងល់សង្ស័យចំពោះព្រះសង្ឃ ងឿងឆ្ងល់សង្ស័យចំពោះសិក្ខា ងឿងឆ្ងល់សង្ស័យចំពោះខន្ធជាចំណែកខាងដើម ងឿងឆ្ងល់សង្ស័យចំពោះខន្ធ ជាចំណែកខាងចុង ងឿងឆ្ងល់សង្ស័យចំពោះខន្ធ ទាំងចំណែកខាងដើម ទាំងចំណែកខាងចុង ងឿងឆ្ងល់សង្ស័យចំពោះពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗនិងសេចក្ដីសង្ស័យ អាការសង្ស័យ ភាពនៃចិត្តសង្ស័យ ការយល់ច្រឡំ ការសង្ស័យ ការបែកចិត្តជាចំពាមពីរ ការបែកជាផ្លូវពីរ ការងឿងឆ្ងល់ ការប្រកាន់យកចំណែកដ៏ច្រើន ការសាញប្រដាញ ការសាន់វាន់ចិត្ត ការប្រកាន់មិនដាច់ស្រេច ភាពនៃចិត្តវិង្វេស ការរសេមរសាមនៃចិត្ត

ណាដែលមានសភាពបែបនេះ នេះហៅថា វិចិកិច្ឆានីវរណៈ ។

[ ២៥៤ ] បណ្តានីវរណៈទាំងនោះ អវិជ្ជានីវរណៈ តើដូចម្តេច ។ ការមិនដឹងក្នុងទុក្ខ មិនដឹងក្នុងហេតុឲ្យកើតទុក្ខ មិនដឹងក្នុងការរលត់ទុក្ខ មិនដឹងក្នុងបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ មិនដឹងក្នុងខន្ធជាចំណែកខាងដើម មិនដឹងក្នុងខន្ធ ជាចំណែកខាងចុង មិនដឹងក្នុងខន្ធជាចំណែកខាងដើម ទាំងចំណែកខាងចុង មិនដឹងក្នុងពួកធម៌ដែលកើត ព្រោះអាស្រ័យបច្ច័យនោះៗ និងការមិនដឹង ការមិនឃើញ ការមិនត្រាស់ដឹង ការមិនភ្ញាក់រឭក ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក ការមិនចុះចិត្តស៊ប់ មិនរំពឹងមើល ការមិនពិចារណា អំពើមិនជាក់ច្បាស់ ការយល់ខុសភាពនៃសេចក្តីល្ងង់ ការមិនដឹងខ្លួន ការវង្វេង វង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា អន្លង់គឺអវិជ្ជា ការប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាក់ដំណើរគឺអវិជ្ជា គន្លឹះគឺអវិជ្ជា ការវង្វេង ជាអកុសលមូលណា ដែលមានសភាពបែបនេះ នេះហៅថា អវិជ្ជានីវរណៈ ។

## នេះពួកធម៌ជានីវរណៈ ។

[ ២៥៥ ] ពួកធម៌មិនមែននីវរណៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែននីវរណៈ ។

[ ២៥៦ ] ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ តើដូចម្តេច ។ ពួកធម៌

ប្រកបដោយអាសវៈជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាប្រយោជន៍ដល់នីវរណៈ ។ ពួកធម៌មិនជាប្រយោជន៍ដល់នីវរណៈ តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនជាប្រយោជន៍ដល់នីវរណៈ ។

[ ២៥៧ ] ពួកធម៌ប្រកបដោយនីវរណៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយនីវរណៈ ។ ពួកធម៌ប្រាសចាកនីវរណៈ តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកនីវរណៈ ។

[ ២៥៨ ] ពួកធម៌ជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង តើដូចម្តេច ។ នីវរណៈទាំងនោះឯង ហៅថា នីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង ។ ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ តើដូចម្តេច ។ ពួកធម៌ណាជាប្រយោជន៍ដល់នីវរណៈដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាប្រយោជន៍ ដល់នូវនីវរណៈ តែមិនមែនជានីវរណៈ ។

[ ២៥៩ ] ពួកធម៌ជានីវរណៈផង ប្រកបដោយនីវរណៈផង តើដូច

ម្តេច ។ កាមច្ឆន្ទនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ អវិជ្ជានីវរណៈ ជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយកាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈជានីវរណៈផង ប្រកបដោយនី-វរណៈផង ដោយអវិជ្ជានីវរណៈ អវិជ្ជានីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ អវិជ្ជានីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ អវិជ្ជានីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ កុក្កុច្ចនីវរណៈ ជានីវ-រណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ អវិជ្ជានីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយកុក្កុច្ចនីវរណៈ វិចិកិច្ឆានី-វរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ អ-វិជ្ជានីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយវិចិកិច្ឆានីវរណៈ កាមច្ឆន្ទនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ ឧទ្ធច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយកាមច្ឆន្ទនី-វរណៈ ព្យាបាទនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ ឧទ្ធច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ ឧទ្ធច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង

ដោយថីនមិទ្ធនីវរណៈ កុក្កុច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ ឧទ្ធច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយកុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ ឧទ្ធច្ចនីវរណៈ ជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយវិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ ជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយឧទ្ធច្ចនីវរណៈ ឧទ្ធច្ចនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ នេះពួកធម៌ជានីវរណៈផង ប្រកបដោយនីវរណៈផង ពួកធម៌គ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ វៀរតែធម៌នោះចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ ។

[ ២៦០ ] ពួកធម៌ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកនីវរណៈតែជាប្រយោជន៍ដល់នីវរណៈ ។ ពួកធម៌ប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផង ។

[ ២៦១ ] ពួកធម៌ជាបរាមាសៈ តើដូចម្ដេច ។ ទិដ្ឋិបរាមាសៈ ។ បណ្ដាធម៌ទាំងនោះ ទិដ្ឋិបរាមាសៈ តើដូចម្ដេច ។ ( ការយល់ឃើញ ) ថាលោកទៀងក្ដី ថាលោកមិនទៀងក្ដី ថាលោកមានទីបំផុតក្ដី ថាលោកមិនមានទីបំផុតក្ដី ថាជីវិតនោះ គឺសរីរៈនោះក្ដី ថាជីវិតដទៃ សរីរៈដទៃក្ដី ថាសត្វស្លាប់ទៅកើតទៀតក្ដី ថាសត្វស្លាប់ទៅមិនកើតទៀតក្ដី ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានក្ដី ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនក្ដី និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ច្រើងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្ដួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណាដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋិបរាមាសៈ ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋិបរាមាសៈដែរ ។ នេះពួកធម៌ជាបរាមាសៈ ។ ពួកធម៌មិនមែនជាបរាមាសៈ តើដូចម្ដេច ។ វៀរតែធម៌ទាំងនេះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាបរាមាសៈ ។

[ ២៦២ ] ពួកធម៌ដែលបរាមាសៈស្ទាបអង្អែល តើដូចម្ដេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដែលបរាមាសៈ

ស្ទាបអង្អែល ។ ពួកធម៌ដែលបរាមាសៈ មិនស្ទាបអង្អែល តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ដែលបរាមាសៈមិនស្ទាបអង្អែល ។

[ ២៦៣ ] ពួកធម៌ដែលប្រកបដោយបរាមាសៈ តើដូចម្តេច ។ ពួកធម៌ណាប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ដែលប្រកបដោយបរាមាសៈ ។ ពួកធម៌ដែលប្រាសចាកបរាមាសៈ តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ដែលប្រាសចាកបរាមាសៈ ។

[ ២៦៤ ] ពួកធម៌ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង តើដូចម្តេច ។ បរាមាសៈនោះឯង ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង ។ ពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ តើដូចម្តេច ។ ពួកធម៌ណាដែលបរាមាសៈស្ទាបអង្អែល ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ ។

[ ២៦៥ ] ពួកធម៌ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូ-

បក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល ។ ពួកធម៌ប្រាសចាកបរាមាសៈផង បរាមាសៈមិនស្ទាបអង្អែលផង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកបរាមាសៈផង បរាមាសៈមិនស្ទាបអង្អែលផង ។

[ ២៦៦ ] ពួកធម៌ប្រកបដោយអារម្មណ៍ តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយអារម្មណ៍ ។ ពួក ធម៌មិនមែនជាអារម្មណ៍ តើដូចម្តេច ។ រូបទាំងអស់ និងអសង្ខតធាតុ នេះ ពួកធម៌មិនមែនជាអារម្មណ៍ ។

[ ២៦៧ ] ពួកធម៌ជាចិត្ត តើដូចម្តេច ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោធាតុ មនោវិញ្ញាណធាតុ នេះពួកធម៌ជាចិត្ត ។ ពួកធម៌មិនមែនជាចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាចិត្ត ។

[ ២៦៨ ] ពួកធម៌ជាចេតសិក តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ជាចេតសិក ។ ពួកធម៌មិនមែនជាចេតសិក តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌ មិនមែនជាចេតសិក ។

[ ២៦៩ ] ពួកធម៌ប្រកបដោយចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រកបដោយចិត្ត ពួកធម៌ប្រាសចាកចិត្ត តើដូចម្តេច ។

រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកចិត្ត ។ ចិត្តគេមិនគប្បីពោលថា ប្រកបដោយចិត្តផង ថាប្រាសចាកចិត្តផងទេ ។

[ ២៧០ ] ពួកធម៌ប្រឡូកប្រឡំដោយចិត្ត តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំដោយចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំដោយចិត្ត តើដូចម្ដេច ។ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនប្រឡូកប្រឡំដោយចិត្ត ។ ចិត្តគេមិនគប្បីពោលថា ប្រឡូកប្រឡំដោយចិត្តផង ថាមិនប្រឡូកប្រឡំដោយចិត្តផងទេ ។

[ ២៧១ ] ពួកធម៌តាំងឡើងដោយចិត្ត តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ ( ការកម្រើកកាយ ) វចីវិញ្ញត្តិ ( ការកម្រើកវាចា ) ឬក៏រូបដទៃណា គឺរូបកើតអំពីចិត្ត មានចិត្តជាហេតុ មានចិត្តជាសមុដ្ឋាន រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ រូបស្សលហុតា ( ភាពនៃរូបស្រាល ) រូបស្សមុទុតា ( ភាពនៃរូបទន់ ) រូបស្សកម្មញ្ញតា ( ភាពនៃរូបគួរដល់ការងារ ) រូបស្សឧបចយៈ ( ការសន្សំនៃរូប ) រូបស្សសន្តតិ ( តំណនៃរូប ) កពឡិង្ការាហារ នេះពួកធម៌ដែលតាំងឡើងដោយចិត្ត ពួកធម៌មិនតាំងឡើងដោយចិត្ត តើដូចម្ដេច ។ ចិត្តផង រូបដ៏សេសផង អសង្ខតធាតុផង នេះពួកធម៌មិនតាំងឡើងដោយចិត្ត ។

[ ២៧២ ] ពួកធម៌កើតជាមួយនឹងចិត្ត តើដូចម្ដេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះពួកធម៌កើតជាមួយនឹងចិត្ត ។ ពួក

ធម៌មិនកើតជាមួយនឹងចិត្ត តើដូចម្តេច ។ ចិត្តផង រូបដ៏សេសផង អសង្ខតធាតុផង នេះពួកធម៌មិនកើតជាមួយនឹងចិត្ត ។

[ ២៧៣ ] ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះពួកធម៌ប្រព្រឹត្តទៅតាមចិត្ត ។ ពួកធម៌មិនប្រព្រឹត្តទៅតាមចិត្តតើដូចម្តេច ។ ចិត្តផង រូបដ៏សេសផង អសង្ខតធាតុផង នេះពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត ។

[ ២៧៤ ] ពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើងដោយចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើងដោយចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើងដោយចិត្ត តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើងដោយចិត្ត ។

[ ២៧៥ ] ពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ។

[ ២៧៦ ] ពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំ

ទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ ចិត្តផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ។

[ ២៧៧ ] ពួកធម៌ជាខាងក្នុង តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ មនាយតនៈ នេះពួកធម៌ជាខាងក្នុង ពួកធម៌ជាខាងក្រៅ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ធម្មាយតនៈ នេះពួកធម៌ជាខាងក្រៅ ។

[ ២៧៨ ] ពួកធម៌ជាឧបាទា ( ឧបាទារូប ) តើដូចម្តេច ។ ចក្ខាយតនៈ កពឡិង្ការាហារ នេះពួកធម៌ជាឧបាទា ។ ពួកធម៌មិនមែនជាឧបាទា តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ មហាភូតរូបទាំង ៤ និងអសង្ខតធាតុ នេះធម៌មិនមែនជាឧបាទា ។

[ ២៧៩ ] ពួកធម៌ជាឧបាទិន្នៈ ( ធម៌មានកម្មប្រកបដោយកិលេសមានតណ្ហាជាដើមកាន់យកហើយ ) តើដូចម្តេច ។ វិបាក ប្រកបដោយអាសវៈរបស់ពួកធម៌ជាកុសលនិងអកុសលជាកាមាវចរ រូបាវចរ អរូបាវចរ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ និងរូបដែលជាកម្មសម្បកតត្តា នេះពួកធម៌ជាឧបាទិន្នៈ ។ ពួកធម៌ជាអនុបាទិន្នៈ ( ធម៌មិនមានកម្មប្រកបដោយកិលេស មាន

តណ្ហាជាដើមកាន់យកហើយ ) តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសលនិងអកុសល ជាកាមាវចរ រូបាវចរ អរូបាវចរ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ឬពួកធម៌ជាកិរិយាដែលមិនមែនជាកុសល មិនមែនជាអកុសល មិនមែនជាកម្មវិបាក រូបដែលមិនមែនជាកម្មសមុដ្ឋាន មគ្គជាអបរិយាបន្ន ផលនៃមគ្គនិងអសង្ខតធាតុ នេះពួកធម៌ជាអនុបាទិន្នៈ ។

# អដ្ឋកថា

# នីវរណគោច្ឆកជាដើម(១)

[ ២៤៨-២៧៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបីនមិទ្ធនិទ្ទេសនៃនីវរណគោច្ឆកៈ ដូចតទៅនេះថា

បទថា **ចិត្តស្ស អកល្យតា** គឺការៈនៃអ្នកជំងឺ ។ មែនពិត អ្នកជំងឺហៅថា **អកល្លកោ** ។ សូម្បីក្នុងវិន័យ ( ទុតិយបារាជិក ) ក៏ពោលទុកថា **ណាហំ ភន្តេ អកល្លកោ** បពិត្រលោកម្ចាស់ ខ្ញុំមិនឈឺទេ ដូច្នេះ ។

បទថា **អកម្មញ្ញតា** បានដល់ អាការនៃការមិនគួរដល់ការងារ គឺភាពមានជំងឺនៃចិត្តនោះឯង ។ បទថា **ឱលីយនា** បានដល់ អាការដែលរួញរា ។ មែនពិត ចិត្តដែលញុំាងឥរិយាបថ ឲ្យកើតឡើង កាលមិនអាចទ្រទ្រង់ឥរិ-យាបថទុកបាន រមែងរាថយ ដូចសត្វប្រចៀវសំយុងខ្លួនលើដើមឈើ រមែងរាថយ ដូចផ្ទាំងទឹកឃឹកព្យួរទុកត្រង់សសរ ។ ព្រះមានព្រះភាគ ត្រាស់ថាការជ្រប់នៅ ដូច្នេះ ទ្រង់សំដៅដល់អាការៈនោះនៃចិត្តនោះ ។ បទទី ២ ( **សល្លីយនា** ការសម្ងំនៅ ) ទ្រង់បន្ថែមបទឧបសគ្គ ។

បទថា **លីនំ** បានដល់ រួញត្រឡប់ហើយ ព្រោះមិនផ្សាយចេញទៅ ។ បទ ២ ក្រៅអំពីនេះ ( គឺ **លីយនា** និង **លីយិតត្តំ** អាការរួញរា ភាពរួញរា ) ជាបទសម្ដែងដល់អាការនិងការៈនៃចិត្តនោះ ។

បទថា **ថីនំ** សេចក្ដីថា ដែលឈ្មោះថា **ថីន** ដោយភាពជាដុំ ព្រោះមិន

---

១-ក្នុងនោះមានបរាមាសគោច្ឆកៈនិងមហន្តរទុកៈផងដែរ តែបិដកខ្មែរមិនមានចំណងជើងទេ ។

ផ្សាយទៅ ដូចដុំសប្បិ ។ បទថា **ថីយនា** ជាការសម្តែងអាការនៃចិត្ត ។ ភាវៈដែលចិត្តធុញទ្រាន់ហើយ ឈ្មោះថា **ថីយិតត្តំ** អធិប្បាយថា ការដែលចិត្តជាធម្មជាតរឹងត្អឹង ដោយអំណាចនៃការមិនផ្សាយចេញទៅនោះឯង ។

បទថា **កាយស្ស** បានដល់ នាមកាយ គឺខន្ធ ៣ ។ បទថា **អកល្យតា អកម្មញ្ញតា** មានន័យដូចពោលទុកក្នុងខាងដើមនុ៎ះឯង ។ ដែលឈ្មោះថា **ឱនាហោ** ព្រោះអត្ថថា រមែងគ្របសង្កត់កាយ ដូចដុំពពក គ្របអាកាស ដូច្នោះ ការគ្របដោយចំណែកទាំងអស់ ឈ្មោះថា **បរិយោនាហោ** ( ការស្រពោន ) ។ ដែលឈ្មោះថា **អន្តោសមោរោធោ** ព្រោះអត្ថថា រមែងបិទបាំងទុកខាងក្នុង ។ ដូចនគរដែលគេបិទហើយ ពួកមនុស្ស រមែងចេញទៅខាងក្រៅមិនបានយ៉ាងណា ធម៌ទាំងឡាយដែលមិទ្ធៈបិទទុកហើយ រមែងមិនបានដើម្បីនឹងចេញទៅ ដោយអំណាចការផ្សាយទៅក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបត្រាស់ថា **អន្តោសមោរោធោ** ( ការងងឹតឈ្ងប់ខាងក្នុង ) ។ ដែលឈ្មោះថា **មិទ្ធំ** ព្រោះអត្ថថា កម្ចាត់ អធិប្បាយថា បៀតបៀនដោយការមិនគួរដល់ការងារ ។ ដែលឈ្មោះថា **សោប្បំ** ព្រោះអត្ថថា ជាហេតុឲ្យដេកលក់ ។ ដែលឈ្មោះថា **បចលាយិកា** ព្រោះអត្ថថា រមែងធ្វើឲ្យត្របកភ្នែកជាដើមកម្រើក ។ បទថា **សុបនា សុបិតត្តំ** ( អាការសុបសៅ ភាពសុបសៅ ) ជាបទសម្តែងអាការនិងភាវៈ ។ បទថា **សោប្បំ** ខាងមុខនៃបទទាំងពីរនេះឯណា ហេតុក្នុងការពោលបទនោះដដែលទៀត ខ្ញុំពោលទុកហើយនោះឯង ។ បទថា **ឥទំ វុច្ចតិ ថិនមិទ្ធនីវរណំ** នេះ លោករួមថីនៈ

និងមិទ្ធៈនេះចូលគ្នាហើយពោលថា **ថីនមិទ្ធនីវរណៈ** ដោយអត្ថថា រាំង ។ ថីនមិទ្ធនីវរណៈណា កើតឡើងក្នុងវេលាមុនឬក្រោយការដេកលក់របស់ព្រះសេក្ខៈនិងបុថុជ្ជនទាំងឡាយដោយច្រើន ថីនមិទ្ធនីវរណៈនោះ រមែងកាត់បានដោយអរហត្តមគ្គ ។ តែការឈានចុះកាន់ភវង្គ របស់ព្រះខីណាស្រពទាំងឡាយ រមែងមានដោយភាពទុព្វលនៃករជកាយ កាលភវង្គនោះមិនលាយដោយអារម្មណ៍ដទៃប្រព្រឹត្តទៅ ព្រះខីណាស្រពទាំងនោះ រមែងដេកលក់ ឈ្មោះថា ការដេកលក់នោះ រមែងមានដល់ព្រះខីណាស្រពទាំងនោះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ទុក ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលអគ្គិវេស្សនៈ តថាគតត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាបច្ឆាភត្ត ហើយក្រាលនូវសង្ឃាដិមានជាន់ ៤ ហើយធ្លាប់សិងដោយចំហៀងខាងស្តាំ មានសតិនិងសម្បជញ្ញៈ ចុះស៊ប់កាន់កិរិយាលក់ ក្នុងខែជាទីបំផុតនៃគិម្ហរដូវ ដូច្នេះ ។

ការដែលករជកាយទន់ខ្សោយនេះ មានសភាពបែបនេះ មិនមែនភាវៈដែលមគ្គគប្បីសម្លាប់ ការដែលកាយទុព្វលនេះ រមែងបានទាំងក្នុងរូប ដែលមានចិត្តគ្រប់គ្រង និងក្នុងរូបដែលមិនមានចិត្តគ្រប់គ្រង កាលនឹងបានក្នុងរូបដែលមានចិត្តគ្រប់គ្រង រមែងបានក្នុងវេលាដែលព្រះខីណាស្រពធ្វើដំណើរផ្លូវឆ្ងាយ ឬធ្វើការងារឯណានីមួយ ហត់នឿយ កាលបានក្នុងរូបដែលមិនមានចិត្តគ្រប់គ្រង រមែងបានក្នុងស្លឹកឈើ ផ្កាឈើទាំងឡាយ ពិតណាស់ ស្លឹកឈើរបស់ដើមឈើប្រភេទខ្លះ រមែងលាចេញដោយពន្លឺថ្ងៃ ក្នុងវេលារាត្រី

រមែងក្តោប ផ្កាឈូកជាដើម រមែងរីកដោយពន្លឺព្រះអាទិត្យ តែក្នុងវេលារាត្រី រមែងក្តោប ។ មិទ្ធៈនេះរមែងមិនមានដល់ព្រះខីណាស្រពទាំងឡាយ ព្រោះ មិទ្ធៈនោះជាអកុសល ដូច្នេះឯង ។

ក្នុងអធិការនៃមិទ្ធៈនោះ បើមានអ្នកសួរថា មិទ្ធៈ មិនមែនជាអកុសល ព្រោះហេតុអ្វី ព្រោះមិទ្ធៈជារូប រូបជាអព្យាកតៈ ឯមិទ្ធៈនេះក៏ជារូប ដោយ ហេតុនោះ ក្នុងអធិការនេះ ទើបព្រះមានព្រះភាគត្រាស់ធ្វើ កាយ សព្ទ ថា ការមិនសមប្រកបនៃកាយ ការមិនសមគួរដល់ការងារនៃកាយ ដូច្នេះ ។ គប្បីឆ្លើយថា បើមិទ្ធៈនេះជារូបដោយត្រឹមតែពាក្យដែលត្រាស់ថា **កាយស្ស** សោត ធម៌ទាំងឡាយ មានកាយបស្សទ្ធិជាដើម ក៏គប្បីជារូបទាំងអស់ ។ សូម្បីការធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈ ដោយការសោយសុខដែលត្រាស់ ទុក ( ក្នុងអភិធម្មធម្មសង្គណិ ) ថា សោយសុខដោយនាមកាយផង និង ក្នុងមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកថា ធ្វើឲ្យជាក់ច្បាស់នូវបរមសច្ចៈដោយ នាមកាយ ដូច្នេះ ។ គប្បីជារូបកាយប៉ុណ្ណោះ ព្រោះហេតុនោះ មិនគួរនិយាយ ថា មិទ្ធៈនេះជារូប ។

សួរថា ក្នុងអធិការនេះ នាមកាយ ឈ្មោះថា **កាយ** បើកាយជានាម-កាយសោត កាលបើយ៉ាងនោះ ព្រោះហេតុអ្វី ទើបត្រាស់ថា **សោប្បំ ប-ចលាយិកា** ដូច្នេះទៅវិញ ដ្បិតថានាមកាយរមែងមិនសុបសៅ រមែងមិន ងោកងក់ ។ ឆ្លើយថា ព្រោះការសុបសៅនិងការងោកងក់នោះជាផលរបស់ មិទ្ធៈនោះ ដូចទ្រង់ទ្រាយជាដើមជាផលរបស់ឥន្ទ្រិយដូច្នោះ ដូចទ្រង់ទ្រាយជា

ដើមទាំងនេះ គឺទ្រង់ទ្រាយស្រី គ្រឿងសម្គាល់ឲ្យដឹងថាស្រី កិរិយាស្ត្រី អាការស្ត្រី ត្រាស់ទុកព្រោះភាពជាផលនៃឥត្ថិន្ទ្រិយយ៉ាងណា ការសុបសៅជាដើមក៏ត្រាស់ទុក ព្រោះភាពជាផលនៃមិទ្ធៈនេះ ពោលគឺ ភាពអាពាធនៃនាមកាយ ក៏យ៉ាងនោះ ដ្បិតថា កាលមិទ្ធៈមាន ការសុបសៅជាដើមនោះក៏មាន ព្រោះហេតុនោះ ទើបត្រាស់មិទ្ធៈ សូម្បីជាអរូប ( នាម ) ដោយផលូបចារន័យ ( ពោលហេតុសំដៅដល់ផល ) ថា ការសុបសៅ អាការយឺតក្លឹះៗ អាការសុបសៅ ភាពសុបសៅ ដូច្នេះ ។ មួយទៀត សូម្បីដោយវចនត្ថថា ដែលឈ្មោះថា **បចលាយិកា** ព្រោះអត្ថថា ធ្វើឲ្យត្របកភ្នែកជាដើមកម្រើកដូច្នេះ ក៏ឲ្យសម្រេចសេចក្តីនេះដូចគ្នា ព្រោះហេតុនោះ មិទ្ធៈទើបមិនមែនជារូប ។ មួយទៀត ការដែលមិទ្ធៈនោះជាអរូប ព្រះអង្គ ក៏ទ្រង់សម្តែងសូម្បីដោយការជ្រប់ជាដើមនុ៎ះឯង ព្រោះថា រូបនឹងជាការជ្រប់ ការស្រពោន ការផងឹតឈ្ងប់ខាងក្នុងនៃនាមកាយក៏ទេ ។

បើមានអ្នកចោទសួរទៀតថា មិទ្ធៈនេះជារូបដោយហេតុ ( មានការជ្រប់ជាដើម ) នេះឯងមិនមែនឬ ព្រោះអរូប ( នាម ) មិនជាការជ្រប់ ការស្រពោន ការផងឹតឈ្ងប់ខាងក្នុងនូវអ្វី ។ គប្បីឆ្លើយថា បើយ៉ាងនេះ សូម្បីការរារាំងកុសលធម៌ ក៏មិនគប្បីមាន ព្រោះហេតុនោះ គប្បីជ្រាបភាពដែលមិទ្ធៈនេះ ជាការជ្រប់ជាដើម ដោយអត្ថថា មានការស្រពោនជាដើម ដូចអរូបធម៌ មានកាមច្ឆន្ទៈជាដើមឈ្មោះថា **នីវរណៈ** ដោយអត្ថថា រារាំង ។

ម្យ៉ាងទៀត មិទ្ធៈនេះសូម្បីឈ្មោះថា ជាអរូប ព្រោះព្រះបាលី ( ក្នុង

ទីឃនិកាយមហាវគ្គ ) ថា លះនូវនីវរណធម៌ទាំង ៥ ដែលជាឧបក្កិលេស របស់ចិត្ត ជាធម៌ធ្វើប្រាជ្ញាឲ្យថយកម្លាំង ដូច្នេះ ព្រោះរូបធ្វើចិត្តឲ្យសៅហ្មង មិនបាន បន្ថយនូវបញ្ញាក៏មិនបាន ។

សួរថា ព្រោះហេតុអ្វីទើបរូបធ្វើចិត្តឲ្យសៅហ្មងមិនបាន ធ្វើបញ្ញាឲ្យថយកម្លាំងមិនបាន ពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ( ក្នុងអង្គុត្តរនិកាយ-ចតុក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ពួកមួយ ផឹកនូវសុរានិងមេរ័យ មិនវៀរចាកការផឹកនូវសុរានិងមេរ័យឡើយ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ពួកមួយ សៅហ្មងព្រោះឧបក្កិលេសណា តែងមិនក្តៅ មិនភ្លឺ មិនរុងរឿង នេះជាឧបក្កិលេសរបស់ពួកសមណព្រាហ្មណ៍ទី ១ ដូច្នេះ មានមិនមែនឬ ។ ម្យ៉ាងទៀត ព្រះតម្រាស់ ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា ម្នាលគហបតិបុត្ត ទោសក្នុងកិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺសុរានិងមេរ័យដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទនេះ មាន ៦ យ៉ាង គឺវិនាសទ្រព្យដែលឃើញជាក់ស្តែងខ្លួនឯង ១ ការកឲ្យកើតជម្លោះ ១ ហេតុនាំឲ្យកើតរោគទាំងឡាយ ១ ការនាំឲ្យខូចឈ្មោះ ១ ការបង្ហាញកេរ្តិ៍ខ្មាស ១ ហេតុជាគម្រប់ ៦ គឺធ្វើបញ្ញាឲ្យមានកម្លាំងថយ ១ ដូច្នេះ ។ ពាក្យថា រូបធ្វើចិត្តឲ្យសៅហ្មង ធ្វើបញ្ញាឲ្យថយកម្លាំង សម្រេចហើយ ឃើញបានជាក់ច្បាស់នោះឯង ព្រោះកាលទឹកស្រវឹងចូលដល់ពោះ ចិត្តរមែងសៅហ្មង បញ្ញារមែងទុព្វល ហេតុនោះ សុម្បីមិទ្ធៈក៏ប្រៀបដូចទឹកស្រវឹង គប្បីធ្វើចិត្តឲ្យសៅហ្មង បន្ថយនូវ

បញ្ញាបាន មិនមែនឬ ។ ឆ្លើយថា មិនគួរយល់ឃើញយ៉ាងនោះ ព្រោះទ្រង់សម្ដែងដល់ភាពជាបច្ច័យ មែនពិត បើទឹកស្រវឹងគប្បីជាសង្កិលេសសោត ទឹកស្រវឹងនោះ ក៏គប្បីមកកាន់និទ្ទេស ក្នុងនិទ្ទេសនៃឧបក្កិលេសទាំងឡាយ មានយ៉ាងនេះថា ភិក្ខុនោះលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងចិត្ត[1] ដូច្នេះជាដើម ឬព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះមែនហើយ ឧបក្កិលេសនៃចិត្តទាំង ៥ នេះ ដែលធ្វើឲ្យចិត្តសៅហ្មងទៅ ជាធម្មជាតិមិនទន់ផង មិនគួរដល់ការនាកម្មផង មិនមានពន្លឺផង ជាចិត្តអ័ព្ទអួរផង មិនតម្កល់មាំដោយប្រពៃដើម្បីកិរិយាអស់ទៅនៃអាសវៈទាំងឡាយផង ។ ឧបក្កិលេសទាំង ៥ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈជាឧបក្កិលេសនៃចិត្ត ដូច្នេះ ។ ឬព្រះតម្រាស់ ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ ពួកឧបក្កិលេស គឺសេចក្ដីសៅហ្មងនៃចិត្ត តើដូចម្ដេច ។ គឺអភិជ្ឈាវិសមលោភៈ ជាឧបក្កិលេសនៃចិត្ត ១ ដូច្នេះ ។ ព្រោះកាលទឹកស្រវឹងនោះដែលបុគ្គលផឹកហើយ កិលេសទាំងឡាយដែលធ្វើចិត្តឲ្យសៅហ្មងនិងធ្វើបញ្ញាឲ្យថយកម្លាំងរមែងកើតឡើងក៏យ៉ាងនោះដូចគ្នា ទើបទឹកស្រវឹងនោះព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដោយសម្ដែងភាពជាបច្ច័យ ព្រោះទឹកស្រវឹងជាបច្ច័យដល់ឧបក្កិលេសទាំងនោះ ។ ចំណែកមិទ្ធៈជាសង្កិលេសនៃចិត្តដោយខ្លួនឯង និងធ្វើបញ្ញាឲ្យថយកម្លាំង ព្រោះហេតុនោះ ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ។

---

១-មជ្ឈិមនិកាយ មូលបណ្ណាសក ។

នៅមានសេចក្តីខ្វះដែលនឹងគប្បីពោលឲ្យក្រៃលែងជាងនេះ ។ ដោយការពោលដល់សម្បយោគ ពិតណាស់ ព្រះមានព្រះភាគត្រាស់ថា ថីនមិទ្ធនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ ដូច្នេះ ព្រោះហេតុនោះ ទើបមិទ្ធៈនេះមិនមែនរូប ដោយការពោលដល់សម្បយោគ ព្រោះរូបមិនរាប់ថាជាសម្បយុត្តធម៌ ។ បើមានពាក្យសួរថា ពាក្យនេះ ព្រះមានព្រះភាគត្រាស់ទុកដោយអំណាចនៃធម៌ តាមដែលមាន ដូចព្រះតម្រាស់ដែលត្រាស់ទុក ( ក្នុងទីឃនិកាយសីលក្ខន្ធវគ្គ ) ដោយអំណាចនៃធម៌តាមដែលមាន យ៉ាងនេះថា ក៏គប្បីឃើញនូវខ្យងនិងខ្ចៅផង នូវក្រួសនិងដុំថ្មផង នូវហ្វូងនៃត្រីផង កំពុងត្រាច់ទៅក្តី ឈប់នៅក្តី ដូច្នេះ ការពិត ដុំក្រួសនិងដុំថ្មតាំងនៅមួយកន្លែងប៉ុណ្ណោះ មិនត្រាច់ទៅ វត្ថុពីរយ៉ាងក្រៅនេះរមែងតាំងនៅខ្លះ ត្រាច់ទៅខ្លះយ៉ាងណា ក្នុងអធិការនៃមិទ្ធៈនេះ ក៏យ៉ាងនោះ មិទ្ធៈជានីវរណៈតែម្យ៉ាងមិនជាសម្បយុត្តធម៌ ថីនៈជានីវរណៈផង សម្បយុត្តដោយធម៌ផង ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថីនមិទ្ធៈទាំងអស់រួមគ្នាដោយអំណាចនៃធម៌តាមដែលមានថា ជានីវរណៈផង ប្រកបដោយនីវរណៈផង ដូច្នេះ តែមិទ្ធៈជានីវរណៈតែម្យ៉ាង មិនជាសម្បយុត្តធម៌ ដូចដុំក្រួសនិងដុំថ្មតាំងនៅមួយកន្លែង មិនត្រាច់ទៅ ព្រោះហេតុនោះទើបមិទ្ធៈជារូបប៉ុណ្ណោះ ។

គប្បីឆ្លើយថា មិទ្ធៈមិនមែនជារូបព្រោះមិនសម្រេចភាពជារូប ពិតណាស់ ពាក្យថា ដុំក្រួសនិងដុំថ្ម មិនត្រាច់ទៅ សូម្បីវៀរចាកព្រះសូត្រក៏យល់បាន ព្រោះហេតុនោះ អត្ថដោយអំណាចនៃធម៌ តាមដែលមាន ក្នុងព្រះសូត្រនេះ

ចូរលើកទុក តែពាក្យដែលពោលថា មិទ្ធៈជារូបនេះមិនត្រឹមត្រូវ បុគ្គលណាមួយ មិនអាចឲ្យមិទ្ធៈនោះជារូបបានដោយសូត្រនេះ ព្រោះហេតុនោះ មិទ្ធៈនេះ មិនបានត្រាស់ដោយអំណាចនៃធម៌តាមដែលមាន ព្រោះមិទ្ធៈមិនសម្រេចភាពជារូប ហេតុនោះទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ។

នៅមានសេចក្ដីខ្លះទៀត ដែលគប្បីពោលឲ្យក្រៃលែងជាងនេះ ពោលដោយព្រះបាលី ( ក្នុងអភិធម្មវិភង្គ ) ថា **ចត្តត្តា** ( លោកលះបង់ ) ជាដើម មែនពិត ក្នុងវិភង្គប្បករណ៍ ព្រះមានព្រះភាគ ត្រាស់ពាក្យជាដើមថា លោកលះបង់យ៉ាងនេះថា ពាក្យថា ជាអ្នកប្រាសចាកថីនៈនិងមិទ្ធៈ ដូច្នេះ ព្រោះភាពនៃថីនៈនិងមិទ្ធៈនោះលោកលះបង់ ខ្ជាក់ចេញ រួចស្រឡះ បន្សាត់បង់ រលាស់ចេញ បន្សាត់បង់ ទាំងរលាស់ចេញអស់ហើយ ព្រោះហេតុនោះទើបពោលថា ជាអ្នកប្រាសចាកថីនៈនិងមិទ្ធៈ ដូច្នេះ ។ និងព្រះតម្រាស់ថា ភិក្ខុញុំាងចិត្តនេះឲ្យស្អាត ឲ្យបរិសុទ្ធិ ឲ្យផូរផង់ ឲ្យរួច ឲ្យរួចស្រឡះ ឲ្យរបូតចេញចាកថីនៈនិងមិទ្ធៈនេះ ព្រោះហេតុនោះ ទើបពោលថា ជម្រះចិត្តឲ្យស្អាតចាកថីនៈនិងមិទ្ធៈ ដូច្នេះ ។ ចំណែករូបមិនបានហៅយ៉ាងនេះ ព្រោះហេតុនោះឯង ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ។

អាចារ្យអ្នកពោលមិទ្ធៈថាជារូប ជំទាស់ថា មិទ្ធៈមិនមែនជាអរូប ព្រោះត្រាស់ការមិនកើតឡើងនៃថីនមិទ្ធៈ ដែលកើតអំពីចិត្ត ។ មែនពិត មិទ្ធៈមាន ៣ យ៉ាង គឺកើតអំពីចិត្ត ១ កើតអំពីឧតុ ១ កើតអំពីអាហារ ១ ។ ព្រោះហេតុនោះ បណ្ដាមិទ្ធៈទាំង ៣ នេះ មិទ្ធៈណាកើតអំពីចិត្ត ក្នុងវិភង្គព្រះមាន

ព្រះភាគត្រាស់ការមិនកើតឡើងនៃមិទ្ធៈនោះ ព្រោះឈានចិត្តទាំងឡាយទើបមិទ្ធៈមិនសម្រេចជាអរូប ព្រោះហេតុនោះ ទើបមិទ្ធៈជារូបប៉ុណ្ណោះ ។

ឆ្លើយថា មិទ្ធៈមិនជារូបបានឡើយ ព្រោះមិទ្ធៈសម្រេចភាពជារូបមិនបាន ដ្បិតថា កាលមិទ្ធៈសម្រេចភាពជារូប បុគ្គលណាមួយ ក៏អាចមានមិទ្ធៈនោះបាន លោកពោលការមិនកើតនៃមិទ្ធៈ ដែលកើតអំពីចិត្ត ព្រោះឈានចិត្តនោះ ក៏សភាវៈនោះសម្រេចមិនបានឡើយ ព្រោះហេតុនោះ ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ។

នៅមានសេចក្តីខ្លះដែលគប្បីពោលឲ្យក្រៃលែងជាងនេះ ។ ពោលដោយការពោលដល់ការលះ ។ ពិតណាស់ ព្រះមានព្រះភាគត្រាស់ការលះមិទ្ធៈទុក ( ក្នុងអង្គុត្តរនិកាយឆក្កនិបាត ) ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលលះបង់ធម៌ ៦ យ៉ាងទើបជាអ្នកគួរបានបឋមជ្ឈាន ។ ធម៌ ៦ យ៉ាងតើអ្វីខ្លះ ។ គឺកាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ថីនមិទ្ធៈ ១ ឧទ្ធច្ចកុក្កុច្ចៈ ១ វិចិកិច្ឆា ១ ទោសក្នុងកាមទាំងឡាយ បុគ្គលនោះពិចារណាឃើញដោយប្រាជ្ញារបស់ខ្លួនតាមពិត ១ ដូច្នេះ និងព្រះតម្រាស់ ( ក្នុងអង្គុត្តរនិកាយបញ្ចកនិបាត ) ថា **សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្ពលីករណេ អត្តត្ថំ វា បរត្ថំ វា ញស្សតិ** ភិក្ខុនោះសោត បានលះបង់នូវធម៌ទាំង ៥ យ៉ាងនេះ រករំងនឹងដឹងនូវប្រយោជន៍ខ្លួន ដឹងនូវប្រយោជន៍អ្នកដទៃ ដោយប្រាជ្ញាមានកម្លាំងដូច្នេះ ចំណែករូបមិនមែនបហាតព្វធម៌ គឺធម៌ដែលបុគ្គលគប្បីលះ ដូចព្រះតម្រាស់ ( ក្នុងអភិធម្មវិភង្គ ) ថា រូបក្ខន្ធ គេគួរដឹងច្បាស់ គួរកំណត់ដឹង

តែមិនគួរលះបង់ មិនគួរបម្រើន មិនគួរធ្វើឲ្យជាក់ច្បាស់ទេ ដូច្នេះ ទើបមិទ្ធៈជាអរូបប៉ុណ្ណោះ ដោយការពោលដល់ការលះមិទ្ធៈនេះ ។

អាចារ្យអ្នកពោលមិទ្ធៈថាជារូបជំទាស់ថា មិទ្ធៈមិនមែនជាអរូប ព្រោះត្រាស់ដល់ការលះនូវរូបក៏មាន ។ ពិតណាស់ ព្រះមានព្រះភាគត្រាស់ការលះនូវរូបទុំះឯង ក្នុងព្រះបាលី ( ក្នុងមជ្ឈិមនិកាយមូលបណ្ណាសក ) នេះថា ម្នាលភិក្ខុទាំងឡាយ រូបមិនមែនរបស់អ្នកទាំងឡាយទេ អ្នកទាំងឡាយ ចូរលះបង់រូបនោះចេញ ដូច្នេះ ព្រោះហេតុនោះ ទើបការលះមិនមែនជាហេតុ ។

អាចារ្យអ្នកចង្អុលបង្ហាញពោលថា លោកមិនគួរយល់ឃើញយ៉ាងនោះទេ ព្រោះព្រះតម្រាស់នោះ ត្រាស់ដោយប្រការដទៃ មែនពិត ក្នុងព្រះសូត្រនោះ ព្រះមានព្រះភាគ ត្រាស់ការលះរូប ដោយអំណាចនៃការលះតម្រេកដោយអំណាចសេចក្តីពេញចិត្ត ដែលទ្រង់ត្រាស់ទុក ( ក្នុងសំយុត្តនិកាយ-ខន្ធវារវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ឆន្ទរាគៈណា មានក្នុងរូប អ្នកទាំងឡាយ ចូរលះបង់នូវឆន្ទរាគៈនោះចេញ ដូច្នេះ ទើបមិទ្ធៈមិនមែនរូប ព្រោះត្រាស់ទុកដោយប្រការដទៃថា មិនត្រាស់រូបថា ជាធម៌គួរលះ ដូចព្រះតម្រាស់ថា លះធម៌ ៦ យ៉ាង លះនីវរណៈ ៥ យ៉ាង ព្រោះហេតុនោះ ព្រះមានព្រះភាគត្រាស់សូត្រទាំងនេះថា ភិក្ខុនោះ លះនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបថា មិទ្ធៈជាអរូបប៉ុណ្ណោះ ដោយព្រះសូត្រទាំងឡាយនេះផង ដោយព្រះសូត្រទាំងឡាយដទៃផង ។

ពិតយ៉ាងនោះ ព្រះមានព្រះភាគត្រាស់ព្រះសូត្រ មិនមែនតិច ដែលបំភ្លឺដល់កាលដែលមិទ្ធៈនោះជាអរូបប៉ុណ្ណោះ មានព្រះតម្រាស់ ( ក្នុងសំយុត្តនិកាយមហាវារវគ្គ ) ថា ម្នាលភិក្ខុទាំងឡាយ ធម៌ជាគ្រឿងរារាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ មាន ៥ ប្រការនេះ ។ ធម៌ ៥ ប្រការ គឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ កាមច្ឆន្ទៈជាគ្រឿងរារាំង ជាគ្រឿងបិទបាំង ។បេ។ ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធៈជាគ្រឿងរារាំង ជាគ្រឿងបិទបាំង ជាឧបក្កិលេសរបស់ចិត្ត ធ្វើប្រាជ្ញាឲ្យមានកម្លាំងខ្សោយ ដូច្នេះ ។ និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ថីនមិទ្ធនីវរណៈ ជាធម្មជាតធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុឲ្យរលត់ទៅនៃបញ្ញា ជាបក្ខពួកនៃសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ដូច្នេះ ។ និងព្រះតម្រាស់ថា **ឃរមេវ ខោ ព្រាហ្មណ យស្មឹ សមយេ ថិនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ថិនមិទ្ធបរេតេន** ម្នាលព្រាហ្មណ៍ ក្នុងសម័យណាបុគ្គលមានចិត្តដែលថីនមិទ្ធៈរួបរឹត ដែលថីនមិទ្ធៈគ្របសង្កត់ ដូច្នេះ ។ និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលធ្វើទុកក្នុងចិត្តដោយមិនមានឧបាយប្រាជ្ញា កាមច្ឆន្ទៈដែលមិនទាន់កើតឡើងក៏កើតឡើង ។បេ។ ថីនមិទ្ធៈដែលមិនទាន់កើតឡើងក៏កើតឡើង ដូច្នេះ ។ និងព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ គំនរនៃអកុសលទាំងអស់នេះ គឺនីវរណៈទាំង ៥ នេះឯង ដូច្នេះ ព្រោះមិទ្ធៈនេះជាអរូប ហេតុនោះ ទើបកើតឡើងសូម្បីក្នុងអរូបភូមិ មែនពិត ពាក្យនេះត្រាស់ទុកក្នុងបដ្ឋានមហាបករណ៍

ថា នីវរណធម៌អាស្រ័យនូវនីវរណធម៌ ទើបកើតឡើង ព្រោះនបុរេជាតប្បច្ច័យ ដូច្នេះ ។ ពុទ្ធវចនៈទាំងអស់ក្នុងការចែកនៃមហាបករណ៍ យ៉ាងនេះថា ថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈ អាស្រ័យនូវកាមច្ឆន្ទនីវរណៈ ក្នុងអរូប ដូច្នេះ ។ គប្បីឲ្យពិស្តារ ព្រោះហេតុនោះ ក្នុងអធិការនេះ គប្បីដល់នូវសេចក្តីយល់ព្រមថា មិទ្ធៈជាអរូបប៉ុណ្ណោះ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងកុក្កុច្ចនិទ្ទេស ដូចតទៅនេះថា

បទថា **អកប្បិយេ កប្បិយសញ្ញិតា** ជាដើម ត្រាស់ទុកដើម្បីសម្តែងកុក្កុច្ចៈដោយមូល មែនពិត កាលភិក្ខុមានសតិវៀកក្នុងការប្រព្រឹត្តកន្ទង់វត្តនិងអជ្ឈាចារ ដែលធ្វើហើយដោយមានសេចក្តីសម្គាល់យ៉ាងនេះ ក៏ក្តៅក្រហាយក្នុងកាលជាខាងក្រោយយ៉ាងនេះថា អញធ្វើកម្មអាក្រក់ហើយ ដូច្នេះ កុក្កុច្ចៈនេះ រមែងកើតឡើងដោយអំណាចនៃការតាមក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ។ ដោយហេតុនោះ ដើម្បីទ្រង់សម្តែងកុក្កុច្ចៈនោះដោយមូល ទើបត្រាស់ពាក្យជាដើមថា **អកប្បិយេ កប្បិយសញ្ញិតា** ដូច្នេះ ។

ក្នុងព្រះពុទ្ធវចនៈនោះ អធិប្បាយថា ភិក្ខុមានការសម្គាល់ថាគួរ រមែងឆាន់កត្តដែលមិនគួរ មានការសម្គាល់ថាសាច់ដែលគួរ រមែងឆាន់សាច់ដែលមិនគួរ គឺរមែងទំពាស៊ីសាច់ខ្លាឃ្មុំ ដោយសម្គាល់ថាជាសាច់ជ្រូក ឬរមែងទំពាស៊ីសាច់ខ្លាដំបង ដោយសម្គាល់ថាជាសាច់ឈ្លូស វិកាល សម្គាល់ថានៅជាកាល ហាមកត្តហើយសម្គាល់ថាមិនទាន់ហាមកត្ត កាលធូលីធ្លាក់ចូលក្នុងបាត្រ រមែងឆាន់ដោយសម្គាល់ថាទទួលប្រគេនហើយ យ៉ាងនេះឈ្មោះថា

ប្រព្រឹត្តកន្លងដោយសម្គាល់ថាគួរក្នុងរបស់មិនគួរ ។ ភិក្ខុកាលឆាន់សាច់ជ្រូក ដោយសម្គាល់ថា ជាសាច់ខ្លាឃ្មុំ និងឆាន់កត្តក្នុងកាល ដោយសម្គាល់ថា វិកាល ឈ្មោះថា ប្រព្រឹត្តកន្លងដោយការសម្គាល់ថា មិនគួរក្នុងរបស់គួរ ។

មួយទៀត វត្ថុខ្លះមិនមានទោស ភិក្ខុធ្វើដោយសម្គាល់ថាមានទោស និង ដែលមានទោសធ្វើដោយសម្គាល់ថា មិនមានទោស ឈ្មោះថា ប្រព្រឹត្តកន្លង ដោយសម្គាល់ថា ជាទោសក្នុងរបស់មិនមែនទោស ដោយសម្គាល់ថាមិនជា ទោស ក្នុងរបស់ជាទោស ។ ព្រោះកុក្កុច្ចៈនេះកើតឡើង ព្រោះការប្រព្រឹត្ត កន្លង ដែលធ្វើហើយ ដោយសម្គាល់ថា មានទោសក្នុងរបស់ដែលមិនមាន ទោស យ៉ាងនេះថា អំពើល្អអញមិនបានធ្វើហើយហ្ន៎ កុសលអញនៅមិន ទាន់បានធ្វើ គ្រឿងការពាររបស់បុរសក្លៀវក្លា អញនៅមិនទាន់បានធ្វើហ្ន៎ បាបអញធ្វើហើយហ្ន៎ សេចក្តីអាក្រក់អញបានធ្វើហើយ សេចក្តីប្រទូស្តអញ បានធ្វើហើយ ដូច្នេះ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់ប្រារព្ធវត្ថុ ដទៃនៃកុក្កុច្ចៈនោះទើបត្រាស់ថា **យំ ឯវរូបំ** ដូច្នេះជាដើម ។ ក្នុងអធិការនេះ បទថា **កុក្កុច្ចំ** មានអត្ថដូចពោលហើយនោះឯង ។ អាការនៃការរង្កៀស ឈ្មោះថា **កុក្កុច្ចាយនា** ។ ភាវៈនៃធម៌ដែលកុក្កុច្ចៈឲ្យប្រព្រឹត្តទៅហើយ ឈ្មោះ ថា **កុក្កុច្ចាយិតត្តំ** ។

ក្នុងបទថា **ចេតសោ វិប្បដិសារោ** នេះ សេចក្តីថា ការប្រឈមមុខ ចំពោះកម្មដែលធ្វើហើយ និងមិនទាន់ធ្វើ ឬប្រឈមមុខចំពោះវត្ថុដែលមាន ទោស និងមិនមានទោស ឈ្មោះថា **វិប្បដិសារោ** ។ ព្រោះការរឭកដែល

ខុសប្រក្រតី ឬដែលគួររង្កៀសព្រោះមិនធ្វើបាបដែលធ្វើហើយឲ្យជាបាបដែលមិនបានធ្វើ ឬមិនធ្វើសេចក្ដីល្អ ដែលមិនទាន់បានធ្វើហើយឲ្យជាសេចក្ដីដែលធ្វើហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **វិប្បដិសារោ** ។ មួយទៀតដើម្បីឲ្យជ្រាបថា វិប្បដិសារនោះជារបស់ចិត្ត មិនមែនរបស់សត្វទើបត្រាស់ថា **ចេតសោ វិប្បដិសារោ** ដូច្នេះ ។ សេចក្ដីនេះជាការអធិប្បាយសភាវៈរបស់កុក្កុច្ចៈនោះ ។

កុក្កុច្ចៈកាលកើតឡើង រមែងកើតឡើងពុះវះនូវចិត្តដូចចុងដែកស្រួចធូតភាជនសំរឹទ្ធិទុំះឯង ព្រោះហេតុនោះ ទើបត្រាស់ថា **មនោវិលេខោ** សេចក្ដីនេះអធិប្បាយកិច្ចរបស់កុក្កុច្ចៈនោះ ។ ចំណែកកុក្កុច្ចៈណាដែលត្រាស់ទុកក្នុងព្រះវិន័យថា ព្រះសារីបុត្តដ៏មានអាយុ មានសេចក្ដីសង្ស័យថា ការដែលនៅត្រាំត្រែង ឆាន់បិណ្ឌបាតក្នុងផ្ទះសម្នាក់ ឬរោងទាន ព្រះដ៏មានព្រះភាគបានហាមហើយ ដូច្នេះ កុក្កុច្ចៈនោះមិនមែនជានីវរណៈព្រោះព្រះអរហន្តមិនមានសេចក្ដីក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយថា វត្ថុនេះ អញធ្វើខុសហើយ ដូច្នេះ ឈ្មោះថា **កុក្កុច្ច** ក្នុងព្រះវិន័យ ពោលគឺការពិចារណានេះថា វត្ថុនេះគួរ វត្ថុនេះមិនគួរ ជានីវរណបដិរូបកៈ ( ស្រដៀងគ្នានឹងនីវរណៈ ) ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃបទថា **កតមេ ធម្មា នីវរណា ចេវ នីវរណសម្បយុត្តា ច** ដូចតទៅនេះថា ព្រោះថីនៈនិងមិទ្ធៈ រមែងមិនបែកគ្នា ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ដោយមិនបែងចែកថា ថីន-មិទ្ធនីវរណៈជានីវរណៈផង ប្រកបដោយនីវរណៈផង ដោយអវិជ្ជានីវរណៈ

ដូច្នេះ ។ តែព្រោះឧទ្ធច្ចៈសូម្បីវៀរចាកកុក្កុច្ចៈក៏កើតឡើងបាន ព្រោះកាលមានឧទ្ធច្ចៈ មិនចាំបាច់មានកុក្កុច្ចៈក៏បាន ហេតុនោះទើបត្រាស់ញែកឧទ្ធច្ចៈនោះទុក ។ម្យ៉ាងទៀត នីវរណៈណា មិនដល់ការប្រកបចូលនឹងនីវរណៈណា គប្បីជ្រាបថា នីវរណៈនោះ ព្រះអង្គទ្រង់មិនបានប្រកបទុក ។

នីវរណៈទាំងនេះគួរនាំមកពោលតាមលំដាប់នៃកិលេសខ្លះ តាមលំដាប់នៃមគ្គខ្លះ ។ ពោលដោយលំដាប់នៃកិលេស កាមច្ឆន្ទនីវរណៈនិងព្យាបាទ-នីវរណៈដែលអនាគាមិមគ្គរមែងលះ ថីនមិទ្ធនីវរណៈនិងឧទ្ធច្ចនីវរណៈដែលអរហត្តមគ្គរមែងលះ កុក្កុច្ចនីវរណៈនិងវិចិកិច្ឆានីវរណៈដែលសោតាបត្តិមគ្គរមែងលះ អវិជ្ជានីវរណៈដែលអរហត្តមគ្គរមែងលះ ពោលដោយលំដាប់នៃមគ្គ សោតាបត្តិមគ្គលះកុក្កុច្ចនីវរណៈនិងវិចិកិច្ឆានីវរណៈ អនាគាមិមគ្គលះកាមច្ឆន្ទនីវរណៈនិងព្យាបាទនីវរណៈ អរហត្តមគ្គលះថីនមិទ្ធនីវរណៈ ឧទ្ធច្ច-នីវរណៈ និងអវិជ្ជានីវរណៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបរាមាសគោច្ឆកៈ ដូចតទៅនេះថា

បទថា **តេ ធម្មេ ឋបេត្វា** អធិប្បាយថា ទ្រង់ធ្វើឲ្យជាពហុវចនៈដោយស្មើជាមួយនឹងពាក្យសួរ ។

# អភិធម្មបិដក

## ឧបាទានគោច្ឆក

[ ២៨០ ] ពួកធម៌ជាឧបាទាន ( សេចក្តីប្រកាន់មាំ ) តើដូចម្តេច ។ ឧបាទាន ៤ គឺកាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ។

[ ២៨១ ] បណ្តាឧបាទានទាំងនោះ កាមុបាទាន តើដូចម្តេច ។ សេចក្តីប្រាថ្នាចំពោះកាម ការត្រេកអរចំពោះកាម ការរីករាយចំពោះកាម ការអន្ទះសាចំពោះកាម សេចក្តីស្រឡាញ់ចំពោះកាម ការរោលរាលចំពោះកាម ការជ្រុលជ្រប់ចំពោះកាម ការជ្រុលងប់ចំពោះកាមណា ក្នុងកាមទាំងឡាយ នេះហៅថា កាមុបាទាន ។

[ ២៨២ ] បណ្តាឧបាទានទាំងនោះ ទិដ្ឋុបាទាន តើដូចម្តេច ។ ការយល់ថា ទានដែលបានឲ្យហើយមិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អ ឬធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឧបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោកជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងហើយសម្តែងប្រាប់បានក៏មិនមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ច្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តី

ប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋុ-បាទាន ។ លើកលែងតែសីលព្វតុបាទាន និងអត្តវាទុបាទានចេញ សូម្បី មិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋុបាទានដែរ ។

[ ២៨៣ ] បណ្តាឧបាទានទាំងនោះ សីលព្វតុបាទាន តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅអំពីសាសនានេះ ( ប្រកាន់ថា ) សេចក្តី បរិសុទ្ធដោយសីល បរិសុទ្ធិដោយវត្ត បរិសុទ្ធិដោយសីលនិងវត្ត និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញាតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ ឆ្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅ ថា សីលព្វតុបាទាន ។

[ ២៨៤ ] បណ្តាឧបាទានទាំងនោះ អត្តវាទុបាទាន តើដូចម្តេច ។ បុ-ថុជ្ជន ជាអ្នកមិនចេះដឹងក្នុងលោកនេះ មិនធ្លាប់ឃើញពួកព្រះអរិយៈ មិនឈ្លាស វៃក្នុងអរិយធម៌ មិនទូន្មានខ្លួនក្នុងអរិយធម៌ មិនធ្លាប់ឃើញពួកសប្បុរស មិន ឈ្លាសវៃក្នុងសប្បុរិសធម៌ មិនទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងយល់ឃើញ រូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថា មានក្នុងរូបខ្លះ ឃើញវេទនាថាជាខ្លួន ឃើញខ្លួនថាមានវេទនាខ្លះ ឃើញ វេទនាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវេទនាខ្លះ ឃើញសញ្ញាថាជាខ្លួន ឃើញខ្លួនថាមានសញ្ញាខ្លះ ឃើញសញ្ញាថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមាន

ក្នុងសញ្ញាខ្លះ ឃើញសង្ខារថាជាខ្លួន ឃើញខ្លួនថាមានសង្ខារខ្លះ ឃើញសង្ខារថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងសង្ខារខ្លះ ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃញៀតស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ច្រេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្តីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា អត្តវាទុបាទាន ។

## នេះពួកធម៌ជាឧបាទាន ។

[ ២៨៥ ] ពួកធម៌មិនមែនជាឧបាទាន តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាឧបាទាន ។

[ ២៨៦ ] ពួកធម៌ជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនជាប្រយោជន៍ដល់ឧបាទាន ។

[ ២៨៧ ] ពួកធម៌ប្រកបដោយឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកឧបាទាន ។

[ ២៨៨ ] ពួកធម៌ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង តើដូចម្តេច ។ ឧបាទានទាំងនោះឯងជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ។ ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទានតែមិនមែនជាឧបាទាន តើដូចម្តេច ។ ពួកធម៌ណាជាប្រយោជន៍ដល់ឧបាទាន ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ រូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ។

[ ២៨៩ ] ពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង តើដូចម្តេច ។ ទិដ្ឋុបាទានជាឧបាទានផង ប្រកបដោយឧបាទានផង ដោយកាមុបាទាន កាមុបាទានជាឧបាទានផង ប្រកបដោយឧបាទានផង ដោយទិដ្ឋុបាទាន សីលព្វតុបាទានជាឧបាទានផង ប្រកបដោយឧបាទានផង ដោយកាមុបាទាន កាមុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយសីលព្វតុបាទាន អត្តវាទុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយកាមុបាទាន

កាមុបាទាន ជាឧបាទានផង ប្រកបដោយឧបាទានផង ដោយអត្តវាទុបាទាន នេះពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង ។ ពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទាន ។

[ ២៩០ ] ពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង ។

# អដ្ឋកថា

## ឧបាទានគោច្ឆកៈ

[ ២៨០-២៩០ ] គប្បីជ្រាបវិគ្គហៈក្នុងនិទ្ទេសនៃឧបាទាន ដូចតទៅនេះថា ដែលឈ្មោះថា **កាមុបាទាន** ព្រោះអត្ថថា រមែងប្រកាន់មាំនូវកាម ពោលគឺវត្ថុ ។ កាមនោះផង ជាឧបាទានផង ព្រោះហេតុនោះទើបឈ្មោះថា **កាមុ-បាទាន** ។

បទថា **ឧបាទានំ** បានដល់ សេចក្តីប្រកាន់មាំ ។ ព្រោះ **ឧប** សព្ទក្នុងពាក្យនេះមានអត្ថថា មាំ ដូចក្នុងពាក្យទាំងឡាយមាន **ឧបាយាស** ( សេចក្តីចង្អៀតចង្អល់ ) **ឧបកដ្ឋ** ( ជិតដល់ហើយ ) ជាដើម ។

មួយទៀត ទិដ្ឋិនោះផង ជាឧបាទានផង ព្រោះហេតុនោះ ទើបឈ្មោះថា **ទិដ្ឋុបាទាន** ឬដែលឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះអត្ថថា រមែងប្រកាន់មាំនូវទិដ្ឋិ ។ ពិតណាស់ ទិដ្ឋិក្រោយរមែងប្រកាន់មាំទិដ្ឋិមុន ដូចក្នុងប្រយោគជាដើមថា **សស្សតោ អត្តា ច លោកោ ច** ខ្លួននិងលោក ជាសភាវៈទៀងទាត់ ដូច្នេះ ។ មួយទៀត ដែលឈ្មោះថា **សីលព្វតុបាទាន** ព្រោះអត្ថថា រមែងប្រកាន់មាំនូវសីលនិងវត្ត ។ សីលនិងវត្តនោះផង ជាឧបាទានផង ព្រោះហេតុនោះ ទើបឈ្មោះថា **សីលព្វតុបាទាន** ។ មែនពិត ពាក្យថា គោសីលនិងគោវត្តជាដើមជាឧបាទានឯងនោះឯង ព្រោះប្រកាន់មាំថា សេចក្តីបរិសុទ្ធរមែងមានដោយអាការយ៉ាងនេះ ។ម្យ៉ាងទៀត ឈ្មោះថា **វាទ** ព្រោះអត្ថថា ជាហេតុពោល ។ ដែលឈ្មោះថា **ឧបាទាន** ព្រោះអត្ថថា ជាហេតុប្រកាន់

មាំ ។ សួរថា ពោលឬប្រកាន់មាំនូវអ្វី ឆ្លើយថា ពោលឬប្រកាន់មាំនូវខ្លួន ។ ការពោល និងការប្រកាន់នូវខ្លួន ឈ្មោះថា **អត្តវាទុបាទាន** ។ ម្យ៉ាងវិញទៀត ហេតុត្រឹមតែវាទៈថាជាខ្លួនតែម្យ៉ាង ឈ្មោះថា **អត្តវាទុបាទាន** ព្រោះអត្ថថា ជាហេតុប្រកាន់មាំ ថាជាខ្លួន ។

ក្នុងបទថា **យោ កាមេសុ កាមច្ឆន្ទោ** នេះ ព្រះមានព្រះភាគ ទ្រង់បំណងយកវត្ថុកាមនិងកិលេសកាមទាំងឡាយ ដោយមិនសេសសល់ថា ជាកាម ព្រោះហេតុនោះ សេចក្តីពេញចិត្ត គឺសេចក្តីប្រាថ្នាក្នុងវត្ថុកាមទាំងឡាយ ឈ្មោះថា **កាមុបាទាន** ក្នុងអធិការនេះ ព្រោះហេតុនោះ កាមុបាទាននោះសូម្បីព្រះអនាគាមីក៏នៅមាន តែកាមរាគៈដែលជាទីតាំងរបស់កាមគុណ ៥ នោះឯង រមែងមិនមានដល់ព្រះអនាគាមីនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃទិដ្ឋុបាទាន ដូចតទៅនេះថា

បទថា **នត្ថិ ទិន្នំ** សេចក្តីថា គេរមែងដឹងថា ឈ្មោះថាទានដែលបុគ្គលឲ្យហើយមាន គឺបុគ្គលណាមួយអាចដើម្បីឲ្យរបស់ណាមួយ ដល់បុគ្គលណាមួយក៏បាន តែរមែងយល់ថា ផលវិបាករបស់ទានមិនមាន ។ បទថា **នត្ថិ យិដ្ឋំ** សេចក្តីថា ការបូជាធំ ត្រាស់ហៅថា **យិដ្ឋំ** គឺរមែងដឹងថា ការបូជានោះ បុគ្គលណាមួយអាចបូជាបាន តែរមែងយល់ថា ផលវិបាករបស់ការបូជាមិនមាន ។ បទថា **នត្ថិ ហុតំ** សេចក្តីថា ការនាំរបស់មកប្រគេន ការទទួលភ្ញៀវនិងការឲ្យដើម្បីជាមង្គល រមែងដឹងថា ការបូជាតូចនោះ បុគ្គលណាមួយក៏អាចធ្វើបាន តែរមែងយល់ថា ផលវិបាកនៃការបូជាតូចនោះ មិន

មាន ។ ក្នុងបទថា **ឆិន្ន សុកតទុក្កដានំ** នេះ កុសលកម្មបថ ១០ ឈ្មោះ ថា កម្មដែលធ្វើល្អ អកុសលកម្មបថ ១០ ឈ្មោះថា កម្មដែលធ្វើអាក្រក់ ។ បុគ្គលរមែងដឹងដល់ភាវៈនៃកម្មល្អ កម្មអាក្រក់ទាំងនោះមាន តែរមែងយល់ ថា ផលវិបាកមិនមាន ។ បទថា **ឆត្ថិ អយំ លោកោ** សេចក្តីថា បុគ្គល ដែលតាំងនៅក្នុងលោកដទៃ រមែងយល់ថា លោកនេះមិនមាន ។ បទថា **ឆត្ថិ បរលោកោ** សេចក្តីថា បុគ្គលដែលតាំងនៅក្នុងលោកនេះ រមែងយល់ ថា លោកដទៃមិនមាន ។ បទថា **ឆត្ថិ មាតា ឆត្ថិ បិតា** សេចក្តីថា បុគ្គល នោះ រមែងដឹងភាពដែលមាតាបិតាមាន តែយល់ថាផលវិបាកណាមួយដោយ បច្ច័យដែលធ្វើហើយក្នុងមាតាបិតាទាំងនោះ មិនមាន ។ បទថា **ឆត្ថិ សត្តា ឱបបាតិកា** សេចក្តីថា បុគ្គលនោះយល់ថា សត្វដែលចុតិនិងបដិសន្ធិ មិន មាន ។ បទថា **សម្មគ្គតា សម្មាបដិបន្នា** សេចក្តីថា បុគ្គលនោះ រមែង យល់ថា សមណៈនិងព្រាហ្មណ៍ អ្នកតាំងនៅក្នុងធម៌ ដែលប្រព្រឹត្តទៅកាន់ អនុលោមប្បដិបទាមិនមានក្នុងលោក ។ បទថា **យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ** សេចក្តីថា រមែងយល់ថា ឈ្មោះថា សព្វញ្ញុពុទ្ធ អ្នកអាចដឹងលោកនេះនិងលោកដទៃ ដោយញាណដ៏ វិសេសក្រៃលែងដោយខ្លួនប៉ុណ្ណោះ ហើយប្រកាសឲ្យអ្នកដទៃដឹងមិនមាន ។

ឧបាទានទាំងនេះ គួរនាំមកពោលតាមលំដាប់កិលេសខ្លះ តាមលំដាប់នៃមគ្គខ្លះ ។ ពោលដោយលំដាប់នៃកិលេស កាមុបាទានដែលមគ្គទាំង ៤ រមែងប្រហារឧបាទាន ៣ ដ៏សេសដែលសោតាបត្តិមគ្គ រមែងប្រហារ ។ ពោលដោយលំដាប់នៃមគ្គសោតាបត្តិមគ្គរមែងប្រហារទិដ្ឋុបាទានជាដើម មគ្គទាំង ៤ រមែងប្រហារកាមុបាទាន ។

# អភិធម្មបិដក

## កិលេសគោច្ឆក

[ ២៩១ ] ពួកធម៌ជាកិលេស ( គ្រឿងសៅហ្មង ) តើដូចម្តេច ។ កិលេសវត្ថុ ១០ គឺលោភៈ ទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ ។

[ ២៩២ ] បណ្តាកិលេសវត្ថុទាំងនោះ លោភៈ តើដូចម្តេច ។ តម្រេក ការត្រេកអរខ្លាំង ការជាប់ចំពាក់ ក្នុងអារម្មណ៍ ការស្រើបស្រាល ការរីករាយ ការរីករាយខ្លាំង តម្រេកខ្លាំងនៃចិត្ត សេចក្តីប្រាថ្នា ការជ្រុលជ្រប់ ការងុលងប់ចិត្ត ការពាក់ព័ន្ធ ការរួបរឹត ការជាប់ចំពាក់ ការលិចចុះ ធម្មជាតិនាំសត្វឲ្យកើតក្នុងភព មាយា ធម្មជាតិបង្កើតសត្វ ការញុំាងសត្វឲ្យប្រកបដោយទុក្ខ ធម្មជាតិចាក់ស្រែះសត្វទុក បណ្តាញ ការបង្ហូរទៅ ការផ្សាយទៅកាន់អារម្មណ៍ផ្សេងៗ ចំណងចងសត្វទុក ការផ្សាយទៅកាន់អារម្មណ៍ ធម្មជាតិញុំាងសត្វឲ្យបម្រើន ធម្មជាតិជាគម្រប់ ២ ការតាំងចិត្តទុក ធម្មជាតិនាំសត្វទៅកាន់ភព ធម្មជាតិដូចជាព្រៃ ដូចព្រៃញាតស្បាត ការមូលមិត្ត សេចក្តីស្រឡាញ់ ការអាឡោះអាល័យ ផៅពង្សត្រទៅ សេចក្តីប៉ុនប៉ង អាការប៉ុនប៉ង ភាពនៃចិត្តប៉ុនប៉ង ការប៉ុនប៉ងរូប ប៉ុនប៉ងសំឡេង ប៉ុនប៉ងក្លិន ប៉ុនប៉ងរស ប៉ុនប៉ងផ្សព្វ ប៉ុនប៉ងលាភ ប៉ុនប៉ងទ្រព្យ ប៉ុនប៉ងបុត្ត ប៉ុនប៉ងជីវិត ធម្មជាតិច្ចេច្ឆា ច្ចេច្ឆាជ្រុល ច្ចេច្ឆាខ្លាំង សេចក្តីច្ចេច្ឆា អាការច្ចេច្ឆា ភាពនៃចិត្តច្ចេច្ឆា ការរុលត្បុល អាការប្រព្រឹត្តរុលត្បុល ភាពនៃចិត្តរុលត្បុល

ការញាប់ញ័រ ការចង់បានឲ្យសម្រេចប្រយោជន៍ ការត្រេកអរខុសទំនងធម៌ ការលោភហួសកំណត់ ការត្រេកត្រអាល ការចង់បានមិនឈប់ សេចក្តីប្រាថ្នា សេចក្តីស្រឡាញ់ សេចក្តីប្រាថ្នាព្រម សេចក្តីប្រាថ្នាក្នុងកាម ប្រាថ្នាភព ប្រាថ្នាប្រាសចាកភព ប្រាថ្នាក្នុងរូបភព ប្រាថ្នាក្នុងអរូបភព ប្រាថ្នាក្នុងនិរោធ ប្រាថ្នារូប ប្រាថ្នាសំឡេង ប្រាថ្នាក្លិន ប្រាថ្នារស ប្រាថ្នាផ្សព្វ ប្រាថ្នាធម៌ កិលេសដូចជាជំនន់ គ្រឿងប្រកប គ្រឿងចងក្រង គ្រឿងប្រកាន់មាំ គ្រឿងរារាំងទូទៅ គ្រឿងរារាំងមិនសល់ គ្រឿងបិទបាំង គ្រឿងចង គ្រឿងចូលទៅជិតសៅហ្មង គ្រឿងស្ទាក់ដំណើរ តណ្ហាដូចជាវល្លិ ប្រាថ្នាផ្សេងៗ ឫសគល់នៃទុក្ខ ហេតុនៃទុក្ខ ហេតុជាដែនកើតនៃទុក្ខ អន្ទាក់នៃមារ នុយនៃមារ អារម្មណ៍នៃមារ ស្ទឹងគឺតណ្ហា បណ្តាញគឺតណ្ហា ខ្នោះគឺតណ្ហា សមុទ្រគឺតណ្ហា ការសម្លឹងរំពៃ សេចក្តីជាប់ចំពាក់ជាអកុសលមូលណា នេះហៅថា លោភៈ ។

[ ២៩៣ ] បណ្តាកិលេសវត្ថុទាំងនោះ ទោសៈតើដូចម្តេច ។ គំនុំកើតឡើងថា ជនឯណោះបានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះកំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់អញ គំនុំកើតឡើងថា ជនឯណោះនឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់អញ គំនុំកើតឡើងថា ជនឯណោះ បានប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីពេញចិត្តនៃអញ ។បេ។ កំពុងប្រព្រឹត្តនូវកម្មមិនជាប្រយោ-ជន៍ ។បេ។ នឹងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ គំនុំកើតឡើងថា ជនឯណោះ

បាន ប្រព្រឹត្តនូវកម្មជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីពេញចិត្តនៃអញ ។បេ។ កំពុងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ។បេ។ នឹងប្រព្រឹត្តនូវកម្មជាប្រយោជន៍ ឬគំនុំកើតឡើង ក្នុងហេតុមិនគួរ និងការគុំកួននៃចិត្ត ការគុំកួនតប សេចក្តីថ្នាំងថ្នាក់ ការទឹងតប ការទឹងញ៉រ ការក្រោធខ្លាំង ការក្រោធញ៉រ ការប្រទូស្ត ការប្រទូស្តតប ការប្រទូស្តគ្រប់យ៉ាង ការខូចនៃចិត្ត ការប្រទុស្តនៃចិត្ត ការក្រោធ ការទឹង ភាពនៃចិត្តទឹង សេចក្តីប្រទូស្ត អាការប្រទូស្ត ភាពនៃចិត្តប្រទូស្ត សេចក្តីវិនាស អាការវិនាស ភាពនៃចិត្តវិនាស ការទឹង ការទឹងតប ភាពនៃចិត្តកាច ការទឹង ការតូចចិត្តណាដែលមានសភាពបែបនេះ នេះហៅថា ទោសៈ ។

[ ២៩៤ ] បណ្តាកិលេសវត្ថុទាំងនោះ មោហៈ តើដូចម្តេច ។ ការមិនដឹងច្បាស់ក្នុងទុក្ខ មិនដឹងច្បាស់ក្នុងទុក្ខសមុទ័យ មិនដឹងច្បាស់ក្នុងទុក្ខនិរោធ មិនដឹងច្បាស់ក្នុងទុក្ខនិរោធគាមិនីបដិបទា មិនដឹងច្បាស់ក្នុងខន្ធ ជាចំណែកខាងដើម មិនដឹងច្បាស់ក្នុងខន្ធជាចំណែកខាងចុង មិនដឹងច្បាស់ក្នុងខន្ធទាំងចំណែកខាងដើមនិងខាងចុង មិនដឹងច្បាស់ក្នុងពួកធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងការមិនដឹងច្បាស់ ការមិនឃើញ ការមិនត្រាស់ដឹង ការមិនភ្ញាក់រឭក ការមិនត្រាស់ដឹងព្រម ការមិនចាក់ធ្លុះ ការមិនបានដោតក្រងទុក ការមិនចុះចិត្តស៊ប់ ការមិនរំពឹងមើល ការមិនបានពិចារណាអំពើមិនជាក់ច្បាស់ ការយល់បានដោយក្រ ភាពនៃសេចក្តីល្ងង់ ការមិនដឹងខ្លួន ការវង្វេង ការវង្វេងជ្រប់ ការភ្លេចភ្លាំង អវិជ្ជា ជំនន់គឺអវិជ្ជា ការ

ប្រកបគឺអវិជ្ជា អនុស័យគឺអវិជ្ជា ការស្ទាត់ជំពាក់គឺអវិជ្ជា គន្ទឹះគឺអវិជ្ជា ការវង្វេងជាអកុសលមូលណាដែលមានសភាពបែបនេះ នេះហៅថា មោហៈ ។

[ ២៩៥ ] បណ្ដាកិលេសវត្ថុទាំងនោះ មានះតើដូចម្ដេច ។ សេចក្ដីប្រកាន់ថា អញប្រសើរ ( ជាងគេ ) ប្រកាន់ថា អញស្មើ ( នឹងគេ ) ប្រកាន់ថា អញថោកទាប ( ជាងគេ ) សេចក្ដីប្រកាន់ អាការប្រកាន់ ភាពនៃចិត្តប្រកាន់ ការលើកខ្លួន ការប៉ោងឡើង អាការដូចទង់ជ័យ ការតម្កើងភាពនៃចិត្តប្រាថ្នាដូចដងទង់ណាដែលមានសភាពបែបនេះ នេះហៅថា មានះ ។

[ ២៩៦ ] បណ្ដាកិលេសវត្ថុទាំងនោះ ទិដ្ឋិ តើដូចម្ដេច ។ ( ការយល់ ) ថាលោកទៀងក្ដី ថាលោកមិនទៀងក្ដី ថាលោកមានទីបំផុតក្ដី ថាលោកមិនមានទីបំផុតក្ដី ថាជីវិតនោះ គឺសរីរៈនោះក្ដី ថាជីវិតដទៃ សរីរៈដទៃក្ដី ថាសត្វស្លាប់ទៅកើតទៀតក្ដី ថាសត្វស្លាប់ទៅមិនកើតទៀតក្ដី ថាសត្វស្លាប់ទៅកើតទៀតក៏មាន មិនកើតទៀតក៏មានក្ដី ថាសត្វស្លាប់ទៅកើតទៀតក៏មិនមែនមិនកើតទៀតក៏មិនមានក្ដី ទិដ្ឋិ ដំណើរគឺទិដ្ឋិ ព្រៃស្បាតគឺទិដ្ឋិ ផ្លូវឆ្ងាយគឺទិដ្ឋិ ចម្រូងគឺទិដ្ឋិ ការយល់ឆ្វេងគឺទិដ្ឋិ ការជាប់ចំពាក់គឺទិដ្ឋិ ការក្តួចកាន់ ការប្រកាន់ ការប្រកាន់ខ្ជាប់ ការស្ទាបអង្អែល ផ្លូវអាក្រក់ ផ្លូវខុស ភាពនៃចិត្តខុស លទ្ធិដូចជាកំពង់ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ទិដ្ឋិ ។ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា ទិដ្ឋិដែរ ។

[ ២៩៧ ] បណ្ដាកិលេសវត្ថុទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ បុគ្គលងឿងឆ្ងល់សង្ស័យចំពោះព្រះសាស្ដា ងឿងឆ្ងល់សង្ស័យចំពោះព្រះធម៌ ងឿង

ឆ្ងល់សង្ស័យចំពោះព្រះសង្ឃ ងឿងឆ្ងល់សង្ស័យចំពោះសិក្ខា ងឿងឆ្ងល់សង្ស័យចំពោះខន្ធ ជាចំណែកខាងដើម ងឿងឆ្ងល់សង្ស័យចំពោះខន្ធ ជាចំណែកខាងចុង ងឿងឆ្ងល់សង្ស័យចំពោះខន្ធ ទាំងជាចំណែកខាងដើម និងខាងចុង ។ ងឿងឆ្ងល់សង្ស័យចំពោះធម៌ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យនោះៗ និងសេចក្តីងឿងឆ្ងល់ អាការងឿងឆ្ងល់ ភាពនៃសេចក្តីងឿងឆ្ងល់ ការយល់ស្មុគស្មើរ ការសង្ស័យ ការបែកចិត្តជាចំពាមពីរ ការបែកជាផ្លូវពីរ ការកន្ទះរា ការប្រកាន់យកចំណែកដ៏ច្រើន ការសាញប្រដាញ ការសាន់វាន់ចិត្ត ការប្រកាន់មិនដាច់ស្រេច ភាពនៃចិត្តរីងរូស ការសេមរសាមនៃចិត្តណាដែលមានសភាពបែបនេះ នេះហៅថា វិចិកិច្ឆា ។

[ ២៩៨ ] បណ្តាកិលេសវត្ថុទាំងនោះ ថីនៈ តើដូចម្តេច ។ ភាពនៃចិត្តមិនស្រួល មិនគួរដល់ការងារ ការជ្រប់នៅ ការសម្ងំនៅ សេចក្តីរួញរាអាការរួញរា ភាពនៃចិត្តរួញរា សេចក្តីធុញទ្រាន់ អាការធុញទ្រាន់ ភាពនៃចិត្តធុញទ្រាន់ណា នេះហៅថា ថីនៈ ។

[ ២៩៩ ] បណ្តាកិលេសវត្ថុទាំងនោះ ឧទ្ធច្ចៈ តើដូចម្តេច ។ ភាពនៃចិត្តរវើរវាយ ការមិនស្ងប់រម្ងាប់ ការរាយមាយនៃចិត្ត ការក័ន្តកាំងនៃចិត្តណា នេះហៅថា ឧទ្ធច្ចៈ ។

[ ៣០០ ] បណ្តាកិលេសវត្ថុទាំងនោះ អហិរិកៈ តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនខ្មាសដោយអំពើដែលគួរខ្មាស មិនខ្មាសដោយការគប់ប្រសព្វនូវអកុសលធម៌ដ៏លាមក នេះហៅថា អហិរិកៈ ។

[ ៣០១ ] បណ្ដាកិលេសវត្ថុទាំងនោះ អនោត្តប្បៈ តើដូចម្ដេច ។ ត្រង់ដែលបុគ្គលមិនតក់ស្លុត ដោយអំពើដែលគួរតក់ស្លុត មិនតក់ស្លុតដោយការកប់ប្រសព្វនូវអកុសលធម៌ដ៏លាមក នេះហៅថា អនោត្តប្បៈ ។

## នេះពួកធម៌ជាកិលេស ។

[ ៣០២ ] ពួកធម៌មិនមែនកិលេស តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មិនមែនជាកិលេស ។

[ ៣០៣ ] ពួកធម៌គួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គួរដល់សេចក្ដីសៅហ្មង ។ ពួកធម៌មិនគួរដល់សេចក្ដីសៅហ្មង តើដូចម្ដេច ។ មគ្គ ជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនគួរដល់សេចក្ដីសៅហ្មង ។

[ ៣០៤ ] ពួកធម៌ដែលសៅហ្មង តើដូចម្ដេច ។ អកុសលមូល ៣ យ៉ាង គឺលោភៈ ទោសៈ មោហៈ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងអកុសលមូល មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយអកុសលមូល មានលោភៈជាដើមនោះ និងកាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីអកុសលមូល មានលោភៈជាដើមនោះ នេះពួកធម៌ដែលសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង តើដូចម្ដេច ។ ពួកធម៌ជា

កុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនា-ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ដែលមិនសៅហ្មង ។

[ ៣០៥ ] ពួកធម៌ប្រកបដោយកិលេស តើដូចម្ដេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ និងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយកិលេស ។ ពួកធម៌ប្រាសចាកកិលេស តើដូចម្ដេច ។ ពួកធម៌ណា ប្រាសចាកធម៌ទាំងនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ប្រាសចាកកិលេស ។

[ ៣០៦ ] ពួកធម៌ជាកិលេសផង គួរដល់សេចក្ដីសៅហ្មងផង តើដូចម្ដេច ។ កិលេសទាំងនោះឯងជាកិលេសផង គួរដល់សេចក្ដីសៅហ្មងផង ។ ពួកធម៌គ្រាន់តែគួរដល់សេចកក្ដីសៅហ្មង តែមិនមែនកិលេស តើដូចម្ដេច ។ ពួកធម៌ណាគួរដល់សេចក្ដីសៅហ្មង ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ប្រកបដោយអាសវៈ ជាកុសល អកុសល និងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញា-ណក្ខន្ធ នេះពួកធម៌គ្រាន់តែគួរដល់សេចក្ដីសៅហ្មង តែមិនមែនជាកិលេស ។

[ ៣០៧ ] ពួកធម៌ជាកិលេសផង សៅហ្មងផង តើដូចម្ដេច ។ កិលេសទាំងនោះឯង ជាកិលេសផង សៅហ្មងផង ។ ពួកធម៌គ្រាន់តែសៅហ្មង តែមិនមែនកិលេស តើដូចម្ដេច ។ ពួកធម៌ណាសៅហ្មង ដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញនិងវេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់

តែសៅហ្មង តែមិនមែនកិលេស ។

[ ៣០៨ ] ពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង តើដូចម្ដេច ។ លោភៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មានះជាកិលេសផង ប្របកដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមានះ ទិដ្ឋិជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិ-លេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆាជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិ-លេសផង ដោយវិចិកិច្ឆា ថីនៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផងដោយអហិរិកៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ លោភៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈជា

កិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មានះជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមានះ ទិដ្ឋិជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆាជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ លោភៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មានះជាកិលេសផង ប្រកបដោយកិលេស

ផងដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមានះ ទិដ្ឋិជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយទិដ្ឋិ វិចិកិច្ឆាជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិ-រិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ លោភៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយលោភៈ ទោសៈជាកិលេសផង ប្រកបដោយកិ-លេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយទោសៈ មោហៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈ ជាកិលេសផង ប្រកបដោយកិលេសផង ដោយមោហៈ មានះជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយមានះ ទិដ្ឋិជាកិ-លេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផងដោយទិដ្ឋិ វិចិកិច្ឆាជាកិលេសផង ប្រកបដោយ

កិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយវិចិកិច្ឆា ថីនៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយថីនៈ ឧទ្ធច្ចៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយឧទ្ធច្ចៈ អហិរិកៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអនោត្តប្បៈ អនោត្តប្បៈជាកិលេសផង ប្រកបដោយកិលេសផង ដោយអហិរិកៈ នេះពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង ។ ពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស តើដូចម្តេច ។ ពួកធម៌ណា ប្រកបដោយធម៌ទាំងនោះ វៀរតែធម៌ទាំងនោះចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស ។

[ ៣០៩ ] ពួកធម៌ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ ពួកធម៌ណាប្រាសចាកធម៌ទាំងនោះ ពួកធម៌ប្រកបដោយអាសវៈ ជាកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មង ។ ពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់សេចក្តីសៅហ្មងផង តើដូចម្តេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់សេចក្តីសៅហ្មងផង ។

# អដ្ឋកថា
# កិលេសគោច្ឆក

[ ២៩១-៣០៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងកិលេសគោច្ឆកៈ ដូចតទៅនេះថា

កិលេសនោះឯង ឈ្មោះថា កិលេសវត្ថុ ។ ម្យ៉ាងទៀត ដែលឈ្មោះថា វត្ថុ ព្រោះអត្ថថា ជាទីនៅរបស់សត្វ អ្នកមានអាសវៈនៅមិនទាន់អស់ ព្រោះសត្វទាំងនោះតាំងនៅក្នុងកិលេស មានលោភៈជាដើម ។ ដែលឈ្មោះថា កិលេសវត្ថុ ព្រោះអត្ថថា កិលេសទាំងនោះផង ជាវត្ថុរបស់សត្វដែលតាំងនៅក្នុងកិលេសទាំងនោះផង ។ ព្រោះកិលេសទាំងឡាយ កាលកើតឡើងដោយភាពជាអនន្តរប្បច្ច័យជាដើម ឈ្មោះថា រមែងនៅក្នុងកិលេសដែលជាបច្ច័យនេះឯង ហេតុនោះ ទើបឈ្មោះថា កិលេសវត្ថុ សូម្បីដោយអត្ថថា ជាវត្ថុ ( ទីតាំង ) របស់កិលេសទាំងឡាយ ។

លោកៈនេះថា **តត្ថ កតមោ លោភោ យោ រាគោ សារាគោ** ដូច្នេះ ទ្រង់ពង្រីកចេញជាងមួយរយបទ ក្នុងឋានៈទាំង ៣ គឺហេតុគោច្ឆកៈ គន្ថ-គោច្ឆកៈនិងក្នុងកិលេសគោច្ឆកៈនេះ ។ ទ្រង់អធិប្បាយទុកក្នុងអាសវគោច្ឆកៈ សញ្ញោជនគោច្ឆកៈ ឱឃគោច្ឆកៈ យោគគោច្ឆកៈ នីវរណគោច្ឆកៈនិងឧបា-ទានគោច្ឆកៈ គោច្ឆកៈនីមួយៗ ៨ បទ ។ លោកៈនេះបណ្ឌិតគប្បីជ្រាបថា ទ្រង់កាន់យកដោយមិនមានសេសសល់ ក្នុងឋានៈដែលទ្រង់ចម្អលបង្ហាញទុកជាងមួយរយបទខ្លះ ក្នុងឋានៈដែលទ្រង់ចម្អលបង្ហាញទុកគោច្ឆកៈនីមួយៗ ៨ បទខ្លះ នៅក្នុងហេតុគោច្ឆកៈ គន្ថគោច្ឆកៈ នីវរណគោច្ឆកៈ ឧបាទានគោច្ឆកៈ

និងកិលេសគោច្ឆកៈទាំងនោះ តណ្ហាដែលមគ្គទាំង ៤ គប្បីសម្លាប់តាំងនៅមួយចំណែកប៉ុណ្ណោះ ក្នុងអាសវគោច្ឆកៈ សញ្ញោជនគោច្ឆកៈ ឱឃគោច្ឆកៈ និងយោគគោច្ឆកៈ តណ្ហាដែលមគ្គទាំង ៤ គប្បីសម្លាប់តាំងនៅ ២ ចំណែក សេចក្តីនេះដូចម្តេច សេចក្តីថា ក្នុងអាសវគោច្ឆកៈជាកាមាសវៈនិងភវាសវៈ ក្នុងសញ្ញោជនគោច្ឆកៈ ជាកាមរាគសញ្ញោជនៈ និងភវរាគសញ្ញោជនៈ ក្នុងឱឃគោច្ឆក ជាកាមោឃៈនិងភវោឃៈ ក្នុងយោគគោច្ឆកៈ ជាកាមយោគៈនិងភវយោគៈ ។

កិលេសវត្ថុទាំងនេះ គួរនាំមកតាមលំដាប់កិលេសខ្លះ តាមលំដាប់មគ្គខ្លះ ។ ពោលដោយលំដាប់កិលេស លោភៈដែលមគ្គទាំង ៤ រមែងប្រហារ ទោសៈដែលអនាគាមិមគ្គ រមែងប្រហារ មោហៈនិងមានៈដែលអរហត្តមគ្គរមែងប្រហារ ទិដ្ឋិនិងវិចិកិច្ឆាដែលសោតាបត្តិមគ្គរមែងប្រហារ ថីនៈជាដើមដែលអរហត្តមគ្គរមែងប្រហារ ។ ពោលដោយលំដាប់នៃមគ្គ សោតាបត្តិមគ្គរមែងប្រហារទិដ្ឋិនិងវិចិកិច្ឆា អនាគាមិមគ្គ រមែងប្រហារទោសៈ អរហត្តមគ្គរមែងប្រហារកិលេស ៧ ដ៏សេស ។

# អភិធម្មបិដក

# បិដ្ឋធុក

[ ៣១០ ] ពួកធម៌គួរលះដោយទស្សនៈ ( សោតាបត្តិមគ្គ ) តើដូចម្ដេច ។ សញ្ញោជនៈ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វតបរាមាស ។

[ ៣១១ ] បណ្ដាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្ដេច ។ បុថុជ្ជនក្នុងលោកនេះជាអ្នកមិនចេះដឹង មិនឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួន ក្នុងសប្បុរិសធម៌ រមែងយល់ឃើញថារូបជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងរូបខ្លះ ឃើញវេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សក្កាយទិដ្ឋិ ។

[ ៣១២ ] បណ្ដាសំយោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្ដេច ។ បុគ្គលងឿងឆ្ងល់សង្ស័យចំពោះព្រះសាស្ដា ។បេ។ ភាពនៃចិត្តរឹងរូស ការរសេមរសាមនៃចិត្ត នេះហៅថា វិចិកិច្ឆា ។

[ ៣១៣ ] បណ្ដាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាសៈ តើដូចម្ដេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅអំពីសាសនានេះ ( យល់ឃើញ )

ថា សេចក្ដីបរិសុទ្ធដោយសីល បរិសុទ្ធិដោយវត្ត បរិសុទ្ធិដោយសីលនិងវត្ត ទិដ្ឋិ ដំណើរតឹទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតបរាមាសៈ ។

[ ៣១៤ ] សញ្ញោជនៈ ៣ នេះ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយសញ្ញោជនៈនោះ កាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីសញ្ញោជនៈនោះ នេះពួកធម៌គួរលះដោយទស្សនៈ ។ ពួកធម៌មិនគួរលះដោយទស្សនៈ តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនា-ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនគួរលះដោយទស្សនៈ ។

[ ៣១៥ ] ពួកធម៌គួរលះដោយភាវនា តើដូចម្ដេច ។ លោភៈ ទោសៈ មោហៈដ៏សេសសល់ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេសមានលោភៈជាដើមនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌គួរលះដោយភាវនា ។ ពួកធម៌មិនគួរលះដោយភាវនា តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូ-បាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និង

អសង្ខតធាតុ នេះពួកធម៌មិនគួរលះដោយភាវនា ។

[ ៣១៦ ] ពួកធម៌មានហេតុ គួរលះដោយទស្សនៈ តើដូចម្តេច ។ សញ្ញោជនៈ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វតបរាមាសៈ ។

[ ៣១៧ ] បណ្តាសញ្ញោជនៈទាំងនោះ សក្កាយទិដ្ឋិ តើដូចម្តេច ។ បុថុជ្ជនក្នុងលោកនេះជាអ្នកមិនចេះដឹង មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនបានឃើញពួកសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិសធម៌ មិនបានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងយល់ឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូបខ្លះ ឃើញរូបថាមានក្នុងខ្លួនខ្លះ ឃើញខ្លួន ថាមានក្នុងរូបខ្លះ ( ឃើញ ) វេទនា ។បេ។ សញ្ញា ។បេ។ សង្ខារ ។បេ។ ឃើញវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណខ្លះ ឃើញវិញ្ញាណថាមានក្នុងខ្លួនខ្លះ ឃើញខ្លួនថាមានក្នុងវិញ្ញាណខ្លះ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ ការប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សក្កាយទិដ្ឋិ ។

[ ៣១៨ ] បណ្តាសញ្ញោជនៈទាំងនោះ វិចិកិច្ឆា តើដូចម្តេច ។ បុគ្គលងឿងឆ្ងល់សង្ស័យចំពោះព្រះសាស្តា ។បេ។ ភាពនៃសេចក្តីរង្វេស ការរសេមរសាមចិត្ត នេះហៅថា វិចិកិច្ឆា ។

[ ៣១៩ ] បណ្តាសញ្ញោជនៈទាំងនោះ សីលព្វតបរាមាសៈ តើដូចម្តេច ។ ពួកសមណព្រាហ្មណ៍ ខាងក្រៅអំពីសាសនានេះ ( យល់ឃើញ ) ថា សេចក្តីបរិសុទ្ធដោយសីល បរិសុទ្ធិដោយវត្ត បរិសុទ្ធិដោយសីលនិងវត្ត និង

ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ ការប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា សីលព្វតបរាមាសៈ ។

[ ៧២០ ] សញ្ញោជនៈ ៣ នេះ និងពួកកិលេសដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយសញ្ញោជនៈនោះ កាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីសញ្ញោជនៈនោះ នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ។ សញ្ញោជនៈ ៣ គឺសក្កាយទិដ្ឋិ វិចិកិច្ឆានិងសីលព្វតបរាមាសៈ នេះពួកធម៌គួរលះដោយទស្សនៈ ។ លោភៈ ទោសៈ មោហៈដែលតាំងនៅជាមួយនឹងសញ្ញោជនៈនោះ នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ។ ទាំងពួកកិលេសដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ កាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ។ ពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ ។

[ ៧២១ ] ពួកធម៌មានហេតុគួរលះដោយភាវនា តើដូចម្តេច ។ លោភៈ ទោសៈ មោហៈដ៏សេសសល់ នេះពួកធម៌មានហេតុគួរលះដោយភាវនា ។

ទាំងពួកកិលេស ដែលតាំងនៅជាមួយនឹងកិលេស មានលោភៈជាដើមនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយកិលេស មានលោភៈជាដើមនោះ កាយកម្ម វចីកម្ម មនោកម្មដែលតាំងឡើងអំពីកិលេស មានលោភៈជាដើមនោះ នេះពួកធម៌មានហេតុគួរលះដោយភាវនា ។ ពួកធម៌មានហេតុមិនគួរលះដោយភាវនា តើដូចម្តេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់ និងអសង្ខតធាតុ នេះពួកធម៌មានហេតុមិនគួរលះដោយភាវនា ។

[ ៣២២ ] ពួកធម៌ប្រកបដោយវិតក្កៈ តើដូចម្តេច ។ វៀរតែវិតក្កៈក្នុងសវិតក្កភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នៈចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយវិតក្កៈនោះ នេះពួកធម៌ប្រកបដោយវិតក្កៈ ។ ពួកធម៌មិនមានវិតក្កៈ តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ក្នុងអវិតក្កភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នទិងវិតក្កៈផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនមានវិតក្កៈ ។

[ ៣២៣ ] ពួកធម៌ប្រកបដោយវិចារៈ ( ការពិចារណា ) តើដូចម្តេច ។ វៀរតែវិចារៈក្នុងសវិចារភូមិជាកាមាវចរ រូបាវចរ អបរិយាបន្នចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយវិចារៈនោះ នេះពួកធម៌ប្រកបដោយវិចារៈ ។ ពួកធម៌មិនមានវិចារៈ តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធក្នុងអវិចារភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន

និងវិចារៈផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនមានវិចារៈ ។

[ ៣២៤ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ តើដូចម្តេច ។ វៀរតែបីតិក្នុងសប្បីតិកភូមិជាកាមាវចរ រូបាវចរ អបរិយាបន្នចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ដែលប្រកបដោយបីតិនោះ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងបីតិ តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធក្នុងអប្បីតិកភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន និងបីតិផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងបីតិ ។

[ ៣២៥ ] ពួកធម៌ប្រកបដោយបីតិ តើដូចម្តេច ។ វៀរតែបីតិក្នុងបីតិ-ភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នចេញ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធដែលប្រកបដោយបីតិនោះ នេះពួកធម៌ប្រកបដោយបីតិ ។ ពួកធម៌មិនប្រកបដោយបីតិ តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ក្នុងទីមិនមែនជាបីតិភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ននិងបីតិផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រកបដោយបីតិ ។

[ ៣២៦ ] ពួកធម៌ប្រកបដោយសុខៈ តើដូចម្តេច ។ វៀរតែសុខៈ ក្នុងសុខភូមិ ជាកាមាវចរ រូបាវចរ អបរិយាបន្នចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធប្រកបដោយសុខនោះ នេះពួកធម៌ប្រកបដោយសុខៈ ។ ពួកធម៌មិនប្រកបដោយសុខៈ តើដូចម្តេច ។ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ក្នុងទីមិនមែនជាសុខភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ននិងសុខៈ

ផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រកបដោយសុខៈ ។

[ ៣២៧ ] ពួកធម៌ប្រកបដោយឧបេក្ខា តើដូចម្ដេច ។ វៀរតែឧបេក្ខាក្នុងឧបេក្ខាភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្នចេញ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ដែលប្រកបដោយឧបេក្ខានោះ នេះពួកធម៌ប្រកបដោយឧបេក្ខា ។ ពួកធម៌មិនប្រកបដោយឧបេក្ខា តើដូចម្ដេច ។ វេទនា-ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ក្នុងទីមិនមែនជាឧបេក្ខាភូមិ ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន និងឧបេក្ខាផង រូបទាំងអស់ផង អសង្ខតធាតុផង នេះពួកធម៌មិនប្រកបដោយឧបេក្ខា ។

[ ៣២៨ ] ពួកធម៌ជាកាមាវចរ តើដូចម្ដេច ។ ខាងក្រោមកំណត់យកអវីចិនរកជាទីបំផុត ខាងលើកំណត់យកបរនិម្មិតវសវត្តីទេវលោកជាទីបំផុត ទីណាដែលមានក្នុងចន្លោះនេះ ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណដែលត្រាច់ចុះក្នុងទីនុ៎ះ រាប់បញ្ចូលក្នុងទីនោះ នេះពួកធម៌ជាកាមាចវរ ។ ពួកធម៌មិនមែនជាកាមាវចរ តើដូចម្ដេច ។ រូបាវចរ អរូបាវចរ អបរិយាបន្ន នេះពួកធម៌មិនមែនជាកាមាវចរ ។

[ ៣២៩ ] ពួកធម៌ជារូបាវចរ តើដូចម្ដេច ។ ខាងក្រោម កំណត់យកព្រហ្មលោកជាទីបំផុត ខាងលើកំណត់យកអកនិដ្ឋទេវលោក ជាទីបំផុត ទីណាដែលមានក្នុងចន្លោះនេះ ធម៌ គឺចិត្តនិងចេតសិក ដែលត្រាច់ទៅក្នុងទីនុ៎ះ រាប់បញ្ចូលក្នុងទីនុ៎ះនៃបុគ្គលអ្នកចូល ( កាន់សមាបត្តិ ) ឬបុគ្គលដែលកើតហើយ ឬក៏បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន នេះពួកធម៌ជារូបាវចរ ។ ពួក

ធម៌មិនមែនជារូបាវចរ តើដូចម្តេច ។ កាមាវចរ អរូបាវចរ អបរិយាបន្ន នេះពួកធម៌មិនមែនជារូបាវចរ ។

[ ៣៣០ ] ពួកធម៌ជាអរូបាវចរ តើដូចម្តេច ។ ខាងក្រោមកំណត់យកពួកទេវតាដែលកើតក្នុងអាកាសានញ្ចាយតនភព ជាទីបំផុត ខាងលើកំណត់យកទេវតាដែលកើតក្នុងនេវសញ្ញានាសញ្ញាយតនភពជាទីបំផុត ទីណាដែលមានក្នុងចន្លោះនេះ ធម៌ គឺចិត្តនិងចេតសិកត្រាច់ចុះក្នុងទីនោះ រាប់បញ្ចូលក្នុងទីនោះនៃបុគ្គលអ្នកចូល ( កាន់សមាបត្តិ ) ឬបុគ្គលដែលទៅកើតហើយ ឬក៏បុគ្គលអ្នកនៅជាសុខក្នុងបច្ចុប្បន្ន នេះពួកធម៌ជាអរូបាវចរ ។ ពួកធម៌មិនមែនជាអរូបាវចរ តើដូចម្តេច ។ កាមាវចរ រូបាវចរ អបរិយាបន្ន នេះពួកធម៌មិនមែនជាអរូបាវចរ ។

[ ៣៣១ ] ពួកធម៌ជាបរិយាបន្ន តើដូចម្តេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ និងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ជាបរិយាបន្ន ។ ពួកធម៌ជាអបរិយាបន្ន តើដូចម្តេច ។ មគ្គផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌ជាអបរិយាបន្ន ។

[ ៣៣២ ] ពួកធម៌ជានិយ្យានិកៈ ( ធម៌នាំសត្វឲ្យរួចចាកវដ្តៈ ) តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្ន នេះពួកធម៌ជានិយ្យានិកៈ ។ ពួកធម៌ជា

និយ្យានិកៈ តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ជាអនិយ្យានិកៈ ។

[ ៣៣៣ ] ពួកធម៌ជានិយតៈ ( ទៀង ) តើដូចម្ដេច ។ អនន្តរិកកម្ម ៥ និយតមិច្ឆាទិដ្ឋិ និងមគ្គ ៤ ជាអបរិយាបន្ន នេះពួកធម៌ជានិយតៈ ។ ពួកធម៌ជាអនិយតៈ តើដូចម្ដេច ។ វៀរតែធម៌ទាំងនោះចេញ ពួកធម៌ដ៏សេសសល់ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌ជាអនិយតៈ ។

[ ៣៣៤ ] ពួកធម៌ប្រកបដោយឧត្តរៈ ( ការរើឡើងនូវខ្លួន ) តើដូចម្ដេច ។ ពួកធម៌ប្រកបដោយអាសវៈ ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរនិងរូបក្ខន្ធ ។បេ។ វិញ្ញាណក្ខន្ធ នេះពួកធម៌ប្រកបដោយឧត្តរៈ ។ ពួកធម៌មិនមែនជាឧត្តរៈ តើដូចម្ដេច ។ មគ្គជាអបរិយាបន្នផង ផលនៃមគ្គផង អសង្ខតធាតុផង នេះពួកធម៌មិនមែនជាឧត្តរៈ ។

[ ៣៣៥ ] ពួកធម៌ប្រកបដោយរណៈ ( សឹកសត្រូវ ) តើដូចម្ដេច ។ អកុសលមូល ៣ គឺលោភៈ ទោសៈនិងមោហៈ ទាំងពួកកិលេសដែលតាំង

នៅជាមួយនឹងអកុសលមូលនោះ វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ ប្រកប ដោយអកុសលមូលនោះ កាយកម្ម វចីកម្ម មនោកម្ម ដែលតាំងឡើងអំពី អកុសលមូលនោះ នេះពួកធម៌ប្រកបដោយរណៈ ។ ពួកធម៌មិនមែនជា រណៈ ( មិនជាសឹកសត្រូវ ) តើដូចម្តេច ។ ពួកធម៌ជាកុសលនិងអព្យា-ក្រឹត ជាកាមាវចរ រូបាវចរ អរូបាវចរ អបរិយាបន្ន វេទនាខន្ធ ។បេ។ វិញ្ញាណក្ខន្ធ រូបទាំងអស់និងអសង្ខតធាតុ នេះពួកធម៌មិនមែនជារណៈ ។

# អដ្ឋកថា

# បិដ្ឋិទុក

[ ៣១០-៣៣៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃកាមាវចរ ដូចតទៅនេះថា

បទថា **ហេដ្ឋតោ** បានដល់ ចំណែកខាងក្រោម ។ បទថា **អវីចិនិរយំ** មានសេចក្តីថា ដែលឈ្មោះថា **អវីចិ** ព្រោះអត្ថថា ក្នុងនរកនេះ មិនមានចន្លោះប្រហោង រវាងរលកនៃអណ្តាតភ្លើងទាំងឡាយ ឬនៃទុក្ខវេទនារបស់សត្វទាំងឡាយ ។ ដែលឈ្មោះថា **និរយ** ព្រោះអត្ថថា ក្នុងទីនេះមិនមានសេចក្តីចម្រើន ពោលគឺ សេចក្តីសុខម្យ៉ាងវិញទៀត ឈ្មោះថា **នរក** ដោយអត្ថថា មិនមានសេចក្តីត្រេកអរខ្លះ ដោយអត្ថថា មិនមានសេចក្តីពេញចិត្តខ្លះ ។

បទថា **បរិយន្តំ ករិត្វា** បានដល់ ធ្វើនរក ពោលគឺ អវីចិនោះជាទីបំផុត ។ បទថា **ឧបរិតោ** បានដល់ ចំណែកខាងលើ ។ បទថា **បរនិម្មិត-វសវត្តិទេវេ** សេចក្តីថា ទេវតា ឈ្មោះថា បានរាំហារយ៉ាងនេះ ព្រោះធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងសេចក្តីប្រាថ្នា ( កាម ) ទាំងឡាយ ដែលទេវតាដទៃនិម្មិតឲ្យ ។ បទថា **អន្តោ ករិត្វា** បានដល់ រាប់ទុកក្នុងទីបំផុត ។ បទថា **យំ ឯតស្មឹ អន្តរេ** បានដល់ ក្នុងឱកាសនេះឯណា ។

ដោយបទថា **ឯត្ថាវចរា** នេះ ព្រោះធម៌ពួកដទៃត្រាច់ទៅក្នុងរវាងភូមិនេះ ដោយការកើតឡើងក្នុងភូមិខ្លះ ក្នុងកាលខ្លះ ហេតុនោះ ដើម្បីមិនរួបរួម

ធម៌ទាំងនោះ ទើបត្រាស់ថា **អវចរា** ។ ដោយពាក្យនោះ ធម៌ទាំងឡាយណា រមែងត្រាច់ទៅ ឈមចុះក្នុងរវាងភូមិនេះ ដោយការកើតឡើងគ្រប់ទីកន្លែងនិងគ្រប់កាល ធម៌ពួកណារមែងត្រាច់ទៅក្នុងចំណែកខាងក្រោមដោយការប្រព្រឹត្តទៅនៃភូតរូបនិងឧបាទាយរូបខាងក្រោមរបស់អវីចិនរក ទើបទ្រង់ធ្វើការរួបរួមធម៌ទាំងនោះទុក ព្រោះថា ធម៌ទាំងនោះឈមចុះហើយនោះឯងត្រាច់ទៅ គឺឈមចុះក្នុងចំណែកខាងក្រោម ព្រោះហេតុនោះ ទើបហៅថា **អវចរ** ។ ដោយពាក្យថា **ឯត្ថ បរិយាបន្នា** នេះ ព្រោះធម៌ទាំងនេះត្រាច់ទៅក្នុងភូមិនេះ រមែងត្រាច់ទៅសូម្បីក្នុងភូមិដទៃបាន តែមិនរាប់បញ្ចូលក្នុងភូមិដទៃនោះ ហេតុនោះ ទើបទ្រង់ធ្វើការកំណត់ធម៌ទាំងនោះ ដែលត្រាច់ទៅសូម្បីក្នុងភូមិដទៃ ។ ឥឡូវនេះកាលនឹងសម្តែងធម៌ទាំងនោះ ដែលជាធម៌រាប់បញ្ចូលក្នុងភូមិនេះដោយភាពជារាសី ( គំនរ ) ដោយភាពទទេ ដោយភាពជាបច្ច័យ និងដោយជាសភាវៈ ទើបត្រាស់ពាក្យថា **ខន្ធា** ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃរូបាវចរ ដូចតទៅនេះថា

បទថា **ព្រហ្មលោកំ** បានដល់ ស្ថានទីតាំងនៅនៃព្រហ្ម ពោលគឺបឋមជ្ឈានភូមិ ។ ពាក្យដ៏សេសក្នុងនិទ្ទេសនេះ គប្បីជ្រាបដោយន័យដែលពោលទុក ក្នុងកាមាវចរនិទ្ទេសនុ៎ះឯង ។ ក្នុងបទជាដើមថា **សមាបន្នស្ស វា** គប្បីជ្រាបថា ទ្រង់ត្រាស់អកុសលជ្ឈាន ដោយបទទី ១ ត្រាស់វិបាកជ្ឈានដោយបទទី ២ ត្រាស់កិរិយាឈានដោយបទទី ៣ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអរូបាវចរនិទ្ទេស ដូចតទៅនេះថា

បទថា **អាកាសានញ្ចាយតនូបគេ** បានដល់ អ្នកចូលដល់កព ពោល គឺអាកាសានញ្ចាយតនៈ ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះឯង ។ ពាក្យ ដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយខាងដើមនុ៎ះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសរណទុកនិទ្ទេស ដូចតទៅនេះថា

បណ្ដាអកុសលមូល ៣ អកុសលមូល គឺមោហៈនេះឯណា មោហៈ នោះប្រកបជាមួយនឹងលោភៈ គប្បីជ្រាបថាជាសរណៈ ( កើតព្រមជាមួយ នឹងកិលេសជាហេតុឲ្យសត្វលោកទួញយំ ) ដោយលោភៈ ដែលសម្បយុត្ត ដោយទោសៈ គប្បីជ្រាបថា ជាសរណៈដោយទោសៈ តែដែលសម្បយុត្ត ដោយវិចិកិច្ឆានិងឧទ្ធច្ចៈ គប្បីជ្រាបថាជាសរណៈដោយកិលេស ជាហេតុឲ្យ សត្វទួញយំ គឺរាគៈដែលសម្បយុត្តដោយទិដ្ឋិ និងដែលជារូបរាគៈ អរូបរាគៈ ព្រោះជាកិលេស ដែលតាំងនៅក្នុងឋានៈតែមួយនៃការប្រហារ គឺជាសរជៈ ( ប្រព្រឹត្តទៅជាមួយសេចក្ដីសៅហ្មង ) ។

## ទុកនិក្ខេប ចប់

# អភិធម្មបិដក

# សុត្តន្តិកទុកនិក្ខេប

[ ៣៣៦ ] ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា តើដូចម្តេច ។ ពួកធម៌ប្រកបដោយវិជ្ជា នេះពួកធម៌ ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា ។ ពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា តើដូចម្តេច ។ ពួកធម៌ប្រកបដោយអវិជ្ជា នេះពួកធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃអវិជ្ជា ។

[ ៣៣៧ ] ពួកធម៌ប្រៀបដូចផ្លេកបន្ទោរ តើដូចម្តេច ។ បញ្ញាក្នុងអរិយមគ្គ ៣ ខាងក្រោម នេះពួកធម៌ប្រៀបប្រដូចផ្លេកបន្ទោរ ។ ពួកធម៌ប្រៀបដូចពេជ្រ តើដូចម្តេច ។ បញ្ញាក្នុងអរហត្តមគ្គខាងលើ នេះពួកធម៌ប្រៀបដូចពេជ្រ ។

[ ៣៣៨ ] ពួកធម៌ពាល តើដូចម្តេច ។ អហិរិកៈនិងអនោត្តប្បៈ នេះពួកធម៌ពាល សូម្បីអកុសលធម៌ទាំងអស់ក៏ជាពួកធម៌ពាលដែរ ។ ពួកធម៌បណ្ឌិត តើដូចម្តេច ។ ហិរិនិងឱត្តប្បៈ នេះពួកធម៌បណ្ឌិត សូម្បីកុសលធម៌ទាំងអស់ក៏ជាពួកធម៌បណ្ឌិតដែរ ។

[ ៣៣៩ ] ពួកធម៌ខ្មៅ តើដូចម្តេច ។ អហិរិកៈនិងអនោត្តប្បៈ នេះពួកធម៌ខ្មៅ សូម្បីអកុសលធម៌ទាំងអស់ ក៏ជាពួកធម៌ខ្មៅដែរ ។ ពួកធម៌ស តើដូចម្តេច ។ ហិរិនិងឱត្តប្បៈ នេះពួកធម៌ស សូម្បីកុសលធម៌ទាំងអស់ ក៏ជាពួកធម៌សដែរ ។

[ ៣៤០ ] ពួកធម៌ដុតកម្តៅ តើដូចម្តេច ។ កាយទុច្ចរិត វចីទុច្ចរិត

មនោទុច្ចរិត នេះពួកធម៌ដុតកម្ដៅ សូម្បីអកុសលធម៌ទាំងអស់ ក៏ជាពួកធម៌ដុតកម្ដៅដែរ ។ ពួកធម៌មិនដុតកម្ដៅ តើដូចម្ដេច ។ កាយសុចរិត វចីសុចរិត មនោសុចរិត នេះពួកធម៌មិនដុតកម្ដៅ សូម្បីកុសលធម៌ទាំងអស់ក៏ជាពួកធម៌មិនដុតកម្ដៅដែរ ។

[ ៣៨១ ] ពួកធម៌ជាអភិវចនៈ ( ឈ្មោះ ) តើដូចម្ដេច ។ ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយឈ្មោះ ការធ្វើនូវឈ្មោះ ការតម្កល់ទុកនូវឈ្មោះ លំនាំពាក្យពោល ព្យញ្ជនៈ ការនិយាយចំពោះឈ្មោះណានៃពួកធម៌នោះៗ នេះពួកធម៌ជាអភិវចនៈ ។ ឯពួកធម៌ទាំងអស់ ក៏ជាគន្លងនៃអភិវចនៈដែរ ។

[ ៣៨២ ] ពួកធម៌ជានិរុត្តិ ( ពាក្យពោល ) តើដូចម្ដេច ។ ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយឈ្មោះ ការធ្វើនូវឈ្មោះ ការតម្កល់ទុកនូវឈ្មោះ លំនាំពាក្យពោល ព្យញ្ជនៈ ការនិយាយចំឈ្មោះណានៃពួកធម៌នោះៗ នេះពួកធម៌ជានិរុត្តិ ។ ឯពួកធម៌ទាំងអស់ក៏ជាគន្លងនៃនិរុត្តិដែរ ។

[ ៣៨៣ ] ពួកធម៌ជាបញ្ញត្តិ តើដូចម្ដេច ។ ការរាប់ ការដឹងដោយប្រពៃ ការតាំងទុក ការនិយាយឈ្មោះ ការធ្វើនូវឈ្មោះ ការតម្កល់ទុកនូវឈ្មោះ លំនាំពាក្យពោល ព្យញ្ជនៈ ការនិយាយចំឈ្មោះណានៃពួកធម៌នោះៗ នេះពួកធម៌ជាបញ្ញត្តិ ។ ពួកធម៌ទាំងអស់ក៏ជាគន្លងនៃបញ្ញត្តិដែរ ។

[ ៣៨៤ ] បណ្ដាធម៌ទាំងនោះ នាម តើដូចម្ដេច ។ វេទនាខន្ធ សញ្ញា

ខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ និងអសង្ខតធាតុ នេះហៅថា នាម ។ បណ្ដាធម៌ទាំងនោះ រូប តើដូចម្ដេច ។ មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូបទាំង ៤ នេះហៅថា រូប ។

[ ៣៤៥ ] បណ្ដាធម៌ទាំងនោះ អវិជ្ជា តើដូចម្ដេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះគឺអវិជ្ជា សេចក្ដីវង្វេង ជាអកុសលមូលណា នេះហៅថា អវិជ្ជា ។ បណ្ដាធម៌ទាំងនោះ ភវតណ្ហា តើដូចម្ដេច ។ ការប្រាថ្នាក្នុងភព ។បេ។ ការចុះចិត្តស៊ប់ក្នុងភព ចំពោះភពទាំងឡាយណា នេះហៅថា ភវតណ្ហា ។

[ ៣៤៦ ] បណ្ដាធម៌ទាំងនោះ ភវទិដ្ឋិ ( ការយល់ឃើញថាសត្វកើតទៀត ) តើដូចម្ដេច ។ ( សេចក្ដីយល់ ) ថាខ្លួនក្ដី លោកក្ដីនឹងកើតមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ភវទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ វិភវទិដ្ឋិ ( សេចក្ដីយល់ឃើញថាសត្វមិនកើតទៀត ) តើដូចម្ដេច ។ ( សេចក្ដីយល់ ) ថា ខ្លួនក្ដី លោកក្ដីនឹងមិនកើតមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា វិភវទិដ្ឋិ ។

[ ៣៤៧ ] បណ្ដាធម៌ទាំងនោះ សស្សតទិដ្ឋិ ( សេចក្ដីយល់ថាខ្លួននិងលោកទៀង ) តើដូចម្ដេច ។ ( សេចក្ដីយល់ ) ថា ខ្លួនក្ដី លោកក្ដីទៀងទាត់ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា

ដែលមានសភាពបែបនេះ នេះហៅថា សស្សតទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ ឧច្ឆេទទិដ្ឋិ ( សេចក្ដីយល់ថា សត្វសូន្យមិនកើតទៀត ) តើដូចម្ដេច ។ ( សេចក្ដីយល់ ) ថា ខ្លួនក្ដី លោកក្ដីដាច់សូន្យ និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា ឧច្ឆេទទិដ្ឋិ ។

[ ៣៤៨ ] បណ្ដាធម៌ទាំងនោះ អន្តវាទិដ្ឋិ ( សេចក្ដីយល់ថាលោកមានទីបំផុត ) តើដូចម្ដេច ។ ( សេចក្ដីយល់ ) ថា ខ្លួនក្ដី លោកក្ដី មានទីបំផុត និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា អន្តវាទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ អនន្តវាទិដ្ឋិ តើដូចម្ដេច ។ ( សេចក្ដីយល់ ) ថា ខ្លួនក្ដី លោកក្ដីមិនមានទីបំផុត និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា អនន្តវាទិដ្ឋិ ។

[ ៣៤៩ ] បណ្ដាធម៌ទាំងនោះ បុព្វន្តានុទិដ្ឋិ ( សេចក្ដីយល់តាមចំណែកនៃខន្ធខាងដើម ) តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា កើតឡើងព្រោះប្រារព្ធនូវខន្ធ ជាចំណែកខាងដើម នេះហៅថា បុព្វន្តានុទិដ្ឋិ ។ បណ្ដាធម៌ទាំងនោះ អបរន្តានុទិដ្ឋិ តើដូចម្ដេច ។ ទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា កើតឡើងព្រោះប្រារព្ធនូវខន្ធ ជាចំណែកខាងចុង នេះហៅថា អបរន្តានុទិដ្ឋិ ។

[ ៣៥០ ] បណ្ដាធម៌ទាំងនោះ អហិរិកៈ តើដូចម្ដេច ។ ត្រង់ដែល

បុគ្គលមិនខ្មាសដោយអំពើដែលគួរខ្មាស មិនខ្មាសដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា អហិរិកៈ ។ បណ្តាធម៌ទាំងនោះ អនោត្តប្បៈ តើដូចម្តេច ។ ត្រង់ដែលបុគ្គលមិនក្តៅក្រហាយ ដោយអំពើដែលគួរក្តៅក្រហាយ មិនក្តៅក្រហាយដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា អនោត្តប្បៈ ។

[ ៣៥១ ] បណ្តាធម៌ទាំងនោះ ហិរិ តើដូចម្តេច ។ ត្រង់ដែលបុគ្គលខ្មាសដោយអំពើដែលគួរខ្មាស ខ្មាសដោយការជួបប្រទះ នូវធម៌ជាអកុសលដ៏លាមក នេះហៅថា ហិរិ ។ បណ្តាធម៌ទាំងនោះ ឱត្តប្បៈ តើដូចម្តេច ។ ត្រង់ដែលបុគ្គលក្តៅក្រហាយដោយអំពើដែលគួរក្តៅក្រហាយ ក្តៅក្រហាយដោយការជួបប្រទះនូវធម៌ជាអកុសលដ៏លាមក នេះហៅថា ឱត្តប្បៈ ។

[ ៣៥២ ] បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលដែលគេប្រដៅក្រ តើដូចម្តេច ។ សេចក្តីប្រដៅក្រ ការស្តីថាក្រ ភាពនៃបុគ្គល ដែលគេប្រដៅក្រ ភាពនៃបុគ្គលប្រកាន់យកខាងខុស ភាពនៃបុគ្គលត្រេកអរ ក្នុងធម៌ជាសត្រូវ ការមិនអើពើ ភាពនៃបុគ្គលមិនយកចិត្តទុកដាក់ ភាពនៃបុគ្គលមិនគោរព ភាពនៃបុគ្គលមិនទទួលស្តាប់បង្គាប់ចំពោះសហធម្មិកជនដែលស្តីប្រដៅ នេះហៅថា ភាពនៃបុគ្គល ដែលគេប្រដៅក្រ ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមានមិត្តអាក្រក់ តើដូចម្តេច ។ ពួកបុគ្គលណា ជាអ្នកមិនមានសទ្ធា ទ្រុស្តសីល ចេះដឹងតិច ជាមនុស្សកំណាញ់ គ្មានប្រាជ្ញា ការសេព ការជិតដិតនឹងគ្នា ការត្រូវគំនិតគ្នា ការគប់រកគ្នា ការស្រេបគំនិតគ្នា សេចក្តីស្រឡាញ់

គ្នា ការជិតស្និទ្ធនឹងគ្នា ភាពនៃបុគ្គលមូលមិត្តនឹងគ្នាណា នៃបុគ្គលទាំងនោះ នេះហៅថា ភាពនៃបុគ្គលមានមិត្តអាក្រក់ ។

[ ៣៥៣ ] បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលដែលគេប្រដៅងាយ តើដូចម្តេច ។ ការប្រដៅងាយ ការស្តីថាងាយ ភាពនៃបុគ្គលដែលគេប្រដៅងាយ ភាពនៃបុគ្គលមិនកាន់យកខាងខុស ភាពនៃបុគ្គលមិនត្រេកអរចំពោះធម៌ជាសត្រូវ សេចក្តីអើពើ ភាពនៃបុគ្គលយកចិត្តទុកដាក់ ភាពនៃបុគ្គលប្រកបដោយសេចក្តីគោរព ភាពនៃបុគ្គលប្រកបដោយការទទួលស្តាប់បង្គាប់ចំពោះសហធម្មិកជនដែលស្តីប្រដៅ នេះហៅថា ភាពនៃបុគ្គលប្រដៅងាយ ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលមានមិត្តល្អ តើដូចម្តេច ។ បុគ្គលណាជាអ្នកមានសទ្ធា មានសីល ចេះដឹងច្រើន មានចាគៈ មានប្រាជ្ញា ការសេពការជិតដិតនឹងគ្នា ការត្រូវគំនិតគ្នា ការគប់រកគ្នា ការស្រេបគំនិតគ្នា សេចក្តីស្រឡាញ់គ្នា ការជិតស្និទ្ធនឹងគ្នា ភាពនៃបុគ្គលមូលមិត្តនឹងគ្នាណានៃបុគ្គលទាំងនោះ នេះហៅថា ភាពនៃបុគ្គលមានមិត្តល្អ ។

[ ៣៥៤ ] បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងអាបត្តិ តើដូចម្តេច ។ ពួកអាបត្តិ មានកងនៃអាបត្តិ ៥ ក្តី ពួកអាបត្តិ មានកងនៃអាបត្តិ ៧ ក្តី សេចក្តីឈ្លាសក្នុងអាបត្តិ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណាចំពោះអាបត្តិទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងអាបត្តិ ។ បណ្តាធម៌ទាំងនោះ ភាពនៃបុគ្គលអ្នកឈ្លាសក្នុងការចេញចាកអាបត្តិ តើដូចម្តេច ។ សេចក្តីឈ្លាស ក្នុងការចេញចាក

អាបត្តិទាំងនោះ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា នេះហៅថា សេចក្តីឈ្លាសក្នុងការចេញចាកអាបត្តិ ។

[ ៣៥៥ ] បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងសមាបត្តិ តើដូចម្តេច ។ សមាបត្តិប្រកបដោយវិតក្កៈនិងវិចារៈក៏មាន សមាបត្តិមិនមានវិតក្កៈមានត្រឹមតែវិចារៈក៏មាន សមាបត្តិមិនមានវិតក្កៈ ទាំងមិនមានវិចារៈ ក៏មាន សេចក្តីឈ្លាសក្នុងសមាបត្តិ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណាចំពោះសមាបត្តិទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងសមាបត្តិ ។ បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងការចេញចាកសមាបត្តិ តើដូចម្តេច ។ សេចក្តីឈ្លាសក្នុងការចេញចាកសមាបត្តិទាំងនោះ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា នេះហៅថា សេចក្តីឈ្លាសក្នុងការចេញចាកសមាបត្តិ ។

[ ៣៥៦ ] បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងធាតុ តើដូចម្តេច ។ ធាតុ ១៨ គឺចក្ខុធាតុ រូបធាតុ ចក្ខុវិញ្ញាណធាតុ សោតធាតុ សទ្ទធាតុ សោតវិញ្ញាណធាតុ ឃានធាតុ គន្ធធាតុ ឃានវិញ្ញាណធាតុ ជិវ្ហាធាតុ រសធាតុ ជិវ្ហាវិញ្ញាណធាតុ កាយធាតុ ផោដ្ឋព្វធាតុ កាយវិញ្ញាណធាតុ មនោធាតុ ធម្មធាតុ មនោវិញ្ញាណធាតុ សេចក្តីឈ្លាសក្នុងធាតុ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា

ចំពោះធាតុទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងធាតុ ។ បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត តើដូចម្តេច ។ សេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា ចំពោះធាតុទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត ។

[ ៣៥៧ ] បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាស ក្នុងអាយតនៈ តើដូចម្តេច ។ អាយតនៈ ១២ គឺចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ សទ្ទាយតនៈ ឃានាយតនៈ គន្ធាយតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ សេចក្តីឈ្លាសក្នុងអាយតនៈ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា ចំពោះអាយតនៈទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងអាយតនៈ ។ បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងបដិច្ចសមុប្បាទ តើដូចម្តេច ។ សង្ខារកើតឡើង ព្រោះវិជ្ជាជាបច្ច័យ វិញ្ញាណកើតឡើង ព្រោះសង្ខារជាបច្ច័យ នាមរូបកើតឡើង ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតឡើង ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតឡើង ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតឡើង ព្រោះផស្សៈជាបច្ច័យ តណ្ហាកើតឡើង ព្រោះវេទនាជាបច្ច័យ ឧបាទានកើតឡើង ព្រោះតណ្ហាជាបច្ច័យ ភពកើតឡើង ព្រោះឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះភពជាបច្ច័យ ជរាមរណកើតឡើង ព្រោះជាតិជាបច្ច័យ សេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្សនិង

សេចក្តីចង្អៀតចង្អល់ចិត្ត ក៏កើតឡើងព្រម ការកើតឡើងនៃកងទុក្ខទាំងអស់នុ៎ះ រមែងមានដោយអាការយ៉ាងនេះ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណាចំពោះបដិច្ចសមុប្បាទ-ធម៌នោះ នេះហៅថា សេចក្តីឈ្លាសក្នុងបដិច្ចសមុប្បាទ ។

[ ៣៥៨ ] បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងឋាន: ( ហេតុ ) តើដូចម្តេច ។ ពួកធម៌ណាៗជាហេតុ ជាបច្ច័យនៃពួកធម៌ណាៗ ពួកធម៌នោះៗឈ្មោះថា ឋាន: ព្រោះអាស្រ័យនូវហេតុប្បច្ច័យនោះៗ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណាចំពោះធម៌ទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងឋាន: ។ បណ្តាធម៌ទាំងនោះ សេចក្តីឈ្លាសក្នុងអដ្ឋាន: ( មិនមែនជាហេតុ ) តើដូចម្តេច ។ ពួកធម៌ណាៗមិនមែនជាហេតុ មិនមែនជាបច្ច័យនៃពួកធម៌ណាៗ ពួកធម៌នោះៗឈ្មោះថាអដ្ឋាន: ព្រោះអាស្រ័យនូវហេតុប្បច្ច័យនោះៗ ការដឹងច្បាស់ ការយល់ច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណាចំពោះធម៌ទាំងនោះ នេះហៅថា សេចក្តីឈ្លាសក្នុងអដ្ឋាន: ។

[ ៣៥៩ ] បណ្តាធម៌ទាំងនោះ ភាពត្រង់ តើដូចម្តេច ។ ភាពនៃអាការត្រង់ ការមិនច្នៃងច្នៃ ការមិនវៀចវេរ ការមិនកោងកាចណា នេះហៅថា ភាពត្រង់ ។ បណ្តាធម៌ទាំងនោះ ភាពទន់ភ្លន់ តើដូចម្តេច ។ ភាពនៃអាការទន់ភ្លន់ ដំណើរទន់ភ្លន់ ការមិនរឹងរូស ការមិនក្រអឺតក្រអោង ការមានចិត្តរាបទាបណា នេះហៅថា ភាពទន់ភ្លន់ ។

[ ៣៦០ ] បណ្ដាធម៌ទាំងនោះ សេចក្ដីអត់សង្កត់ តើដូចម្ដេច ។ សេចក្ដីអត់ធន់ ភាពអត់ធ្មត់ ការអត់សង្កត់ ភាពមិនកាច មិនព្រហើន ភាពនៃចិត្តរីករាយណា នេះហៅថា សេចក្ដីអត់សង្កត់ ។ បណ្ដាធម៌ទាំងនោះ សេចក្ដីស្ងួត តើដូចម្ដេច ។ ការមិនប្រព្រឹត្តិល្មើសកាយ ការមិនប្រព្រឹត្តិល្មើសវាចា ការមិនប្រព្រឹត្តិល្មើសកាយនិងវាចាណា នេះហៅថា សេចក្ដីស្ងួត ។ សូម្បីការសង្រួមក្នុងសីលទាំងអស់ ក៏ហៅថា សេចក្ដីស្ងួតដែរ ។

[ ៣៦១ ] បណ្ដាធម៌ទាំងនោះ សេចក្ដីរាក់ទាក់ តើដូចម្ដេច ។ វាចាណាជាវាចាពកកន្ទួល ពុកស្អុយ វាចាមិនជាទីពេញចិត្តអ្នកដទៃ វាចាជាលវាលដល់អ្នកដទៃ ជាសម្ដីជិតការក្រោធ មិនប្រព្រឹត្តទៅដើម្បីសមាធិ បុគ្គលក៏លះបង់នូវវាចាបែបនោះចេញ វាចាណា មិនជាទោស ជាវាចាសុខដល់ត្រចៀក ជាទីស្រឡាញ់ ជាទីពេញចិត្ត ជាវាចានៃអ្នកក្រុង ជាទីត្រេកអរនៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន បុគ្គលក៏ជាអ្នកនិយាយចំពោះវាចាបែបនោះ បានដល់ ការពោលពាក្យពីរោះ ការពោលពាក្យផ្ទូរផង់ ការពោលពាក្យមិនទ្រគោះ នេះហៅថា សេចក្ដីរាក់ទាក់ ។ បណ្ដាធម៌ទាំងនោះ ការទទួលរាក់ទាក់ តើដូចម្ដេច ។ ការទទួលរាក់ទាក់ មាន ២ យ៉ាងគឺ ការទទួលរាក់ទាក់ដោយអាមិស ១ ការទទួលរាក់ទាក់ដោយធម៌ ១ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទទួលរាក់ទាក់ ដោយការទទួលរាក់ទាក់ដោយអាមិស ឬដោយការទទួលរាក់ទាក់ដោយធម៌ នេះហៅថា ការទទួលរាក់ទាក់ ។

[ ៣៦២ ] បណ្ដាធម៌ទាំងនោះ ការមិនរក្សាទ្វារក្នុងឥន្ទ្រិយ តើដូចម្ដេច ។

បុគ្គលខ្លះក្នុងលោកនេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏មិនប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធភ្លក្សដោយអណ្ដាត ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។បេ។ ដឹងច្បាស់ធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកកាន់យកនូវនិមិត្ត កាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏មិនប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនុ៎ះ មិនរក្សានូវមនិន្ទ្រិយ មិនដល់នូវការសង្រួមក្នុងមនិន្ទ្រិយ និងសេចក្ដីមិនគ្រប់គ្រង អាការមិនគ្រប់គ្រង ការមិនរក្សា ការមិនសង្រួមនូវឥន្ទ្រិយទាំង ៦ នេះណា នេះហៅថា ការមិនរក្សាទ្វារក្នុងឥន្ទ្រិយ ។ បណ្ដាធម៌ទាំងនោះ ការមិនដឹងប្រមាណក្នុងភោជន តើដូចម្ដេច ។ បុគ្គលខ្លះក្នុងលោកនេះ មិនបានពិចារណាដោយឧបាយប្រាជ្ញា ហើយបរិភោគអាហារ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង សេចក្ដីមិនសន្តោស ការមិនដឹងប្រមាណ ការមិនពិចារណា ក្នុងភោជននោះណា នេះហៅថា ការមិនដឹងប្រមាណក្នុងភោជន ។

[ ៣៦៣ ] បណ្ដាធម៌ទាំងនោះ ការរក្សាទ្វារក្នុងឥន្ទ្រិយ តើដូចម្ដេច ។

បុគ្គលខ្លះ ក្នុងលោកនេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ លិទ្ធភ្លក្សដោយអណ្តាត ។បេ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។បេ។ ដឹងធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ និងសេចក្តីគ្រប់គ្រង អាការគ្រប់គ្រង ការរក្សា ការសង្រួមនូវឥន្ទ្រិយទាំង ៦ នេះណា នេះហៅថា ការរក្សាទ្វារក្នុងឥន្ទ្រិយ ។ បណ្តាធម៌ទាំងនោះ ការដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ពិចារណាដោយឧបាយប្រាជ្ញា ហើយទើបបរិភោគនូវអាហារ មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាង គឺបរិភោគដើម្បីតាំងនៅនៃកាយនេះ ដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះនូវព្រហ្មចរិយធម៌តែប៉ុណ្ណោះ អាត្មាអញ នឹងកម្ចាត់បង់នូវវេទនាចាស់ផង នឹងមិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថក្តី ការ

មិនមានទោសក្តី ការនៅជាសុខសប្បាយក្តីនឹងមានដល់អញ សេចក្តីសន្តោស ការដឹងប្រមាណ ការពិចារណាដូច្នេះ ក្នុងភោជននោះណា នេះហៅថា ការដឹងប្រមាណក្នុងភោជន ។

[ ៣៦៤ ] បណ្តាធម៌ទាំងនោះ ការភ្លេចស្មារតី តើដូចម្តេច ។ ការគ្មានស្មារតី ការនឹកមិនឃើញ ការភ្លេចស្មារតី ការមិនមានស្មារតី ការមិនរឭក ការមិនបានចាំទុក ការភ្លេចភ្លាំង និងការវង្វេងណា នេះហៅថា ការភ្លេចស្មារតី ។ បណ្តាធម៌ទាំងនោះ សេចក្តីមិនដឹងខ្លួន តើដូចម្តេច ។ ការមិនដឹង ការមិនឃើញ ។បេ។ គន្លឹះគឺអវិជ្ជា សេចក្តីវង្វេងជាអកុសលមូលណា នេះហៅថា សេចក្តីមិនដឹងខ្លួន ។

[ ៣៦៥ ] បណ្តាធម៌ទាំងនោះ ស្មារតី តើដូចម្តេច ។ ការមានស្មារតី ការនឹកឃើញ ការនឹករឭក ស្មារតី សេចក្តីរឭក ការចាំទុក ការមិនភ្លេចភ្លាំង ការមិនវង្វេង សតិ ( ការរឭក ) ឥន្ទ្រិយគឺសតិ ពលគឺសតិ ការនឹកត្រូវណា នេះហៅថា ស្មារតី ។ បណ្តាធម៌ទាំងនោះ សេចក្តីដឹងខ្លួន តើដូចម្តេច ។ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា នេះហៅថា សេចក្តីដឹងខ្លួន ។

[ ៣៦៦ ] បណ្តាធម៌ទាំងនោះ កម្លាំងគឺការពិចារណា តើដូចម្តេច ។ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការយល់ត្រូវណា នេះហៅថា កម្លាំងគឺការពិចារណា ។ បណ្តាធម៌ទាំងនោះ កម្លាំងគឺភាវនា តើដូចម្តេច ។ ការគប់រក ការអប់រំ ការធ្វើឲ្យច្រើននូវពួកកុសលធម៌

ណា នេះហៅថា កម្លាំងគឺភាវនា សូម្បីពោជ្ឈង្គទាំង ៧ ក៏ហៅថា កម្លាំងគឺភាវនាដែរ ។

[ ៣៦៧ ] បណ្ដាធម៌ទាំងនោះ សមថៈ ( សភាពរម្ងាប់ធម៌ជាសត្រូវ ) តើដូចម្ដេច ។ ការឋិតនៅនៃចិត្ត ។បេ។ ការតម្កល់ចិត្តត្រូវណា នេះហៅថា សមថៈ ។ បណ្ដាធម៌ទាំងនោះ វិបស្សនា ( ធម្មជាតិឃើញដោយអាការផ្សេងៗ ) តើដូចម្ដេច ។ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណា សេចក្ដីយល់ត្រូវណា នេះហៅថា វិបស្សនា ។

[ ៣៦៨ ] បណ្ដាធម៌ទាំងនោះ និមិត្តគឺសមថៈ តើដូចម្ដេច ។ ការឋិតនៅនៃចិត្ត ។បេ។ ការតម្កល់ចិត្តត្រូវណា នេះហៅថា និមិត្តគឺសមថៈ ។ បណ្ដាធម៌ទាំងនោះ និមិត្តគឺការផ្គងឡើង តើដូចម្ដេច ។ ការប្រារព្ធព្យាយាមប្រកបដោយចិត្ត ។បេ។ ព្យាយាមត្រូវណា នេះហៅថា និមិត្ត គឺការផ្គងឡើង ។

[ ៣៦៩ ] បណ្ដាធម៌ទាំងនោះ ការផ្គងឡើង តើដូចម្ដេច ។ ការប្រារព្ធព្យាយាម ប្រកបដោយចិត្ត ។បេ។ ព្យាយាមត្រូវណា នេះហៅថា ការផ្គងឡើង ។ បណ្ដាធម៌ទាំងនោះ ការមិនរាយមាយ តើដូចម្ដេច ។ ការឋិតនៅនៃចិត្ត ។បេ។ ការតម្កល់ចិត្តត្រូវណា នេះហៅថា ការមិនរាយមាយ ។

[ ៣៧០ ] បណ្ដាធម៌ទាំងនោះ វិបត្តិនៃសីល តើដូចម្ដេច ។ ការប្រព្រឹត្តល្មើសប្រកបដោយកាយ ការប្រព្រឹត្តល្មើសប្រកបដោយវាចា ការប្រព្រឹត្តល្មើសប្រកបដោយកាយនិងវាចាណា នេះហៅថា វិបត្តិនៃសីល សូម្បីទ្រុស្ដ

សីលទាំងអស់ក៏ហៅថា វិបត្តិនៃសីលដែរ ។ បណ្ដាធម៌ទាំងនោះ វិបត្តិនៃទិដ្ឋិ តើដូចម្ដេច ។ ( សេចក្ដីយល់ឃើញ ) ថា ទានដែលគេឲ្យហើយមិនមានផល បូជាធំមិនមានផល បូជាតូចមិនមានផល ផលវិបាកនៃកម្មដែលគេធ្វើល្អ ធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ ពួកសត្វជាឱបបាតិកៈកំណើតមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោកអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្ដមដោយខ្លួនឯងហើយសម្ដែងបានក៏មិនមាន និងទិដ្ឋិ ដំណើរគឺទិដ្ឋិ ។បេ។ សេចក្ដីប្រកាន់ក្នុងការស្វែងរកខុសណា ដែលមានសភាពបែបនេះ នេះហៅថា វិបត្តិនៃទិដ្ឋិ សូម្បីមិច្ឆាទិដ្ឋិទាំងអស់ ក៏ហៅថា វិបត្តិនៃទិដ្ឋិដែរ ។

[ ៣៧១ ] បណ្ដាធម៌ទាំងអស់ ការបរិបូណ៌ដោយសីល តើដូចម្ដេច ។ ការមិនប្រព្រឹត្តល្មើសប្រកបដោយកាយ ការមិនប្រព្រឹត្តល្មើសប្រកបដោយវាចា ការមិនប្រព្រឹត្តល្មើសប្រកបដោយកាយនិងវាចា នេះហៅថា ការបរិ-បូណ៌ដោយសីល សូម្បីការសង្រួមក្នុងសីលទាំងអស់ក៏ហៅថា ការបរិបូណ៌ដោយសីលដែរ ។ បណ្ដាធម៌ទាំងនោះ ការបរិបូណ៌ដោយទិដ្ឋិ តើដូចម្ដេច ។ ( សេចក្ដីយល់ឃើញ ) ថា ទានដែលគេឲ្យហើយមានផល បូជាធំមានផល បូជាតូចមានផល ផលវិបាកនៃកម្មដែលគេធ្វើល្អនិងធ្វើអាក្រក់មាន លោកនេះមាន លោកខាងមុខមាន មាតាមានគុណ បិតាមានគុណ ពួកសត្វជាឱបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកប្រព្រឹត្តល្អ

ប្រតិបត្តិត្រឹមត្រូវ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្ដែងបានមាន និងប្រាជ្ញា ការដឹងច្បាស់ ។បេ។ សេចក្ដីមិនវង្វេង ការពិចារណាធម៌ សេចក្ដីយល់ត្រូវណា ដែលមានសភាពបែបនេះ នេះហៅថា ការបរិបូណ៌ដោយទិដ្ឋិ សូម្បីសម្មាទិដ្ឋិទាំងអស់ ក៏ហៅថា ការបរិបូណ៌ដោយទិដ្ឋិដែរ ។

[ ៣៧២ ] បណ្ដាធម៌ទាំងនោះ ការបរិសុទ្ធនៃសីល តើដូចម្ដេច ។ ការមិនប្រព្រឹត្តល្មើសប្រកបដោយកាយ ការមិនប្រព្រឹត្តល្មើសប្រកបដោយវាចា ការមិនប្រព្រឹត្តល្មើសប្រកបដោយកាយនិងវាចា នេះហៅថា ការបរិសុទ្ធនៃសីល សូម្បីការសង្រួមក្នុងសីលទាំងអស់ ក៏ហៅថា ការបរិសុទ្ធនៃសីលដែរ ។ បណ្ដាធម៌ទាំងនោះ ការបរិសុទ្ធនៃទិដ្ឋិ តើដូចម្ដេច ។ កម្មស្សកតញ្ញាណ ( ការដឹងច្បាស់កម្មជារបស់ខ្លួន ) សច្ចានុលោមិកញ្ញាណ ( ការដឹងច្បាស់អនុលោមតាមសច្ចៈ ៤ ) ការដឹងច្បាស់ របស់បុគ្គលអ្នកព្រមព្រៀងដោយមគ្គ ការដឹងច្បាស់របស់បុគ្គលអ្នកព្រមព្រៀងដោយផល ( នេះហៅថា ការបរិសុទ្ធនៃទិដ្ឋិ ) ។

[ ៣៧៣ ] ពាក្យថា ការបរិសុទ្ធនៃទិដ្ឋិ បានដល់ ប្រាជ្ញា ការដឹងច្បាស់ ។បេ។ សេចក្ដីមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវ ។ ពាក្យថា សេចក្ដីព្យាយាមនៃបុគ្គលដែលមានទិដ្ឋិសមគួរ បានដល់ សេចក្ដីប្រារព្ធព្យាយាមប្រកបដោយចិត្ត ។បេ។ ការព្យាយាមត្រូវ ។

[ ៣៧៤ ] ពាក្យថា សង្វេគ បានដល់ ជាតិភ័យ ជរាភ័យ ព្យាធិភ័យ

មរណភ័យ ។ ពាក្យថា ទីដែលគួរសង្វេគ បានដល់ ជាតិ ជរា ព្យាធិ មរណៈ ។ ពាក្យថា សេចក្តីព្យាយាមដោយឧបាយប្រាជ្ញានៃបុគ្គលដែលមានសង្វេគ សេចក្តីថា ភិក្ខុក្នុងសាសនានេះ ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាម ដើម្បីញុំាងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតមិនឲ្យកើត ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាម ដើម្បីលះបង់អកុសលធម៌ដ៏លាមកដែលកើតហើយ ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាម ដើម្បីញុំាងកុសលធម៌ ដែលមិនទាន់កើតឲ្យកើតឡើង ញុំាងសេចក្តីប៉ុនប៉ងឲ្យកើត ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តាំងព្យាយាម ដើម្បីឋិតនៅ ដើម្បីមិនវិនាស ដើម្បីចម្រើនក្រៃលែង ដើម្បីធំទូលាយ ដើម្បីចម្រើន ដើម្បីបរិបូណ៌ឡើងនៃកុសលធម៌ដែលកើតហើយ ។

[ ៣៧៥ ] ពាក្យថា សេចក្តីមិនសន្តោសក្នុងកុសលធម៌ បានដល់សេចក្តី ប្រាថ្នាក្រៃលែងនៃបុគ្គលអ្នកមិនត្រេកអរ ក្នុងការចម្រើននូវកុសលធម៌ ។ ពាក្យថា សេចក្តីមិនបន្ធូបន្ថយក្នុងព្យាយាម បានដល់ ការធ្វើដោយគោរព ការធ្វើរឿយៗ ការធ្វើមិនឈប់ ការប្រព្រឹត្តមិនរួញរា ការមិនដាក់ចោលនូវសេចក្តីប៉ុនប៉ង ការមិនដាក់ចោលនូវធុរៈ ការសេព ការអប់រំ ការឲ្យរឿយៗក្នុងការចម្រើននូវកុសលធម៌ ។

[ ៣៧៦ ] ពាក្យថា វិជ្ជា បានដល់ វិជ្ជា ៣ គឺបុព្វេនិវាសានុស្សតិញ្ញាណ-

វិជ្ជា ១ សត្តានំចុតូបបាតញ្ញាណវិជ្ជា ១ អាសវក្ខយញ្ញាណវិជ្ជា ១ ។ ពាក្យថា វិមុត្តិ បានដល់ វិមុត្តិ ២ គឺ ការរួចស្រឡះនៃចិត្ត ១ ព្រះនិព្វាន ១ ។

[ ៣៧៧ ] ពាក្យថា សេចក្តីដឹងក្នុងធម៌ជាគ្រឿងអស់ទៅនៃកិលេស បានដល់ សេចក្តីដឹងនៃបុគ្គលដែលព្រមព្រៀងដោយមគ្គ ។ ពាក្យថា សេចក្តីដឹងក្នុងធម៌ ដែលធ្វើកិលេសមិនឲ្យកើតឡើងទៀត បានដល់ សេចក្តីដឹងនៃបុគ្គលដែលព្រមព្រៀងដោយផល ។

**ចប់ និក្ខេបកណ្ឌ ។**

# អដ្ឋកថា
# សុត្តន្តិកទុកនិក្ខេប

[ ៣៣៦-៣៧៧ ] បទទាំងឡាយ ក្នុងសុត្តន្តិកទុកៈ ដោយច្រើនមានអត្ថងាយយល់ហើយ ព្រោះខ្ញុំបានចែកសម្តែងដោយអត្ថ ក្នុងមាតិកាកថាហើយ ព្រោះនិទ្ទេសបទនៃសុត្តន្តិកទុកៈទាំងនោះ យល់ងាយ ដោយន័យដែលធ្លាប់ពោលមកហើយនុ៎ះឯង ។ តែក្នុងទីនេះ ខ្ញុំនឹងសម្តែងត្រឹមតែអត្ថដែលផ្សេងគ្នា ដូចតទៅនេះថា

គប្បីជ្រាបវិនិច្ឆ័យក្នុងវិជ្ជូបមទុកៈមុន បានឮថា បុរសដែលមានចក្ខុដើរតាមផ្លូវក្នុងវេលាយប់មានមេឃងងឹត ផ្លូវរមែងមិនប្រាកដ ដល់បុរសនោះ ព្រោះងងឹត ផ្លេកបន្ទោរភ្លឺហើយកម្ចាត់ងងឹតទៅ ពេលនោះផ្លូវក៏ប្រាកដដល់បុរសនោះព្រោះប្រាសចាកងងឹត ។ ទើបបុរសនោះដើរតាមផ្លូវតទៅ សូម្បីគ្រាទីពីរ ងងឹតក៏រមែងគ្របដណ្តប់ទៀត ទើបផ្លូវមិនប្រាកដ ផ្លេកបន្ទោរភ្លឺហើយកម្ចាត់ងងឹតនោះ កាលប្រាសចាកងងឹតហើយផ្លូវក៏បានប្រាកដ ។ ទើបបុរសនោះដើរទៅតាមផ្លូវ ក្នុងលើកទីបីតទៅ ងងឹតបានគ្របដណ្តប់ហើយ ផ្លូវក៏មិនប្រាកដ ។ ផ្លេកបន្ទោរជាលឡើងហើយ ក៏កម្ចាត់ងងឹតទៅ ។

បណ្តាសេចក្តីឧបមាទាំងនោះ ការផ្តើមវិបស្សនារបស់អរិយសាវកដើម្បីប្រយោជន៍ចាក់ធ្លុះសោតាបត្តិមគ្គ ដូចការដើរតាមផ្លូវងងឹត របស់បុរសដែលមានចក្ខុ ។ ងងឹតដែលបិទបាំងសច្ចៈដូចវេលាដែលផ្លូវមិនប្រាកដក្នុងងងឹត ។ វេលាដែលពន្លឺ គឺសោតាបត្តិមគ្គកើតឡើង កម្ចាត់ងងឹតបិទបាំងសច្ចៈ ដូច

វេលាដែលផ្ទេកបន្ទោរដាលប្រវាត់ឡើង កម្ចាត់ងងឹត ។ វេលាដែលសច្ចៈ ៤ ប្រាកដដល់សោតាបត្តិមគ្គ ដូចវេលាដែលផ្លូវប្រាកដ ក្នុងការប្រាសចាកងងឹត ។ ការប្រាកដរបស់ផ្លូវ គឺការប្រាកដរបស់សច្ចៈ ៤ ដល់បុគ្គលដែលដល់ព្រមដោយមគ្គនោះឯង ។

ការផ្ដើមវិបស្សនាដើម្បីសម្រេចសកទាគាមិមគ្គ ដូចការដើរផ្លូវតទៅក្នុងលើកទីពីរ ។ ងងឹតដែលបិទបាំងសច្ចៈ ដូចវេលាដែលផ្លូវមិនប្រាកដក្នុងងងឹត ។ វេលាដែលពន្លឺ គឺសកទាគាមិមគ្គកើតឡើង កម្ចាត់ងងឹតដែលបិទបាំងសច្ចៈ ដូចវេលាដែលផ្ទេកបន្ទោរដាលប្រវាត់ឡើងគ្រាទីពីរ កម្ចាត់ងងឹត វេលាដែលសច្ចៈ ៤ ប្រាកដដល់សកទាគាមិមគ្គ ដូចវេលាដែលផ្លូវប្រាកដក្នុងការប្រាសចាកងងឹត ។ ការប្រាកដរបស់ផ្លូវ គឺការប្រាកដរបស់សច្ចៈ ៤ ដល់បុគ្គល ដែលដល់ព្រមដោយមគ្គនុ៎ះឯង ។ ការផ្ដើមវិបស្សនា ដើម្បីសម្រេចអនាគាមិមគ្គ ដូចបុគ្គលដើរតាមផ្លូវតទៅក្នុងគ្រាទីបី ។ ងងឹតដែលបិទបាំងសច្ចៈ ដូចវេលាដែលផ្លូវមិនប្រាកដក្នុងវេលាងងឹត ។ វេលាដែលពន្លឺ គឺអនាគាមិមគ្គកើតឡើងកម្ចាត់ងងឹតបិទបាំងសច្ចៈ ដូចវេលាដែលផ្ទេកបន្ទោរដាលប្រវាត់ឡើងក្នុងគ្រាទីបី កម្ចាត់ងងឹត ។ វេលាដែលសច្ចៈ ៤ ប្រាកដដល់អនាគាមិមគ្គ ដូចវេលាដែលផ្លូវប្រាកដក្នុងវេលាប្រាសចាកងងឹត ។ ការប្រាកដរបស់ផ្លូវ ក៏គឺការប្រាកដរបស់សច្ចៈ ៤ ដល់បុគ្គលដែលដល់ព្រមដោយមគ្គនុ៎ះឯង ។

ម្យ៉ាងទៀត ផ្ទាំងថ្មឬកែវមណី ដែលឈ្មោះថា មិនបែកទៅដោយវជិរៈ

( នុ្ទះ ) រមែងមិនមាន វជិរៈធ្លាក់ទៅក្នុងទីណា ទីនោះរមែងជាការដែលត្រូវកម្ចាត់ហើយនោះឯង កាលបាញ់ទៅ រមែងបាញ់មិនឲ្យមានអ្វីនៅសេសសល់ ដែលឈ្មោះថា ផ្លូវដែលវជិរៈឆ្វងកាត់ហើយ នឹងមិនប្រព្រឹត្តទៅតាមប្រក្រតីទៀត ឈ្មោះថាកិលេសដែលមិនត្រូវអរហត្តមគ្គប្រហារហើយ រមែងមិនមានយ៉ាងនោះដូចគ្នា ។ សូម្បីអរហត្តមគ្គក៏ដូចរន្ទះ រមែងកម្ចាត់កិលេសទាំងអស់ គឺកាលធ្វើកិលេសឲ្យអស់ទៅ រមែងឲ្យអស់ទៅដោយមិនសេសសល់ ។ ឈ្មោះថា ការត្រឡប់មកកើតទៀតនៃកិលេសដែលត្រូវអរហត្តមគ្គប្រហារហើយ រមែងមិនមាន ដូចផ្លូវដែលរន្ទះឆ្វងកាត់ហើយ មិនមានការប្រព្រឹត្តទៅតាមប្រក្រតីទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសពាលទុកៈ ដូចតទៅនេះថា

អហិរិកៈនិងអនោត្តប្បៈប្រាកដហើយ ក្នុងពាលជនទាំងឡាយ ។ មួយទៀត អហិរិកៈនិងអនោត្តប្បៈទាំងនោះនៅជាមូលនៃពាលធម៌ដ៏សេស ដ្បិតថា ជនដែលមិនមានហិរិ មិនមានឱត្តប្បៈ ឈ្មោះថា មិនធ្វើអកុសលណាមួយរមែងមិនមាន ព្រោះហេតុនោះ ទើបធម៌ទាំង ២ នេះ ទ្រង់ត្រាស់ញែកទុកមុននោះឯង ។ សូម្បីក្នុងធម៌ដែលមានចំណែកស ( សុក្កធម៌ ) ក៏មានន័យនេះឯង ។ ក្នុងកណ្ហទុកៈ ( ធម៌ខ្មៅ ) ក៏ដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃតបនីយទុកៈ ដូចតទៅនេះថា

បណ្ឌិតគប្បីជ្រាប ពួកធម៌ដុតកម្តៅ ព្រោះហេតុដែលធ្វើ និងព្រោះហេតុដែលមិនធ្វើ ។ មែនពិត កាយទុច្ចរិតជាដើម រមែងឲ្យក្តៅក្រហាយ ព្រោះ

ហេតុដែលធ្វើ កាយសុចរិតជាដើម រមែងឲ្យក្តៅក្រហាយ ព្រោះហេតុដែល មិនធ្វើ ។ ពិតយ៉ាងនោះ បុគ្គលរមែងក្តៅក្រហាយថា កាយទុច្ចរិត អញ ធ្វើហើយ និងរមែងក្តៅក្រហាយថា កាយសុចរិតអញមិនទាន់បានធ្វើ រមែង ក្តៅក្រហាយថា វចីទុច្ចរិត អញធ្វើហើយ ។បេ។ រមែងក្តៅក្រហាយថា មនោសុចរិត អញមិនទាន់បានធ្វើ ។ សូម្បីក្នុងអតបនីយធម៌ ( ពួកធម៌មិន ដុតកម្តៅ ) ក៏មានន័យនេះឯង ។

មែនពិត បុគ្គលដែលធ្វើសេចក្តីល្អ រមែងមិនក្តៅក្រហាយដោយគិតថា កាយសុចរិត អញធ្វើទុកហើយ រមែងមិនក្តៅក្រហាយដោយគិតថា កាយ-ទុច្ចរិតអញមិនបានធ្វើ រមែងមិនក្តៅក្រហាយដោយគិតថា វចីសុចរិត អញ ធ្វើហើយ ។បេ។ មិនក្តៅក្រហាយដោយគិតថា មនោទុច្ចរិត អញមិនបាន ធ្វើ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃអធិវចនទុកៈ ដូចតទៅនេះថា

បទថា **យា តេសំ តេសំ ធម្មានំ** បានដល់ ទ្រង់រួបរួមយកធម៌ទាំង អស់ ។ ដែលឈ្មោះថា **សង្ខា** ( ការរាប់ ) ព្រោះដែលគេប្រាប់ គឺដែល គេសន្ទនាគ្នា រមែងសន្ទនាគ្នា យ៉ាងដូចម្តេច រមែងសន្ទនាគ្នាដោយអាការ ច្រើនប្រការ យ៉ាងនេះថា យើង របស់យើង ជនដទៃ របស់ជនដទៃ ថាជា សត្វ ជាភាវៈ ជាបុរស ជាបុគ្គល ជានរៈ ជាមាណព ថាឈ្មោះតិស្សៈ ថា ឈ្មោះទត្ត គ្រែ តាំង ពូក ខ្នើយ វិហារ បរិវេណ ទ្វារ បង្អួច ដូច្នេះ ព្រោះហេតុនោះ ទើបឈ្មោះថា **សង្ខា** ។

ដែលឈ្មោះថា **សមញ្ញា** ( ការដឹងដោយប្រពៃ ) ព្រោះអត្ថថា រមែងដឹងដោយប្រពៃ ។ រមែងដឹងដោយប្រពៃ យ៉ាងដូចម្ដេច រមែងដឹងដោយប្រពៃថា យើង របស់យើង ។បេ។ ទ្វារ បង្អួច ព្រោះហេតុនោះទើបឈ្មោះថា **សមញ្ញា** ។ ដែលឈ្មោះថា **បញ្ញត្តិ** ព្រោះអត្ថថា ដែលគេរមែងតែងតាំង ។ ដែលឈ្មោះថា **វោហារោ** ព្រោះអត្ថថា ដែលគេរមែងហៅ រមែងហៅ យ៉ាងដូចម្ដេច រមែងហៅថា យើង របស់យើង ។បេ។ ទ្វារ បង្អួច ព្រោះហេតុនោះ ទើបឈ្មោះថា **វោហារោ** ។

បទថា **នាមំ** បានដល់ នាម ៤ យ៉ាងគឺ សាមញ្ញនាម ឈ្មោះទូទៅ ១ គុណនាម ឈ្មោះដោយគុណ ១ កិត្តិមនាម ឈ្មោះដោយការលើកសរសើរ ១ ឱបបាតិកនាម ឈ្មោះតាមដែលកើតឡើង ១ ។

បណ្ដានាម ៤ យ៉ាងនោះ នាមរបស់ព្រះរាជាថា **មហាសម្មត** ដែលព្រះមានព្រះភាគ ទ្រង់សំដៅដល់ ត្រាស់ទុក ( ក្នុងទីឃនិកាយបាដិកវគ្គ ) ថា ម្នាលវាសេដ្ឋៈ សត្វនោះមហាជនសន្មតហើយ ព្រោះហេតុនោះឯង ទើបអក្ខរៈជាដំបូងក៏កើតឡើងថា មហាសន្មត ដូច្នេះ ឈ្មោះថា សាមញ្ញនាម ព្រោះមហាជនក្នុងសម័យបឋមកប្បប្រជុំគ្នាតាំងទុក ។ នាមដែលមកហើយដោយគុណយ៉ាងនេះថា ព្រះធម្មកថិក អ្នកទ្រទ្រង់បង្សុកូលចីវរ ព្រះវិន័យធរ អ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកមានសទ្ធា អ្នកជ្រះថ្លាហើយ ដូច្នេះ ឈ្មោះថា គុណនាម ។

សូម្បីព្រះនាមរបស់ព្រះតថាគត មានច្រើនរយជាដើមថា **ភគវា អរហំ**

**សម្មាសម្ពុទ្ធោ** ដូច្នេះ ក៏ឈ្មោះថា **គុណនាម** ដូចគ្នា ព្រោះហេតុនោះទើបបោរាណាចារ្យពោលថា

ព្រះពុទ្ធទ្រង់ស្វែងរកនូវគុណដ៏ធំ មានព្រះនាមដោយព្រះគុណរបស់ព្រះអង្គ រាប់មិនអស់ បណ្ឌិតគប្បីលើកយកព្រះនាមដោយព្រះគុណ ឡើងមកសម្តែង សូម្បីរាប់ពាន់ព្រះនាមដូច្នេះ ។

ចំណែកពួកញាតិទាំងឡាយ ដែលតាំងនៅក្នុងទីជិត ធ្វើសក្ការៈដល់ព្រះទក្ខិណេយ្យបុគ្គលទាំងឡាយ ក្នុងថ្ងៃដាក់ឈ្មោះរបស់ទារកដែលកើតមក នាំគ្នាគិតកំណត់ហើយធ្វើការដាក់ឈ្មោះថា ទារកនេះឈ្មោះនោះ នាមនេះឈ្មោះថា កិត្តិមនាម ។ មួយទៀត បញ្ញត្តិដំបូង រមែងធ្លាក់មកដល់បញ្ញត្តិក្រោយ វោហារដំបូង រមែងធ្លាក់មកដល់វោហារក្រោយ ដូចព្រះចន្ទ សូម្បីក្នុងកប្បមុន ឈ្មោះថា ព្រះចន្ទ សូម្បីក្នុងបច្ចុប្បន្ន ក៏ហៅថា ព្រះចន្ទដូចគ្នា ព្រះអាទិត្យ សមុទ្ទ បឋវី បព៌ត ក្នុងអតីតឈ្មោះថា បព៌ត សូម្បីក្នុងបច្ចុប្បន្ន ក៏ហៅថា បព៌តនុ៎ះឯង នាមនេះឈ្មោះថា **ឱបបាតិកនាម** ។ នាមសូម្បីទាំង ៤ យ៉ាងនេះ ក៏ជានាមដូចគ្នាតែមួយនុ៎ះឯង ។

បទថា **នាមកម្មំ** គឺការឲ្យឈ្មោះ ។ បទថា **នាមធេយ្យំ** គឺការកំណត់ឈ្មោះ ។ បទថា **និរុត្តិ** បានដល់ ការហៅឈ្មោះ ។ បទថា **ព្យញ្ជនំ** បានដល់ ការប្រកាសឈ្មោះ ព្រោះការប្រាប់ឈ្មោះនេះ រមែងធ្វើសេចក្តីសម្គាល់ឲ្យប្រាកដ ហេតុនោះទើបត្រាស់ទុកយ៉ាងនោះ ។ បទថា **អភិលា-**

ចោ បានដល់ ការពោលដល់ឈ្មោះនុ៎ះឯង ។

បទថា **សព្វេវ ធម្មា អធិវចនបថា** បានដល់ ឈ្មោះថា ធម៌ដែលមិនជាផ្លូវនៃធម៌ជាឈ្មោះ រមែងមិនមាន ធម៌មួយរមែងរួមចុះក្នុងធម៌ទាំងអស់ ធម៌ទាំងអស់ក៏ប្រជុំចុះក្នុងធម៌មួយ សេចក្ដីនេះតើដូចម្ដេច គឺថា នាមប្បញ្ញត្តិនេះជាធម៌មួយ ធម៌មួយនោះ រមែងសង្គ្រោះចូលក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ទាំងអស់ គឺសត្តក្ដី សង្ខារក្ដី ឈ្មោះថា ផុតចាកឈ្មោះមិនមាន ។

សូម្បីដើមឈើក្នុងព្រៃនិងភ្នំជាដើម ក៏នៅជាភារៈ ( ពាក្យនិយាយ ) របស់អ្នកជនបទ ព្រោះថា អ្នកជនបទទាំងនោះត្រូវគេសួរថា ដើមឈើនេះឈ្មោះអ្វី ក៏នឹងប្រាប់ឈ្មោះ ដែលខ្លួនស្គាល់ថា ដើមឈើនោះជាដើមគគីរ ដូច្នេះ ពួកគេមិនស្គាល់ឈ្មោះដើមឈើណា ក៏នឹងនិយាយថា ដើមឈើនោះមិនមានឈ្មោះ ដូច្នេះ សូម្បីពាក្យថា ដើមឈើមិនមានឈ្មោះ នោះក៏ជានាមធេយ្យ ( ការដាក់ឈ្មោះ ) របស់ដើមឈើនោះនុ៎ះឯង ។ សូម្បីត្រីនិងអណ្ដើកជាដើម ក្នុងសមុទ្រក៏មានន័យនេះដូចគ្នា ។ ទុកៈពីរក្រៅនេះ ( គឺនិរុត្តិទុកៈនិងបញ្ញត្តិទុកៈ ) ក៏មានន័យដូចទុកៈនេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃនាមរូបទុកៈ ដូចតទៅនេះថា

ដែលឈ្មោះថា **ឈាមំ** ដោយអត្ថថា ជានាមករណៈ ( ការឲ្យឈ្មោះ ) ដោយអត្ថថា ការបង្អោនទៅកាន់អារម្មណ៍ និងដោយអត្ថថា ការបង្អោនទៅ ។ បណ្ដាអត្ថទាំង ៣ នោះ ខន្ធ ៤ ឈ្មោះថា **ឈាម** ដោយអត្ថថា ការឲ្យឈ្មោះ ដូចព្រះនាមថា **មហាសម្មត** ជាឈ្មោះរបស់ព្រះបាទមហាសម្មតព្រះ

អង្គនោះ ព្រោះមហាជនសន្មតហើយយ៉ាងណា ឬថាមាតានិងបិតាតាំងឈ្មោះដែលកំណត់ឡើងដល់បុត្តយ៉ាងនេះថា កូននេះចូរឈ្មោះថា **តិស្សៈ** កូននេះចូរឈ្មោះថា **បុស្ស** យ៉ាងណា ឬថា **ឈាម** ដែលមកដោយគុណថា ព្រះធម្មកថិក ព្រះវិន័យធរយ៉ាងណា នាមរបស់ខន្ធ ៤ មានវេទនាខន្ធជាដើម យ៉ាងនោះក៏មិនមែន ព្រោះខន្ធ ៤ មានវេទនាខន្ធជាដើម ក៏ដូចមហាប្រឹថពីជាដើម រមែងកើតឡើងធ្វើនូវឈ្មោះដល់ខ្លួននោះឯង កាលវេទនាជាដើមទាំងនោះកើតឡើងហើយ ឈ្មោះរបស់ខន្ធ មានវេទនាជាដើមទាំងនោះ ក៏រមែងកើតឡើងដោយពិត មែនពិត បុគ្គលណាមួយនឹងនិយាយដល់វេទនា ដែលកើតឡើងហើយថា អ្នកចូរឈ្មោះថា វេទនា ក៏ទេដែរ កិច្ចដែលនឹងដាក់ឈ្មោះរបស់វេទនានោះក៏មិនមាន ។ កាលប្រឹថពីកើតឡើងហើយ កិច្ចដែលនឹងដាក់ឈ្មោះថា អ្នកចូរឈ្មោះថា ប្រឹថពី ដូច្នេះ មិនមាន កាលចក្កវាឡភ្នំសិនេរុ ព្រះចន្ទ ព្រះអាទិត្យ ផ្កាយនក្ខត្តឫក្សកើតឡើងហើយ កិច្ចដែលនឹងដាក់ឈ្មោះថា អ្នកចូរឈ្មោះថា ចក្កវាឡ អ្នកចូរឈ្មោះថា ភ្នំសិនេរុ អ្នកចូរឈ្មោះថា ផ្កាយនក្ខត្តឫក្ស មិនមាន នាមរមែងកើតឡើងហើយនុ៎ះឯង រមែងសង្គ្រោះចូលក្នុងឱបបាតិកបញ្ញត្តិ ( បានឈ្មោះតាមសភាវៈដែលកើតឡើង ) យ៉ាងណា កាលវេទនាកើតឡើងហើយក៏យ៉ាងនោះ កិច្ចដែលនឹងដាក់ឈ្មោះថា អ្នកចូរឈ្មោះថា វេទនា មិនមាន ។ កាលវេទនានោះកើតឡើងហើយ ឈ្មោះថា **វេទនា** ក៏រមែងកើតឡើងនុ៎ះឯង ។ សូម្បីក្នុងខន្ធមានសញ្ញាខន្ធជាដើម ក៏មានន័យនេះដូចគ្នា ។

មែនពិត ក្នុងអតីត វេទនា ក៏ឈ្មោះថាវេទនាទុំះឯង សញ្ញា ក៏ឈ្មោះថាសញ្ញា សង្ខារ ក៏ឈ្មោះថាសង្ខារ និងវិញ្ញាណក៏ឈ្មោះថាវិញ្ញាណដូចគ្នា សូម្បីក្នុងអនាគត ក្នុងបច្ចុប្បន្ន ក៏ដូចគ្នា ។ ទោះបីព្រះនិព្វាន ក៏ឈ្មោះថាព្រះនិព្វានទុំះឯងសព្វកាល ព្រោះហេតុនោះ ទើបខន្ធ ៤ ឈ្មោះថា **នាម** ដោយអត្ថថា ការឲ្យឈ្មោះ ។

ចំណែកក្នុងពាក្យថា ដោយអត្ថថា ការបង្អោនទៅកាន់អារម្មណ៍នេះ ខន្ធ ៤ ឈ្មោះថា **នាម** មែនពិត ខន្ធ ៤ ទាំងនោះ រមែងបង្អោនទៅចំពោះអារម្មណ៍ ។ នាមទាំងអស់ឈ្មោះថា **នាម** ដោយអត្ថថា ឲ្យបង្អោនទៅ ។ ព្រោះថា ខន្ធ ៤ រមែងញុំាងគ្នានឹងគ្នា ឲ្យបង្អោនទៅក្នុងអារម្មណ៍ ។ ព្រះនិព្វានរមែងញុំាងធម៌មិនមានទោសឲ្យបង្អោនទៅក្នុងខ្លួន ព្រោះជាអារម្មណប្បច្ច័យនិងអធិបតិប្បច្ច័យ ។

ក្នុងអវិជ្ជាទុកនិទ្ទេស ព្រះមានព្រះភាគ ទ្រង់កំណត់អវិជ្ជានិងភវតណ្ហា ដើម្បីសម្ដែងការកើតឡើងរបស់វដ្ដមូល ។

( ក្នុងភវទិដ្ឋិនិទ្ទេស ) បទថា **ភវិស្សតិ អត្តា ច លោកោ ច** បានដល់ សស្សតទិដ្ឋិ ដែលប្រកាន់ខន្ធ ៥ ថាជាខ្លួននិងលោក ហើយប្រកាន់មាំដោយអាការប្រកាន់ថា ខន្ធបញ្ចកនោះនឹងកើត ។ ទិដ្ឋិទី ២ គឺឧច្ឆេទទិដ្ឋិ ដែលប្រកាន់មាំដោយអាការថា ខន្ធ ៥ នោះនឹងមិនកើត ។

( ក្នុងបុព្វន្តានុទិដ្ឋិទុកនិទ្ទេស ) បទថា **បុព្វន្តំ អារព្ភ** បានដល់ ធ្វើចំណែកអតីតឲ្យជាអារម្មណ៍ ទ្រង់កាន់យកបុព្វន្តានុទិដ្ឋិ ១៨ ដែលមកក្នុង

ព្រហ្មជាលសូត្រដោយពាក្យនេះថា ប្រារព្ធចំណែកអតីត ។

បទថា **អបរន្តំ អារព្ភ** បានដល់ ធ្វើចំណែកអនាគត ឲ្យជាអារម្មណ៍ ទ្រង់កាន់យកអបរន្តានុទិដ្ឋិ ៤៤ ដែលមកក្នុងព្រហ្មជាលសូត្រនោះឯងដោយពាក្យនេះថា ប្រារព្ធចំណែកអនាគត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទោវចស្សតានិទ្ទេស ដូចតទៅនេះថា

បទថា **សហធម្មិកេ វុច្ចមានេ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់បញ្ញត្តិសិក្ខាបទឯណា ដែលឈ្មោះថា សហធម៌ កាលភិក្ខុត្រូវចន្លុលដល់វត្ថុក្នុងសិក្ខាបទនោះ ត្រូវកាត់អាបត្តិថា លោកត្រូវអាបត្តិឈ្មោះនេះ សូមលោកសម្ដែងអាបត្តិ សូមលោកចេញចាកអាបត្តិ សូមធ្វើតបអាបត្តិ ដូច្នេះ ។

ក្នុងបទថា **ទោវចស្សាយំ** ជាដើម ( មានសេចក្ដីដូចតទៅនេះថា ) កម្មយ៉ាងនេះរបស់បុគ្គលដែលត្រូវជាស់តឿន ក៏នៅតែប្រដៅក្រ ដោយការតបតខ្វះ ដោយការមិនព្រមទទួលឱវាទដោយគោរពខ្វះ ឈ្មោះថា **ទោវ-ចស្សាយំ** ( សេចក្ដីប្រដៅក្រ ) ។ កិរិយារបស់អ្នកប្រដៅក្រនុ៎ះឯង ហៅថា **ទោវចស្សំ** ( ការស្ដីថាក្រ ) ដូច្នេះក៏មាន ។ ភាវៈនៃអ្នកប្រដៅក្រនោះ ឈ្មោះថា **ទោវចស្សិយំ** ( ភាពនៃបុគ្គលដែលគេប្រដៅក្រ ) ពាក្យក្រៅអំពីនេះមានពាក្យថា ភាពនៃបុគ្គលប្រកាន់យកខាងខុសជាដើម ជាវេវចនៈរបស់ភាពនៃអ្នកប្រដៅក្រនុ៎ះឯង ។

បទថា **វិប្បដិកុលគាហិតា** បានដល់ ការប្រកាន់ដោយមិនស្របតាមបុគ្គលឈ្មោះថា **វិបច្ចនីកសាតោ** ព្រោះអត្ថថា បុគ្គលនោះ មានសេចក្ដី

ត្រេកអរដោយការប្រកែកប្រណាំង ពោលគឺដោយមិនស្របតាម ។ ពាក្យនេះជាឈ្មោះរបស់បុគ្គល ដែលកាន់យកពាក្យប្រកែកប្រណាំង ហើយបានសេចក្តីសុខថា ត្រឹមតែពាក្យមួយម៉ាត់ប៉ុណ្ណោះ អញធ្វើឲ្យបុគ្គលនេះ ស្ងាត់មាត់បាន ។ ភាវៈរបស់បុគ្គលអ្នកពេញចិត្ត ក្នុងការប្រកែកប្រណាំងនោះ ឈ្មោះថា **វិបច្ចនីកសាតតា** ។ ភាវៈនៃបុគ្គលអ្នកមិនអើពើដោយអំណាចការមិនទទួលយកឱវាទ ឈ្មោះថា **អនាទរិយំ** ពាក្យក្រៅអំពីនេះមានភាវៈនៃបុគ្គលមិនយកចិត្តទុកដាក់ជាដើម ជាវេវចនៈនៃការមិនអើពើនោះឯង ។ម្យ៉ាងវិញទៀត អាការដែលមិនអើពើ ឈ្មោះថា **អនាទរតា** ។

ភាវៈដែលមិនគោរព ដែលកើតឡើងដោយអំណាចការមិនទៅដោយសេចក្តីគោរពក្នុងគ្រូ ឈ្មោះថា **អគារវតា** ។ ភាវៈដែលមិនព្រមជឿស្តាប់ ដែលកើតឡើងដោយការមិនទៅក្នុងអំណាច ការមិនទៅដោយគោរពក្នុងបុគ្គលដែលជារច្បង ឈ្មោះថា **អប្បដិស្សវតា** ។

បទថា **អយំ វុច្ចតិ** សេចក្តីថា កិរិយានេះ គឺបែបនេះ ហៅថា **ទោវ-ចស្សតា** ។ **ទោវចស្សតា** នេះ ពោលដោយអត្ថ បានដល់ខន្ធ ៤ ដែលប្រព្រឹត្តទៅដោយអាការៈនោះ ឬបានដល់សង្ខារក្ខន្ធតែម្យ៉ាង ។ ក្នុងបាប-មិត្តតា ជាដើម ក៏មានន័យនេះឯង ។ មែនពិត ទោវចស្សតានិងបាបមិត្តតាជាដើម ឈ្មោះថា ជាចេតសិកធម៌ចំណែកមួយរមែងមិនមាន ។

ដែលឈ្មោះថា **អស្សទ្ធា** ព្រោះអត្ថថា សទ្ធារបស់បុគ្គលទាំងនោះ មិនមាន អធិប្បាយថា រមែងមិនជឿវត្ថុទាំងឡាយមានព្រះពុទ្ធជាដើម ។ បទថា

**ទុស្សីលា** មានអធិប្បាយថា ឈ្មោះថា ភាពអាក្រក់នៃសីល រមែងមិនមាន ទើបពាក្យថា **ទុស្សីលា** បានដល់ អ្នកមិនមានសីល ។ បទថា **អប្បស្សុតា** បានដល់ វៀរចាកការសិក្សា ។

ដែលឈ្មោះថា **មច្ឆរិនោ** ព្រោះអត្ថថា មានសេចក្ដីកំណាញ់ ៥ យ៉ាង ។ ដែលឈ្មោះថា **ទុប្បញ្ញា** បានដល់ គ្មានបញ្ញា ។ ឈ្មោះថា **សេវនា** ដោយអំណាចការគប់រក ។ ការសេពដ៏មានកម្លាំង ឈ្មោះថា **និសេវនា** ។ ការសេពដោយចំណែកទាំងអស់ ឈ្មោះថា **សំសេវនា** ។ម្យ៉ាងទៀត ទ្រង់បន្ថែមបទឧបសគ្គ ( **និ** ឧបសគ្គនិង **សំ** ឧបសគ្គ ) ។ ត្រាស់ការសេពដោយបទទាំង ៣ នោះឯង ។

បទថា **ភជនា** បានដល់ ការចូលទៅជិត ។ បទថា **សម្ភជនា** បានដល់ ការសេពគប់ដោយចំណែកទាំងពួង ឈ្មោះថា **សម្ភជនា** ។ ម្យ៉ាងវិញទៀត ទ្រង់បន្ថែមបទឧបសគ្គ ។ បទថា **ភត្តិ** បានដល់ សេចក្ដីស្រឡាញ់គ្នាយ៉ាងជិតស្និទ្ធ ។ បទថា **សម្ភត្តិ** បានដល់ សេចក្ដីស្រឡាញ់ដោយចំណែកទាំងអស់ ។ ម្យ៉ាងទៀត ទ្រង់បន្ថែមបទឧបសគ្គ ។ ត្រាស់សេចក្ដីស្រឡាញ់ជិតស្និទ្ធដោយពាក្យទាំងពីរនោះឯង ។

បទថា **តំសម្បវង្កតា** បានដល់ ភាវៈដែលទោរទន់ដោយកាយនិងចិត្តក្នុងបុគ្គលទាំងនោះ អធិប្បាយថា ការទោរទៅ ការទោរទន់ទៅ ការបង្អោនទៅ ក្នុងបុគ្គលនោះ ។ សូម្បីសោវចស្សតាទុកនិទ្ទេស ក៏គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយ ។

ក្នុងអាបត្តិកុសលតាទុកនិទ្ទេស បទថា **បញ្ចបិ អាបត្តិក្ខន្ធា** បានដល់អាបត្តិ ៥ កងទាំងនេះ តាមនិទ្ទេសនៃមាតិកាគឺ បារាជិក សង្ឃាទិសេស បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ។ បទថា **សត្តបិ អាបត្តិក្ខន្ធា** បានដល់អាបត្តិ ៧ កងទាំងនេះ តាមនិទ្ទេសនៃវិន័យគឺ បារាជិក សង្ឃាទិសេស ថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត ។ បញ្ញាដែលដឹងការកំណត់អាបត្តិទាំងនោះ មួយអន្លើដោយវត្ថុក្នុងអាបត្តិ ៥ កង ៧ កងទាំងនោះ ឈ្មោះថា **អាបត្តិកុសលតា** ។ ចំណែកបញ្ញាដែលដឹងការកំណត់ក្នុងការចេញចាកអាបត្តិព្រមទាំងកម្មវាចា ឈ្មោះថា **អាបត្តិវុដ្ឋានកុសលតា** ។

ក្នុងសមាបត្តិកុសលតាទុកនិទ្ទេស ដែលឈ្មោះថា **សមាបត្តិ** ព្រោះព្រះយោគីគប្បីចូល ។ ចំណែកបញ្ញាដែលដឹងការកំណត់អប្បនា មួយអន្លើដោយបរិកម្ម ឈ្មោះថា **សមាបត្តិកុសលតា** ។ ឈ្មោះថា **សមាបត្តិវុដ្ឋានកុសលតា** ព្រោះកាលតាំងចិត្តថា កាលព្រះចន្ទ ឬព្រះអាទិត្យ ឬផ្កាយនក្ខត្តឫក្សគោចរ មកកាន់ទីប្រមាណប៉ុណ្ណេះហើយ អញនឹងចេញចាកសមាបត្តិ ដូច្នេះ មានបញ្ញាជាគ្រឿងចេញចាកសមាបត្តិ ក្នុងសម័យនោះដោយមិនខុសក្លាំងក្លាត់ ។

ក្នុងធាតុកុសលតាទុកនិទ្ទេស បញ្ញាដែលដឹងការកំណត់ ក្នុងការរៀនមនសិការ ការស្តាប់ ការចងចាំនូវធាតុ ១៨ ឈ្មោះថា **ធាតុកុសលតា** ។ បញ្ញាដែលដឹងការរៀន មនសិការនូវធាតុទាំងនោះឯង ឈ្មោះថា **មនសិការ កុសលតា** ។

ក្នុងអាយតនកុសលតាទុកនិទ្ទេស បញ្ញាដែលដឹងការកំណត់ក្នុងការរៀន មនសិការ ការស្តាប់ ការចងចាំនូវអាយតនៈ ១២ ឈ្មោះថា **អាយតន-កុសលតា** ។

ម្យ៉ាងវិញទៀត បណ្តាកុសលតាទាំងនេះសូម្បីទាំង ៣ ( ធាតុកុស-លតា មនសិការកុសលតា អាយតនកុសលតា ) ការដឹងទាំងពួង គឺការរៀន មនសិការ ការស្តាប់ ការត្រិះរិះ ការចាក់ធ្លុះ ការពិចារណាឃើញរមែងសមគួរ ។ បណ្តាការដឹងទាំង ៦ នោះ ការស្តាប់ ការរៀន ការពិ-ចារណាឃើញជាលោកិយ ការចាក់ធ្លុះជាលោកុត្តរ ការត្រិះរិះ និងមនសិការជាលោកិយៈផង លោកុត្តរផងលាយគ្នា ។

បទថា **អវិជ្ជាបច្ចយា សង្ខារា** ជាដើម នឹងជាក់ច្បាស់ក្នុងបដិច្ច-សមុប្បាទវិភង្គ ។ បញ្ញាដែលដឹងថា ធម៌នេះជាបច្ច័យដល់ធម៌នេះ ដូច្នេះ ឈ្មោះថា **បដិច្ចសមុប្បាទកុសលតា** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឋានាឋានទុកនិទ្ទេស ដូចតទៅនេះថា

ពាក្យសូម្បីទាំង ២ នេះថា **ហេតូ បច្ចយា** ជាពាក្យវេវចនៈនៃគ្នានឹងគ្នា ។ មែនពិត ចក្ខុបសាទជាហេតុនិងជាបច្ច័យដល់ចក្ខុវិញ្ញាណដែលធ្វើរូបឲ្យជាអារម្មណ៍កើតឡើង ។ មួយទៀត សោតបសាទជាដើមក៏ជាហេតុនិងជាបច្ច័យដល់សោតវិញ្ញាណជាដើម ពូជទាំងឡាយ មានពូជស្វាយជាដើម ក៏ជាហេតុនិងជាបច្ច័យដល់ផ្លែស្វាយជាដើម ។

ក្នុងន័យទី ២ គប្បីជ្រាបសេចក្តីយ៉ាងនេះថា បទថា **យេ យេ ធម្មា**

ជាពាក្យសម្តែងបច្ច័យធម៌ ដែលជាវិសភាគៈគ្នា ។ បទថា **យេសំ យេសំ** ជាពាក្យសម្តែងដល់បច្ច័យសមុប្បន្នធម៌ ដែលជាវិសភាគៈគ្នា ។ បទថា **ន ហេតូ ន បច្ចយា** បានដល់ ចក្ខុបសាទ មិនជាហេតុ មិនជាបច្ច័យដល់សោតវិញ្ញាណដែលធ្វើសំឡេង ឲ្យជាអារម្មណ៍កើតឡើង ។ គប្បីជ្រាបអត្ថយ៉ាងនេះ សោតបសាទជាដើម មិនជាហេតុ មិនជាបច្ច័យដល់វិញ្ញាណដ៏សេស ពូជស្វាយជាដើម ក៏មិនជាហេតុ មិនជាបច្ច័យដល់ការកើតឡើងនៃដើមត្នោតជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអាជ្ជវៈនិងមទ្ទវទុកនិទ្ទេស ដូចតទៅនេះថា

បទថា **នីចចិត្តតា** ប៉ុណ្ណោះ ជាពាក្យដែលផ្សេងគ្នា ។ អត្ថនៃពាក្យនេះថា បុគ្គលឈ្មោះថា **នីចចិត្តោ** ព្រោះអត្ថថា មានចិត្តរាបទាបដោយមិនមានមានះ ។ ភាវៈនៃបុគ្គលអ្នកមានចិត្តរាបទាប ឈ្មោះថា **នីចចិត្តតា** ។ ពាក្យដ៏សេសមកហើយក្នុងបទភាជនីយនៃចិត្តុជុកតានិងចិត្តមុទុតាទុំះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងខន្តិទុកនិទ្ទេស ដូចតទៅនេះថា

ដែលឈ្មោះថា **ខន្តិ** ដោយអំណាចការអត់ធន់ ។ អាការនៃសេចក្តីអត់ធន់ ឈ្មោះថា **ខមនតា** ។ ដែលឈ្មោះថា **អធិវាសនតា** ព្រោះអត្ថថា ជាហេតុអត់សង្កត់ គឺជាហេតុលើកឡើងលើខ្លួន អត់ធន់ មិនតតាំង មិនជាសត្រូវ តាំងនៅ ។

ភាវៈនៃការមិនកាច ឈ្មោះថា **អចណ្ឌិក្កំ** ។ ក្នុងបទថា **អនសុរោបោ** មានអធិប្បាយថា ពាក្យដែលនិយាយចេញមកអាក្រក់ ព្រោះលើកឡើង

និយាយ មិនត្រឹមត្រូវ ហៅថា **អសុរោចោ** ។ ឈ្មោះថា **អឆសុរោចោ** ព្រោះមានសភាពផ្ទុយគ្នានឹងការនិយាយពាក្យអាក្រក់នោះ បានដល់ វាចាដែលបន្ទឺចេញមកល្អ ។ ក្នុងអធិការនេះ ទ្រង់សម្តែងដល់ហេតុដោយផលូបចារន័យយ៉ាងនេះ ។

បទថា **អត្តមនតា ចិត្តស្ស** បានដល់ ភាពដែលចិត្តជាចិត្តរបស់ខ្លួនដោយអំណាចសោមនស្ស អធិប្បាយថា ភាវៈនៃចិត្តជារបស់ខ្លួនឯង គឺភាពដែលចិត្តមិនព្យាបាទហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសោរច្ចទុកនិទ្ទេស ដូចតទៅនេះថា

បទថា **កាយិកោ អវីតិក្កមោ** បានដល់ កាយសុចរិត ៣ យ៉ាង ។ បទថា **វាចសិកោ អវីតិក្កមោ** បានដល់ វចីសុចរិត ៤ យ៉ាង ។ ដោយបទថា **កាយិកវាចសិកោ** នេះ ទ្រង់កំណត់កាន់យក អាជីវដ្ឋមកសីល ( សីលមានអាជីវៈជាគម្រប់ ៨ ) ដែលតាំងឡើងតាមកាយទ្វារ និងវចីទ្វារ ។ បទថា **ឥទំ វុច្ចតិ សោរច្ចំ** នេះ ត្រាស់ឈ្មោះសោរច្ចៈទុក ព្រោះវៀរដោយល្អចាកបាប ។ បទថា **សព្វោបិ សីលសំវរោ** នេះ ព្រះមានព្រះភាគ ត្រាស់ទុកដើម្បីទ្រង់សម្តែងការកំណត់សីលផ្លូវចិត្ត ព្រោះបុគ្គលមិនមែនប្រព្រឹត្តអនាចារដោយកាយនិងវាចាប៉ុណ្ណោះ សូម្បីដោយចិត្ត ក៏ត្រូវប្រព្រឹត្តដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសាខល្យទុកនិទ្ទេស ដូចតទៅនេះថា

បទថា **អណ្ឌកា** បានដល់ កើតជាពកកន្ទួលដោយវាចាជេរប្រទេចនិង

ចំអកជាដើម ព្រោះប្រកបដោយទោសៈ ដូចពកដែលកើតឡើង ត្រង់ដើមឈើដែលមានទោស ។

បទថា **កក្កសា** បានដល់ វាចាខូច គឺវាចានោះជាសំណល់ ដូចដើមឈើដែលខូច រមែងជាសំណល់ ជាលម្អិតហូរចេញមក ។ វាចាដែលជាសំណល់នោះ ដូចជាចាក់ដោតត្រចៀកចូលទៅ ដោយហេតុនោះទើបត្រាស់ថា ពុកស្អុយ ។

បទថា **បរកដុកា** បានដល់ ក្តៅក្រហាយ មិនជាទីគាប់ចិត្ត ឲ្យកើតទោសៈដល់អ្នកដទៃ ។ បទថា **បរាភិសជ្ជនី** បានដល់ ដូចជាមែកឈើដែលមានបន្លាខ្ទបថ្ពក់ស្បែកអ្នកដទៃទុក សូម្បីគេនឹងទៅក៏ធ្វើឲ្យជាប់ មិនឲ្យទៅ ។

បទថា **កោធសាមន្តា** បានដល់ ជាវាចាជិតចំពោះសេចក្តីក្រោធ ។ បទថា **អសមាធិសំវត្តនិកា** បានដល់ មិនប្រព្រឹត្តទៅដើម្បីអប្បនាសមាធិ ឬឧបចារសមាធិ ពាក្យទាំងអស់នោះ ជាវេវចនៈរបស់វាចាដែលមានទោសដោយប្រការដូច្នេះ ។

បទថា **តថារូបឹ វាចំ បហាយ** នេះ ត្រាស់ទុកដើម្បីសម្តែងថា វាចាទន់ភ្លន់សូម្បីប្រព្រឹត្តទៅក្នុងចន្លោះៗរបស់បុគ្គល ដែលមិនបានលះផរុសវាចាតាំងនៅ ក៏ឈ្មោះថា ជាវាចាមិនពីរោះនុ៎ះឯង ។

បទថា **នេឡា** អធិប្បាយថា ទោស ហៅថា **ឯឡំ** ទោសរបស់វាចានោះមិនមាន ព្រោះហេតុនោះ ទើបវាចានោះឈ្មោះថា **នេឡា** អធិប្បាយថា មិនមានទោស ដូចសីលដែលត្រាស់ទុក ( ក្នុងខុទ្ទកនិកាយខុទ្ទកបាឋ ) ថា

**នេលង្គោ សេតបច្ឆានោ** របៀអត្តភាព មានអវយវៈឥតទោស មានដំបូល ស ដូច្នេះ ។

បទថា **កណ្ណសុខា** បានដល់ សុខដល់ត្រចៀកទាំងគូ ព្រោះជាវាចាដ៏ពីរោះ ដោយព្យញ្ជនៈ គឺមិនធ្វើការចាក់ដោតត្រចៀកឲ្យកើតឡើង ដូចការចាក់ដោយម្ជុល ។

វាចាណា មិនញុំាងសេចក្ដីក្រោធឲ្យកើត រមែងញុំាងសេចក្ដីស្រឡាញ់ឲ្យកើតឡើងក្នុងសរីរៈ ព្រោះជាវាចាពីរោះដោយអត្ថ ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **បេមនីយា** ។

វាចាណា ចូលទៅកាន់ហឫទ័យ មិនមានអ្វីរាំងចូលទៅកាន់ចិត្តដោយងាយ ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **ហទយង្គមា** ។

វាចាណា ជារបស់មានក្នុងក្រុង ព្រោះជាវាចាបរិបូរណ៍ដោយគុណ ព្រោះហេតុនោះ ទើបវាចានោះឈ្មោះថា **បោរី** ។ កុមារីដែលល្អ ដូចជានារីដែលចម្រើនក្នុងក្រុង វាចាដែលពីរោះ ដូចជាវាចាដែលចម្រើនក្នុងក្រុង ព្រោះហេតុនោះ ទើបឈ្មោះថា **បោរី** ។ វាចានេះជារបស់អ្នកក្រុង ព្រោះហេតុនោះ ទើបឈ្មោះថា **បោរី** អធិប្បាយថា ជាសម្ដីរបស់អ្នកក្រុង ។ មែនពិតអ្នកក្រុងមានសម្ដីសមគួរ រមែងហៅបុគ្គលស្រករឪពុក ថាពុក រមែងហៅបុគ្គលដែលស្រករបងប្រុស ប្អូនប្រុស ថាបងប្រុស ប្អូនប្រុស ជាដើម ។

វាចាណា មានសភាពបែបនេះ រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តដល់ជនច្រើន ព្រោះហេតុនោះ ទើបវាចានោះ ឈ្មោះថា **ពហុជនកន្តា** ។

វាចាណា ធ្វើចិត្តឲ្យត្រជាក់ គឺធ្វើសេចក្ដីចម្រើននៃចិត្តដល់ជនច្រើន ដោយភាពជាវាចាដែលពេញចិត្តរបស់ជនច្រើននោះឯង ទើបវាចានោះ ឈ្មោះថា **ពហុជនមនាបា** ។ បទថា **យា តត្ថ** បានដល់ ក្នុងបុគ្គលនោះឯណា ។ បទថា **សណ្ហវាចតា** បានដល់ ភាពជាអ្នកមានវាចារៀបរយ ។ បទថា **សខិលវាចតា** បានដល់ ភាពជាអ្នកមានវាចាទន់ភ្លន់ ។ បទថា **អផរុស-វាចតា** បានដល់ ភាពជាអ្នកមានវាចាមិនរឹងត្អឹង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបដិសន្ថារទុកនិទ្ទេស ដូចតទៅនេះថា

បទថា **អាមិសបដិសន្ថារោ** បានដល់ ប្រហោង ( ស្នាមប្រេះស្រាំនៃភាពសាមគ្គី ) របស់ពួកជនដទៃជាមួយនឹងខ្លួនព្រោះមិនបានអាមិស រមែងបិទជិតបានដោយប្រការណា ការទទួលរាក់ទាក់ភ្ញៀវដោយអាមិសៈ ដោយប្រការនោះ ។

បទថា **ធម្មបដិសន្ថារោ** បានដល់ ចន្លោះប្រហោង របស់ពួកជនដទៃជាមួយនឹងខ្លួន ព្រោះការមិនបានធម៌ រមែងបិទជិតបានដោយប្រការណា ការទទួលរាក់ទាក់ភ្ញៀវដោយធម៌ ដោយប្រការនោះ ។

បទថា **បដិសន្ថារកោ ហោតិ** សេចក្ដីថា ចន្លោះប្រហោងរបស់លោកសន្និវាស មាន ២ ប៉ុណ្ណោះ បុគ្គលដែលធ្វើបដិសន្ថារ ( បិទនូវប្រហោង ) ទាំង ២ នោះ គឺបុគ្គលដែលធ្វើបដិសន្ថារនោះ រមែងបិទនូវប្រហោង គឺការធ្វើជានិច្ចដោយបដិសន្ថារទាំង ២ នេះ គឺដោយអាមិសបដិសន្ថារ ឬដោយធម្មបដិសន្ថារ ក្នុងអធិការនេះ គប្បីជ្រាបកថានេះចាប់តាំងអំពីដើម ។

ពិតណាស់ ភិក្ខុអ្នកធ្វើបដិសន្ថារ ឃើញអាគន្តុកភិក្ខុមក គប្បីក្រោកទទួល ទទួលបាត្រចីវរ ប្រគេនអាសនៈ បក់ដោយផ្ចិតស្លឹកត្នោត លាងជើងលាបប្រេង កាលមានទឹកដោះថ្លានិងស្ករអំពៅ គប្បីប្រគេនជាភេសជ្ជៈ គប្បីអើពើដោយទឹកផឹក គប្បីចាត់ចែងទីអាស្រ័យ ដោយអាការយ៉ាងនេះ ឈ្មោះថា ភិក្ខុធ្វើអាមិសបដិសន្ថារហើយដោយចំណែកមួយ ។

មួយទៀត ក្នុងវេលាល្ងាច កាលភិក្ខុដែលខ្ចីជាង នៅមិនទាន់មកកាន់ទីបម្រើរបស់ខ្លួនទុំះឯង គួរទៅកាន់សម្នាក់របស់ភិក្ខុអាគន្តុកៈនោះ គប្បីអង្គុយកុំសួរបញ្ហាដែលហួសវិស័យ សួរតែបញ្ហាក្នុងវិស័យរបស់លោក គឺមិនសួរថា ពួកលោករៀននិកាយណា គប្បីសួរថា អាចារ្យនិងឧបជ្ឈាយ៍ របស់លោកជំនាញគម្ពីរណា ដូច្នេះ ហើយសួរបញ្ហាក្នុងឋានៈដែលសមគួរ ។ បើលោកអាចឆ្លើយបាន សេចក្ដីនោះជាការល្អ ។ បើលោកមិនអាចឆ្លើយបាន ក៏គប្បីឆ្លើយឯង ដោយអាការយ៉ាងនេះ ឈ្មោះថា ភិក្ខុធ្វើធម្មបដិសន្ថារហើយដោយចំណែកមួយ ។

បើលោកនៅក្នុងសម្នាក់របស់ខ្លួន គប្បីនាំលោកទៅបិណ្ឌបាតជានិច្ច បើលោកប្រាថ្នាដើម្បីនឹងទៅ ថ្ងៃស្អែកឡើង គប្បីនាំលោកទៅក្នុងទីដែលលោកចង់ទៅ នាំលោកត្រាច់បិណ្ឌបាតក្នុងស្រុកមួយហើយ សឹមបញ្ជូនទៅ ។ បើពួកភិក្ខុទទួលនិមន្តន៍ទុកក្នុងទីដទៃ ភិក្ខុនោះប្រាថ្នានឹងទៅ ក៏គប្បីនាំទៅដែរ កាលលោកមិនប្រាថ្នានឹងទៅក្នុងទីនោះ ដោយពោលថា ទីនោះមិនគួរដល់ខ្ញុំ ក៏គប្បីបញ្ជូនពួកភិក្ខុដ៏សេសទៅ ហើយនាំលោកត្រាច់ទៅបិណ្ឌបាត អាមិស

ដែលខ្លួនបានហើយគួរប្រគេនលោក យ៉ាងនេះឈ្មោះថា ភិក្ខុធ្វើអាមិសបដិ-សន្ថារហើយ ។

សួរថា ភិក្ខុដែលធ្វើបដិសន្ថារ គប្បីប្រគេនអាមិសដែលខ្លួនបានហើយដល់អ្នកណា ឆ្លើយថា គួរប្រគេនភិក្ខុអាគន្តុកៈមុន ។ បើភិក្ខុមានអាពាធ ឬនៅមិនទាន់មានវស្សា មានសោត គប្បីប្រគេនដល់ភិក្ខុដែលមានអាពាធជាដើមនោះ គប្បីប្រគេនដល់អាចារ្យនិងឧបជ្ឈាយ៍ គប្បីប្រគេនដល់ភិក្ខុអ្នករក្សារបស់សង្ឃ តែភិក្ខុអ្នកបំពេញសារាណីយធម៌ គប្បីប្រគេនដល់ភិក្ខុទាំងឡាយដែលមកហើយ សូម្បីមួយរយជង មួយពាន់ជង ចាប់ផ្តើមអំពីថេរ-សនៈទៅ ចំណែកភិក្ខុអ្នកធ្វើបដិសន្ថារ គប្បីឲ្យដល់ភិក្ខុដែលមិនទាន់បានចេញទៅខាងក្រៅស្រុកហើយ ឃើញភិក្ខុឬភិក្ខុនីដែលជរា ឬឥតទីពឹង គប្បីប្រគេនដល់លោកទាំងនោះ ។ ក្នុងសេចក្តីនោះមានរឿងនេះជាឧទាហរណ៍ ។

បានឮថា កាលពួកចោរប្លន់ស្រុក ឈ្មោះថា គុត្តសាលៈ ក្នុងខណៈនោះឯង ព្រះខីណាសវត្ថេរីមួយរូប ចេញអំពីនិរោធសមាបត្តិហើយឲ្យភិក្ខុនីក្រមុំកាន់បង្វិចកណ្ឌ ហើយធ្វើដំណើរជាមួយមហាជន ក្នុងវេលាថ្ងៃត្រង់ដល់ទ្វារស្រុកនកុលនគរ អង្គុយនៅក្បែរគល់ឈើ ។ ក្នុងសម័យនោះ ព្រះមហានាគត្ថេរ អ្នកនៅក្នុងវិហារកាឡវល្លិមណ្ឌប ត្រាច់ទៅបិណ្ឌបាត ត្រង់ស្រុកនកុលនគរ ចេញមកឃើញព្រះថេរី ទើបសួរអើពើដោយកត្ត ព្រះថេរីឆ្លើយថា ខ្ញុំមិនមានបាត្រ ។ ព្រះថេរៈពោលថា សូមអ្នកនាងម្ចាស់ ឆាន់ដោយបាត្រនេះ បានឲ្យភត្តមួយអន្ទើដោយបាត្រ ។ ព្រះថេរីធ្វើភត្តកិច្ចស្រេច

ហើយ លាងបាត្រឲ្យព្រះថេរៈ ហើយពោលថា លោកម្ចាស់លំបាកដោយភិក្ខាចារ ត្រឹមតែថ្ងៃនេះប៉ុណ្ណោះ ចាប់តាំងអំពីថ្ងៃនេះទៅ ដែលឈ្មោះថាការលំបាកដោយភិក្ខាចាររបស់លោកម្ចាស់មិនមាន ចាប់តាំងអំពីថ្ងៃនោះ ដែលឈ្មោះថា បិណ្ឌបាតមានតម្លៃតិចជាងមួយកហាបណៈ មិនបានកើតឡើងដល់ព្រះថេរៈឡើយ នេះឈ្មោះថា **អាមិសបដិសន្ថារ** ។

ភិក្ខុកាលធ្វើអាមិសបដិសន្ថារនេះហើយ គួរតាំងនៅក្នុងចំណែកសង្គ្រោះប្រាប់កម្មដ្ឋានដល់ភិក្ខុនោះ គប្បីប្រាប់ធម៌ គប្បីកម្ចាត់សេចក្តីសង្ស័យ គប្បីធ្វើករណីយកិច្ចដែលកើតឡើង គប្បីឲ្យអព្ភាន វុដ្ឋានៈ មានត្ត និងបរិវាសអ្នកដែលគួរបព្វជ្ជា ក៏គប្បីឲ្យបព្វជ្ជា អ្នកដែលគួរឧបសម្បទា ក៏គប្បីឲ្យឧបសម្បទា ។ ការធ្វើកម្មវាចា សូម្បីដល់ភិក្ខុនីដែលប្រាថ្នាឧបសម្បទា ក្នុងសម្នាក់របស់ខ្លួនក៏គួរ នេះឈ្មោះថា **ធម្មបដិសន្ថារ** ។

ភិក្ខុអ្នកធ្វើបដិសន្ថារទាំង ២ នេះ រមែងញ៉ាំងលាភដែលនៅមិនទាន់កើតឡើងឲ្យកើតឡើងបាន រមែងធ្វើលាភដែលកើតឡើងហើយ ឲ្យរឹងរឹតតែមាំទាំឡើង រមែងរក្សាជីវិតរបស់ខ្លួន ក្នុងឋានៈដែលតានតឹង ( គឺប្រកបដោយភ័យដ៏កាចសាហាវ ) បាន ដូចព្រះថេរៈ ( ដែលធ្លាក់នៅក្នុងឋានៈដ៏លំបាក ) ទាំងដែលឱបបាត្រនោះឯង ចាប់កត្តចំណែកខាងលើចេញហើយ ចាក់កត្តមួយបាត្រថ្វាយដល់ព្រះបាទចោរនាគនោះឯង ។

ចំណែកក្នុងការញ៉ាំងលាភដែលមិនទាន់បានមក ឲ្យកើតឡើង បណ្ឌិតគប្បីសម្តែងដល់រឿងដែលព្រះបាទមហានាគ យាងគេចអំពីត្រើយអាយទៅ

កាន់ត្រើយនាយ ហើយបានទទួលការសង្គ្រោះក្នុងសម្នាក់របស់ព្រះថេរៈមួយរូប បានត្រឡប់មកតាំងនៅក្នុងរាជសម្បត្តិទៀត ទ្រង់ថ្វាយមហាភេសជ្ជៈឲ្យប្រព្រឹត្តទៅក្នុងទីជាវត្តសេតម្ពវិហារ ដរាបដល់អស់ជីវិត ។ ក្នុងការធ្វើលាភដែលកើតឡើងហើយឲ្យវិនាសទៅតែម្តងទាំ គប្បីសម្តែងរឿង ដែលពួកចោរបានទទួលបដិសន្ធារអំពីដៃរបស់ព្រះទីឃភាណកអភយត្ថេរហើយ មិនប្លន់ភណ្ឌៈក្នុងចេតិយបព៌ត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយគុត្តទ្វារតានិទ្ទេស ដូចតទៅនេះថា

បទថា **ចក្ខុនា រូបំ ទិស្វា** បានដល់ ឃើញរូប ដោយចក្ខុវិញ្ញាណ ដែលអាចក្នុងការឃើញរូប ដែលបានវោហារថា **ចក្ខុ** ដូច្នេះ ដោយអំណាចនៃហេតុ ។ បោរាណាចារ្យទាំងឡាយពោលទុកថា ចក្ខុរមែងមិនឃើញរូប ព្រោះចក្ខុមិនមែនចិត្ត ចិត្តក៏ឃើញរូបមិនបានព្រោះចិត្តមិនមានចក្ខុ តែបុគ្គលរមែងឃើញបានដោយចិត្តដែលមានបសាទវត្ថុ ដោយការប៉ះខ្ទប់គ្នានៃទ្វារនិងអារម្មណ៍ កថាបែបនេះ ឈ្មោះថា **សសម្ភារកថា** ដូចក្នុងប្រយោគជាដើមថា គេបាញ់ដោយធ្នូ ដូច្នេះ ព្រោះហេតុនោះ ក្នុងអធិការនេះទើបមានពាក្យអធិប្បាយថា ឃើញរូបដោយចក្ខុវិញ្ញាណ ដូច្នេះ ។

បទថា **និមិត្តគ្គាហី** បានដល់ រមែងកាន់យកនិមិត្តថាជាស្រី ជាប្រុស ឬនិមិត្តដែលជាទីតាំងនៃកិលេស មានសុភនិមិត្តជាដើម ដោយអំណាចឆន្ទរាគៈមិនតាំងនៅក្នុងរូប ត្រឹមតែការឃើញប៉ុណ្ណោះ ។

បទថា **អនុព្យញ្ជនគ្គាហី** បានដល់ កាន់យកកិរិយាអាការៈ មានដៃ

ដើង ការញញឹម ការសើច ការនិយាយ ការសម្លឹងមើល ការក្រឡេកឆ្វេងស្តាំ ជាដើម ដែលបានពោលហាវថា **អនុព្យញ្ជនៈ** ព្រោះជាគ្រឿងប្រាកដរបស់កិលេសទាំងឡាយ គឺព្រោះធ្វើកិលេសឲ្យប្រាកដ ។

បទថា **យត្វាធិករណមេនំ** ជាដើម សេចក្តីថា ធម៌ទាំងឡាយ មានអភិជ្ឈាជាដើមទាំងនេះ គប្បីគ្របសង្កត់ គឺគប្បីជាប់តាម គប្បីគ្របសង្កត់បុគ្គលនេះ អ្នកមានចក្ខុន្ទ្រិយមិនសង្រួមហើយ ដោយសន្ទះទ្វារគឺសតិ គឺជាអ្នកមានចក្ខុទ្វារ មិនបិទហើយនេះ ព្រោះហេតុណា គឺព្រោះហេតុដែលមិនសង្រួមចក្ខុន្ទ្រិយណា ។

បទថា **តស្ស សំវរាយ ន បដិបជ្ជតិ** សេចក្តីថា រមែងមិនបដិបត្តិដើម្បីប្រយោជន៍ដល់ការបិទចក្ខុន្ទ្រិយ ដោយទ្វារគឺសតិ ។ បុគ្គលបែបនេះឯង ទ្រង់ត្រាស់ហៅថា មិនរក្សានូវចក្ខុន្ទ្រិយ មិនដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា មិនដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយនោះដូចតទៅនេះថា សំវរៈក្តី អសំវរៈក្តី រមែងមិនមានក្នុងចក្ខុន្ទ្រិយដោយពិត ព្រោះថា សតិ ឬសេចក្តីវង្វេងភ្លេចសតិ រមែងកើតឡើង ព្រោះអាស្រ័យចក្ខុបសាទក៏ទេ ។ តែក្នុងកាលណា រូបារម្មណ៍មកដល់គន្លងចក្ខុ ក្នុងកាលនោះ កាលភវង្គចិត្តកើតរលត់ ២ វារៈហើយ កិរិយាមនោធាតុក៏ញុំាងអាវជ្ជនកិច្ចឲ្យសម្រេចកើតរលត់ ក្នុងលំដាប់នោះ ចក្ខុវិញ្ញាណក៏ញុំាងទស្សនកិច្ចឲ្យសម្រេចកើតរលត់ បន្ទាប់ពីនោះ វិបាកមនោធាតុក៏ញុំាងសម្បដិច្ឆន្នកិច្ចឲ្យ

សម្រេចកើតរលត់ បន្ទាប់អំពីនោះ អហេតុកមនោវិញ្ញាណធាតុដែលជាវិបាក ក៏ញុំាងសន្តីរណកិច្ចឲ្យសម្រេចកើតរលត់ បន្ទាប់អំពីនោះ មនោវិញ្ញាណធាតុដែលជាអហេតុកិរិយា ក៏ញុំាងវោដ្ឋវនកិច្ចឲ្យសម្រេចកើតរលត់ ក្នុងលំដាប់នោះ ជវនចិត្តរមែងស្ទុះទៅ សំវរៈក្តី អសំវរៈក្តីនឹងមានក្នុងសម័យនៃភវង្គ-ចិត្តនោះក៏ទេ ឬនឹងមានក្នុងសម័យនៃអាវជ្ជនចិត្តជាដើម សម័យណាមួយក៏ទេ តែក្នុងខណៈនៃជវនចិត្ត ភាពជាអ្នកទ្រុស្តសីលខ្វះ ភាពជាអ្នកមិនមានសតិខ្វះ ការមិនដឹងខ្វះ សេចក្តីមិនអត់ធន់ខ្វះ ការខ្ជិលច្រអូសខ្វះ រមែងកើតឡើង អសំវរៈរមែងមាន ។ ក៏អសំវរៈនោះជាយ៉ាងនេះ ហៅថា អសំវរៈក្នុងចក្ខុន្ទ្រិយ ។ ព្រោះហេតុអ្វី ព្រោះកាលអសំវរៈនោះមាន សូម្បីទ្វារ សូម្បីភវង្គ សូម្បីវិថីចិត្ត មានអាវជ្ជនចិត្តជាដើម រមែងជាការមិនបានគ្រប់គ្រងដែរ ។ ដូចអ្វី ដូចទ្វារទាំង ៤ ក្នុងនគរគេមិនបានបិទទុក ទោះបីក្នុងខាងក្នុងផ្ទះ ខ្លោងទ្វារ និងបន្ទប់ជាដើមនឹងបិទដោយល្អក៏ពិត តែក៏ឈ្មោះថាទ្រព្យទាំងអស់ក្នុងខាងក្នុងព្រះនគរមិនបានរក្សា មិនបានគ្រប់គ្រង ព្រោះពួកចោរចូលទៅតាមទ្វារនគរ គប្បីធ្វើតាមប្រាថ្នាបានយ៉ាងណា កាលភាពជាអ្នកទ្រុស្តសីលជាដើមកើតឡើងហើយក្នុងជវនចិត្ត កាលអសំវរៈនោះមាន សូម្បីទ្វារ សូម្បីភវង្គ សូម្បីវិថីចិត្តទាំងឡាយ មានអាវជ្ជនៈជាដើម ក៏ឈ្មោះថាមិនបានរក្សាយ៉ាងនោះដូចគ្នា ។ សូម្បីពាក្យថា **សោតេន សទ្ទំ សុត្វា** ជាដើមក៏មានន័យនេះឯង ។

បទថា **យា ឥមេសំ** សេចក្តីថា ការមិនគ្រប់គ្រង កិរិយាមិនគ្រប់គ្រង

ការមិនរក្សា ការមិនសង្រួមឥន្ទ្រិយទាំង ៦ នេះ របស់បុគ្គល ដែលមិនសម្រេចការសង្រួមនោះឯណា អធិប្បាយថា ការមិនរាំង ការមិនបិទឥន្ទ្រិយទាំង ៦ នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **ភោជនេ អមត្តញ្ញុតា** ដូចតទៅនេះថា

បទថា **ឥធេកច្ចោ** បានដល់ បុគ្គលខ្លះក្នុងសត្វលោកនេះ ។ បទថា **អប្បដិសង្ខា** បានដល់ មិនដឹង គឺមិនពិចារណាដោយបញ្ញាជាគ្រឿងពិចារ-ណា ។ បទថា **អយោនិសោ** បានដល់ មិនមែនឧបាយ ( នៃប្រាជ្ញា ) ។ បទថា **អាហារំ** បានដល់ វត្ថុដែលគប្បីលេបចូល មានរបស់ស៊ី របស់ផឹកជាដើម ។ បទថា **អាហារេតិ** បានដល់ រមែងបរិភោគ គឺរមែងលេបចូល ។ បទថា **ទវាយ** ជាដើមនេះ ត្រាស់ទុកដើម្បីសម្តែងដល់វត្ថុ ដែលមិនមែនឧបាយ ។ មែនពិត បុគ្គលកាលបរិភោគអាហារ មិនពិចារណាដោយឧបាយនៃប្រាជ្ញា រមែងបរិភោគដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង មិនបរិភោគអាស្រ័យអាហារដែលជាប្រយោជន៍នេះ ។

បទថា **យា តត្ថ អសន្តុដ្ឋិតា** បានដល់ កិរិយាដែលមិនពេញចិត្ត គឺភាពដែលមិនពេញចិត្តក្នុងការបរិភោគអាហារ ដោយមិនមែនឧបាយនោះ ឯណា ។ បទថា **អមត្តញ្ញុតា** បានដល់ ភាវៈនៃខ្លួនជាអ្នកមិនស្គាល់ប្រមាណ គឺការមិនស្គាល់ប្រមាណ ពោលគឺការវែ្កតល្មម ។

បទថា **អយំ វុច្ចតិ** សេចក្តីថា ការប្រព្រឹត្តទៅ ដោយអំណាចការមិនពិចារណាហើយបរិភោគ នេះឈ្មោះថា **ភោជនេ អមត្តញ្ញុតា** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃឥន្ទ្រិយគុត្តទ្វារតា ដូចតទៅនេះថា

បទថា **ចក្ខុនា** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយនុ៎ះឯង ។ បទថា **ន និមិត្តគ្គាហី ហោតិ** បានដល់ រមែងមិនកាន់យកនិមិត្ត មានប្រការតាមដែលពោលហើយ ដោយអំណាចឆន្ទរាគៈ ។ ដោយអាការយ៉ាងនេះ បទដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពាក្យដែលពោលហើយនោះ ។ ពាក្យដែលខ្ញុំធ្លាប់ពោលទុកហើយថា កាលភាពជាអ្នកទ្រុស្តសីលជាដើម កើតឡើងហើយក្នុងជវនចិត្ត កាលអសំវរៈនោះមាន សូម្បីទ្វារ សូម្បីភវង្គចិត្ត សូម្បីវិថិចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម ក៏ជាការដែលមិនបានគ្រប់គ្រងយ៉ាងណា ក្នុងអធិការនេះក៏យ៉ាងនោះ កាលសីលជាដើម កើតឡើងក្នុងជវនចិត្តនោះសូម្បីទ្វារ សូម្បីភវង្គចិត្ត សូម្បីវិថិចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើម ក៏ជាការគ្រប់គ្រងហើយ ។ ដូចអ្វី ដូចទ្វារព្រះនគរដែលបិទល្អហើយ ខាងក្នុងស្រុកជាដើមទោះបីមិនបានបិទក៏ពិត តែទ្រព្យទាំងអស់ខាងក្នុងព្រះនគរឈ្មោះថា រក្សាល្អហើយ គ្រប់គ្រងល្អហើយដូចគ្នា ។ ព្រោះថា កាលទ្វារនគរបិទហើយ ចោរក៏ចូលទៅមិនបាន យ៉ាងណា កាលសីលជាដើម កើតក្នុងជវនចិត្តហើយ សូម្បីទ្វារ សូម្បីភវង្គចិត្ត សូម្បីវិថីចិត្តទាំងឡាយ មានអាវជ្ជនៈជាដើម ក៏ឈ្មោះថាគ្រប់គ្រងហើយ យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ សំវរៈសូម្បីកើតនៅក្នុងខណៈនៃជវនចិត្ត ព្រះមានព្រះភាគក៏ត្រាស់ថា សំវរៈក្នុងចក្ខុន្ទ្រិយ ។ សូម្បីក្នុងបទជាដើមថា **សោតេន សទ្ទំ សុត្វា** ក៏ន័យនេះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេស **ភោជនេ មត្តញ្ញុតា** ដូចតទៅនេះថា

បទថា **បដិសង្ខា យោនិសោ អាហារំ អាហារេតិ** បានដល់ ដឹង ដោយបញ្ញា ជាគ្រឿងពិចារណា ហើយបរិភោគអាហារ ដោយឧបាយ ។ ឥឡូវនេះ ដើម្បីទ្រង់សម្តែងឧបាយ ទើបត្រាស់ពាក្យជាដើមថា **នេវ ទវាយ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **នេវ ទវាយ** បានដល់ មិនបរិភោគដើម្បីលេង ។ ក្នុងព្រះបាលីនោះ អ្នករាំរែកនិងអ្នកលោតដាំដូងជាដើម ឈ្មោះថា បរិភោគដើម្បីលេង ។ ព្រោះកាលគេបរិភោគភោជនណាហើយ ការលេងពោលគឺការរាំរែក ច្រៀង កាព្យឃ្លោង និងការលេងពាក្យស្លោក រមែងជាក់ច្បាស់ក្រៃលែង ជនទាំងនោះ ស្វែងរកភោជននោះដោយធម៌មិនស្មើ ហើយរមែងបរិភោគ តែភិក្ខុនេះមិនបរិភោគយ៉ាងនោះ ។

បទថា **ន មទាយ** បានដល់ រមែងមិនបរិភោគ ដើម្បីការកពូនសេចក្តីស្រវឹងដោយមានះ និងស្រវឹងដោយសម្គាល់ថាជាបុរស ។ ក្នុងសេចក្តីនោះ ព្រះរាជានិងមហាមាត្យរបស់ព្រះរាជា ឈ្មោះថា រមែងបរិភោគដើម្បីស្រវឹង ព្រោះជនទាំងនោះ រមែងបរិភោគភោជន មានរសឆ្ងាញ់ និងប្រណីត ដើម្បីចម្រើនការស្រវឹងដោយមានះ និងស្រវឹងដោយភាពជាបុរសរបស់ខ្លួន ។ តែភិក្ខុនេះ រមែងមិនបរិភោគយ៉ាងនេះ ។

បទថា **ន មណ្ឌនាយ** សេចក្តីថា មិនបរិភោគដើម្បីតាក់តែងសរីរៈ ។ ក្នុងបទនោះ ស្រីដែលអាស្រ័យរូបចិញ្ចឹមជីវិត ស្រីអ្នកស្រុក ស្រីស្នំជាដើម រមែងផឹកទឹកដោះថ្លានិងទឹកអំពៅ រមែងបរិភោគអាហារដែលល្អិត ទន់និងតិច

ដោយគិតថា ការបរិភោគយ៉ាងនេះ សន្ធាក់នៃអវយវៈរបស់ពួកយើងនឹងតាំងនៅដោយល្អ ឆវីវណ្ណក្នុងសរីរៈនឹងផូរផង់ តែភិក្ខុនេះ រមែងមិនបរិភោគយ៉ាងនោះ ។

បទថា **ន វិភូសនាយ** បានដល់ មិនបរិភោគ ដើម្បីប្រាថ្នាស្អិតស្អាងដោយសាច់ក្នុងសរីរៈ ក្នុងបទនោះ អ្នកចំបាប់និងអ្នកប្រដាល់ជាដើម រមែងញុំាងសរីរៈឲ្យមាំមួន ដោយភោជនាហារ មានត្រីនិងសាច់ជាដើមដែលសមគួរ ដោយគិតថា ដោយការបរិភោគយ៉ាងនេះ សាច់របស់ពួកយើងនឹងរឹងមាំ ដើម្បីប្រយោជន៍ដល់ការធន់ចំពោះការវាយតប់ តែភិក្ខុនេះ រមែងមិនបរិភោគ ដើម្បីធ្វើសាច់ឲ្យមាំមួនក្នុងសរីរៈយ៉ាងនោះ ។

បទថា **យាវទេវ** នេះ ជាពាក្យសម្តែងការកំណត់ប្រយោជន៍ ក្នុងការបរិភោគអាហារ ។ បទថា **ឥមស្ស កាយស្ស ឋិតិយា** បានដល់ រមែងបរិភោគ ដើម្បីឲ្យករជកាយដែលប្រកបដោយមហាភូតរូបទាំង ៤ នេះតាំងនៅ សេចក្តីនេះ ជាប្រយោជន៍ក្នុងការបរិភោគអាហាររបស់ភិក្ខុនេះ ។ បទថា **យាបនាយ** បានដល់ រមែងបរិភោគ ដើម្បីប្រយោជន៍ដល់ការឲ្យជីវិ-តិន្ទ្រិយ ប្រព្រឹត្តទៅ ។ បទថា **វិហឹសូបរតិយា** បានដល់ សេចក្តីស្រេកឃ្លានកើតឡើងព្រោះការមិនបានបរិភោគជាបច្ច័យ ឈ្មោះថា **វិហឹសា** រមែងបរិភោគ ដើម្បីកម្ចាត់បង់វិហឹសានោះ គឺដើម្បីឲ្យវិហឹសានោះស្ងប់រម្ងាប់ ។ បទថា **ព្រហ្មចរិយានុគ្គហាយ** សេចក្តីថា ត្រៃសិក្ខា គឺសាសនាទាំងមូលឈ្មោះថា ព្រហ្មចរិយៈ រមែងបរិភោគដើម្បីអនុគ្រោះព្រហ្មចរិយៈនោះ ។

បទថា **ឥតិ** នេះ ជាបទសម្តែងដល់ឧបាយ អធិប្បាយថា ដោយឧបាយនេះ ។ បទថា **បុរាណញ្ច វេទនំ បដិហង្ខាមិ** សេចក្តីថា វេទនាដែលកើតឡើងព្រោះការមិនបានបរិភោគអាហារជាបច្ច័យ ឈ្មោះថា វេទនាចាស់ ភិក្ខុរមែងបរិភោគអាហារ ដោយគិតថា អញនឹងកម្ចាត់បង់នូវវេទនាចាស់នោះ ។

បទថា **នវញ្ច វេទនំ ន ឧប្បាទេស្សាមិ** សេចក្តីថា វេទនាដែលកើតឡើង ព្រោះការបរិភោគច្រើនពេកជាបច្ច័យ ឈ្មោះថា វេទនាថ្មី ភិក្ខុរមែងបរិភោគដោយគិតថា អញនឹងមិនឲ្យវេទនាថ្មីនោះកើតឡើង ។ មួយវិញទៀត វេទនាដែលកើតឡើងព្រោះការបរិភោគហើយជាបច្ច័យ ឈ្មោះថា វេទនាថ្មី ភិក្ខុរមែងបរិភោគដើម្បីមិនឲ្យកើតវេទនានោះដែលមិនទាន់កើតឡើងនុ៎ះឯង ។ បទថា **យាត្រា ច មេ ភវិស្សតិ** បានដល់ ការញុំាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅនឹងមានដល់អញផង ។ បទថា **អនវជ្ជតា ច** នេះបានដល់ ក្នុងការបរិភោគនេះ វត្ថុដែលមានទោសក៏មាន វត្ថុដែលមិនមានទោសក៏មាន ។ ក្នុងពីរយ៉ាងនោះ ការស្វែងរកដោយមិនត្រូវតាមធម៌ ការទទួលយកដោយមិនត្រូវតាមធម៌ ការបរិភោគដោយមិនត្រូវតាមធម៌ នេះឈ្មោះថា **សាវជ្ជ** ( មានទោស ) ។ ការស្វែងរកដោយធម៌ ការទទួលយកដោយធម៌ ពិចារណាហើយបរិភោគ នេះឈ្មោះថា **អនវជ្ជ** ( មិនមានទោស ) ។

បុគ្គលខ្លះ រមែងធ្វើអាហារដែលមិនមានទោសនុ៎ះឯង ឲ្យមានទោស គឺធ្វើទុកក្នុងចិត្តថា អញបានអាហារបរិភោគលើសប្រមាណ លោករមែងមិន

អាចដើម្បីឲ្យអាហារនោះ ៗ រលួយ រមែងលំបាកដោយការក្អួត និងបញ្ចុះលាមកជាដើម ពួកភិក្ខុមួយវត្ត ត្រូវនាំគ្នាជួយខ្វល់ខ្វាយក្នុងការបដិបត្តិរាងកាយ និងស្វែងរកថ្នាំជាដើមឲ្យភិក្ខុនោះ កាលត្រូវសួរថា មានរឿងអ្វី ពួកភិក្ខុនឹងនិយាយថា ភិក្ខុរបងណោះហើមពោះ ដូច្នេះជាដើម ភិក្ខុទាំងឡាយក៏នឹងនាំគ្នានិន្ទាតិះដៀលថា លោកអង្គនេះ មានប្រក្រតីយ៉ាងនេះជានិច្ចកាលយ៉ាងហ្នឹងឯង រមែងមិនស្គាល់ប្រមាណផ្ទៃរបស់ខ្លួន ដូច្នេះ ភិក្ខុនេះឈ្មោះថារមែងធ្វើអាហារដែលមិនមានទោស ឲ្យមានទោសយ៉ាងនេះ ។ ភិក្ខុមិនធ្វើយ៉ាងនោះ រមែងឆាន់អាហារដោយមនសិការថា ការមិនមានទោសនឹងមានដូច្នេះ ។

សូម្បីក្នុងបទថា **ផាសុវិហារោ ច** សេចក្តីថា ការនៅដោយផាសុកក៏មាន ការនៅដោយមិនផាសុកក៏មាន ។

ក្នុងការបរិភោគនោះ ការបរិភោគរបស់ព្រាហ្មណ៍ទាំង ៥ នាក់នេះ គឺព្រាហ្មណ៍ឈ្មោះ អាហរហត្ថកៈ ១ ព្រាហ្មណ៍ឈ្មោះ អលំសាដកៈ ១ ព្រាហ្មណ៍ឈ្មោះ តត្ថវដ្ដកៈ ១ ព្រាហ្មណ៍ឈ្មោះ កាកមាសកៈ ១ ព្រាហ្មណ៍ឈ្មោះ ភុត្តវមិតកៈ ១ ឈ្មោះថា ការនៅមិនជាផាសុក ។

ពិតណាស់ បណ្តាព្រាហ្មណ៍ទាំងនោះ ព្រាហ្មណ៍ឈ្មោះ អាហរហត្ថកៈ បរិភោគច្រើន មិនអាចក្រោកឡើងបានតាមធម្មតារបស់ខ្លួន ទើបនិយាយថា ជួយទាញដៃយើង ដូច្នេះ ។ ព្រាហ្មណ៍ឈ្មោះអលំសាដកៈ បរិភោគអាហារច្រើន សូម្បីក្រោកឡើងបាន តែមិនអាចស្លៀកសំពត់បាន ព្រោះមានក្បាល

ពោះធំពេក ។ ព្រាហ្មណ៍ឈ្មោះ តត្ថវដ្ដកៈ បរិភោគច្រើន មិនអាចក្រោកឡើងបាន រមែងបម្រះនទៀលទៅក្នុងទីនោះឯង ។ ព្រាហ្មណ៍ឈ្មោះ កាក-មាសកៈ បរិភោគអាហារច្រើន ទាល់តែហៀរដល់មាត់ របូតដល់ពួកក្អែកអាចចឹកស៊ីបាន ។ ព្រាហ្មណ៍ឈ្មោះ ភុត្តវមិតកៈ បរិភោគច្រើន មិនអាចដើម្បីបិទមាត់បាន រមែងក្អួតក្នុងទីនោះឯង ។ ភិក្ខុ រមែងមិនធ្វើយ៉ាងនេះ រមែងឆាន់អាហារ ដោយមនសិការថា ការនៅជាផាសុក នឹងមានដល់អញ ដូច្នេះ ។ ការដែលពោះខ្វះពំនូតបាយ ៤-៥ ម៉ាត់ ឈ្មោះថា ការនៅជាផាសុក ព្រោះកាលភិក្ខុបរិភោគអាហារត្រឹមប៉ុណ្ណោះហើយផឹកទឹក ឥរិយាបថ ៤ រមែងប្រព្រឹត្តទៅដោយស្រួល ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីពោលគាថាទុកយ៉ាងនេះថា

ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត )
ហើយគប្បីផឹកទឹក នេះជាការល្មម ដល់កិរិយានៅជាសុខនៃ
ភិក្ខុអ្នកមានចិត្តស្ងប់ទៅរក ( ព្រះនិព្វាន ) ដូច្នេះ ។

ក្នុងឋានៈនេះ គួរប្រមូលអង្គទាំងឡាយ គឺពាក្យថា មិនមែនដើម្បីលេងជាអង្គ ១ ពាក្យថា មិនមែនដើម្បីស្រវឹង ជាអង្គ ១ ពាក្យថា មិនមែនដើម្បីប្រដាប់ ជាអង្គ ១ ពាក្យថា មិនមែនដើម្បីស្អិតស្អាង ជាអង្គ ១ ពាក្យថា ដើម្បីតាំងនៅនៃកាយនេះ និងដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ជាអង្គ ១ ដើម្បីកម្ចាត់បង់នូវសេចក្ដីលំបាក ដើម្បីអនុគ្រោះនូវព្រហ្មចរិយធម៌ ជាអង្គ ១ ។ ពាក្យថា ដោយឧបាយនេះ អាត្មាអញនឹងកម្ចាត់បង់នូវវេទនា

ចាស់ផង និងមិនឲ្យវេទនាថ្មី កើតឡើងបានផង ជាអង្គ ១ ពាក្យថា ការប្រព្រឹត្តទៅនៃឥរិយាបថក្តីនឹងមានដល់អញ ជាអង្គ ១ ពាក្យថា ការមិនមានទោស និងការនៅជាសុខសប្បាយក្តី ជាអង្គ ១ នេះជាអានិសង្សនៃការបរិភោគ ក្នុងភាពជាអ្នកដឹងប្រមាណក្នុងភោជនីយហារនេះ ។

ចំណែកព្រះមហាសីវត្ថេរ ពោលថា អង្គ ៤ ខាងដើម ឈ្មោះថា ជាបទហាមប្រាម គប្បីប្រមូលអង្គ ៨ ខាងចុងមក ក្នុងអង្គ ៨ ខាងចុងនោះ ពាក្យថា ដើម្បីការតាំងនៅនៃកាយនេះ ចាត់ជាអង្គ ១ ពាក្យថា ការប្រព្រឹត្តទៅនៃឥរិយាបថ ចាត់ជាអង្គ ១ ពាក្យថា ដើម្បីកម្ចាត់បង់នូវសេចក្តីលំបាក ចាត់ជាអង្គ ១ ពាក្យថា ដើម្បីអនុគ្រោះនូវព្រហ្មចរិយធម៌ ចាត់ជាអង្គ ១ ពាក្យថា ដោយឧបាយនេះ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ ចាត់ជាអង្គ ១ ពាក្យថា និងមិនឲ្យវេទនាថ្មីកើតឡើងបាន ចាត់ជាអង្គ ១ ពាក្យថា ការប្រព្រឹត្តទៅនៃឥរិយាបថក្តី នឹងមានដល់អញ ចាត់ជាអង្គ ១ ពាក្យថា ការមិនមានទោស ចាត់ជាអង្គ ១ ការនៅជាសុខសប្បាយ ជាអង្គ ១ នេះជាអានិសង្សនៃការបរិភោគ ។

ភិក្ខុកាលបរិភោគអាហារដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ឈ្មោះថាជាអ្នកស្គាល់ប្រមាណក្នុងការបរិភោគអាហារ ។ បទថា **អយំ វុច្ចតិ** សេចក្តីថា ការបរិភោគបច្ច័យដែលពិចារណាហើយដែលប្រព្រឹត្តទៅដោយអំណាចការស្គាល់ប្រមាណដែលគួរក្នុងការស្វែងរក ក្នុងការទទួល និងក្នុងការបរិភោគនេះ ឈ្មោះថា **ភោជនេ មត្តញ្ញុតា** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមុដ្ឋស្សច្ចៈ ដូចតទៅនេះថា

បទថា **អសតិ** បានដល់ នាមក្ខន្ធ ៤ ដែលវៀរចាកសតិ ។ បទថា **អននុស្សតិ អប្បដិស្សតិ** នេះ ទ្រង់បន្ថែមបទឧបសគ្គ ។ បទថា **អស-រណតា** បានដល់ អាការនៃការរឭកមិនបាន ។ បទថា **អធារណតា** បានដល់ ការមិនអាចដើម្បីនឹងទ្រទ្រង់ចាំ ។ ព្រោះបុគ្គលដែលប្រកបដោយការមិនទ្រទ្រង់ចាំនោះ ទោះបីនឹងតាំងចិត្តថា អញនឹងចាំ ក៏មិនអាចរក្សាទុកបាន ។ ដែលឈ្មោះថា **បិលាបនតា** ព្រោះអត្ថថា រមែងអណ្តែតអណ្តូងក្នុងអារម្មណ៍ ដូចសំបកឃ្លោកអណ្តែតក្នុងទឹក ដូច្នោះ ។ បទថា **សំមុស-នតា** បានដល់ ការមិនមានសតិនិងការភ្លេច ព្រោះបុគ្គលដែលមិនមានសតិឬភ្លេចនោះ រមែងដូចជាក្អែកដែលលាក់ដុំបាយ និងដូចជាចចកដែលលាក់ដុំសាច់ ដូច្នោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសភាវនាពលៈ ដូចតទៅនេះថា

បទថា **កុសលានំ ធម្មានំ** បានដល់ នូវពោធិបក្ខិយធម៌ទាំងឡាយ ។ បទថា **អាសេវនា** បានដល់ ការសេពតាំងអំពីដើម ។ បទថា **ភាវនា** បានដល់ ការចម្រើនឡើង ។ បទថា **ពហុលីកម្មំ** បានដល់ ការធ្វើរឿយៗ ។

គប្បីជ្រាបនិទ្ទេសនៃសីលវិបត្តិ ដោយចំណែកផ្ទុយគ្នានឹងសីលសម្បទានិទ្ទេស ។ម្យ៉ាងទៀត គប្បីជ្រាបទិដ្ឋិវិបត្តិនិទ្ទេសដោយចំណែកផ្ទុយ គ្នានឹងទិដ្ឋិសម្បទានិទ្ទេស គប្បីជ្រាបទិដ្ឋិសម្បទានិទ្ទេសដោយចំណែកផ្ទុយគ្នា នឹងទិដ្ឋុបាទាននិទ្ទេស ។ សីលវិសុទ្ធិនិទ្ទេសដូចគ្នានឹងសីលសម្បទានិទ្ទេស ក៏ពិត

ទោះបីជាយ៉ាងនោះ ក្នុងនិទ្ទេសនៃសីលសម្បទានោះ ព្រះអង្គត្រាស់ បាតិ-មោក្ខសំវរសីលដែលឲ្យដល់វិសុទ្ធិ ក្នុងនិទ្ទេសនៃសីលវិសុទ្ធិនេះត្រាស់សីលដែលដល់វិសុទ្ធិហើយ ។

មួយទៀត ព្រះមានព្រះភាគត្រាស់លោកិយធម៌និងលោកុត្តរធម៌ សូម្បីប្រព្រឹត្តទៅក្នុងភូមិ ៤ ទុកដោយ ៦ ទុកៈនេះ គឺសតិនិងសម្បជញ្ញៈទុកៈ ១ ( ទុកៈទី ៣០ ) បដិសង្ខានពលៈនិងភាវនាពលៈទុកៈ ១ ( ទុកៈទី ៣១ ) សមថៈនិងវិបស្សនាទុកៈ ១ ( ទុកៈទី ៣២ ) សមថនិមិត្តនិងបគ្គាហ-និមិត្តទុកៈ ១ ( ទុកៈទី ៣៣ ) បគ្គាហៈនិងអវិក្ខេបៈទុកៈ ១ ( ទុកៈ ទី ៣៤ ) សីលសម្បទាទិដ្ឋិសម្បទាទុកៈ ១ ( ទុកៈទី ៣៦ ) ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទិដ្ឋិវិសុទ្ធិនិទ្ទេស ដូចតទៅនេះថា

បទថា **កម្មស្សកតញ្ញាណំ** បានដល់ បញ្ញាជាគ្រឿងដឹងថា កម្មនេះជារបស់ខ្លួន កម្មនេះមិនមែនរបស់ខ្លួន បណ្ដាកម្មទាំង ២ នោះ កម្មដែលខ្លួនធ្វើហើយឬអ្នកដទៃធ្វើហើយ អកុសលកម្មទាំងអស់មិនមែនរបស់ខ្លួន ព្រោះហេតុអ្វី ព្រោះទម្លាយប្រយោជន៍ និងព្រោះញុំាងវត្ថុដែលមិនជាប្រយោជន៍ឲ្យកើត ។ ចំណែកកុសលកម្ម ឈ្មោះថាជារបស់ខ្លួន ព្រោះទម្លាយវត្ថុមិនជាប្រយោជន៍ និងព្រោះញុំាងប្រយោជន៍ឲ្យកើត ។ ក្នុងសេចក្ដីនោះ ដូចបុរសមានទ្រព្យ មានភោគៈដើរផ្លូវឆ្ងាយ ក្នុងចន្លោះផ្លូវ កាលគេប្រកាសការលេងនក្ខត្តឫក្សក្នុងស្រុក និងនិគមជាដើម ក៏មិនបានគិតថា អញជាអាគន្តុកៈគប្បីអាស្រ័យអ្វីហ្ន៎លេងនក្ខត្តឫក្ស កាលលេងនក្ខត្តឫក្ស តាមទំនងដែលខ្លួនត្រូវ

ការ រមែងចូលផ្លូវកន្តារដោយសប្បាយយ៉ាងណា សត្វទាំងនេះ តាំងនៅក្នុងកម្មស្សកតញ្ញាណនេះក៏យ៉ាងនោះដូចគ្នា ធ្វើកម្មដែលជាវដ្តគាមីច្រើន សោយសេចក្តីសុខ សម្រេចអរហត្តហើយ ហួសនឹងរាប់បាន ។

បទថា **សច្ចានុលោមិកញាណំ** បានដល់ វិបស្សនាញាណដែលអនុលោមតាមសច្ចៈ ៤ ។ បទថា **មគ្គសមង្គិស្ស ញាណំ ផលសមង្គិស្ស ញាណំ** បានដល់ មគ្គញ្ញាណនិងផលញ្ញាណនុ៎ះឯង ។

ក្នុងនិទ្ទេសនៃបទថា **ទិដ្ឋិវិសុទ្ធិ ខោ បន** ព្រះមានព្រះភាគទ្រង់ចែកញាណ ៤ មាន កម្មស្សកតញ្ញាណជាដើម ដែលធ្លាប់ត្រាស់មកហើយនុ៎ះឯង ដោយបទជាដើមថា **យា បញ្ញា បជានទា** ។

ក្នុងនិទ្ទេសនៃបទថា **យថា ទិដ្ឋិស្ស ច បធានំ** សេចក្តីព្យាយាមដែលទ្រង់សម្តែង ដោយបទជាដើមថា **យោ ចេតសិកោ វីរិយារម្ភោ** ប្រព្រឹត្តទៅ ដូចបញ្ញានុ៎ះឯង ។ ក្នុងឋានៈនៃបញ្ញា ដែលជាលោកិយ គប្បីជ្រាបថា វីរិយៈនោះជាលោកិយ ក្នុងឋានៈនៃលោកុត្តរបញ្ញាក៏គប្បីជ្រាបថា វីរិយៈនោះជាលោកុត្តរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃសំវេគទុកៈ ដូចតទៅនេះថា

បទថា **ជាតិភយំ** បានដល់ ញាណដែលឃើញជាតិ ( ការកើត ) ដោយភាពជាភ័យតាំងនៅ ។ ក្នុងពាក្យថា ញាណដែលឃើញជរាភ័យ និងឃើញមរណៈភ័យជាដើម ក៏ន័យនេះឯង ។

ដោយបទថា **អនុប្បន្នានំ ទាបកានំ** ជាដើម ព្រះមានព្រះភាគត្រាស់

សេចក្តីព្យាយាម ដែលជាឧបាយនៃភិក្ខុដែលឃើញជាតិជាដើម ដោយភាពជាភ័យហើយប្រាថ្នាដើម្បីផុតទៅចាកជាតិ ជរា ព្យាធិនិងមរណៈ ។ ចំណែកសេចក្តីនៃបទភាជនីយនឹងមានជាក់ច្បាស់ក្នុងអដ្ឋកថាវិភង្គ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃបទថា **អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ** ដូចតទៅនេះថា

បទថា **ភិយ្យោកម្យតា** បានដល់ សេចក្តីពេញចិត្តដែលច្រើនជាងមុន ។ មែនពិត បុគ្គលខ្លះក្នុងលោកនេះ រមែងប្រគេនបក្ខិកភត្ត ( ភត្តដែលប្រគេនប្រចាំបក្ខ ) ខ្លះ សលាកភត្ត ( ភត្តដែលប្រគេនដោយវិធីចាប់ស្លាក ) ខ្លះ ឧបោសថិកភត្ត ( ភត្តដែលប្រគេនក្នុងថ្ងៃឧបោសថ ) ខ្លះ បាដិបទិកភត្ត ( ភត្តដែលប្រគេនក្នុងថ្ងៃបាដិបទ ) ខ្លះ តាំងពីដើមទុំឯង បុគ្គលនោះជាអ្នកមិនឆ្អែតដោយការឲ្យទាននោះៗ ទើបប្រគេនធុវភត្ត ( ភត្តប្រគេនជាប្រចាំ ) សង្ឃភត្ត ( ភត្តប្រគេនដល់សង្ឃ ) វស្សាវាសិកភត្ត ( ភត្តប្រគេនដល់ភិក្ខុអ្នកនៅចាំវស្សា ) ទៀត រមែងកសាងអាវាស រមែងប្រគេនបច្ច័យសូម្បីទាំង ៤ ។ គេក៏នៅជាអ្នកមិនឆ្អែតសូម្បីក្នុងការឲ្យនោះៗទើបទទួលសរណៈទាំងឡាយ សមាទានបញ្ចសីល គេក៏នៅជាអ្នកមិនឆ្អែត សូម្បីក្នុងការធ្វើកុសលនោះៗទើបបួស កាលបួសហើយក៏រៀនព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក គឺនិកាយមួយ និកាយពីរ រមែងញ៉ាំងសមាបត្តិ ៨ ឲ្យកើត ចម្រើនវិបស្សនាកាន់យកព្រះអរហត្ត ចាប់ផ្តើមអំពីការសម្រេចព្រះអរហត្តហើយ រមែងជាអ្នកឈ្មោះថា **មហាសន្តុដ្ឋ** ( ឆ្អែតយ៉ាងធំ ) សេចក្តីពេញចិត្តដែលច្រើន

ជាងមុន រហូតដល់អរហត្តយ៉ាងនេះ ឈ្មោះថា **ភិយ្យោកម្យតា** ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងនិទ្ទេសនៃបទថា **អប្បដិវានិតា ច បធានស្មឹ** ដូចតទៅនេះថា ព្រោះកិច្ចជិនណាយក្នុងការចម្រើនកុសលធម៌ដ៏ក្រៃលែងទាំងឡាយ ក្នុងសេនាសនៈដ៏ស្ងាត់ទាំងឡាយ ឈ្មោះថា ធ្វើសេចក្តីព្យាយាមឲ្យធូរថយ ។ កិច្ចកាលមិនទៀយណាយ ឈ្មោះថា មិនធ្វើសេចក្តីព្យាយាមឲ្យធូរថយ ព្រោះហេតុនោះ ដើម្បីសម្តែងន័យនោះ ទើបត្រាស់ពាក្យជាដើមថា **យា កុសលានំ ធម្មានំ** ដូច្នេះ ។

ក្នុងព្រះបាលីទាំងនោះ បទថា **សក្កច្ចកិរិយតា** បានដល់ ភាពជាអ្នកធ្វើដោយគោរព ក្នុងការធ្វើកុសលទាំងឡាយ ។ បទថា **សាតច្ចកិរិយតា** គឺធ្វើជាប់តគ្នាទុំះឯង ។ បទថា **អដ្ឋិតកិរិយតា** គឺធ្វើមិនឲ្យដាច់ ធ្វើមិនឈប់ឈរ ។ បទថា **អនោលីនវុត្តិតា** គឺការចិញ្ចឹមជីវិតមិនធូរថយ ឬការប្រព្រឹត្តមិនធូរថយ ។ បទថា **អនិក្ខិត្តឆន្ទតា** គឺមិនបោះបង់កុសលឆន្ទៈ ។ បទថា **អនិក្ខិត្តធុរតា** បានដល់ មិនបោះបង់ធុរៈ គឺសេចក្តីព្យាយាមក្នុងការបំពេញកុសល ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **បុព្វេនិវាសានុស្សតិញ្ញាណំ វិជ្ជា** នេះ ដូចតទៅនេះថា

បទថា **បុព្វេនិវាសោ** បានដល់ ខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន និងវត្ថុដែលទាក់ទងដោយខន្ធ ។ ការតាមរឭកដល់បុព្វេនិវាសបានឈ្មោះថា **បុព្វេនិវាសានុស្សតិ** ។ ញាណដែលសម្បយុត្តដោយបុព្វេនិវាសានុស្សតិ

នោះ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ ។ បុព្វេនិវាសានុស្សតិញ្ញាណ នោះ ឈ្មោះថា វិជ្ជា ព្រោះអត្ថថា កម្ចាត់ងងឹតដែលបិទបាំងខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ។ ញាណនោះកម្ចាត់ងងឹតហើយ ធ្វើខន្ធទាំងនោះឲ្យជាក់ច្បាស់ គឺឲ្យប្រាកដ ព្រោះហេតុនោះ ទើបញាណនោះ ឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើខន្ធឲ្យជាក់ច្បាស់ ។

បទថា **ចុតូបបាតេ ញាណំ** បានដល់ ញាណក្នុងចុតិនិងឧបបត្តិ ។ ញាណនេះ ក៏ឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា កម្ចាត់ងងឹតដែលបិទបាំងចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ។ ញាណនោះ កម្ចាត់ងងឹតហើយធ្វើចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយឲ្យជាក់ច្បាស់គឺឲ្យប្រាកដ ព្រោះហេតុនោះទើបញាណនោះ ឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើចុតិនិងបដិសន្ធិឲ្យជាក់ច្បាស់ ។

បទថា **អាសវានំ ខយេ ញាណំ** បានដល់ ញាណក្នុងសម័យអស់ទៅនៃកិលេសទាំងឡាយទាំងពួង ញាណនេះ ឈ្មោះថា **វិជ្ជា** ព្រោះអត្ថថា កម្ចាត់ងងឹតដែលបិទបាំងសច្ចៈទាំង ៤ ។ ញាណនោះ កម្ចាត់ងងឹតហើយធ្វើសច្ចៈទាំង ៤ ឲ្យជាក់ច្បាស់ គឺឲ្យប្រាកដ ព្រោះហេតុនោះ ទើបឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើសច្ចៈ ៤ ឲ្យជាក់ច្បាស់ ។

ក្នុងបទថា **ចិត្តស្ស ច អធិមុត្តិ និព្វានញ្ច** នេះ សមាបត្តិ ៨ ឈ្មោះថា ការរួចស្រឡះនៃចិត្ត ដោយអត្ថថា បង្អោនទៅក្នុងអារម្មណ៍ និងដោយអត្ថថារួចផុតដោយល្អចាកធម៌ដែលជាសត្រូវទាំងឡាយ ។ ចំណែកញាណក្រៅអំពីនេះ ឈ្មោះថា **និព្វាន** ព្រោះអត្ថថា **វាន** ពោលគឺ តណ្ហាមិនមានក្នុងនិព្វាន

នេះ ឬនិព្វាននេះចេញទៅអំពី **វាន** នោះ ។ បណ្ដាធម៌ទាំង ២ ( គឺការរួចស្រឡះនៃចិត្តនិងព្រះនិព្វាន ) នោះ សមាបត្តិ ៨ ត្រាស់ថា **វិមុត្តិ** ព្រោះរួចផុតហើយចាកកិលេស ដែលគ្របសង្កត់បានឯង ។ តែនិព្វាន ទ្រង់ត្រាស់ថា **វិមុត្តិ** ព្រោះរួចផុតដោយចំណែកមួយចាកកិលេសទាំងឡាយទាំងពួង ។

បទថា **មគ្គសមង្គិស្ស ញាណំ** បានដល់ មគ្គញាណទាំង ៤ ។ បទថា **ផលសមង្គិស្ស ញាណំ** បានដល់ ផលញាណទាំង ៤ ។

បណ្ដាញាណទាំងនោះ មគ្គញាណទី ១ ឈ្មោះថា **ខយេ ញាណំ** ព្រោះអត្ថថា កើតឡើងញ៉ាំងកិលេស ៥ យ៉ាងឲ្យអស់ទៅ ឲ្យរលត់ទៅ ឲ្យស្ងប់ ឲ្យរម្ងាប់ ។ មគ្គញាណទី ២ ញ៉ាំងកិលេស ៤ យ៉ាងឲ្យអស់ទៅ ។ មគ្គញាណទី ៣ ក៏ញ៉ាំងកិលេស ៤ យ៉ាងឲ្យអស់ទៅដូចគ្នា តែមគ្គញាណទី ៤ ឈ្មោះថា **ខយេ ញាណំ** ព្រោះអត្ថថា កើតឡើង ធ្វើកិលេស ៨ យ៉ាងឲ្យអស់ទៅ ឲ្យរលត់ទៅ ឲ្យស្ងប់ ឲ្យរម្ងាប់ ។

តែផលញាណរបស់មគ្គនោះៗ ឈ្មោះថា **អនុប្បាទេ ញាណំ** ព្រោះអត្ថថា កើតឡើងក្នុងទីបំផុតនៃការអស់ទៅ ក្នុងទីបំផុតនៃការរលត់ទៅ ក្នុងទីបំផុតនៃការស្ងប់ទៅ ក្នុងទីបំផុតនៃការរម្ងាប់ទៅ ក្នុងទីបំផុតនៃការមិនកើតឡើង ក្នុងទីបំផុតនៃការមិនប្រព្រឹត្តទៅនៃកិលេសទាំងនោះដូច្នេះឯង ។

## អដ្ឋកថានិក្ខេបកណ្ឌ ចប់

# អភិធម្មបិដក

## អដ្ឋទ្វារកណ្ឌ

[ ៣៧៨ ] ពួកធម៌ជាកុសស តើដូចម្ដេច ។ កុសលក្នុងភូមិ ៤ នេះពួកធម៌ជាកុសល ។ ពួកធម៌ជាអកុសល តើដូចម្ដេច ។ អកុសលចិត្តុប្បាទ ( ការកើតនៃចិត្តជាអកុសល ) ១២ នេះពួកធម៌ជាអកុសល ។ ពួកធម៌ជាអព្យាក្រឹត តើដូចម្ដេច ។ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ជាអព្យាក្រឹត ។

[ ៣៧៩ ] ពួកធម៌ដែលប្រកបដោយសុខវេទនា តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយសោមនស្ស ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៥ ខាងវិបាកផង ខាងកិរិយាផងនៃកាមាវចរកុសល រូបាវចរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង វៀរតែសុខវេទនា ដែលកើតឡើងក្នុងទីនោះចេញ នេះពួកធម៌ដែលប្រកបដោយសុខវេទនា ។ ពួកធម៌ដែលប្រកបដោយទុក្ខវេទនា តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយទោមនស្ស ២ និងកាយវិញ្ញាណប្រកបដោយទុក្ខ វៀរតែទុក្ខវេទនា ដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ដែលប្រកបដោយទុក្ខវេទនា ។ ពួកធម៌ប្រកបដោយវេទនា មិនជាទុក្ខ មិនជាសុខ តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយឧបេក្ខា ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងអកុសល ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរកុសស ចិត្តុប្បាទ ៦ ខាងវិបាកនៃអកុសល ចិត្តុ-

ប្បាទ ៦ ខាងកិរិយា ចតុត្ថជ្ឈានជារូបាវចរខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង ចតុត្ថជ្ឈានជាលោកុត្តរៈ ខាងកុសលផង ខាងវិបាក ៤ វៀរតែវេទនា មិនជាទុក្ខ មិនជាសុខ ដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ដែលប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខ ។ វេទនា ៣ ផង រូបផង និព្វានផង នេះពួកធម៌ដែលមិនគប្បីពោលថា ប្រកបដោយសុខវេទនាផង ថាប្រកបដោយទុក្ខវេទនាផង ថាប្រកបដោយវេទនាមិនជាទុក្ខ មិនជាសុខផងទេ ។

[ ៣៨០ ] ពួកធម៌ជាវិបាក តើដូចម្ដេច ។ វិបាកក្នុងភូមិ ៤ នេះពួកធម៌ជាវិបាក ។ ពួកធម៌ មានវិបាកធម៌ជាប្រក្រតី តើដូចម្ដេច ។ កុសលនិងអកុសលក្នុងភូមិ ៤ នេះពួកធម៌មានវិបាកធម៌ជាប្រក្រតី ។ ពួកធម៌មិនមែនវិបាក ទាំងមិនមែនជាធម៌ មានវិបាកជាប្រក្រតី តើដូចម្ដេច ។ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាវិបាក ទាំងមិនមែនជាធម៌ មានវិបាកជាប្រក្រតី ។

[ ៣៨១ ] ពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន តើដូចម្ដេច ។ វិបាកក្នុងភូមិ ៣ និងរូបដែលជាកម្មស្សកតត្តា នេះពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន តើដូចម្ដេច ។ កុសលនិងអកុសលក្នុងភូមិ ៣ កិរិយា

និងអព្យាក្រឹត ក្នុងភូមិ ៣ និងរូបដែលមិនមែនជាកម្មសមុដ្ឋាន នេះពួកធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តែជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌មិនមានកម្ម ប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ទាំងមិនជាប្រយោជន៍ដល់ឧបាទាន ។

[ ៣៨២ ] ពួកធម៌ដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ អកុសលចិត្តុប្បាទ ១២ នេះពួកធម៌ដែលសៅហ្មង ទាំងគួរដល់សេចក្តីសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ដែលមិនសៅហ្មង តែគួរដល់សេចក្តីសៅហ្មង ។ ពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ដែលមិនសៅហ្មង ទាំងមិនគួរដល់សេចក្តីសៅហ្មង ។

[ ៣៨៣ ] ពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ តើដូចម្តេច ។ កាមាវចរកុសលនិងអកុសល ចិត្តុប្បាទ ១១ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ២ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ១១ ខាងកិរិយា បឋមជ្ឈានជារូបាវចរខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង បឋ-

មជ្ឈានជាលោកុត្តរៈ ខាងកុសលផង ខាងវិបាកផង វៀរតែវិតក្កៈ វិចារៈដែលកើតឡើង ក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈ ។ ពួកធម៌មិនមានវិតក្កៈ មានត្រឹមតែវិចារៈ តើដូចម្តេច ។ ទុតិយជ្ឈានក្នុងរូបាវចរបញ្ចកន័យ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង ទុតិយជ្ឈាន ក្នុងលោកុត្តរបញ្ចកន័យ ខាងកុសលផង ខាងវិបាកផង វៀរតែវិចារៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ។ ពួកធម៌មិនមានវិតក្កៈ ទាំងមិនមានវិចារៈ តើដូចម្តេច ។ បញ្ចវិញ្ញាណ ២ រូបាវចរតិកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង វិចារៈដែលកើតក្នុងទុតិយជ្ឈានជាបញ្ចកន័យផង រូបផង និព្វានផង នេះពួកធម៌មិនមានវិតក្កៈ ទាំងមិនមានវិចារៈ ។ វិចារៈដែលកើតជាមួយនឹងវិតក្កៈ មិនត្រូវពោលថាប្រកបដោយវិតក្កៈ ទាំងប្រកបដោយវិចារៈផង ថាមិនមានវិតក្កៈ មានត្រឹមតែវិចារៈផង ថាមិនមានវិតក្កៈ ទាំងមិនមានវិចារៈផងទេ ។

[ ៣៨៤ ] ពួកធម៌ប្រកបដោយបីតិ តើដូចម្តេច ។ ចិត្តុប្បាទ ប្រកបដោយសោមនស្ស ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៥ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរទុកតិកជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរទុកជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែបីតិដែលកើតឡើងក្នុងទីនុ៎ះ

ចេញ នេះពួកធម៌ប្រកបដោយបីតិ ។ ពួកធម៌ប្រកបដោយសុខៈ តើដូចម្តេច ។ ចិត្តុប្បាទប្រកបដោយសោមនស្ស ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែសុខៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយសុខៈ ។ ពួកធម៌ប្រកបដោយឧបេក្ខា តើដូចម្តេច ។ ចិត្តុប្បាទប្រកបដោយឧបេក្ខា ៤ ខាងកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងអកុសល ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា ចតុត្ថជ្ឈានជារូបាវចរខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង ចតុត្ថជ្ឈានជាលោកុត្តរៈខាងកុសលផង ខាងវិបាកផង វៀរតែឧបេក្ខា ដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយឧបេក្ខា ។ បីតិ មិនប្រកបដោយបីតិ ប្រកបតែដោយសុខៈ មិនប្រកបដោយឧបេក្ខាទេ សុខៈមិនប្រកបដោយសុខៈ ប្រកបតែដោយបីតិ មិនប្រកបដោយឧបេក្ខាក៏មាន មិនគប្បីពោលថា ប្រកបដោយបីតិក៏មាន ។ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស កាយវិញ្ញាណប្រកបដោយទុក្ខនិងឧបេក្ខាវេទនាផង រូបផង និព្វានផង នេះពួកធម៌មិនត្រូវពោលថា ប្រកបដោយបីតិផង ថាប្រកបដោយសុខៈផង ថាប្រកបដោយឧបេក្ខាផងឡើយ ។

[ ៣៨៥ ] ពួកធម៌ត្រូវលះដោយទស្សនៈ ( សោតាបត្តិមគ្គ ) តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិនិងចិត្តុប្បាទប្រកបដោយវិចិកិច្ឆា នេះពួកធម៌ដែលត្រូវលះដោយទស្សនៈ ។ ពួកធម៌ត្រូវលះដោយវេទនា តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ នេះពួកធម៌ត្រូវលះដោយភាវនា ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិតែប្រកបដោយលោភៈ និងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌ត្រូវលះដោយទស្សនៈ ក៏មាន ត្រូវលះដោយភាវនាក៏មាន ។ ពួកធម៌ដែលមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា តើដូចម្ដេច ។ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ។

[ ៣៨៦ ] ពួកធម៌មានហេតុត្រូវលះដោយទស្សនៈ តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា វៀរតែមោហៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈ ។ ពួកធម៌មានហេតុត្រូវលះដោយភាវនា តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ វៀរតែមោហៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌មានហេតុត្រូវលះដោយភាវនា ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិតែប្រកបដោយលោភៈនិងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌មានហេតុត្រូវលះដោយទស្សនៈក៏មាន មានហេតុត្រូវលះដោយភាវនាក៏មាន ។ ពួកធម៌មានហេតុមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា តើដូចម្ដេច ។

មោហៈប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មានហេតុមិនត្រូវលះដោយទស្សនៈ ទាំងមិនត្រូវលះដោយភាវនា ។

[ ៣៨៧ ] ពួកធម៌ដល់នូវការសន្សំកពូនឡើង តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ នេះពួកធម៌ដល់នូវការសន្សំកពូនឡើង ។ ពួកធម៌មិនដល់នូវការសន្សំកពូនឡើង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្ន នេះពួកធម៌មិនដល់នូវការសន្សំកពូនឡើង ។ ពួកធម៌មិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនមិនដល់នូវការសន្សំកពូនឡើង តើដូចម្តេច ។ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនដល់នូវការសន្សំកពូនឡើង ទាំងមិនមែនមិនដល់នូវការសន្សំកពូនឡើង ។

[ ៣៨៨ ] ពួកធម៌ ជារបស់សេក្ខបុគ្គល តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៣ ខាងក្រោមផង នេះពួកធម៌ជារបស់សេក្ខបុគ្គល ។ ពួកធម៌ជារបស់អសេក្ខបុគ្គល តើដូចម្តេច ។ អរហត្តផលខាងលើ នេះពួកធម៌ជារបស់អសេក្ខបុគ្គល ។ ពួកធម៌មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ មិនមែនជារបស់សេក្ខបុគ្គល ទាំងមិនមែនជារបស់អសេក្ខបុគ្គល ។

[ ៣៨៩ ] ពួកធម៌មានសភាពតូចឆ្មារ តើដូចម្តេច ។ កាមាវចរកុសល

និងអកុសល វិបាកទាំងអស់នៃកាមាវចរ កិរិយានិងអព្យាក្រឹតជាកាមាវចរ និងរូបទាំងអស់ នេះពួកធម៌មានសភាពតូចឆ្មារ ។ ពួកធម៌ដល់នូវសភាពធំ តើដូចម្តេច ។ រូបាវចរ អរូបាវចរ កុសលនិងអព្យាក្រឹត នេះពួកធម៌ដល់នូវសភាពធំ ពួកធម៌ប្រមាណមិនបាន តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រមាណមិនបាន ។

[ ៣៩០ ] ពួកធម៌មានអារម្មណ៍តូចឆ្មារ តើដូចម្តេច ។ វិបាកទាំងអស់នៃកាមាវចរ កិរិយា មនោធាតុនិងមនោវិញ្ញាណធាតុ ជាកិរិយាហេតុកៈប្រកបដោយសោមនស្ស នេះពួកធម៌មានអារម្មណ៍តូចឆ្មារ ។ ពួកធម៌មានអារម្មណ៍ដល់សភាពធំ តើដូចម្តេច ។ វិញ្ញាណញ្ចាយតនៈនិងនេវសញ្ញានាសញ្ញាយតនៈ នេះពួកធម៌មានអារម្មណ៍ដល់នូវសភាពធំ ។ ពួកធម៌មានអារម្មណ៍ប្រមាណមិនបាន តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង នេះពួកធម៌មានអារម្មណ៍ប្រមាណមិនបាន ។ ចិត្តុប្បាទ ៤ ជាញាណវិប្បយុត្តខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ជាញាណវិប្បយុត្តខាងកិរិយា និងអកុសលទាំងអស់ នេះពួកធម៌មានអារម្មណ៍តូចឆ្មារ ក៏មាន មានអារម្មណ៍ដល់នូវសភាពធំ តែមិនមែនមានអារម្មណ៍ប្រមាណមិនបានទេ ក៏មាន មិនគប្បីពោលថា មានអារម្មណ៍តូចឆ្មារផង ថាមានអារម្មណ៍ដល់នូវសភាពធំផងក៏មាន ។ ចិត្តុប្បាទ ៤ ជាញាណសម្បយុត្ត ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ជាញាណសម្បយុត្តខាងកិរិយា រូបាវចរចតុត្ថជ្ឈានខាងកុសលផង ខាងកិរិយាផង និងមនោវិញ្ញាណធាតុ ជាកិរិយាហេតុកៈ

ប្រកបដោយឧបេក្ខា នេះពួកធម៌មានអារម្មណ៍តូចថ្មារក៏មាន មានអារម្មណ៍ដល់នូវសភាពធំក៏មាន មានអារម្មណ៍ប្រមាណមិនបានក៏មាន មិនគប្បីពោលថា មានអារម្មណ៍តូចថ្មារផង ថាមានអារម្មណ៍ដល់នូវសភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងក៏មាន ។ រូបាវចរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង វិបាកនៃចតុត្ថជ្ឈាន អាកាសានញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ នេះពួកធម៌មិនគប្បីពោលថា មានអារម្មណ៍តូចថ្មារផង ថាមានអារម្មណ៍ដល់នូវសភាពធំផង ថាមានអារម្មណ៍ប្រមាណមិនបានផងឡើយ ។ ឯរូបនិងនិព្វាន មិនមែនមានអារម្មណ៍ទេ ។

[ ៣៩១ ] ពួកធម៌ដ៏ថោកទាប តើដូចម្ដេច ។ អកុសលចិត្តុប្បាទ ១២ នេះពួកធម៌ដ៏ថោកទាប ។ ពួកធម៌ជាកណ្ដាល តើដូចម្ដេច ។ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ជាកណ្ដាល ។ ពួកធម៌ដ៏ឧត្ដម តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ដ៏ឧត្ដម ។

[ ៣៩២ ] ពួកធម៌មានសភាពខុស និងទៀង តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌មានសភាពខុស និងទៀងក៏មាន មិនទៀងក៏មាន ពួកធម៌មានសភាពត្រូវ និងទៀង តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្ន នេះពួកធម៌មានសភាពត្រូវនិងទៀង ។ ពួកធម៌មិនទៀង តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយ

ឧទ្ទេសៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនទៀង ។

[ ៣៩៣ ] ពួកធម៌មានមគ្គជាអារម្មណ៍ តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ជាញាណសម្បយុត្ត ខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ជាញាណសម្បយុត្ត ខាងកិរិយា នេះពួកធម៌មានមគ្គជាអារម្មណ៍ តែមិនមែនមានមគ្គជាហេតុក៏មាន មានមគ្គជាអធិបតីក៏មាន មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាអធិបតីផងក៏មាន ។ អរិយមគ្គ ៤ មិនមែនមានមគ្គជាអារម្មណ៍ តែមានមគ្គជាហេតុ មានមគ្គជាអធិបតិក៏មាន មិនគប្បីពោលថា មានមគ្គជាអធិបតីក៏មាន ។ រូបាវចរចតុត្ថជ្ឈាន ខាងកុសលផង ខាងកិរិយាផង និងមនោវិញ្ញាណធាតុជាកិរិយាហេតុកៈ ប្រកបដោយឧបេក្ខា នេះពួកធម៌មានមគ្គជាអារម្មណ៍ តែមិនមែនមានមគ្គជាហេតុ មិនមែនមានមគ្គជាអធិបតី ក៏មាន មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ក៏មាន ។ ចិត្តុប្បាទ ៤ ជាញាណ-វិប្បយុត្ត ខាងកាមាវចរកុសល អកុសលទាំងអស់ វិបាកទាំងអស់នៃកា-មាវចរ ចិត្តុប្បាទ ៦ ខាងកិរិយា រូបាវចរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង វិបាកនៃចតុត្ថជ្ឈាន អរូបជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង និងសាមញ្ញផល ៤ នេះពួកធម៌មិនគប្បីពោលថា មានមគ្គជាអារម្មណ៍ផង ថាមានមគ្គជាហេតុផង ថាមានមគ្គជាអធិបតីផងឡើយ ។ ឯរូបនិងនិព្វានមិនមែនមានអារម្មណ៍ទេ ។

[ ៣៩៤ ] ពួកធម៌ដែលកើតឡើងហើយ តើដូចម្ដេច ។ វិបាកក្នុងភូមិ ៤

និងរូបជាកម្មស្សកតត្តា នេះពួកធម៌ដែលកើតឡើងហើយក៏មាន ដែលប្រុង នឹងកើតឡើង តែមិនគប្បីពោលថា មិនទាន់កើតឡើងក៏មាន ។ កុសលនិង អកុសលក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបដែលមិនមែនជា កម្មស្សកតត្តា នេះពួកធម៌កើតឡើងហើយក៏មាន មិនទាន់កើតឡើង តែមិន គប្បីពោលថា ប្រុងនឹងកើតឡើងក៏មាន ។ ឯនិព្វានមិនគប្បីពោលថា កើត ឡើងហើយផង ជាមិនទាន់កើតឡើងផង ជាប្រុងនឹងកើតផងឡើយ ។

[ ៣៩៥ ] វៀរតែនិព្វានចេញ ពួកធម៌ទាំងអស់ជាអតីតក៏មាន ជាអនា-គតក៏មាន ជាបច្ចុប្បន្នក៏មាន ។ ឯនិព្វានមិនគប្បីពោលថា ជាអតីតផង ជា ជាអនាគតផង ជាជាបច្ចុប្បន្នផងឡើយ ។

[ ៣៩៦ ] ពួកធម៌មានអារម្មណ៍ជាអតីតៈ តើដូចម្តេច ។ វិញ្ញាណញ្ចា-យតនៈ និងនេវសញ្ញានាសញ្ញាយតនៈ នេះពួកធម៌មានអារម្មណ៍ជាអតីត ។ ពួកធម៌អស់ការប្រកប មានអារម្មណ៍ជាអនាគត មិនមានទេ ។ ពួកធម៌មាន អារម្មណ៍ជាបច្ចុប្បន្ន តើដូចម្តេច ។ បញ្ចវិញ្ញាណ ២ និងមនោធាតុ ៣ នេះ ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ។ ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរ-កុសល មនោវិញ្ញាណធាតុប្រកបដោយឧបេក្ខា ខាងវិបាកនៃអកុសល និង មនោវិញ្ញាណធាតុ ជាកិរិយាហេតុកៈ ប្រកបដោយសោមនស្ស នេះពួកធម៌ មានអារម្មណ៍ជាអតីតក៏មាន ។ មានអារម្មណ៍ជាអនាគតក៏មាន មានអារម្មណ៍ ជាបច្ចុប្បន្នក៏មាន ។ កាមាវចរកុសល អកុសល និងចិត្តុប្បាទ ៩ ខាង កិរិយា រូបាវចរ ចតុត្ថជ្ឈានខាងកុសលផង ខាងកិរិយាផង នេះពួកធម៌មាន

អារម្មណ៍ជាអតីតក៏មាន មានអារម្មណ៍ជាអនាគត ក៏មាន មានអារម្មណ៍ជាបច្ចុប្បន្នក៏មាន មិនគប្បីពោលថា មានអារម្មណ៍ជាអតីតៈផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងក៏មាន ។ រូបាវចរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង វិបាកនៃចតុត្ថជ្ឈានអាកាសានញ្ចាយតនៈ អាកិញ្ចញ្ញាយតនៈ មគ្គ ៤ ជាអបរិយាបន្ន និងសាមញ្ញផល ៤ នេះពួកធម៌មិនគប្បីពោលថា មានអារម្មណ៍ជាអតីតៈផង ថាមានអារម្មណ៍ជាអនាគតផង ថាមានអារម្មណ៍ជាបច្ចុប្បន្នផងឡើយ ។ ឯរូបនិងនិព្វានមិនមែនមានអារម្មណ៍ទេ ។

[ ៣៩៧ ] វៀរលែងតែរូបដែលមិនជាប់ដោយឥន្ទ្រិយ និងនិព្វានចេញ ពួកធម៌ទាំងអស់ជាខាងក្នុងក៏មាន ជាខាងក្រៅក៏មាន ជាខាងក្នុងនិងខាងក្រៅក៏មាន ។ ឯរូបដែលមិនជាប់ដោយឥន្ទ្រិយ និងនិព្វាន ទុកជាខាងក្រៅ ។

[ ៣៩៨ ] ពួកធម៌មានអារម្មណ៍ខាងក្នុង តើដូចម្តេច ។ វិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈ នេះពួកធម៌មានអារម្មណ៍ខាងក្នុង ។ ពួកធម៌មានអារម្មណ៍ខាងក្រៅ តើដូចម្តេច ។ រូបាវចរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង វិបាកនៃចតុត្ថជ្ឈាន អាកាសានញ្ចាយតនៈ មគ្គ ៤ ជាអបរិយាបន្ន និងសាមញ្ញផល ៤ នេះពួកធម៌មានអារម្មណ៍ខាងក្រៅ ។ វៀរតែរូបចេញ ពួកធម៌ជាកុសល អកុសលនិងអព្យាក្រឹត ជាកាមាវចរទាំងអស់ រូបាវចរចតុត្ថជ្ឈានខាងកុសលផង ខាងកិរិយាផង នេះពួកធម៌មានអារម្មណ៍ខាងក្នុងក៏មាន មានអារម្មណ៍ខាងក្រៅក៏

មាន មានអារម្មណ៍ខាងក្នុងនិងខាងក្រៅក៏មាន អាកិញ្ចញ្ញាយតនៈ មិនគប្បីពោលថា មានអារម្មណ៍ខាងក្នុងផង ថាមានអារម្មណ៍ខាងក្រៅផង ថាមានអារម្មណ៍ខាងក្នុងនិងខាងក្រៅផងឡើយ ។ ឯរូបនិងនិព្វាន មិនមែនមានអារម្មណ៍ទេ ។

[ ៣៩៩ ] ពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ រូបាយតនៈ នេះពួកធម៌ប្រកបដោយការឃើញ ទាំងប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះពួកធម៌មិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ កុសលនិងអកុសល ក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបជាអនិទស្សនៈ ជាអប្បដិឃៈ ដែលរាប់បញ្ចូលក្នុងធម្មាយតនៈ និងនិព្វាន នេះពួកធម៌មិនប្រកបដោយការឃើញ ទាំងមិនប្រកបដោយការប៉ះពាល់ ។

**ចប់ ពួកតិកៈ ។**

# អដ្ឋកថាកណ្ឌ

# អធិប្បាយ តិកអត្ថុទ្ធារ

[ ៣៧៨-៣៩៩ ] ឥឡូវនេះដល់លំដាប់នៃការពណ៌នាអដ្ឋកថាកណ្ឌដែលលោកតាំងទុក ក្នុងលំដាប់នៃនិក្ខេបកណ្ឌ ។ សួរថា កណ្ឌនេះ ឈ្មោះថា អដ្ឋកថាកណ្ឌ ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលើកសេចក្ដីនៃព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកឡើងមកពង្រីកសេចក្ដី ។

មែនពិត ព្រះពុទ្ធវចនៈដែលមកក្នុងលំដាប់នៃធម៌ក្នុងបិដកទាំង ៣ ទ្រង់កំណត់វិនិច្ឆ័យទុកដោយអដ្ឋកថាកណ្ឌនុ៎ះឯង រមែងឈ្មោះថា ជាពាក្យដែលលោកវិនិច្ឆ័យល្អហើយ ។ កាលកំណត់មិនបាននូវគន្លងរបស់ព្រះវិន័យ ក្នុងព្រះអភិធម្មបិដកទាំងមូល កាលលើកបញ្ហាឡើងសួរក្នុងមហាបករណ៍ និងការរាប់ ការរួបរួមទុកដោយអដ្ឋកថាកណ្ឌនោះឯង រមែងគួរ ។

សួរថា អដ្ឋកថាកណ្ឌនេះកើតអំពីនរណា ឆ្លើយថា កើតអំពីព្រះសារីបុត្តត្ថេរ ។ ពិតណាស់ ព្រះសារីបុត្តត្ថេរបានពោលអដ្ឋកថាកណ្ឌឲ្យសទ្ធិវិហារិករបស់លោកមួយរូបដែលមិនអាចកំណត់សេចក្ដីក្នុងនិក្ខេបកណ្ឌបាន ។ តែអដ្ឋកថាកណ្ឌនេះ លោកពោលជំទាស់ទុកក្នុងមហាអដ្ឋកថា ។ ឈ្មោះថាព្រះអភិធម្ម មិនមែនជាវិស័យរបស់សាវក មិនមែនជាគោចររបស់សាវក ព្រះអភិធម្មនេះជាពុទ្ធវិស័យ ជាគោចររបស់ព្រះពុទ្ធ តែព្រះធម្មសេនាបតីត្រូវសទ្ធិវិហារិកសួរហើយ ទើបនាំសទ្ធិវិហារិកនោះ ទៅកាន់សម្នាក់ព្រះសាស្ដា ហើយទូលសួរចំពោះព្រះសម្មាសម្ពុទ្ធ ទើបព្រះសម្មាសម្ពុទ្ធ ត្រាស់អដ្ឋកថា-

កណ្ឌប្រទានដល់ភិក្ខុនោះ ។ បានត្រាស់ប្រទានយ៉ាងដូចម្ដេច គឺព្រះមាន-ព្រះភាគ ត្រាស់សួរថា **កតមេ ធម្មា កុសលា** ដូច្នេះ ។ អធិប្បាយថា អ្នកកំណត់ថា ឈ្មោះថាពួកធម៌ជាកុសល តើដូចម្ដេច ។ គ្រានោះព្រះមាន-ព្រះភាគ កាលទ្រង់សម្ដែងធម៌ មានកុសលជាដើម ដោយអំណាចការពន្រើកសេចក្ដី បានប្រទានធ្វើឲ្យជាពួកៗ ជាក្រុមៗ ប្រទានដល់ភិក្ខុដែលនៅដោយតុណ្ហីភាពនោះ ដោយន័យនេះថា កុសលណា ដែលតថាគតសម្ដែងដោយប្រភេទនៃភូមិដោយន័យជាដើមថា ពួកធម៌ជាកុសល ដូចម្ដេចខ្លះ ។ ចិត្តជាកាមាវចរកុសល... កើតឡើង ក្នុងសម័យណា កុសលទាំងអស់នោះ ជាកុសលក្នុងភូមិ ៤ សភាវៈធម៌ទាំងនេះ ឈ្មោះថា ធម៌ជាកុសលមិនមែនឬ ។

បណ្ដាបទទាំងនោះ បទថា **ចតូសុ** បានដល់ កាមាវចរភូមិ រូបាវចរភូមិ អរូបាវចរភូមិនិងលោកុត្តរភូមិ ។ បទថា **កុសលំ** បានដល់ កុសល មានផស្សៈជាដើម ។ បទថា **ឥមេ ធម្មា កុសលា** បានដល់ ធម៌ទាំងអស់នេះ មានផស្សៈជាដើម ដែលត្រាស់ទុកក្នុងភូមិ ៤ នោះ ឈ្មោះថា **ពួកធម៌ជាកុសល** ។

ព្រោះអកុសលធម៌ទាំងឡាយ មិនមានការផ្សេងគ្នា ដោយអំណាចភូមិ ទើបត្រាស់ថា **ទ្វាទស អកុសលចិត្តុប្បាទា** អកុសលចិត្តុប្បាទ ( ការកើតនៃចិត្តជាអកុសល ) ១២ ដូច្នេះ ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា អកុសលចិត្តុប្បាទនោះ ដូចតទៅនេះថា ដែលឈ្មោះថា ឧប្បាទៈ ព្រោះអត្ថថា កើតឡើង ។ ឧប្បាទៈ គឺចិត្តនុ៎ះឯង ឈ្មោះថា ចិត្តុប្បាទ ។ ពាក្យថា

ចិត្តុប្បាទនេះ ជាប្រធាននៃទេសនានោះឯង ដូចមហាជនពោលថា ព្រះរាជា ស្ដេចយាងមកហើយ ដូច្នេះ រមែងជាការដែលពោលដល់ការមកនៃអាមាត្យជាដើមយ៉ាងណា កាលព្រះអង្គត្រាស់ថា **ចិត្តុប្បាទ** ដូច្នេះ សម្បយុត្តធម៌ទាំងឡាយក៏ជាការដែលត្រាស់ហើយផងដែរ យ៉ាងនោះដូចគ្នា ព្រោះហេតុនោះ គប្បីជ្រាបថា ទ្រង់កាន់យកចិត្ត ព្រមទាំងសម្បយុត្តធម៌ ដោយសព្ទថា ចិត្តុប្បាទក្នុងទីទាំងពួង ។

ខាងមុខអំពីនេះទៅ សេចក្ដីនៃបទតិកកាជនីយ និងទុកកាជនីយទាំងអស់ មានពាក្យថា **ចក្ខុសុ ភូមីសុ វិចាកោ** ជាដើម និងភាពដែលសុខវេទនាជាដើម ក្នុងវេទនាតិកៈជាដើម ជានវត្តព្វធម៌ បណ្ឌិតពិចារណាព្រះបាលីនិងអដ្ឋកថាហើយ គប្បីជ្រាបបានដោយន័យ ដែលពោលហើយនុ៎ះឯង ខ្ញុំនឹងពោលតែសេចក្ដីដែលផ្សេងគ្នាប៉ុណ្ណោះ ។

បណ្ដាតិកៈទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងបរិត្តារម្មណត្តិកៈមុន ក្នុងបទថា **សព្ពោ កាមាវចរស្ស វិចាកោ** នេះ បានដល់ ទ្វិបញ្ចវិញ្ញាណ ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ( កាមអារម្មណ៍ ) ព្រោះអត្ថថា អាស្រ័យចក្ខុបសាទជាដើម ហើយប្រារព្ធធម៌ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មានឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើម ប្រព្រឹត្តទៅដោយពិតប្រាកដនោះឯង ។ មនោធាតុ ២ គឺកុសលវិបាកនិងអកុសលវិបាក ក៏ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ព្រោះអត្ថថា អាស្រ័យហទយវត្ថុ ប្រារព្ធអារម្មណ៍ទាំងឡាយ មានរូបជាដើមនុ៎ះឯងប្រព្រឹត្តទៅក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម

ដោយពិតប្រាកដ ។ អហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាកសហ-គតៈដោយសោមនស្ស ក៏ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ព្រោះអត្ថថា ប្រារព្ធអារម្មណ៍ដែលជាកាមាវចរៈ ៦ មានរូបារម្មណ៍ជាដើមនោះឯងប្រព្រឹត្ត ទៅដោយពិតប្រាកដ គឺដោយអំណាចជាសន្តីរណៈ ក្នុងទ្វារ ៥ និងដោយ អំណាចជាតទារម្មណៈក្នុងទ្វារ ៦ ។

អហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក និងអកុសលវិបាកទាំង ២ ក៏ឈ្មោះថា ធម៌មានអារម្មណ៍ ជាបរិត្តៈ ព្រោះអត្ថថា ប្រារព្ធអារម្មណ៍ ដែលជាកាមាវចរ ៦ មានរូបារម្មណ៍ជាដើមនុ៎ះឯង ប្រព្រឹត្តទៅដោយពិត ប្រាកដ ដោយអំណាចជាសន្តីរណៈក្នុងបញ្ចទ្វារ និងដោយអំណាចជាតទា-រម្មណៈក្នុងទ្វារ ៦ កាលប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ ក៏រមែងធ្វើបរិត្ត-កម្ម កម្មនិមិត្ត ឬគតិនិមិត្តឲ្យជាអារម្មណ៍ កាលប្រព្រឹត្តទៅដោយភវង្គក្នុង បវត្តិកាល និងដោយអំណាចចុតិ ក្នុងកាលជាទីបំផុត ក៏ធ្វើបរិត្តកម្មជាដើម នោះឯងឲ្យជាអារម្មណ៍ ។ មួយទៀត ចិត្តុប្បាទដែលជាសហេតុកកុសល-វិបាក ៨ ដួង ក៏ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ព្រោះអត្ថថា ប្រារព្ធ បរិត្តធម៌នុ៎ះឯងប្រព្រឹត្តទៅ ដោយអំណាចជាតទារម្មណៈ និងដោយអំណាច បដិសន្ធិ ភវង្គ និងចុតិ ដោយន័យដែលពោលក្នុងអហេតុកមនោវិញ្ញាណ ធាតុដែលជាកុសលវិបាក និងអកុសលវិបាក ២ ដួងនោះនុ៎ះឯង ។

កិរិយាមនោធាតុ ក៏ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ព្រោះអត្ថថា ប្រារព្ធអារម្មណ៍មានរូបជាដើម ប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ។ អហេតុកកិរិយា-

មនោវិញ្ញាណធាតុ ដែលសហគតៈដោយសោមនស្ស ក៏ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ព្រោះអត្ថថា ប្រារព្ធធម៌មានរូបារម្មណ៍ជាដើម ដែលជាកាមាវចរៈទាំងឯងដែលជាបច្ចុប្បន្នក្នុងទ្វារ ៦ សូម្បីដែលជាអតីត និងអនាគតក្នុងមនោទ្វារ ធ្វើអាការរីករាយ ប្រព្រឹត្តទៅដល់ព្រះខីណាស្រព ។ ដោយប្រការយ៉ាងនេះ ចិត្តុប្បាទទាំង ២៥ នេះ គប្បីជ្រាបថា មានអារម្មណ៍ជាបរិត្តៈដោយចំណែកមួយ ។

ធម៌គឺ វិញ្ញាណញ្ចាយតនៈនិងនេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា ធម៌មានអារម្មណ៍ជាមហគ្គតៈ ព្រោះប្រារព្ធសមាបត្តិជាន់ទាបរៀងៗខ្លួន ប្រព្រឹត្តទៅ ។ ធម៌គឺ មគ្គនិងផល ឈ្មោះថា ធម៌មានអារម្មណ៍ប្រមាណមិនបានព្រោះមាននិព្វានជាអារម្មណ៍ ។

ចិត្តុប្បាទ ដែលជាញាណវិប្បយុត្ត ៨ គឺ ខាងកុសល ៤ ដួង ខាងកិរិយា ៤ ដួង ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈ ក្នុងវេលាដែលសេក្ខបុគ្គល បុថុជ្ជននិងព្រះខីណាស្រព ប្រារព្ធកាមាវចរធម៌ប្រព្រឹត្តទៅក្នុងការឲ្យទាន ការពិចារណានិងការស្តាប់ធម៌ដោយមិនគោរពជាដើម ឈ្មោះថា ធម៌មានអារម្មណ៍ជាមហគ្គតៈ ក្នុងវេលាដែលពិចារណាធម៌ មានបឋមជ្ឈានជាដើមដែលស្ទាត់ជំនាញក្រៃលែង ឈ្មោះថា ធម៌មានអារម្មណ៍ជានវត្តព្វៈ ក្នុងការពិចារណាបញ្ញត្តិ មានកសិណនិងនិមិត្តជាដើម ។ ចិត្តុប្បាទដែលសម្បយុត្តដោយទិដ្ឋិខាងអកុសល ៤ ដួង ឈ្មោះថា ធម៌មានអារម្មណ៍ជាបរិត្តៈក្នុងវេលាដែលប្រកាន់មាំ ត្រេកអររីករាយក្នុងកាមាវចរធម៌ ៥៥[១]ថាជាសត្វ

---

១-កាមាវចរចិត្ត ៥៤ និងរូប ១ ( ដីកា ) ។

ថាជាបុគ្គល ឈ្មោះថា ធម៌មានអារម្មណ៍ជាមហគ្គតៈ ក្នុងវេលាប្រារព្ធមហគ្គត-ធម៌ ២៧ ដួង ប្រព្រឹត្តទៅដោយអាការនោះៗឯង ឈ្មោះថា ធម៌មានអា-រម្មណ៍ជានវត្តព្វៈក្នុងវេលាដែលប្រារព្ធបញ្ញត្តិធម៌ប្រព្រឹត្តទៅ ។ ចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្ត គប្បីជ្រាបថា មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ និងនវត្តព្វៈ ក្នុងវេលាប្រារព្ធធម៌ទាំងនោះៗឯង ប្រព្រឹត្តទៅដោយអំណាចសេចក្តីត្រេកអររីករាយតែម្យ៉ាង ចិត្តុប្បាទដែលជាបដិឃសម្បយុត្ត គប្បីជ្រាបថា មានអា-រម្មណ៍ជាបរិត្តៈ មហគ្គតៈនិងនវត្តព្វៈក្នុងវេលាប្រព្រឹត្តទៅដោយអំណាចទោ-មនស្ស ចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆា គប្បីជ្រាបថា មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ និងនវត្តព្វៈ ក្នុងវេលាប្រព្រឹត្តទៅដោយអំណាចការមិនអាចសម្រេចចិត្តបាន ចិត្តុប្បាទដែលសហគតៈដោយឧទ្ធច្ចៈ ក៏គប្បីជ្រាបថា មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ និងនវត្តព្វៈ ក្នុងវេលាប្រព្រឹត្តទៅដោយអំណាចសេចក្តីរាយមាយ គឺដោយអំណាចនៃសេចក្តីមិនស្ងប់ ។

បណ្តាធម៌ទាំងនោះ សូម្បីធម៌មួយ រមែងមិនអាចប្រារព្ធអប្បមាណធម៌ឲ្យប្រព្រឹត្តទៅ ។ ព្រោះហេតុនោះ ធម៌ទាំងនោះទើបមិនឈ្មោះថា **ឆ អប្ប-មាណារម្មណា** ( តែមិនមែនមានអារម្មណ៍ប្រមាណមិនបានទេ ) ។

ចិត្តុប្បាទដែលសម្បយុត្តដោយញាណ ៨ គឺខាងកុសល ៤ ខាងកិរិយា ៤ ជាធម៌មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈនិងនវត្តព្វៈ ក្នុងវេលាព្រះសេក្ខ-បុគ្គលបុថុជ្ជន និងព្រះខីណាស្រព ប្រារព្ធធម៌ មានប្រការតាមដែលពោលហើយ ប្រព្រឹត្តទៅក្នុងការឲ្យទាន ការពិចារណានិងការស្តាប់ធម៌ដោយគោរព

ជាដើម ។ ចិត្តុប្បាទដែលសម្បយុត្តដោយញាណទាំងនោះ គប្បីជ្រាបថា ជាធម៌មានអារម្មណ៍ប្រមាណមិនបាន ក្នុងកាលនៃគោត្រភូ និងក្នុងកាលពិចារណាលោកុត្តរធម៌ ។

រូបាវចរចតុត្ថជ្ឈាននេះ ខាងកុសលក្តី ខាងកិរិយាក្តី នីមួយៗ មាន ១២ គឺ ចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួង ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអាកាសកសិណ ១ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងអាលោកកសិណ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអានាបានៈ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វសោត ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងយថាកម្មូបគញ្ញាណ ១ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងទិព្វចក្ខុញ្ញាណ ១ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ១ ។

បណ្តាចតុត្ថជ្ឈានទាំងនោះ ចតុត្ថជ្ឈានក្នុងកសិណ ៨ ឈ្មោះថា ចតុត្ថជ្ឈានជាបាទក្នុងធម៌ទាំងពួង មែនពិត ចតុត្ថជ្ឈានក្នុងកសិណ ៨ នោះ ជាបាទនៃវិបស្សនាខ្លះ ជាបាទនៃអភិញ្ញាទាំងឡាយខ្លះ ជាបាទនៃនិរោធខ្លះ ជាបាទនៃវដ្តៈខ្លះ ព្រោះហេតុនោះឯង ទើបពោលថា ចតុត្ថជ្ឈានជាបាទក្នុងធម៌ទាំងពួង ។ ចំណែកចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងអាកាសកសិណ និងអាលោកកសិណ ជាបាទនៃវិបស្សនាខ្លះ ជាបាទនៃអភិញ្ញាទាំងឡាយខ្លះ ជាបាទនៃវដ្តៈខ្លះ តែមិនមែនជាបាទនៃនិរោធឡើយ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្ត

ទៅក្នុងព្រហ្មវិហារ និងអានាបានៈ ជាបាទនៃវិបស្សនានិងជាបាទនៃវដ្តៈ តែមិនជាបាទនៃអភិញ្ញាទាំងឡាយ និងមិនជាបាទនៃនិរោធ ។ បណ្ដាចតុត្ថជ្ឈានទាំងនោះ ឈានដែលមានកសិណជាអារម្មណ៍ សូម្បីទាំង ១០ ( កសិណ ១០ ) ឈ្មោះថា នវត្តព្វារម្មណ៍ គឺមានអារម្មណ៍ដែលមិនគប្បីពោលដោយអំណាចនៃបរិត្តារម្មណ៍ជាដើម ព្រោះប្រារព្ធកសិណបញ្ញត្តិប្រព្រឹត្តទៅ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ ក៏ឈ្មោះថា នវត្តព្វារម្មណ៍ គឺមានអារម្មណ៍ដែលពោលមិនបាន ដោយអំណាចនៃបរិត្តារម្មណ៍ជាដើម ព្រោះប្រារព្ធសត្វបញ្ញត្តិប្រព្រឹត្តទៅ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអានាបានៈ ក៏ឈ្មោះថា នវត្តព្វារម្មណ៍ គឺមានអារម្មណ៍ដែលពោលមិនបានដោយអំណាចនៃបរិត្តារម្មណ៍ជាដើម ព្រោះប្រារព្ធនិមិត្តប្រព្រឹត្តទៅ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធៈ រមែងមានអារម្មណ៍ជាបរិត្តៈនិងមហគ្គតៈ តើដូចម្ដេច គឺក្នុងកាលណា ព្រះយោគាវចរមានសេចក្ដីប្រាថ្នាធ្វើកាយឲ្យអាស្រ័យចិត្តហើយហោះទៅ ដោយកាយដែលមើលមិនឃើញ ក៏បង្អោនកាយទៅដោយអំណាចនៃចិត្ត រមែងសង្រ្គោះទុក គឺរមែងលើកកាយឡើងក្នុងមហគ្គតចិត្ត ក្នុងកាលនោះ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធៈនោះ ព្រោះធ្វើអារម្មណ៍ដែលបានហើយដោយការប្រកប ទើបមានអារម្មណ៍ជាបរិត្តៈ ដោយមានរូបកាយជាអារម្មណ៍ ។ ក្នុងកាលណា ព្រះយោគាវចរបំណងធ្វើចិត្ត ឲ្យអាស្រ័យកាយហើយទៅ ដោយកាយដែលមើលឃើញ ក៏បង្អោនចិត្តទៅដោយអំណាចនៃកាយ រមែងសង្រ្គោះចូល គឺរមែងលើកចិត្ត

ដែលមានឈានជាបាទទុកក្នុងរូបកាយ ក្នុងកាលនោះចតុត្ថជ្ឈានដែលប្រព្រឹត្ត ទៅក្នុងឥទ្ធិវិធៈនោះ ព្រោះធ្វើអារម្មណ៍ដែលបានដោយការប្រកប ទើបមាន អារម្មណ៍ជាមហគ្គតៈ ដោយមានមហគ្គតៈចិត្តជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វសោត មានអារម្មណ៍ជាបរិត្តៈតែម្យ៉ាង ព្រោះប្រារព្ធសំឡេងប្រព្រឹត្តទៅ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិ-យញ្ញាណ មានអារម្មណ៍ជាបរិត្តៈ មហគ្គតៈ និងអប្បមាណៈ ។ សេចក្តីនេះ តើដូចម្តេច គឺក្នុងវេលាដែលដឹងចិត្តជាកាមាវចររបស់ពួកជនដទៃ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណនោះ ក៏មានអារម្មណ៍ជាបរិត្ត ក្នុង វេលាដែលដឹងរូបាវចរចិត្តនិងអរូបាវចរចិត្តរបស់ជនពួកដទៃ ក៏មានអារម្មណ៍ ជាមហគ្គតៈ ក្នុងវេលាដែលដឹងមគ្គនិងផលរបស់ពួកជនដទៃ ក៏មានអារម្មណ៍ អប្បមាណ ។ ក្នុងអធិការនេះ បុថុជ្ជន រមែងមិនដឹងចិត្តនៃព្រះសោតាបន្ន ព្រះសោតាបន្នរមែងមិនដឹងចិត្តរបស់ព្រះសកទាគាមី ដោយអាការយ៉ាងនេះ គប្បីជ្រាបរហូតដល់ព្រះអរហន្ត តែព្រះអរហន្តរមែងដឹងចិត្តរបស់បុគ្គលទាំង អស់ ។ គប្បីជ្រាបការផ្សេងគ្នានេះថា អរិយបុគ្គលដទៃទៀតដែលមានភូមិ-ចិត្តខ្ពស់ រមែងដឹងចិត្តរបស់បុគ្គលដែលមានភូមិចិត្តទាបជាង ។ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងយថាកម្មូបគញ្ញាណ រមែងមានអារម្មណ៍ជាបរិត្តៈ ក្នុង វេលាដែលដឹងកម្មដែលជាកាមាវចរ មានអារម្មណ៍ជាមហគ្គតៈក្នុងវេលាដែល ដឹងកម្មដែលជារូបាវចរនិងអរូបាវចរ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វ-ចក្ខុញ្ញាណរមែងមានអារម្មណ៍ជាបរិត្តៈតែម្យ៉ាង ព្រោះមានរូបជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ រមែងមានអារម្មណ៍ជាបរិត្ត មហគ្គត អប្បមាណនិងនវត្តព្វ តើមានដូចម្តេច គឺថា ក្នុងវេលាដែលតាមរឭកដល់ខន្ធជាកាមាវចរ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណនោះ ក៏មានអារម្មណ៍ជាបរិត្តៈ ក្នុងវេលាដែលតាមរឭកដល់ខន្ធដែលជារូបាវចរ និងអរូបាវចរ ក៏មានអារម្មណ៍ជាមហគ្គតៈ ។ ក្នុងវេលាដែលតាមរឭកដល់មគ្គដែលខ្លួនឯង ឬបុគ្គលដទៃចម្រើនហើយ និងផលដែលខ្លួន ឬបុគ្គលដទៃធ្វើឲ្យជាក់ច្បាស់ហើយក្នុងអតីត ក៏មានអារម្មណ៍ជាអប្បមាណ ។ មានអារម្មណ៍ជាអប្បមាណដោយការពិចារណាមគ្គ ផល និព្វាន ដោយអំណាចការតាមរឭកដល់ព្រះពុទ្ធដែលមានវដ្ដៈដាច់ហើយថា ព្រះពុទ្ធទាំងឡាយ ក្នុងអតីតចម្រើនមគ្គហើយ ធ្វើផលឲ្យជាក់ច្បាស់ហើយ បរិនិព្វានហើយ ដោយនិព្វានធាតុ ។ មានអារម្មណ៍ជានវត្តព្វៈ ក្នុងវេលាដែលតាមរឭកនាម គោត្ត និងនិមិត្តនៃបឋវីកសិណជាដើម ដោយន័យជាដើមថា ក្នុងអតីតកាល ព្រះមានព្រះភាគព្រះនាមថា វិបស្សីមានហើយ ព្រះនគររបស់ព្រះអង្គមានឈ្មោះថា ពន្ធុមតី ព្រះរាជបិតាមាននាមថា ពន្ធុមរាជ ព្រះរាជមាតាមាននាមថា ពន្ធុមតី ។

សូម្បីក្នុងចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ក៏មានន័យនេះដូចគ្នា ។ មែនពិត ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណនោះ មានអារម្មណ៍ជាបរិត្តៈ ក្នុងវេលាដែលដឹងថា បុគ្គលនេះក្នុងអនាគតកាលនឹងកើតក្នុងកាមាវចរភូមិ មានអារម្មណ៍ជាមហគ្គតៈក្នុងវេលាដែលដឹងថា សត្វ

នេះ ក្នុងអនាគតកាលនឹងកើតក្នុងរូបាវចរភូមិ ឬអរូបាវចរភូមិ មានអារម្មណ៍ជាអប្បមាណ ក្នុងវេលាដែលដឹងដល់បុគ្គលដែលកាត់វដ្តៈថា ក្នុងអនាគតកាលបុគ្គលនេះនឹងចម្រើនមគ្គ និងធ្វើផលឲ្យជាក់ច្បាស់ នឹងបរិនិព្វានដោយនិព្វានធាតុ និងមានអារម្មណ៍ជានវត្តព្វៈ ក្នុងវេលាដែលដឹងឈ្មោះ និងគោត្តដោយន័យជាដើមថា ក្នុងអនាគតកាលព្រះមានព្រះភាគព្រះនាមថា មេត្តេយ្យទ្រង់នឹងឧប្បត្តិកឡើង ព្រាហ្មណ៍ឈ្មោះថា សុព្រហ្មនឹងជាព្រះពុទ្ធបិតា ព្រាហ្មណីឈ្មោះថា ព្រហ្មវតី នឹងជាព្រះពុទ្ធមាតា ។

ចំណែកចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអរូបាវចរ និងចតុត្ថជ្ឈានក្នុងការអស់អាសវៈទាំងឡាយ ខ្ញុំនឹងពោលក្នុងទីដែលមានព្រះបាលីប្រាកដហើយនុ៎ះឯង ។ អហេតុកកិរិយាមនោវិញ្ញាណធាតុ ដែលសហគតដោយឧបេក្ខា ជាបុរេចារិកនៃកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្តទាំងអស់នេះ ។ គប្បីជ្រាបប្រភេទនៃអារម្មណ៍ របស់អហេតុកកិរិយាមនោវិញ្ញាណធាតុ ដែលសហគតដោយឧបេក្ខានោះ ដោយន័យដែលពោលទុកក្នុងកុសលចិត្ត អកុសលចិត្ត និងកិរិយាចិត្តទាំងនោះនុ៎ះឯង ។ តែក្នុងវេលាប្រព្រឹត្តទៅ ដោយអំណាចវោដ្ឋព្វន ក្នុងទ្វារ ៥ រមែងមានអារម្មណ៍ជាបរិត្តៈតែម្យ៉ាងប៉ុណ្ណោះ ។ ឈាន ៣ ឬឈាន ៤ ដែលជារូបាវចរជាដើម មានអារម្មណ៍ជានវត្តព្វៈ ព្រោះប្រារព្ធនវត្តព្វធម៌ប្រព្រឹត្តទៅ ដោយភាពជាបរិត្តធម៌ជាដើម ។ ដ្បិតថា ក្នុងឈាន ៣ ឬឈាន ៤ ដែលជារូបាវចរជាដើមទាំងនេះ រូបាវចរឈានទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងបឋវីកសិណជាដើម អាកាសានញ្ចាយត-

នជ្ឈាន ក៏ប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណហើយ អាកិញ្ចញ្ញាយតនជ្ឈាន ក៏ប្រព្រឹត្តទៅក្នុងការប្រាសចាកវិញ្ញាណនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងមគ្គារម្មណត្តិកៈ ដូចតទៅនេះថា

ចិត្តុប្បាទដែលជាញាណសម្បយុត្ត ៨ ដួង ដែលត្រាស់ទុកក្នុងខាងដើម ជាពួកធម៌ មានមគ្គជាអារម្មណ៍ ក្នុងវេលាដែលព្រះសេក្ខៈបុគ្គល និងព្រះអសេក្ខបុគ្គល ពិចារណាមគ្គដែលខ្លួនចាក់ធ្លុះហើយ តែមិនមែនមានមគ្គហេតុ ព្រោះមិនកើតព្រមជាមួយមគ្គ ដែលឈ្មោះថា **មគ្គាធិបតិនោ** ដោយអំណាចអារម្មណាធិបតិ ក្នុងវេលាពិចារណា ធ្វើមគ្គដែលខ្លួនចាក់ធ្លុះហើយ ឲ្យជាធំ ដែលឈ្មោះថា **ន វត្តព្វា មគ្គារម្មណាតិបិ មគ្គាធិបតិនោតិបិ** ក្នុងវេលាដែលធ្វើធម៌ដទៃជាអារម្មណ៍ ។ អរិយមគ្គ ៤ ជាធម៌មានហេតុ ជាធម៌មានហេតុ គឺមគ្គដោយចំណែកមួយ ព្រោះមានហេតុ ពោលគឺមគ្គ ឬហេតុដែលសម្បយុត្តដោយមគ្គ តែក្នុងវេលាដែលចម្រើនមគ្គ ធ្វើវិរិយៈឬវីមំសាឲ្យជាធំ អរិយមគ្គ ដែលមានអធិបតីធម៌កើតព្រមគ្នា មានមគ្គជាអធិបតីក៏មាន ក្នុងវេលាដែលធ្វើឆន្ទៈ ឬចិត្តៈយ៉ាងណាមួយ ឲ្យជាធំ គប្បីពោលថា មានមគ្គជាអធិបតីមិនបានក៏មាន ដូច្នេះ ។

ក្នុងរូបាវចរចតុត្ថជ្ឈាន ១២ ចតុត្ថជ្ឈាន ៩ មានចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួងជាដើម មិនមានមគ្គជាអារម្មណ៍ មិនមានហេតុ គឺមគ្គ មិនមានមគ្គជាអធិបតី ។ ចំណែកចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ បុព្វេនិវាសញ្ញាណ និងអនាគតំសញ្ញាណ ក្នុងវេលាដែលដឹងមគ្គ-

ចិត្តរបស់ព្រះអរិយៈទាំងឡាយមានមគ្គជាអារម្មណ៍ តែមិនមានហេតុ គឺមគ្គ ព្រោះមិនកើតព្រមជាមួយនឹងមគ្គ ។ មិនមានមគ្គជាអធិបតី ព្រោះមិនធ្វើមគ្គឲ្យជាធំប្រព្រឹត្តទៅ ។

សួរថា ព្រោះហេតុអ្វីទើបចតុត្ថជ្ឈានទាំង ៣ នេះ មិនធ្វើមគ្គឲ្យជាធំ ។ ឆ្លើយថា ព្រោះខ្លួនជាមហគ្គតៈ ។ ដូចសត្វលោកទាំងអស់ ធ្វើព្រះរាជាឲ្យជាទីគោរព ចំណែកព្រះមាតានិងព្រះបិតាទ្រង់មិនធ្វើសេចក្តីគោរព ព្រោះព្រះមាតាបិតាទាំងនោះឃើញព្រះរាជាហើយ ក៏មិនក្រោកចាកអាសនៈ មិនសំពះជាដើម រមែងត្រាស់ហៅដោយន័យដែលត្រាស់ហៅក្នុងវេលា ដែលទ្រង់ជាយុវរាជនុ៎ះឯងយ៉ាងណា សូម្បីចតុត្ថជ្ឈានទាំង ៣ ដែលប្រព្រឹត្តទៅក្នុងចេ-តោបរិយញ្ញាណជាដើមទាំងនេះ ក៏យ៉ាងនោះ រមែងមិនធ្វើមគ្គឲ្យជាធំ ព្រោះខ្លួនជាមហគ្គតៈ ។

សូម្បីអហេតុកកិរិយាមនោវិញ្ញាណធាតុ ( មនោទ្វារាវជ្ជនចិត្ត ) ក៏ជាធម៌មានមគ្គជាអារម្មណ៍ ព្រោះជាបុរេចារិករបស់បច្ចវេក្ខណៈ ក្នុងវេលាពិ-ចារណា មគ្គរបស់ព្រះអរិយៈទាំងឡាយ តែមិនមានហេតុ គឺមគ្គ ព្រោះមិនកើតព្រមជាមួយនឹងមគ្គ ។ មិនមានមគ្គជាអធិបតី ព្រោះមិនធ្វើមគ្គនោះឲ្យជាធំប្រព្រឹត្តទៅ ។

សួរថា ព្រោះហេតុអ្វីទើបចិត្តនេះមិនធ្វើមគ្គឲ្យជាធំ ។ ឆ្លើយថា ព្រោះខ្លួនជាអហេតុកៈ ជាសភាវៈថោកទាប ជាសភាវៈល្ងង់ ។ ដូចសត្វលោកទាំងពួងរមែងគោរពព្រះរាជា តែរាជបរិវារមានអ្នកបម្រើដែលជាមនុស្សគម

មនុស្សតៀជាដើម មិនធ្វើសេចក្ដីគោរពក្រៃលែងក្នុងព្រះរាជា ដូចបុគ្គលជាបណ្ឌិត ( ធ្វើសេចក្ដីគោរពក្រៃលែង ) ព្រោះភាពដែលខ្លួនជាមនុស្សល្ងង់ យ៉ាងណា ចិត្តនេះក៏យ៉ាងនោះដូចគ្នា រមែងមិនធ្វើមគ្គឲ្យជាធំ ព្រោះខ្លួនជាអហេតុកៈ ជាសភាវៈថោកទាប ជាសភាវៈល្ងង់ ។

កុសលចិត្តដែលជាញាណវិប្បយុត្តជាដើម រមែងមិនបានភាវៈ មានមគ្គជាអារម្មណ៍ជាដើម ព្រោះមិនមានញាណ និងព្រោះមានអារម្មណ៍ជាលោកិយធម៌ គប្បីជ្រាបថា មានអារម្មណ៍ជានវត្តព្វៈតែម្យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអតីតារម្មណត្តិកៈ ដូចតទៅនេះថា

ធម៌គឺ វិញ្ញាណញ្ចាយតនៈនិងនេវសញ្ញានាសញ្ញាយតនៈ ជាពួកធម៌មានអារម្មណ៍ជាអតីតដោយចំណែកមួយប៉ុណ្ណោះ ព្រោះប្រារព្ធសមាបត្តិដែលជាអតីតខាងដើមប្រព្រឹត្តទៅ ។

បទថា **និយោគា អនាគតារម្មណា នត្ថិ** សេចក្ដីថា ឈ្មោះថា ចិត្តដែលមានអារម្មណ៍ចំពោះតែម្យ៉ាង ដោយពិតប្រាកដមិនមាន ។ សួរថា ចិត្តដែលជាអនាគតំសញ្ញាណមានអារម្មណ៍ជាអនាគតដោយចំណែកមួយ សូម្បីចិត្តដែលជាចេតោបរិយញ្ញាណក៏ប្រារព្ធអនាគតប្រព្រឹត្តទៅ មិនមែនឬ ឆ្លើយថា មិនមែនមិនប្រារព្ធអនាគតប្រព្រឹត្តទៅទេ តែចិត្តដែលជាអនាគតំសញ្ញាណនិងចេតោបរិយញ្ញាណនេះ ដែលមានអារម្មណ៍ចំពោះតែមួយ រមែងមិនមាន មានតែអារម្មណ៍ដែលលាយឡំជាមួយមហគ្គតចិត្តដទៃៗ ព្រោះទ្រង់សង្គ្រោះទុកដោយអរូបាវចរចតុត្ថជ្ឈាន ដោយហេតុនោះ ទើបត្រាស់ថា **និយោគា**

**អនាគតារម្មណា នត្ថិ** ដូច្នេះ ។

ទ្វិបញ្ចវិញ្ញាណនិងមនោធាតុ ៣ ឈ្មោះថា ពួកធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះប្រព្រឹត្តទៅក្នុងរូបារម្មណ៍ជាដើមដែលជាបច្ចុប្បន្ន ។

ក្នុងបទថា **ឧស ចិត្តុប្បាទា** នេះ មានអធិប្បាយថា សហេតុកវិបាកចិត្ត ៨ ដួង ឈ្មោះថា មានអារម្មណ៍ជាអតីតប៉ុណ្ណោះ ក្នុងការប្រារព្ធកម្ម ឬកម្មនិមិត្តប្រព្រឹត្តទៅ ក្នុងវេលាចាប់បដិសន្ធិរបស់ពួកទេវតានិងមនុស្ស ។ សូម្បីក្នុងវេលាដែលជាភវង្គនិងចុតិ ក៏មានន័យនេះឯង ។

តែក្នុងវេលាដែលចិត្តទាំងនេះប្រារព្ធគតិនិមិត្តចាប់បដិសន្ធិ និងក្នុងវេលាដែលជាភវង្គ តអំពីបដិសន្ធិ ចិត្តនោះមកជាធម៌មានអារម្មណ៍បច្ចុប្បន្ន ក្នុងខណៈដែលប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ដោយអំណាចជា**តទារម្មណៈ**ក៏មានអារម្មណ៍ជាបច្ចុប្បន្នដូចគ្នា តែព្រោះទទួលអារម្មណ៍តអំពីជវនដែលមានអារម្មណ៍ជាអតីត អនាគត និងបច្ចុប្បន្នក្នុងមនោទ្វារប្រព្រឹត្តទៅ ទើបមានអារម្មណ៍ជាអតីត អនាគត និងបច្ចុប្បន្ន ។ សូម្បីក្នុងមនោវិញ្ញាណធាតុដែលសហគតដោយឧបេក្ខាខាងអហេតុកៈកុសលវិបាក ក៏មានន័យនេះឯង ។ ក្នុងអធិការនេះ មានសេចក្ដីផ្សេងគ្នាយ៉ាងនេះគឺ មនោវិញ្ញាណធាតុដែលសហគតដោយឧបេក្ខាខាងអហេតុកកុសលវិបាកនោះ ជាបដិសន្ធិរបស់ជនទាំងឡាយអ្នកខ្វាក់ខ្វែកអំពីកំណើតជាដើមក្នុងពួកមនុស្សតែម្យ៉ាង និងមានអារម្មណ៍ជាបច្ចុប្បន្ន ដោយអំណាចជាសន្តីរណៈក្នុងបញ្ចទ្វារ ។ ចំណែកមនោវិញ្ញាណធាតុដែលសហគតដោយសោមនស្សខាងអហេតុកៈកុសលវិបាក ជាធម៌មាន

អារម្មណ៍ជាបច្ចុប្បន្នដោយអំណាចជាសន្តីរណៈ និងជាតទារម្មណៈក្នុងបញ្ច-ទ្វារ ។ គប្បីជ្រាបថា មានអារម្មណ៍ជាអតីត អនាគត និងបច្ចុប្បន្ន ដោយអំណាចតទារម្មណៈក្នុងមនោទ្វារ ដូចមនោវិញ្ញាណធាតុ ដែលជាសហេតុក-វិបាក ។

ចំណែកមនោវិញ្ញាណធាតុដែលជាអហេតុកៈអកុសលវិបាក មានគតិដូចមនោវិញ្ញាណធាតុ ដែលសហគតដោយឧបេក្ខា ខាងអហេតុកកុសលវិបាកនុ៎ះឯង ។ តែក្នុងទីនេះ មានសេចក្តីប្លែកគ្នាដូច្នេះថា មនោវិញ្ញាណធាតុខាងអហេតុកៈអកុសលវិបាកនោះ រមែងប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ ភវង្គ និងចុតិរបស់ពួកសត្វដែលកើតក្នុងអបាយភូមិទាំងឡាយ តែម្យ៉ាង ។ មនោ-វិញ្ញាណធាតុដែលសហគតដោយសោមនស្សខាងអហេតុកកិរិយា កាលធ្វើអាការត្រេកអរ ក្នុងបញ្ចទ្វាររបស់ព្រះខីណាស្រពទាំងឡាយ ក៏ជាធម៌មានអារម្មណ៍បច្ចុប្បន្នក្នុងវេលាប្រារព្ធធម៌មានអតីតជាដើម ក្នុងមនោទ្វារប្រព្រឹត្តទៅដោយអំណាចជាហសិតុប្បាទៈ ក៏ជាធម៌មានអារម្មណ៍ជាអតីត អនាគត និងបច្ចុប្បន្ន ។

ក្នុងបទថា **កាមាវចរកុសលំ** ជាដើម មានអធិប្បាយថា ពោលដោយកុសលមុន ចិត្តុប្បាទដែលជាញាណសម្បយុត្ត ៤ ដួង រមែងជាធម៌មានអារម្មណ៍ជាអតីតៈ អនាគត និងបច្ចុប្បន្ន ដល់ព្រះសេក្ខៈនិងបុថុជ្ជនដែលពិ-ចារណាខន្ធ ធាតុ និងអាយតនៈ មានអតីតជាដើម ។ ក្នុងខណៈពិចារណាបញ្ញត្តិនិងព្រះនិព្វានជានវត្តព្វារម្មណ៍ គឺជាធម៌មានអារម្មណ៍មិនគប្បីពោល ។

សូម្បីក្នុងចិត្តុប្បាទដែលជាញាណវិប្បយុត្ត ក៏មានន័យនេះឯង ។ ត្រឹមតែការពិចារណាមគ្គ ផល និងនិព្វានដោយចិត្តុប្បាទ ដែលជាញាណវិប្បយុត្តទាំងនោះ មិនមាន នេះប៉ុណ្ណោះជាសេចក្ដីផ្សេងគ្នាក្នុងអធិការនេះ ។

ពោលដោយអកុសលចិត្តុប្បាទដែលសម្បយុត្តដោយទិដ្ឋិ ៤ ដួង ជាធម៌មានអារម្មណ៍ជាអតីត ជាដើម ក្នុងវេលាដែលត្រេកអររីករាយក្នុងការយល់ខុសនូវខន្ធ ធាតុ និងអាយតនៈ មានខន្ធដែលជាអតីតជាដើម ជាធម៌មានអារម្មណ៍ជានវត្តព្វៈដល់បុគ្គលអ្នកត្រេកអររីករាយប្រារព្ធបញ្ញត្តិ អ្នកប្រកាន់ខុស ប្រកាន់មាំថាជាសត្វ ជាតួខ្លួន ។ សូម្បីក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្ត ក៏មានន័យនេះដូចគ្នា ។ ត្រឹមតែការប្រកាន់ខុស ប្រកាន់មាំដោយទិដ្ឋិទាំងនោះមិនមាន ។ ចិត្តុប្បាទដែលសម្បយុត្តដោយបដិឃៈ ២ ដួង រមែងជាធម៌មានអារម្មណ៍ជាអតីតជាដើមដល់បុគ្គលអ្នកទោមនស្សប្រារព្ធធម៌ មានអតីតក្ខន្ធជាដើម ជាធម៌មានអារម្មណ៍ ជានវត្តព្វៈ ដល់បុគ្គលដែលទោមនស្សប្រារព្ធបញ្ញត្តិ ។ ចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆានិងឧទ្ធច្ចៈជាធម៌មានអារម្មណ៍ជាអតីតៈ បច្ចុប្បន្ន នវត្តព្វារម្មណ៍និងនវត្តព្វៈ ក្នុងខណៈប្រព្រឹត្តទៅក្នុងធម៌ទាំងឡាយនោះឯង ដោយភាពជាធម៌ដែលសម្រេចចិត្តមិនបាន និងដោយភាពជាធម៌ដែលរាយមាយ ។

ពោលដោយកិរិយា សហេតុកចិត្តុប្បាទ ៨ មានគតិដូចកុសលចិត្តុប្បាទនុ៎ះឯង ។ អហេតុកកិរិយាមនោវិញ្ញាណធាតុដែលសហគតដោយឧបេក្ខា ជាធម៌មានអារម្មណ៍បច្ចុប្បន្នប៉ុណ្ណោះ ក្នុងខណៈប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ដោយ

អំណាចជាវោហារ៍ ជាធម៌មានអារម្មណ៍ជាអតីតៈ អនាគត បច្ចុប្បន្ន និង នវត្តព្វៈ ក្នុងវេលាដែលចិត្តមានធម៌ជាអតីតៈ អនាគត និងបច្ចុប្បន្នជាអារម្មណ៍ និងមានបញ្ញត្តិជាអារម្មណ៍ជាបុរេចារិកក្នុងមនោទ្វារ ។

ក្នុងចតុត្ថជ្ឈានដែលជារូបាវចរ មានប្រភេទដូចដែលពោលហើយ ចតុត្ថជ្ឈានទាំង ៥ នេះ គឺចតុត្ថជ្ឈានដែលជាបាទនៃធម៌ទាំងពួង ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអាកាសកសិណ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអាលោកកសិណ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងព្រហ្មវិហារ ១ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអានាបានសមាធិ ១ ជានវត្តព្វារម្មណ៍ទាំងអស់ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធជាធម៌មានអារម្មណ៍ជាអតីត ព្រោះយោគាវចរបុគ្គលដែលញ៉ាំងចិត្ត ឲ្យផ្លាស់ប្តូរទៅតាមអំណាចនៃកាយ ប្រារព្ធឈានចិត្តក្នុងអតីតជាបាទ ឲ្យប្រព្រឹត្តទៅ តែជាធម៌មានអារម្មណ៍ជាអនាគតដល់យោគាវចរបុគ្គលដែលអធិដ្ឋានធម៌ដែលជាអនាគត ដូចព្រះមហាកស្សបត្ថេរជាដើម អធិដ្ឋានក្នុងគ្រាបញ្ចុះ ( កប់ ) ព្រះបរមសារីរិកធាតុ ។

បានឮថា ព្រះមហាកស្សបត្ថេរ កាលបញ្ចុះព្រះបរមសារីរិកធាតុ បានអធិដ្ឋានថា ក្នុងអនាគតកាល អស់កាល ២១៨ ឆ្នាំ សូមក្លិនក្រអូបទាំងនេះកុំវិនាសទៅ ផ្កាទាំងឡាយកុំស្វិតស្រពោន ប្រទីបទាំងឡាយកុំរលត់ ។ វត្ថុទាំងអស់បានដូចការអធិដ្ឋាននុ៎ះឯង ។ ព្រះអស្សគុត្តត្ថេរ ឃើញពួកភិក្ខុដែលឆាន់កត្តាហារក្រៀមក្នុងរោងឆាន់ ទើបអធិដ្ឋានថា សូមឲ្យថ្លុកទឹកជារសទឹកដោះជូរ ក្នុងវេលាបុរេភត្តរាល់ៗថ្ងៃ ដូច្នេះ ទឹកដែលដួសមកក្នុងវេលាបុរេ-

កត្ត ទើបមានរសជាទឹកដោះជូរ ក្នុងវេលាបច្ឆាភត្តទឹកនោះក៏ជាទឹកធម្មតាដូចដើមនុ៎ះឯង តែក្នុងវេលាដែលព្រះយោគាវចរបុគ្គលធ្វើកាយឲ្យអាស្រ័យចិត្តហើយទៅដោយកាយ ដែលមើលមិនឃើញ ឬថាក្នុងវេលាធ្វើបាដិហារ្យដទៃ ចតុត្ថជ្ឈាន ក៏ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះប្រារព្ធកាយប្រព្រឹត្តទៅនោះឯង ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វសោតជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ព្រោះប្រារព្ធសំឡេងដែលមាននៅនុ៎ះឯង ប្រព្រឹត្តទៅ ។ ចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ រមែងជាធម៌មានអារម្មណ៍ជាអតីត ដល់បុគ្គលដែលដឹងចិត្តរបស់អ្នកដទៃ ក្នុងអតីតខាងក្នុង ៧ ថ្ងៃ និងជាធម៌មានអារម្មណ៍ជាអនាគត ដល់បុគ្គលដែលដឹងចិត្តរបស់អ្នកដទៃ ក្នុងអនាគតខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ។ តែក្នុងវេលាលើស ៧ ថ្ងៃហើយ ក៏មិនអាចដឹងចិត្តនោះបាន ព្រោះថា នោះជាវិស័យរបស់អតីតំសញ្ញាណ និងអនាគតំសញ្ញាណ ។ តែក្នុងវេលាដែលបុគ្គលនោះដឹងចិត្តបច្ចុប្បន្នរបស់អ្នកដទៃ ក៏ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ។

ឈ្មោះថា បច្ចុប្បន្ន នេះមាន ៣ យ៉ាងគឺ ខណបច្ចុប្បន្ន សន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ន ។ បណ្ដាបច្ចុប្បន្នទាំង ៣ នោះ បច្ចុប្បន្នដែលដល់ឧប្បាទក្ខណៈ ឋិតិខណៈនិងភង្គក្ខណៈ ឈ្មោះថា ខណបច្ចុប្បន្ន ។ បច្ចុប្បន្នដែលទាក់ទងដោយវារៈ ប្រព្រឹត្តទៅជាប់តគ្នាអស់មួយវារៈ ឬពីរវារៈ ឈ្មោះថា សន្តតិបច្ចុប្បន្ន ។ ក្នុងសន្តតិបច្ចុប្បន្ននោះកាលបុគ្គលអង្គុយក្នុងទីងងឹតហើយ

ចេញមកកាន់ទីភ្លឺ អារម្មណ៍មិនទាន់ប្រាកដ អារម្មណ៍នោះប្រាកដដរាបណា ក្នុងចន្លោះនេះ គប្បីជ្រាបវារៈដែលជាប់គ្នាអស់មួយ ឬពីរវារៈ កាលបុគ្គលត្រាច់ទៅក្នុងទីវាលហើយ ចូលទៅកាន់បន្ទប់តូច ( បន្ទប់ងងឹត ) រូបារម្មណ៍ក៏នៅមិនទាន់ប្រាកដភ្លាមទេ រូបារម្មណ៍នោះនៅមិនទាន់ប្រាកដដរាបណា ខាងក្នុងរវាងនេះ ក៏គប្បីជ្រាបវារៈការបន្តអស់មួយវារៈ ឬពីរវារៈ ម្យ៉ាងទៀត កាលបុគ្គលឈរនៅក្នុងទីឆ្ងាយ សូម្បីឃើញការកម្រើកដៃរបស់ជាងជ្រលក់ និងការកម្រើកដៃវាយរគាំង វាយស្គរក៏នៅមិនទាន់បានឮសំឡេងភ្លាមឡើយ បុគ្គលបានឮសំឡេងនោះដរាបណា ក្នុងចន្លោះនេះគប្បីជ្រាបវារៈការបន្តមួយ ឬពីរវារៈ ។ ព្រះមជ្ឈិមភាណកាចារ្យពោលទុកយ៉ាងនេះ ។

ចំណែកព្រះសំយុត្តភាណកាចារ្យ ពោលដល់សន្តតិ មាន ២ យ៉ាងគឺ រូបសន្តតិនិងអរូបសន្តតិហើយពោលថា កាលបុគ្គលដើរលុយទឹកទៅ ស្នាមក្នុងទឹកដែលត្រូវជាន់មិនទាន់ជិតដរាបណា កាលបុគ្គលមកអំពីចម្ងាយ កម្តៅក្នុងកាយមិនទាន់ស្ងប់ដរាបណា នេះឈ្មោះថា រូបសន្តតិ កាលបុគ្គលមកអំពីថ្ងៃក្តៅចូលទៅកាន់បន្ទប់ ងងឹតនៅមិនទាន់អស់ដរាបណា កាលបុគ្គលមនសិការកម្មដ្ឋានខាងក្នុងបន្ទប់បើកបង្អួចក្រឡេកមើលក្នុងវេលាថ្ងៃ ការស្រវាំងនៃភ្នែក នៅមិនទាន់ស្ងប់ដរាបណា នេះក៏ឈ្មោះថា រូបសន្តតិ វារៈនៃជវន ២-៣ វារៈ ឈ្មោះថា អរូបសន្តតិ ហើយពោលថា សន្តតិទាំងពីរនេះឈ្មោះថា សន្តតិបច្ចុប្បន្ន ។

ចំណែកបច្ចុប្បន្ន ដែលកំណត់ដោយភពមួយ ដែលព្រះមហាកច្ចានត្ថេរ

សំដៅយកពោលទុកក្នុងកទ្ទេកវត្ថុសូត្រថា ម្នាលអាវុសោ ចិត្តនិងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគ ក្នុងចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលរមែងត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចិត្តនិងធម្មារម្មណ៍ជាបច្ចុប្បន្ននោះ ឈ្មោះថា រសេមរសាមក្នុងពួកធម៌ ជាបច្ចុប្បន្ន ដូច្នេះ ឈ្មោះថា អទ្ធាបច្ចុប្បន្ន ។ ក្នុងបច្ចុប្បន្នដែលជាសន្តតិនិងអទ្ធាទាំងនេះ សន្តតិបច្ចុប្បន្ន មកក្នុងអដ្ឋកថាទាំងឡាយ អទ្ធាបច្ចុប្បន្ន មកហើយក្នុងព្រះសូត្រ ។ ក្នុងខណបច្ចុប្បន្នជាដើមនោះ កេចិអាចារ្យទាំងឡាយ ពោលថា ចិត្តដែលជាខណបច្ចុប្បន្ន រមែងជាអារម្មណ៍របស់ចេតោបរិយញ្ញាណ ព្រោះហេតុអ្វី ព្រោះចិត្តរបស់លោកអ្នកមានឫទ្ធិ និងរបស់បុគ្គលដទៃកើតឡើងក្នុងខណៈជាមួយគ្នា ។ សេចក្តីឧបមា របស់កេចិអាចារ្យទាំងឡាយនោះ មានដូច្នេះថា ក្នុងបាច់ផ្កាដែលបុគ្គលបោះទៅឰដ៏អាកាស ផ្កាមួយទង រមែងពាក់ទងដោយទងរបស់ផ្កាមួយពិតប្រាកដយ៉ាងណា កាលព្រះយោគាវចរពិចារណាចិត្តរបស់មហាជនដោយអំណាចជាគំនរថា អញស្គាល់ចិត្តរបស់ជនដទៃ ដូច្នេះ ក៏នឹងដឹងចិត្តរបស់បុគ្គលមួយ ដោយចិត្តមួយដូងក្នុងឧប្បាទក្ខណៈ ឬ ឋិតិខណៈ ឬភង្គក្ខណៈបានដោយពិតយ៉ាងនោះ ពាក្យរបស់ពួកកេចិអាចារ្យនោះ លោកបដិសេធទុកក្នុងអដ្ឋកថាទាំងឡាយថា មិនត្រឹមត្រូវ ព្រោះចិត្តពីរដួងដែលជាហេតុឲ្យបុគ្គលរឭកសូម្បីមួយរយឆ្នាំ សូម្បីមួយពាន់ឆ្នាំ រឭកបាន និងដឹងបាន មិនមានឋានៈរួមគ្នា និងព្រោះទោសដែលដល់គាវៈដែលអាវជ្ជន-

ចិត្ត និងជវនចិត្តមានអារម្មណ៍ផ្សេងគ្នាក្នុងឋានៈដែលមិនគួរប្រាថ្នា ។ ចំណែក សន្តតិបច្ចុប្បន្ននិងអទ្ធាបច្ចុប្បន្ន គប្បីជ្រាបថា ជាអារម្មណ៍ ( របស់ចេតោ-បរិយញ្ញាណ ) ។

បណ្តាសន្តតិបច្ចុប្បន្ននិងអទ្ធាបច្ចុប្បន្នទាំងនោះ ពាក្យណាដែលពោលទុកក្នុងអដ្ឋកថាថា ចិត្តណារបស់បុគ្គលដទៃ ក្នុងវេលាដែលផ្លាស់ប្តូរទៅ ២ ឬ ៣ ជវនវិថី ដោយអំណាចអតីតនិងអនាគត តអំពីជវនវិថីបច្ចុប្បន្ន ចិត្តទាំងអស់នោះ ឈ្មោះថា សន្តតិបច្ចុប្បន្ន ចំណែកអទ្ធាបច្ចុប្បន្ន គប្បីសម្តែងដោយវារៈនៃជវន ពាក្យនោះលោកពោលទុកល្អហើយ ។

ក្នុងពាក្យរបស់ព្រះអដ្ឋកថានោះ មានសម្តែងទុកដូច្នេះ លោកអ្នកមានឫទ្ធិប្រាថ្នានឹងដឹងចិត្តរបស់បុគ្គលដទៃ រមែងនឹកដល់ ។ ការនឹកដល់ រមែងធ្វើខណបច្ចុប្បន្ន ឲ្យជាអារម្មណ៍ ហើយក៏រលត់ទៅព្រមជាមួយនឹងអារម្មណ៍នោះៗឯង តអំពីនោះ ក៏ជាជវន ៤-៥ ជវន មានឥទ្ធិចិត្តជាជួងចុងក្រោយ ចិត្តដ៏សេសជាកាមាវចរ បណ្តាចិត្តទាំងអស់នោះ ចិត្តដែលរលត់ហើយនោះៗឯង រមែងជាអារម្មណ៍ ចិត្តទាំងនោះមិនមែនមានអារម្មណ៍ផ្សេងគ្នាទេ រមែងមានអារម្មណ៍ដូចគ្នាទុំះឯង ព្រោះចិត្តទាំងនោះមានអារម្មណ៍បច្ចុប្បន្ន ដោយអំណាចអទ្ធាបច្ចុប្បន្ន កាលចិត្តមានអារម្មណ៍ជាមួយគ្នា ឥទ្ធិចិត្តប៉ុណ្ណោះរមែងដឹងចិត្តរបស់បុគ្គលដទៃ ចិត្តដទៃដឹងមិនបានឡើយ ដូចចក្ខុវិញ្ញាណប៉ុណ្ណោះរមែងឃើញរូបក្នុងចក្ខុទ្វារ វិញ្ញាណក្រៅនេះឃើញមិនបានឡើយ ។ ព្រោះហេតុនោះ ទើបឥទ្ធិចិត្តនេះជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអំណាចនៃ

សន្តតិបច្ចុប្បន្ន និងអទ្ធាបច្ចុប្បន្ន ។

ម្យ៉ាងទៀត ព្រោះសន្តតិបច្ចុប្បន្នរមែងប្រព្រឹត្តទៅក្នុងអទ្ធាបច្ចុប្បន្នទាំងឯង ហេតុនោះ ឥទ្ធិចិត្តនេះ បណ្ឌិតគប្បីជ្រាបថា ជាធម៌មានអារម្មណ៍ជាបច្ចុប្បន្ន ដោយអំណាចអទ្ធាបច្ចុប្បន្ន ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ មានអារម្មណ៍ជានវត្តព្វៈ ក្នុងការតាមរឭកដល់ឈ្មោះ និងគោត្ត និងក្នុងការពិចារណាដល់និព្វាន និង និមិត្ត មានអារម្មណ៍ជាអតីតៈតែម្យ៉ាងក្នុងកាលដ៏សេស ។ សូម្បីចតុត្ថជ្ឈាន ដែលប្រព្រឹត្តទៅក្នុងយថាកម្មូបគញ្ញាណ ក៏មានអារម្មណ៍ជាអតីតៈដូចគ្នា ។

បណ្តាចតុត្ថជ្ឈានទាំងនោះ គប្បីជ្រាបការផ្សេងគ្នាដូច្នេះគឺ បុព្វេនិវា-សញ្ញាណ និងចេតោបរិយញ្ញាណ ជាធម៌មានអារម្មណ៍ជាអតីតក៏ពិត តែក្នុង ញាណទាំងនោះ បុព្វេនិវាសញ្ញាណ ដែលឈ្មោះថា មិនមានខន្ធក្នុងអតីតៈ និងមិនមានអ្វីដែលទាក់ទងដោយខន្ធជាអារម្មណ៍ មិនមាន ព្រោះបុព្វេនិវា-សញ្ញាណនោះ មានគតិស្មើដោយសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយដែលជា ខន្ធក្នុងអតីត និងដែលទាក់ទងដោយខន្ធ ។ ចំណែកចេតោបរិយញ្ញាណដែល មានចិត្តកន្លងទៅខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ជាអារម្មណ៍ ព្រោះថាចេតោបរិ-យញ្ញាណនោះ រមែងមិនដឹងខន្ធដទៃ ឬធម៌ដែលទាក់ទងដោយខន្ធ តែដោយ អមត្រាស់ថា ចេតោបរិយញ្ញាណ មានមគ្គជាអារម្មណ៍ ព្រោះមានចិត្តដែល សម្បយុត្តដោយមគ្គជាអារម្មណ៍ ។ ចំណែកយថាកម្មូបគញ្ញាណមានត្រឹមតែ ចេតនាក្នុងអតីតប៉ុណ្ណោះជាអារម្មណ៍ ។ ក្នុងឋានៈនេះគប្បីជ្រាបន័យអដ្ឋកថា

ដូចតទៅនេះថា ព្រោះត្រាស់ទុកក្នុងបដ្ឋានថា ពួកកុសលក្ខន្ធ ជាបច្ច័យនៃឥទ្ធិវិធញ្ញាណ ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណ យថាកម្មុបគញ្ញាណនិងអនាគតំសញ្ញាណ ដោយអារម្មណប្បច្ច័យ ដូច្នេះ ។ ហេតុនោះ ខន្ធសូម្បីទាំង ៤ ទើបជាអារម្មណ៍របស់ចេតោបរិយញ្ញាណនិងយថាកម្មូបគញ្ញាណ ។ ក្នុងញាណទាំង ២ នោះ យថាកម្មូបគញ្ញាណ ក៏មានកុសលនិងអកុសលទុំះឯងជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វចក្ខុ ឈ្មោះថា មានអារម្មណ៍ជាបច្ចុប្បន្នប៉ុណ្ណោះ ព្រោះពណ៌ ( វណ្ណៈ ) ដែលមានជាអារម្មណ៍ ។ ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ មានអារម្មណ៍ជាអនាគតប៉ុណ្ណោះ ព្រោះថា អនាគតំសញ្ញាណនោះ មានគតិដូចសព្វញ្ញុតញ្ញាណ ក្នុងធម៌ទាំងឡាយដែលជាខន្ធក្នុងអនាគត និងដែលទាក់ទងដោយខន្ធដូចបុព្វេនិវាសញ្ញាណ ។ បណ្ដាចតុត្ថជ្ឈានទាំងនោះ ចេតោបរិយញ្ញាណ ទោះមានអារម្មណ៍ជាអនាគតក៏ពិត តែចេតោបរិយញ្ញាណនោះរមែងធ្វើចិត្តដែលកើតឡើងខាងក្នុង ៧ ថ្ងៃប៉ុណ្ណោះ ឲ្យជាអារម្មណ៍ អនាគតំសញ្ញាណនេះ រមែងធ្វើចិត្តដែលកើតឡើងខ្លះ ខន្ធខ្លះ ធម៌ដែលទាក់ទងដោយខន្ធខ្លះ ក្នុងអនាគតរាប់សែនកប្ប ឲ្យជាអារម្មណ៍ ។ ឈាន ៣ ឬឈាន ៤ ដែលជារូបាវចរជាដើម គប្បីជ្រាបថាជានវត្តព្វារម្មណ៍តែម្យ៉ាងប៉ុណ្ណោះ ព្រោះមិនប្រារព្ធធម៌ឯណានីមួយ ក្នុងធម៌ដែលជាអតីត អនាគតនិងបច្ចុប្បន្នប្រព្រឹត្តទៅ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ដែលជាអជ្ឈត្តិកៈ ដូចតទៅនេះថា

បទថា **អជ្ឈត្តិកពហិទ្ធា និព្វានញ្ច ពហិទ្ធា** នេះទ្រង់ត្រាស់ថា **ពហិទ្ធា** ( ពួកធម៌ជាខាងក្រៅ ) ព្រោះមិនមានបរិយាយនៃធម៌ខាងក្នុង ដែលកើតក្នុងខ្លួនដោយប្រការដែលថា ធម្មជាតិនេះ នឹងចាត់ជាធម៌ខាងក្នុងដោយបរិយាយណាមួយមិនបាន ដូចរូបដែលទាក់ទងដោយឥន្ទ្រិយ ទោះហៅថាជាខាងក្រៅ ព្រោះការបន្តក្នុងបុគ្គលដទៃខ្លះ ទោះជាធម៌ខាងក្នុង ដែលកើតក្នុងខ្លួន ព្រោះរូបដែលទាក់ទងដោយឥន្ទ្រិយនោះ ទាក់ទងដោយការបន្តរបស់ខ្លួន មិនមែនត្រាស់ថា ជាខាងក្រៅ ព្រោះត្រឹមតែមិនកើតខាងក្នុងខ្លួន ។

ចំណែកក្នុងអជ្ឈត្តារម្មណត្តិកៈ ត្រាស់ថា ពួកធម៌មានអារម្មណ៍ខាងក្រៅ ទ្រង់សំដៅត្រឹមតែការមិនកើតឡើងនៃធម៌ ត្រឹមតែជាខាងក្នុង ដែលកើតក្នុងខ្លួន ។ ព្រះមានព្រះភាគត្រាស់ថា អាកិញ្ចញ្ញាយតនៈ មិនគប្បីពោលថាមានអារម្មណ៍ខាងក្នុងផងជាដើម ព្រោះទ្រង់មិនព្រមទទួល សូម្បីភាវៈដែលជាខាងក្នុង សូម្បីភាវៈដែលជាខាងក្រៅ សូម្បីភាវៈទាំងខាងក្នុងទាំងខាងក្រៅនៃអារម្មណ៍របស់អាកិញ្ចញ្ញាយតនៈ ដោយហេតុត្រឹមតែការប្រាសចាកធម៌ខាងក្នុងប៉ុណ្ណោះ ។

ក្នុងព្រះតម្រាស់នោះ អាកិញ្ចញ្ញាយតនៈនោះប៉ុណ្ណោះជាធម៌មានអារម្មណ៍ជានវត្តព្វៈតែម្យ៉ាងក៏មិនមែន សូម្បីអាវជ្ជនចិត្ត សូម្បីឧបចារចិត្តទាំងឡាយរបស់អាកិញ្ចញ្ញាយតនៈនោះ សូម្បីចិត្តដែលពិចារណាអារម្មណ៍របស់អាកិញ្ចញ្ញាយតនៈនោះ សូម្បីអកុសលចិត្តទាំងឡាយ ដែលប្រព្រឹត្តទៅដោយអំណាចសេចក្ដីត្រេកអរជាដើម ព្រោះអាកិញ្ចញ្ញាយតនៈនោះ ក៏ជានវត្តព្វ-

រម្មណ៍នោះ ។ ធម្មជាតិទាំងនេះ កាលត្រាស់ដល់អាកិញ្ចញ្ញាយតនៈហើយ ក៏ឈ្មោះថា ជាការដែលត្រាស់ហើយដូចគ្នា ព្រោះហេតុនោះ ទើបមិនបាន ត្រាស់ទុកមួយផ្នែក ។ សួរថា ឈ្មោះថាជាការដែលត្រាស់ហើយដូចគ្នា ដូចម្តេច ឆ្លើយថា អាកិញ្ចញ្ញាយតនៈនេះ គប្បីមានអារម្មណ៍ដូចគ្នានឹងធម្មជាតិ ដែលជាបុរេចារិករបស់អាកិញ្ចញ្ញាយតនៈនោះដែលប្រព្រឹត្តទៅដោយអំណាច នៃអាវជ្ជនៈនិងឧបចារៈជាដើម ។ ធម៌ទាំងអស់នោះទ្រង់ត្រាស់ថា ជានវត្ត-ព្វារម្មណ៍ ព្រោះក្នុងអតីតារម្មណត្តិកៈ ទ្រង់ទទួលភាពដែលចិត្តុប្បាទទាំងនេះ ដែលត្រាស់ទុកយ៉ាងនេះថា កាមាវចរកុសល អកុសលចិត្តុប្បាទខាងកិរិយា ៩ ដួង រូបាវចរចតុត្ថជ្ឈាន ជាធម៌មានអារម្មណ៍ជានវត្តព្វៈ ដោយន័យជា ដើមថា ដែលនឹងពោលថាជាអារម្មណ៍ជាអតីតៈក៏មិនបាន ព្រោះព្រះតម្រាស់ ថា អាកិញ្ចញ្ញាយតនៈជាធម៌មានអារម្មណ៍ជានវត្តព្វៈដោយចំណែកមួយយ៉ាង នេះថា អាកិញ្ចញ្ញាយតនៈ មគ្គ ៤ ដែលជាលោកុត្តរ និងសាមញ្ញផល ៤ សភាវៈធម៌ទាំងនេះ នឹងពោលថា មានជាអតីតៈ ក៏មិនបាន ។ ឥឡូវនេះ អាកិញ្ចញ្ញាយតនៈនោះ សូម្បីព្រះអង្គត្រាស់ទុកតែម្យ៉ាង ក្នុងអជ្ឈត្តារម្ម-ណត្តិកៈ តែព្រោះភាពដែលកាមាវចរកុសលជាដើម ជានវត្តព្វារម្មណ៍ ត្រាស់ សំដៅដល់ភាពជាអារម្មណ៍តែមួយ ជាមួយអាកិញ្ចញ្ញាយតនៈនោះ ក្នុងខាង ដើម ហេតុនោះទើបសម្តែងថា កាមាវចរកុសលជាដើមនោះជានវត្តព្វារម្មណ៍ ក្នុងទីនេះ ។ ពិតណាស់ អ្វីសោតនឹងរារាំងក្នុងភាពដែលកាមាវចរកុសលជា ដើម ដែលមានអារម្មណ៍តែមួយជាមួយអាកិញ្ចញ្ញាយតនៈនោះ ជាធម៌មាន

អារម្មណ៍ជានវត្តព្វៈ កាលត្រាស់ដល់អាកិញ្ចញ្ញាយតនៈនោះហើយ ដោយអាការយ៉ាងនេះ ក៏គប្បីជ្រាបបានថា កាមាវចរកុសលជាដើម រមែងជាការត្រាស់ទុកហើយដូចគ្នា ។ ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ដោយព្រះបាលីក្នុងអជ្ឈត្តារម្មណត្តិកៈ ។

ពោលដោយការចែកអារម្មណ៍ ចិត្តុប្បាទទាំងនេះគឺ វិញ្ញាណញ្ចាយតនៈ និងនេវសញ្ញានាសញ្ញាយតនៈ ៦ ដួង ដោយអំណាចនៃកុសលវិបាកនិងកិរិយា គប្បីជ្រាបថា ជាធម៌មានអារម្មណ៍ខាងក្នុងព្រោះប្រារព្ធសមាបត្តិថ្នាក់ក្រោមដែលទាក់ទងក្នុងសន្តាននៃខ្លួនប្រព្រឹត្តទៅ ។ បណ្តាចិត្តុប្បាទទាំង ៦ នេះ អាកាសានញ្ចាយតនៈដែលជាកិរិយា រមែងជាអារម្មណ៍របស់វិញ្ញាណញ្ចាយតនៈដែលជាកិរិយាប៉ុណ្ណោះ មិនជាអារម្មណ៍របស់វិញ្ញាណញ្ចាយតនៈដែលជាកុសលនិងវិបាកក្រៅនេះទេ ព្រោះហេតុអ្វី ព្រោះបុគ្គលដែលដល់ព្រមដោយអាកាសានញ្ចាយតនកិរិយា មិនមានវិញ្ញាណញ្ចាយតនៈដែលជាកុសល ឬវិបាក ។ តែកុសលរមែងជាអារម្មណ៍ដល់កុសលវិបាក និងកិរិយាទាំង ៣ បាន ព្រោះហេតុអ្វី ព្រោះបុគ្គលញ៉ាំងអាកាសានញ្ចាយតនកុសលឲ្យកើតឡើង ហើយតាំងនៅ ញ៉ាំងការកើតនៃវិញ្ញាណញ្ចាយតនៈទាំង ៣ យ៉ាង ឲ្យកើតឡើងខ្ពស់ជាងអាកាសានញ្ចាយតនកុសលនោះបាន ។ ចំណែក វិបាករមែងមិនជាអារម្មណ៍របស់ចិត្តុប្បាទណាមួយ ព្រោះហេតុអ្វី ព្រោះចិត្ត ( ក្នុងសមាបត្តិ ) ចេញចាកវិបាកហើយ មិនកើតអភិនីហារ ។ សូម្បីក្នុងការធ្វើឲ្យជាអារម្មណ៍របស់នេវសញ្ញានាសញ្ញាយតនៈ ក៏ន័យនេះឯង ។

ចិត្តុប្បាទទាំងអស់ មានឈាន ៣ ឬ ៤ ដែលជារូបាវចរជាដើម គប្បីជ្រាប ថាជាធម៌មានអារម្មណ៍ខាងក្រៅ ព្រោះប្រារព្ធបឋវីកសិណជាដើម ដែលជាខាងក្រៅ ប្រព្រឹត្តទៅដោយភាពជាខាងក្រៅចាកធម៌ខាងក្នុង ដែលកើតក្នុងខ្លួន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សព្វេវ កាមាវចរា កុសលាកុសលាព្យាកតា ធម្មា រូបាវចរំ ចតុត្ថំ ឈានំ** នេះ ដូចតទៅនេះថា

ពោលដោយកុសល ចិត្តុប្បាទដែលជាញាណសម្បយុត្ត ៤ ដួង ជាធម៌មានអារម្មណ៍ជាខាងក្នុង ដល់អ្នកពិចារណាធម៌ មានខន្ធជាដើមរបស់ខ្លួន ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងការពិចារណាខន្ធជាដើមរបស់ពួកជនដទៃ និងក្នុងការពិចារណាបញ្ញត្តិនិងព្រះនិព្វាន ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅ ដោយអំណាចនៃការពិចារណាធម៌ មានខន្ធជាដើម ទាំងជារបស់ខ្លួននិងជារបស់បុគ្គលនោះ ៗ ក្នុងចិត្តុប្បាទដែលជាញាណវិប្បយុត្ត ក៏ន័យនេះឯង ។ ត្រឹមតែការពិចារណាព្រះនិព្វានរបស់ចិត្តុប្បាទ ដែលជាញាណវិប្បយុត្តប៉ុណ្ណោះមិនមាន ។

ពោលដោយអកុសល ចិត្តុប្បាទដែលសម្បយុត្តដោយទិដ្ឋិ ៤ ដួង ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាត្រេកអរពីកកាយ និងបបោសអង្អែលនូវធម៌ មានខន្ធជាដើមរបស់ខ្លួន ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងវេលាដែលប្រព្រឹត្តទៅយ៉ាងនោះឯង និងក្នុងខន្ធជាដើមរបស់បុគ្គលដទៃ និងក្នុងរូបកសិណដែលមិនទាក់ទងដោយឥន្ទ្រិយជាដើម ជាធម៌មានអារម្មណ៍ទាំងខាងក្នុង

និងខាងក្រៅ ដោយអំណាចនៃអារម្មណ៍ទាំងពីរនោះ ។ សូម្បីក្នុងចិត្តុប្បាទ ដែលជាទិដ្ឋិវិប្បយុត្ត ក៏ន័យនេះដូចគ្នា ។ ត្រឹមតែការបេបោសអង្អែលរបស់ចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តទាំងនោះមិនមាន ។ ចិត្តុប្បាទដែលសម្បយុត្ត ដោយបដិឃៈ ២ ដួង ជាធម៌មានអារម្មណ៍ខាងក្នុង ដល់បុគ្គលអ្នកដល់នូវទោមនស្សក្នុងខន្ធជាដើមរបស់ខ្លួន ជាធម៌មានអារម្មណ៍ខាងក្រៅ ដល់បុគ្គលអ្នកដល់នូវទោមនស្សក្នុងខន្ធជាដើមរបស់បុគ្គលដទៃ និងក្នុងរូបបញ្ញត្តិដែលមិនទាក់ទងដោយឥន្ទ្រិយ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរនោះ ។ សូម្បីចិត្តុប្បាទ ដែលសម្បយុត្តដោយវិចិកិច្ឆានិងឧទ្ធច្ចៈក៏គប្បីជ្រាបថា មានអារម្មណ៍ជាខាងក្នុងជាដើម ក្នុងវេលាប្រព្រឹត្តទៅដោយអំណាចនៃសេចក្ដីសង្ស័យ និងការញាប់ញ័រ ក្នុងធម៌ទាំងឡាយ មានប្រការតាមដែលពោលមកហើយ ។

ចិត្តុប្បាទទាំង ១៣ ដួងនេះ គឺទ្វិបញ្ចវិញ្ញាណ ១០ មនោធាតុ ៣ ក្នុងវេលាដែលប្រារព្ធរូបជាដើមរបស់ខ្លួនប្រព្រឹត្តទៅ ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាប្រារព្ធរូបជាដើម របស់បុគ្គលដទៃប្រព្រឹត្តទៅ ជាធម៌មានអារម្មណ៍ខាងក្រៅ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងទាំងខាងក្រៅ ដោយអំណាចអារម្មណ៍ទាំងពីរនោះ ។

អហេតុកវិបាកមនោវិញ្ញាណធាតុ ដែលសហគតដោយសោមនស្ស ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាប្រារព្ធធម៌មានរូបជាដើម ៥ យ៉ាងរបស់ខ្លួនដោយអំណាចសន្តីរណៈ និងតទារម្មណៈប្រព្រឹត្តទៅក្នុងបញ្ចទ្វារ និងក្នុង

វេលាប្រារព្ធកាមាវចរធម៌ខាងក្នុងពួកដទៃ ដោយអំណាចជាតទារម្មណៈនោះ ឯងប្រព្រឹត្តទៅ ក្នុងមនោទ្វារដែលប្រព្រឹត្តទៅក្នុងធម៌របស់អ្នកដទៃ ក៏ជាធម៌មានអារម្មណ៍ខាងក្រៅ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅ ដោយអំណាចនៃអារម្មណ៍ទាំងពីរ ។ ក្នុងអហេតុកវិបាកមនោវិញ្ញាណធាតុ ដែលសហគតដោយឧបេក្ខាទាំង ២ ដួង ក៏ន័យនេះឯង ។ ត្រឹមតែមនោវិញ្ញាណ-ធាតុទាំងនេះប្រព្រឹត្តទៅក្នុងកម្មជាដើម មានអជ្ឈត្តធម៌ជាដើម ដោយអំណាចនៃបដិសន្ធិ ភវង្គនិងចុតិ ក្នុងសុគតិភូមិនិងទុគ្គតិភូមិ ។

មហាវិបាកចិត្ត ៨ ដួង មានគតិដូចអហេតុកវិបាកមនោវិញ្ញាណធាតុ ដែលសហគតដោយឧបេក្ខាទាំង ២ នោះឯង ។ ត្រឹមតែមហាវិបាកចិត្តទាំងនេះមិនប្រព្រឹត្តទៅដោយអំណាចនៃសន្តីរណៈ រមែងប្រព្រឹត្តទៅក្នុងសុគតិភូមិ ដោយអំណាចបដិសន្ធិ ភវង្គ និងចុតិប៉ុណ្ណោះ ។ អហេតុកកិរិយាមនោវិញ្ញាណ-ធាតុ ដែលសហគតដោយសោមនស្សក្នុងបញ្ចទ្វារ ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាប្រារព្ធរូបជាដើមរបស់ខ្លួនប្រព្រឹត្តទៅ ដោយអំណាចការធ្វើអាការត្រេកអរដែលប្រព្រឹត្តទៅក្នុងរូបជាដើមរបស់បុគ្គលដទៃ ជាធម៌មានអារម្មណ៍ខាងក្រៅ ក្នុងមនោទ្វារដែលប្រព្រឹត្តទៅដោយអំណាចហសិតុប្បាទដល់ព្រះតថាគត ដែលទ្រង់ពិចារណាកិរិយាដែលទ្រង់ធ្វើហើយក្នុងវេលាជាជោតិបាលមាណព មឃទេវរាជនិងកណ្ហតាបសជាដើម ជាធម៌មានអារម្មណ៍ខាងក្នុង ក្នុងវេលាទ្រង់ប្រារព្ធការធ្វើកិរិយារបស់ពួកសាវកជាដើម យ៉ាងនេះគឺ ព្រះនាងមល្លិកាទេវី សន្តតិមហាមាត្យនិងនាយសុមនមាលាការ ប្រព្រឹត្ត

ទៅ ជាធម៌មានអារម្មណ៍ជាខាងក្រៅ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។ អហេតុកកិរិយាមនោវិញ្ញាណធាតុដែលសហគតដោយឧបេក្ខា ជាធម៌មានអារម្មណ៍ជាខាងក្នុងជាដើម ក្នុងវេលាប្រព្រឹត្តទៅក្នុងបញ្ចទ្វារ ដោយអំណាចជាវោដ្ឋព្វនៈ និងក្នុងវេលាប្រព្រឹត្តទៅក្នុងមនោទ្វារដោយអំណាចជាអាវជ្ជនៈ ។ មហាកិរិយាចិត្ត ៨ ដួង មានគតិដូចកុសលចិត្តនុ៎ះឯង ។ ត្រឹមតែមហាកិរិយាចិត្តទាំងនោះ រមែងកើតឡើងដល់ព្រះខីណាស្រព មហាកុសលចិត្ត រមែងកើតដល់ព្រះសេក្ខៈ និងបុថុជ្ជនក្នុងសេចក្ដីនេះ ការផ្សេងគ្នាមានប្រមាណប៉ុណ្ណេះឯង ដោយប្រការដូច្នេះ ។

ក្នុងឈាន ៥ យ៉ាង មានចតុត្ថជ្ឈានដែលជាបាទក្នុងធម៌ទាំងពួងជាដើម ក្នុងរូបាវចរចតុត្ថជ្ឈាន មានប្រការតាមដែលពោលហើយ រមែងបានឱកាសក្នុងតិកៈនេះ ។ ពិតណាស់ ឈានទាំង ៥ តាមដែលពោលមកនេះ ជាធម៌មានអារម្មណ៍ខាងក្រៅ ព្រោះមានកសិណ បញ្ញត្តិ និងនិមិត្តជាអារម្មណ៍ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងឥទ្ធិវិធៈជាធម៌មានអារម្មណ៍ខាងក្នុង ព្រោះធ្វើកាយនិងចិត្តរបស់ខ្លួនឲ្យជាអារម្មណ៍ ក្នុងវេលាដែលញ៉ាំងចិត្តឲ្យផ្លាស់ប្ដូរទៅតាមអំណាចកាយ ឬញ៉ាំងកាយឲ្យផ្លាស់ប្ដូរទៅតាមអំណាចចិត្ត និងក្នុងវេលាដែលនិម្មិតខ្លួនឲ្យជាកុមារជាដើម ជាធម៌មានអារម្មណ៍ជាខាងក្រៅ ក្នុងវេលាដែលសម្ដែងរូបជារូបដំរី និងសេះជាដើមក្នុងខាងក្រៅ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅ ក្នុងវេលាដែលប្រព្រឹត្តទៅក្នុងខាងក្នុង តាមកាលដែលគួរ និងក្នុងវេលាដែលប្រព្រឹត្តទៅខាងក្រៅតាមកាលដែលគួរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វសោត ជាធម៌មានអារម្មណ៍ជាខាងក្នុង ក្នុងវេលាដែលស្តាប់សំឡេងក្នុងពោះរបស់ខ្លួន ជាធម៌មានអារម្មណ៍ជាខាងក្រៅក្នុងវេលាដែលស្តាប់សំឡេងជនដទៃ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងចេតោបរិយញ្ញាណ ជាធម៌មានអារម្មណ៍ជាខាងក្រៅតែម្យ៉ាងព្រោះមានចិត្តអ្នកដទៃជាអារម្មណ៍ ។ ចេតោបរិយញ្ញាណនោះ មិនមានប្រយោជន៍ក្នុងការដឹងចិត្តរបស់ខ្លួន ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងបុព្វេនិវាសញ្ញាណ ជាធម៌មានអារម្មណ៍ជាខាងក្នុង ក្នុងវេលាដែលតាមរឭកដល់ខន្ធរបស់ខ្លួន ជាធម៌មានអារម្មណ៍ជាខាងក្រៅ ព្រោះតាមរឭកដល់ខន្ធរបស់អ្នកដទៃ រូបដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយនិងបញ្ញត្តិទាំង ៣ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងទិព្វចក្ខុ ជាធម៌មានអារម្មណ៍ ជាខាងក្នុងក្នុងវេលាឃើញរូបក្នុងពោះរបស់ខ្លួនជាដើម ជាធម៌មានអារម្មណ៍ជាខាងក្រៅក្នុងវេលាដែលឃើញរូបដ៏សេស ជាធម៌មានអារម្មណ៍ ទាំងខាងក្នុងនិងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ចតុត្ថជ្ឈានដែលប្រព្រឹត្តទៅក្នុងអនាគតំសញ្ញាណ ជាធម៌មានអារម្មណ៍ជាខាងក្នុងក្នុងវេលាតាមរឭកដល់ខន្ធក្នុងអនាគតរបស់ខ្លួន ជាធម៌មានអារម្មណ៍ជាខាងក្រៅ ក្នុងវេលាតាមរឭកដល់ខន្ធដែលជាអនាគតរបស់អ្នកដទៃ ឬរូប

ដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជាធម៌មានអារម្មណ៍ទាំងខាងក្នុងនិងខាងក្រៅដោយអំណាចនៃអារម្មណ៍ទាំងពីរ ។

ហេតុដែលអាកិញ្ចញ្ញាយតនជ្ឈានជាធម៌មានអារម្មណ៍ជានវត្តព្វៈ ខ្ញុំបានពោលទុកនុ៎ះឯង ។

## តិកអត្ថុទ្ធារ ចប់

# អភិធម្មបិដក

## ហេតុគោច្ឆកជាដើម

[ ៤០០ ] ពួកធម៌ជាហេតុ តើដូចម្តេច ។ កុសលហេតុ ៣ អកុសលហេតុ ៣ អព្យាកតហេតុ ៣ អលោភៈ ជាកុសលហេតុ អទោសៈជាកុសលហេតុ កើតឡើងក្នុងកុសលក្នុងភូមិ ៤ អមោហៈជាកុសលហេតុ ក៏កើតឡើងក្នុងកុសលក្នុងភូមិ ៤ ដែរ វៀរតែចិត្តុប្បាទ ៤ ជាញាណវិប្បយុត្ត ខាងកាមាវចរកុសលចេញ លោភៈកើតឡើងក្នុងចិត្តុប្បាទ ៨ ប្រកបដោយលោភៈ ឯទោសៈកើតឡើងក្នុងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស មោហៈកើតឡើងក្នុងអកុសលទាំងអស់ អលោភៈជាវិបាកហេតុ អទោសៈជាវិបាកហេតុកើតឡើងក្នុងវិបាកក្នុងភូមិ ៤ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងវិបាកនៃកាមាវចរចេញ អមោហៈជាវិបាកហេតុកើតឡើងក្នុងវិបាកក្នុងភូមិ ៤ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងវិបាកនៃកាមាវចរ និងវៀរតែចិត្តុប្បាទ ៤ ជាញាណវិប្បយុត្តចេញ អលោភៈជាកិរិយហេតុ អទោសៈជាកិរិយហេតុ កើតឡើងក្នុងកិរិយាក្នុងភូមិ ៣ វៀរតែចិត្តុប្បាទជាអហេតុក ខាងកាមាវចរកិរិយាចេញ អមោហៈជាកិរិយហេតុកើតឡើងក្នុងកិរិយាក្នុងភូមិ ៣ វៀរតែចិត្តុប្បាទជាអហេតុកៈខាងកាមាវចរកិរិយានិងវៀរតែចិត្តុប្បាទ ៤ ជាញាណវិប្បយុត្តចេញ នេះពួកធម៌ជាហេតុ ។ ពួកធម៌មិនមែនជាហេតុ តើដូចម្តេច ។ វៀរតែពួកហេតុចេញ កុសលនិងអកុសល ក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាហេតុ ។

[ ៤០១ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ អកុសល

ក្រៅពីនេះ វៀរតែមោហៈ ប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងវិបាកនៃកាមាវចរចេញ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ វៀរតែចិត្តុប្បាទជាអហេ-តុកៈ ខាងកាមាវចរកិរិយាចេញ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនិងហេតុ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ មោហៈប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ បញ្ចវិញ្ញាណ ២ មនោធាតុ ៣ មនោ-វិញ្ញាណធាតុជាអហេតុកៈ ៥ រូបនិងនិព្វាន នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងហេតុ ។

[ ៤០២ ] ពួកធម៌ប្រកបដោយហេតុ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែមោហៈប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ វៀរតែចិត្តុប្បាទ ជាអហេតុកៈ ខាងវិបាកនៃកាមាវចរចេញ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងកាមាវចរកិរិយាចេញ នេះពួកធម៌ប្រកបដោយហេតុ ។ ពួកធម៌ប្រាសចាកហេតុ តើដូចម្តេច ។ មោហៈប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ បញ្ចវិញ្ញាណ ២ មនោធាតុ ៣ មនោវិញ្ញាណធាតុជាអហេតុកៈ ៥ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកហេតុ ។

[ ៤០៣ ] ពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង តើដូចម្តេច ។ ហេតុ ២ ឬ ៣ កើតឡើងជាមួយគ្នាក្នុងធម៌ណា នេះពួកធម៌ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ។ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជា

មួយនឹងហេតុ តែមិនមែនជាហេតុ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងវិបាកនៃកាមាវចរចេញ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ វៀរតែចិត្តុប្បាទ ជាអហេតុកៈ ខាងកាមាវចរកិរិយាចេញ វៀរតែពួកហេតុដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុ ។ ពួកធម៌មិនមានហេតុ មិនគប្បីពោលថា ជាហេតុផង ប្រព្រឹត្តទៅជាមួយនឹងហេតុផង ជាគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងហេតុ តែមិនមែនជាហេតុផងឡើយ ។

[ ៤០៤ ] ពួកធម៌ជាហេតុផង ប្រកបដោយហេតុផង តើដូចម្តេច ។ ហេតុ ២ ឬ ៣ កើតឡើងជាមួយគ្នា ក្នុងធម៌ណា នេះពួកធម៌ជាហេតុផង ប្រកបដោយហេតុផង ។ ពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងវិបាកនៃកាមាវចរចេញ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងកាមាវចរកិរិយាចេញ វៀរតែពួកហេតុដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌គ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុ ។ ពួកធម៌ប្រាសចាកហេតុ មិនគប្បីពោលថា ជាហេតុផង ប្រកបដោយហេតុផង ជាគ្រាន់តែប្រកបដោយហេតុ តែមិនមែនជាហេតុផងឡើយ ។

[ ៤០៥ ] ពួកធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ វៀរតែចិត្តុ-

ប្បាទជាអហេតុកៈ ខាងវិបាកនៃកាមាវចរចេញ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ វៀរតែចិត្តុប្បាទជាអហេតុកៈ ខាងកាមាវចរកិរិយាចេញ វៀរតែពួកហេតុ ដែលកើតឡើងក្នុងទីនោះចេញ នេះពួកធម៌មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុ ។ ពួកធម៌មិនមែនជាហេតុផង មិនប្រព្រឹត្តទៅជាមួយនឹងហេតុផង តើដូចម្ដេច ។ បញ្ចវិញ្ញាណ ២ មនោធាតុ ៣ មនោវិញ្ញាណធាតុជាអហេតុកៈ ៥ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាហេតុផង មិនប្រព្រឹត្តទៅជាមួយនឹងហេតុផង ។ ពួកធម៌ជាហេតុ មិនគប្បីពោលថា មិនមែនជាហេតុ តែប្រព្រឹត្តទៅជាមួយនឹងហេតុផង ថាមិនមែនជាហេតុ មិនប្រព្រឹត្តទៅជាមួយនឹងហេតុផងឡើយ ។

[ ៤០៦ ] ពួកធម៌ប្រកបដោយបច្ច័យ តើដូចម្ដេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបទាំងអស់ នេះពួកធម៌ប្រកបដោយបច្ច័យ ។ ពួកធម៌មិនមានបច្ច័យតើដូចម្ដេច ។ និព្វាន នេះពួកធម៌មិនមានបច្ច័យ ។

[ ៤០៧ ] ពួកធម៌មានបច្ច័យតាក់តែង តើដូចម្ដេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌មានបច្ច័យតាក់តែង ។ ពួកធម៌មិនមានបច្ច័យតាក់តែង តើដូចម្ដេច ។ និព្វាន នេះពួកធម៌មិនមានបច្ច័យតាក់តែង ។

[ ៤០៨ ] ពួកធម៌ប្រកបដោយការឃើញ តើដូចម្ដេច ។ រូបាយតនៈ នេះពួកធម៌ប្រកបដោយការឃើញ ។ ពួកធម៌មិនប្រកបដោយឃើញ តើដូច

ម្តេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបដែលជាអនិទស្សនៈជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈ និងនិព្វាន នេះពួកធម៌មិនប្រកបដោយការឃើញ ។

[ ៤០៩ ] ពួកធម៌ប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ នេះពួកធម៌ប្រកបដោយការប៉ះពាល់ ។ ពួកធម៌មិនប្រកបដោយការប៉ះពាល់ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបដែលជាអនិទស្សនៈជាអប្បដិឃៈ រាប់បញ្ចូលក្នុងធម្មាយតនៈនិងនិព្វាន នេះពួកធម៌ មិនប្រកបដោយការប៉ះពាល់ ។

[ ៤១០ ] ពួកធម៌មានរូប តើដូចម្តេច ។ មហាភូតរូប ៤ ផង រូបអាស្រ័យនូវមហាភូតរូប ៤ ផង នេះពួកធម៌មានរូប ។ ពួកធម៌មិនមានរូប តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងនិព្វាន នេះពួកធម៌មិនមានរូប ។

[ ៤១១ ] ពួកធម៌ជាលោកិយ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ជាលោកិយៈ ។ ពួកធម៌ជាលោកុត្តរៈ តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នៈផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ជាលោកុត្តរៈ ។

[ ៤១២ ] ពួកធម៌ទាំងអស់ គប្បីដឹងច្បាស់ដោយវិញ្ញាណនីមួយ មិនគប្បីដឹងច្បាស់ដោយវិញ្ញាណនីមួយ ។

[ ៤១៣ ] ពួកធម៌ជាអាសវៈ តើដូចម្ដេច ។ អាសវៈ ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ អវិជ្ជាសវៈ ឯកាមាសវៈ តែងកើតក្នុងចិត្តុប្បាទ ៨ ដែលប្រកបដោយលោភៈ ភវាសវៈតែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រាសចាកទិដ្ឋិតែប្រកបដោយលោភៈ ទិដ្ឋាសវៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ អវិជ្ជាសវៈតែងកើតក្នុងអកុសលទាំងអស់ នេះពួកធម៌ជាអាសវៈ ។ ពួកធម៌មិនមែនជាអាសវៈ តើដូចម្ដេច ។ អកុសលក្រៅពីនេះ វៀរតែអាសវៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាអាសវៈ ។

[ ៤១៤ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្ដេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នផងសាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌មិនប្រព្រឹត្តទៅជាមួយអាសវៈ ។

[ ៤១៥ ] ពួកធម៌ប្រកបដោយអាសវៈ តើដូចម្ដេច ។ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស អកុសលក្រៅពីនេះ វៀរតែមោហៈដែលកើតឡើងក្នុងទីទុំ៖ ទាំងវៀរតែមោហៈប្រកបដោយវិចិកិច្ឆា ប្រកបដោយឧទ្ធច្ចៈចេញ នេះពួកធម៌ប្រកបដោយអាសវៈ ។ ពួកធម៌ប្រាសចាកអាសវៈតើដូចម្ដេច ។

មោហៈដែលកើតក្នុងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស មោហៈប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកអាសវៈ ។

[ ៤១៦ ] ពួកធម៌ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង តើដូចម្តេច ។ អាសវៈទាំងនោះឯង ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។ ពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែអាសវៈចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌គ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈ ។ ពួកធម៌មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈ មិនគប្បីពោលថា ជាអាសវៈផង ប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ថាគ្រាន់តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តែមិនមែនជាអាសវៈផងឡើយ ។

[ ៤១៧ ] ពួកធម៌ជាអាសវៈផង ប្រកបដោយអាសវៈផង តើដូចម្តេច ។ អាសវៈ ២ ឬ ៣ កើតឡើងជាមួយគ្នាក្នុងធម៌ណា នេះពួកធម៌ជាអាសវៈផង ប្រកបដោយអាសវៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ តើដូចម្តេច ។ អកុសលក្រៅពីនេះវៀរតែអាសវៈចេញ នេះពួកធម៌គ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈ ។ ពួកធម៌ប្រាសចាកអាសវៈ មិនគប្បីពោលថា ជាអាសវៈផង ប្រកបដោយអាសវៈ

ជាគ្រាន់តែប្រកបដោយអាសវៈ តែមិនមែនជាអាសវៈផងឡើយ ។

[ ៤១៨ ] ពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ តើដូចម្តេច ។ មោហៈ កើតឡើងក្នុងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស មោហៈប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈ ។ ពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ។ ពួកធម៌ប្រកបដោយអាសវៈ មិនគប្បីពោលថា ប្រាសចាកអាសវៈ តែប្រព្រឹត្តទៅជាមួយនឹងអាសវៈផង ជាប្រាសចាកអាសវៈផង មិនប្រព្រឹត្តទៅជាមួយនឹងអាសវៈផងឡើយ ។

[ ៤១៩ ] ពួកធម៌ជាសញ្ញោជនៈ តើដូចម្តេច ។ សញ្ញោជនៈ ១០ យ៉ាងគឺ កាមរាគសញ្ញោជនៈ បដិឃសញ្ញោជនៈ មានសញ្ញោជនៈ ទិដ្ឋិ-សញ្ញោជនៈ វិចិកិច្ឆាសញ្ញោជនៈ សីលព្វតបរាមាសសញ្ញោជនៈ ភវរាគ-សញ្ញោជនៈ ឥស្សាសញ្ញោជនៈ មច្ឆរិយសញ្ញោជនៈ អវិជ្ជាសញ្ញោជនៈ ឯកាមរាគសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ៨ ដែលប្រកបដោយលោភៈ បដិឃសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ២ ដែលប្រកបដោយទោមនស្ស មានសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រាសចាកទិដ្ឋិ តែប្រកប

ដោយលោភៈ ទិដ្ឋិសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ វិចិកិច្ឆាសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ដែលប្រកបដោយវិចិកិច្ឆា សីលព្វតបរាមាសសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ ភវរាគសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ឥស្សាសញ្ញោជនៈនិងមច្ឆរិយសញ្ញោជនៈ តែងកើតក្នុងចិត្តុប្បាទ ២ ដែលប្រកបដោយទោមនស្ស អវិជ្ជាសញ្ញោជនៈ តែងកើតក្នុងអកុសលទាំងអស់ នេះពួកធម៌ជាសញ្ញោជនៈ ។ ពួកធម៌មិនមែនជាសញ្ញោ-ជន តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែសញ្ញោជនៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាសញ្ញោជនៈ ។

[ ៤២០ ] ពួកធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ជាប្រយោជន៍ដល់សញ្ញោជនៈ ។ ពួកធម៌មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ ។

[ ៤២១ ] ពួកធម៌ប្រកបដោយសញ្ញោជនៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែមោហៈប្រកបដោយឧទ្ធច្ចៈចេញ នេះពួកធម៌ប្រកបដោយសញ្ញោជនៈ ។ ពួកធម៌ប្រាសចាកសញ្ញោជនៈ តើដូចម្តេច ។ មោហៈប្រកប

ដោយឧទ្ទេសៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកសញ្ញោជនៈ ។

[ ៤២២ ] ពួកធម៌ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង តើដូចម្ដេច ។ សញ្ញោជនៈទាំងនោះឯង ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង ។ ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ តើដូចម្ដេច ។ អកុសលក្រៅពីនេះ វៀរតែសញ្ញោ-ជនៈចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌គ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ។ ពួកធម៌មិនមែនជាប្រយោជន៍ដល់សញ្ញោជនៈ មិនគប្បីពោលថា ជាសញ្ញោជនៈផង ជាប្រយោជន៍ដល់សញ្ញោជនៈផង ថាគ្រាន់តែជាប្រយោជន៍ដល់សញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផងឡើយ ។

[ ៤២៣ ] ពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង តើដូចម្ដេច ។ សញ្ញោជនៈ ២ ឬ ៣ កើតក្នុងទីជាមួយគ្នា ក្នុងធម៌ណា នេះពួកធម៌ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយសញ្ញោជនៈតែមិនមែនជាសញ្ញោជនៈ តើដូចម្ដេច ។ អកុសលក្រៅពីនេះ វៀរតែពួកសញ្ញោជនៈចេញ នេះពួកធម៌គ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈ ។ ពួកធម៌ប្រាសចាកសញ្ញោជនៈ មិនគប្បីពោលថា ជាសញ្ញោជនៈផង ប្រកបដោយសញ្ញោជនៈផង ថាគ្រាន់តែប្រកបដោយសញ្ញោជនៈ តែមិនមែនជាសញ្ញោជនៈផងឡើយ ។

[ ៤២៤ ] ពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោ-ជនៈ តើដូចម្តេច ។ មោហៈប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ដល់សញ្ញោជនៈ ។ ពួកធម៌ប្រាសចាកសញ្ញោជនៈផង មិនជាប្រយោជន៍ដល់សញ្ញោជនៈផង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រាសចាកសញ្ញោជនៈផង មិនជាប្រយោជន៍ដល់សញ្ញោជនៈផង ។ ពួកធម៌ប្រកបដោយសញ្ញោជនៈ មិនគប្បីពោលថា ប្រាសចាកសញ្ញោជនៈ តែជាប្រយោជន៍ ដល់សញ្ញោជនៈផង ថាប្រាសចាកសញ្ញោជនៈផង មិនជាប្រ-យោជន៍ដល់សញ្ញោជនៈផងឡើយ ។

[ ៤២៥ ] ពួកធម៌ជាគន្ថៈ ( ធម៌ដោតក្រងសត្វទុកក្នុងវដ្តៈ ) តើដូចម្តេច ។ គន្ថៈ ៤ គឺអភិជ្ឈាកាយគន្ថៈ ព្យាបាទកាយគន្ថៈ សីលព្វតបរា-មាសកាយគន្ថៈ ឥទំសច្ចាភិនិវេសកាយគន្ថៈ ឯអភិជ្ឈាកាយគន្ថៈតែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយលោភៈ ព្យាបាទកាយគន្ថៈ តែងកើតក្នុងចិត្តុប្បាទ ២ ដែលប្រកបដោយទោមនស្ស សីលព្វតបរាមាសកាយគន្ថៈនិងឥទំសច្ចាភិនិវេសកាយគន្ថៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ នេះពួកធម៌ជាគន្ថៈ ។ ពួកធម៌មិនមែនជាគន្ថៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែពួកគន្ថៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាគន្ថៈ ។

[ ៤២៦ ] ពួកធម៌ដែលគន្ថៈគប្បីដោតក្រង តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ដែលគន្ថៈគប្បីដោតក្រង ។ ពួកធម៌ដែលគន្ថៈមិនគប្បីដោតក្រង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ដែលគន្ថៈមិនគប្បីដោតក្រង ។

[ ៤២៧ ] ពួកធម៌ប្រកបដោយគន្ថៈ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ វៀរតែលោភៈដែលកើតឡើងក្នុងទីនុ៎ះចេញ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស វៀរតែបដិឃៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយគន្ថៈ ។ ពួកធម៌ប្រាសចាកគន្ថៈ តើដូចម្តេច ។ លោភៈកើតក្នុងចិត្តុប្បាទ ៤ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ បដិឃៈកើតក្នុងចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកគន្ថៈ ។

[ ៤២៨ ] ពួកធម៌ជាគន្ថៈផង ដែលគន្ថៈគប្បីដោតក្រងផង តើដូចម្តេច ។ គន្ថៈទាំងនោះឯង ជាគន្ថៈផង ដែលគន្ថៈគប្បីដោតក្រងផង ។ ពួកធម៌ដែលគន្ថៈគប្បីដោតក្រង តែមិនមែនជាគន្ថៈ តើដូចម្តេច ។ អកុសលក្រៅពីនេះវៀរតែពួកគន្ថៈចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ដែលគន្ថៈគប្បីដោតក្រង តែមិន

មែនជាគន្ថៈ ។ ពួកធម៌ដែលគន្ថៈមិនគប្បីដោតក្រង មិនគប្បីពោលថា ជាគន្ថៈផង ដែលគន្ថៈគប្បីដោតក្រងផង ថាគន្ថៈគប្បីដោតក្រង តែមិនមែនជាគន្ថៈផងឡើយ ។

[ ៤២៩ ] ពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈផង តើដូចម្ដេច ។ ទិដ្ឋិនិងលោភៈ កើតឡើងក្នុងទីជាមួយគ្នា ក្នុងធម៌ណា នេះពួកធម៌ជាគន្ថៈផង ប្រកបដោយគន្ថៈផង ។ ពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈ តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស វៀរតែពួកគន្ថៈដែលកើតក្នុងទីនុ៎ះចេញ នេះពួកធម៌គ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈ ។ ពួកធម៌ប្រាសចាកគន្ថៈ មិនគប្បីពោលថាជាគន្ថៈផង ប្រកបដោយគន្ថៈផង ថាគ្រាន់តែប្រកបដោយគន្ថៈ តែមិនមែនជាគន្ថៈផងឡើយ ។

[ ៤៣០ ] ពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង តើដូចម្ដេច ។ លោភៈ កើតក្នុងចិត្តុប្បាទ ៤ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ បដិឃៈកើតក្នុងចិត្តុប្បាទ ២ ដែលប្រកបដោយទោនមស្ស ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកគន្ថៈ តែគន្ថៈគប្បីដោតក្រង ។ ពួកធម៌ប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីដោតក្រងផង តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីដោត

ក្រេងផង ។ ពួកធម៌ប្រកបដោយគន្ថៈមិនគប្បីពោលថា ប្រាសចាកគន្ថៈ តែគន្ថៈគប្បីជោតក្រេងផង ថាប្រាសចាកគន្ថៈផង ដែលគន្ថៈមិនគប្បីជោតក្រេងផងឡើយ ។

[ ៤៣១ ] ពួកធម៌ជាឱឃៈ ( ធម៌ញុំាងសត្វឲ្យលង់នៅក្នុងវដ្ដៈ ) តើដូចម្ដេច ។បេ។ ពួកធម៌ជាយោគៈ ( ធម៌ញុំាងសត្វឲ្យជាប់នៅក្នុងវដ្ដៈ ) តើដូចម្ដេច ។បេ។ ពួកធម៌ជានីវរណៈ ( ធម៌រាំងចិត្តសត្វ ) តើដូចម្ដេច ។ នីវរណៈ ៦ គឺកាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈ ថីនមិទ្ធនីវរណៈ ឧទ្ធច្ច-កុក្កុច្ចនីវរណៈ វិចិកិច្ឆានីវរណៈ អវិជ្ជានីវរណៈ កាមច្ឆន្ទនីវរណៈ កើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយលោភៈ ព្យាបាទនីវរណៈ កើតក្នុងចិត្តុប្បាទ ២ ដែលប្រកបដោយទោមនស្ស ថីនមិទ្ធនីវរណៈ កើតក្នុងអកុសលជាស-សង្ខារិកៈ ឧទ្ធច្ចនីវរណៈ កើតក្នុងចិត្តុប្បាទដែលប្រកបដោយឧទ្ធច្ចៈ កុក្កុច្ច-នីវរណៈកើតក្នុងចិត្តុប្បាទ ២ ដែលប្រកបដោយទោមនស្ស វិចិកិច្ឆានីវរណៈ កើតក្នុងចិត្តុប្បាទដែលប្រកបដោយវិចិកិច្ឆា អវិជ្ជានីវរណៈកើតឡើងក្នុងអកុ-សលទាំងអស់ នេះពួកធម៌ជានីវរណៈ ។ ពួកធម៌មិនមែនជានីវរណៈ តើដូចម្ដេច ។ អកុសលក្រៅពីនេះ វៀរតែពួកនីវរណៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជានីវរណៈ ។

[ ៤៣២ ] ពួកធម៌ជាប្រយោជន៍ដល់នីវរណៈ តើដូចម្ដេច ។ កុសលនិងអកុសល ក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣

និងរូបទាំងអស់ នេះពួកធម៌ជាប្រយោជន៍ដល់នីវរណៈ ។ ពួកធម៌មិនជាប្រ-យោជន៍ដល់នីវរណៈ តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញ-ផល ៤ ផង និព្វានផង នេះពួកធម៌មិនជាប្រយោជន៍ដល់នីវរណៈ ។

[ ៤៣៣ ] ពួកធម៌ប្រកបដោយនីវរណៈ តើដូចម្តេច ។ ចិត្តុប្បាទជាអកុសល ១២ នេះពួកធម៌ប្រកបដោយនីវរណៈ ។ ពួកធម៌ប្រាសចាកនី-វរណៈ តើដូចម្តេច ។ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យា-ក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកនីវរណៈ ។

[ ៤៣៤ ] ពួកធម៌ជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង តើដូចម្តេច ។ នីវរណៈទាំងនោះឯងជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង ។ ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែពួកនីវរណៈចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួក ធម៌គ្រាន់តែជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈ ។ ពួកធម៌មិន ជាប្រយោជន៍ដល់នីវរណៈ មិនគប្បីពោលថា ជានីវរណៈផង ជាប្រយោជន៍ដល់នីវរណៈផង ថាគ្រាន់តែជាប្រយោជន៍ដល់នីវរណៈ តែមិនមែនជានីវរណៈផងឡើយ ។

[ ៤៣៥ ] ពួកធម៌ជានីវរណៈផង ប្រកបដោយនីវរណៈផង តើដូចម្តេច ។ នីវរណៈ ២ ឬ ៣ កើតក្នុងទីជាមួយគ្នាក្នុងធម៌ណា នេះពួកធម៌ជានីវរណៈផង ប្រកបដោយនីវរណៈផង ពួកធម៌គ្រាន់តែប្រកបដោយនីវរណៈ

តែមិនមែនជានីវរណៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែពួកនីវរណៈចេញ នេះពួកធម៌គ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈ ។ ពួកធម៌ប្រាសចាកនីវរណៈមិនគប្បីពោលថាជានីវរណៈផង ប្រកបដោយនីវរណៈផង ជាគ្រាន់តែប្រកបដោយនីវរណៈ តែមិនមែនជានីវរណៈផងឡើយ ។

[ ៤៣៦ ] ពួកធម៌ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ តើដូចម្តេច ។ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈ ។ ពួកធម៌ប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផងនិព្វានផង នេះពួកធម៌ប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផង ។ ពួកធម៌ប្រកបដោយនីវរណៈ មិនគប្បីពោលថា ប្រាសចាកនីវរណៈ តែជាប្រយោជន៍ដល់នីវរណៈផង ជាប្រាសចាកនីវរណៈផង មិនជាប្រយោជន៍ដល់នីវរណៈផងឡើយ ។

[ ៤៣៧ ] ពួកធម៌ជាបរាមាសៈ ( ប្រកាន់ខុស ) តើដូចម្តេច ទិដ្ឋិបរាមាសៈ តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ នេះពួកធម៌ជាបរាមាសៈ ។ ពួកធម៌មិនមែនជាបរាមាសៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែបរាមាសៈចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាបរាមាសៈ ។

[ ៤៣៨ ] ពួកធម៌ដែលបរាមាសៈស្ទាបអង្អែល តើដូចម្តេច ។ កុសល និងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ដែលបរាមាសៈស្ទាបអង្អែល ។ ពួកធម៌ដែលបរាមាសៈ មិនស្ទាបអង្អែល តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ដែលបរាមាសៈមិនបានស្ទាបអង្អែល ។

[ ៤៣៩ ] ពួកធម៌ប្រកបដោយបរាមាសៈ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ វៀរតែបរាមាសៈ ដែលកើតឡើងក្នុងទីនោះចេញ នេះពួកធម៌ប្រកបដោយបរាមាសៈ ។ ពួកធម៌ប្រាសចាកបរាមាសៈ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ច កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកបរាមាសៈ ។ បរាមាសៈ មិនគប្បីពោលថាប្រកបដោយបរាមាសៈផង ថាប្រាសចាកបរាមាសៈផងឡើយ ។

[ ៤៤០ ] ពួកធម៌ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង តើដូចម្តេច ។ បរាមាសៈនោះឯង ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង ។ ពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែបរាមាសៈចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំង

អស់ នេះពួកធម៌គ្រាន់តែបរាមាសៈស្ទាបអង្អែល តែមិនមែនជាបរាមាសៈ ។ ពួកធម៌ដែលបរាមាសៈមិនបានស្ទាបអង្អែល មិនគប្បីពោលថា ជាបរាមាសៈផង ដែលបរាមាសៈស្ទាបអង្អែលផង ថាគ្រាន់តែបរាមាសៈ ស្ទាបអង្អែល តែមិនមែនជាបរាមាសៈផងឡើយ ។

[ ៤៤១ ] ពួកធម៌ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិតែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែល ។ ពួកធម៌ប្រាសចាកបរាមាសៈផង ដែលបរាមាសៈ មិនបានស្ទាបអង្អែលផង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រាសចាកបរាមាសៈផង ដែលបរាមាសៈ មិនបានស្ទាបអង្អែលផង ។ ពួកធម៌ជាបរាមាសៈផង ប្រកបដោយបរាមាសៈផង មិនគប្បីពោលថា ប្រាសចាកបរាមាសៈ តែបរាមាសៈស្ទាបអង្អែលផង ថាប្រាសចាកបរាមាសៈផង ដែលបរាមាសៈមិនបានស្ទាបអង្អែលផងឡើយ ។

[ ៤៤២ ] ពួកធម៌ប្រកបដោយអារម្មណ៍ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ នេះពួកធម៌ប្រកបដោយអារម្មណ៍ ។ ពួកធម៌មិនមានអារម្មណ៍ តើដូចម្តេច ។ រូបនិងនិព្វាន នេះពួកធម៌មិនមានអារម្មណ៍ ។

[ ៤៤៣ ] ពួកធម៌ជាចិត្ត តើដូចម្តេច ។ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោធាតុ មនោវិញ្ញាណធាតុ នេះពួកធម៌ជាចិត្ត ។ ពួកធម៌មិនមែនជាចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាចិត្ត ។

[ ៤៤៤ ] ពួកធម៌ជាចេតសិក តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ជាចេតសិក ។ ពួកធម៌មិនមែនជាចេតសិក តើដូចម្តេច ។ ចិត្តផង រូបផង និព្វានផង នេះពួកធម៌មិនមែនជាចេតសិក ។

[ ៤៤៥ ] ពួកធម៌ប្រកបដោយចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញា-ខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រកបដោយចិត្ត ។ ពួកធម៌ប្រាសចាកចិត្ត តើដូចម្តេច ។ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកចិត្ត ។ ចិត្តមិនគប្បីពោលថា ប្រកបដោយចិត្តផង ថាប្រាសចាកចិត្តផងឡើយ ។

[ ៤៤៦ ] ពួកធម៌ប្រឡូកប្រឡំដោយចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំដោយចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំដោយចិត្ត តើដូចម្តេច ។ រូបនិងនិព្វាន នេះពួកធម៌មិនប្រឡូកប្រឡំដោយចិត្ត ។ ចិត្តមិនគប្បីពោលថា ប្រឡូកប្រឡំដោយចិត្តផង ថាមិនប្រឡូកប្រឡំដោយចិត្តផងឡើយ ។

[ ៤៤៧ ] ពួកធម៌តាំងឡើងដោយចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញា-ខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ វចីវិញ្ញត្តិ ឬរូបដទៃណាមួយ គឺរូបកើតអំពីចិត្ត មានចិត្តជាហេតុតាំងឡើងដោយចិត្ត រូបាយតនៈ សទ្ទាយតនៈ គន្ធាយតនៈ

រសាយតនៈ ផោដ្ឋព្វាយតនៈ អាកាសធាតុ អាបោធាតុ ភាពនៃរូបស្រាល ភាពនៃរូបទន់ភ្លន់ ភាពនៃរូបគួរដល់ការងារ ការចម្រើននៃរូប ការកើតតៗនៃរូប អាហារដែលធ្វើជាពំនូត នេះពួកធម៌តាំងឡើងដោយចិត្ត ។ ពួកធម៌មិនតាំងឡើងដោយចិត្ត តើដូចម្តេច ។ ចិត្តផង រូបក្រៅពីនេះផង និព្វានផង នេះពួកធម៌មិនតាំងឡើងដោយចិត្ត ។

[ ៤៤៨ ] ពួកធម៌កើតជាមួយនឹងចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះពួកធម៌កើតជាមួយនឹងចិត្ត ។ ពួកធម៌មិនកើតជាមួយនឹងចិត្ត តើដូចម្តេច ។ ចិត្តផង រូបក្រៅពីនេះផង និព្វានផង នេះពួកធម៌មិនកើតជាមួយនឹងចិត្ត ។

[ ៤៤៩ ] ពួកធម៌ប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ កាយវិញ្ញត្តិ វចីវិញ្ញត្តិ នេះពួកធម៌ប្រព្រឹត្តទៅតាមចិត្ត ។ ពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ ចិត្តផង រូបក្រៅពីនេះផង និព្វានផង នេះពួកធម៌មិនប្រព្រឹត្តទៅតាមចិត្ត ។

[ ៤៥០ ] ពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើងដោយចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើងដោយចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំមិនតាំងឡើងដោយចិត្ត តើដូចម្តេច ។ ចិត្តផង រូបផង និព្វានផង នេះពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើងដោយចិត្ត ។

[ ៤៥១ ] ពួកធម៌ប្រឡូកប្រឡំ ទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត

តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើង ទាំងកើតជាមួយនឹងចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត តើដូចម្តេច ។ ចិត្តផង រូបផង និព្វានផង នេះពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនកើតជាមួយនឹងចិត្ត ។

[ ៤៥២ ] ពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ នេះពួកធម៌ប្រឡូកប្រឡំទាំងតាំងឡើង ទាំងប្រព្រឹត្តទៅតាមចិត្ត ។ ពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត តើដូចម្តេច ។ ចិត្តផង រូបផង និព្វានផង នេះពួកធម៌មិនប្រឡូកប្រឡំ មិនតាំងឡើង មិនប្រព្រឹត្តទៅតាមចិត្ត ។

[ ៤៥៣ ] ពួកធម៌ជាខាងក្នុង តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ មនាយតនៈ នេះពួកធម៌ជាខាងក្នុង ។ ពួកធម៌ជាខាងក្រៅ តើដូចម្តេច ។ រូបាយតនៈ ។បេ។ ធម្មាយតនៈ នេះពួកធម៌ជាខាងក្រៅ ។

[ ៤៥៤ ] ពួកធម៌ជាឧបាទា ( ឧបាទារូប ) តើដូចម្តេច ។ ចក្ខាយតនៈ ។បេ។ កពឡិង្ការាហារ នេះពួកធម៌ជាឧបាទា ។ ពួកធម៌មិនជាឧបាទា តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ មហាភូតរូប ៤ និងនិព្វាន នេះពួកធម៌មិនជាឧបាទា ។

[ ៤៥៥ ] ពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ តើដូចម្តេច ។ វិបាកក្នុងភូមិ ៣ និងរូបដែលជាកម្មស្សកតត្តា នេះពួកធម៌មានកម្មប្រកបដោយកិលេស មានតណ្ហាជាដើមកាន់យកហើយ ។

ពួកធម៌មិនមានកម្មប្រកបដោយកិលេស មានតណ្ហាជាដើម កាន់យកហើយ តើដូចម្តេច ។ កុសលនិងអកុសល ក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបដែលមិនមែនជាកម្មស្សកេតត្តាផង មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌មិនមានកម្មប្រកបដោយកិ-លេស មានតណ្ហាជាដើមកាន់យកហើយ ។

[ ៤៥៦ ] ពួកធម៌ជាឧបាទាន ( សេចក្តីប្រកាន់មាំ ) តើដូចម្តេច ។ ឧបាទាន ៤ គឺកាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន អត្តវាទុបាទាន ឯកាមុបាទាន តែងកើតក្នុងចិត្តុប្បាទ ៨ ដែលប្រកបដោយលោភៈ ទិដ្ឋុបា-ទាន សីលព្វតុបាទាននិងអត្តវាទុបាទាន តែងកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ នេះពួកធម៌ជាឧបាទាន ។ ពួកធម៌មិនមែនជាឧបាទាន តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែឧបាទានចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាឧបាទាន ។

[ ៤៥៧ ] ពួកធម៌ជាប្រយោជន៍ដល់ឧបាទាន តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌មិនជាប្រ-យោជន៍ដល់ឧបាទាន តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌មិនមែនជាប្រយោជន៍ដល់ឧបាទាន ។

[ ៤៥៨ ] ពួកធម៌ប្រកបដោយឧបាទាន តើដូចម្តេច ។ ចិត្តុប្បាទ ៤

ប្រកបដោយទិដ្ឋិ ទាំងប្រកបដោយលោភៈ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ វៀរតែលោភៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទាន តើដូចម្តេច ។ លោភៈកើតក្នុងចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកឧបាទាន ។

[ ៤៥៩ ] ពួកធម៌ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង តើដូចម្តេច ។ ឧបាទានទាំងនោះឯង ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ។ ពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន តើដូចម្តេច ។ កុសលក្រៅពីនេះ វៀរតែឧបាទានចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌គ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបាទាន ។ ពួកធម៌មិនជាប្រយោជន៍ដល់ឧបាទាន មិនគប្បីពោលថា ជាឧបាទានផង ជាប្រយោជន៍ដល់ឧបាទានផង ថាគ្រាន់តែជាប្រយោជន៍ដល់ឧបាទាន តែមិនមែនជាឧបា-ទានផងឡើយ ។

[ ៤៦០ ] ពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង តើដូចម្តេច ។ ទិដ្ឋិនិងលោភៈកើតក្នុងទីជាមួយគ្នា ក្នុងពួកធម៌ណា នេះពួកធម៌ជាឧបាទានផង ប្រកបដោយឧបាទានផង ។ ពួកធម៌គ្រាន់តែប្រកបដោយឧបាទាន តែ

មិនមែនជាឧបាទាន តើដូចម្ដេច ។ ចិត្តុប្បាទ ៨ ប្រកបដោយលោភៈ វៀរតែឧបាទានដែលកើតក្នុងទីនុ៎ះចេញ នេះពួកធម៌គ្រាន់តែប្រកបដោយឧបាទានតែមិនមែនជាឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទាន មិនគប្បីពោលថា ជាឧបាទានផង ប្រកបដោយឧបាទានផង ថាគ្រាន់តែប្រកបដោយឧបាទាន តែមិនមែនជាឧបាទានផងឡើយ ។

[ ៤៦១ ] ពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន តើដូចម្ដេច ។ លោភៈកើតក្នុងចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស ចិត្តុប្បាទប្រកបដោយវិចិកិច្ឆាចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទាន ។ ពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង តើដូចម្ដេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផង ។ ពួកធម៌ប្រកបដោយឧបាទាន មិនគប្បីពោលថា ប្រាសចាកឧបាទាន តែជាប្រយោជន៍ដល់ឧបាទានផង ថាប្រាសចាកឧបាទានផង មិនជាប្រយោជន៍ដល់ឧបាទានផងឡើយ ។

[ ៤៦២ ] ពួកធម៌ជាកិលេស តើដូចម្ដេច ។ កិលេសវត្ថុ ១០ គឺលោភៈទោសៈ មោហៈ មានះ ទិដ្ឋិ វិចិកិច្ឆា ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈឯលោភៈកើតក្នុងចិត្តុប្បាទ ៨ ដែលប្រកបដោយលោភៈ ទោសៈកើតក្នុង

ចិត្តុប្បាទ ២ ដែលប្រកបដោយទោមនស្ស មោហៈកើតក្នុងអកុសលទាំងអស់ មានះកើតក្នុងចិត្តុប្បាទ ៤ ដែលប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ទិដ្ឋិកើតក្នុងចិត្តុប្បាទ ៤ ដែលប្រកបដោយទិដ្ឋិ វិចិកិច្ឆាកើតក្នុងចិត្តុប្បាទដែលប្រកបដោយវិចិកិច្ឆា ថីនៈកើតក្នុងអកុសលជាសសង្ខារិកៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈកើតក្នុងអកុសលទាំងអស់ នេះពួកធម៌ជាកិលេស ។ ពួកធម៌មិនមែនជាកិលេស តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែពួកកិលេសចេញ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជាកិលេស ។

[ ៤៦៣ ] ពួកធម៌គួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌គួរដល់សេចក្តីសៅហ្មង ។ ពួកធម៌មិនគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផងនិព្វានផង នេះពួកធម៌មិនគួរដល់សេចក្តីសៅហ្មង ។

[ ៤៦៤ ] ពួកធម៌ដែលសៅហ្មងហើយ តើដូចម្តេច ។ អកុសលចិត្តុប្បាទ ១២ នេះពួកធម៌ដែលសៅហ្មងហើយ ។ ពួកធម៌ដែលមិនសៅហ្មងហើយ តើដូចម្តេច ។ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ដែលមិនសៅហ្មងហើយ ។

[ ៤៦៥ ] ពួកធម៌ប្រកបដោយកិលេស តើដូចម្តេច ។ អកុសលចិត្តុប្បាទ ១២ នេះពួកធម៌ប្រកបដោយកិលេស ។ ពួកធម៌ប្រាសចាកកិលេស

តើដូចម្តេច ។ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ប្រាសចាកកិលេស ។

[ ៤៦៦ ] ពួកធម៌ជាកិលេសផង គួរដល់សេចក្តីសៅហ្មងផង តើដូចម្តេច ។ កិលេសទាំងនោះឯងជាកិលេសផង គួរដល់សេចក្តីសៅហ្មងផង ។ ពួកធម៌គ្រាន់តែគួរដល់សេចក្តីសៅហ្មងតែមិនមែនជាកិលេស តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែកិលេសចេញ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌គ្រាន់តែគួរដល់សេចក្តីសៅហ្មង តែមិនមែនជាកិលេស ។ ពួកធម៌មិនគួរដល់សេចក្តីសៅហ្មង មិនគប្បីពោលថា ជាកិលេសផង គួរដល់សេចក្តីសៅហ្មងផង ថាគ្រាន់តែគួរដល់សេចក្តីសៅហ្មង តែមិនមែនជាកិលេសផងឡើយ ។

[ ៤៦៧ ] ពួកធម៌ជាកិលេសផង សៅហ្មងហើយផង តើដូចម្តេច ។ កិលេសទាំងនោះឯង ជាកិលេសផង សៅហ្មងហើយផង ។ ពួកធម៌គ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិលេស តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែកិលេសចេញ នេះពួកធម៌គ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិ-លេស ។ ពួកធម៌ដែលមិនសៅហ្មងហើយ មិនគប្បីពោលថា ជាកិលេសផង សៅហ្មងហើយផង ថាគ្រាន់តែសៅហ្មងហើយ តែមិនមែនជាកិលេសផងឡើយ ។

[ ៤៦៨ ] ពួកធម៌ជាកិលេសផង ប្រកបដោយកិលេសផង តើដូចម្តេច ។ ពួកកិលេស ២ ឬ ៣ កើតក្នុងទីជាមួយគ្នាក្នុងធម៌ណា នេះពួកធម៌ជាកិលេស

ផង ប្រកបដោយកិលេសផង ។ ពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស តើដូចម្តេច ។ អកុសលក្រៅពីនេះ វៀរតែកិលេសចេញ នេះពួកធម៌គ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេស ។ ពួកធម៌ប្រាសចាកកិលេស មិនគប្បីពោលថា ជាកិលេសផង ប្រកបដោយកិលេសផង ថាគ្រាន់តែប្រកបដោយកិលេស តែមិនមែនជាកិលេសផងឡើយ ។

[ ៤៦៩ ] ពួកធម៌ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មង តើដូចម្តេច ។ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មង ។ ពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់សេចក្តីសៅហ្មងផង តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ប្រាសចាកកិលេសផង មិនគួរដល់សេចក្តីសៅហ្មងផង ។ ពួកធម៌ប្រកបដោយកិលេស មិនគប្បីពោលថា ប្រាសចាកកិលេស តែគួរដល់សេចក្តីសៅហ្មងផង ថាប្រាសចាកកិលេសផង មិនគួរដល់សេចក្តីសៅហ្មងផងឡើយ ។

[ ៤៧០ ] ពួកធម៌គួរលះដោយទស្សនៈ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទ ប្រកបដោយវិចិកិច្ឆា នេះពួកធម៌គួរលះដោយទស្សនៈ ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌គួរលះដោយទស្សនៈក៏មាន មិនគួរ

លះដោយទស្សនៈក៏មាន ។ ពួកធម៌មិនគួរលះដោយទស្សនៈ តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនគួរលះដោយទស្សនៈ ។

[ ៤៧១ ] ពួកធម៌គួរលះដោយភាវនា តើដូចម្ដេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ នេះពួកធម៌គួរលះដោយភាវនា ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌គួរលះដោយភាវនាក៏មាន មិនគួរលះដោយភាវនាក៏មាន ។ ពួកធម៌មិនគួរលះដោយភាវនា តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនគួរលះដោយភាវនា ។

[ ៤៧២ ] ពួកធម៌មានហេតុគួរលះដោយទស្សនៈ តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា វៀរតែមោហៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌មានហេតុគួរលះដោយទស្សនៈ ក៏មាន មានហេតុមិនគួរលះដោយទស្សនៈ ក៏មាន ។ ពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ តើដូចម្ដេច ។ មោហៈប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មានហេតុមិនគួរលះដោយទស្សនៈ ។

[ ៤៧៣ ] ពួកធម៌មានហេតុគួរលះដោយភាវនា តើដូចម្តេច ។ ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ វៀរតែមោហៈ ដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌មានហេតុគួរលះដោយភាវនា ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌មានហេតុគួរលះដោយភាវនាក៏មាន មានហេតុមិនគួរលះដោយភាវនាក៏មាន ។ ពួកធម៌មានហេតុមិនគួរលះដោយភាវនា តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា មោហៈប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មានហេតុមិនគួរលះដោយភាវនា ។

[ ៤៧៤ ] ពួកធម៌ប្រកបដោយវិតក្កៈ តើដូចម្តេច ។ កាមាវចរកុសលនិងអកុសល ចិត្តុប្បាទ ១១ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ២ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ១១ ខាងកិរិយា រូបាវចរបឋមជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរបឋមជ្ឈានខាងកុសលផង ខាងវិបាកផង វៀរតែវិតក្កៈដែលកើតក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយវិតក្កៈ ។ ពួកធម៌មិនមានវិតក្កៈ តើដូចម្តេច ។ បញ្ចវិញ្ញាណ ២ រូបាវចរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អារុប្បជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង វិតក្កៈផង រូបផង និព្វានផង នេះពួកធម៌មិនមានវិតក្កៈ ។

[ ៤៧៥ ] ពួកធម៌ប្រកបដោយវិចារៈ តើដូចម្តេច ។ កាមាវចរកុសល និងអកុសល ចិត្តុប្បាទ ១១ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ២ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ១១ ខាងកិរិយា រូបាវចរឯកទុកជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរឯកទុកជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែវិចារៈដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយវិចារៈ ។ ពួកធម៌មិនមានវិចារៈ តើដូចម្តេច ។ បញ្ចវិញ្ញាណ ២ រូបាវចរតិកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អារុប្បជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង វិចារៈផង រូបផង និព្វានផង នេះពួកធម៌មិនមានវិចារៈ ។

[ ៤៧៦ ] ពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយសោមនស្សខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៥ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរទុកតិកជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរទុកតិកជ្ឈានខាងកុសលផង ខាងវិបាកផង វៀរតែបីតិដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រព្រឹត្តទៅជាមួយនឹងបីតិ ។ ពួកធម៌មិនមានបីតិ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយឧបេក្ខា ខាងកាមាវចរកុសល ចិត្តុប្បាទ ៨ ខាងអកុសល ចិត្តុប្បាទ ១១ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៧ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា រូបាវចរទុកទុ-

កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អារុប្បជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរទុកទុកជ្ឈាន ខាងកុសលផង ខាងវិបាកផង បីតិផង រូបផង និព្វានផង នេះពួកធម៌មិនមានបីតិ ។

[ ៤៧៧ ] ពួកធម៌ប្រកបដោយបីតិ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយសោមនស្សខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល ចិត្តុប្បាទ ៥ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរទុកតិកជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរទុកតិកជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែបីតិដែលកើតឡើងក្នុងទីនុ៎ះចេញ នេះពួកធម៌ប្រកបដោយបីតិ ។ ពួកធម៌មិនប្រកបដោយបីតិ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយឧបេក្ខា ខាងកាមាវចរកុសល ចិត្តុប្បាទ ៨ ខាងអកុសល ចិត្តុប្បាទ ១១ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៧ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា រូបាវចរទុកទុកជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អារុប្បជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរទុកទុកជ្ឈាន ខាងកុសលផង ខាងវិបាកផង បីតិផង រូបផង និព្វានផង នេះពួកធម៌មិនប្រកបដោយបីតិ ។

[ ៤៧៨ ] ពួកធម៌ប្រកបដោយសុខៈ តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយសោមនស្សខាងកាមាវចរកុសល ចិត្តុប្បាទ ៤ ខាងអកុសល

ចិត្តុប្បាទ ៦ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបា-វចរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោ-កុត្តរតិកចតុក្កជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែសុខៈដែលកើតឡើងក្នុងទីទុំះចេញ នេះពួកធម៌ប្រកបដោយសុខៈ ។ ពួកធម៌មិនប្រកបដោយសុខៈ តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយឧបេក្ខា ខាងកាមាវចរ-កុសល ចិត្តុប្បាទ ៨ ខាងអកុសល ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរ-កុសល ចិត្តុប្បាទ ៧ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា រូបាវចរចតុត្ថជ្ឈាន ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អារុប្ប-ជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរចតុត្ថ-ជ្ឈាន ខាងកុសលផង ខាងវិបាកផង សុខផង រូបផង និព្វានផង នេះពួកធម៌មិនប្រកបដោយសុខៈ ។

[ ៤៧៩ ] ពួកធម៌ប្រកបដោយឧបេក្ខា តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយឧបេក្ខា ខាងកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងអកុសល ចិត្តុប្បាទ ១០ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៦ ខាងកិរិយា រូបាវចរចតុត្ថជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង អារុប្បជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរចតុត្ថជ្ឈាន ខាងកុសលផង ខាងវិបាកផង វៀរតែឧបេក្ខាដែលកើតឡើងក្នុងទីទុំះចេញ នេះពួកធម៌ប្រកបដោយឧបេក្ខា ។ ពួកធម៌មិនប្រកបដោយឧបេក្ខា តើដូចម្ដេច ។ ចិត្តុប្បាទ ៤ ប្រកបដោយ

សោមនស្ស ខាងកាមាវចរកុសល ចិត្តុប្បាទ ៦ ខាងអកុសល ចិត្តុប្បាទ ៦ ខាងវិបាកនៃកាមាវចរកុសល ចិត្តុប្បាទ ១ ខាងវិបាកនៃអកុសល ចិត្តុប្បាទ ៥ ខាងកិរិយា រូបាវចរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង លោកុត្តរតិកចតុក្កជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង ឧបេក្ខាផង រូបផង និព្វានផង នេះពួកធម៌ មិនប្រកបដោយឧបេក្ខា ។

[ ៤៨០ ] ពួកធម៌ជាកាមាវចរៈ តើដូចម្តេច ។ កាមាវចរកុសលនិងអកុសលវិបាកនៃកាមាវចរៈទាំងអស់ កាមាវចរកិរិយានិងអព្យាក្រឹត និងរូបទាំងអស់ នេះពួកធម៌ជាកាមាវចរៈ ។ ពួកធម៌មិនមែនជាកាមាវចរៈ តើដូចម្តេច ។ រូបាវចរៈ អរូបាវចរ អបរិយាបន្ន នេះពួកធម៌មិនមែនជាកាមាវចរៈ ។

[ ៤៨១ ] ពួកធម៌ជារូបាវចរៈ តើដូចម្តេច ។ រូបាវចរចតុក្កបញ្ចកជ្ឈានខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង នេះពួកធម៌ជារូបាវចរៈ ។ ពួកធម៌មិនមែនជារូបាវចរៈ តើដូចម្តេច ។ កាមាវចរ អរូបាវចរ អបរិយាបន្ន នេះពួកធម៌មិនមែនជារូបាវចរៈ ។

[ ៤៨២ ] ពួកធម៌ជាអរូបាវចរៈ តើដូចម្តេច ។ អារុប្បជ្ឈាន ៤ ខាងកុសលផង ខាងវិបាកផង ខាងកិរិយាផង នេះពួកធម៌ជាអរូបាវចរៈ ។ ពួកធម៌មិនមែនជាអរូបាវចរៈ តើដូចម្តេច ។ កាមាវចរៈ រូបាវចរៈ អបរិយាបន្ន នេះពួកធម៌មិនមែនជាអរូបាវចរៈ ។

[ ៤៨៣ ] ពួកធម៌ជាបរិយាបន្ន តើដូចម្តេច កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ជាបរិយាបន្នៈ ។ ពួកធម៌ជាអបរិយាបន្ន តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ជាអបរិយាបន្នៈ ។

[ ៤៨៤ ] ពួកធម៌ជានិយ្យានិកៈ ( ធម៌ជាគ្រឿងនាំសត្វចេញចាកវដ្តៈ ) តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នៈ នេះពួកធម៌ជានិយ្យានិកៈ ។ ពួកធម៌ជាអនិយ្យានិកៈ តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹត ក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌ជាអនិយ្យានិកៈ ។

[ ៤៨៥ ] ពួកធម៌ទៀង តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រកបដោយទិដ្ឋិ ចិត្តុប្បាទ ២ ប្រកបដោយទោមនស្ស នេះពួកធម៌ទៀងក៏មាន មិនទៀងក៏មាន មគ្គ ៤ ជាអបរិយាបន្នៈ នេះពួកធម៌ទៀង ។ ពួកធម៌មិនទៀង តើដូចម្តេច ។ ចិត្តុប្បាទ ៤ ប្រាសចាកទិដ្ឋិ តែប្រកបដោយលោភៈ ចិត្តុប្បាទប្រកបដោយវិចិកិច្ឆា ចិត្តុប្បាទប្រកបដោយឧទ្ធច្ចៈ កុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនទៀង ។

[ ៤៨៦ ] ពួកធម៌ប្រកបដោយឧត្តរៈ ( ការរើឡើងនូវខ្លួន ) តើដូចម្តេច ។ កុសលនិងអកុសលក្នុងភូមិ ៣ វិបាកក្នុងភូមិ ៣ កិរិយានិងអព្យា-

កើតក្នុងភូមិ ៣ និងរូបទាំងអស់ នេះពួកធម៌ប្រកបដោយឧត្តរៈ ។ ពួកធម៌ជាអនុត្តរៈ តើដូចម្តេច ។ មគ្គ ៤ ជាអបរិយាបន្នផង សាមញ្ញផល ៤ ផង និព្វានផង នេះពួកធម៌ជាអនុត្តរៈ ។

[ ៤៨៧ ] ពួកធម៌ប្រកបដោយរណៈ តើដូចម្តេច ។ អកុសលចិត្តុប្បាទ ១២ នេះពួកធម៌ប្រកបដោយរណៈ ។ ពួកធម៌មិនមែនជារណៈ តើដូចម្តេច ។ កុសលក្នុងភូមិ ៤ វិបាកក្នុងភូមិ ៤ កិរិយានិងអព្យាក្រឹតក្នុងភូមិ ៣ រូបនិងនិព្វាន នេះពួកធម៌មិនមែនជារណៈ ។

## ចប់ ធម្មសង្គណិប្បករណៈ ។

# អដ្ឋកថា

## អធិប្បាយ ទុកអត្ថទ្វារ

## ហេតុគោច្ឆកជាដើម

[ ៤០០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងហេតុគោច្ឆកនិទ្ទេស ដូចតទៅនេះថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងហេតុ ដោយន័យជាដើមថា **តយោ កុសលហេតូ** ដូច្នេះហើយ ដើម្បីទ្រង់សម្តែងហេតុទាំងនោះឯងដោយឋានៈនៃការកើតឡើងទៀត ទើបត្រាស់ព្រះតម្រាស់ ជាដើមថា **ចតូសុ ភូមីសុ កុសលេសុ ឧប្បជ្ជន្តិ** ដូច្នេះ ។ បណ្ឌិតគប្បីជ្រាបន័យរបស់ទេសនា ក្នុងគោច្ឆកៈដ៏សេសដោយឧបាយនេះ ។

[ ៤១៣ ] ក្នុងអាសវគោច្ឆកនិទ្ទេសថា **យត្ថ ទ្វេ តយោ អាសវា ឯកតោ ឧប្បជ្ជន្តិ** នេះ បណ្ឌិតគប្បីជ្រាបការកើតឡើងរួមគ្នានៃអាសវៈទាំងឡាយ ៣ យ៉ាង ។ ក្នុងការកើតទាំង ៣ យ៉ាងនោះ កាមាសវៈ រមែងកើតរួមគ្នា ២ យ៉ាង គឺកើតឡើងក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្ត ៤ ដួង ព្រមជាមួយអវិជ្ជាសវៈ និងកើតឡើងក្នុងចិត្តុប្បាទដែលជាទិដ្ឋិសម្បយុត្ត ៤ ដួង ព្រមជាមួយទិដ្ឋាសវៈនិងអវិជ្ជាសវៈ ។ ចំណែកភវាសវៈ រមែងកើតរួមគ្នាតែម្យ៉ាង គឺកើតឡើងក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្ត ៤ ដួង ព្រមជាមួយអវិជ្ជាសវៈ ។

[ ៤១៩ ] មួយទៀត ក្នុងពាក្យនេះថា អាសវៈ ២ អាសវៈ ៣ រមែងកើតឡើងរួមគ្នាយ៉ាងណា សូម្បីក្នុងពាក្យនេះថាសញ្ញោជនៈ ២ ឬ ៣ កើត

ក្នុងទីជាមួយគ្នាក្នុងធម៌ណាក៏យ៉ាងនោះដែរ ការកើតឡើងរួមគ្នានៃសញ្ញោជនៈទាំងឡាយ ក៏មាន ១០ យ៉ាង ។ ក្នុងការកើត ១០ យ៉ាងនោះ កាមរាគសញ្ញោជនៈ រមែងកើតរួមគ្នា ៤ យ៉ាង បដិឃសញ្ញោជនៈ រមែងកើតរួមគ្នា ៣ យ៉ាង មានសញ្ញោជនៈ រមែងកើតរួមគ្នា ១ យ៉ាង វិចិកិច្ឆាសញ្ញោជនៈ និងភវរាគសញ្ញោជនៈ ក៏កើតរួមគ្នានីមួយៗ ១ យ៉ាងដូចគ្នា សេចក្តីនេះដូចម្តេច គឺកាមរាគសញ្ញោជនៈ រមែងកើតរួមគ្នា ៤ យ៉ាង គឺកើតរួមគ្នាជាមួយមានសញ្ញោជនៈនិងអវិជ្ជាសញ្ញោជនៈ ១ កើតជាមួយគ្នានឹងទិដ្ឋិសញ្ញោជនៈនិងអវិជ្ជាសញ្ញោជនៈ ១ កើតជាមួយគ្នានឹងសីលព្វតបរាមាសសញ្ញោជនៈនិងអវិជ្ជាសញ្ញោជនៈ ១ កើតជាមួយគ្នានឹងអវិជ្ជាសញ្ញោជនៈប៉ុណ្ណោះ ១ ។ ចំណែកបដិឃសញ្ញោជនៈ រមែងកើតឡើងរួមគ្នា ៣ យ៉ាងនេះ គឺកើតឡើងជាមួយគ្នានឹងឥស្សាសញ្ញោជនៈនិងអវិជ្ជាសញ្ញោជនៈ ១ កើតឡើងជាមួយគ្នានឹងមច្ឆរិយសញ្ញោជនៈនិងអវិជ្ជាសញ្ញោជនៈ ១ កើតឡើងជាមួយគ្នានឹងអវិជ្ជាសញ្ញោជនៈប៉ុណ្ណោះ ១ ។ មានសញ្ញោជនៈ រមែងកើតរួមជាមួយនឹងភវរាគសញ្ញោជនៈនិងអវិជ្ជាសញ្ញោជនៈ ១ ប៉ុណ្ណោះ ។ វិចិកិច្ឆាសញ្ញោជនៈក៏យ៉ាងនោះដូចគ្នា ។ មែនពិត វិចិកិច្ឆាសញ្ញោជនៈនោះ រមែងកើតឡើងជាមួយគ្នាតែម្យ៉ាង គឺរួមគ្នាជាមួយនឹងអវិជ្ជាសញ្ញោជនៈ ។ សូម្បីក្នុងភវរាគសញ្ញោជនៈ ក៏មានន័យនេះឯង ។ ក្នុងចិត្តុប្បាទទាំងនេះ សញ្ញោជនៈ ២ សញ្ញោជនៈ ៣ រមែងកើតឡើងរួមគ្នា ដោយប្រការដូច្នេះ ។

[ ៤៣៣ ] ព្រះតម្រាស់ណាដែលត្រាស់ទុកក្នុងនីវរណគោច្ឆកៈថា **យត្ថ**

**ទ្វេ តីណិ នីវរណានិ ឯកតោ ឧប្បជ្ជន្តិ** ដូច្នេះ សូម្បីក្នុងព្រះតម្រាស់នោះ បណ្ឌិតគប្បីជ្រាបការកើតឡើងរួមគ្នានៃនីវរណៈទាំងឡាយ ៨ យ៉ាង ។

មែនពិត ក្នុងការកើត ៨ យ៉ាងនោះ កាមច្ឆន្ទនីវរណៈ កើតរួមគ្នា ២ យ៉ាង ព្យាបាទនីវរណៈកើតរួមគ្នា ៤ យ៉ាង ឧទ្ធចនីវរណៈកើតរួមគ្នាតែម្យ៉ាង វិចិកិច្ឆាក៏កើតរួមគ្នាតែម្យ៉ាងដូចគ្នា ។ សេចក្តីនេះ តើដូចម្តេច គឺកាមច្ឆន្ទនីវរណៈ រមែងកើតឡើងរួមគ្នា ២ យ៉ាង ព្រមជាមួយឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈក្នុងចិត្តុប្បាទដែលជាអសង្ខារិក ១ ព្រមជាមួយថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈក្នុងចិត្តុប្បាទដែលជាសសង្ខារិក ១ ។ ពាក្យណាដែលត្រាស់ថា នីវរណៈ ២ ឬ ៣ ពាក្យនោះ ត្រាស់ដោយការកំណត់ចំនួនយ៉ាងទាប ព្រោះហេតុនោះ ការកើតឡើងរួមគ្នានៃនីវរណៈ សូម្បី ៤ ក៏ត្រឹមត្រូវនោះឯង ។ ចំណែកព្យាបាទនីវរណៈ រមែងកើតឡើងរួមគ្នា ៤ យ៉ាងគឺ កើតរួមគ្នាជាមួយនឹងឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈ ក្នុងចិត្តុប្បាទដែលជាអសង្ខារិក ១ ព្រមជាមួយថីនមិទ្ធនីវរណៈ ឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈក្នុងចិត្តុប្បាទដែលជាសសង្ខារិក ១ ព្រមជាមួយឧទ្ធច្ចកុក្កុច្ចនីវរណៈនិងអវិជ្ជានីវរណៈក្នុងចិត្តុប្បាទ ដែលជាអសង្ខារិកប៉ុណ្ណោះ ១ ព្រមជាមួយថីនមិទ្ធនីវរណៈ ឧទ្ធច្ចកុក្កុច្ចនីវរណៈនិងអវិជ្ជានីវរណៈ ក្នុងចិត្តុប្បាទដែលជាសសង្ខារិកប៉ុណ្ណោះ ១ ។ ចំណែកឧទ្ធច្ចនីវរណៈ រមែងកើតឡើងរួមគ្នាតែម្យ៉ាងប៉ុណ្ណោះព្រមជាមួយអវិជ្ជានីវរណៈ ។ វិចិកិច្ឆា រមែងកើតឡើងរួមគ្នាត្រឹមតែម្យ៉ាង ព្រមជាមួយឧទ្ធច្ចនីវរណៈនិងអវិជ្ជានីវរណៈ ។

[ ៤៦២ ] ក្នុងព្រះតម្រាស់ដែលត្រាស់ទុកក្នុងកិលេសគោច្ឆកៈនេះថា ពួកកិលេស ២ ឬ ៣ កើតក្នុងទីជាមួយគ្នា ក្នុងធម៌ណា ដូច្នេះ បណ្ឌិតគប្បីជ្រាបសេចក្តីយ៉ាងនេះ កិលេស ២ ឬ ៣ រមែងកើតឡើងព្រមជាមួយកិលេសពួកដទៃ ឬកិលេស ៣ រមែងកើតឡើង ព្រមជាមួយកិលេសពួកដទៃក្នុងចិត្តុប្បាទណា ។ ព្រោះហេតុអ្វី ព្រោះកិលេសដែលកើតរួមគ្នាត្រឹមតែ ២ ឬ ៣ ប៉ុណ្ណោះមិនមាន ។

ក្នុងព្រះតម្រាស់នោះ ការកើតឡើងរួមគ្នានៃកិលេស មាន ១០ យ៉ាងពិតណាស់ ក្នុង ១០ យ៉ាងនេះ លោភៈរមែងកើតឡើងរួមគ្នា ៦ យ៉ាង បដិឃរមែងកើតឡើងរួមគ្នា ២ យ៉ាង មោហៈក៏គប្បីជ្រាបថា កើតឡើងរួមគ្នា ២ យ៉ាងដូចគ្នា ។ សេចក្តីនេះដូចម្តេច គឺលោភៈ រមែងកើតឡើងរួមគ្នា ៦ យ៉ាង គឺកើតព្រមគ្នាជាមួយមោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តអសង្ខារិក ១ កើតព្រមជាមួយមោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តសសង្ខារិក ១ កើតព្រមជាមួយគ្នានឹងមោហៈ មានៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈក្នុងចិត្តុប្បាទ ដែលជាទិដ្ឋិវិប្បយុត្តអសង្ខារិកនុ៎ះឯង ១ កើតព្រមជាមួយមោហៈ មានៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ក្នុងចិត្តុប្បាទដែលជាទិដ្ឋិវិប្បយុត្តសសង្ខារិកនុ៎ះឯង ១ ។ ចំណែកក្នុងចិត្តុប្បាទដែលជាទិដ្ឋិសម្បយុត្តអសង្ខារិក កើតព្រមជាមួយមោហៈ ឧទ្ធច្ចៈ ទិដ្ឋិ អហិរិកៈនិងអនោត្តប្បៈ ១ ដែលជាអសង្ខារិកកើតព្រមជាមួយមោហៈ ទិដ្ឋិ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិង

អនោត្តប្បៈ ១ ។

ចំណែកបឋវិយៈ រមែងកើតរួមគ្នា ២ យ៉ាងគឺ កើតរួមជាមួយនឹងមោហៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ក្នុងចិត្តុប្បាទដែលជាអសង្ខារិក ១ កើតរួមជាមួយនឹងមោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ក្នុងចិត្តុប្បាទដែលជាសសង្ខារិក ១ ។

ចំណែកមោហៈរមែងកើតឡើងរួមគ្នា ២ យ៉ាងគឺ កើតព្រមគ្នានឹងវិចិកិច្ឆា ឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈ ក្នុងចិត្តុប្បាទដែលសម្បយុត្តដោយវិចិកិច្ឆា ១ កើតព្រមគ្នានឹងឧទ្ធច្ចៈ អហិរិកៈនិងអនោត្តប្បៈក្នុងចិត្តុប្បាទដែលសម្បយុត្តដោយឧទ្ធច្ចៈ ១ ។ ពាក្យដ៏សេសក្នុងទីទាំងពួងមានអត្ថងាយយល់ហើយ ។

## អធិប្បាយ អត្ថុទ្ធារ ចប់

## អដ្ឋកថាកណ្ឌ

## ក្នុងអដ្ឋសាលិនី អដ្ឋកថាធម្មសង្គណី ចប់

# និគមកថា

ដោយពាក្យមានប្រមាណប៉ុណ្ណេះ

ព្រះលោកនាថ កាលទ្រង់ចែកចិត្តុប្បាទកណ្ឌ រូបកណ្ឌ និក្ខេបកណ្ឌនិងអត្ថុទ្ធារកណ្ឌគួរជាទីរីករាយនៃចិត្ត ទ្រង់សម្តែងព្រះធម្មសង្គណីណា ការពណ៌នាសេចក្តីនៃព្រះធម្មសង្គណីនោះ ដែលរួបរួមធម៌នៃព្រះអភិធម្មបិដក ដោយឥតសេសសល់ហើយតាំងទុកដែលខ្ញុំប្រារព្ធហើយ ការពណ៌នាសេចក្តីនេះ ដល់នូវសេចក្តីសម្រេចហើយដោយឈ្មោះថា អដ្ឋសាលិនី ព្រោះមានសេចក្តីមិនច្របូកច្របល់ ។

ខ្ញុំធ្វើការពណ៌នាអត្ថនោះឲ្យចប់ដោយព្រះបាលី ៣៩ ភាណវារៈ ដើម្បីការតាំងមាំ ស្ថិតស្ថេរនៃព្រះសទ្ធម្ម សម្រេចហើយនូវកុសលណា ដោយអានុភាពនៃកុសលនោះ សូមសត្វទាំងអស់ ដឹងព្រះធម៌របស់ព្រះធម្មរាជា ដែលនាំមកនូវសេចក្តីសុខហើយ ចូរសម្រេចសន្តិសុខគឺព្រះនិព្វានដ៏កំពូលមិនមានសេចក្តីសោក មិនមានសេចក្តីចង្អៀតចង្អល់ចិត្តដោយកិច្ចបដិបទាដ៏បរិសុទ្ធ ដោយងាយ ។

សូមព្រះសទ្ធម្មតាំងនៅអស់កាលយូរ សូមពពួកសត្វទាំងអស់គោរពធម៌ សូមភ្លៀងបង្អុរចុះមកតាមរដូវកាល ព្រះរាជាដែលទ្រទ្រង់គុណធម៌អំពីបុរាណ ទ្រង់គ្រប់គ្រងប្រជាដោយធម៌ណា សូមព្រះរាជាបច្ចុប្បន្ន ទ្រង់គ្រប់គ្រងប្រជារបស់ព្រះ

អត្ថ ដោយធម៌នោះចុះ ។

អដ្ឋកថាធម្មសង្គណី ឈ្មោះថា **អដ្ឋសាលិនី** នេះ ដែលព្រះថេរៈ អ្នកមាននាមដែលគ្រូទាំងឡាយនាំគ្នាដាក់ឲ្យថា **ពុទ្ធឃោស** ដែលប្រដាប់ដោយសទ្ធា បញ្ញានិងវីរិយៈដ៏បរិសុទ្ធយ៉ាងក្រៃលែង ជាអ្នកញ៉ាំងហេតុនៃគុណមានសីលាចារ ភាពស្មោះត្រង់ ការឱនលំទោនជាដើមឲ្យតាំងឡើង ហើយអាចឈានចុះកាន់ជដា ( ព្រៃក្រាស់ ) ក្នុងសេចក្តីផ្សេងគ្នានៃលទ្ធិរបស់ខ្លួននិងអ្នកដទៃ អ្នកប្រកបដោយសេចក្តីឈ្លាសនៃបញ្ញា មានប្រាជ្ញាញាណដែលមិនទើសទាក់ក្នុងសត្ថុសាសន មានបរិយត្តិ គឺព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ជាអ្នកជំនាញក្នុងវេយ្យាករណ៍ អ្នកអធិប្បាយសេចក្តីដ៏ទូលំទូលាយ អ្នកប្រកបដោយសម្តីដ៏ពីរោះ និងជ្រាលជ្រៅ ដែលបន្លឺចេញទៅបានស្ទាត់ជំនាញ កើតអំពីករណសម្បត្តិ ជាអ្នកនិយាយដ៏ឆ្នើម ទាំងជាអ្នកចង ទាំងជាអ្នកស្រាយ ជាមហាកវី ជាអលង្ការនៃវង្សរបស់ពួកព្រះថេរៈខាងមហាវិហារ ដែលជាប្រទីបនៃថេរវង្ស ជាអ្នកមានចំណេះដឹងតាំងមាំល្អហើយក្នុងឧត្តរិមនុស្សធម៌ ប្រកបដោយគុណមានការបែកធ្លាយក្នុងអភិញ្ញា ៦ ជាដើម មានបដិសម្ភិទា ដែលបែកធ្លាយហើយជាបរិវារ ជាអ្នកមានចំណេះដឹងដ៏បរិបូណ៌ និងបរិសុទ្ធវិសេស ហើយរចនាទុក ។

សូមអដ្ឋកថាធម្មសង្គណី ឈ្មោះអដ្ឋសាលិនីនេះ ដែលសម្តែងន័យនៃបញ្ញាវិសុទ្ធិ ដល់កុលបុត្តទាំងឡាយ អ្នកស្វែងរកធម៌ជាគ្រឿងរលាស់ចេញចាកលោក ចូរតាំងនៅក្នុងលោកដរាបព្រះនាមថា ពុទ្ធោ របស់ព្រះលោក-

ជេដ្ឋ ជាព្រះមហាឥសី មានព្រះហឫទ័យបរិសុទ្ធ នឹងធឹង នៅប្រព្រឹត្តទៅក្នុងលោកហោង ។

## អដ្ឋកថា ធម្មសង្គហៈ ឈ្មោះ អដ្ឋសាលិនី ចប់

# ក្បាលទី ៦៥

# អភិធម្មបិដក បាលីប្រែ -៧៨

## សន្ទឹកចង្អុលប្រាប់មាតិកា

| មាតិកា | ទំព័រ |
|---|---|
| អភិធម្មបិដក អកុសលចិត្តដួងទី ១ | ២ |
| អដ្ឋកថា អកុសលចិត្តដួងទី ១ | ៤ |
| អភិធម្មបិដក និទ្ទេសវារ | ១៥ |
| អដ្ឋកថា និទ្ទេសវារ | ២៤ |
| អភិធម្មបិដក អកុសលចិត្តដួងទី ២ ជាដើម | ៣១ |
| អដ្ឋកថា អកុសលចិត្តដួងទី ២ ជាដើម | ៤៥ |
| អភិធម្មបិដក អហេតុកកុសលវិបាកជាដើម | ៦២ |
| អដ្ឋកថា អហេតុកកុសលវិបាកជាដើម | ៨១ |
| អភិធម្មបិដក មហាវិបាក ៨ ដួង | ៩០ |
| អដ្ឋកថា មហាវិបាក ៨ ដួង | ៩១ |
| វិបាកុទ្ធារកថា | ៩៤ |
| អភិធម្មបិដក រូបាវចរវិបាក | ១៣៦ |
| អភិធម្មបិដក អរូបាវចរវិបាក | ១៣៧ |
| អធិប្បាយ រូបាវចរវិបាកនិងអរូបាវចរវិបាក | ១៤០ |
| អភិធម្មបិដក សុទ្ធិកប្បដិបទាជាដើម | ១៤២ |
| អដ្ឋកថា អធិប្បាយលោកុត្តរវិបាក | ១៧៦ |
| អភិធម្មបិដក អកុសលវិបាកជាអព្យាក្រឹត | ១៨២ |
| អដ្ឋកថា អធិប្បាយអកុសលវិបាកជាអព្យាក្រឹត | ១៨៧ |

អភិធម្មបិដក កាមាវចរកិរិយា ........... ១៨៩
អដ្ឋកថា អធិប្បាយកិរិយាមនោធាតុចិត្ត ........... ១៩៤
អធិប្បាយ កិរិយាមនោវិញ្ញាណធាតុចិត្តសហគតដោយសោមនស្ស ...... ១៩៦
អធិប្បាយ កិរិយាមនោវិញ្ញាណធាតុចិត្តសហគតដោយឧបេក្ខា ........... ១៩៨
អធិប្បាយ មហាកិរិយាចិត្ត ៨ ដួង ........... ១៩៩
ពោលដោយហសនកចិត្ត ១៣ ដួង ........... ១៩៩
អភិធម្មបិដក រូបាវចរកិរិយានិងអរូបាវចរកិរិយា ........... ២០០
អដ្ឋកថា រូបាវចរកិរិយានិងអរូបាវចរកិរិយា ........... ២០៣

## អភិធម្មបិដក បាលីប្រែ -៧៩

## ធម្មសង្គណី ទុតិយភាគ

## រូបកណ្ឌ

អភិធម្មបិដក ធម៌មានប្រមាណមួយជាដើម ........... ២០៤
អធិប្បាយ ឧទ្ទេស ........... ២១៨
សង្គ្រោះរូបពួក ១ ........... ២២៧
សង្គ្រោះរូបពួក ២ ........... ២២៨
សង្គ្រោះរូបពួក ៣ ........... ២២៩
សង្គ្រោះរូបពួក ៤ ជាដើម ........... ២៣០
អភិធម្មបិដក ឯកកនិទ្ទេស ........... ២៣៣
អធិប្បាយ ឯកកនិទ្ទេស ........... ២៣៥
អត្ថរបស់ វិធ សព្ទ ........... ២៣៨
អភិធម្មបិដក ទុកនិទ្ទេសជាដើម ........... ២៤១
អដ្ឋកថា អធិប្បាយទុកនិទ្ទេសជាដើម .......... .......... ............ ២៩៦
អភិធម្មបិដក រូបមានប្រមាណ ៤ .......... .......... ............ ៣៦៣

អដ្ឋកថា អធិប្បាយចតុក្កនិទ្ទេស .......... .......... ............. ៣៧៦
អភិធម្មបិដក រូបមានប្រមាណ ៥ .......... .......... ............. ៣៧៧
អដ្ឋកថា អធិប្បាយបញ្ចកនិទ្ទេស .......... .......... ............. ៣៧៨
អភិធម្មបិដក រូបមានប្រមាណ ៦ ជាដើម .......... .......... ............. ៣៨០
អដ្ឋកថា អធិប្បាយឆក្កនិទ្ទេសជាដើម .......... .......... ............. ៣៨២
អភិធម្មបិដក រូបមានប្រមាណ ៩ ជាដើម .......... .......... ............. ៣៨៣
អដ្ឋកថា អធិប្បាយនវកនិទ្ទេសជាដើម .......... .......... ............. ៣៨៥
បកិណ្ណកកថា .......... .......... ............. ៣៨៥

## និក្ខេបកណ្ឌ

អភិធម្មបិដក និក្ខេបកណ្ឌ .......... .......... ............. ៣៩៤
អដ្ឋកថា អធិប្បាយតិកនិក្ខេប .......... .......... ............. ៤១០
អភិធម្មបិដក ហេតុគោច្ឆក .......... .......... ............. ៤៤៦
អដ្ឋកថា ហេតុគោច្ឆក .......... .......... ............. ៤៥៥
អភិធម្មបិដក ចូឡន្តរទុក .......... .......... ........... ៤៦៩
អដ្ឋកថា ចូឡន្តរទុក .......... .......... .......... ៤៧៤
អភិធម្មបិដក អាសវគោច្ឆក .......... .......... ............. ៤៧៧
អដ្ឋកថា អាសវគោច្ឆក .......... .......... ............. ៤៨២
អភិធម្មបិដក សញ្ញោជនគោច្ឆក .......... .......... ............. ៤៨៨
អដ្ឋកថា សញ្ញោជនគោច្ឆក .......... .......... ............. ៤៩៦
អភិធម្មបិដក គន្ថគោច្ឆក .......... .......... ............. ៥០៦
អដ្ឋកថា គន្ថគោច្ឆកៈជាដើម .......... .......... .......... ............. ៥១៣
អភិធម្មបិដក នីវរណគោច្ឆក .......... .......... .......... ............. ៥១៥
អដ្ឋកថា នីវរណគោច្ឆកៈជាដើម .......... .......... .......... ............. ៥២៩

អភិធម្មបិដក ឧបាទានគោច្ឆកៈ .......... .......... .......... ............. ៥៤៥
អដ្ឋកថា ឧបាទានគោច្ឆកៈ .......... .......... .......... ............. ៥៥០
អភិធម្មបិដក កិលេសគោច្ឆក .......... .......... .......... ............. ៥៥៤
អដ្ឋកថា កិលេសគោច្ឆក .......... .......... .......... ............. ៥៦៥
អភិធម្មបិដក បិដ្ឋិទុកៈ .......... .......... .......... ............. ៥៦៧
អដ្ឋកថា បិដ្ឋិទុកៈ .......... .......... .......... ............. ៥៧៧
អភិធម្មបិដក សុត្តន្តិកទុកនិក្ខេប .......... .......... .......... ............. ៥៨០
អដ្ឋកថា សុត្តន្តិកទុកនិក្ខេប .......... .......... .......... ............. ៥៩៨

## អត្ថុទ្ធារកណ្ឌ

អភិធម្មបិដក អត្ថុទ្ធារកណ្ឌ .......... .......... .......... ............. ៦៣៨
អធិប្បាយ តិកអត្ថុទ្ធារ .......... .......... .......... ............. ៦៥១
អភិធម្មបិដក ហេតុគោច្ឆកជាដើម .......... .......... .......... ............. ៦៨៤
អធិប្បាយ ទុកអត្ថុទ្ធារ .......... .......... .......... ............. ៧១៩
និគមកថា .......... .......... .......... ............. ៧២៤